សាកលវិទ្យាល័យភូមិន្ទកសិកម្ម
មហាវិទ្យាល័យវិទ្យាសាស្ត្រព្រៃឈើ

# ក្របខណ្ឌច្បាប់នៃការប្រែប្រួលអាកាសធាតុ

## Legal Framework of Climate Change

លោក សុខ តាក់

លោក ហ៊ីន សារុន          លោក គឹម សុបិន្ត

ឧបត្ថម្ភដោយ

CAMBODIA
RESEARCH CREATIVITY INNOVATION

២០២១

សាកលវិទ្យាល័យភូមិន្ទកសិកម្ម
មហាវិទ្យាល័យវិទ្យាសាស្ត្រព្រៃឈើ

# ក្របខណ្ឌច្បាប់នៃការប្រែប្រួលអាកាសធាតុ
## Legal Framework of Climate Change

លោក សុខ តាក់

លោក ហ៊ីន សារុន លោក គឹម សុបិន្ត

២០២១

# គណៈកម្មការបច្ចេកទេស

## ចំណងជើងសៀវភៅ ៖ ក្រមខណ្ឌច្បាប់នៃការប្រែប្រួលអាកាសធាតុ

| ល.រ | គោត្តនាម និងនាម | សមាសភាពគណៈកម្មការ | ហត្ថលេខា |
|---|---|---|---|
| ១ | លោក  គឹម សុបិន្ត | ប្រធាន | |
| ២ | លោក  ទឹម សុភា | អនុប្រធាន | |

២០២១

# រក្សាសិទ្ធ

© ឆ្នាំ ២០២១
**រក្សាសិទ្ធគ្រប់យ៉ាង**
គ្មានផ្នែកណាមួយនៃសៀវភៅនេះ អាចត្រូវបានថតចម្លង និងផលិតឡើងវិញ ដោយគ្មានការអនុញ្ញាតជាលាយលក្ខណ៍អក្សរពីអ្នកនិពន្ធ និងសាកលវិទ្យាល័យភូមិន្ទកសិកម្ម។

បោះពុម្ពលើកទី១ ដោយមូលនិធិស្រាវជ្រាវ គំនិតច្នៃប្រឌិត និងនវានុវត្តន៍ (ស.គ.ន) នៃក្រសួងអប់រំ យុវជន និងកីឡា នៅព្រះរាជាណាចក្រកម្ពុជា ។

**ទំនាក់ទំនងព័ត៌មាន:**
អ្នកនិពន្ធ៖ លោក សុខ ភាក់ / លោក គឹម សុបិន្ត / លោក ហ៊ន សារុន
ទូរស័ព្ទ៖ (+៨៥៥) ៩៨ ៣៧៨ ៧២១ / (+៨៥៥) ១២ ៧២៤ ៦៨៦ / (+៨៥៥) ៨៧ ២០៩ ៩២៦
អ៊ីមែល៖ sopheakstar14@gmail.com / kimsoben@gmail.com / hornsarun@gmail.com

©. 2021 by Sok Pheak. All rights reserved. No part of this publication may be reproduced, stored in a retrieval system, or transmitted by any process without the prior written permission from the author and the Royal University of Agriculture.

First Edition
Printed by the Research Creativity and Innovation Fund (RCI Fund) of Ministry of Education, Youth and Sport, the Kingdom of Cambodia

Enquiries about the book:
Author: Mr. Sok Pheak / Mr. Kim Soben / Mr. Horn Sarun
Mobile phone: +855 98 378 721 / +855 12 724 686 / +855 87 209 926
Email: sopheakstar14@gmail.com / kimsoben@gmail.com / hornsarun@gmail.com

# បុព្វកថា

ដំណើរអភិវឌ្ឍនៃព្រះរាជាណាចក្រកម្ពុជានៅក្នុងយុគសម័យទំនើបនេះ ជាមេរៀនដ៏ជោគជ័យបំផុតមួយ ដែលចាប់ឫសគល់ចេញពីការបញ្ចប់របបប្រល័យពូជសាសន៍ ការបញ្ចប់សង្គ្រាម ការផ្សះផ្សារជាតិ ការកសាងមូលដ្ឋានរឹងមាំនៃសន្តិភាពនិងស្ថេរភាព និងការអភិវឌ្ឍសេដ្ឋកិច្ច។ នៅក្រោយពេលដែលសន្តិភាពត្រូវបានកើតឡើងដោយបរិបូរណ៍នៅឆ្នាំ១៩៩៨ កម្ពុជាទទួលកំណើនសេដ្ឋកិច្ចខ្ពស់ គឺប្រមាណ៨% ក្នុងមួយឆ្នាំ។ លើសពីនេះទៀត អត្រានៃភាពក្រីក្រត្រូវបានកាត់បន្ថយពីប្រមាណ៥៣% នៅឆ្នាំ២០០៤ មកនៅទាបជាង១០% នៅឆ្នាំ២០១៩។ ដំណើរនៃការអភិវឌ្ឍជាតិជាសកម្មភាពដែលបន្តទៅមុខជាប់ជានិច្ច ហើយគោលនយោបាយថ្មីៗដែលមានលក្ខណៈអន្តរវិស័យគ្រប់ដណ្ដប់ក៏កំពុងលេចរូបរាងឡើង ដើម្បីតម្រង់ទិសកម្ពុជាឆ្ពោះទៅកាន់ប្រទេសមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងឈានឡើងជាប្រទេសមានប្រាក់ចំណូលខ្ពស់ នៅឆ្នាំ២០៥០។ ការប្រែប្រួលឆាប់រហ័សនៃនិម្មាបនកម្មពិភពលោកនិងតំបន់ រួមទាំងទំនាក់ទំនងភូមិសាស្ត្រនយោបាយ បានផ្ដល់កាលានុវត្តភាពសម្រាប់ការអភិវឌ្ឍឧស្សាហកម្មនៅកម្ពុជា ដែលត្រូវបានរាជរដ្ឋាភិបាលចាត់ទុកជាមូលដ្ឋានគ្រឹះនៃកំណើនសេដ្ឋកិច្ចកម្ពុជា។ រាជរដ្ឋាភិបាលកម្ពុជាបាន និងកំពុងបន្តពង្រឹងនិងអភិវឌ្ឍវិស័យអប់រំឆ្ពោះទៅរកការស្រាវជ្រាវនិងនវានុវត្តន៍ ដើម្បីពង្រឹងសមត្ថភាពនិងជំនាញរបស់ធនធានមនុស្សនៅកម្ពុជា ឱ្យស្របទៅនឹងបរិបទថ្មីនៃការអភិវឌ្ឍ ជាពិសេសការពង្រឹងសហគ្រិនភាពក្នុងការរៀបចំម៉ូដែលធុរកិច្ចថ្មីៗ។ ដើម្បីចាប់យកកាលានុវត្តភាពពីបដិវត្តន៍ឧស្សាហកម្មទី៤ និងសេដ្ឋកិច្ចឌីជីថលដែលកំពុងផុសផុលឡើង ប្រព័ន្ធអេកូឡូហ្ស៊ីដែលបង្កលក្ខណៈអំណោយផលដល់ការបង្កើតថ្មី នវានុវត្តន៍ ការស្រាវជ្រាវ និងអភិវឌ្ឍន៍ត្រូវតែមានការកែលម្អ។

បណ្ដាប្រទេសនៅទ្វីបអាស៊ីកំពុងនាំមុខក្នុងការវិនិយោគលើការស្រាវជ្រាវនិងអភិវឌ្ឍ ដោយមានភាគហ៊ុនប្រមាណ៤៤% នៃការវិនិយោគទាំងមូលរបស់ពិភពលោក។ ប្រទេសចិនកំពុងបន្តកសាងហេដ្ឋារចនាសម្ព័ន្ធនៃការវិនិយោគលើការស្រាវជ្រាវនិងអភិវឌ្ឍ ក៏ដូចជាសមត្ថភាពមនុស្ស។ ផ្ទុយទៅវិញ ប្រទេសនៅទ្វីបអាមេរិកខាងត្បូងនិងអាហ្វ្រិក កំពុងស្ថិតនៅឆ្ងាយពីការវិនិយោគនេះ ហើយជាលទ្ធផលប្រទេសទាំងនោះក៏ពុំមានកំណើនសេដ្ឋកិច្ចគួរឱ្យកត់សម្គាល់ដែរ។ ទុនវិនិយោគសរុបលើការស្រាវជ្រាវនិងអភិវឌ្ឍរបស់ប្រទេសនៅទ្វីបអាមេរិកខាងត្បូងនិងអាហ្វ្រិក មានប្រមាណ៥%នៃការវិនិយោគទាំងមូលរបស់ពិភពលោក ក្នុងពេលដែលតំបន់ទាំង២នេះមានប្រជាជនប្រមាណ២០%នៃប្រជាជនពិភពលោក។ ប្រទេសចំនួន៦ដែលមានលំដាប់ខ្ពស់ជាងគេនៅក្នុងការវិនិយោគលើការស្រាវជ្រាវនិងអភិវឌ្ឍ រួមមានសហរដ្ឋអាមេរិក ចិន ជប៉ុន អាល្លឺម៉ង់ ឥណ្ឌា និងកូរ៉េខាងត្បូង ដែលស្មើនឹងប្រមាណ៧០%នៃទុនវិនិយោគសរុបរបស់ពិភពលោក។

តើចំណេះដឹង ផលិតផល និងសេវាកម្មថ្មីទាំងនេះកើតឡើងពីអ្វី? ហើយកើតឡើងដោយរបៀបណា? ព្រះរាជាណាចក្រកម្ពុជាកំពុងតែកសាងមូលដ្ឋានសម្រាប់ការត្រៀមខ្លួនទទួល និងប្រកួតប្រជែងក្នុងយុគសម័យបដិវត្តឧស្សាហកម្មទី៤ នៅក្នុងសេដ្ឋកិច្ចដែលផ្អែកលើពុទ្ធិ ហើយដែលប្រការនេះ

ចាំបាច់តម្រូវឱ្យពលរដ្ឋកម្ពុជា ត្រូវក្លាយខ្លួនជាពលរដ្ឋឌីជីថល ពលរដ្ឋសកល និងពលរដ្ឋដែលប្រកបដោយការទទួលខុសត្រូវ ដែលមានសមត្ថភាពក្នុងការផលិត ចែកចាយ និងប្រើប្រាស់ពុទ្ធិដើម្បីទទួលមនុញ្ញផល និងរួមចំណែកក្នុងកំណើន។ ធនាគារពិភពលោកបានធ្វើការកត់សម្គាល់តាំងពីឆ្នាំ២០០២នូវបម្លាស់ប្តូរនៃមូលដ្ឋានសេដ្ឋកិច្ច ពីសេដ្ឋកិច្ចដែលពឹងផ្អែកលើកម្លាំងពលកម្ម និងធនធានអតិកម្ម (Labour and Resource Based Economy) ទៅកាន់សេដ្ឋកិច្ចដែលពឹងផ្អែកលើពុទ្ធិ (Knowledge Based-Economy) ដែលក្នុងន័យនេះ ពុទ្ធិគឺជាគន្លឹះនៃការអភិវឌ្ឍ។ អាស្រ័យហេតុនេះ នៅលើគន្លងដែលកម្ពុជាកំពុងធ្វើដំណើរឆ្ពោះទៅកាន់សេដ្ឋកិច្ចឌីជីថល សង្គមកម្ពុជាត្រូវតែមានសមត្ថភាពក្នុងការផលិត ជ្រើសរើស បន្សុំ បង្កើតមុខរបរ និងប្រើប្រាស់ពុទ្ធិ ដើម្បីរក្សានិរន្តរភាពនៃកំណើន និងកែលម្អជីវភាពរស់នៅ។ សមត្ថភាពទាំងនេះ អាចកើតឡើងនៅពេលពលរដ្ឋកម្ពុជាមានឱកាសក្នុងការទទួលបានបទពិសោធន៍ពីការស្រាវជ្រាវ ការបណ្តុះគំនិតច្នៃប្រឌិត និងការស្វែងរកនវានុវត្តន៍។

កំណែទម្រង់វិស័យអប់រំ គឺជាការត្រួសត្រាយមាគ៌ាសម្រាប់ដំណើរឆ្ពោះទៅកាន់សង្គមប្រកបដោយពុទ្ធិ និងប្រជាពលរដ្ឋប្រកបដោយភាពរស់រវើក។ តាមរយៈមូលដ្ឋានអប់រំ សង្គមប្រកបដោយពុទ្ធិនឹងប្រមូលផ្តុំ បង្កើត និងចែករំលែក ទៅកាន់សមាជិកក្នុងសង្គមនូវសម្បទាអប់រំ ពិសេសគឺពុទ្ធិសម្បទាក្នុងបុព្វហេតុនៃមនុស្សជាតិនិងឧត្តមប្រយោជន៍នៃប្រទេស។ សង្គមប្រកបដោយពុទ្ធិ គឺពុំគ្រាន់តែជាសង្គមដែលសម្បូរព័ត៌មានប៉ុណ្ណោះទេ តែជាសង្គមដែលប្រជាពលរដ្ឋអាចធ្វើបរិវត្តកម្មពីព័ត៌មានទៅជាមូលធនប្រកបដោយប្រសិទ្ធភាព។ ការរីកចម្រើនទៅមុខជាលំដាប់នៃបច្ចេកវិទ្យានិងតំណភ្ជាប់ បានពង្រីកព្រំដែននៃការចូលទៅកាន់ និងការទទួលបានព័ត៌មានជាសកល ហើយដែលក្នុងន័យនេះ ការអប់រំនឹងបន្តវិវត្តទៅមុខនិងមានការផ្លាស់ប្តូរ។ សង្គមមួយដែលមានអំណាន និងរបាប់ជាបុរេលក្ខខណ្ឌនៃជីវភាពប្រចាំថ្ងៃនៃប្រជាពលរដ្ឋ ពេលនោះបំណិននៃអំណាន និពន្ធ និងការគណនាលេខនព្វន្ត គឺជាចលករនៃការរៀនរបស់សិស្ស។ ធាតុដ៏ចម្បងមួយដែលស្ថិតនៅក្នុងការកសាងសង្គមដែលប្រកបដោយពុទ្ធិគឺសៀវភៅសិក្សា ហើយការរៀបរៀង និពន្ធ និងកែលម្អសៀវភៅសិក្សាជាប្រចាំ គឺជានវានុវត្តន៍នៃវិស័យអប់រំដែលនាំទៅរកការសិក្សាពេញមួយជីវិត ការអភិវឌ្ឍសម្បទាអប់រំ និងការចែករំលែកចំណេះដឹង។ មូលដ្ឋានអប់រំ ជាពិសេសគឺគ្រឹះស្ថានឧត្តមសិក្សាត្រូវមានតួនាទីដែលប្រកបដោយការឆ្លើយតប ចំពោះតម្រូវការខាងលើនេះ។ សាស្ត្រាចារ្យ អ្នកស្រាវជ្រាវ និងបុគ្គលិកអប់រំត្រូវបន្តសិក្សាជាប់ជានិច្ច តាមរយៈការរៀបរៀង និពន្ធ និងកែលម្អសៀវភៅសិក្សា ហើយដែលសៀវភៅសិក្សាទាំងនេះនឹងក្លាយជាស្ពាននៃទំនាក់ទំនងរវាងនវានុវត្តន៍នៃបច្ចេកវិទ្យា និងការរៀននិងបង្រៀននៅក្នុងថ្នាក់រៀន។

សង្គមដែលប្រកបពុទ្ធិ ក៏ជាសង្គមដែលបណ្តុះឱ្យមានរចនាសម្ព័ន្ធទន់នៃសេដ្ឋកិច្ចដែលពឹងផ្អែកលើពុទ្ធិដែរ។ ឧទាហរណ៍ជាក់ស្តែងនៃបែបផែននេះរួមមាន Silicon Valley នៃសហរដ្ឋអាមេរិក សួនឧស្សាហកម្មវិស្វកម្មអាកាសយានយន្តនិងយានយន្តនៅទីក្រុង Munich ប្រទេសអាល្លឺម៉ង់ តំបន់ជីវបច្ចេកវិទ្យានៅក្រុង Hyderabad ប្រទេសឥណ្ឌា តំបន់ផលិតគ្រឿងអេឡិចត្រូនិកនិងសារគមនាគមន៍ឌីជីថលនៅទីក្រុង Seoul ប្រទេសកូរេខាងត្បូង ក៏ដូចជាសួនឧស្សាហកម្មថាមពល និងឥន្ទនគីមីសាស្ត្រនៃប្រទេសប្រេស៊ីល ហើយក៏នៅមានទីក្រុងនៃប្រទេសជាច្រើនទៀតនៅលើពិភពលោក។ លក្ខណៈសម្បត្តិ

នៃទីក្រុងទាំងនេះគឺការប្រើប្រាស់និន្នាការនៃការអភិវឌ្ឍដែលជំរុញ និងតម្រង់ទិសដោយចំណេះដឹង ហើយដែលចំណេះដឹងទាំងនោះកើតចេញជាដំបូងពីការវិនិយោគទៅលើគ្រឹះស្ថានឧត្តមសិក្សា ស្ថាប័នស្រាវជ្រាវ មជ្ឈមណ្ឌលឧត្តមភាពនៃជំនាញជាន់ខ្ពស់ ការប្រកួតប្រជែងដោយគុណាធិបតេយ្យ និងជាពិសេសគឺការបណ្ដុះវប្បធម៌អំណាននិងនិពន្ធសៀវភៅ។ ល្បឿននៃការរីកចម្រើនផ្នែកពុទ្ធិ និងបច្ចេកវិទ្យាកំពុងមានសន្ទុះលឿនជាងអ្វីដែលសិស្ស និងនិស្សិតអាចទទួលបានពីគ្រូនៅគ្រឹះស្ថានសិក្សា ដែលធ្វើឱ្យគោលដៅនៃការអប់រំនៅពេលបច្ចុប្បន្ននេះ មានការប្រឈមខ្លាំងជាងពេលណាទាំងអស់។ ឧទាហរណ៍ក្នុងមួយឆ្នាំ មានសៀវភៅជាង២,២លានចំណងជើង ត្រូវបានសរសេរនិងបោះពុម្ព ដែលក្នុងនោះប្រទេសចិនមាន៤៤០ពាន់ ចំណែកឯសហរដ្ឋអាមេរិកមាន៣០៥ពាន់ និងប្រទេសរុស្ស៊ីមាន១២០ពាន់ចំណងជើង។

ខណៈពេលដែលបច្ចេកវិទ្យាកំពុងរីកចម្រើនជារៀងរាល់ថ្ងៃ មធ្យោបាយសម្រាប់អំណានក៏មានច្រើនជម្រើសសម្រាប់សិស្ស-និស្សិត និងសាធារណៈជន រួមមានការអានសៀវភៅ ការអានលើឧបករណ៍អេឡិចត្រូនិក ការអានដោយប្រើទូរសព្ទវៃឆ្លាត និងការអានលើកុំព្យូទ័រ ដែលសុទ្ធសឹងជាមធ្យោបាយសំខាន់ៗដែលនាំអ្នកអានទាំងឡាយឱ្យសម្រេចគោលបំណងអានរបស់ខ្លួន។ ម្យ៉ាងវិញទៀត អំណានដោយប្រើមធ្យោបាយបច្ចេកវិទ្យាទំនើប ចំណាយពេលតិច ងាយស្រួលអាន និងជួយដល់បរិស្ថានមួយកម្រិតទៀត។ នាពេលបច្ចុប្បន្ន សិស្ស-និស្សិត និងសាធារណៈជនកម្ពុជាដែលស្រឡាញ់អំណានកំពុងតែប្រើប្រាស់មធ្យោបាយអំណានទាំងនេះ។ បើយើងក្រឡេកមើលទៅប្រទេសជឿនលឿន ទោះបីជាបច្ចេកវិទ្យារីកចម្រើនខ្លាំងយ៉ាងណា អំណានតាមរយៈសៀវភៅនៅតែមានសន្ទុះដដែល។ ម្យ៉ាងវិញទៀត បច្ចេកវិទ្យាអានបែបទំនើបតាមរយៈឧបករណ៍ទំនើប អាស្រ័យលើលទ្ធភាពនៃធនធានអប់រំឌីជីថល និងមាតិកាឌីជីថលគ្រប់គ្រាន់ដែលបានផលិត និងបង្ហោះចែកចាយសម្រាប់អំណាន។

ក្នុងបរិបទកម្ពុជា ជាពិសេសក្នុងបរិការណ៍នៃការផ្ទុះរីករាលដាលនៃជំងឺកូវីដ-១៩ ក្រសួងអប់រំ យុវជន និងកីឡា បានជំរុញឱ្យមានបរិវត្តកម្មឌីជីថលនៅក្នុងអេកូស៊ីស្តែមនៃការអប់រំ ជាពិសេសការអប់រំតាមប្រព័ន្ធអេឡិចត្រូនិកនិងការអប់រំពីចម្ងាយ ដើម្បីលើកកម្ពស់អំណាន តាមរយៈការផលិតមាតិកាឌីជីថលដែលមានភាពចំរុះ ការកសាងសមត្ថភាពផ្នែកតំណភ្ជាប់និងវេទិកាឌីជីថល ការពង្រីកវិសាលភាពនៃមជ្ឈមណ្ឌលទិន្នន័យ និងការលើកកម្ពស់គុណភាពនៃការផលិតធនធានអប់រំឌីជីថល គួបផ្សំជាមួយការចែកសន្លឹកកិច្ចការឱ្យសិស្សយកទៅរៀននៅផ្ទះ និងការចុះទៅជួបជាមួយសិស្សជាបណ្ដុំនៅតាមសហគមន៍។ ក្នុងន័យលើកកម្ពស់អំណាន និងភាពសម្បូរបែបនៃធនធានសៀវភៅសិក្សា ឱ្យកាន់តែមានប្រសិទ្ធភាពនិងភាពសក្ដិសិទ្ធិ និងផ្ដល់ឱកាសអំណានកាន់តែច្រើនថែមទៀតដល់សិស្សានុសិស្ស និស្សិត និងសាធារណៈជន ក្រសួងអប់រំ យុវជន និងកីឡាលើកទឹកចិត្តនូវចំណុចមួយចំនួនដូចខាងក្រោម៖

១. សាស្ត្រាចារ្យ អ្នកស្រាវជ្រាវ និងបុគ្គលិកអប់រំ សូមបន្តនិងបង្កើនការបោះពុម្ពស្នាដៃបន្ថែមទៀត ដើម្បីធ្វើឱ្យធនធានសម្រាប់អំណានកាន់តែសម្បូរបែប ជាពិសេសធនធានអំណានជាខេមរភាសា

២. គ្រឹះស្ថានឧត្តមសិក្សា សូមផ្តល់លទ្ធភាពគ្រប់បែបយ៉ាង ដើម្បីឱ្យបុគ្គលិកអប់រំគ្រប់លំដាប់ថ្នាក់ និងនិស្សិតគ្រប់កម្រិតសិក្សាអាចចូលរួមអាន និងសិក្សាស្រាវជ្រាវតាមគ្រប់លទ្ធភាពជាមួយធនធានអំណាន ជាពិសេសការរៀបចំឱ្យមានពេលវេលាសម្រាប់សហសិក្សា និងអំណានក្នុងបណ្ណាល័យ
៣. សាស្ត្រាចារ្យតាមមុខវិជ្ជា និងអ្នកស្រាវជ្រាវតាមជំនាញឬវិស័យ ត្រូវរៀបចំដំណើរការរៀនបង្រៀន និងស្រាវជ្រាវដែលមានដាក់បញ្ចូលកិច្ចការស្វ័យសិក្សា សហសិក្សា ឬការស្រាវជ្រាវបណ្ណាល័យដែលតម្រូវឱ្យនិស្សិត ត្រូវអាននិងស្រាវជ្រាវជាមួយធនធានអំណាន
៤. គ្រឹះស្ថានឧត្តមសិក្សា និងមជ្ឈមណ្ឌលស្រាវជ្រាវ ត្រូវខិតខំឱ្យអស់លទ្ធភាពក្នុងការបង្កើតបណ្ណាល័យ មជ្ឈមណ្ឌលរក្សាឯកសារ ឬមជ្ឈមណ្ឌលអប់រំឌីជីថលជាដើម ដើម្បីឱ្យបុគ្គលិកអប់រំគ្រប់លំដាប់ថ្នាក់និងនិស្សិតគ្រប់កម្រិតសិក្សាអាចទទួលបាន និងស្វែងរកប្រភពសម្រាប់អំណានកាន់តែសម្បូរបែប និងមានភាពបត់បែន ឆ្លើយតបតាមតម្រូវការអ្នកអាន
៥. និស្សិតគ្រប់កម្រិតសិក្សាត្រូវខិតខំនិងចំណាយពេលវេលាដើម្បីអាន និងចាត់ទុកវប្បធម៌និងអកប្បកិរិយាអំណានជាផ្នែកមួយ នៃពេលវេលានិងភាពស៊ីវិល័យនៃជីវិតប្រចាំថ្ងៃ
៦. បងប្អូនជនរួមជាតិ ដែលជាមាតាបិតា ឬអ្នកអាណាព្យាបាល សូមជួយជំរុញនិងបង្កលក្ខណៈកាន់តែច្រើនថែមទៀត ជាពិសេសការលៃលកចំណាយនៅក្នុងគ្រួសារសម្រាប់ការទិញសម្ភារៈសិក្សា សៀវភៅអាន និងឧបករណ៍សម្រាប់អំណានដល់កូនៗ ដែលចាត់ទុកជាការវិនិយោគមួយដ៏សំខាន់ សម្រាប់ បង្កើនចំណេះដឹង និងអនាគតរបស់ពួកគេ។

ដោយមានការគាំទ្រពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នៅឆ្នាំ២០២០ ក្រសួងអប់រំ យុវជន និងកីឡា បានបង្កើតមូលនិធិស្រាវជ្រាវ គំនិតច្នៃប្រឌិត និងនវានុវត្តន៍ ដែលហៅកាត់ថា “មូលនិធិ ស.គ.ន.” និងហៅជាភាសាអង់គ្លេសថា The Research Creativity and Innovation Fund ដែលហៅកាត់ជាភាសាអង់គ្លេសថា “RCI Fund”។ គោលដៅចម្បងនៃមូលនិធិនេះ គឺរួមចំណែកលើកកម្ពស់វប្បធម៌នៃការស្រាវជ្រាវ បំផុសគំនិតច្នៃប្រឌិត និងជំរុញការធ្វើនវានុវត្ត ដើម្បីជាប្រយោជន៍ដល់វិស័យអប់រំ យុវជន និងកីឡា ដែលឆ្លើយតបទៅនឹងទីផ្សារពលកម្ម និងសាកលភាវូបនីយកម្ម។ មូលនិធិ ស.គ.ន. បានសម្រេចកំណត់ប្រធានបទ ជាអាទិភាពសម្រាប់ការគាំទ្រដោយមូលនិធិចំនួន៣ រួមមានឌីជីថលនីយកម្មសម្រាប់បដិវត្តឧស្សាហកម្ម៤.០ (Digitalization for IR.4.0) ការស្រាវជ្រាវអនុវត្តលើវិស័យកសិកម្ម (Applied Agricultural Research) និងការស្រាវជ្រាវគរុកោសល្យសតវត្សទី២១ (21st Century Pedagogy Research)។

ដោយមានការធ្វើអាទិភាពវូបនីយកម្មទៅលើទិសដៅ នៃការប្រើប្រាស់ថវិកាមូលនិធិសម្រាប់ឆ្នាំ ២០២០ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងអប់រំ យុវជន និងកីឡា បានផ្តល់ការគាំទ្រដល់ការរៀបរៀង និពន្ធ និងកែលម្អ សៀវភៅសិក្សា (Text book) ដែលនឹងត្រូវប្រើប្រាស់នៅកម្រិតឧត្តមសិក្សា។ គោលបំណងនៃការរៀបរៀង និពន្ធ និងកែលម្អ សៀវភៅសិក្សានៅកម្រិតឧត្តមសិក្សា គឺដើម្បីបង្កើនបរិមាណ លើកកម្ពស់គុណភាព និងពង្រីកសមធម៌នៃធនធានសិក្សាជាខេមរភាសា ជូនដល់និស្សិត

ដែលកំពុងបន្តការសិក្សា និងត្រៀមខ្លួនធ្វើការស្រាវជ្រាវនៅកម្រិតឧត្តមសិក្សា។ លើសពីនេះទៀត ការរៀបរៀង និពន្ធ និងកែលម្អសៀវភៅសិក្សានៅកម្រិតឧត្តមសិក្សា មានគោលដៅដូចខាងក្រោម ៖

១. ឆ្លើយតបជាបន្ទាន់ចំពោះការខ្វះខាតធនធានសិក្សា ដែលជាតម្រូវការសិក្សារបស់និស្សិតនៅកម្រិតឧត្តមសិក្សា

២. លើកកម្ពស់ទំនើបភាវូបនីយកម្ម និងឧត្តមានុវត្តន៍នៃការរៀននិងបង្រៀន និងការស្រាវជ្រាវនៅលើមុខវិជ្ជា កម្មវិធីសិក្សា ឬមុខជំនាញជាក់លាក់

៣. បង្កើនភាពស៊ីជម្រៅក្នុងការកសាងវិជ្ជាជីវៈនិងបទពិសោធន៍សម្រាប់បាន:សាស្ត្រាចារ្យ និងអ្នកស្រាវជ្រាវ

៤. រួមចំណែកដល់ការកសាងភាពជាសហគមន៍វិជ្ជាជីវៈ ការចែករំលែកបទពិសោធន៍ និងវប្បធម៌នៃការរៀបរៀង និពន្ធ និងកែលម្អសៀវភៅសិក្សានៅកម្រិតឧត្តមសិក្សា។

ក្រសួងអប់រំ យុវជន និងកីឡា បានវាយតម្លៃខ្ពស់ចំពោះការបោះជំហានប្រកបដោយមនសិការវិជ្ជាជីវៈនៃគ្រឹះស្ថានឧត្តមសិក្សា និងបុគ្គលិកអប់រំទាំងអស់ ក្នុងការរៀបចំ រៀបរៀង និពន្ធ និងកែលម្អសៀវភៅសិក្សា ដើម្បីបង្កើនបរិមាណ លើកកម្ពស់គុណភាព និងពង្រឹងសមធម៌នៃធនធានសិក្សាជាខេមរភាសា ជូននិស្សិតដែលកំពុងបន្តការសិក្សា និងត្រៀមខ្លួនធ្វើការស្រាវជ្រាវនៅកម្រិតឧត្តមសិក្សា។ សៀវភៅសិក្សាជាផ្នែកមួយនៃការទទួលស្គាល់គុណភាពអប់រំនៃគ្រឹះស្ថានឧត្តមសិក្សា និងជាធនធានសិក្សាដែលជាមូលដ្ឋានមួយដ៏សំខាន់ ក្នុងការគាំទ្រដល់ការបង្រៀន និងរៀន ហើយត្រូវមានបរិមាណគ្រប់គ្រាន់ ឆ្លើយតបទៅនឹងកម្មវិធីអប់រំ និងតម្រូវការសិក្សាស្រាវជ្រាវ។ ជាគោលការណ៍ គ្រឹះស្ថានឧត្តមសិក្សាទាំងអស់ ត្រូវមានសៀវភៅសិក្សាដែលប្រើជាគោលសម្រាប់មុខវិជ្ជានីមួយៗ។ ចំនួនសៀវភៅសិក្សាដែលគ្រប់គ្រាន់សម្រាប់ការស្រាវជ្រាវ និងការសិក្សារបស់និស្សិត ត្រូវមានយ៉ាងតិចមួយចំណងជើងក្នុងមួយមុខវិជ្ជា ហើយត្រូវតម្កល់យ៉ាងតិច២ច្បាប់នៅក្នុងបណ្ណាល័យ ឬអាចរកបានតាមប្រព័ន្ធអេឡិចត្រូនិក។ ក្រសួងអប់រំ យុវជន និងកីឡា លើកទឹកចិត្តបន្ថែមទៀតជូនដល់គ្រឹះស្ថានឧត្តមសិក្សារដ្ឋ និងឯកជនដែលបានស្នើសុំថវិកាមូលនិធិ ស.គ.ន រួច សូមចូលរួមបន្ថែមទៀតដើម្បីបង្កើនចំនួនចំណងជើងសៀវភៅ។ ចំណែកគ្រឹះស្ថានឧត្តមសិក្សារដ្ឋ និងឯកជនដែលពុំទាន់បានដាក់ពាក្យស្នើសុំថវិកាមូលនិធិ ដើម្បីរៀបរៀង និពន្ធ និងកែលម្អ សៀវភៅសិក្សានៅកម្រិតឧត្តមសិក្សា សូមរួសរាន់ចូលរួមដើម្បីជាគុណប្រយោជន៍ដល់តម្រូវការដ៏ទទូចនិងថ្លៃថ្លានៃនិស្សិតកម្ពុជាក្នុងការសិក្សា និងស្រាវជ្រាវនៅកម្រិតឧត្តមសិក្សា។

## សេចក្តីបញ្ជាក់
## នៃមូលនិធិស្រាវជ្រាវ គំនិតច្នៃប្រឌិត និងនវានុវត្តន៍

សៀវភៅសិក្សានេះជាលទ្ធផលនៃការស្នើសុំអនុវត្តថវិកាមូលនិធិស្រាវជ្រាវ គំនិតច្នៃប្រឌិត និងនវានុវត្តន៍ ក្នុងគម្រោងរៀបរៀង និពន្ធ និងកែលម្អសៀវភៅសិក្សា ដែលនឹងត្រូវប្រើប្រាស់នៅកម្រិតឧត្តមសិក្សា។ សៀវភៅសិក្សានេះ ត្រូវបានរៀបរៀង និពន្ធ ឬកែលម្អដោយមានការធានាអះអាងថាជាស្នាដៃរបស់អ្នកនិពន្ធផ្ទាល់ និងបានឆ្លងកាត់ត្រួតពិនិត្យ ផ្តល់យោបល់ និងវាយតម្លៃដោយក្រុមប្រឹក្សាអប់រំ ក្រុមប្រឹក្សាស្រាវជ្រាវ ឬក្រុមប្រឹក្សាដែលមានតម្លៃស្មើនៃគ្រឹះស្ថានឧត្តមសិក្សា និងតាមរយៈកិច្ចសន្យាដែលបានធ្វើឡើង និងដែលបានតម្កល់ទុកនៅមូលនិធិស្រាវជ្រាវ គំនិតច្នៃប្រឌិត និងនវានុវត្តន៍។ រាល់ខ្លឹមសារ ការបកស្រាយ ឬរូបភាព ដែលមាននៅក្នុងសៀវភៅនេះ គឺជាជំហរនិងទស្សនៈផ្ទាល់របស់អ្នកនិពន្ធ ហើយពុំឆ្លុះបញ្ចាំង ឬជាតំណាងដល់មូលនិធិស្រាវជ្រាវ គំនិតច្នៃប្រឌិត និងនវានុវត្តន៍ នៃក្រសួងអប់រំ យុវជន និងកីឡាឡើយ។

# ឧទ្ទិសកថា

កូនសូមឧទ្ទិស នូវអំណរអរគុណ យ៉ាងជ្រាលជ្រៅផងដែរ ចំពោះវិញ្ញាណក្ខន្ធ លោកឪពុក និងអ្នកម្ដាយ ដែលបានផ្ដល់កំណើតឱ្យរូបកូន និងសតិបញ្ញា ភ្លឺថ្លា ឈ្លាសវៃ ដែលកូនមាន ព្រមទាំងការបីបាច់ថែរក្សាកន្លងមក ជាពិសេសជាងនេះទៅទៀត បានផ្ដល់កំណើតដល់ក្រុមគ្រួសារឱ្យមានបង និងប្អូនស្រីដែលមានចិត្តសប្បុរសល្អ មេត្តាករុណា និងអំណត់អត់ធ្មត់ជាទីបំផុត។

# សេចក្តីថ្លែងអំណរគុណ

សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះឯកឧត្តមសាស្ត្រាចារ្យបណ្ឌិត **ង៉ោ ប៊ុនថាន** សាកលវិទ្យាធិការនៃសាកលវិទ្យាល័យភូមិន្ទកសិកម្ម ក៏ដូចជាមហាវិទ្យាល័យវិទ្យាសាស្ត្រព្រៃឈើ នៃសាកលវិទ្យាល័យភូមិន្ទកសិកម្មដែលបានផ្តល់អនុញ្ញាត និងលើកទឹកចិត្តនៅក្នុងការរៀបចំសរសេរសៀវភៅមួយក្បាលនេះដើម្បីចែករំលែកចំណេះដឹងខ្លះៗដល់អ្នកអាន។

សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ មូលនិធិស្រាវជ្រាវ គំនិតច្នៃប្រឌិត និងនវានុវត្តន៍ នៃក្រសួងអប់រំ យុវជន និងកីឡា ដែលបានគាំទ្រថវិការជួយជ្រោមជ្រែងនៅក្នុងការងាររៀបចំបង្កើត ក៏ដូចជាការបោះពុម្ពឡើងជាសៀវភៅមួយក្បាលនេះ។

សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ **ឯកឧត្តម សាន វឌ្ឍនា** អនុរដ្ឋលេខាធិការនៃក្រសួងអប់រំ យុវជន និងកីឡា ដែលបានផ្តួចផ្តើមនៅក្នុងការលើកទឹកចិត្ត និងធ្វើឱ្យបញ្ញាវន្តខ្មែរជាច្រើនអ្នកមានឱកាសបញ្ចេញស្នាដៃនៅក្នុងការបោះពុម្ពសៀវភៅជាខេមរភាសារសម្រាប់និស្សិតបញ្ញវន្ត ក៏ដូចជាភាគីពាក់ព័ន្ធនានាអាចយកទៅធ្វើការសិក្សាស្រាវជ្រាវប្រកបដោយភាពងាយស្រួល។

សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ គណៈកម្មការត្រួតពិនិត្យ គណៈកម្មការបច្ចេកទេស និងផ្នែកស្រាវជ្រាវ និងនុវានុវត្តន៍ នៃសាកលវិទ្យាល័យភូមិន្ទកិសកម្ម ទាំងអស់ដែលមានគាំទ្រ និងសម្របសម្រួលរហូតដល់ជោគជ័យ។

សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុត ចំពោះអ្នកមានគុណទាំងពីរ ប្អូនស្រី ព្រមទាំងបង ប្អូនប្រុស ដែលបានចំណាយអស់នូវកំលាំងកាយ និងកំលាំងចិត្តតស៊ូនឿយហត់ លំបាកលំបិន ក្នុងការរកប្រាក់ចិញ្ចឹមកូន ព្រមទាំងប្អូនៗទាំងអស់ ដែលប្រកបទៅដោយគុណធម៌ សីលធម៌ និងមេត្តាធម៌។

# អារម្ភកថា

ក្នុងឆ្នាំ២០១៥ កម្ពុជាបានផ្ញើនូវរបាយការណ៍ស្តីពីការចូលរួមចំណែករបស់ជាតិក្នុងការអនុវត្តន៍ អនុសញ្ញា UNFCCC ដែលហៅកាត់ថា INDC ទៅលេខាធិការដ្ឋាន UNFCCC ដែលជាផ្នែកមួយនៃការចូល រួមនៅក្នុងកិច្ចប្រជុំសមាជិកភាគីលើកទី២១។ ដំណាក់កាលដំបូង វាបានកំណត់នូវគោលដៅកាត់បន្ថយ ការបញ្ចេញឧស្ម័នពីការប្រើប្រាស់វិស័យថាមពលឱ្យបាន ២៧% (៣១ មេហ្គាតោនឧស្ម័នកាបូនិច) នៅឆ្នាំ ២០៣០ បើប្រៀបធៀបទៅនឹងសេណារ៉ូប្រើប្រាស់ធម្មតា(BAU) និងកំណើនគម្របព្រៃឈើជាតិឱ្យបាន ៦០% នៅឆ្នាំ២០៣០។

ជាទូទៅ ការកាត់បន្ថយជាគោលដៅតិចតួចជាងការបន្សាំសម្រាប់ប្រទេសកម្ពុជា។ ក្របខ័ណ្ឌហិរញ្ញប្បទានអាកាសធាតុ (CCFF) ត្រូវបានរៀបចំឡើងដោយបង្ហាញអំពីរចនាសម្ព័ន្ធថវិកា និងការកៀរគរហិរញ្ញប្បទានអាកាសធាតុ។ ឯកសារនេះមានគោលបំណងដើម្បីកំណត់ពីការសម្របសម្រួល អាទិភាព និងហិរញ្ញប្បទានសម្រាប់សកម្មភាពបន្សាំ និងកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់។ ប្រភពហិរញ្ញប្បទាន អាកាសធាតុត្រូវបានកំណត់នៅក្នុង CCFF ដែលបានគូសបញ្ជាក់ពីថវិការដ្ឋាភិបាល ឬប្រភពមកពីមូលនិធិពិភពលោក ព្រមទាំងម្ចាស់ជំនួយទ្វេភាគី និងពហុភាគីផងដែរ។

នៅកម្រិតវិស័យ ផែនការសកម្មភាពប្រែប្រួលអាកាសធាតុ(CCAPs) បានអនុម័តដោយក្រសួង និងស្ថាប័នពាក់ព័ន្ធ ដើម្បីកំណត់សកម្មភាពដែលពាក់ព័ន្ធនឹងគោលបំណងនៃផែនការយុទ្ធសាស្ត្រ ផ.យ.ប.ក. ផែនការសកម្មភាពតាមវិស័យ (CCAPs) រួមបញ្ចូលនូវសកម្មភាពសរុប៦៨ ជាមួយនឹងគោល នយោបាយ ផែនការ ការពង្រឹងសមត្ថភាព ពង្រឹងស្ថាប័ន ៣៩សកម្មភាពទៀតពាក់ព័ន្ធនឹងការផ្តល់សេវា កម្មដល់ក្រុមទទួលផលគម្រោង និង១០សកម្មភាពទៀតពាក់ព័ន្ធនឹងការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធ ។ ជាឧទាហរណ៍ សកម្មភាពមួយដែលបានកំណត់នៅក្នុងវិស័យដឹកជញ្ជូនដែលនឹងអាចមានឥទ្ធិពលដោយផ្ទាល់ទៅដល់វិស័យឯកជន សង្កតភាពទៅនឹងការជំរុញនូវការថែទាំ ការត្រួតពិនិត្យរថយន្តដែលជាផ្នែកមួយនៃការខិតខំប្រឹងប្រែងកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់ ។

រវាងឆ្នាំ២០០៦ និង២០១៥ ស្ថាប័នសាធារណៈទទួលបន្ទុកការប្រែប្រួលអាកាសធាតុ (មិនរួម បញ្ចូល REDD+ ដែលបានបញ្ជាក់អំពីស្ថាប័នទទួលបន្ទុក) គឺជាគណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុ (NCCC) ដែលមានតួនាទីក្នុងការសម្របសម្រួលការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុនៅក្នុងប្រទេសកម្ពុជា (ឧទាហរណ៍៖ ការរៀបចំ សម្របសម្រួលនិងតាមដានការអនុវត្តគោល នយោបាយយុទ្ធសាស្ត្រ ការណែនាំផ្នែកច្បាប់ផែនការកម្មវិធីដែលពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុ) ។

ក្នុងខែឧសភា ឆ្នាំ២០១៥ ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព (ក.ជ.អ.ច.) បានទទួលរាប់រងតួនាទី និងភារកិច្ចនេះពី NCCC និងគណៈកម្មាធិការផ្សេងៗចំនួនបួនទៀត។ ក.ជ.អច. មានសមាសភាពពី

រដ្ឋលេខាធិការ និងអនុរដ្ឋលេខាធិការពីក្រសួងនានា និងដឹកនាំដោយរដ្ឋមន្ត្រីក្រសួងបរិស្ថាន។ បើប្រៀបធៀបទៅនឹង NCCC សមាជិករបស់ ក.ជ.អ.ច. បានកើនឡើង (ក្រសួងជាច្រើនត្រូវបានបញ្ចូល និងអភិបាលនៃគណៈអភិបាលខេត្តផងដែរ) ក.ជ.អ.ច.បានដើរតួនាទីយ៉ាងសំខាន់ក្នុងការរៀបចំផែនការ យុទ្ធសាស្ត្រប្រែប្រួលអាកាសធាតុកម្ពុជា ២០១៤-២០២៣ ផែនការសកម្មភាពប្រែប្រួលអាកាសធាតុតាមវិស័យ និងក្របខ័ណ្ឌហិរញ្ញប្បទានអាកាសធាតុ ។

សព្វថ្ងៃនេះ វានឹងអាចប្រែប្រួលទៅជាថ្ងៃស្អែក ស្នាដៃនេះជាពន្លឺនាំមុខមួយដើម្បីត្រួសត្រាយផ្លូវទៅខាងមុខ សំដៅដោះស្រាយនូវបញ្ហាមួយចំនួនក្នុងចំណោមបញ្ហានៅក្នុងវិស័យព្រៃឈើ ក៏ដូចជាការប្រែប្រួលអាកាសធាតុ ។

ខ្ញុំបាទនឹងរង់ចាំទទួលនូវការរិះគន់កែលំអរក្នុងន័យស្ថាបនា ដើម្បីធ្វើឱ្យឯកសារនេះកាន់តែសុក្រិតថែមទៀត។ ខ្ញុំបាទសូមអភ័យទោសដល់លោក លោកស្រី និស្សិត ប្រជាពលរដ្ឋ ព្រមទាំងមិត្តអ្នកអានទាំងអស់ផងដែរ ប្រសិនបើមានការខុសឆ្គងដោយអចេតនាក្នុងការប្រើឃ្លាប្រយោគ ឬកំហុសអក្ខរាវិរុទ្ធ ដែលមាននៅក្នុងសៀវភៅនេះ។

ខ្ញុំបាទសូមជូនពរ ដល់អស់លោក លោកស្រី អ្នកនាង ព្រមទាំងមិត្តអ្នកអានទាំងអស់ជួបតែនឹងសេចក្តីសុខ និងសុភមង្គលគ្រប់ពេលវេលា។

ថ្ងៃ.................ខែ.............ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥

រាជធានីភ្នំពេញថ្ងៃទី......... ខែ...........គ.ស ២០២១

**អ្នកនិពន្ធ**

**លោក សុខ គាក់**

# អ្នកនិពន្ធ



| | | |
|---|---|---|
| នាម និងគោត្តនាម | ៖ | លោក **សុខ ភាក់** |
| អាស័យដ្ឋាន | ៖ | សង្កាត់/ខណ្ឌ ស្ទឹងមានជ័យ ភ្នំពេញ |
| ស្ថាប័នការងារ | ៖ | មជ្ឈមណ្ឌលសិក្សាស្រាវជ្រាវ កសិកម្ម និង បរិស្ថាន នៃ ស.វ.ភ.ក |
| ឯកទេស ឬមុខជំនាញ | ៖ | ការគ្រប់គ្រងធនធានធម្មជាតិ & ការប្រែប្រួលអាកាសធាតុ |
| ប្រវត្តិការសិក្សា | ៖ | បរិញ្ញបត្រផ្នែក អក្សរសាស្ត្រអង់គ្លេស ឆ្នាំ ២០១២<br>អនុបណ្ឌិតផ្នែក ការគ្រប់គ្រងធនធានធម្មជាតិ ឆ្នាំ ២០១៩ |
| បទពិសោធន៍ការងារ | ៖ | ការប្រប្រែប្រួលអាកាសធាតុ តំបន់ដីសើម ព្រៃឈើ រយៈពេល ៨ ឆ្នាំ |

# សហអ្នកនិពន្ធ



នាម និងគោត្តនាម ៖ លោក **គឹម សុបិន្ត**

អាស័យដ្ឋាន ៖ សង្កាត់/ខណ្ឌ ដង្កោ ភ្នំពេញ

ស្ថាប័នការងារ ៖ មហាវិទ្យាល័យវិទ្យាសាស្ត្រព្រៃឈើ និង
មជ្ឈមណ្ឌលសិក្សាស្រាវជ្រាវ កសិកម្ម
និង បរិស្ថាន នៃ ស.វ.ភ.ក

ឯកទេស ឬមុខជំនាញ ៖ ព្រៃឈើ ការប្រែប្រួលអាកាសធាតុ

ប្រវត្តិការសិក្សា ៖ បរិញ្ញាបត្រផ្នែក វិស្វ័កកម្មព្រៃឈើ ឆ្នាំ ១៩៩៧
អនុបណ្ឌិតផ្នែក ការគ្រប់គ្រងធនធានធម្មជាតិ ឆ្នាំ ២០០៦
អនុបណ្ឌិតផ្នែក វិទ្យាសាស្ត្របរិស្ថាន ឆ្នាំ ២០០៧

បទពិសោធន៍ការងារ ៖ ការប្រប្រែប្រួលអាកាសធាតុ តំបន់ដីសើម កសិកម្ម ព្រៃឈើ បទពិសោធន៍
រយៈពេល ២០ ឆ្នាំ

# សហអ្នកនិពន្ធ



| | | |
|---|---|---|
| នាម និងគោត្តនាម | ៖ | លោក **ហ៊ិន សារុន** |
| អាស័យដ្ឋាន | ៖ | សង្កាត់/ខណ្ឌ ដង្កោ ភ្នំពេញ |
| ស្ថាប័នការងារ | ៖ | មជ្ឈមណ្ឌលសិក្សាស្រាវជ្រាវ កសិកម្ម និង បរិស្ថាន នៃ ស.វ.ភ.ក |
| ឯកទេស ឬមុខជំនាញ | ៖ | ការគ្រប់គ្រងធនធានធម្មជាតិ |
| ប្រវត្តិការសិក្សា | ៖ | បរិញ្ញបត្រផ្នែក ក្សេត្រសាស្ត្រ ឆ្នាំ ២០១៤<br>អនុបណ្ឌិតផ្នែក ការគ្រប់គ្រងធនធានធម្មជាតិ ឆ្នាំ ២០១៩ |
| បទពិសោធន៍ការងារ | ៖ | ព្រៃឈើ ការប្រែប្រួលអាកាសធាតុ កសិកម្ម រយៈពេល ៦ ឆ្នាំ |

# មាតិកា

បុព្វកថា និងសេចក្តីបញ្ជាក់មូលនិធិ

**ទំព័រ**


សេចក្តីថ្លែងអំណរគុណ ........ i
អារម្ភកថា ........ ii
មាតិកា ........ vii

**ជំពូកទី ១ សេចក្តីផ្តើមអំពីក្របខណ្ឌច្បាប់នៃការប្រែប្រួលអាកាស**

មេរៀនទី ១ បច្ចុប្បន្នភាពក្របខណ្ឌច្បាប់នៃការប្រែប្រួលអាកាសធាតុនៅកម្ពុជា ........ ២
១. សន្និសីទអង្គការសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ ........ ៣
១.១ ផែនការការចូលរួមចំណែកដែលកំណត់ដោយរដ្ឋភាគី ........ ៤
១.២ ភាពខុសគ្នា ........ ៥
១.៣ ហិរញ្ញវត្ថុ ........ ៥
១.៤ ការបាត់បង់ និងការខូចខាត ........ ៦
១.៥ ជំហរកម្ពុជា (សេចក្តីថ្លែងការនៅ COP20) ........ ៦
១.៦ ជំហររបស់អាស៊ានស្តីពីការគាំទ្ររបស់ប្រទេសអភិវឌ្ឍន៍ ........ ៧
១.៧ គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ឬ របៀបវារៈឆ្នាំ ២០៣០ ........ ៧
២. អាស៊ាន និងការប្រែប្រួលអាកាសធាតុ ........ ៨
៣. សកម្មភាពកម្ពុជាឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ ........ ១០
មេរៀនទី ២ កម្ពុជា និងអនុសញ្ញាក្របខណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ ........ ១៣
១. សេចក្តីផ្តើម ........ ១៣
២. បរិបទជាតិ ........ ១៤
៣. ការបន្សាំ ........ ១៦
៣.១ ភាពងាយរងគ្រោះចំពោះការប្រែប្រួលអាកាសធាតុ ........ ១៦
៤. សកម្មភាពជាអាទិភាព ........ ១៧
៥. ការកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់ ........ ១៩
៥.១ ការរួមចំណែក ........ ១៩
៥.២ ព័ត៌មានដើម្បីផ្ទៀងផ្ទាត់អំពីសុក្រឹតភាព តម្លាភាព និងការយោគយល់ ........ ២២
៥.៣ ភាពត្រឹមត្រូវ និងមហិច្ឆិតា ........ ២៤
៦. ដំណើរការរៀបចំផែនការនិងការអនុវត្ត ........ ២៥
៧. មធ្យោបាយនៃការអនុវត្ត ........ ២៧

មេរៀនទី ៣ ពិធីសារក្យូតូ ........ ៣៤
១. សេចក្តីផ្តើម ........ ៣៤
២. ការឆ្លើយតបរបស់មនុស្សជាតិ ........ ៣៤
២.១ អនុសញ្ញាក្របខ័ណសហប្រជាជាតិ ស្តីពីការប្រប្រួលអាកាសធាតុ ........ ៣៤
២.២ ពិធីសារកតូ ........ ៣៥
២.៣ យន្តការអេភិវឌ្ឍន៍ស្អាត (The Clean development Mechanism, CDM) ........ ៣៥
៣. កម្ពុជា និងបញ្ហាបប្រួលអាកាសធាតុ ........ ៣៦
៤. កាលានុវត្តភាពដល់កម្ពុជាអាចទទួលបានពីពិធីសារក្យូតូ ........ ៣៨
មេរៀនទី ៤ កិច្ចព្រមព្រៀងទីក្រុងបារីស៍ ........ ៤០
មេរៀនទី ៥ ពិធីសារ និងអនុសញ្ញាក្របខណ្ឌពាក់ព័ន្ធផ្សេងៗ ........ ៦៤
១. ពិធីសារកាតាហ្សេណា ........ ៦៤
១.១ ពិធីសារកាតាហ្សេណា ស្តីពីជីវសុវត្ថិភាពនៃអនុសញ្ញាស្តីពីជីវៈចម្រុះ ........ ៦៥
១.១.១ គោលបំណង ........ ៦៦
១១.២ លក្ខខ័ណ្ឌទូទៅ ........ ៦៦
១.១.៣ ការប្រើប្រាស់ពាក្យ ........ ៦៧
១.១.៤ វិសាលភាព ........ ៦៨
២. ពិធីសារម៉ុងអាល់ ........ ៦៩
៣. ពិធីសារម៉ុងរ៉េអាល់ស្តីពី សារជាតុដែលបំផ្លាញស្រទាប់ អូហ្សូន ........ ៧២
៤. អនុសញ្ញា ស្តុកខូម ស្តីពី សារជាតុបំពុលសរីរាង្គមិនងាយបំបែកជាតុ ........ ៧៣

**ជំពូកទី ២ ផែនការសកម្មភាព យុទ្ធសាស្ត្រ និងគោលនយោបាយការប្រែប្រួលអាកាសធាតុ**

មេរៀនទី ១ ផែនការសកម្មភាពការប្រែប្រួលអាកាសធាតុតាមវិស័យ ........ ៧៧
១. ផែនការសកម្មភាពឆ្លើយតមការប្រែប្រួលអាកាសធាតុ ២០១៦-២០១៨
ក្រសួងបរិស្ថាន ........ ៧៧
១.១ ផែនការសកម្មភាពការប្រែប្រួលអាកាសធាតុ ........ ៧៧
១.១.១ វិសាលភាពនៃផែនការសកម្មភាពប្រែប្រួលអាកាសធាតុ ........ ៧៧
១.១.២ តារាងផែនការសកម្មភាព ........ ៧៨
១.១.៣ យន្តការគ្រប់គ្រង និងហិរញ្ញប្បទាន ........ ៨០
២. ផែនការសកម្មភាព ស្តីពីយេនឌ័រ និងការប្រែប្រួលអាកាសធាតុ ២០១៤-២០១៨
ក្រសួងកិច្ចការនារី ........ ៨៣

៣. ផែនការយុទ្ធសាស្ត្រឆ្លើយតបទៅនឹងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ ២០១៣-២០១៨ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ........ ៨៦
៣.១ យុទ្ធសាស្ត្រា Strategies ........ ៨៦
៣.១.១ វិធានការជាយុទ្ធសាស្តលើវិស័យកសិកម្ម និងកសិឧស្សាហកម្ម ........ ៨៦
៣.១.២ វិធានការជាយុទ្ធសាស្ត្រលើវិស័យកៅស៊ូ ........ ៨៨
៣.១.៣ វិធានការជាយុទ្ធសាស្តលើវិស័យផលិតកម្មសត្វ និង សុខភាពសត្វ ........ ៨៩
៣.១.៤ វិធានការជាយុទ្ធសាស្ត្រលើវិស័យព្រៃឈើ ........ ៩១
៣.១.៥ វិធានការជាយុទ្ធសាស្ត្រលើវិស័យជលផល ........ ៩៣
៤. ផែនការសកម្មភាព ឆ្លើយតបការប្រែប្រួលអាកាសធាតុក្រសួងអភិវឌ្ឍន៍ជនបទ ........ ៩៥
៥. ផែនការសកម្មភាព និងហានិភ័យដែលឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ ក្រសួងធនធានទឹក និងឧតុនិយម ........ ៩៩
៦. ផែនការសកម្មភាព ឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ ក្នុងវិស័យថាមពល (២០២១-២០២៣) ក្រសួងរ៉ែ និងថាមពល ........ ១០១
៦.១ សង្ខេបវិសាលភាពនផែនការ ........ ១០១
៦.២ តារាងផនការសកម្មភាព ........ ១០១
មេរៀនទី ២ ផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ ........ ១០៤
១. សេចក្តីផ្តើម ........ ១០៤
២. ចក្ខុវិស័យ ........ ១០៦
៣. បេសកកម្ម ........ ១០៦
៤. គោលបំណង ........ ១០៦
៥. ក្របខ័ណ្ឌយុទ្ធសាស្ត្រ ........ ១០៦
៥.១. គោលការណ៍ណែនាំ ........ ១០៦
៥.២. ការវិភាគយុទ្ធសាស្ត្រ ........ ១០៧
៥.៣.ទិសដៅជាយុទ្ធសាស្ត្រ និងយុទ្ធសាស្ត្រ ........ ១១៦
៦. សកម្មភាព ........ ១២២
៦.១. ដំណាក់កាលសម្រាប់អនុវត្ត ផ.យ.ប.អ.ក. ........ ១២៣
៧. ការឆ្លើយតបជាស្ថាប័នចំពោះការបន្សុំាទៅនឹងកាបប្រួលអាកាសធាតុ ........ ១២៥
៧.១ ស្ថាប័នសំរបសំរួលថ្នាក់ជាតិសំខាន់ៗដែលពាក់ព័ន្ធក្នុងការបន្សុំាទៅនឹងការ ប្រែប្រួលអាកាសធាតុ ........ ១២៥
៧.១.១ គណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុ ........ ១២៥

៧.២ ក្រុមបង្គោល និងអង្គការមិនមែនរដ្ឋាភិបាលដែលរួមចំណែកក្នុងការបន្សាំទៅនឹងការ ប្រែប្រួលអាកាសធាតុ.......................................................................................................១២៦
៧.២.១ ក្រុមជំនាញសម្រាប់ប្រទេសមានការលូតលាស់តិច ....................................១២៦
៧.២.២ ក្រុមការងារអន្តរជាតិស្តីពីការប្រែប្រួលអាកាសធាតុ (IPCC) អង្គការឧតុនិយមពិភពលោក (WMO) និងកម្មវិធី បរិស្ថានសហប្រជាជាតិ (UNEP) ....................................១២៦
៧.៣ ក្រសួងបង្គោល និងរដ្ឋបាលពាក់ព័ន្ធផ្សេងៗទៀត.............................................១២៦
៧.៣.១ ការិយាល័យប្រែប្រួលអាកាសធាតុ កម្ពុជា ....................................................១២៦
៧.៣.២ គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ............................................. ១២៧
៧.៣.៣ អាជ្ញាធរជាតិទទួលបន្ទុកយន្តការអភិវឌ្ឍន៍ស្អាត ............................................ ១២៧
៧.៤ ស្ថាប័នថ្នាក់ក្រសួងសំខាន់ៗដែលចូលរួមចំណែកដល់ការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ..................................................................................................................... ១២៧
៧.៤.១ ក្រសួងធនធានទឹក និងឧតុនិយម....................................................................... ១២៧
៧.៤.២ នាយកដ្ឋានឧតុនិយម នៃក្រសួងធនធានទឹក និងឧតុនិយម.............................១២៨
៧.៤.៣ ក្រសួងបរិស្ថាន....................................................................................................១២៨
៧.៤.៤ ក្រសួងសុខាភិបាល ............................................................................................១២៨
៧.៤.៥ ក្រសួងផែនការ ...................................................................................................១២៨
៧.៤.៦ ក្រសួងបង្គោល និងរដ្ឋបាលពាក់ព័ន្ធផ្សេងៗ......................................................១២៩
មេរៀនទី ៣ ផែនយុទ្ធសាស្ត្រជាតិ និងគោលនយោបាយជាតិពាក់ព័ន្ធផ្សេងៗ............................ ១៣៥
១.ដំណើរការត្រៀមផែនការជាតិបន្សាំការប្រែប្រួលអាកាសធាតុ.................................... ១៣៥
១.១ ផែនការរដ្ឋាភិបាល និងគោលនយោបាយឆ្លើយតបការប្រែប្រួលអាកាសធាតុ............ ១៣៥
១.២ ក្របខ័ណ្ឌស្ថាប័នសម្រាប់ការប្រែប្រួលអាកាសធាតុ .............................................. ១៣៦
២. ការអនុវត្តផែនការជាតិបន្សាំក្នុងប្រទេសកម្ពុជា....................................................... ១៣៩
២.១ ការចូលរួមរបស់អ្នកពាក់ព័ន្ធ និងការដាក់បញ្ចូលសម្រាប់ដំណើរការរៀបចំគម្រោងបន្សាំ ............................................................................................................................ ១៣៩
២.២ ដំណើរការប្រកបដោយប្រសិទ្ធភាពនៃការប្រើប្រាស់មូលនិធិបន្សាំ និងការទទួលបានជាសាធារណៈ.................................................................................................................. ១៣៩
២.៣ ដំណើរការផែនការបន្សាំកម្រិតមូលដ្ឋាន និងការចូលរួមពីសហគមន៍ងាយរងគ្រោះ.... ១៤០
៣. ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ..................................................................១៤១
៣.១ គោលនយោបាយនៃការប្រែប្រួលអាកាសធាតុ និង ផែនការយុទ្ធសាស្ត្រ .................១៤១

៣.២ ការវិភាគស្ថានភាពផលិតកម្មដំណាំ ការចិញ្ចឹមសត្វ ការនេសាទ និងព្រៃឈើនៅ កម្ពុជា ........................................................................................................ ១៤១
៣.៣ អាណត្តិ បេសកកម្ម និងការទទួលខុសត្រូវ ........................................ ១៤៤
៣.៤ បទដ្ឋានគតិយុត្ត និងគោលនយោបាយ ........................................ ១៤៥
៣.៥ យុទ្ធសាស្ត្រ និងផនការ ........................................ ១៤៥
៣.៦ ការរៀបចំស្ថាប័ន ........................................ ១៤៨
៣.៧ នីតិវិធីសម្រាប់ការប្រែប្រួលអាកាសធាតុ ........................................ ១៤៨
៣.៨ ជំនាញ និងសមត្ថភាពផ្សេងៗ ........................................ ១៤៨
៣.៩ ការបញ្ជ្រាបការប្រែប្រួលអាកាសធាតុ ........................................ ១៤៩

**ជំពូកទី ៣ ការរៀបចំក្របខណ្ឌស្ថាប័នពាក់ព័ន្ធ**

មេរៀនទី ១ ការរៀបចំក្របខណ្ឌស្ថាប័ននៃការប្រែប្រួលអាកាសធាតុ ........................................ ១៥២
មេរៀនទី ២ ស្ថាប័នបង្គោលថ្នាក់ជាតិ ........................................ ១៥៦
១. ការរៀបចំនិងការប្រព្រឹត្តទៅន អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព ........................................ ១៥៦
១.១ បទប្បញ្ញត្តិទូទៅ ........................................ ១៥៦
១.២ តួនាទីនិងភារកិច្ច ........................................ ១៥៦
១.៣ រចនាសម្ព័ន្ធ ........................................ ១៥៧
១.៤ តួនាទីនិងភារកិច្ចរបស់នាយកដ្ឋាននីមួយៗ ........................................ ១៥៨
១.៥ អវសានប្បញ្ញត្តិ ........................................ ១៦៣
២. ការរៀបចំ និងការប្រព្រឹត្តទៅរបស់នាយកដ្ឋានប្រែប្រួលអាកាសធាតុ នៃអគ្គលេខាធិការដ្ឋាន ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព ........................................ ១៦៤
៣. ការបង្កើតក្រុមការងារបច្ចេកទេសបប្រួលអាកាសធាតុ ........................................ ១៧០
មេរៀនទី ៣ គ្រឹះស្ថានអប់រំ និងស្រាវជ្រាវ និងវិស័យឯកជន ........................................ ១៧៤
មេរៀនទី ៤ អង្គការក្រៅរដ្ឋាភិបាល និងសង្គមស៊ីវិល ........................................ ១៨៨
១. កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ ........................................ ១៨៨
២. ធនាគារពិភពលោក - មូលនិធិសាកលសម្រាប់កាត់បន្ថយគ្រោះមហន្តរាយ ........................................ ១៨៨
៣. ជំនួយអភិវឌ្ឍន៍អន្តរជាតិប្រទេសដានីម៉ាក (DANIDA) ........................................ ១៨៨
៤. សហព័ន្ធអន្តរជាតិកាកបាទក្រហម និងសង្គមអឌ្ឍចន្ទក្រហមអន្តរជាតិ ........................................ ១៨៨
៥. ភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិប្រទេសស៊ុយអែដ (SIDA) ........................................ ១៨៩

៦. អង្គការ GROUPE ENERGIES RENOUVELABLES, ENVIRONEMENTET SOLIDARITÉS ( GERES ) CAMBODIA ........ ១៩០
៧. អង្គការ PLAN - កម្ពុជា ........ ១៩០
៨. អង្គការអុកស្វាមសហរដ្ឋអាមេរិក ........ ១៩០
៩. កម្មវិធីសកម្មភាពជាតិដើម្បីបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ ........ ១៩០

## ជំពូកទី ៤ ហិរញ្ញប្បទានការប្រែប្រួលអាកាសធាតុ

មេរៀនទី ១ ស្ថានភាពមូលនិធិបន្សាំការប្រែប្រួលអាកាធាតុនៅក្នុងប្រទេសកម្ពុជា ........ ១៩៣
១. ហិរញ្ញប្បទានអាកាសធាតុក្នុងប្រទេសកម្ពុជា ........ ១៩៣
២. ប្រភពមូលនិធិ ........ ១៩៤
៣. គម្រោងបន្សាំ និងគម្រោងកាត់បន្ថយ ........ ១៩៤
៤. ការបន្សាំនឹងការប្រែប្រួលអាកាសធាតុតាមវិស័យ ........ ១៩៦
៥. គម្រោងមូលនិធិបន្សាំនៅក្នុងប្រទេសកម្ពុជា ........ ១៩៨
៦. ទំនាក់ទំនងជាមួយនឹងផែនការជាតិបន្សាំ ........ ១៩៩
៦.១ ភាពបន្សាំគ្នាទៅនឹងកម្រិតជាតិ ........ ២០០
៦.២ ភាពបន្សាំគ្នាទៅនឹងផែនការសកម្មភាព និងផែនការយុទ្ធសាស្ត្រការប្រែប្រួលអាកាសធាតុ ........ ២០០
៦.៣ ទំនាក់ទំនងរវាង CCAPs និង INDCs ........ ២០១
៧. បរិយាកាសអំណោយផលផ្នែកការគាំទ្របរិស្ថាន និងរដ្ឋាភិបាលសម្រាប់ដំណើរការបន្សាំជាតិ ........ ២០៥
៧.១ កង្វះចន្លោះនៃការរៀបចំ NAP នៅកម្ពុជា ........ ២០៨
៧.២ ការកៀងគរធនធានសម្រាប់សកម្មភាពបន្សាំ ........ ២០៨
មេរៀនទី ២ ទិដ្ឋភាពទូទៅនៃមូលនិធិការប្រែប្រួលអាកាសធាតុ ........ ២១០
១. មូលនិធិការប្រែប្រួលអាកាសធាតុសកល ........ ២១០
២. មូលនិធិវិនិយោគលើការប្រែប្រួលអាកាសធាតុ ( CIF ) ........ ២១១
៣. មូលនិធិបន្សាំ ........ ២១២
៤. សម្ព័ន្ធការប្រែប្រួលអាកាសធាតុសកល ( GCCA ) ........ ២១៣
៥. មូលនិធិអាកាសធាតុបៃតង ( GCF ) ........ ២១៣
៦. យន្តការហិរញ្ញប្បទានអាកាសធាតុ ........ ២១៥
៦.១ ស្ថាបត្យកម្មនៃហិរញ្ញប្បទានអាកាសធាតុសាកល ........ ២១៥
៧. មូលនិធិការប្រែប្រួលអាកាសធាតុសម្រាប់សកម្មភាពបន្សាំនៅលើពិភពលោក ........ ២១៧

៨. មូលនិធិការប្រែប្រួលអាកាសធាតុសម្រាប់សកម្មភាពកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់ក្នុងពិភពលោក ........................................................................................................ ២២០
មេរៀនទី ៣ ក្របខណ្ឌហិរញ្ញប្បទានការប្រែប្រួលអាកាសធាតុ ........................................ ២២៤
១. ផលប៉ះពាល់សេដ្ឋកិច្ច សង្គម ពីការប្រែប្រួលអាកាសធាតុដែលបានប៉ាន់ស្មាននៅក្នុងប្រទេសកម្ពុជា ........................................................................................................ ២២៤
១.១ ផលប៉ះពាល់នៅថ្នាក់ជាតិ ........................................................................ ២២៤
១.២ ផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុមកលើការវិនិយោគជាក់លាក់ ................. ២២៦
២. វិធានការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុនៅកម្ពុជា៖ កម្រិតបច្ចុប្បន្ននៃការចំណាយទាក់ទងនឹងអាកាសធាតុ និងវិធានការស្នើឡើងសម្រាប់ប្រាំឆ្នាំខាងមុខ .......................... ២២៨
២.១ ស្ថានភាពបច្ចុប្បន្ននៃការចំណាយលើគម្រោងអាកាសធាតុ ................................ ២២៨
២.២ ស្ថានភាព និងថ្លៃចំណាយលើវិធានការដែលស្នើសម្រាប់រយៈពេលប្រាំឆ្នាំខាងមុខ ..... ២៣០
៣. ការណែនាំដើម្បីបង្កើតក្របខ័ណ្ឌហិរញ្ញប្បទានបប្រួលអាកាសធាតុដែលមាន តម្លាភាព អាចទុកចិត្តបាន និងមានភាពទាក់ទាញ .................................................................. ២៣៤
៣.១ អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព ................................ ២៣៦
៣.២ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ .................................................................. ២៣៧
៣.៣ ក្រសួងផែនការ ......................................................................................... ២៣៨
៣.៤ ក្រសួង និងស្ថាប័នពាក់ព័ន្ធនៅក្នុងវិធានការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ ... ២៣៨
៣.៥ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា/គណៈកម្មាធិការស្តារនិងអភិវឌ្ឍន៍កម្ពុជា (CDC/CRDB) ២៣៩
៣.៦ លេខាធិការដ្ឋានគណៈកម្មាធិការជាតិ សម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ និងរដ្ឋបាលក្រោមជាតិ ........................................................................ ២៣៩
៣.៧ ដៃគូអភិវឌ្ឍន៍ .......................................................................................... ២៤០
មេរៀនទី ៤ ការគ្រប់គ្រងហិរញ្ញប្បទានអាកាសធាតុ ................................................. ២៤២
១. កម្មវិធីហិរញ្ញប្បទានអាកាសធាតុថ្នាក់ជាតិ ..................................................... ២៤២
១.១ ការបង្កើតក្របខ័ណ្ឌហិរញ្ញប្បទានប្រែប្រួលអាកាសធាតុ ...................................... ២៤២
១.២ ការបង្កើតក្របខ័ណ្ឌពិនិត្យ តាមដាន និងវាយតម្លៃ .............................................. ២៤២
១.៣ ការបង្កើតក្របខ័ណ្ឌច្បាប់ស្តីពីការប្រែប្រួលអាកាសធាតុ ...................................... ២៤២
១.៣.១ ការបង្កើតកម្មវិធី និងការកសាងផែនការសកម្មភាព .......................................... ២៤២
២. ការផ្តល់ធនធានហិរញ្ញវត្ថុ និងមូលនិធិអាកាសធាតុថ្នាក់ជាតិ .................................. ២៤៥
២.១ គោលការណ៍នានា ........................................................................................ ២៤៥
២.២ វិធីសាស្ត្រ .................................................................................................. ២៤៦

២.៣ ការគ្រប់គ្រង និងរចនាសម្ព័ន្ធស្ថាប័នសម្រាប់ការអនុវត្ត ........................................ ២៤៧
៣. ការតាមដាន និងវាយតម្លៃ ........................................................................................ ២៤៨
៣.១ គោលការណ៍នានា ................................................................................................. ២៤៩
៣.២. វិធីសាស្ត្រ ............................................................................................................ ២៥០
៣.៣ ការគ្រប់គ្រង និងរចនាសម្ព័ន្ធស្ថាប័នសម្រាប់ការអនុវត្ត ........................................ ២៥១
បណ្ណាល័យសាស្ត្រ

# ជំពូកទី ១ សេចក្តីផ្តើមអំពីក្របខណ្ឌច្បាប់នៃការប្រែប្រួលអាកាស


មេរៀនទី ១ បច្ចុប្បន្នភាពក្របខណ្ឌច្បាប់នៃការប្រែប្រួលអាកាសធាតុនៅកម្ពុជា

មេរៀនទី ២ កម្ពុជា និងអនុសញ្ញាក្របខណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ

មេរៀនទី ៣ ពិធីសារក្យូតូ

មេរៀនទី ៤ កិច្ចព្រមព្រៀងទីក្រុងប៉ារីស

មេរៀនទី ៥ អនុសញ្ញាក្របខណ្ឌពាក់ព័ន្ធផ្សេងៗ

# មេរៀនទី ១ បច្ចុប្បន្នភាពក្របខណ្ឌច្បាប់នៃការប្រែប្រួលអាកាសធាតុនៅកម្ពុជា

អនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ (United Nations Framework Convention on Climate Change; UNFCCC) គឺជាកិច្ចព្រមព្រៀងអន្តរជាតិដំបូង ទទួលស្គាល់ និងដែលបង្កើតឡើងដើម្បីដោះស្រាយបញ្ហានៃការប្រែប្រួលអាកាសធាតុ ដែលមនុស្សជាអ្នកបង្កឡើង។ អនុសញ្ញា នេះចូលជាធរមាននៅថ្ងៃទី ២១ ខែ មីនា ឆ្នាំ១៩៩៤។ ប្រទេសចំនួន ១៩៥ ដែលបានផ្តល់សច្ចាប័នដល់ អនុសញ្ញានេះហៅរដ្ឋភាគី។ កម្ពុជាផ្តល់សច្ចាប័នដល់អនុសញ្ញានេះនៅឆ្នាំ១៩៩៥ និងអនុសញ្ញានេះចូល ជាធរមាននៅកម្ពុជានៅឆ្នាំ ១៩៩៦។

ដោយមើលឃើញថាការប្រែប្រួលអាកាសធាតុគឺជាបញ្ហារួមមួយរបស់មនុស្សជាតិ អនុសញ្ញានេះ (UNFCCC) បានបង្កើតក្របខណ្ឌច្បាប់សម្រាប់ប្រទេសជាសមាជិកដើម្បីដោះស្រាយបញ្ហានៃការប្រែប្រួល អាកាសធាតុ នេះ។ ដោយយោងទៅលើសន្ធិសញ្ញានេះ មានលក្ខខណ្ឌសំខាន់ចំនួនបីសម្រាប់ភាគីជាសមាជិក៖

១. ប្រមូល និងចែករំលែកព័ត៌មានទាក់ទងនឹងការបំភាយឧស្ម័នផ្ទះកញ្ចក់ (greerhouse gas emissions) គោលនយោបាយជាតិ និងគំរូអនុវត្តន៍ល្អៗ។

២. ដាក់ចេញនូវយុទ្ធសាស្ត្រជាតិសម្រាប់ឆ្លើយតបនឹងការបំភាយឧស្ម័នផ្ទះកញ្ចក់ (greenhouse gas emissiors) និងការការបន្សាំទៅនឹងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុដែលអាចកើតមាន។

៣. សហការរៀបចំកម្មវិធីការបន្សាំនឹងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ

ជាងនេះទៅទៀត UNFCCC បានជំរុញឱ្យបណ្តាប្រទេសអភិវឌ្ឍន៍ជួយឧបត្ថម្ភគាំទ្រផ្នែកហិរញ្ញវត្ថុ បច្ចេកទេស និងការកសាងសមត្ថភាពដល់ប្រទេសកំពុងអភិវឌ្ឍន៍ដើម្បីឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ។

គោលបំណងដ៏សំខាន់របស់ UNFCCC គឺការរក្សាឱ្យបាននូវស្ថេរភាពកំហាប់ឧស្ម័នផ្ទះកញ្ចក់ (greenhouse gas concentrations) ក្នុងកម្រិតមួយដែលនឹងការពារកុំឱ្យមានការប៉ះពាល់កាន់តែច្រើនទៀតទៅលើអាកាសធាតុតាមរយៈសកម្មភាពរបស់មនុស្ស។ ទោះជាយ៉ាងនេះក្តី UNFCCC ពុំមានកំណត់គោលដៅ នៃការកាត់បន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់សម្រាប់រដ្ឋភាគីទេ។ ដើម្បីសម្រេចគោលដៅដ៏សំខាន់របស់ UNFCCC ពិធីសារក្យូតូ (Kyoto Protocol) ត្រូវបានអនុម័តនៅប្រទេសជប៉ុន ថ្ងៃទី ១១ ខែធ្នូ ឆ្នាំ១៩៩៧ និងចូលជាធរមាន ថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០០៥។ កម្ពុជាផ្តល់សច្ចាប័នដល់ពិធីសារក្យូតូនេះ

នៅឆ្នាំ២០០២ ដែលចូលជាធរមាននៅឆ្នាំ២០០៥។ ពិធីសារខ្យូតូនេះ តម្រូវឱ្យប្រទេសអភិវឌ្ឍន៍ កាត់បន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់។ ពិធីសារនេះ ក៏តម្រូវឱ្យបង្កើតមូលនិធិការបន្សាំ ដែលនឹងជួយឧបត្ថម្ភគាំទ្រថវិកាគម្រោងកម្មវិធីបន្សាំនឹងការប្រែប្រួលអាកាសធាតុរបស់ប្រទេសកំពុងអភិវឌ្ឍន៍ ដែលជារដ្ឋភាគីរបស់ពិធីសារខ្យូតូ ដើម្បីឱ្យរដ្ឋភាគីដែលជាប្រទេសកំពុងអភិវឌ្ឍន៍ទាំងនោះ អាចការបន្សាំទៅនឹងការប្រែប្រួល អាកាសធាតុ។

## ១. សន្និសីទអង្គការសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ

សន្និសីទអង្គការសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុឆ្នាំ ២០១៥ ឬសម័យប្រជុំលើកទី២១ សន្និសីទរដ្ឋភាគីរបស់អនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ (United Nations Framework Convention on Climate Change: COP21(CMP11) ឬអាចហៅបានថា ប៉ារីស៍ ឆ្នាំ២០១៥ នឹងប្រារព្ធឡើងនៅ ទីក្រុងប៉ារីស ប្រទេសបារាំង ចាប់ពីថ្ងៃទី៣០ ខែ វិច្ឆិកា រហូតដល់ ថ្ងៃទី១១ ខែធ្នូ ឆ្នាំ ២០១៥។ ប៉ារីសឆ្នាំ២០១៥ មានគោលដៅឈានទៅរកកិច្ចព្រមព្រៀងអន្តរជាតិថ្មីមួយស្តីពីការប្រែប្រួលអាកាសធាតុ ដែលនឹងអនុវត្តដោយគ្រប់រដ្ឋភាគី និងចូលជាធរមានចាប់ពីឆ្នាំ២០២០។ កិច្ចព្រមព្រៀងអន្តរជាតិថ្មីស្តីពីការប្រែប្រួលអាកាសធាតុនេះ ដែលនឹងជំនួសពិធីសារខ្យូតូនឹងផុតកំណត់នៅឆ្នាំ២០២០ មានគោលដៅការរក្សាការកើនកម្តៅពិភពលោកឱ្យស្ថិតនៅក្រោម២អង្សាសេ។

### កិច្ចព្រមព្រៀងអន្តរជាតិស្តីពីការប្រែប្រួលអាកាសធាតុ ឆ្នាំ ២០១៥

សេចក្តីព្រាងនៃកិច្ចព្រមព្រៀងដែលរៀបចំឡើងសម្រាប់កិច្ចចរចារ មានវិធានការសំខាន់ៗចំនួនបី៖ (១) វិធាន ការកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់ (២)វិធានការការបន្សាំ និង (៣)វិធានការគាំទ្រ។ ទីមួយ វិធានការកាត់ បន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់ក្នុងរយៈពេលវែង មានគោលបំណងកាត់បន្ថយការបំភាយឧស្ម័នផ្ទះ កញ្ចក់ដើម្បីទប់ការកើនឡើងកម្តៅផែនដីឱ្យស្ថិតនៅក្រោម២អង្សាសេ ដូចដែលបានបញ្ជាក់នៅក្នុងមាត្រា២ នៃអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ (United Nations Framework Convention on Climate Change)។ ទីពីរ វិធានការការបន្សាំក្នុងរយៈពេលវែងកាត់បន្ថយភាពងាយរងគ្រោះទៅនឹងផលប៉ះពាល់ ដែលបណ្តាលមកពីការប្រែប្រួលអាកាសធាតុ និងជួយសហគមន៍ដែលប្រឈមនឹងផលប៉ះពាល់។ ទីបី កញ្ចប់កាគាំទ្ររួមមាន ហិរញ្ញវត្ថុ ការបង្កើនសមត្ថភាព និង ការអភិវឌ្ឍន៍ និងការផ្ទេរបច្ចេកវិទ្យាទៅប្រទេសកំពុងអភិវឌ្ឍន៍ ដើម្បីជួយឱ្យពួកគេអាចសម្រេចគោលដៅ កាត់បន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់ និងបន្សាំរយៈពេលវែង។ វិធានការកាត់បន្ថយបំភាយឧស្ម័នផ្ទះ កញ្ចក់ និងការបន្សាំនឹងអនុវត្តដោយផ្អែកទៅលើគោលការណ៍ ការទទួលខុសត្រូវរួមគ្នាតែមានតួនាទីផ្សេងគ្នា និងទៅតាមស្ថានភាពរបស់រដ្ឋភាគីនីមួយៗ។

មានសន្និសីទអង្គការសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ ចំនួន៤ គឺ នៅទីក្រុងឌឺបិន (Durban) ឆ្នាំ២០១១ ដូហា (Doha) ឆ្នាំ២០១២ វ៉ស (Warsaw) ឆ្នាំ២០១៣ និងលីម៉ា (Lima) ឆ្នាំ ២០១៤ ដែល ពាក់ព័ន្ធនឹងដំណើរការរៀបចំឱ្យមានកិច្ចព្រមព្រៀងអន្តរជាតិថ្មីនេះ។ សន្និសីទអង្គការសហប្រជាជាតិស្តីពី ការប្រែប្រួលអាកាសធាតុឆ្នាំ២០១៥ រំពឹងថានឹងឈានទៅរកកិច្ចព្រមព្រៀងអន្តរជាតិថ្មី ស្តីពីការប្រែប្រួល អាកាសធាតុនេះ។

**បញ្ហាដែលទាក់ទិននឹងអត្ថប្រយោជន៍របស់កម្ពុជា**

ផ្នែកខាងក្រោមនេះ ជាបញ្ហាដែលកម្ពុជាគួរចាប់អារម្មណ៍ ដែលត្រូវបានពិភាក្សានៅក្នុងកិច្ចចរចារ នៅសន្និសីទអង្គការសហប្រជាជាតិពីការប្រែប្រួលអាកាសអាកាសធាតុឆ្នាំ២០១៤ នៅទីក្រុងលីម៉ា៖

## ១.១ ផែនការការចូលរួមចំណែកដែលកំណត់ដោយរដ្ឋភាគី

ការកំណត់គោលដៅ និងភាពជោគជ័យ នៃកិច្ចព្រមព្រៀងថ្មីនេះ គឺពឹងផ្អែកមួយផ្នែកធំលើ ផែនការការចូល រួមចំណែកដែលបានកំណត់ដោយរដ្ឋភាគី (INDCs)។ ត្រឹមថ្ងៃទី៣១ ខែមិនា ឆ្នាំ ២០១៥ រដ្ឋភាគីទាំង អស់ត្រូវផ្ញើផែនការការចូលរួមចំណែកដែលកំណត់ដោយរដ្ឋភាគី (INDCs) ដែលបង្ហាញអំពីការសន្យា កាត់បន្ថយឧស្ម័នផ្ទះកញ្ចក់នៅឆ្នាំ ២០២៥ ដើម្បីរួមចំណែកក្នុងការសម្រេចគោលបំណង នៃអនុសញ្ញា ក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ (UNFCCC)។

នៅសន្និសីទនៅទីក្រុងលីម៉ា គេពុំអាចឈានទៅរកការព្រមព្រៀងគ្នាថាតើផែនការការចូលរួមចំណែកដែល កំណត់ដោយរដ្ឋភាគី (INDCs) គួរតែនិយាយផ្តោតជាសំខាន់តែលើវិធានកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់ ឬក៏ ទៅលើវិធានការបន្សាំ និងការសន្យារបស់ប្រទេសអភិវឌ្ឍន៍ចំពោះការផ្តល់ជំនួយហិរញ្ញវត្ថុ និងបច្ចេកទេស មកដល់ប្រទេសកំពុងអភិវឌ្ឍន៍។

មកដល់ពេលនេះ មានប្រទេសចំនួន ១១៩ ដែលបានដាក់ជូន អង្គការសហប្រជាជាតិ នូវផែនការការចូលរួមចំណែកដែលកំណត់ដោយរដ្ឋភាគី (INDCs)។ បន្ទាប់ពីពិនិត្យផែនការនេះ (INDCs) ពីប្រទេសអភិវឌ្ឍន៍ ពុំមានការសន្យារបស់ប្រទេសអភិវឌ្ឍន៍លើការផ្តល់ជំនួយហិរញ្ញវត្ថុ និងបច្ចេកទេសមកកាន់ ប្រទេសកំពុងអភិវឌ្ឍន៍ឡើយ។

ប្រទេសកម្ពុជាបានផ្ញើផែនការការចូលរួមចំណែកដែលកំណត់ដោយរដ្ឋភាគី (INDC) នៅខែ កញ្ញា ឆ្នាំ ២០១៥។ បើផ្អែកទៅលើ INDC របស់កម្ពុជា ប្រទេសកម្ពុជា មានវិធានការកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់ ២៧% នៅឆ្នាំ ២០៣០ នឹង ពង្រីកគម្របព្រៃឈើឱ្យបាន ៦០%។ ទាក់ទងនឹងវិធានការបន្សាំវិញ ប្រទេស

កម្ពុជានឹងកាត់បន្ថយភាពងាយរងគ្រោះទៅនឹងការប្រែប្រួលអាកាសធាតុ តាមរយៈការពង្រឹងសមត្ថភាពការបន្សាំរបស់សហគមន៍កែលម្អប្រព័ន្ធផ្តល់ព្រមានជាមុន កែលម្អរហេដ្ឋារចនាសម្ព័ន្ធកសិកម្ម អនុវត្តបច្ចេកទេសកសិកម្មដែលធន់នឹងការប្រែប្រួលអាកាសធាតុ អនុវត្តកម្មវិធីដែលកាត់បន្ថយការប្រឈមនឹង ជម្ងឺផ្សេងៗដែលបណ្តាលពីការប្រែប្រួលអាកាសធាតុ នឹងបង្កើនសមត្ថភាពបច្ចេកទេស និងស្ថាប័នដែល ពាក់ព័ន្ធនឹងបញ្ហាការប្រែប្រួលអាកាសធាតុ។

## ១.២ ភាពខុសគ្នា

ប្រទេសកំពុងអភិវឌ្ឍន៍ភាគច្រើនជម្រុញឱ្យមានការបែងចែកតួនាទីឱ្យច្បាស់លាស់ រវាងប្រទេសអភិវឌ្ឍន៍ និង ប្រទេសកំពុងអភិវឌ្ឍន៍ ក្នុងយុទ្ធនាការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ (ឧ. គួរឱ្យមានការបែង ចែកឱ្យច្បាស់អំពីតួនាទីរវាងប្រទេសអភិវឌ្ឍន៍ និងប្រទេសកំពុងអភិវឌ្ឍន៍ក្នុងការដោះស្រាយការប្រែប្រួល អាកាសធាតុ)។ ក៏ប៉ុន្តែប្រទេសអភិវឌ្ឍន៍បានបដិសេធគោលជំហនេះ។ ប្រទេសចិន និងសហរដ្ឋអាមេរិច បានចេញសេចក្តីថ្លែងការណ៍ ដែលមានលក្ខណៈសម្របសម្រួលមួយ ដែលផ្តល់ពាក្យពេចន៍មួយចំនួន ដែលប្រទេសអភិវឌ្ឍន៍ និងប្រទេសកំពុងអភិវឌ្ឍន៍យកមកប្រើប្រាស់ដើម្បីសម្របសម្រួលគ្នា។ ពាក្យពេចន៍ ទាំងនោះដកស្រង់ចេញពីគោលការណ៍របស់ UNFCCC ពោលគឺគោលការណ៍ «ការទទួលខុសត្រូវរួមគ្នា តែមានតួនាទីផ្សេងគ្នា (Common but differentiated responsibilities) ទៅតាមសមត្ថភាព (respective capabilities) និងគោលការណ៍ ទៅតាមស្ថានភាពរបស់រដ្ឋភាគីនីមួយៗ» (in light of difference national circumstances)

## ១.៣ ហិរញ្ញវត្ថុ

មូលនិធិបៃតងសម្រាប់បម្រែបម្រួលអាកាសធាតុ (GCF) ត្រូវបង្កើតឡើងជាយន្តការហិរញ្ញវត្ថុតាមមាត្រា ១១ នៃអនុសញ្ញា (UNFCCC)។ មូលនិធិនេះគាំទ្រគម្រោង កម្មវិធី គោលនយោបាយ និងសកម្មភាពរបស់ប្រទេសកំពុងអភិវឌ្ឍន៍តាមរយៈការផ្តល់ជំនួយឥតសំណង និងប្រាក់កម្ចីបែបសម្បទានមូលនិធិ នេះមានគណនេយ្យភាពចំពោះ និងប្រតិបត្តការក្រោមការតម្រង់ទិសរបស់ (COP)។ ១០២ កោដិដុល្លារ អាមេរិកត្រូវបានសន្យានៅឆ្នាំ២០១៤។ នៅក្នុងក្របខ័ណ្ឌអនុសញ្ញា (UNFCCC) ប្រទេសអភិវឌ្ឍន៍បាន បានសន្យាជាផ្លូវការថានឹងផ្តល់ប្រាក់មូលនិធិឱ្យបាន ១០០កោដ ក្នុង១ឆ្នាំ ចាប់ពីឆ្នាំ ២០២០។ មូលនិធិ បៃតងនេះនឹងផ្តោតទៅលើទាំង វិធានការកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់ និងវិធានការការបន្សាំ និងធានាថាប្រទេសដែលប្រើប្រាស់មូលនិធិ ជាប្រទេសដៃគូ និងមានភាពជាម្ចាស់លើសកម្មភាព ឬគម្រោងដែល ទទួលការគាំទ្រថវិកាពីមូលនិធិបៃតងនេះ។

មូលនិធិបៃតងនេះជាយន្តការហិរញ្ញវត្ថុថ្មីចុងក្រោយ ដែលរំពឹងថានឹងផ្តល់ជំនួយ ឬកម្ចី នៅឆ្នាំ២០១៥។ មូលនិធិបៃតងនេះ ក៏ជាយន្តការហិរញ្ញវត្ថុ ដែលបំពេញបន្ថែមទៅលើយន្តការហិរញ្ញវត្ថុដែលមានស្រាប់នៅក្រោម UNFCCC ដែលមិនបានបំពេញតម្រូវការគ្រប់គ្រាន់នៅឡើយ។ យន្តការហិរញ្ញវត្ថុបច្ចុប្បន្ន រួមមាន៖ (១) ហិរញ្ញវត្ថុជាសាកល (២) មូលនិធិការប្រែប្រួលអាកាសធាតុពិសេស (៣) មូលនិធិសម្រាប់ ប្រទេសមានការអភិវឌ្ឍន៍តិចតួច និង (៤) មូលនិធិការបន្សាំ។

នៅសន្និសីទឆ្នាំ ២០១៤ (COP២០) នៅទីក្រុងលីម៉ា ប្រទេសចិនបានបដិសេធការធ្វើវិភាគទានទៅឱ្យ មូលនិធិបៃតងសម្រាប់ការប្រែប្រួលអាកាសធាតុនេះ និងមានគម្រោងបង្កើតមូលនិធិសហប្រតិបត្តិការត្បូង-ត្បូង សម្រាប់ការប្រែប្រួលអាកាសធាតុ (Climate Change South-South Cooperation Fund) និងធ្វើការជាមួយប្រទេសកំពុងអភិវឌ្ឍន៍ ប្រទេសចិនក៏បានសន្យាថានឹងបង្កើនថវិកាទ្វេរដងសម្រាប់ គម្រោងបង្កើតមូលនិធិសហប្រតិបត្តិការត្បូង-ត្បូងនេះ។

### ១.៤ ការបាត់បង់ និងការខូចខាត

សន្និសីទធាតុអង្គការសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុឆ្នាំ ២០១៣ នៅទីក្រុង Warsaw បាន បើកដំណើរការដើម្បីពិចារណាលើវិធានការ ក្នុងការជួយប្រទេសកំពុងអភិវឌ្ឍន៍ និងងាយរងគ្រោះ(ពីផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុដែលមិនអាចចៀសវាងបាន ទៅលើកិច្ចខិតខំប្រឹងប្រែងទាំងការកាត់ បន្ថយឧស្ម័នផ្ទះកញ្ចក់ និងការការបន្សាំ។ ទោះជាយ៉ាងនេះក្តី ប្រទេសទាំងអស់នេះ ពុំអាចបញ្ចូលបញ្ហាការ បាត់បង់ និងការខូចខាត របស់ខ្លួនទៅក្នុងបញ្ជីបញ្ហាសម្រាប់ពិភាក្សារបស់សន្និសីទទីក្រុងប៉ារីស ឆ្នាំ២០១៥ ឡើយ។

### ១.៥ ជំហរកម្ពុជា (សេចក្តីថ្លែងការនៅ COP20)

កម្ពុជាបានចាត់ទុកបញ្ហាប្រឈមនឹង ការប្រែប្រួលអាកាសធាតុ ជាបញ្ហាសំខាន់នៅក្នុងគោលនយោបាយអភិវឌ្ឍន៍របស់ខ្លួន ដែលមានគោលបំណងកសាងសង្គមដែលធន់នឹងការប្រែប្រួលអាកាសធាតុ បញ្ចេញ កាបូនិចតិច និង គិតគូពីបញ្ហាបរិស្ថាន និង ចូលរួមចំណែកក្នុងយុទ្ធនាការប្រឆាំងនឹងការប្រែប្រួលអាកាសធាតុជាសកល ។ ចំណែកកម្ពុជាទទូចឱ្យកិច្ចព្រមព្រៀងថ្មីនេះនឹងត្រូវបានធ្វើឡើងដោយផ្អែកលើគោលការណ៍របស់ UNFCCC ដែលធានាឱ្យមានការអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាពសម្រាប់ប្រទេសកំពុងអភិវឌ្ឍន៍។ ជាពិសេស ការចូលរួមចំណែក និងកិច្ចខិតខំប្រឹងប្រែងផ្សេងៗរបស់ប្រទេសមានការអភិវឌ្ឍន៍តិច (Least Developed Countries LDC) គួរតែជាការស្ម័គ្រចិត្ត និងមានការគាំទ្រពីប្រទេសអភិវឌ្ឍន៍ទៅលើ ការកសាងសមត្ថភាព ហិរញ្ញវត្ថុ និងការផ្ទេរមកឱ្យនូវបច្ចេកវិទ្យា។ ប្រទេសអភិវឌ្ឍន៍គួរធានាជំនួយហិរញ្ញវត្ថុ បន្ថែមថ្មីទៀត ដែលទៀងទាត់ពេលវេលា និង ងាយនឹងយកមកប្រើប្រាស់។

***សម្គាល់៖*** *ធនាគារពិភពលោកបានដាក់កម្ពុជាក្នុងបញ្ជីប្រទេសមានប្រាក់ចំណូលទាប និងចាត់ជាប្រទេសមួយក្នុងចំណោមប្រទេសជាច្រើន ដែលងាយទទួលរងផលប៉ះពាល់បំផុតពីការប្រែប្រួលអាកាសធាតុ ។*

### ១.៦ ជំហររបស់អាស៊ានស្តីពីការគាំទ្ររបស់ប្រទេសអភិវឌ្ឍន៍

ទាក់ទងនឹងការគាំទ្រពីប្រទេសអភិវឌ្ឍន៍ អាស៊ានបានជម្រុញ និង លើកទឹកចិត្តឱ្យប្រទេសអភិវឌ្ឍន៍បង្កើនការគាំទ្រលើ ការកសាងសមត្ថភាព បច្ចេកទេស ការផ្ទេរបច្ចេកវិទ្យា និងហិរញ្ញប្បទានទៅឱ្យប្រទេសអភិវឌ្ឍន៍តិចបំផុត និងប្រទេសកំពុងអភិវឌ្ឍន៍ ដើម្បីសម្រេចឱ្យបានគោលបំណងនៃការកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់ និងការការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ។ បន្ថែមលើនេះទៀត ការព្រមព្រៀងគ្នា និងការដាក់ ឱ្យដំណើរការ ការគាំទ្រដែលសន្យាដោយប្រទេសអភិវឌ្ឍន៍ គឺជាការងារបន្ទាន់ សម្រាប់ប្រទេសមានការអភិវឌ្ឍន៍តិចបំផុត។

### ១.៧ គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ឬ របៀបវារៈឆ្នាំ ២០៣០

នៅថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០១៥ មហាសន្និបាតអង្គការសហប្រជាជាតិដែលមានប្រទេស ១៩៣ ចូល រួម បានអនុម័តលើគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ឬ របៀបវារៈឆ្នាំ ២០៣០ នៅឯជំនួបកំពូលអង្គការសហប្រជាជាតិស្តីពីអភិវឌ្ឍន៍ប្រកបដោយចីរភាព។ របៀបវារៈឆ្នាំ ២០៣០ រៀបរៀងដោយក្រុមការងារពិគ្រោះយោបល់របស់អង្គការសហប្រជាជាតិ ដោយមានការពិគ្រោះយោបល់ជាមួយរដ្ឋជាសមាជិក និងមានគោលដៅបំបាត់ភាពក្រីក្រនៃគ្រប់រូបភាពទាំងអស់។

របៀបវារៈឆ្នាំ ២០៣០ ក៏នឹងដោះស្រាយបញ្ហាការប្រែប្រួលអាកាសធាតុផងដែរ។ គោលដៅទី១៣ នៃ របៀបវារៈឆ្នាំ ២០៣០ គឺចាត់វិធានការបន្ទាន់ដើម្បីឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ នឹងផលប៉ះពាល់ ដែលបណ្តាលមកពីការប្រែប្រួលអាកាសធាតុ។ គោលដៅទី ១៣ រំពឹងថានឹងបំពេញបន្ថែមដល់កិច្ចព្រម ព្រៀងស្តីពីការប្រែប្រួលអាកាសធាតុ ដែលរដ្ឋភាគីនិងអនុម័តនៅប៉ារីសនៅចុងឆ្នាំ ២០១៥ នេះ។ គោលដៅទី ១៣ ដកចេញសកម្មភាពនានាដូចខាងក្រោមនេះ៖

- ជាការពង្រឹងភាពធន់ និងសមត្ថភាពការបន្សាំទៅនឹងមុខសញ្ញាគ្រោះថ្នាក់ និងគ្រោះមហន្តរាយដែលបណ្តាលមកពីការប្រែប្រួលអាកាសធាតុនៅគ្រប់ប្រទេស។
- បញ្ចូលវិធានការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុទៅក្នុងគោលនយោបាយ យុទ្ធសាស្ត្រ និងការរៀបចំផែនការថ្នាក់ជាតិ។
- លើកកម្ពស់សកម្មភាពអប់រំ ការយល់ដឹង សមត្ថភាពមនុស្ស និងស្ថាប័នលើវិធានការកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់ វិធានការការបន្សាំ ការកាត់បន្ថយការប៉ះពាល់ និងប្រព័ន្ធផ្តល់ព្រមានជាមុន។

ក្រៅពីគោលដៅទី ១៣ របៀបវារៈឆ្នាំ ២០៣០ ក៏មានវិធានការផ្សេងទៀត ដែលឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ។ វិធានការទាំងនោះរួមមាន៖

- លើកកម្ពស់ភាពធន់នៃអ្នកក្រីក្រទៅនឹងការប្រែប្រួលអាកាសធាតុ (ចំណុចដៅ ១.៥) នៃគោលដៅ ១៖ បំបាត់ភាពក្រីក្រនៃគ្រប់រូបភាពទាំងអស់)។
- អនុវត្តបច្ចេកទេសកសិកម្មដែលធននឹងការប្រែប្រួលអាកាសធាតុ និង កសាងសមត្ថភាពការបន្សាំ (ចំណុចដៅ ២៤ នៃ គោលដៅ ២៖ លុបបំបាត់ភាពស្រេកឃ្លាន សម្រេចឱ្យបានសន្តិសុខស្បៀង និង អាហាររូបត្ថម្ភប្រសើរឡើង និងលើកកម្ពស់កសិកម្មដែលមាននិរន្តរភាព)។
- ធនាឱ្យបាននូវលទ្ធភាពទទួលបានទឹកស្អាតសម្រាប់មនុស្សគ្រប់រូប និងដោយស្មើរភាពគ្នា(ចំណុចដៅ ៦.១) នៃ គោលដៅ ៦៖ ធនាឱ្យបាននូវលទ្ធភាពទទួលបានទឹកស្អាត និងអនាម័យ សម្រាប់មនុស្សគ្រប់រូប)។
- កសាងហេដ្ឋារចនាសម្ព័ន្ធកសិកម្មដែលមានគុណភាព និរន្តរភាព និង ធន់នឹងការប្រែប្រួលអាកាសធាតុ (ចំណុចដៅ ៩.១ នៃគោលដៅ ៩៖ កសាងហេដ្ឋារចនាសម្ព័ន្ធកសិកម្មដែលធន់ នឹង ការប្រែប្រួលអាកាសធាតុ និងលើកកម្ពស់ឧស្សាហូបនីយកម្ម ដែលមាននិរន្តរភាព និង ការឆ្នៃប្រឌិត)។
- បង្កើនចំនួនទីក្រុង និងលំនៅដ្ឋាន ដែលជ្រើសយក និងអនុវត្តគោលនយោបាយ និងផែនការ ដែលឆ្ពោះទៅរកការរួមបញ្ចូល ប្រសិទ្ធភាពនៃការប្រើប្រាស់ធនធានវិធានការកាត់បន្ថយ ឧស្ម័នផ្ទះកញ្ចក់ វិធានការការបន្សាំនឹងការប្រែប្រួលអាកាសធាតុ និងភាពធន់ទៅនឹងគ្រោះមហន្តរាយ(ចំណុចដៅ ១១.៦ នៃ គោលដៅ ១១ ធ្វើឱ្យទីក្រុងមានភាពធន់ មានសុវត្ថិភាព និងមាននិរន្តរភាពសម្រាប់មនុស្សគ្រប់រូប)។
- គ្រប់គ្រង និងការពារប្រព័ន្ធអេកូឡូស៊ីសមុទ្រ និងឆ្នេរសមុទ្រ (ចំណុចដៅ ១៤.២ នៃគោលដៅ ១៤ ៖ អភិរក្ស និងប្រើប្រាស់ មហាសមុទ្រ សមុទ្រ និងធនធនាសមុទ្រដោយមាននិរន្តរភាព)។

## ២. អាស៊ាន និងការប្រែប្រួលអាកាសធាតុ

អាស៊ានបានបង្ហាញពីក្តីបារម្ភណ៍ និងការប្តេជ្ញាចិត្តក្នុងការចូលរួមដោះស្រាយបញ្ហាការប្រែប្រួលអាកាសធាតុ តាមរយៈសេចក្តីប្រកាស និងសេចក្តីថ្លែងការណ៍មួយចំនួននៅក្នុងសន្និសីទអង្គការសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ។ នៅក្នុងសេចក្តីថ្លែងការណ៍ក្នុងកិច្ចប្រជុំកំពូលអាស៊ាន លើកទី១៦ នៅឆ្នាំ២០១០ អាស៊ាន យល់ឃើញថាតំបន់អាស៊ីភាគអាគ្នេយ៍ គឺជាតំបន់ដែលងាយទទួលរង គ្រោះពីការប្រែប្រួលអាកាសធាតុ ហើយសេចក្តីថ្លែងការណ៍នោះដែរក៏បានបញ្ជាក់សារជាថ្មីពីការប្តេជ្ញាចិត្ត ក្នុងការសម្រេចគោលដៅរបស់អនុសញ្ញាស្តីពីការប្រែប្រួលអាកាសធាតុក្នុងក្របខ័ណ្ឌសហប្រជាជាតិ (United Nations Framework Convention on Climate Change)

អាស៊ានមានគោលនយោបាយ និងកម្មវិធីសកម្មភាពរបស់ខ្លួន ទាក់ទងនឹងបញ្ហាការប្រែប្រួលអាកាសធាតុ។ នៅក្នុងឯកសារផែនការសហគមន៍ សង្គមវប្បធម៌របស់អាស៊ាន (ASEAN-Socio-Cultural Community Blueprint) បានបង្ហាញថា អាស៊ានមានគោលដៅពង្រឹងកិច្ចសហប្រតិបត្តិការទាំងថ្នាក់តំបន់ និងថ្នាក់អន្តរជាតិ ដើម្បីដោះស្រាយបញ្ហា និងផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុ តាមរយៈបង្កើតឱ្យមាន សកម្មភាព យុទ្ធសាស្ត្រផ្សេងៗ។ សកម្មភាពយុទ្ធសាស្ត្រគន្លឹះមួយចំនួនដែលបានបញ្ចូល នៅក្នុងផែនការនេះរួមមាន៖

- លើកកម្ពស់ការយល់ដឹងជារួមរបស់បណ្ដាប្រទេសអាស៊ានទៅលើការប្រែប្រួលអាកាសធាតុ
- ជម្រុញការខិតខំប្រឹងប្រែងក្នុងការបង្កើតគំនិតផ្ដួចផ្ដើមទាក់ទងទៅនឹងការប្រែប្រួលអាកាសធាតុ នៅសម្រាប់អាស៊ាន
- ជម្រុញ ផ្សព្វផ្សាយ និងសម្របសម្រួលទៅលើការផ្លាស់ប្ដូរចំណេះដឹង/ព័ត៌មាន ស្ដីពីការអភិវឌ្ឍន៍ និងការស្រាវជ្រាវបែបវិទ្យាសាស្ត្រ (Research & Development; R&D) ការចែករំលែក និងការផ្ទេរ បច្ចេកវិទ្យា និងការអនុវត្តន៍ល្អៗ ពាក់ព័ន្ធនឹងវិធានការណ៍ការការបន្សាំ និងកាត់បន្ថយ ឧស្ម័នផ្ទះកញ្ចក់
- បង្កើតយុទ្ធសាស្ត្រថ្នាក់តំបន់ ដើម្បីពង្រឹងសមត្ថភាពបន្សាំ និងសេដ្ឋកិច្ចដែលបញ្ចេញកាបូនតិច (low carbon ecoromy) និង
- ការជម្រុញយុទ្ធសាស្ត្រ ដើម្បីធានាថាគំនិតផ្ដួចផ្ដើមទាក់ទងនឹងបញ្ហាអាកាសធាតុនេះ នឹងឱ្យសហគមន៍អាស៊ានមានភាពរីកចម្រើនផ្នែកសេដ្ឋកិច្ច ព្រមទាំងមានបរិស្ថានល្អផងដែរ។

ដើម្បីអនុវត្តទៅតាមសេចក្ដីថ្លែងការណ៍នៅកិច្ចប្រជុំកំពូលអាស៊ានលើកទី ១៦ ឆ្នាំ ២០១០ បានអនុម័តផែនការសកម្មភាពអាស៊ានរួមស្ដីពីការប្រែប្រួលអាកាសធាតុ (AAP-JRCC) ឆ្នាំ ២០១២។ ផែនការសកម្មភាពដែលបានបង្កើតឡើង ឆ្នាំ ២០១២ រួមមាន៖ (១) ការការបន្សាំ (២) ការកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់ (៣) ហិរញ្ញវត្ថុ និងប្រើប្រាស់ថវិកា (៤) ការផ្ទេរបច្ចេកវិទ្យា (៥) ការកសាងសមត្ថភាព និង (៦) កិច្ចសហប្រតិបត្តិការតំបន់ផ្សេងៗទៀត។ គួរកត់សម្គាល់ផងដែរថា ផែនការសកម្មភាពរួមស្ដីពីការប្រែប្រួលអាកាសធាតុ (AAP-JRCC) របស់អាស៊ានមិនមានការកំណត់គោលដៅ ដើម្បីឱ្យប្រទេសជាសមាជិកអាស៊ានអនុវត្តទេ ផ្ទុយទៅវិញ AAP-JRCC ផ្ដោតទៅលើការចែករំលែកព័ត៌មាន បទពិសោធន៍ល្អៗ និង ការរៀនសូត្រពីគ្នា។

ក្រុមការងារការប្រែប្រួលអាកាសធាតុអាស៊ាន (ASEAN_Working Group on Climate Change: AWGCC) បានបង្កើតនៅឆ្នាំ ២០០៩ និងមានតួនាទីទទួលខុសត្រូវលើ ផែនការសកម្មភាពអាស៊ានរួម ស្ដីពីការប្រែប្រួលអាកាសធាតុ។ គំនិតផ្ដួចផ្ដើមស្ដីពីការប្រែប្រួលអាកាសធាតុអាស៊ាន

( ASEAN ) Climate Change Initiative: ACCI ) គឺជាវេទិកាប្រឹក្សាយោបល់ ដើម្បីសម្របសម្រួល និងកិច្ចសហការ រវាងអង្គភាពអាស៊ាន តាមវិស័យដែលរងផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុ ដូចជាថាមពល រុក្ខាប្រមាញ់ កសិកម្ម និង គ្រប់គ្រងគ្រោះមហន្តរាយ ដើម្បីជានាឱ្យបាននូវ វិធីសាស្ត្រសម្របសម្រួលដ៏ល្អ ក្នុងការដោះស្រាយបញ្ហាទាក់ទងនឹងការប្រែប្រួលអាកាសធាតុ។

AWGCC បានបង្កើតនៅឆ្នាំ ២០០៩ និងមានតួនាទីទទួលខុសត្រូវលើ ផែនការសកម្មភាពអាស៊ាន រួមដោយមូលហេតុថាការប្រែប្រួលអាកាសធាតុជាបញ្ហាដែលពាក់ព័ន្ធនឹងវិស័យច្រើន មិនត្រឹមតែក្រុមការងារ ការប្រែប្រួលអាកាសធាតុអាស៊ាន (AWGCC) ទេដែលធ្វើការលើបញ្ហាការប្រែប្រួលអាកាសធាតុ មានក្រុមការងារផ្សេងៗទៀតដូចជា បរិស្ថាន កសិកម្ម និង រុក្ខាប្រមាញ់ ថាមពល និងដឹកជញ្ជូន វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា។

ឧទាហរណ៍គម្រោងការប្រែប្រួលអាកាសធាតុអនុវត្តដោយអាស៊ានមានដូចតទៅ៖

- ខ្យល់បរិសុទ្ធក្នុងក្រុងតូចៗរបស់អាស៊ាន
- ការស្តារឡើងវិញ និង ការប្រើប្រាស់ដោយនិរន្តរភាពនូវតំបន់ព្រៃដីល្បាប់នៅតំបន់អាស៊ីអាគ្នេយ៍
- ការគ្រប់គ្រងប្រកបដោយនិរន្តរភាពនូវតំបន់ព្រៃដីល្បាប់នៅអាស៊ីអាគ្នេយ៍
- សកម្មភាពអាស៊ានស្តីពីការបំពុលឆ្លងដែន ដោយផ្សែង ( ឧ ផ្សែងបណ្តាលមកពីភ្លើងឆេះព្រៃ )
- និងកិច្ចសហប្រតិបត្តិការអាស៊ានស្តីពីទីក្រុងដែលមានបរិស្ថានស្អាត និងមាននិរន្តរភាព។

## ៣. សកម្មភាពកម្ពុជាឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ

កម្ពុជាផ្តល់សច្ចាប័ន ដល់អនុសញ្ញា UNFCCC នឹងពិធីសារខ្យូតូ។ ដើម្បីបំពេញតួនាទីជារដ្ឋភាគីរាជរដ្ឋាភិបាលកម្ពុជាបានបំពេញការងារដូចខាងក្រោម៖

- ដាក់ជូនលេខាធិការដ្ឋាននៃ អនុសញ្ញា UNFCCC នូវផែនការទំនាក់ទំនងជាតិដំបូង ( Cambodia's Initial National Communication 2002 ) 0001 នេះជា របាយការណ៍ដែលផ្តល់ព័ត៌មានស្តីពីឧស្ម័នផ្ទះកញ្ចក់( GHG ) និង ជាវិធានការកាត់បន្ថយ និង មធ្យោបាយការបន្ស៊ាំនឹងការប្រែប្រួលអាកាសធាតុ។
- បានអនុម័ត និងដាក់ជូនលេខាធិការដ្ឋានអនុសញ្ញា UNFCCC នូវកម្មវិធីសកម្មភាពការបន្ស៊ាំជាតិ ( National Adaptation Program of Action: NAPA ) ។ តាមរយៈកម្មវិធីនេះ រាជរដ្ឋាភិបាលកម្ពុជា បានបង្ហាញថា កម្ពុជាគឺជាប្រទេសមានការអភិវឌ្ឍន៍តិចបំផុត និងជា ប្រទេសកសិកម្ម ដែលងាយទទួលរងផលប៉ះពាល់ពីកាប្រែប្រួលអាកាសធាតុ។ ក្នុងន័យនេះ កម្មវិធីសកម្មភាពមានគោល

បំណងផ្តល់ក្របខណ្ឌសម្រាប់ណែនាំ ដល់ការសម្របសម្រួលការអនុវត្តគំនិតផ្តួចផ្តើមការការបន្សាំ តាមរយៈការចូលរួមដើម្បីប្រមូលផ្តុំកម្លាំង ច្រើនទៀតស្តីពីបរិស្ថាន និងការអភិវឌ្ឍ។

- បានបង្កើត គណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុ (NCCC) ឆ្នាំ២០០៦។ គណៈកម្មាធិការនេះ ជាយន្តការអន្តរក្រសួង និងមានតួនាទីបង្កើតយុទ្ធសាស្ត្រ គោលនយោបាយ ឧបករណ៍គតិយុទ្ធ កម្មវិធីពាក់ពន្ធ័នឹងបញ្ហាការប្រែប្រួលអាកាសធាតុ។ គណៈកម្មាធិការ នេះក៏ជំរុញឱ្យមានការដាក់បញ្ចូលបញ្ហាការប្រែប្រួលអាកាសធាតុ ទៅក្នុងយុទ្ធសាស្ត្រ គោលនយោបាយ ឧបករណ៍គតិយុទ្ធ ព្រមទាំងជម្រុញឱ្យមានការចូលរួមកាន់តែផុសផុល។
- គណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុ (NCCC) ជាមួយនឹងការចូលរួមពី ក្រសួងពាក់ព័ន្ធ ដៃគូអភិវឌ្ឍន៍ និងអង្គការមិនមែនរដ្ឋាភិបាល បានបង្កើតផែនការយុទ្ធសាស្ត្រ ឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុកម្ពុជា (Cambodia Climate Change Strategic Plan: CCCSP 2014-2023) ២០១៤ ដល់ ២០២៣។ ទស្សនវិស័យរបស់យុទ្ធសាស្ត្រនេះ គឺ តម្រូវឱ្យកម្ពុជាជំរុញបង្កើតសង្គមបៃតង ដើម្បីកាត់បន្ថយការបញ្ចេញឧស្ម័នកាបូនតិច ភាពធន់នឹងអាកាសធាតុ សមភាព និរន្តរភាព ហើយសង្គមបៃតងនេះត្រូវផ្អែកលើចំនេះដឹង។

ស្របជាមួយផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុកម្ពុជា(CCCSP) ស្ថានប័ន និងក្រសួងពាក់ព័ន្ធចំនួន ១០០ ក៏បានបង្កើតផែនការសកម្មភាព និងយុទ្ធសាស្ត្រស្តីពីការ ប្រែប្រួលអាកាសធាតុតាម វិស័យដែរ។ ទាំងផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាពតាម វិស័យផ្សេងៗសុទ្ធតែធ្វើឡើងឱ្យស្របនឹង CCCSP និងដើម្បីសម្រេចគោលដៅ CCCSP។ ជាងនេះទៅទៀត ផែនការនេះក៏បានឆ្លុះបញ្ចាំងពីសារៈសំខាន់នៃការបញ្ជ្រាបបញ្ហាការប្រែប្រួល អាកាសធាតុទៅក្នុងដំណើរកសាងផែនថ្នាក់ក្រោមជាតិដែរ។

បន្ថែមពីលើអ្វីដែលបានរៀបរាប់ខាងលើ នៅមានកម្មវិធីមានសារៈប្រយោជន៍ជាច្រើនទៀតដែលទាក់ទង នឹងវិធានការការបន្សាំ និងការកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់។ កម្មវិធីទាំងនោះមានដូចខាងក្រោម៖

- កម្មវិធីសាកល្បងសម្រាប់ភាពធន់នឹងអាកាសធាតុ បានបញ្ចប់នៅឆ្នាំ២០១៣ (Pilot Progam for Climate Resilience Project ended in 2013) មានគោលបំណងធានាថាការចំណាយ ផ្សេងៗទៅលើវិស័យកសិកម្ម ត្រូវផ្តោតជាសំខាន់ទៅលើផលវិជ្ជមាន និងអវិជ្ជមានដែលបណ្តាល ពីការប្រែប្រួលអាកាសធាតុ។
- សម្ព័ន្ធភាពការប្រែប្រួលអាកាសធាតុកម្ពុជា ដែលកំពុងស្ថិតក្នុងដំណើរការ (ongoing Cambodia Climate Change Alliance) គឺជាគម្រោងដែលបានទទួលមូលនិធិសម្រាប់ ការគាំទ្រសម្រាប់ការការបន្សាំ និងការកាត់បន្ថយការប្រែប្រួលអាកាសធាតុ។

- កម្មវិធីបណ្តុំនៅសហគមន៍នៅកម្ពុជា បានបញ្ចប់ឆ្នាំ ២០១៥ (Cambodia Communities Based Adaptation Program ended in 2015 គឺជាកម្មវិធីដែលទទួលជំនួយសម្រាប់ ការបង្កើនភាពធន់របស់សហគមន៍ជនបទទៅនឹងការបម្រែបម្រួលអាកាសធាតុ។
- កម្មវិធី UN-REDD (កាត់បន្ថយការបំភាយឧស្ម័នដោយការមិនកាប់បំផ្លាញព្រៃឈើ (កំពុងដំណើរការបច្ចុប្បន្ន) រំពឹងថាការកាប់ព្រៃឈើនឹងអាចថយចុះ ពង្រឹងការអភិរក្ស និងលើកកម្ពស់ការគ្រប់គ្រងព្រៃដោយមាននិរន្តរភាព សម្រាប់ប្រយោជន៍ប្រជាពលរដ្ឋជាពិសេសគឺជនក្រីក្រតាមជនបទ សត្វព្រៃ និងអាកាសធាតុ។
- គម្រោងលើកកម្ពស់ ការគ្រប់គ្រងទឹកឱ្យមានភាពធន់នឹងអាកាសធាតុ និង កម្មវិធីការអនុវត្តក្នុងវិស័យកសិកម្មនៅតាមទីជនបទ (កំពុងដំណើរការ) (ongoing project for: Prornoting Climate Resilliant Water Management and Agricultural Practices in Rural Cambodia) មានកម្មវត្ថុជួយឱ្យវិស័យកសិកម្ម មិនសូវ ទទួលផលប៉ះពាល់ពីការប្រែប្រួលនៃ ធនធានទឹកដែលបណ្តាលមកពីការប្រែប្រួលអាកាសធាតុ។
- គម្រោងការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាពបានបញ្ចប់នៅខែកុម្ភៈ២០១៥ (Sustanable Forest Management Project erded_in_ February 2015) មានគោលបំណង ពង្រឹងការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាព តាមរយៈការបញ្ចូលការគ្រប់គ្រងព្រៃឈើប្រកប ដោយនិរន្តរភាពសម្រាប់ព្រៃសហគមន៍ និងតំបន់ដែលមានការពារដោយសហគមន៍ ទៅក្នុងគោលនយោបាយ ការធ្វើផែនការ និងការអនុវត្ត។

គម្រោងដូចបានរៀបរាប់ខាងលើ គឺគ្រាន់តែជាគម្រោងមួយចំនួនដែលដកស្រង់ចេញពីគេហទំព័ររបស់ នាយកដ្ឋានការប្រែប្រួលអាកាសធាតុនៃក្រសួងបរិស្ថាន និងកម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិ (UNDP) នៅកម្ពុជាប៉ុណ្ណោះ មានគម្រោងដ៏ទៃទៀត ដែលនឹងអនុវត្ត ដោយក្រសួងពាក់ព័ន្ធចំនួន ១០ ខាងលើ ដែលបានរៀបចំផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាពរួចហើយ។

# មេរៀនទី ២ កម្ពុជា និងអនុសញ្ញាក្របខណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ

## ១. សេចក្តីផ្តើម

កម្ពុជាទទួលស្គាល់ពីតម្រូវចាំបាច់ក្នុងការគោរពគោលការណ៍នានា នៃអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ (UNFCCC) ជាពិសេស "គោលការណ៍ទទួលខុសត្រូវរួម ប៉ុន្តែក្នុងកម្រិតដោយឡែកពីគ្នា និងទៅតាមសមត្ថភាពរៀងៗខ្លួន និងសិទ្ធិរបស់ប្រទេសកំពុងអភិវឌ្ឍន៍ក្នុងការអភិវឌ្ឍដោយចីរភាព ការកំហិតជាសកលក្នុងការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ក៏ជាការ ចាំបាច់ផងដែរ ដើម្បីសម្រេចបានគោលដៅចុងក្រោយនៃអនុសញ្ញានេះ " *ដើម្បីរក្សាតុល្យភាពនៃកំហាប់ ឧស្ម័នផ្ទះកញ្ចក់ក្នុងបរិយាកាសនៅកម្រិត ដែលអាចទប់ស្កាត់ការរំខានប្រកបដោយគ្រោះថ្នាក់ នៃសកម្មភាពមនុស្សមកលើប្រព័ន្ធអាកាសធាតុ*"។ ជាការឆ្លើយតបនឹង ការអំពាវនាវឱ្យមានសកម្មភាពទី ក្រុង លីម៉ា កម្ពុជាសូមដាក់ជូននូវរបាយការណ៍ស្តីពីការចូលរួមចំណែករបស់ខ្លួន (INDC) ដើម្បីអនុ វត្តអនុសញ្ញា UNFCCC នៅមុនសន្និសីទបណ្តាភាគីនៃអនុសញ្ញា (UNFCCC) លើកទី២១ (COP21) នៅក្រុងប៉ារីស នាខែធ្នូ ឆ្នាំ២០១៥ របាយការណ៍ស្តីពីការចូលរួមចំណែករបស់កម្ពុជាដើម្បីអនុវត្ត អនុសញ្ញា UNFCCC នេះនឹងអាចកែសម្រួលដើម្បីឆ្លើយតបនឹងស្ថានភាពជាតិនៅពេលកម្ពុជាបន្តមាគ៌ា នៃការអភិវឌ្ឍរបស់ខ្លួន។

កម្ពុជា ជាប្រទេសដែលបញ្ចេញឧស្ម័នផ្ទះកញ្ចក់តិច ប៉ុន្តងាយរងគ្រោះជាខ្លាំងនៅចំពោះមុខ ផលប៉ះពាល់អវិជ្ជមាននៃការប្រែប្រួលអាកាសធាតុ។

ដូច្នេះ ការចូលរួមចំណែករបស់កម្ពុជា ត្រូវតែស្របទៅតាមអាទិភាពនៃការអភិវឌ្ឍរបស់ខ្លួន។ បាយការណ៍ស្តីពីការចូលរួមចំណែករបស់កម្ពុជា ដើម្បីអនុវត្តអនុសញ្ញា UNFCCC បានដាក់បញ្ចូល ទាំងសកម្មភាពបន្សាំ និងការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ ដោយផ្អែកលើស្ថានភាពរបស់ជាតិ។

របាយការណ៍ស្តីពីការចូលរួមចំណែករបស់កម្ពុជាដើម្បីអនុវត្តអនុសញ្ញា UNFCCC ចែកចេញជាប្រាំផ្នែក៖

- ផ្នែកទី១៖ រៀបរាប់អំពីបរិបទជាតិដែលបង្ហាញពីស្ថានភាពទូទៅទាក់ទងនឹងរបាយការណ៍ស្តីពីការចូលរួមចំណែករបស់កម្ពុជាដើម្បីអនុវត្តអនុសញ្ញា UNFCCC
- ផ្នែកទី២៖ មានព័ត៌មានស្តីពីការបន្សាំ ដែលរៀបរាប់អំពីភាពងាយរងគ្រោះរបស់កម្ពុជា ដោយសារការប្រែប្រួលអាកាសធាតុ និងសកម្មភាពបន្សាំជាអាទិភាព

- ផ្នែកទី៣៖ ការកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់ ដែលបញ្ជាក់អំពីការរួមចំណែករបស់កម្ពុជា ដើម្បីអនុវត្តអនុសញ្ញា UNFCCC ក្នុងការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ ជាមួយព័ត៌មាន ដែលធានាបាននូវភាពច្បាស់លាស់ តម្លាភាព ការយោគយល់ និងការពិចារណាពីភាពត្រឹមត្រូវ និងមហិច្ឆិតានៃការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់
- ផ្នែកទី៤៖ គឺជាដំណើរការរៀបចំផែនការនិងការអនុវត្ត ដែលបញ្ជាក់អំពីស្ថាប័ន គោលនយោបាយ យុទ្ធសាស្ត្រ និងផែនការនានា ដែលនឹងទ្រទ្រង់ដល់ការអនុវត្តសកម្មភាពស្តីពីការចូលរួមចំណែករបស់កម្ពុជាដើម្បីអនុវត្តអនុសញ្ញា UNFCCC
- ផ្នែកទី៥ ៖ មធ្យោបាយអនុវត្ត ជាមួយព័ត៌មានអំពីការគាំទ្រដែលចាំបាច់សម្រាប់ការអនុវត្តការ ។

ចូលរួមចំណែករបស់កម្ពុជា ដើម្បីអនុវត្តអនុសញ្ញា UNFCCC។ កម្ពុជាជឿជាក់ថា តាមរយៈរបាយការណ៍ស្តីពីការចូលរួមចំណែករបស់ខ្លួន ដើម្បីអនុវត្តអនុសញ្ញ UNFCCC ដែលជាអភិក្រមថ្មីមួយ " ផ្តើមចេញពីប្រទេសនីមួយៗ" សម្រាប់ដោះស្រាយការប្រែប្រួល អាកាសធាតុ យើងនឹងអាចជំនះភាពទ័លច្រកក្នុងការចរចា ដូចដែលបានជួបប្រទះក្នុងបណ្តាឆ្នាំកន្លង មកនេះ។ កម្ពុជាក៏សង្ឃឹមផងដែរថា កិច្ចព្រមព្រៀងថ្មីដែលនឹងត្រូវអនុម័តក្នុងសន្និសីទបណ្តាភាគីនៃ អនុសញ្ញា UNFCCC លើកទី២១ នៅក្រុងប៉ារីស៍ នឹងទទួលជោគជ័យក្នុងការកំណត់សីតុណ្ហភាពនៅ ត្រឹមកម្រិតដែលអាចទប់ស្កាត់ការរំខានប្រកបដោយគ្រោះថ្នាក់ នៃសកម្មភាពមនុស្សមកលើប្រព័ន្ធអាកាសធាតុពិភពលោក និងទន្ទឹមនឹងនេះរួមចំណែកកាត់បន្ថយភាពក្រីក្រលើពិភពលោកនឹងជំរុញកិច្ចប្រឹងប្រែង អភិវឌ្ឍន៍សេដ្ឋកិច្ចផងដែរ ។

## ២. បរិបទជាតិ

កម្ពុជា ជាប្រទេសដែលងាយរងគ្រោះជាខ្លាំងដោយសារផលវិបាកនានា ដែលបណ្តាលមកពីប្រែប្រួលអាកាសធាតុ ជាពិសេសគ្រោះទឹកជំនន់ គ្រោះរាំងស្ងួត ខ្យល់ព្យុះ និងការជ្រាបចូលនៃទឹកប្រៃ។ កសិកម្ម ហេដ្ឋារចនាសម្ព័ន្ធ ព្រៃឈើ សុខភាពមនុស្ស និងតំបន់ឆ្នេរ គឺជាវិស័យដែលរងគ្រោះខ្លាំងបំផុតដោយសារប្រែប្រួលអាកាសធាតុ អាទិភាពអភិវឌ្ឍន៍ជាតិសំខាន់ៗរបស់កម្ពុជា ដូចមានចែងក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (ផ.យ.អ.ជ) សម្រាប់ឆ្នាំ២០១៤-២០១៨ គឺការកាត់បន្ថយភាពក្រីក្រ ទន្ទឹមនឹងការពង្រឹងកំណើនសេដ្ឋកិច្ចតាមអត្រាថេរ៧-៨%ក្នុងមួយឆ្នាំ។ កម្ពុជាមានបំណងឈាន ពីប្រទេសអភិវឌ្ឍន៍តិចតួច (LDC) ទៅជាប្រទេសកំពុងអភិវឌ្ឍន៍ដែលមានចំណូលកម្រិតទាបមធ្យម នៅ ឆ្នាំ២០១៨ និងខ្ពស់មធ្យមនៅឆ្នាំ២០៣០។ គោលដៅនេះនឹងអាចសម្រេចបានតាមរយៈពិពិធកម្ម សេដ្ឋកិច្ច ដែលរួមទាំងឧស្សាហូបនីយកម្ម និងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត។

កិច្ចប្រឹងប្រែងនានាក្នុងការដោះស្រាយបញ្ហាប្រែប្រួលអាកាសធាតុនៅកម្ពុជា មិនអាចកាត់ផ្តាច់ចេញពីគោលដៅនៃការអភិវឌ្ឍសេដ្ឋកិច្ច និងគោលដៅកាត់បន្ថយភាពក្រីក្របានឡើយ វិស័យកសិកម្មត្រូវបានរំពឹងថានឹងកើនឡើងតាមអត្រា ៥% ក្នុងមួយឆ្នាំ ដើម្បីឈានដល់ចំណុចដៅនៃកំណើន សេដ្ឋកិច្ចជាតិ និងការនាំចេញ ក៏ដូចជាដើម្បីរួមចំណែកបំពេញតម្រូវការសន្តិសុខស្បៀងរបស់ប្រជាជន ផងដែរ។ ទន្ទឹមនឹងនេះ កម្ពុជាមានគម្របព្រៃឈើច្រើនជាង៥៧% ហើយរាជរដ្ឋាភិបាលកំពុងបន្ត ប្រឹងប្រែងក្នុងការបង្កើន និងរក្សាអត្រានេះ ដើម្បីជានារបរចិញ្ចឹមជីវិតសម្រាប់សហគមន៍ដែលពឹងផ្អែកលើព្រៃឈើ និងសម្រាប់មនុស្សជំនាន់ក្រោយៗផងដែរ ។ ពិតមែនតែសម្ពាធលើធនធាន និងដីធ្លីមានកម្រិតខ្ពស់ក្តី ក៏សារពើភ័ណ្ឌឧស្ម័នផ្ទះកញ្ចក់ ចុងក្រោយបានបង្ហាញថា កម្ពុជានៅជាប្រទេសអាងស្តុក កាបូននៅឡើយនៅឆ្នាំ២០០០ ។

ទោះបីមានការប្រឈមជាច្រើន ដែលពាក់ព័ន្ធជាមួយមហិច្ឆិតាខ្លាំងក្លាទាំងនេះក៏ដោយ កម្ពុជា មានមោទនភាពចំពោះវឌ្ឍនភាព ដែលសម្រេចបានលើការរៀបចំគោលនយោបាយប្រែប្រួលអាកាសធាតុ ជាពិសេសចាប់តាំងពីការចូលជាសមាជិកនៃអនុសញ្ញា UNFCCC នៅឆ្នាំ១៩៩៦។ កិច្ចខិតខំ ប្រឹងប្រែងនានាត្រូវបានអនុវត្តតាមរយៈការបញ្ជ្រាបការប្រែប្រួលអាកាសធាតុទៅក្នុងផែនការថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ ឧទាហរណ៍ កម្ពុជាបានរៀបចំ និងអនុវត្តផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុឆ្នាំ២០១៤-២០២៣ (ផ.យ.ប.អ.ក.) និងបណ្តាផែនការសកម្មភាពដែលបានរៀបចំឡើងដោយក្រសួងពាក់ព័ន្ធ ផែនការទាំងនេះគឺជាឯកសារគោលនយោបាយជាតិពេញលេញ ដំបូងបង្អស់របស់កម្ពុជា ដែលមិនត្រឹមតែបង្ហាញអំពីតម្រូវការបន្សុំា អាទិភាពរបស់ប្រទេសនេះប៉ុណ្ណោះទេ។

*ប្រភព៖ RGC (2014), National Strategic Development Plan 2014-18, Ministry of Planning. Available at: http://www.mop.gov.kh/Home/NSDP/NSDP20142018/tabid/216/Default.aspx*
*យោងតាមសារពើភណ្ឌឧស្ម័នផ្ទះកញ្ចក់ចុងក្រោយបង្អស់សម្រាប់ឆ្នាំ២០០០នៅក្នុង # RGC (2015), 5econd National Communication to the UNFCCC, Ministry of Environment (unpublished)*

ប៉ុន្តែក៏ផ្តល់ជាផែនទីបង្ហាញផ្លូវសម្រាប់កាត់បន្ថយការបញ្ចេញកាបូនពីវិស័យសេដ្ឋកិច្ចសំខាន់ៗ និងការពង្រីកអាងស្តុកកាបូនផងដែរ។ លើសពីនេះ កម្ពុជាបានរៀបចំគោលនយោបាយ និង ផែនទីបង្ហាញផ្លូវអភិវឌ្ឍន៍បៃតង ដែលកំណត់មាគ៌ាសម្រាប់ជំរុញសេដ្ឋកិច្ចតាមរយៈជម្រើសការបញ្ចេញកាបូនតិច ការសន្សំសំចៃ និងការបង្កើតការងារ ការពារក្រុមជនងាយរងគ្រោះ និងលើកកម្ពស់ចីរភាពបរិស្ថាន។

កម្ពុជាក៏សម្រេចបាននូវវឌ្ឍនភាពច្រើនផងដែរ ក្នុងការធ្វើសមាហរណកម្មបញ្ហាប្រែប្រួល អាកាសធាតុទៅក្នុងគម្រោងថវិកា តាមរយៈការរៀបចំក្របខ័ណ្ឌហិរញ្ញប្បទានប្រែប្រួលអាកាសធាតុ ការពិនិត្យជាទៀងទាត់នូវការចំណាយសាធារណៈលើការងារអាកាសធាតុ និងបានកែលម្អការឃ្លាំមើល ហិរញ្ញវត្ថុ

អាកាសធាតុនៅក្នុងកម្រងទិន្នន័យជំនួយអភិវឌ្ឍន៍ផ្លូវការ (ODA)។ នៅក្នុងវិស័យជាអាទិភាពនានា មានការងារដែលកំពុងអនុវត្តដើម្បីកែលម្អឯកសារថវិកា ដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុ និងនៅក្នុងការធ្វើសមាហរណកម្មការប្រែប្រួលអាកាសធាតុទៅក្នុងប្រព័ន្ធពិនិត្យតាមដាន និងវាយតម្លៃ។ កម្មវិធីសិក្សាហិរញ្ញវត្ថុអាកាសធាតុក៏កំពុងត្រូវបានដាក់បញ្ចូលទៅក្នុងវគ្គបណ្តុះបណ្តាលអំពីការគ្រប់គ្រង ហិរញ្ញវត្ថុសាធារណៈផងដែរ ដែលបានរៀបចំឡើងសម្រាប់មន្ត្រីរដ្ឋាភិបាល។

# ៣. ការបន្សាំ

## ៣.១ ភាពងាយរងគ្រោះចំពោះការប្រែប្រួលអាកាសធាតុ

កម្ពុជា គឺជាប្រទេសមួយដែលស្ថិតក្នុងចំណោមបណ្តាប្រទេស ដែលងាយរងគ្រោះបំផុតពីការប្រែប្រួលអាកាសធាតុនៅក្នុងពិភពលោក។ ក្នុងនាមជាប្រទេសអភិវឌ្ឍន៍តិចតួចមួយ ដែលពឹងផ្អែកលើវិស័យកសិកម្ម កម្ពុជាងាយរងគ្រោះចំពោះការប្រែប្រួលអាកាសធាតុ ជាចម្បងដោយសារតែលក្ខខណ្ឌ ភូមិសាស្ត្ររបស់ខ្លួន ការពឹងផ្អែកលើវិស័យកសិកម្ម និងសមត្ថភាពបន្សាំនៅមានកម្រិតទាប រួមទាំង ធនធានហិរញ្ញវត្ថុ បច្ចេកទេស និងធនធានមនុស្សមានកម្រិតកំណត់ ក្នុងទសវត្សរ៍កន្លងមកនេះ ប្រទេសកម្ពុជាបានជួបប្រទះគ្រោះទឹកជំនន់ គ្រោះរាំងស្ងួត និងខ្យល់ព្យុះកាន់តែញឹកញាប់ និងធ្ងន់ធ្ងរ ដែលបង្កជាការប្រឈមធ្ងន់ធ្ងរចំពោះការអភិវឌ្ឍសេដ្ឋកិច្ច សង្គម។ ខ្យល់ព្យុះកំពុងកើតឡើងកាន់តែញឹ កញាប់ និងបង្កផលប៉ះពាល់កាន់តែខ្លាំងឡើងចំពោះហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងសេដ្ឋកិច្ច ជាពិសេស នៅតាមទីជនបទ។ ជាឧទាហរណ៍ការធ្លាក់ភ្លៀងខ្លាំងនៅខែតុលាឆ្នាំ២០១៣ បាននាំមកនូវទឹកជំនន់យ៉ាងគំហុក ដែលបង្កផលប៉ះពាល់លើប្រជាជនជនច្រើនជាងកន្លះលាននាក់។ ខេត្តចំនួនច្រើនជាង ពាក់កណ្តាលនៅកម្ពុជាបានរងផលប៉ះពាល់ ហើយតំបន់មេគង្គទាំងមូលបានរងនូវផលប៉ះពាល់ ពិសេសនៅពេលដែលកម្ពស់ទឹកទន្លេនេះបានកើនឡើងរួមជាមួយជំនន់ទឹកភ្លៀង។

*ប្រភព៖ RGC (2012), RGC (2006) and RGC (2015), Second National Communication to the UNFCCC, Ministry of Environment (unpublished)*

ការប៉ាន់ប្រមាណមួយបានបង្ហាញថាទំហំនៃការខូចខាត និងការបាត់បង់ដែលបង្កដោយទឹក ជំនន់ឆ្នាំ២០១៣ មានប្រហែលជា៣៥៦លានដុល្លារអាមេរិក ក្នុងនោះ១៥៣លានដុល្លារអាមេរិក ជាការ ខូចខាតចំពោះហេដ្ឋារចនាសម្ព័ន្ធរូបវន្តនៅក្នុងតំបន់រងគ្រោះ និង២០៣លានដុល្លារអាមេរិក ជាការបាត់បង់ផលិតផល និងចរន្តសេដ្ឋកិច្ច ដូចគ្នានេះដែរនៅឆ្នាំ២០១២ គ្រោះរាំងស្ងួតបានកើតមាន ចំនួនក្នុង១១ខេត្តក្នុងចំណោមខេត្តសរុប២៤ នៅកម្ពុជា ហើយបានបង្កការខូចខាតចំពោះដំណាំស្រូវ ជាច្រើនពាន់ហិកតា។

ម៉ូឌែលឧតុនិយមបានព្យាករថា សីតុណ្ហភាពនឹងកើនឡើងនៅពេលអនាគត បូកបន្ថែមពីលើ ទឹកជំនន់ធ្ងន់ធ្ងរ ដែលកើតមានឡើងកាន់តែញឹកញាប់ ដូចដែលបានជួបប្រទះក្នុងប៉ុន្មានទសវត្សរ៍ចុង ក្រោយនេះ។ របបទឹកភ្លៀងនឹងកាន់តែមិនអាចព្យាករណ៍បានរហូតដល់ឆ្នាំ២០៥០។ កសិកម្ម ព្រៃឈើ ហេដ្ឋារចនាសម្ព័ន្ធ សុខភាពមនុស្ស និងតំបន់ឆ្នេរ គឺជាវិស័យដែលងាយរងគ្រោះបំផុតបណ្តាល មកពីផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ៖

- កសិកម្ម៖ ប្រព័ន្ធផលិតកម្មកសិកម្មជាច្រើនរបស់កម្ពុជាពឹងផ្អែកលើទឹកភ្លៀង ឬទឹកជំនន់ទន្លេ និងការស្រកចុះប្រចាំឆ្នាំនៃទឹកបឹងទន្លេសាប ដូច្នេះប្រព័ន្ធបែបនេះងាយរងគ្រោះបណ្តាលមក ពីការប្រែប្រួលអាកាសធាតុប្រចាំទី និងរបបខ្យល់មូសុង
- ហេដ្ឋារចនាសម្ព័ន្ធ ការកើតឡើងកាន់តែញឹកញាប់ និងធ្ងន់ធ្ងរ នៃទឹកជំនន់ ដោយសារប ប្រួលអាកាសធាតុ តម្រូវឱ្យមានការចំណាយកាន់តែខ្ពស់លើការថែទាំនិងការកែលម្អផ្លូវថ្នល់ និងហេដ្ឋារចនាសម្ព័ន្ធនៃប្រព័ន្ធស្រោចស្រព។ នេះជាករណីជាក់ស្តែងដែលកើតឡើងនៅតាម ទីប្រជុំជនដែលមានការប្រមូលផ្តុំកាន់តែច្រើនឡើងនូវចំនួនប្រជាជន និងទ្រព្យសម្បត្តិ
- វិស័យព្រៃឈើ ៖ នៅក្រោមសេណារីយ៉ូការបញ្ចេញឧស្ម័ន SRESB1 និង SRES 2 បាន បង្ហាញថារហូតដល់ឆ្នាំ២០៥០ ព្រៃឈើភាគច្រើននៅតំបន់វាលទំនាបនឹងជួបប្រទះភាពរាំង ស្ងួតមានរយៈពេលកាន់តែវែង ជាពិសេសព្រៃឈើនៅភាគឦសាន និងភាគនិរតី។ ព្រៃឈើ ច្រើនជាង៤លានហិកតានៅក្នុងតំបន់វាលទំនាប ដែលបច្ចុប្បន្ននេះខ្សត់ទឹកមានរយៈពេលពី៤ ទៅ៦ខែ នឹងកាន់តែខ្សត់ទឹកឡើងមានរយៈពេលកាន់តែវែងពី៦ ទៅ៨ខែ ឬវែងជាងនេះ
- សុខភាពមនុស្ស ការប្រែប្រួលអាកាសធាតុអាចមានផលប៉ះពាល់ដោយផ្ទាល់ និងដោយប យោល។ ជាឧទាហរណ៍នផលប៉ះពាល់ដោយផ្ទាល់ រួមមានការបាត់បង់ជីវិត រងរបួស ប៉ះពាល់ ស្មារតី និងការខូចខាហេដ្ឋារចនាសម្ព័ន្ធសុខភាពសាធារណៈ។ ឧទាហរណ៍នៃផលប៉ះពាល់ ដោយប្រយោលរួមមានការប្រែប្រួលវិសាលភាពភូមិសាស្ត្រ និងគ្រោះថ្នាក់នៃជម្ងឺបង្កឡើងពីមេ រោគ ជម្ងឺចម្លងតាមទឹក ជម្ងឺឆ្លងកង្វះអាហារូបត្ថម្ភ និងភាពអត់ឃ្លាន ដែលជាលទ្ធផលនៃការ រំខានចំពោះប្រព័ន្ធអេកូឡូស៊ី
- តំបន់ឆ្នេរ៖ ធនធានក្នុងតំបន់ឆ្នេរបានប្រឈមរួចមកហើយនូវសម្ពាធមួយចំនួន ដែលរួមមាន ការនេសាទហួសកម្រិត ការធ្វើអាជីវកម្មហួសកម្រិតលើធនធានព្រៃឈើ និងប្រព័ន្ធអេកូឡូស៊ី ព្រៃកោងកាង ដែលនាំឱ្យមានកំណើនការហូរច្រោះដី ការប្រែប្រួលអាកាសធាតុបានបូក បន្ថែមឥទ្ធិពលលើបញ្ហាប្រឈមនានាដែលមានស្រាប់ ដោយសារកំណើននីវ៉ូទឹកសមុទ្រ ការថយចុះដីដាំដំណាំ និងការថយចុះវត្តមានទឹកស្អាត។

## ៤. សកម្មភាពជាអាទិភាព

ការបន្សាំទៅនឹងឥទ្ធិពលនៃការប្រែប្រួលអាកាសធាតុនាពេលបច្ចុប្បន្ន និងទៅអនាគត គឺជាអាទិភាពមួយសម្រាប់កម្ពុជា។ កម្ពុជាជឿជាក់ថា សកម្មភាពបន្សាំនឹងការប្រែប្រួលអាកាសធាតុទាមទារឱ្យមានអភិក្រមចម្រុះពហុវិស័យ ដែលមានប្រសិទ្ធភាព និងដែលអាចគាំទ្រដល់គោលដៅអភិវឌ្ឍន៍របស់ជាតិ។

កម្ពុជា បានជ្រើសយកសកម្មភាពអាទិភាពមួយចំនួនដោយផ្តោតលើសកម្មភាពនានា ដែលផ្តល់សហប្រយោជន៍ជាមួយនឹងការកាត់បន្ថយផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ រួមមានដូចតទៅៈ

- លើកកម្ពស់ និងបង្កើនសមត្ថភាពបន្សាំរបស់សហគមន៍នានា ជាពិសេសតាមរយៈសកម្មភាព បន្សាំផ្អែកលើសហគមន៍ និងការស្តារប្រព័ន្ធអេកូឡូស៊ីធម្មជាតិ ដើម្បីឆ្លើយតបនឹងការប្រែប្រួល អាកាសធាតុ
- ការអនុវត្តវិធានការគ្រប់គ្រងនានាសម្រាប់តំបន់ការពារធម្មជាតិ ដើម្បីបន្សាំនឹងការប្រែប្រួលអាកាសធាតុ
- ការពង្រឹងប្រព័ន្ធប្រកាសផ្តល់ព័ត៌មានជាមុន និងការផ្សព្វផ្សាយព័ត៌មានអំពីអាកាសធាតុ
- ការសាងសង់ និងជួសជុលទំនប់ការពារទឹកជំនន់សម្រាប់វិស័យកសិកម្ម និងការអភិវឌ្ឍទីប្រជុំជន
- បង្កើនការប្រើប្រាស់ស្ថានីយ៍បូមទឹកចល័ត និងស្ថានីយ៍អចិន្ត្រៃយ៍ នៅក្នុងការឆ្លើយតបទៅនឹង ភាពរាំងស្ងួតក្នុងកូនរដូវប្រាំង និងជំរុញការស្រាវជ្រាវទឹកក្រោមដីនៅក្នុងការឆ្លើយតបនឹងគ្រោះ រាំងស្ងួត និងហានិភ័យអាកាសធាតុ
- បង្កើតប្រព័ន្ធកសិកម្មដែលធន់នឹងអាកាសធាតុ សម្រាប់បន្សាំនឹងការប្រែប្រួលរបបទឹក ដើម្បី បង្កើនទិន្នផលដំណាំ
- លើកកម្ពស់កសិកម្មដែលធន់នឹងអាកាសធាតុនៅក្នុងតំបន់ឆ្នេរ តាមរយៈការសង់ទំនប់ការពារ ទឹកប្រៃ និងការពង្រីកប្រព័ន្ធកសិដ្ឋានវៃឆ្លាតចំពោះការប្រែប្រួលអាកាសធាតុ
- បង្កើតពូជដំណាំនានាដែលសមស្របនឹងតំបន់កសិ-កេ្សត្របរិស្ថាន (AEZ) និងធន់នឹងការប្រែប្រួលអាកាសធាតុ
- លើកកម្ពស់ប្រព័ន្ធផលិតកម្មវារីវប្បកម្ម និងទម្លាប់ល្អៗដែលបន្សាំនឹងការប្រែប្រួលអាកាសធាតុ
- ជួសជុល និងស្តារហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ដែលមានស្រាប់ និងធានាប្រតិបត្តិការនិងការថែទាំប្រកបដោយប្រសិទ្ធភាព ដោយគិតគូរផងដែរអំពីផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ
- ពង្រីកកម្មវិធីការពារជម្ងឺគ្រុនចាញ់ឆ្ពោះទៅស្ថានភាពត្រៀមលុបបំបាត់ជម្ងឺគ្រុនចាញ់ទាំងស្រុង
- ពង្រីកកម្មវិធីជាតិស្តីពីជម្ងឺប្រព័ន្ធផ្លូវដង្ហើម ជម្ងឺរាករូស និងអាសន្នរោគនៅក្នុងតំបន់ងាយជួប គ្រោះមហន្តរាយ ដែលរួមទាំងការឃ្លាំមើល និងការស្រាវជ្រាវអំពីជម្ងឺឆ្លងតាមទឹក ជម្ងឺឆ្លងតាមចំណីអាហារ ដែលពាក់ព័ន្ធជាមួយការប្រែប្រួលអាកាសធាតុ

– ការពង្រឹងសមត្ថភាពបច្ចេកទេស និងសមត្ថភាពស្ថាប័ន ដើម្បីវាយតម្លៃផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ ការព្យាករពីការប្រែប្រួលអាកាសធាតុ និងការបញ្ជ្រាបការប្រែប្រួលអាកាស ធាតុទៅក្នុងផែនការអភិវឌ្ឍន៍តាមវិស័យ និងតាមអនុវិស័យ។

## ៥. ការកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់

### ៥.១ ការរួមចំណែក

ការរួមចំណែករបស់កម្ពុជា ដើម្បីកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់មានលក្ខណៈស្របគ្នាទៅនឹងលក្ខខណ្ឌមួយចំនួននៃសេចក្តីអំពាវនាវរបស់ទីក្រុង លីម៉ា (Lima Call for Action) កថាខ័ណ្ឌទី១១ ដែលមានខ្លឹមសារដូចខាងក្រោម៖

*"... ប្រទេសអភិវឌ្ឍន៍តិចតួច និងរដ្ឋកំពុងអភិវឌ្ឍន៍ដែលជាកូនកោះតូចៗ អាចធ្វើរបាយ ការណ៍ស្តីពីយុទ្ធសាស្ត្រ ផែនការ និងសកម្មភាពនានាសម្រាប់ការអភិវឌ្ឍបញ្ចេញឧស្ម័នផ្ទះ កញ្ចក់តិច ដែលឆ្លុះបញ្ចាំងអំពីស្ថានភាពពិសេសរបស់ខ្លួនទាក់ទងទៅនឹង របាយការណ៍ស្តីពី ការចូលរួមចំណែករបស់កម្ពុជា ដើម្បីអនុវត្តអនុសញ្ញា UNFCCC..."*

កម្ពុជាមានបំណងលើកស្នើនូវការចូលរួមចំណែករបស់ខ្លួន ដើម្បីកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់ សម្រាប់ឆ្នាំ២០២០-២០៣០ ហើយការអនុវត្តនេះទាមទារឱ្យមានការគាំទ្រពីសហគមន៍អន្តរជាតិ ជាពិសេស ដោយអនុលោមតាមមាត្រាទី៤.៣ នៃអនុសញ្ញា UNFCCC ។ ពិសេសទៅទៀតនោះ ទោះបីជាប្រទេសកម្ពុជាស្ថិតនៅក្នុងលំដាប់នៃប្រទេសអភិវឌ្ឍន៍តិចតួចក៏ដោយ ក៏កម្ពុជាកំពុងអនុវត្ត សកម្មភាពនានា ស្របតាមតម្រូវការអភិវឌ្ឍដោយចីរភាពរបស់ខ្លួន ហើយក៏បានចូលរួមចំណែកដើម្បី ដោះស្រាយបញ្ហាប្រែប្រួលអាកាសធាតុ ដែលរួមមានដូចជា៖

(i) ក្នុងវិស័យឧស្សាហកម្មថាមពល ឧស្សាហកម្មកម្មន្តសាល ការដឹកជញ្ជូន និងវិស័យដទៃទៀត៖ កម្ពុជាមានបំណងអនុវត្តសកម្មភាពនានា ដូចមានចែងក្នុងតារាងទី១ ដែលការអនុវត្តនេះអាចចូលរួមចំណែកកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់បានរហូតដល់ ៣,១ លានតោនសមមូលឧស្ម័នកាបូនិក ធៀបនឹងការបញ្ចេញឧស្ម័នផ្ទះកញ្ចក់សរុបចំនួន ១១,៦ លានតោនសមមូលឧស្ម័នកាបូនិកត្រឹមឆ្នាំ២០៣០។

(ii) ក្នុងវិស័យការប្រែប្រួលការប្រើប្រាស់ដី និងព្រៃឈើ (LULUCF)៖ កម្ពុជាមានបំណងអនុវត្តសកម្មភាពដោយស្ម័គ្រចិត្ត និងដោយមានលក្ខខណ្ឌមួយចំនួន ដើម្បីសម្រេចបានតាម គោលដៅនៃការបង្កើនគម្របព្រៃឈើឱ្យបានដល់៦០% នៃផ្ទៃដីប្រទេសសរុបនៅឆ្នាំ ២០៣០។ ក្នុងករណីដែលមិនបានអនុវត្តនោះ សមត្ថភាពស្រូបយកកាបូនរបស់វិស័យការប្រែប្រួលការប្រើប្រាស់ដី និងព្រៃឈើនឹងថយចុះមកត្រឹម៧,៨៩៧លានតោនសមមូលឧស្ម័នកាបូនិក នៅឆ្នាំ ២០៣០ ធៀបនឹង

សមត្ថភាពនៃការស្រូបយកកាបូនតាមការប៉ាន់ស្មានរហូតដល់ ១៨,៤៩២ លានតោន សមមូលឧស្ម័នកាបូនិក ក្នុងឆ្នាំ២០១០។

តារាងទី១ និងទី២ បង្ហាញពីព័ត៌មានលំអិតស្ដីពីសក្ដានុពលនៃការកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់ នៅក្នុងវិស័យទាំងនោះ ព្រមទាំងសកម្មភាពចាំបាច់មួយចំនួនដែលត្រូវអនុវត្ត ដើម្បីសម្រេចបានគោលដៅនេះ។

តារាង ១ សកម្មភាពកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់នៅក្នុងវិស័យសំខាន់ៗមួយចំនួន និង បរិមាណកាត់បន្ថយសរុបត្រឹមឆ្នាំ២០៣០

| វិស័យ | សកម្មភាពជាអាទិភាព | បរិមាណកាត់បន្ថយ គិតជាលានតោនសម មូលឧស្ម័នកាបូនិក និង (%) នៅឆ្នាំ ២០៣០ ធៀបនឹង ទិន្នន័យគោល |
|---|---|---|
| ឧស្សាហកម្មថាមពល | ការផលិតថាមពលកកើតឡើងវិញដោយភ្ជាប់ទៅបណ្ដាញជាតិ ថាមពលព្រះអាទិត្យ ថាមពលវារីអគ្គិសនី ជីវៈម៉ាស និងជីវឧស្ម័ន និងការតភ្ជាប់ស្ថានីយ៍ផលិតថាមពលតូចៗទៅបណ្ដាញចែកចាយ។ អគ្គិសនីក្រៅបណ្ដាញ (Off-grid) ដូចជាប្រព័ន្ធថាមពលព្រះអាទិត្យតាមគេហដ្ឋាន ថាមពលវារីអគ្គិសនី (ខ្នាតតូចៗ)។ ការលើកកម្ពស់ប្រសិទ្ធភាពថាមពលដោយអ្នកប្រើប្រាស់ផ្ទាល់។ | ១,៨ (១៦%) |
| ឧស្សាហកម្មកម្មន្តសាល | ជំរុញការប្រើប្រាស់ថាមពលកកើតឡើងវិញ និង អនុវត្តប្រសិទ្ធភាពថាមពលនៅតាមរោងចក្រកាត់ដេរ ម៉ាស៊ីនកិនស្រូវ និងឡឥដ្ឋ | ០,៧២៧ (៧%) |

| | | |
|---|---|---|
| ការដឹកជញ្ជូន | ជំរុញប្រព័ន្ធដឹកជញ្ជូនសាធារណៈ កែលម្អប្រតិបត្តិការ និងការថែទាំយានយន្តតាមរយៈការពិនិត្យ យានយន្ត និងការបើកប្រកបដោយភាពឆ្លាតវៃ និងបង្កើនការប្រើប្រាស់រថយន្តអ៊ីប៊ី រថយន្តអគ្គិសនី និងទោចក្រយានយន្ត | ០,៣៩ (៣%) |
| វិស័យផ្សេងទៀត | ជំរុញការប្រើប្រាស់ប្រសិទ្ធភាពថាមពលនៅតាម អគារនិងការប្រើប្រាស់ចង្ក្រានប្រសិទ្ធភាពថាមពល កាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់មានប្រភព ពីសំណល់តាមរយៈការប្រើប្រាស់ឡជីវឧស្ម័ននិង ធុងចម្រុះ និងការប្រើប្រាស់ថាមពលកកើតឡើង វិញសម្រាប់ស្រោចស្រពដំណាំ និងចង្កៀងព្រះអាទិត្យ។ | ០,១៥៥ (១%) |
| ការកាត់បន្ថយសរុប | | ៣,១ (២៧%) |

*ព័ត៌មាននេះបានផ្អែកលើការប៉ាន់ប្រមាណដែលបានធ្វើឡើងសម្រាប់ការរៀបចំរបាយការណ៍ជាតិលើកទី២។*

តារាង ២ ការរួមចំណែកទៅក្នុងវិស័យការប្រែប្រួល ការប្រើប្រាស់ដី និងព្រៃឈើ

| *ឈ្មោះសកម្មភាព* | *សេចក្តីអធិប្បាយ* | *បរិមាណឧស្ម័នកាត់បន្ថយ* |
|---|---|---|
| កំណត់គម្របព្រៃឈើដល់ ៦០% នៃផ្ទៃប្រទេសរហូតឆ្នាំ ២០៣០ និងការរក្សាគម្របព្រៃឈើអោយនៅដដែរក្រោយ ឆ្នាំ២០៣០ | អនុលោមតាមកម្មវិធីព្រៃឈើជាតិ (២០១០-២០២៩) រាជរដ្ឋាភិបាលកម្ពុជាកំពុងប្រឹងប្រែងបង្កើន និងរក្សាគម្របព្រៃឈើរហូតដល់ ៦០% នៃផ្ទៃប្រទេសពីអត្រាប៉ាន់ស្មានប្រហែល ៥៧% នៅឆ្នាំ២០១០។ ផែនការទាំងនេះរួមមាន៖ ការ | ៤,៧ តោនសមមូល $Co_2$/ហ.ត/ឆ្នាំ |

| | | |
|---|---|---|
| | ធ្វើចំណាត់ថ្នាក់តំបន់ព្រៃឈើឡើងវិញដើម្បីបញ្ចៀសការបាត់បង់ព្រៃឈើ៖<br>– តំបន់ការពារធម្មជាតិ៖ ២,៨លានហិកតា<br>– ព្រៃការពារ៖ ៣លានហិកតា<br>– សហគមន៍ព្រៃឈើ៖ ២លានហិកតា<br>– ព្រៃសម្បទានដែលត្រូវបានចាត់ថ្នាក់ឡើងវិញជាព្រៃការពារនិងព្រៃផ្តល់ផល ៖ ០,៣លានហិកតា<br>– ព្រៃផលិតកម្ម៖ ២,៥លានហិកតា<br>ការអនុវត្តកម្មវិធី FLEGT នៅកម្ពុជាដែលមានគោលដៅកែលម្អអភិបាលកិច្ចព្រៃឈើនិងជម្រុញ ឱ្យមានការធ្វើពាណិជ្ជកម្មអន្តរជាតិនៃឈើស្រប ច្បាប់ដែលបានផ្ទៀងផ្ទាត់រួច។ | |

## ៥.២ ព័ត៌មានដើម្បីផ្ទៀងផ្ទាត់អំពីសុក្រឹតភាព តម្លាភាព និងការយោគយល់

តារាង ៣ ផ្តល់នូវព័ត៌មានបន្ថែម ដើម្បីសម្រួលដល់លេខាធិការដ្ឋានអនុសញ្ញា UNFCCC ក្នុងការចងក្រង និងធ្វើការប្រៀបធៀបពីការរួមចំណែករបស់បណ្តាប្រទេសភាគីនៃអនុសញ្ញានេះក្នុងការអនុវត្តរបាយការណ៍ស្តីពីការចូលរួមចំណែករបស់ខ្លួន នៅក្រោមអនុវត្តអនុសញ្ញា UNFCCC។

តារាង ៣ ព័ត៌មានសង្ខេបដើម្បីផ្ទៀងផ្ទាត់អំពីសុក្រឹតភាព តម្លាភាពនិងការយោគយល់

| ព័ត៌មានសម្រាប់លេខាធិការដ្ឋានអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ | |
|---|---|
| ពេលវេលា និងរយៈពេលសម្រាប់អនុវត្ត | |
| ពេលវេលាសម្រាប់អនុវត្ត | ឆ្នាំ២០២០ដល់ ឆ្នាំ២០៣០ |
| ប្រភេទឧស្ម័ន និងវិសាលភាពគ្របដណ្តប់ | |
| ប្រភេទឧស្ម័នផ្ទះកញ្ចក់ក្នុងរបាយការណ៍ | ឧស្ម័នកាបូនិក ($CO_2$), មេតាន ($CH_4$), ឌីអាសូតម៉ូណូអុកស៊ីត ($N_2O$) |

| | |
|---|---|
| វិសាលភាពនៃការសិក្សាសម្រាប់របាយការណ៍ | ទូទាំងប្រទេស |
| ការសន្មត និងអភិក្រមវិធីសាស្ត | |
| វិធីសាស្ត្រសម្រាប់គណនាការបញ្ចេញឧស្ម័នផ្ទះកញ្ចក់និងនិទស្សន៍ | សារពើភ័ណ្ឌឧស្ម័នផ្ទះកញ្ចក់កន្លងមក៖ ទិន្នន័យស្តីពី ការគណនាការបញ្ចេញ និងសមត្ថភាពស្រូបយកឧស្ម័នផ្ទះកញ្ចក់ប្រើប្រាស់ក្នុងរបាយការណ៍នេះ ផ្អែកលើទិន្នន័យពង្រាងរបាយការណ៍របាយការណ៍ជាតិលើកទី២ ដែលរៀបចំដោយរដ្ឋាភិបាលកម្ពុជា។ ការធ្វើសារពើភ័ណ្ឌឧស្ម័នផ្ទះកញ្ចក់នេះប្រើប្រាស់វិធីសាស្ត្រ លំដាប់ទី១ ដែលចែងក្នុង គោលការណ៍ណែនាំរបស់ក្រុមការងារអន្តររដ្ឋាភិបាលស្តីពី ការប្រែប្រួលអាកាសធាតុ (IPCC 1996), មេគុណបញ្ចេញឧស្ម័នផ្ទះកញ្ចក់របស់ ក្រុមការងារអន្តររដ្ឋាភិបាលស្តីការប្រែប្រួលអាកាសធាតុ និងទិន្នន័យជាក់ស្តែងមួយចំនួនរបស់ ប្រទេសពីឆ្នាំ២០០០។ ការប៉ាន់ស្មាននៃការបញ្ចេញឧស្ម័នផ្ទះកញ្ចក់គោលៈនៅក្នុងវិស័យថាមពល ការប៉ាន់ស្មាននៅក្នុងរបាយការណ៍ជាតិ លើកទី២ប្រើប្រាស់ម៉ូឌែលផែនការថាមពលរយៈពេលវែង (LEAP) ដោយប្រើប្រាស់មេគុណបញ្ចេញជំនួស និង ទិន្នន័យជាក់ស្តែងមកពីប្រភពខុសៗគ្នាជាច្រើន។ ការប៉ាន់ ស្មានសម្រាប់ វិស័យប្រើប្រាស់ដីការប្រែប្រួលការប្រើប្រាស់ដី និងព្រៃឈើ (LULUCF) រួមបញ្ចូលទាំងការ បម្លែងគម្របព្រៃឈើ និងវាលស្មៅ និងដីធ្លីទំនេរ ហើយការ គណនានេះផ្អែកលើវិធីសាស្ត្រនានានៅក្នុងគោលការណ៍ ណែនាំរបស់ក្រុមការងារអន្តររដ្ឋាភិបាលស្តីពីការប្រែប្រួលអាកាសធាតុ (IPCC)។ រាល់ការប៉ាន់ស្មានទាំងអស់បាន គិតគូរដល់ស្ថានភាពម៉ាក្រូសេដ្ឋកិច្ចនយោបាយ និងទីផ្សារ និងស្ថានភាពផ្សេងៗទៀតនៅក្នុងវិស័យដទៃ។ ជម្រើសកាត់បន្ថយ ៖ ជម្រើសទាំងនេះត្រូវបានរៀបចំឡើង ដោយផ្អែកលើការវិភាគកន្លងមក បទពិសោធន៍ពីគម្រោងព័ត៌មាន សម្រាប់លេខាធិការដ្ឋានអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិ ស្តីពីការប្រែប្រួលអាកាស |

| | |
|---|---|
| | ធាតុដែលទទួលបានដោគជ័យគម្រោងសាកល្បង ការសិក្សាវាយ តម្លៃឯកសារស្រាវជ្រាវ និងយោបល់ពីអ្នកជំនាញការនានា។ |
| វិធីសាស្រ្តនានាសម្រាប់ការគណនាការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ពីការប្រើប្រាស់ការប្រែប្រួលការប្រើប្រាស់ដីនិងព្រៃឈើ | ទោះបីសកម្មភាពដែលប្រើប្រាស់ក្នុងវិស័យការប្រើប្រាស់ការប្រែប្រួលការប្រើប្រាស់ដីនិងព្រៃឈើត្រូវបានអនុវត្តដោយមានលក្ខខណ្ឌក៏ដោយ ក៏តារាងបង្ហាញពីសកម្មភាពជាក់ស្តែង និងលទ្ធផលនៃការកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់នឹងត្រូវធ្វើបច្ចុប្បន្នភាពនៅពេលបញ្ចប់យុទ្ធសាស្រ្ត REDD+ ។ |
| សក្តានុពលកំដៅសកល (GWP) | តួលេខសក្តានុពលកំដៅសកល ដែលប្រើប្រាស់សម្រាប់គណនាសមមូលឧស្ម័នកាបូនិក ត្រូវបានស្រង់ចេញពីរបាយការណ៍វាយតម្លៃលើកទី២ របស់ក្រុមការងារអន្តរដ្ឋាភិបាលស្តីពីការប្រែប្រួលអាកាសធាតុ |
| ចំណុចយោង | |
| ការបញ្ចេញក្រោមលក្ខខណ្ឌធម្មតា ដែលមិនគិតពីការកាត់បន្ថយការ បញ្ចេញឧស្ម័នផ្ទះកញ្ចក់ (BAU) នៅក្នុងឆ្នាំគោលដៅ | ១១,៦ លានតោនសមមូលឧស្ម័នកាបូនិក ត្រឹមឆ្នាំ២០៣០ |
| វិធីសាស្រ្តធ្វើការប៉ាន់ស្មានសម្រាប់សេណារីយ៉ូកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ | ម៉ូឌែល LEAP ត្រូវបានប្រើប្រាស់សម្រាប់ធ្វើការប៉ាន់ស្មានសេណារីយ៉ូធម្មតាសម្រាប់វិស័យថាមពលចំណែកម៉ូឌែល COMAP ត្រូវបានប្រើប្រាស់សម្រាប់ វិស័យការប្រើប្រាស់ការប្រែប្រួលការ ប្រើប្រាស់ដី និងព្រៃឈើ ដូចមានបង្ហាញក្នុងសេចក្តីព្រាងរបាយ ការណ៍ជាតិលើកទី២។ |

## ៥.៣ ភាពត្រឹមត្រូវ និងមហិច្ឆិតា

កម្ពុជាជាទទួលស្គាល់ពីភាពចាំបាច់ឱ្យប្រទេសទាំងអស់ បង្ហាញពីរបាយការណ៍ជាតិស្តីពីការចូលរួមចំណែកដើម្បីអនុវត្តអនុសញ្ញា UNFCCC ឱ្យបានត្រឹមត្រូវ និងមានមហិច្ឆិតាខ្ពស់ក្នុងការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ ដើម្បីឆ្លើយតបនឹងគោលបំណង ដូចមានចែងក្នុងសេចក្តីអំពាវនាវនៅក្រុងលីម៉ា។

ក្នុងឋានៈជាប្រទេសអភិវឌ្ឍន៍តិចតួចមួយ កម្ពុជាមានចំណែកតិចតួចនៅក្នុងការបញ្ចេញឧស្ម័នផ្ទះកញ្ចក់សកល នាពេលបច្ចុប្បន្ន ដែលត្រូវជាមួយភាគតូចនៃការបញ្ចេញឧស្ម័នផ្ទះកញ្ចក់លើពិភព លោកក្នុងពេលកន្លងមក។ ដោយពិចារណាអំពីតួនាទីសំខាន់នៃព្រៃឈើក្នុងការស្រូបយកកាបូន កម្ពុជានៅតែមាន

តុល្យភាពជាប្រទេសស្រូបកាបូននៅក្នុងឆ្នាំ២០០០។ តាមការប៉ាន់ស្មាននៅក្នុងសេចក្តីព្រាងរបាយការណ៍ជាតិលើកទី២ ការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ក្នុងមនុស្សម្នាក់ៗនៅកម្ពុជាក្នុងលក្ខខណ្ឌទម្លាប់ធម្មតា នៅឆ្នាំ២០៥០ នឹងមាន២,៥៩តោនសមមូលឧស្ម័នកាបូនិក ដែលតួលេខនេះទាបជាង ពាក់កណ្តាលនៃការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ក្នុងមនុស្សម្នាក់ៗ នាពេលបច្ចុប្បន្នលើពិភពលោក។ សកម្មភាពដែលបានស្នើប្រសិនបើបានទទួលការគាំទ្រគ្រប់គ្រាន់តាមរយៈហិរញ្ញវត្ថុ បច្ចេកវិទ្យា និង ការកសាងសមត្ថភាព នឹងរក្សាកម្រិតបញ្ចេញឧស្ម័នផ្ទះកញ្ចក់ក្នុងមនុស្សម្នាក់ៗត្រឹម២,០៤តោនសមមូលឧស្ម័នកាបូនិករហូត ឆ្នាំ២០៣០ ដែលនៅទាបជាងតួលេខមធ្យមភាគ លើពិភពលោក សម្រាប់ការទប់កំណើនសីតុណ្ហភាពមិនឱ្យលើសពី ២°C។

ទោះបីនៅជាប្រទេសអភិវឌ្ឍន៍តិចតួចក៏ដោយ ក៏កម្ពុជាបានបង្ហាញជូនជាលើកដំបូងនូវតារាង ស្តីពីសកម្មភាពកាត់បន្ថយបញ្ចេញឧស្ម័នផ្ទះកញ្ចក់ច្បាស់លាស់មួយដើម្បីកំណត់កំណើននៃការ បញ្ចេញឧស្ម័នផ្ទះកញ្ចក់របស់ខ្លួន ដែលធ្វើឱ្យមានភាពខុសគ្នាជាច្រើនធៀបនឹងសេណារីយ៉ូតាមទម្លាប់ធម្មតា (BAU) មានន័យថាខ្លួនមានបំណងធ្វើអ្វីលើសពីសកម្មភាពកំពុងអនុវត្តស្រាប់។

កម្ពុជាប្រឹងប្រែងបង្កើនជាអតិបរមានូវភាពបំពេញគ្នារវាងការកាត់បន្ថយ និងការបន្សាំជាមួយ នឹងការអភិវឌ្ឍដោយចីរភាព ដូច្នេះ សកម្មភាពនានាដែលបានស្នើឡើងត្រូវតែធ្វើសមាហរណកម្ម ជាមួយអាទិភាពនៃការអភិវឌ្ឍរបស់កម្ពុជា ដែលធានាថា កំណើនសេដ្ឋកិច្ចងាកទៅរកលំនាំនៃការ អភិវឌ្ឍដែលបញ្ចេញកាបូនតិចនិងបន្ស៊ីគ្នាជាមួយកិច្ចប្រឹងប្រែងនានាដើម្បីបង្កើនភាពធន់នឹងអាកាស ធាតុរបស់ប្រទេសយើង។

## ៦. ដំណើរការរៀបចំផែនការនិងការអនុវត្ត

របាយការណ៍ស្តីពីការចូលរួមចំណែករបស់កម្ពុជា ដើម្បីអនុវត្តអនុសញ្ញា UNFCCC ត្រូវបានរៀបចំឡើងនៅក្រោមការសម្របសម្រួលរបស់ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព។ ក្រុមអ្នករៀបចំរបាយការណ៍នេះត្រូវបានរៀបចំឡើង ដោយមានតំណាងមកពីក្រសួងពាក់ព័ន្ធ ដែលនឹងទទួលខុសត្រូវ លើការអនុវត្តសកម្មភាពជាក់លាក់។

របាយការណ៍ស្តីពីការចូលរួមចំណែករបស់កម្ពុជាដើម្បីអនុវត្តអនុសញ្ញា UNFCCC នេះ (និងការកែសម្រួលទៅអនាគត) គឺជាផ្នែករួមមួយនៃនិម្មាបនកម្មប្រែប្រួលអាកាសធាតុកម្ពុជា។ ដូច្នេះការអនុវត្តនឹងត្រូវបន្ស៊ីគ្នាជាមួយនឹងគោលនយោបាយប្រែប្រួលអាកាសធាតុជាតិកម្ពុជា និងមិនធ្វើឱ្យមានភាពត្រួតគ្នានោះឡើយ។

មានផែនការមួយចំនួនដែលមានស្រាប់នឹងអាចជួយគាំទ្រដល់កាពិនិត្យគោលនយោបាយប្រែប្រួលអាកាសធាតុកម្ពុជា សំដៅសម្រួលដល់ការអនុវត្តឱ្យបានជោគជ័យនូវរាល់សកម្មភាពនានា ដែល មានចែងក្នុងរបាយការណ៍ស្តីពីការចូលរួមចំណែករបស់កម្ពុជា ដើម្បីអនុវត្តអនុសញ្ញា UNFCCC នេះ ជាការច្បាស់

ណាស់ថា យុទ្ធសាស្ត្រ និងផែនការទាំងនេះនឹងត្រូវកែសម្រួលផងដែរនៅពេល ដែលផុតសុពលភាព ក្រោយពីបានវាយតម្លៃលើវឌ្ឍនភាពដែលបានសម្រេចនៅក្រោមយុទ្ធសាស្ត្រ និង ផែនការទាំងនោះ។

នៅក្នុងទសវត្សរ៍កន្លងទៅនេះ កម្ពុជាធ្វើឱ្យសម្រេចបាននូវវឌ្ឍនភាពច្រើនក្នុងការរៀបចំដំណើរការនានាសម្រាប់អនុវត្តវិធានការយតបនឹងការប្រែប្រួលអាកាសធាតុ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (២០១៤-១៨) ដែលជាផែនការអភិវឌ្ឍន៍ប្រទេសទាំងមូល ចែងពីសារៈសំខាន់នៃការអនុវត្ត ផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុកម្ពុជា (២០១៤-២០២៣) និងរួមមានសូចនាករនានាដើម្បីតាមដានទៅលើការអនុវត្តសកម្មភាពប្រែប្រួលអាកាសធាតុ។ លើសពីនេះ ការរៀបចំ របាយការណ៍ស្តីពីការចូលរួមចំណែករបស់កម្ពុជាដើម្បីអនុវត្តអនុសញ្ញា UNFCCC បានប្រព្រឹត្តទៅ អនុលោមផែនទីបង្ហាញផ្លូវអភិវឌ្ឍន៍បៃតង(២០០៩)ដែលបានរៀបចំឡើង ក្នុងគោលដៅគាំទ្រកម្ពុជា ទៅជាប្រទេសមានប្រាក់ចំណូលមធ្យមនៅឆ្នាំ២០៣០។ ផែនការបង្ហាញផ្លូវនេះក៏ចែងពីគម្រោងអាទិភាពសម្រាប់រយៈពេលវែងផងដែរ ពោលគឺឆ្នាំ២០២០-២០៣០។

កម្ពុជាមានបំណងគាំទ្រដល់ការអនុវត្តជំហានដំបូង របាយការណ៍ស្តីពីការចូលរួមចំណែក របស់កម្ពុជាដើម្បីអនុវត្តអនុសញ្ញា UNFCCC ជាពិសេសតាមរយៈការអនុវត្តផែនការយុទ្ធសាស្ត្រ ឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុកម្ពុជា ២០១៤-២០២៣ (ផ.យ.ប.អ.ក.)។ បណ្តាអាទិភាព ជាយុទ្ធសាស្ត្រខាងក្រោមមានគោលដៅអភិវឌ្ឍន៍ប្រទេសកម្ពុជាឆ្ពោះទៅរកសង្គមមួយដែលបតង បញ្ចេញកាបូនតិច ធន់នឹងការប្រែប្រួលអាកាសធាតុ សមធម៌ ចីរភាព និងពឹងផ្អែកលើចំណេះដឹងជាគោលៈ

(១) ក្រសួងពាក់ព័ន្ធបានរៀបចំផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ និង ផែនការសកម្មភាពតាមវិស័យ (ផ.យ.ប.អ. តាមវិស័យ និងផស.ប.អ. តាមវិស័យ) ដោយបានបន្ត គ្នាជាមួយ ផ.យ.ប.អ.កនិងគ្របដណ្តប់វិស័យសំខាន់ៗដែលពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុ ដែលមានចែងនៅក្នុងកម្មវិធីសកម្មភាពជាតិបន្សាំនឹងការប្រែប្រួលអាកាសធាតុ NAPA និង របាយការណ៍ជាតិក្រោមអនុសញ្ញា UNFCCC កម្ពុជាក៏ធ្វើការបញ្ជ្រាបភាពធន់នឹងការប្រែប្រួលអាកាស ធាតុទៅក្នុងប្រព័ន្ធរៀបចំផែនការនិងហិរញ្ញប្បទាននៅថ្នាក់ក្រោមជាតិផងដែរ។

(២) ចំពោះការបន្សាំ កម្ពុជាបានអនុវត្តកិច្ចផ្តួចផ្តើមនានាដើម្បីបញ្ជ្រាបការបន្សាំទៅក្នុងការអភិវឌ្ឍ ជាតិ និងវិស័យជាក់លាក់ដូចជា វិស័យកសិកម្ម ព្រៃឈើ និងសុខភាពមនុស្ស ក៏ដូចជាការគ្រប់គ្រង តំបន់ឆ្នេរផងដែរ។ បន្ថែមលើផ.យ.ប.អ.ក. ផ.យ.ប.អ. តាមវិស័យ និងផ.ស.ប.អ. តាមវិស័យ កម្ពុជា បានរៀបចំកម្មវិធីសកម្មភាពជាតិបន្សាំនឹងការប្រែប្រួលអាកាសធាតុ (២០០៦) ដែលក្នុងនោះយន្តការទាំងដើម្បីដោះស្រាយផលប៉ះពាល់ និងគ្រោះថ្នាក់ពីការប្រែប្រួលអាកាសធាតុ ក៏ដូចជាតម្រូវការបន្សាំសំខាន់ៗ ត្រូវបានកំណត់។

(៣) កម្ពុជាកំពុងអនុវត្ត ដំណើរការរៀបចំផែនការបន្សាំជាតិ (NAP) ដើម្បីពង្រឹងដល់ដំណើរការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ តាមរយៈការរៀបចំកម្មវិធីអន្តរវិស័យ និងការអនុវត្ត ទាំងនៅថ្នាក់ជាតិ និង

ថ្នាក់ក្រោមជាតិ។ NAP អាចផ្តល់ជាព័ត៌មានសម្រាប់រៀបចំយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុទៅអនាគតក្របខ័ណ្ឌហិរញ្ញប្បទាននិងការរៀបចំផែនការអភិវឌ្ឍន៍ជាតិនិងការលើក គម្រោងថវិកាផងដែរ។

(៤) សកម្មភាពដែលទាក់ទងនឹងព្រៃឈើនឹងត្រូវអនុវត្តជាផ្នែកមួយនៃយុទ្ធសាស្ត្រ REDD+។ កម្ពុជាកំពុងរៀបចំប្រព័ន្ធពិនិត្យតាមដានព្រៃឈើ (NFMS) ថ្នាក់ជាតិ និងកំណត់កម្រិតបញ្ចេញឧស្ម័ន ផ្ទះកញ្ចក់គោលសំដៅកំណត់ឱ្យបានជាក់លាក់នូវផលប៉ះពាល់នៃការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ពី សកម្មភាពនានានៃវិស័យនេះ។ កិច្ចការនេះនឹងបង្កើតជាមូលដ្ឋានគ្រឹះសម្រាប់ការអនុវត្ត និងការគណនាសម្រាប់សកម្មភាពក្នុងវិស័យព្រៃឈើនៅក្រោយឆ្នាំ២០២០ លើសពីនេះ កម្រិតនៃការ បញ្ចេញឧស្ម័នគោលពីព្រៃឈើ/កម្រិតយោងព្រៃឈើ (FREL/FRL) និងប្រព័ន្ធព័ត៌មានអំពីកិច្ចការពារ សុវត្ថិភាព (SIS) ក៏នឹងត្រូវប្រើប្រាស់សម្រាប់គណនាបរិមាណនៃការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ ដែលបានកាត់បន្ថយតាមរយៈការអនុវត្តសកម្មភាពដែលបានកំណត់សម្រាប់ឆ្នាំ២០១៦-២០២០។

កម្ពុជាបានរៀបចំជាជំហានៗដើម្បីធានាថា ប្រព័ន្ធត្រួតពិនិត្យតាមដាន និងវាយតម្លៃរបស់ខ្លួន មានបញ្ចូលសូចនាករនានាសម្រាប់វាស់វែងវឌ្ឍនភាព ដែលរួមទាំងការអនុវត្តរបាយការណ៍ស្តីពីការចូលរួមចំណែករបស់កម្ពុជាដើម្បីអនុវត្តអនុសញ្ញា UNFCCC សម្រាប់ការបន្សាំ និង ការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់។ ប្រព័ន្ធត្រួតពិនិត្យ រាយការណ៍ និងផ្ទៀងផ្ទាត់ MRV នឹងរៀបចំឡើងដោយ ផ្អែកលើសារពើភ័ណ្ឌឧស្ម័នផ្ទះកញ្ចក់។ ដោយឡែក ការបន្តគាំទ្រដល់ការរៀបចំប្រព័ន្ធត្រួតពិនិត្យ រាយការណ៍ និងផ្ទៀងផ្ទាត់ MRV សម្រាប់ REDD+ គឺជាតម្រូវការចាំបាច់ ដើម្បីអាចឱ្យកម្ពុជាឈានទៅរកដំណាក់កាលទីបីនៃ REDD+ ដែលកម្ពុជានឹងអាចទទួលការបង់ថ្លៃដែលផ្អែកលើលទ្ធផល។ បច្ចុប្បន្នប្រព័ន្ធត្រួតពិនិត្យតាមដាន និងវាយតម្លៃសម្រាប់ការបន្សាំកំពុងស្ថិតក្នុងការអនុវត្តនៅកម្រិតគម្រោង។ ក្របខ័ណ្ឌប្រព័ន្ធត្រួតពិនិត្យ តាមដាន និងវាយតម្លៃនៅថ្នាក់ជាតិនឹងត្រូវរៀបចំចំណែកសកម្មភាពនានា ដើម្បីដាក់ឱ្យអនុវត្តក្របខ័ណ្ឌនេះនៅក្នុងវិស័យគន្លឹះនានា ក៏បានចាប់ផ្តើមរួចមកហើយផងដែរ។

តារាងនៅក្នុងឧបសម្ព័ន្ធមានសង្ខេបអំពីសកម្មភាពជាអាទិភាពអំពីការកាត់បន្ថយ និងការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ និងដំណើរការដែលបានស្នើឡើងទាក់ទងនឹងការរៀបចំផែនការ និងការអនុវត្ត។ ការពិចារណាអំពីវឌ្ឍនភាព និងមេរៀននានាត្រូវបានរំពឹងថា នឹងធ្វើឡើងនៅឆ្នាំ ២០១៨ ដើម្បីការរៀបចំផែនការសកម្មភាពសម្រាប់អំឡុងពេលបន្ត។

## ៧. មធ្យោបាយនៃការអនុវត្ត

កម្ពុជាត្រូវការគាំទ្រតាមផ្នែកហិរញ្ញវត្ថុ ការកសាងសមត្ថភាព និងការផ្ទេរបច្ចេកវិទ្យា ដើម្បីអនុវត្តសកម្មភាពដែលមានចែងនៅក្នុងរបាយការណ៍ ស្តីពីការចូលរួមចំណែករបស់កម្ពុជាដើម្បីអនុវត្តអនុសញ្ញា UNFCCC នេះ ការវិភាគពិស្តារនៅពេលចាប់ផ្តើមអនុវត្តរបាយការណ៍ស្តីពីការចូលរួមចំណែករបស់កម្ពុជា

ដើម្បីអនុវត្តអនុសញ្ញា UNFCCC មានសារៈសំខាន់ណាស់ ដើម្បីបន្សុីគ្នាជាមួយសកម្មភាពនៃផែនការសកម្មភាពឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ និងកែលម្អការប៉ាន់ប្រមាណ អំពីតម្រូវការមូលនិធិ ជាពិសេសនៅក្រោយឆ្នាំ២០១៨។ ការវិភាគនេះនឹងកំណត់បាននូវប្រភេទ និង កម្រិតជាក់លាក់នៃការគាំទ្រដែលត្រូវការជាចាំបាច់ ជាពិសេសទាក់ទងនឹងការកសាងសមត្ថភាព និង ការផ្ទេរបច្ចេកវិទ្យា។

ការវាយតម្លៃអំពី តម្រូវការគាំទ្រនឹងផ្អែកលើក្របខ័ណ្ឌហិរញ្ញប្បទានប្រែប្រួលអាកាសធាតុដែលបានរៀបចំឡើងជាមួយផែនការសកម្មភាពឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ។ ក្របខណ្ឌនេះរាប់បញ្ចូលទាំងការវិភាគអំពីប្រភពហិរញ្ញប្បទាន ការកំណត់ថ្លៃចំណាយ ការវិភាគផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុមកលើសេដ្ឋកិច្ច និងអនុសាសន៍នានាអំពីគំរូហិរញ្ញប្បទានទាំងឡាយសម្រាប់ការ អនុវត្ត ផ.យ.ប.អ.ក. ។

យោងតាមការវាយតម្លៃតម្រូវការហិរញ្ញវត្ថុ សម្រាប់សកម្មភាពអាទិភាព ដែលមាននៅក្នុងផែនការសកម្មភាពឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុតាមវិស័យ កម្ពុជាត្រូវការថវិកា១,២៧ពាន់លាន ដុល្លារអាមេរិកសម្រាប់គាំទ្រការអនុវត្តបណ្តាសកម្មភាពទាំងនោះ ត្រឹមឆ្នាំ២០១៨។ ការវាយតម្លៃនេះ ក៏បានគិតគូរផងដែរអំពីសមត្ថភាពស្រូបយករបស់កម្ពុជាដើម្បីធានាថា ការវិនិយោគដែលស្នើឡើង មានប្រសិទ្ធិភាព។

ការគាំទ្រហិរញ្ញវត្ថុអន្តរជាតិគឺជាការបំពេញបន្ថែមលើអ្វីដែលកម្ពុជាកំពុងធ្វើវិភាជន៍ ដើម្បីអនុវត្តផែនការអភិវឌ្ឍន៍ដោយចីរភាពរបស់ខ្លួន និងសម្រេចបាននូវមានផលប៉ះពាល់វិជ្ជមាននៃសកម្មភាព កាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់។ ក្របខ័ណ្ឌហិរញ្ញប្បទានប្រែប្រួលអាកាសធាតុ បានប៉ាន់ប្រមាណថានៅឆ្នាំ២០១២ ការចំណាយនេះមាន៦,៥% នៃការចំណាយសរុបក្នុងវិស័យសាធារណៈ ឬ ត្រូវជា១,៣១% នៃផលទុនក្នុងស្រុកសរុប (ផ.ស.ស.)។ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ មានបញ្ជាក់ ពីការបង្កើនអត្រានៃការចំណាយលើការងារអាកាសធាតុ ធៀបនឹងផ.ស.ស. ដែលប៉ាន់ស្មានពី ១,៣៩%នៅឆ្នាំ២០១៥ ដល់ ១,៥% នៅឆ្នាំ២០១៨។

ការគាំទ្រហិរញ្ញវត្ថុអន្តរជាតិនឹងធ្វើឡើង តាមរយៈយន្តការទ្វេភាគី និងពហុភាគី ក៏ដូចជាយន្ត ការទីផ្សារផងដែរ កម្ពុជាកំពុងសម្រេចបាននូវវឌ្ឍនៈភាពច្រើនលើការត្រៀមលក្ខណៈសម្រាប់ការទទួលបានដោយផ្ទាល់នូវមូលនិធិអាកាសធាតុបៃតង (GCF) ដែលអាចក្លាយជាមធ្យោបាយចំបងមួយ សម្រាប់ហិរញ្ញវត្ថុអាកាសធាតុទៅអនាគត ការផ្តល់មូលនិធិដែលផ្តោតលើកិច្ចការឆ្លើយតបនឹងការ ប្រែប្រួលអាកាសធាតុពីប្រភពអន្តរជាតិ ទាំងពីប្រភពទ្វេភាគី/ពហុភាគី ឬតាមរយៈមូលនិធិអាកាសធាតុពិភពលោកនានា តំណាងឱ្យត្រឹមតែ៤០% នៃការវិនិយោគសរុបដែលទាក់ទងនឹងអាកាសធាតុ។ យុទ្ធសាស្ត្រនេះនឹងផ្តោតផងដែរលើមូលនិធិអភិវឌ្ឍន៍ផ្សេងទៀតដែលមាន ដោយសារភាគចំណែកនៃ មូលនិធិទាំងនេះដែលទាក់ទងនឹងអាកាសធាតុ ពីប្រភពក្នុងប្រទេសនិងអន្តរជាតិ គឺជាការគាំទ្រហិរញ្ញប្បទានដ៏សំខាន់។ កម្ពុជាក៏បានចូលរួមរួចមកហើយនៅក្នុងយន្តការ REDD+ សម្រាប់ការងារពាក់ព័ន្ធ នឹងវិស័យព្រៃឈើ។

ផែនការសកម្មភាពឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុតាមវិស័យក៏មានបញ្ជាក់អំពីតម្រូវ ការកសាងសមត្ថភាព។ តាមរយៈការពិគ្រោះយោបល់នានា ដែលបានធ្វើឡើងសម្រាប់ការរៀបចំ របាយការណ៍ស្តីពីការចូលរួមចំណែករបស់កម្ពុជាដើម្បីអនុវត្តអនុសញ្ញា UNFCCC ការរៀបចំប្រព័ន្ធ ត្រួតពិនិត្យ រាយការណ៍ និងផ្ទៀងផ្ទាត់ និងប្រព័ន្ធត្រួតពិនិត្យតាមដាន និងវាយតម្លៃត្រូវបានកំណត់ជា អាទិភាព។ ដូចដែលមានបញ្ជាក់ខាងលើ ការងារនេះបានចាប់ផ្តើមរួចមកហើយ ប៉ុន្តែនៅមានកិច្ចការ ជាច្រើនទៀតដែលត្រូវធ្វើដើម្បីរៀបចំប្រព័ន្ធត្រួតពិនិត្យ រាយការណ៍ និងផ្ទៀងផ្ទាត់ ដោយផ្អែកលើសូចនាករដែលបានកំណត់។

កម្ពុជាបានធ្វើការវាយតម្លៃអំពីតម្រូវការបច្ចេកវិទ្យាសម្រាប់ការបន្សាំ និងការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ ហើយតម្រូវការបច្ចេកវិទ្យាក៏បង្ហាញច្បាស់ផងដែរនៅក្នុងផែនការសកម្មភាព ឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុតាមវិស័យ។នៅពេលចាប់ផ្តើមដំណាក់កាលអនុវត្តរបាយការណ៍ ស្តីពីការចូលរួមចំណែករបស់កម្ពុជាដើម្បីអនុវត្តអនុសញ្ញា UNFCCC កម្ពុជាក៏នឹងត្រូវធ្វើការវាយតម្ល ពិស្តារអំពីតម្រូវការបច្ចេកវិទ្យាផងដែរ។

ឧបសម្ព័ន្ធ៖ ព័ត៌មានបន្ថែម ដែលពាក់ព័ន្ធនឹងយុទ្ធសាស្ត្រ និងគោលនយោបាយ ទាក់ទងនឹងការប្រែប្រួលអាកាសធាតុ

កម្ពុជាមានបំណងគាំទ្រដល់ការអនុវត្តរបាយការណ៍ស្តីពីការចូលរួមចំណែករបស់កម្ពុជាដើម្បី អនុវត្តអនុសញ្ញា UNFCCC ក្នុងដំណាក់កាលដំបូង តាមរយៈការអនុវត្តផែនការយុទ្ធសាស្ត្រឆ្លើយតប នឹង ការប្រែប្រួលអាកាសធាតុកម្ពុជា (ផ.យ.ប.អ.ក) (២០១៤-២០២៣) (សូមអានតារាងទី១ ខាងក្រោម)តាមរយៈអាទិភាពជាយុទ្ធសាស្ត្រក្នុងគោលដៅអភិវឌ្ឍន៍ឆ្ពោះទៅរកសង្គមមួយដែលបៃតង បញ្ចេញកាបូនតិច ធន់នឹងការប្រែប្រួលអាកាសធាតុ សមធម៌ ចីរភាព និងពឹងផ្អែកលើចំណេះដឹងជា គោល។

ទិសដៅជាយុទ្ធសាស្ត្រនៃ ផ.យ.ប.អ.ក. រួមមាន៖

- លើកកម្ពស់ភាពធន់នឹងអាកាសធាតុតាមរយៈការធ្វើឱ្យប្រសើរឡើងនូវសន្តិសុខស្បៀង ទឹក និងថាមពល
- កាត់បន្ថយភាពងាយរងគ្រោះតាមវិស័យ តំបន់ យេនឌ័រ និងសុខភាព នៅចំពោះមុខ ផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ
- លើកកម្ពស់ភាពធន់នឹងអាកាសធាតុនៃប្រព័ន្ធអេកូឡូស៊ីសំខាន់ៗ (បឹងទន្លេសាប ទន្លេមេគង្គ តំបន់ឆ្នេរ តំបន់ខ្ពង់រាប។ល។) ជីវៈចម្រុះ តំបន់ការពារធម្មជាតិ និងតំបន់បេតិកភណ្ឌវប្បធម៌
- លើកកម្ពស់ការកសាងផែនការ និងបច្ចេកវិទ្យាដែលបញ្ចេញកាបូនតិច ដើម្បីគាំទ្រដល់ការអភិវឌ្ឍដោយចីរភាព
- កែលម្អសមត្ថភាព ចំណេះដឹង និងការយល់ដឹងសម្រាប់ការឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ

- លើកកម្ពស់ការចូលរួម និងកិច្ចគាំពារសង្គមតាមបែបបន្សាំនឹងការប្រែប្រួលអាកាសធាតុ ដើម្បី កាត់បន្ថយការបាត់បង់ និងការខូចខាត
- ពង្រឹងស្ថាប័ន និងក្របខ័ណ្ឌការងារសម្របសម្រួល សម្រាប់ឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុនៅថ្នាក់ជាតិ
- ពង្រឹងកិច្ចសហការ និងការចូលរួមយ៉ាងសកម្មនៅក្នុងកិច្ចប្រឹងប្រែងឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ នៅថ្នាក់តំបន់ និងពិភពលោក។

ផ.យ.ប.អ.ក. ចែងពីយុទ្ធសាស្ត្រ និងសកម្មភាពនានាសម្រាប់ដំណាក់កាលខុសៗគ្នា ដូចតទៅ៖

- នៅក្នុងរយៈពេលខ្លី (២០១៣-២០១៤) ៖ ផ្តោយលើការពង្រឹងស្ថាប័ន ការកៀរគរហិរញ្ញវត្ថុសម្រាប់អនុវត្ត ផ.យ.ប.អ.ក. ការបង្កើតក្របខ័ណ្ឌជាតិសម្រាប់ត្រួតពិនិត្យ និងវាយតម្លៃ (M&E) និងសូចនាករ និងការរៀបចំផែនការសកម្មភាពឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ សម្រាប់រយៈពេលមធ្យម (២០១៤-២០១៨) ដោយក្រសួង-ស្ថាប័នពាក់ព័ន្ធ
- នៅក្នុងរយៈពេលមធ្យម (២០១៤-២០១៨) ប្រកាសចាប់ផ្តើមកម្មវិធីដែលមានអាទិភាពខ្ពស់ ជាមួយការផ្តោតដំបូងលើការបន្សាំ ហើយបន្តិចម្តងៗនឹងគាំទ្រការពង្រីកសកម្មភាពកាត់ បន្ថយឧស្ម័នផ្ទះកញ្ចក់ ការរៀបចំយន្តការទទួលបានមូលនិធិបន្សាំ និងមូលនិធិអាកាសធាតុ បៃតង
- នៅក្នុងរយៈពេលវែង (២០១៩-២០២៣) ផ្តោតលើការស្រាវជ្រាវ និងរៀនសូត្រប៉ុន្តែគោល ដៅចំបងនៃដំណាក់កាលនេះគឺពង្រីកកិច្ចផ្តួចផ្តើមជោគជ័យទាំងឡាយដែលសម្រេច កន្លងមក និងបន្តបញ្ជ្រាបការប្រែប្រួលអាកាសធាតុទៅក្នុងកម្មវិធីនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

តារាង ៤ ដំណើរការរៀបចំផែនការ និងការអនុវត្តរបាយការណ៍ស្តីពីការចូលរួមចំណែករបស់កម្ពុជា ដើម្បីអនុវត្តអនុសញ្ញា UNFCCC និងទំនាក់ទំនងជាមួយយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ

| សកម្មភាពជាអាទិភាព | យុទ្ធសាស្ត្រ និងផែនការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុដែលមានស្រាប់ |
|---|---|
| *ការបន្សាំ* | |
| លើកកម្ពស់ និងបង្កើនសមត្ថភាពបន្សាំរបស់សហគមន៍នានា ធម្មជាតិ និងស្តារឡើងវិញនូវប្រព័ន្ធអេកូឡូស៊ី ដើម្បីឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ | អនុវត្តផែនការសកម្មភាពឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុសម្រាប់បរិស្ថាន និងតំបន់ការពារធម្មជាតិឆ្នាំ (២០១៤-២០១៨) |
| ការអនុវត្តវិធានការនានានៃការគ្រប់គ្រង និងការពារតំបន់នានាដើម្បីបន្សាំនឹងការប្រែប្រួលអាកាសធាតុ | អនុវត្តផែនការសកម្មភាពឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុសម្រាប់បរិស្ថាន និងតំបន់ការពារធម្មជាតិ (២០១៤-២០១៨) |

| | |
|---|---|
| ការពង្រឹងប្រព័ន្ធព័ត៌មានអាកាសធាតុ និងប្រព័ន្ធប្រកាសផ្តល់ព័ត៌មានជាមុន | អនុវត្តផែនការសកម្មភាពឆ្លើយតបនឹងការ ប្រែប្រួលអាកាសធាតុសម្រាប់ធនធានទឹក និងឧតុនិយម (២០១៤-២០១៨) |
| ការកសាងជួសជុលទំនប់ការពារទឹកជំនន់ សម្រាប់វិស័យ កសិកម្ម និងការអភិវឌ្ឍទីប្រជុំជន | អនុវត្តផែនការសកម្មភាពឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុសម្រាប់ធនធានទឹក និងឧតុនិយម (២០១៤-២០១៨) |
| ការបង្កើនការប្រើប្រាស់ស្ថានីយ៍បូមទឹកចល័ត និងស្ថានីយ៍អចិន្ត្រៃយ៍ក្នុងការឆ្លើយតបទៅនឹងភាពរាំងស្ងួតក្នុងកូនរដូវប្រាំងនិងជំរុញការស្រាវជ្រាវពីទឹកក្រោមដីជាការឆ្លើយតបនឹងគ្រោះរាំងស្ងួត និងហានិភ័យអាកាសធាតុ | អនុវត្តផែនការសកម្មភាពឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុសម្រាប់ធនធានទឹក និងឧតុនិយម (២០១៤-២០១៨) |
| ការបង្កើតប្រព័ន្ធស្រោចស្រពដែលធន់នឹងអាកាសធាតុនៅថ្នាក់សហគមន៍ដើម្បីបង្កើនទិន្នផលស្រូវ និងផលិតកម្មកសិកម្ម | អនុវត្តផែនការសកម្មភាពឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុសម្រាប់ធនធានទឹក និងឧតុនិយម (២០១៤-២០១៨) |
| ការលើកកម្ពស់កសិកម្មដែលធន់នឹងអាកាសធាតុតាមរយៈការសាងសង់ទំនប់ការពារទឹកប្រៃក្នុងតំបន់ឆ្នេរនិងពង្រីកប្រព័ន្ធកសិដ្ឋានវៃឆ្លាតចំពោះការប្រែប្រួលអាកាសធាតុ | អនុវត្តផែនការសកម្មភាពឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុសម្រាប់ធនធានទឹក និងឧតុនិយម (២០១៤-២០១៨) និងផែនការសកម្មភាពឆ្លើយតបនឹងការប្រែប្រួលអាកាស ធាតុសម្រាប់វិស័យកសិកម្ម ព្រៃឈើ និងនេសាទ (២០១៤-២០១៨) |
| អនុវត្តផែនការសកម្មភាពឆ្លើយតបនឹងការបក្សេត្របរិស្ថាន (AEZ) និងធន់នឹងការប្រែប្រួលប្រួលអាកាសធាតុសម្រាប់វិស័យកសិកម្មព្រៃឈើ និងនេសាទ (២០១៤-២០១៨) | អនុវត្តផែនការសកម្មភាពឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុសម្រាប់វិស័យកសិកម្មព្រៃឈើ និងនេសាទ (២០១៤-២០១៨) |
| លើកកម្ពស់ប្រព័ន្ធផលិតកម្មវារីវប្បកម្ម និងទម្លាប់ប្រតិបត្តិដែលបន្សាំនឹងការប្រែប្រួលអាកាសធាតុ | អនុវត្តផែនការសកម្មភាពឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុសម្រាប់ការអភិវឌ្ឍជនបទ (២០១៤-២០១៨) |

| | |
|---|---|
| ការជួសជុល និងស្តារហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ដែលមានស្រាប់ និងធានាប្រតិបត្តិការនិងការថែទាំដោយគិតគូរផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ | ការអនុវត្តផែនការសកម្មភាពឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុសម្រាប់វិស័យសាធារណៈការ និងដឹកជញ្ជូន(២០១៤-២០១៨) |
| ការពង្រីកកម្មវិធីត្រួតពិនិត្យការពារជម្ងឺគ្រុនចាញ់ឆ្ពោះទៅស្ថានភាពត្រៀមលុបបំបាត់ជម្ងឺគ្រុនចាញ់ទាំងស្រុង | ការអនុវត្តផែនការសកម្មភាពឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុសម្រាប់វិស័យសុខភាពសាធារណៈ (២០១៤-២០១៨) |
| ការពង្រីកកម្មវិធីជាតិស្តីពីជម្ងឺប្រព័ន្ធផ្លូវដង្ហើមធ្ងន់ធ្ងរ ជម្ងឺរាគរូស និងអាសន្នរោគ នៅក្នុងតំបន់ងាយមានគ្រោះមហន្តរាយ រួមទាំងការឃ្លាំមើល និងការស្រាវជ្រាវអំពីជម្ងឺឆ្លងតាមទឹកនិងជម្ងឺឆ្លងតាមអាហារដែលពាក់ព័ន្ធជាមួយការប្រែប្រួលអាកាសធាត | ការអនុវត្តផែនការសកម្មភាពឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុសម្រាប់វិស័យសុខភាពសាធារណៈ (២០១៤-២០១៨) |
| ការពង្រឹងសមត្ថភាពបច្ចេកទេស និងស្ថាប័នដើម្បីធ្វើការវាយតម្លៃផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុការព្យាករពីការប្រែប្រួលអាកាសធាតុ និងការបញ្ជ្រាបការប្រែប្រួលអាកាសធាតុទៅក្នុងផែនការអភិវឌ្ឍន៍តាមវិស័យនិងតាមអនុវិស័យ | ការអនុវត្តអនុសាសន៍ពីសេចក្តីព្រាងរបាយការណ៍ជាតិលើកទី២ |
| *ការកាត់បន្ថយ* | |
| <u>ឧស្សាហកម្មថាមពល</u><br>ការតភ្ជាប់អគ្គិសនីដែលផលិតពីថាមពលកកើតឡើងវិញជាមួយបណ្តាញ (ថាមពលព្រះអាទិត្យ វារីអគ្គិសនី ជីវៈម៉ាស និងជីវឧស្ម័ន) និងការតភ្ជាប់អ្នកផលិតសម្រាប់ការប្រើប្រាស់ ផ្ទាល់ខ្លួនទៅនឹងបណ្តាញចែកចាយ | ការអនុវត្តផែនការសកម្មភាពឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ សម្រាប់ឧស្សាហកម្មកម្មន្តសាល និងវិស័យថាមពល (២០១៤-២០១៨) |

| | |
|---|---|
| ការផលិតអគ្គិសនីកបណ្ដាញ ដូចជាប្រព័ន្ធផលិតអគ្គិសនីដោយពន្លឺព្រះអាទិត្យតាមផ្ទះ<br>ការជម្រុញប្រសិទ្ធភាពថាមពលក្នុងចំណោមអ្នកប្រើប្រាស់ផ្ទាល់ | |
| <u>ឧស្សាហកម្មកម្មន្តសាល</u><br>ការកាត់បន្ថយការបញ្ចេញឧស្ម័នពីដំណើរការកិនស្រូវ រោងចក្រកាត់ដេរ និងការផលិតឥដ្ឋ | ការអនុវត្តផែនការសកម្មភាពឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ សម្រាប់ឧស្សាហកម្មកម្មន្តសាល និងវិស័យថាមពល(២០១៤-២០១៨) |
| <u>វិស័យដឹកជញ្ជូន</u><br>ការត្រួតពិនិត្យយានយន្តការដឹកជញ្ជូនសាធារណៈ និងការកែលម្អប្រសិទ្ធភាពនៃយានយន្ត<br><u>វិស័យដទៃទៀត</u><br>ចង្ក្រានប្រសិទ្ធភាព ឡជីវៈឧស្ម័ន ធុងចម្រោះ | ការអនុវត្តផែនការសកម្មភាពឆ្លើយតបនឹងការ ប្រែប្រួលអាកាសធាតុ សម្រាប់ឧស្សាហកម្មកម្មន្តសាល និងវិស័យថាមពល(២០១៤-២០១៨) |
| <u>វិស័យព្រៃឈើ</u><br>ការបង្កើនគម្របព្រៃឈើដល់៦០%នៃផ្ទៃប្រទេស និងការរក្សាអត្រានេះចាប់ពីឆ្នាំ២០៣០ តទៅ | ការអនុវត្តកម្មវិធីព្រៃឈើជាតិឆ្នាំ២០១០-២០២៩<br>ការអនុវត្តផែនការសកម្មភាពឆ្លើយ តបនឹងការប្រែប្រួលអាកាសធាតុសម្រាប់វិស័ យកសិកម្ម ព្រៃឈើ និងនេសាទ (២០១៤-២០១៨) យុទ្ធសាស្ត្រ REDD+ |

# មេរៀនទី ៣ ពិធីសារក្យូតូ

## អនុសញ្ញាស្តីពីការប្រែប្រួលអាកាសធាតុ ពិធីសារក្យូតូ និងយន្តការអភិវឌ្ឍន៍ស្អាត

( The Climate Change Convention, The Kyoto Protocol and The Clean Development Mechanism ( CDM )

## ១. សេចក្តីផ្តើម

ចាប់តាំងពីពាក់កណ្តាលទសវត្សឆ្នាំទី ៨០ មក គេបានរកឃើញភ័ស្តុតាងវិទ្យាសាស្ត្រជាច្រើន ដែលអះអាងថា សកម្មភាពរបស់មនុស្ស ជាមូលហេតុចំបង នៃការប្រែប្រួលអាកាសធាតុមិនប្រក្រតី នាប៉ុន្មានទសវត្សចុងក្រោយនេះ ប្រសិនបើនិន្នាការប្រែប្រួលអាកាសធាតុនេះនៅតែបន្តទៀត នោះនាពេលអនាគត ពិភពលោកនឹងជួបប្រទះនូវកំណើនកំដៅ ការឡើងកម្ពស់ទឹកសមុទ្រ ការប្រែប្រួលរបបទឹកភ្លៀង និងព្រឹត្តិការណ៍អាកាសធាតុមិនប្រក្រតីជាច្រើនទៀត ( ភាពរាំងស្ងួត ទឹកជំនន់ ខ្យល់ព្យុះសង្ឃរា ។ល។ ដែលអាចមានផលប៉ះពាល់អវិជ្ជមានយ៉ាងធ្ងន់ធ្ងរដល់គ្រប់វិស័យសេដ្ឋកិច្ច ជាពិសេសវិស័យកសិកម្ម រុក្ខកម្ម សុខាភិបាល បរិស្ថាន និងការលិចលង់តំបន់ទំនាបតាមឆ្នេរសមុទ្រជាដើម។ ប្រទេសក្រីក្រជាអ្នកងាយរងគ្រោះជាងគេពីការប្រែប្រួលអាកាសធាតុ ដោយសារតែបណ្តាប្រទេសទាំងនោះភាគច្រើនជាប្រទេសកសិកម្ម ហើយមានសមត្ថភាព មធ្យោបាយ និងធនធានស្តួចស្តើងបំផុត សម្រាប់ចាត់វិធានការឆ្លើយតប ទៅនឹងបញ្ហានេះ ។

## ២. ការឆ្លើយតបរបស់មនុស្សជាតិ

### ២.១ អនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិ ស្តីពីការប្រែប្រួលអាកាសធាតុ

ដោយយល់យ៉ាងច្បាស់ពីផលវិបាកដ៏ធ្ងន់ធ្ងរទាំងនេះ បណ្តាប្រទេសនៅលើពិភពលោកបានឯកភាពគ្នាអនុត អនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិ ស្តីពីការលអាកាសធាតុ ( United Nations Framework Convention on Climate Change, UNFCCC ) នៅក្នុងសន្និសីទកំពូលពិភពលោករបស់អង្គការសហប្រជាជាតិស្តីពីបរិស្ថាន និងការអភិវឌ្ឍន៍ ដែលបានប្រព្រឹត្តទៅនៅខែ មិថុនា ឆ្នាំ ១៩៩២ នាទីក្រុង រីយ៉ូដឺសានេរ៉ូ នៃប្រទេសប្រេស៊ីល ។

គោលបំណងសំខាន់នៃអនុសញ្ញានេះ គឺធ្វើឱ្យកំណកឧស្ម័នផ្ទះកញ្ចក់ ( greenhouse gases ) នៅក្នុងបរិយាកាសមានស្ថេរភាពនៅក្នុងកម្រិតមួយ ដែលអាចរាំងស្កាត់នូវឥទ្ធិពលប្រកបដោយគ្រោះថ្នាក់បណ្តាលមកពីសកម្មភាពមនុស្សទៅលើប្រព័ន្ធអាកាសធាតុ ។

មកទល់បច្ចុប្បន្ន មានប្រទេសចំនួន ១៨៦ នៅលើពិភពលោក បានចូលជាសមាជិកនៃអនុសញ្ញានេះ ប្រទេសកម្ពុជាបានចុះហត្ថលេខា សុំចូលជា សមាជិក នៃអនុសញ្ញាស្តីពីការប្រែប្រួលអាកាសធាតុ នៅ

ថ្ងៃទី ១៨ ខែធ្នូ ឆ្នាំ ១៩៩៥ ហើយនៅថ្ងៃទី ២៤ តុលា ឆ្នាំ ១៩៩៦ រដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា បានអនុម័តច្បាប់ស្តីពីការអនុម័តយល់ព្រម លើអនុសញ្ញាក្របខ័ណ្ឌលហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ នាសម័យ ប្រជុំលើកទី ៧ នីតិកាលទី ១ ។

## ២.២ ពិធីសារកេត្តូ

**ពិធីសារក្យូតូ** (The Kyoto protocol) គឺជាកិច្ចព្រមព្រៀងទីមួយនៅក្រោមអនុសញ្ញាស្តីពីការប្រែប្រួលអាកាសធាតុ ដែលបានកំណត់គោលដៅ ជាក់លាក់ ក្នុងការឈានទៅសម្រេចគោលដៅចំបងនៃអនុសញ្ញាស្តីពីការប្រប្រួលអាកាសធាតុ តាមរយៈការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ នៅក្នុងប្រទេសអភិវឌ្ឍន៍ ពិធីសារស្តូតូត្រូវបានអនុម័តដោយសមាជិកនៃអនុសជ្ជស្តីពីការប្រេលអាកាសធាតុ នៅក្នុងកិច្ចប្រជុំរបស់ភាគីជាសមាជិកលើកទី៣ ដែលបាន ប្រព្រឹត្តទៅ ចាប់ពីថ្ងៃទី ១ ដល់ ១១ ខែ ធ្នូ ឆ្នាំ ១៩៩៧ នៅទីក្រុងក្យូតូ ប្រទេសជប៉ុន។ ពិធីសារនេះត្រូវបានដាក់ឱ្យចុះហត្ថលេខាចាប់ពីថ្ងៃទី ១៦ ខែ មីនា ឆ្នាំ១៩៩៨ ដល់ថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ១៩៩៩ នៅទីស្នាក់ការរបស់អង្គការសហប្រជាជាតិ នាទីក្រុងញូវយ៉ក ។ មកមលំចុងខែមករា ឆ្នាំ ២០០៣ មានប្រទេសចំនួន ១០ បានផ្តល់សច្ចាប័ន ឬសុំចូលជាសមាជិកនៃពិធីសារនេះរួចហើយ ។ ពិធីសារនេះនឹងចូលជាធរមាន នៅក្នុងរយៈពេល ៩០ ថ្ងៃ ក្រោយពីពេលដែលប្រទេសចំនួន ៥៥ផ្តល់សច្ចាប័ន ឬចូលជាសមាជិក ដោយរួមទាំងប្រទេសក្នុងឧបសម្ព័ន្ធទី១-ផង (ពោលគឺក្រុមប្រទេសមានឧស្សាហកម្មល្អពលស់ និងប្រទេសមានសេដ្ឋកិច្ច, ស្ថិតនៅក្នុងអន្តរកាល ជាអតីតប្រទេសក្នុងពួកសង្គមនិយម ដែលបានបញ្ចេញឧស្ម័នកាបូនិចខ្លួន ៥៥% នៃបរិមាណបញ្ចេញសរុបនៅឆ្នាំ ១៩៩០។ ពីធីសារនេះ គឺជាជំហានដាក់ស្តែងទី ១ ដែលអាចជួយពិភពលោក ឈានទៅសម្រេចបាននូវគោលដៅចុងក្រោយ នៃអនុសញ្ញាស្តីពីការប្រែប្រួលអាកាសធាតុ គឺការរាំងស្កាត់ ឥទ្ធិពលប្រកបដោយគ្រោះថ្នាក់ណ្តាលពីសកម្មភាពមនុស្សចំពោះប្រព័ន្ធអាកាសធាតុ ។ យោងតាមពិធីសារនេះ ប្រទេសចំនួន ៣៨ នៅក្នុងការសម្ព័ន្ធទី១ នៃអនុសញ្ញា បានយល់ព្រមបំពេញកាតព្វកិច្ចកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់ប្រាំមួយមុខ ក្នុងបរិមាណយ៉ាងហោចណាស់ចំនួន ៥% ធៀបនឹងកម្រិតដែលប្រទេសទាំងនោះ បានបញ្ចេញនៅឆ្នាំ ១៩៩០ ទៅរវាងឆ្នាំ ២០០៨-២០១២។ បណ្តាប្រទេសទាំងនេះអាចធ្វើការកាត់បន្ថយស្ម័នផ្ទះកញ្ចក់ ដែលជាកាតព្វកិច្ចរបស់ខ្លួន តាមរយៈ យន្តការបី គឺ (១) ការធ្វើពាណិជ្ជកម្មអេប៊ីសង (Lmission Trading ២) ការអនុវត្តន៍រួមគ្នា (Joint Implementation) រវាងប្រទេសអភិវឌ្ឍន៍ដូចគ្នា និង (៣) យន្តការអភិវឌ្ឍន៍ស្អាត (Clean Development Mechanism, CIM) សំដៅលើកទឹកចិត្តឱ្យមានគម្រោងកាត់បន្ថយការបញ្ចេញឧស្ម័នរួមគ្នារវាងប្រទេសអភិវឌ្ឍន៍ និង ប្រទេសកំពុងអភិវឌ្ឍន៍ ។

*ឧស្ម័នផ្ទះកញ្ចក់សំខាន់ៗមាន : ឧស្ម័នកាបូនិក ($CO_2$)) មេតាន ($CH_4$) នីដ្រូសែនអុកស៊ីត ($NO_2$) ស្ពាន់ធ័រអុកស៊ីត ($SO_2$) ។ល។*

### ២.៣ យន្តការអភិវឌ្ឍន៍ស្អាត ( The Clean development Mechanism, CDM )

កាលានុវត្តភាពសំខាន់របស់ពិធីសារក្យូតូសម្រាប់ប្រទេសកំពុងអភិវឌ្ឍន៍ គឺការចូលរួមអនុវត្តគម្រោងក្រោម "**យន្តការអភិវឌ្ឍន៍ស្អាត**" ដែលមានបំណង ជួយប្រទេសកំពុងអភិវឌ្ឍន៍ ឱ្យសម្រេចបាននូវគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព នឹងជួយប្រទេសនៅក្នុងឧបសម្ព័ន្ធទី១ ក្នុងការសម្រេចផ្លូវកាតព្វកិច្ចកាត់បន្ថយការបញ្ចេញឧស្ម័នរបស់ខ្លួន ។ បណ្តាគម្រោងនេះរួមមាន :

១. គម្រោងលើកកម្ពស់ប្រសិទ្ធិភាពថាមពល និងការសន្សំសំចៃថាមពល នៅក្នុងវិស័យឧស្សាហកម្ម ការដឹកជញ្ជូន ការផលិតថាមពល និងលំនៅដ្ឋាន ។

២. គម្រោងប្រើប្រាស់ថាមពលកើតឡើងវិញ (renewable energy) ដូចជាពន្លឺព្រះអាទិត្យ ថាមពលខ្យល់ ថាមពលជីវៈ ម៉ាស (biomass)

៣. គម្រោងស្តារព្រៃឈើ (reforestation) និងដាំដើមឈើនៅតំបន់ថ្មីៗ (afforestation)។

ប្រទេសលូតលាស់ជាច្រើនដែលមានកាតព្វកិច្ចកាត់បន្ថយការបញ្ចេញឧស្ម័នរបស់ខ្លួននោះ បានចាប់អារម្មណ៍ក្នុងការចូលរូបអនុវត្តន៍គម្រោងក្រោយ "យន្តការអភិវឌ្ឍន៍ស្អាត" នៅបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ ដូចជាកម្ពុជាជាដើម ដោយហេតុថា ប្រទេសជឿនលឿនទាំងនោះ មានការលំបាកក្នុងការកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់នៅក្នុងប្រទេសគេផ្ទាល់ ពីព្រោះគេបានប្រើប្រាស់បច្ចេកវិជ្ជាថ្មី និងទំនើបប្រកបដោយប្រសិទ្ធិភាពខ្ពស់រួចទៅហើយ ។ ដោយយល់យ៉ាងច្បាស់ពី កាលានុវត្តភាពដែលពិធីសារក្យូតូអាចផ្តល់ឱ្យប្រទេសជាតិ និងពីកាតព្វកិច្ចក្នុងការរួមចំណែកជាមួយសហគមន៍អន្តរជាតិក្នុងការដោះស្រាយបញ្ហាប្រែប្រួលអាកាសធាតុ សម្តេច ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជាបានចុះហត្ថលេខាលើលិខិតូបករណ៍សុំចូលជាសមាជិក នៃពិធីសារក្យូតូ កាលពីថ្ងៃ ទី ៤ ខែ កក្កដា ឆ្នាំ ២០០២ ដែលអនុញ្ញាតឱ្យកម្ពុជានូវសិទ្ធិអនុវត្តបណ្តាគម្រោងក្រោម " យន្តការអភិវឌ្ឍន៍ស្អាត " នេះ ។

## ៣. កម្ពុជា និងបញ្ហាប្រែប្រួលអាកាសធាតុ

ប្រទេសកម្ពុជាបានចុះហត្ថលេខាលើអនុសញ្ញាស្តីពីការប្រែប្រួលអាកាសធាតុនៅឆ្នាំ ១៩៩៥ ពោលគឺតែក្នុងរយៈពេលពីរឆ្នាំ ក្រោយពីការបង្កើត រដ្ឋាភិបាល ដែលត្រូវបានបោះឆ្នោតជ្រើសរើសដោយសេរីជាលើកទីមួយ ។ នៅឆ្នាំ ១៩៩៨ មូលនិធិបរិស្ថានពិភពលោក (Global Environmental Facity, GEF) និងកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (United Nations Development Programme, UNDP) បានអនុម័តផ្តល់ជំនួយធំនួន ៣២ម៉ឺនដុល្លារអាមេរិច ដើម្បីឱ្យកម្ពុជា រៀបចំរបាយការណ៍ជាតិលើកទីមួយរបស់ខ្លួនសម្រាប់ដាក់ជូនសម័យប្រជុំប្រចាំឆ្នាំនៃភាគីជាសមាជិករបស់អនុសញ្ញា។ យើងបានប្រើប្រាស់ជំនួយនេះសម្រាប់ការធ្វើសារពើភ័ណ្ឌឧស្ម័នផ្ទះកញ្ចក់ជាលើកដំបូងនៅកម្ពុជា ដែលបានកំណត់ឃើញថា នៅឆ្នាំ ១៩៩៤ ប្រទេសកម្ពុជាបានបញ្ចេញឧស្ម័នផ្ទះកញ្ចក់ចំនួនប្រមាណ ៦០ លានតោន ហើយព្រៃឈើយើង

ស្រូបយកឧស្ម័នកាបូនិចពីបរិយាកាស ចំនួនប្រមាណ ៦៥ លានតោន។ គម្រោងនេះគឺជាជំហានជាក់ស្តែងទីមួយ នៃការអនុវត្តន៍ អនុសញ្ញាស្តីពីការប្រែប្រួលអាកាសធាតុនៅកម្ពុជា ។

ពិតមែនតែកិច្ចការប្រែប្រួលអាកាសធាតុពុំមែនជាទិសដៅពិសេស ដោយឡែករបស់រាជរដ្ឋាភិបាលក៏បណ្តាសកម្មភាព និងវិធានការជាច្រើនរបស់រាជរដ្ឋាភិបាល បានរួមចំណែកនៅក្នុងកិច្ចប្រឹងប្រែងជាសកល សំដៅបាននូវគោលដៅនានារបស់អនុសញ្ញា បណ្តាកិច្ចប្រឹងប្រែងទាំងនេះរួមមាន គោលនយោបាយ និងសកម្មភាពគម្រោងនានា នៅក្នុងវិស័យព្រៃឈើ និងថាមពល ដូចជាការរង្កើត និងគ្រប់គ្រងតំបន់ការពារធម្មជាតិចំនួន ២៣ ដែលគ្របដណ្តប់ លើផ្ទៃដីប្រមាណ ១៨% នៃផ្ទៃប្រទេស ការរៀបចំបណ្តាបវិធានច្បាប់នានាទាក់ទងនឹងការគ្រប់គ្រងព្រៃឈើ ការគ្រប់គ្រងសំណល់ និងការត្រួតពិនិត្យការបំពុល កិច្ចប្រឹងប្រែងបច្ចុប្បន្នសំដៅលុបបំបាត់ការកាប់ឈើ និងការជួញដូរសត្វព្រៃខុសច្បាប់ ព្រមទាំងសកម្មភាពរបស់រាជរដ្ឋាភិបាល ក្នុងការជំរុញការអភិវឌ្ឍន៍ថាមពលកើតឡើងវិញ និងបច្ចេកវិជ្ជាស្អាត ហើយមានប្រសិទ្ធិភាពខ្ពស់ នៅក្នុងវិស័យថាមពល ។

ព្រះរាជាណាចក្រកម្ពុជាបានគាំទ្រយ៉ាងសកម្ម ដល់ការជំរុញអនុវត្តពិធីសារក្យូតូឱ្យបានឆាប់តាមដែលអាចធ្វើបាន សំដៅរៀបចំនូវមូលដ្ឋានគ្រឹះ ដំបូងឈានទៅសម្រេចបាននូវគោលដៅចុងក្រោយរបស់អនុសញ្ញាស្តីពីការប្រែប្រួលអាកាសធាតុ ដូចដែលសម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន ធ្លាប់បានមានប្រសាសន៍នៅ ក្នុងកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីបរិស្ថានប្រទេសអាស៊ាននៅទីក្រុងភ្នំពេញ កាលពីខែឧសភា ឆ្នាំ ២០០១ ក៏ដូជានៅក្នុងកិច្ចប្រជុំកំពូលមហាអនុតំបន់ទន្លេមេគង្គលើកទី ១ កាលពីមុងឆ្នាំ ២០០២ នៅក្រុងភ្នំពេញ នឹងក្នុងឱកាសបើកកិច្ចប្រជុំឆ្នាំបរិស្ថានអាស៊ាន ២០០៣ នៅអង្គរវត្ត កាលពីដើមខែមីនា ឆ្នាំ ២០០៣ ថ្មីៗនេះ ។

ប្រទេសកម្ពុជាក៏បានគាំទ្រផងដែរក្នុងការដាក់បញ្ចូលព្រៃឈើ ជាអាងផ្ទុកកាបូន ក្នុងគោលដៅកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់ នៅក្រោមពិធីសារក្យូតូ ដែល ជាការលើកទឹកចិត្តជំរុញឱ្យមានការថែរក្សាព្រៃឈើនៅលើពិភពលោក។ កម្ពុជាបានស្នើឡើងថា ចាំបាច់ត្រូវពិចារណាលើតួនាទីរបស់ព្រៃឈើនៅក្នុងបរិបទ ដ៏ទូលំទូលាយមួយ គឺពុំត្រឹមតែជាភ្នាក់ងារសម្អាតបរិយាកាសប៉ុណ្ណោះទេ ប៉ុន្តែត្រូវពិនិត្យលើពហុយោជន៍ច្រើនយ៉ាងផ្សេងទៀតរបស់ព្រៃឈើ ទាំងផ្នែកសេដ្ឋកិច្ច បរិស្ថាន សំរាលគ្រោះធម្មជាតិនានា ដូចជាគ្រោះទឹកជំនន់ និងព្យុះជាដើម។ លើសពីនេះ ការប្រើប្រាស់ព្រៃឈើជាអាងផ្ទុកកាបូនក៏អាច ចូលរួមចំណែកក្នុងកិច្ចការពារព្រៃឈើ សម្រាប់ផលប្រយោជន៍ និងសេវាកម្មបរិស្ថានជាច្រើនទៀតផងដែរ ។ ទោះជាយ៉ាងណាក្តីភាគចំណែក បានដែលត្រូវយកមកប្រើសំរាកលំអអាងផ្ទុកកាបូន ពុំត្រូវធ្វើឱ្យមានការខូចខាតដល់កិច្ចប្រឹងប្រែងកាត់បន្ថយការបញ្ចេញឧស្ម័ន តាមរយៈការជំរុញការប្រើប្រាស់ថាមពល កើតឡើងវិញ ប្រសិទ្ធិភាពថាមពល និងការផ្ទេរបច្ចេកវិជ្ជាទៅឱ្យប្រទេសក្រីក្រឡើយ។ ប្រទេសកម្ពុជាចាត់ទុកថា សម្រាប់បណ្តាប្រទេសកំពុង

អភិវឌ្ឍន៍ទាំងអស់ វិធានការកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់ណាមួយ ត្រូវតែផ្តល់ឱកាសដល់ បណ្តាប្រទេសទាំងនោះ ក្នុងការសម្រេចបាននូវគោលដៅអភិវឌ្ឍន៍នានារបស់ខ្លួន ។

## ៤. ការលានុបត្តភាពដល់កម្ពុជាអាចទទួលបានពីពិធីសារក្យូតូ

សម្រាប់កម្ពុជា ការចូលជាសមាជិករបស់ពិធីសារនេះ អាចនឹងនាំមកនូវសារៈប្រយោជន៍ច្រើនយ៉ាងដូចជា៖

១. ក្នុងនាមជាប្រទេសកំពុងអភិវឌ្ឍន៍ កម្ពុជាពុំមានជាប់កាតព្វកិច្ចកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់ទ

២. ក្នុងនាមជាប្រទេសកំពុងអភិវឌ្ឍន៍ ពុំតម្រូវឱ្យកម្ពុជាបង់ជាវិភាគទាន ឬចំណាយណាមួយឡើយ

៣. ទទួលផលចំណេញផ្នែកនយោបាយ :

- បង្ហាញពីសុច្ឆទៈ និងការប្តេជ្ញាចិត្ត ក្នុងការរួមចំណែកជាមួយសហគមន៍អន្តរជាតិ ដើម្បីដោះស្រាយបញ្ហាប្រប្រួលអាកាសធាតុ
- លើកកម្ពស់កិត្យានុភាពជាតិ តាមរយៈការចូលរួមប្រជុំដែលរៀបចំឡើងសម្រាប់ពិភាក្សាដោះស្រាយបញ្ហាប្រប្រួលអាកាសធាតុ

៤. ទទួលផលចំណេញ រី ផ្នែកបរិស្ថាន ៖

- រួមចំណែកដោះនស្រាយបញ្ហាអាកាសធាតុមិនប្រក្រតីនៅកម្ពុជា ព្រះអាកាសធាតុកម្ពុជាមិនរវាចកាត់ផ្តាច់ពីរវាកាសធាតុឡើយ
- អាចទទួលជំនួយពីប្រទេសអ្នកមាន និងអង្គការអន្តរជាតិនានា សម្រាប់បណ្តាគម្រោងទប់ស្កាត់ការបំពុលបរិយាកាសនៅទីក្រុង ព្រៃឈើ ការដាំដើមឈើឡើងវិញ ការគ្រប់គ្រងការប្រើប្រាស់ដីធ្លី ការរៀបចំផែនការបន្សាំ (adaptation plan) ទៅនឹងការប្រែប្រួលអាកាសធាតុ ។ល ។

៥. ទទួលបានផលចំណេញផ្នែកសេដ្ឋកិច្ច ៖

- អាចចូលរួមក្នុងការអនុវត្តន៍គម្រោងក្រោមយន្តការអភិវឌ្ឍន៍ស្អាតទាក់ទងនឹង ការសន្សំសំចៃថាមពល ប្រសិទ្ធិភាពថាមពល បច្ចេកវិជ្ជាផលិតកម្មស្អាតដែលមិនបំផ្លាញបរិស្ថានក្នុងវិស័យឧស្សាហកម្ម ការអភិវឌ្ឍន៍ថាមពលកើតឡើងវិញ (renewable energy) គម្រោងការពារ និងដាំព្រៃឈើ ការកែលំអវិស័យគមនាគមន៍ ។
- ទទួលការគាំទ្រផ្នែកស្រាវជ្រាវ និងសង្កេតតាមដានអាកាសធាតុ ដែលមានសារៈសំខាន់បំផុតសម្រាប់ប្រទេសកម្ពុជា ដែលមានសេដ្ឋកិច្ចពឹងផ្អែកលើវិស័យកសិកម្ម
- ទទួលការគាំទ្រផ្នែកបណ្តុះបណ្តាលធនធានមនុស្ស ។

ជារួម ការចូលជាសមាជិក នៃពិធីសារនេះ ពុំនាំមកនូវផលវិបាកជាអវិជ្ជមានណាមួយដល់ការអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គមរបស់កម្ពុជាឡើយ ។ ផ្ទុយទៅវិញ គឺជាឱកាសដ៏ល្អមួយ ដែលអនុញ្ញាតឱ្យកម្ពុជាទទួលបាននូវផលចំណេញលើវិស័យជាច្រើន ដូចបានរៀបរាប់ខាងលើ ដែលជាទុនយ៉ាងសំខាន់សម្រាប់រាជរដ្ឋាភិបាល ក្នុងការអនុវត្តកម្មវិធីកាត់បន្ថយភាពក្រីក្រ ការពារបរិស្ថាន និងធនធានធម្មជាតិ ឆ្ពោះទៅសម្រេចបាននូវការអភិវឌ្ឍន៍ប្រទេសប្រកបដោយចីរភាព ។

# មេរៀនទី ៤ កិច្ចព្រមព្រៀងទីក្រុងបារីស៍

បណ្តាភាគីក្នុងកិច្ចព្រមព្រៀងនេះ

ក្នុងនាមភាគីនៃអនុសញ្ញាក្របខណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ ដែលចាប់ពីនេះទៅហៅថា"អនុសញ្ញានេះ" អនុលោមតាម វេទិកាទីក្រុងឌូបានសម្រាប់ការពង្រឹងសកម្មភាព ដែលបានបង្កើតឡើងដោយសេចក្តីសម្រេច1/CP.17 នៃសន្និសីទបណ្តាភាគីក្នុងអនុសញ្ញានេះនាសម័យប្រជុំលើកទីដប់ប្រាំពីររបស់ខ្លួន នៅក្នុងការជំរុញ គោលបំណងអនុសញ្ញានេះ និងស្របតាមគោលការណ៍នៃអនុសញ្ញានេះ ដែលរួមបញ្ចូលទាំងគោលការណ៍ សមធម៌ និងការទទួលខុសត្រូវរួម តែក្នុងកម្រិតផ្សេងគ្នា អាស្រ័យលើសមត្ថភាព និងកាលៈទេសៈរបស់ប្រទេសរៀងៗខ្លួន ដោយទទួលស្គាល់ ភាពចាំបាច់ឱ្យមានការឆ្លើយតបប្រកបដោយប្រសិទ្ធភាព និងវឌ្ឍនភាពទៅនឹងការគំរាមកំហែងបន្ទាន់ពី ការប្រែប្រួលអាកាសធាតុដោយផ្អែកលើមូលដ្ឋាននៃចំណេះដឹងវិទ្យាសាស្ត្រថ្មីៗបំផុតដែលមាន ដោយទទួលស្គាល់ផងដែរ នូវតម្រូវការជាក់លាក់ និងកាលៈទេសៈពិសេសរបស់បណ្តាភាគីប្រទេសកំពុងអភិវឌ្ឍន៍ ជាពិសេសa បណ្តាប្រទេសដែលងាយរងគ្រោះនៅចំពោះមុខផលប៉ះពាល់ធ្ងន់ធ្ងរនៃការប្រែប្រួលអាកាសធាតុ ដូចមានចែងក្នុងអនុសញ្ញានេះ ដោយពិចារណាពេញលេញលើតម្រូវការជាក់លាក់ និងស្ថានភាពពិសេសរបស់បណ្តាប្រទេសអភិវឌ្ឍន៍តិចតួច ដែលទាក់ទង នឹងការផ្តល់មូលនិធិ និងការផ្ទេរបច្ចេកវិទ្យា ដោយទទួលស្គាល់ បណ្តាភាគីអាចទទួលរងនូវផលប៉ះពាល់ មិនត្រឹមតែដោយសារការប្រែប្រួលអាកាសធាតុប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងដោយសារផលប៉ះពាល់នៃការបាត់វិធានការនៅក្នុងការឆ្លើយតបផងដែរដោយសង្កត់ធ្ងន់ លើទំនាក់ទំនងសំខាន់ៗដែលកើតមានរវាងផលប៉ះពាល់ ការឆ្លើយតប និងសកម្មភាពការប្រែប្រួលអាកាសធាតុ ជាមួយការទទួលបាននូវសមធម៌ក្នុងការអភិវឌ្ឍដោយចីរភាព និងការលុបបំបាត់ភាពក្រីក ដោយទទួលស្គាល់ អាទិភាពជាមូលដ្ឋាននៃការធានាសន្តិសុខស្បៀង និងការបញ្ចប់ភាពអត់ឃ្លាន ហើយជាពិសេសភាព ងាយរងគ្រោះនៃប្រព័ន្ធផលិតកម្មស្បៀងនៅចំពោះមុខផលប៉ះពាល់ធ្ងន់ធ្ងរនៃការប្រែប្រួលអាកាសធាតុ ដោយពិចារណាពី កត្តាចាំបាច់នៃកម្លាំងពលកម្មអន្តរកាលសមស្រប និងការបង្កើតការងារសមរម្យ ព្រមទាំងការងារប្រកប ដោយគុណភាព ស្របតាមអាទិភាពអភិវឌ្ឍន៍ជាតិ ដោយទទួលស្គាល់ ការប្រែប្រួលអាកាសធាតុគឺជាក្តីកង្វល់រួមមួយរបស់មនុស្សជាតិ ដែលនៅពេលចាត់វិធានការឆ្លើយតបនឹង ការប្រែប្រួលអាកាសធាតុ បណ្តាភាគីគួរតែគោរពជំរុញ និងគិតគូរអំពីកាតព្វកិច្ចរៀងៗខ្លួនចំពោះសិទ្ធិមនុស្ស សិទ្ធិទទួលបានសេវាសុខភាព សិទ្ធិរបស់ជនជាតិដើមភាគតិច សហគមន៍មូលដ្ឋាន ជនចំណាកស្រុក កុមារ ជនពិការ និងប្រជាជនដែលស្ថិត ក្នុងស្ថានភាពងាយរងគ្រោះ និងសិទ្ធិទទួលបានការអភិវឌ្ឍ ក៏ដូចជា សមភាពយេនឌ័រ សិទ្ធិអំណាចរបស់ស្ត្រី និងសមធម៌រវាង ជំនាន់មនុស្ស ដោយទទួលស្គាល់សារៈសំខាន់នៃការអភិរក្ស និងការបង្កើនអាងស្រូប និងអាងស្តុកឧស្ម័នផ្ទះកញ្ចក់ ទៅតាមករណីសមស្រប ដូចមានយោងក្នុងអនុសញ្ញានេះ ដោយកត់សម្គាល់ ពីសារៈសំខាន់នៃការធានាបូរណភាពប្រព័ន្ធអេកូឡូស៊ីទាំងអស់ រួមទាំងមហាសមុទ្រ

និងកិច្ចការពារ ជីវៈចម្រុះ ដែលត្រូវបានទទួលស្គាល់ដោយវប្បធម៌មួយចំនួនថាជា មាតាពិភពលោក និងការកត់សម្គាល់ពីសារៈសំខាន់ន ទស្សនទានមួយចំនួនស្តីពី "យុត្តិធម៌អាកាសធាតុ" នៅពេលចាត់វិធានការដើម្បីដោះស្រាយការប្រែប្រួលអាកាសធាតុ ដោយអះអាង ពីសារៈសំខាន់នៃការអប់រំ ការបណ្តុះបណ្តាលការយល់ដឹងសាធារណៈ ការចូលរួមជាសាធារណៈ ការទទួលបានព័ត៌មាន និងកិច្ចសហប្រតិបត្តិការពីសាធារណជនគ្រប់លំដាប់ថ្នាក់លើកិច្ចការនានាដែលមានចែងក្នុងកិច្ចព្រមព្រៀងនេះ ដោយទទួលស្គាល់ពីសារៈសំខាន់នៃការចូលរួមរបស់រដ្ឋាភិបាលនៅគ្រប់លំដាប់ថ្នាក់ និងភ្នាក់ងារនានា អនុលោមតាមច្បាប់ជាតិរបស់ភាគីនីមួយៗ នៅក្នុងការដោះស្រាយបញ្ហាប្រែប្រួលអាកាសធាតុដោយទទួលស្គាល់ផងដែរថារបៀបរស់នៅប្រកបដោយនិរន្តរភាព ព្រមទាំងគំរូនៃផលិតកម្មនិងការប្រើប្រាស់ប្រកបដោយចីរភាព ដែលមានបណ្តាភាគីប្រទេសអភិវឌ្ឍន៍កំពុងឈានមុខ ត្រូវដើរតួនាទីយ៉ាងសំខាន់ក្នុងការដោះស្រាយបញ្ហាប្រែប្រួលអាកាសធាតុ។

## បានឯកភាពគ្នាដូចតទៅ៖

## មាត្រា១

សម្រាប់គោលបំណងនៃកិច្ចព្រមព្រៀងនេះ និយមន័យដូចមានចែងក្នុងមាត្រា១ នៃអនុសញ្ញានេះ នឹងត្រូវយកមកអនុវត្ត។ លើសពីនេះ៖

(ក) អនុសញ្ញា″ មានន័យថា អនុសញ្ញាក្របខណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុដែលបានអនុម័តនៅទីក្រុងញ៉ូវយ៉ក កាលពីថ្ងៃទី៩ ខែឧសភា ឆ្នាំ១៩៩២

(ខ) "សន្និសីទបណ្តាភាគី″ មានន័យថា សន្និសីទនបណ្តាភាគីក្នុងអនុសញ្ញានេះ

(គ) ភាគី″ មានន័យថា ភាគីណាមួយក្នុងកិច្ចព្រមព្រៀងនេះ

## មាត្រា២

១. នៅក្នុងការពង្រឹងការអនុវត្តអនុសញ្ញានេះរួមទាំងគោលដៅរបស់វា កិច្ចព្រមព្រៀងនេះមានគោលបំណងពង្រឹងការឆ្លើយតបជាសកលទៅនឹងការគំរាមកំហែងនៃការប្រែប្រួលអាកាសធាតុ នៅក្នុងបរិបទនៃការអភិវឌ្ឍដោយចីរភាព និងកិច្ចខិតខំប្រឹងប្រែងដើម្បីលុបបំបាត់ភាពក្រីក្រ ដែលរួមមាន៖

(ក) ការកំហិតកំណើនសីតុណ្ហភាពមធ្យមលើពិភពលោកឱ្យនៅត្រឹមក្រោម ២◦C ខ្ពស់ជាងកម្រិតសីតុណ្ហភាពនៅមុនបដិវត្តន៍ ឧស្សាហកម្ម និងការជំរុញកិច្ចប្រឹងប្រែងដើម្បីកំហិតកំណើនសីតុណ្ហភាពឱ្យនៅត្រឹម១,៥ ◦C ខ្ពស់ជាងកម្រិតសីតុណ្ហ ភាពនៅមុនបដិវត្តន៍ឧស្សាហកម្ម ដោយទទួល

ស្គាល់ថា ការធ្វើបែបនេះអាចកាត់បន្ថយយ៉ាងច្រើននូវហានិភ័យ និង ផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ

(ខ) ការបង្កើនសមត្ថភាពដើម្បីបន្សាំទៅនឹងផលប៉ះពាល់ធ្ងន់ធ្ងរនៃការប្រែប្រួលអាកាសធាតុ និង ពង្រឹងភាពធន់នឹងអាកាសធាតុនិងការអភិវឌ្ឍដែលបញ្ចេញឧស្ម័នផ្ទះកញ្ចក់កម្រិតទាប តាមវិធីដែលមិនបង្កការគំរាមកំហែងចំពោះផលិតកម្មស្បៀង

(គ) ការធ្វើឱ្យលំហូរហិរញ្ញវត្ថុមានសង្គតិភាពជាមួយមាគ៌ាឆ្ពោះទៅរកការបញ្ចេញឧស្ម័នផ្ទះកញ្ចក់កម្រិតទាប និងការអភិវឌ្ឍដែលធន់នឹងអាកាសធាតុ

២. កិច្ចព្រមព្រៀងនេះនឹងត្រូវអនុវត្ត ដើម្បីឆ្លុះបញ្ចាំងសមធម៌ និងគោលការណ៍រួម តែនៅកម្រិតនៃការទទួលខុសត្រូវផ្សេងៗគ្នា និងសមត្ថភាពរៀងៗខ្លួន ដោយគិតគូរផងដែរអំពីកាលៈទេសៈខុសៗគ្នារបស់ប្រទេស។

## មាត្រា៣

ដូចមានចែងនៅក្នុងការរួមចំណែកប្ដេជ្ញាអនុវត្តនៅថ្នាក់ជាតិ សម្រាប់ការឆ្លើយតបជាសកលទៅនឹងការប្រែប្រួលអាកាសធាតុ ភាគីទាំងអស់ត្រូវអនុវត្ត និងរាយការណ៍អំពីកិច្ចប្រឹងប្រែងប្រកបដោយមហិច្ចតា ដូចមានចែងក្នុងមាត្រា៤, ៧៩, ១០, ១១ និង ១៣ ដើម្បីសម្រេចឱ្យបាននូវគោលបំណងនៃកិច្ចព្រមព្រៀងនេះ ដូចមានចែងក្នុងមាត្រា២។ កិច្ចប្រឹងប្រែងរបស់បណ្ដាភាគីទាំងអស់ ត្រូវឆ្លុះបញ្ចាំងពីការរីកចម្រើនជាបន្តបន្ទាប់ ទន្ទឹមនឹងការទទួលស្គាល់នូវតម្រូវការចាំបាច់ ដើម្បីគាំទ្រដល់បណ្ដាភាគីប្រទេសកំពុងអភិវឌ្ឍន៍ ដើម្បីអនុវត្តកិច្ចព្រមព្រៀងនេះដោយប្រសិទ្ធភាព។

## មាត្រា៤

១. ដើម្បីសម្រេចបានគោលបំណងសីតុណ្ហភាពរយៈពេលវែង ដូចមានចែងក្នុងមាត្រា២ ភាគីនានាមានបំណងឈានឱ្យដល់កម្រិត ខ្ពស់បំផុតជាសកលនៃការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ឱ្យបានឆាប់បំផុតតាមតែអាចធ្វើទៅបាន ដោយទទួលស្គាល់ថា សម្រាប់បណ្ដាភាគីប្រទេសកំពុងអភិវឌ្ឍន៍ ការឈានដល់កម្រិតកំពូលបែបនេះនឹងត្រូវទាមទាររយៈពេលវែងជាង និងត្រូវកាត់បន្ថយឱ្យបានឆាប់ រហ័សនូវការបញ្ចេញចាប់ពីដំណាក់កាលនោះតទៅដោយអនុលោមតាមវិទ្យាសាស្ត្រថ្មីៗបំផុតដែលមាន ដើម្បីអាចសម្រេចបានតុល្យភាពមួយរវាងការបញ្ចេញដោយសារសកម្មភាពមនុស្ស ដោយគិតតាមប្រភព និងអាងស្រូបឧស្ម័នផ្ទះ

កញ្ចក់ នៅក្នុងពាក់កណ្តាលទី២នៃសតវត្សរ៍នេះ ដោយផ្អែកលើសមធម៌ និងនៅក្នុងបរិបទនៃការអភិវឌ្ឍ ដោយចីរភាព និងកិច្ចខិតខំប្រឹងប្រែងដើម្បី លុបបំបាត់ភាពក្រីក្រ។

២. ភាគីនីមួយៗត្រូវរៀបចំជូនដំណឹង និងរក្សាទុកបរិមាណនៃការរួមចំណែកប្តេជ្ញាអនុវត្តនៅថ្នាក់ជាតិជាបន្តបន្ទាប់ ដែលគ្រោងសម្រេចឱ្យបាន។ ភាគីនានាត្រូវចាត់វិធានការកាត់បន្ថយការប្រែប្រួលអាកាសធាតុនៅក្នុងប្រទេស ក្នុងគោលបំណងសម្រេចគោល ដៅនៃការរួមចំណែកទាំងនោះ។

៣. ការរួមចំណែកជាអនុវត្តនៅថ្នាក់ជាតិរបស់ភាគីនីមួយៗ នឹងតំណាងឱ្យការរីកចម្រើនជាបន្តបន្ទាប់ និងនៅកម្រិតខ្ពស់ជាងកម្រិត ការរួមចំណែកប្តេជ្ញាអនុវត្តនៅថ្នាក់ជាតិលើកមុនៗរបស់ខ្លួន ព្រមទាំងត្រូវឆ្លុះបញ្ចាំងមហិច្ចតាខ្ពស់បំផុតដែលខ្លួនអាចសម្រេចបាន ដែលបញ្ជាក់ពីការទទួលខុសត្រូវរួម តែក្នុងកម្រិតខុសៗគ្នា និងទៅតាមសមត្ថភាពរៀងៗខ្លួន ដោយគិតពីកាលៈទេសៈខុសៗគ្ន របស់ប្រទេសនីមួយៗ។

៤. បណ្តាភាគីប្រទេសអភិវឌ្ឍន៍ ត្រូវបន្តឈានមុខ ដោយអនុវត្តចំណុចដៅកាត់បន្ថយការបញ្ចេញដាច់ខាតនៅគ្រប់ផ្នែកសេដ្ឋកិច្ច។ បណ្តាភាគីប្រទេសកំពុងអភិវឌ្ឍន៍ គួរបន្តពង្រឹងកិច្ចប្រឹងប្រែងកាត់បន្ថយការបញ្ចេញរបស់ខ្លួន និងត្រូវបា កចិត្តឱ្យឈានជាបន្តបន្ទាប់ឆ្ពោះទៅសម្រេចចំណុចដៅកាត់បន្ថយឬកម្រិតលើការបញ្ចេញនៅគ្រប់ផ្នែកសេដ្ឋកិច្ច ដោយគិតគូរផងដែរពីកាលៈទេសៈខុសៗគ្នារបស់ប្រទេសនីមួយៗ។

៥. ការគាំទ្រគួរតែបានផ្តល់ឱ្យបណ្តាភាគីប្រទេសកំពុងអភិវឌ្ឍន៍ សម្រាប់ការអនុវត្តមាត្រានេះ ដោយអនុលោមតាមមាត្រា៩ ១០ និង ១១ ដោយទទួលស្គាល់ថា ការពង្រឹងកិច្ចគាំទ្រដល់បណ្តាភាគីប្រទេសកំពុងអភិវឌ្ឍន៍នឹងអាចជួយធ្វើឱ្យមហិច្ចតានៃសកម្មភាពរបស់បណ្តាភាគីប្រទេសទាំងនោះស្ថិតនៅកម្រិតខ្ពស់ជាងមុន។

៦. បណ្តាប្រទេសអភិវឌ្ឍន៍តិចតួច និងបណ្តារដ្ឋកូនកោះកំពុងអភិវឌ្ឍន៍អាចរៀបចំ និងផ្សព្វផ្សាយយុទ្ធសាស្ត្រ ផែនការ និងសកម្មភាពនានាសម្រាប់ការអភិវឌ្ឍដោយបញ្ចេញឧស្ម័នផ្ទះកញ្ចក់កម្រិតទាប ដែលឆ្លុះបញ្ចាំងពីកាលៈទេសៈពិសេសរបស់ខ្លួន។

៧. សហអត្ថប្រយោជន៍នៃការកាត់បន្ថយដែលកើតចេញពីសកម្មភាពបន្សុាំ និង/ឬផែនការពិពិធកម្មសេដ្ឋកិច្ចរបស់បណ្តាភាគី អាចរួមចំណែកទៅក្នុងលទ្ធផលនៃការកាត់បន្ថយដូចមានចែងក្នុងមាត្រានេះ។

៨. នៅក្នុងការធ្វើរបាយការណ៍អំពីការរួមចំណែកប្តេជ្ញាអនុវត្តនៅថ្នាក់ជាតិរបស់ខ្លួន ភាគីទាំងអស់ត្រូវផ្តល់ព័ត៌មានចាំបាច់សម្រាប់ភាពច្បាស់លាស់ តម្លាភាពនិងការយល់ដឹង អនុលោមតាមសេចក្តីសម្រេច /CP.21 និងសេចក្តីសម្រេចពាក់ព័ន្ធនានានៃសន្និសីទបណ្តាភាគីដែលមាននាទីជាកិច្ចប្រជុំបណ្តាភាគីក្នុងកិច្ចព្រមព្រៀងនេះ។

៩. ភាគីនីមួយៗ ត្រូវធ្វើរបាយការណ៍អំពី ការរួមចំណែកប្តេជ្ញាអនុវត្តនៅថ្នាក់ជាតិរៀងរាល់ប្រាំឆ្នាំម្តងអនុលោមតាមសេចក្តីសម្រេច I/CP.21 និងសេចក្តីសម្រេចពាក់ព័ន្ធនានានៃសន្និសីទបណ្តាភាគីដែលមាននាទីជាកិច្ចប្រជុំបណ្តាភាគីក្នុងកិច្ចព្រមព្រៀងនេះ ហើយ ត្រូវបានទទួលព័ត៌មានតាមរយៈលទ្ធផលនៃរបាយការណ៍សំយោគជាសកល ដូចមានចែងក្នុងមាត្រា១៤។

១០. នៅក្នុងសម័យប្រជុំលើកទីមួយរបស់ខ្លួន សន្និសីទបណ្តាភាគីដែលមាននាទីជាកិច្ចប្រជុំបណ្តាភាគីក្នុងកិច្ចព្រមព្រៀងនេះ ត្រូវពិចារណាអំពីក្របខ័ណ្ឌពេលវេលារួម សម្រាប់ការរួមចំណែកប្តេជ្ញាអនុវត្តនៅថ្នាក់ជាតិ។

១១. ភាគីមួយ អាចធ្វើការកែសម្រួលការរួមចំណែកប្តេជ្ញាអនុវត្តនៅថ្នាក់ជាតិដែលមានស្រាប់របស់ខ្លួនគ្រប់ពេលវេលា ក្នុងបំណងបង្កើន កម្រិតមហិច្ឆតារបស់ខ្លួន ស្របតាមសេចក្តីណែនាំដែលបានអនុម័តដោយសន្និសីទបណ្តាភាគីដែលមាននាទីជាកិច្ចប្រជុំបណ្តាភាគីក្នុងកិច្ចព្រមព្រៀងនេះ។

១២. ការរួមចំណែកប្តេជ្ញាអនុវត្តនៅថ្នាក់ជាតិដែលបណ្តាភាគីបានរាយការណ៍ ត្រូវតែបានកត់ត្រាទុកនៅក្នុងបញ្ជីសាធារណៈមួយដែលរក្សាទុកដោយលេខាធិការដ្ឋាន។

១៣. បណ្តាភាគីត្រូវកត់ត្រាការរួមចំណែកប្តេជ្ញាអនុវត្តនៅថ្នាក់ជាតិរបស់ខ្លួន។ នៅក្នុងការគណនាការស្រូប និងការបញ្ចេញឧស្ម័នផ្ទះ កញ្ចក់ដោយសកម្មភាពមនុស្ស ដែលត្រូវគ្នានឹងរបាយការណ៍រួមចំណែកប្តេជ្ញាអនុវត្តនៅថ្នាក់ជាតិរបស់ខ្លួន បណ្តាភាគីត្រូវលើក កម្ពស់បូរណភាពបរិស្ថាន តម្លាភាព សុក្រិតភាព ភាពពេញលេញ ភាពអាចប្រៀបធៀបបាន និងសង្គតិភាព ហើយត្រូវបញ្ចៀសការគណនាទ្វេដង ដោយគោរពតាមសេចក្តីណែនាំដែលបានអនុម័តដោយសន្និសីទបណ្តាភាគីដែលមាននាទីជាកិច្ចប្រជុំបណ្តាភាគីក្នុងកិច្ចព្រមព្រៀងនេះ។

១៤. នៅក្នុងបរិបទនៃការរួមចំណែកប្តេជ្ញាអនុវត្តនៅថ្នាក់ជាតិ នៅពេលមានការទទួលស្គាល់ និងការអនុវត្តសកម្មភាពកាត់បន្ថយ ដែលទាក់ទងនឹងការស្រូប និងការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ដោយសកម្មភាពមនុស្ស បណ្តាកាគីត្រូវយកចិត្តទុកដាក់ចំពោះវិធីសាស្ត្រ និងការណែនាំដែលមានស្រាប់នានានៅក្រោមអនុសញ្ញានេះ ទៅតាមករណីសមស្រប ដោយយោងតាមប្រការនានាដែលមានចែង ក្នុងកថាខណ្ឌ ១៣ នៃមាត្រានេះ។

១៥. នៅក្នុងការអនុវត្តកិច្ចព្រមព្រៀងនេះ បណ្តាភាគីត្រូវយកចិត្តទុកដាក់ចំពោះកង្វល់របស់បណ្តាភាគីដែលមានសេដ្ឋកិច្ចរងផលប៉ះ ពាល់ខ្លាំងបំផុតដោយសារឥទ្ធិពលនៃវិធានការឆ្លើយតប ជាពិសេស បណ្តាភាគីប្រទេសកំពុងអភិវឌ្ឍន៍។

១៦. បណ្តាភាគី រួមទាំងអង្គការសមាហរណកម្មសេដ្ឋកិច្ចតំបន់ និងរដ្ឋជាសមាជិកនៃអង្គការនោះ ដែលបានឈានដល់កិច្ចព្រមព្រៀង ធ្វើសកម្មភាពរួមគ្នា ដូចមាននៅក្នុងកថាខណ្ឌ២ នៃមាត្រានេះ ត្រូវជូនដំណឹងទៅកាន់លេខាធិការដ្ឋានអំពីលក្ខខណ្ឌនៃកិច្ចព្រម ព្រៀងនោះ រួមទាំងកម្រិតបញ្ចេញ ដែលបានកំណត់ សម្រាប់ភាគីនីមួយៗនៅក្នុងអំឡុងពេលពាក់ព័ន្ធ នៅពេលដែលភាគីទាំង នោះធ្វើរបាយការណ៍រួមចំណែកប្តេជ្ញាអនុវត្តនៅថ្នាក់ជាតិរបស់ខ្លួន។ លេខាធិការដ្ឋានត្រូវជូនដំណឹងដល់បណ្តាភាគី និងហត្ថលេខីនៃអនុសញ្ញានេះ អំពីលក្ខខណ្ឌនៃកិច្ចព្រមព្រៀងនោះ។

១៧. ភាគីនីមួយៗនៅក្នុងកិច្ចព្រមព្រៀងណាមួយ ត្រូវមានទំនួលខុសត្រូវលើកម្រិតនៃការបញ្ចេញរបស់ខ្លួន ដូចមានចែងនៅក្នុងកិច្ចព្រម ព្រៀង ដោយយោងតាមកថាខណ្ឌ១៦ ខាងលើ អនុលោមតាមកថាខណ្ឌ១៣ និង ១៤ នៃមាត្រានេះ ព្រមទាំងមាត្រា១៣ និង ១៥។

១៨. ប្រសិនបើភាគីដែលធ្វើសកម្មភាពរួមគ្នានៅក្នុងក្របខណ្ឌ នៃអង្គការសមាហរណកម្មសេដ្ឋកិច្ចតំបន់ជាមួយគ្នា ដែលជាភាគីមួយនៃ កិច្ចព្រមព្រៀងនេះ រដ្ឋជាសមាជិកនីមួយៗរៀងខ្លួននៃអង្គការសមាហរកម្មសេដ្ឋកិច្ចតំបន់ និងជាមួយអង្គការសមាហរកម្មសេដ្ឋកិច្ចតំបន់ ត្រូវមានការទទួលខុសត្រូវលើកម្រិតនៃការបញ្ចេញរបស់ខ្លួន ដូចមានចែងនៅក្នុងកិច្ចព្រមព្រៀងដែលនៅក្នុងរបាយការណ៍ ក្រោមកថាខណ្ឌ១៦ នៃមាត្រានេះ អនុលោមតាមកថាខណ្ឌ១៣ និង ១៤ នៃមាត្រានេះ និងមាត្រា១៣ និង ១៥។

១៩. ភាគីទាំងអស់គួរប្រឹងប្រែងរៀបចំ និងធ្វើរបាយការណ៍ពីយុទ្ធសាស្ត្រអភិវឌ្ឍន៍ដែលបញ្ចេញឧស្ម័នផ្ទះកញ្ចក់ ទាបសម្រាប់រយៈពេលវែង ដោយត្រូវគិតដល់មាត្រា២ និងត្រូវពិចារណាអំពីការទទួលខុសត្រូវរួម តែក្នុងកម្រិតខុសៗគ្នា និងទៅតាមសមត្ថភាពរៀងៗខ្លួនដោយគិតពីកាលៈទេសៈខុសៗគ្នារបស់ប្រទេសនីមួយៗ។

## មាត្រា ៥

១. បណ្តាភាគីគួរចាត់វិធានការដើម្បីអភិរក្ស និងបង្កើនអាងស្រូប និងអាងស្តុកឧស្ម័នផ្ទះកញ្ចក់ ទៅតាមករណីសមស្រប ដូចមាន យោងក្នុងមាត្រា៤ កថាខណ្ឌ១ (ឃ) នៃអនុសញ្ញានេះ ដែលរួមទាំងព្រៃឈើផងដែរ។

២. បណ្តាភាគីត្រូវបានលើកទឹកចិត្តឱ្យចាត់វិធានការអនុវត្ត និងគាំទ្រ ដោយរួមទាំងតាមរយៈ ការបង់ថ្លៃផ្អែកតាមលទ្ធផល ក្របខណ្ឌ ដែលមានស្រាប់ដូចចែងនៅក្នុងសេចក្តីណែនាំពាក់ព័ន្ធ និងសេចក្តីសម្រេចដែលបានឯកភាពគ្នារួចហើយនៅក្រោមអនុសញ្ញានេះ សម្រាប់៖ អភិក្រមគោលនយោបាយ និងការលើកទឹកចិត្តវិជ្ជមានសម្រាប់សកម្មភាពនានាពាក់ព័ន្ធនឹងការកាត់បន្ថយការបញ្ចេញពី ការបាត់បង់និងរេចរឹលព្រៃឈើ ព្រមទាំងតួនាទីនៃការអភិរក្ស ការគ្រប់គ្រងព្រៃឈើដោយនិរន្តរភាព និងការបង្កើនអាងស្តុកកាបូន ព្រៃឈើនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ និងអភិក្រមគោលនយោបាយជំនួស ដូចជាអភិក្រមរួមនៃការកាត់បន្ថយ និងបន្សាំ សម្រាប់គ្រប់គ្រងព្រៃឈើទាំងមូលនិងដោយមាននិរន្តរភាព ទន្ទឹមនឹងការអះអាងឡើងវិញពីសារៈសំខាន់នៃការផ្តល់ការលើកទឹក ចិត្ត ទៅតាមករណីសមស្រប សម្រាប់អត្ថប្រយោជន៍មិនមែនកាបូនដែលពាក់ព័ន្ធនឹងអភិក្រមបែបនេះ។

## មាត្រា៦

១. បណ្តាភាគីទទួលស្គាល់ថា ភាគីមួយចំនួនជ្រើសយកបន្តកិច្ចសហប្រតិបត្តិការដោយស្ម័គ្រចិត្តនៅក្នុងការអនុវត្តការរួមចំណែកប្តេជ្ញាអនុវត្តនៅថ្នាក់ជាតិរបស់ខ្លួន ដើម្បីអាចឱ្យមានមហិច្ឆតាកម្រិតខ្ពស់ជាងមុននៅក្នុងសកម្មភាពកាត់បន្ថយ និងបន្សាំរបស់ខ្លួន និងដើម្បីលើកកម្ពស់ការអភិវឌ្ឍដោយចីរភាព និងបូរណភាពបរិស្ថាន។

២. ក្នុងករណីការចូលរួមដោយស្ម័គ្រចិត្តនៅក្នុងអភិក្រមបែបសហប្រតិបត្តិការពាក់ព័ន្ធទៅនឹងការប្រើប្រាស់លទ្ធផលនៃការកាត់បន្ថយ ដែលអាចផ្ទេរបានជាអន្តរជាតិ ឆ្ពោះទៅរកការរួមចំណែកប្តេជ្ញាអនុវត្តនៅថ្នាក់ជាតិ បណ្តាភាគីត្រូវជំរុញការអភិវឌ្ឍដោយចីរភាពនិងធានាបូរណភាពនិងតម្លាភាពបរិស្ថាន រួមទាំងអភិបាលកិច្ច និងត្រូវប្រើប្រាស់ការគណនាដែលច្បាស់លាស់ ក្នុងចំណោមបញ្ហា ទាំងនោះដើម្បីបញ្ចៀសការគណនាទ្វេដង និងដើម្បីឱ្យមានសង្គតិភាពជាមួយសេចក្តីណែនាំដែលបានអនុម័តដោយសន្និសីទបណ្តាភាគីដែលមាននាទីជាកិច្ចប្រជុំបណ្តាភាគីក្នុងកិច្ចព្រមព្រៀងនេះ។

៣. ការប្រើប្រាស់លទ្ធផលនៃការកាត់បន្ថយដែលអាចផ្ទេរបានជាអន្តរជាតិ ដើម្បីសម្រេចបានការរួមចំណែកប្តេជ្ញាអនុវត្តនៅថ្នាក់ជាតិនៅក្រោមកិច្ចព្រមព្រៀងនេះ ត្រូវតែជាការស្ម័គ្រចិត្ត និងការអនុញ្ញាតដោយបណ្តាភាគីដែលចូលរួម។

៤. យន្តការមួយដើម្បីរួមចំណែកក្នុងការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ និងគាំទ្រដល់ការអភិវឌ្ឍដោយចីរភាព ត្រូវបង្កើតឡើងនៅក្រោមសមត្ថកិច្ច និងការណែនាំនៃសន្និសីទបណ្តាភាគីមាននាទីជាកិច្ចប្រជុំបណ្តាភាគីក្នុងកិច្ចព្រមព្រៀងនេះ សម្រាប់ប្រើប្រាស់ដោយបណ្តាភាគីតាមការស្ម័គ្រចិត្ត ការប្រើប្រាស់បែបនេះគួរតែស្ថិតក្រោមការណែនាំរបស់អង្គដែលបានតែងតាំងដោយសន្និសីទបណ្តាភាគីមាននាទីជាកិច្ចប្រជុំរបស់ភាគីក្នុងកិច្ចព្រមព្រៀងក្រុងប៉ារីស និងត្រូវមានបំណង ដើម្បី៖

(ក) ជំរុញការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ ទន្ទឹមនឹងការពង្រឹងការអភិវឌ្ឍដោយចីរភាព

(ខ) ផ្តល់ការលើកទឹកចិត្ត និងសម្រួលដល់ការចូលរួមនៅក្នុងការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ដោយអង្គភាពសាធារណៈ និងឯកជន ដោយមានការអនុញ្ញាតពីភាគីណាមួយ

(គ) រួមចំណែកក្នុងការកាត់បន្ថយនៃកម្រិតបញ្ចេញឧស្ម័ននៅក្នុងភាគីជាម្ចាស់ផ្ទះ ដែលនឹងទទួលអត្ថប្រយោជន៍ពីសកម្មភាព កាត់បន្ថយចេញពីការកាត់បន្ថយឧស្ម័ន ដែលក៏អាចប្រើប្រាស់ដោយភាគីដទៃទៀត ដើម្បីបំពេញការរួមចំណែកប្តេជ្ញាអនុ វត្តនៅថ្នាក់ជាតិរបស់ភាគីនោះផងដែរ និង

(ឃ) ផ្តល់នូវការកាត់បន្ថយជារួមក្នុងការបញ្ចេញឧស្ម័នជាសកល។

៥. ការកាត់បន្ថយការបញ្ចេញឧស្ម័នចេញពីយន្តការយោងទៅក្នុងកថាខណ្ឌ៤ នៃមាត្រានេះ នឹងមិនត្រូវប្រើប្រាស់ដើម្បីបង្ហាញពី សមិទ្ធផលការរួមចំណែកប្តេជ្ញាអនុវត្តនៅថ្នាក់ជាតិរបស់ភាគីជាម្ចាស់ផ្ទះឡើយ ប្រសិនបើត្រូវប្រើប្រាស់ដោយភាគីដទៃដើម្បីបង្ហាញពីសមិទ្ធផលនៃការរួមចំណែកប្តេជ្ញាអនុវត្តនៅថ្នាក់ជាតិរបស់ខ្លួន។

៦. សន្និសីទបណ្តាភាគីដែលមាននាទីជាកិច្ចប្រជុំបណ្តាភាគីក្នុងកិច្ចព្រមព្រៀងនេះ ត្រូវធានាថាភាគចំណែកមួយនៃផលចំណូលពីសកម្មភាពនានានៅក្រោមយន្តការយោងទៅក្នុងកថាខណ្ឌ៤ នៃមាត្រានេះនឹងត្រូវប្រើប្រាស់សម្រាប់បំពេញការចំណាយរដ្ឋបាលក៏ដូចជាដើម្បីជួយបណ្តាភាគីប្រទេសកំពុងអភិវឌ្ឍន៍ជាពិសេសប្រទេសងាយរងគ្រោះនៅចំពោះមុខផលប៉ះពាល់ធ្ងន់ធ្ងរពីការប្រែប្រួលអាកាសធាតុដើម្បីបំពេញការចំណាយបន្សាំផងដែរ។

៧. សន្និសីទបណ្តាភាគីដែលមាននាទីជាកិច្ចប្រជុំបណ្តាភាគីក្នុងកិច្ចព្រមព្រៀងនេះ ត្រូវអនុម័តបទបញ្ញាបែបបទ និងនីតិវិធីសម្រាប់យន្តការយោងទៅក្នុងកថាខណ្ឌ ៤ នៃមាត្រានេះ នាសម័យប្រជុំលើកទីមួយរបស់ខ្លួន។

៨. បណ្តាភាគីទទួលស្គាល់សារៈសំខាន់នៃអភិក្រមមិនមែនទីផ្សារមានតុល្យភាពលក្ខណៈចម្រុះ និងគ្រប់ជ្រុងជ្រោយ ដែលបណ្ត ភាគីអាចយកទៅប្រើប្រាស់បាន ដើម្បីជួយនៅក្នុងការអនុវត្តការរួមចំណែកប្តេជ្ញាអនុវត្តនៅថ្នាក់ជាតិរបស់ខ្លួននៅក្នុងបរិបទន ការអភិវឌ្ឍដោយចីរភាព និងការកាត់បន្ថយភាពក្រីក្រ តាមទម្រង់ដែលមានការសម្របសម្រួល និងប្រកបដោយប្រសិទ្ធភាព ដែល រួមទាំង តាមរយៈការកាត់បន្ថយការបន្សាំ ហិរញ្ញវត្ថុ ការផ្ទេរបច្ចេកវិទ្យា និងការកសាងសមត្ថភាព ទៅតាមករណីសមស្រប។ អភិក្រមទាំងនេះត្រូវមានបំណងដើម្បីៈ

(ក) លើកកម្ពស់មហិច្ឆតានៃការកាត់បន្ថយ និងបន្សាំ

(ខ) ពង្រឹងការចូលរួមពីវិស័យសាធារណៈ និងឯកជននៅក្នុងការអនុវត្តការចូលរួមចំណែកប្តេជ្ញាអនុវត្តនៅថ្នាក់ជាតិ និង

(គ) ជំរុញកាលានុវត្តភាពសម្រាប់ការសម្របសម្រួលរវាងបរិធាននានា និងការចាត់ចែងស្ថាប័នពាក់ព័ន្ធ។

៩. ក្របខណ្ឌមួយសម្រាប់អភិក្រមមិនមែនទីផ្សារដើម្បីការអភិវឌ្ឍដោយចីរភាព ត្រូវបានបញ្ជាក់នៅទីនេះដើម្បីលើកកម្ពស់អភិក្រមមិនមែនទីផ្សារ ដូចមានយោងទៅក្នុងកថាខណ្ឌ៨ នៃមាត្រានេះ។

## មាត្រា ៧

១. តាមរយៈនេះ បណ្តាភាគីបង្កើតគោលបំណងជាសកលស្តីពីបណ្តុំនៃការលើកកម្ពស់សមត្ថភាពបន្សាំពង្រឹងភាពធន់ និងកាត់បន្ថយភាពងាយរងគ្រោះទៅនឹងការប្រែប្រួលអាកាសធាតុ ក្នុងទស្សនៈរួមចំណែកទៅក្នុងការអភិវឌ្ឍដោយចីរភាព និងការធានាឱ្យ បានគ្រប់គ្រាន់លើការឆ្លើយតបទៅនឹងបន្សាំ នៅក្នុងបរិបទនៃគោលបំណងសីតុណ្ហភាពដូចមានចែងក្នុងមាត្រា ២។

២. បណ្តាភាគីទទួលស្គាល់ថា បន្សាំ គឺជាការប្រឈមសកលមួយសម្រាប់គ្រប់លំដាប់ថ្នាក់ ទាំងនៅថ្នាក់មូលដ្ឋាន ថ្នាក់ក្រោមជាតិ ថ្នាក់ ជាតិ តំបន់ និងអន្តរជាតិ ហើយនេះជាសមាសភាគគន្លឹះមួយនិងជាការចូល

រួមចំណែកក្នុងការឆ្លើយតបជាសកលរយៈពេលវែងទៅ នឹងការប្រែប្រួលអាកាសធាតុ ដើម្បីការពារប្រជាជន ជីវភាពរស់នៅ និងប្រព័ន្ធអេកូឡូស៊ី ដោយគិតគូរផងដែរអំពីតម្រូវការបន្ទាន់ និងចំពោះមុខរបស់បណ្ដាភាគីប្រទេសកំពុងអភិវឌ្ឍន៍ដែលងាយរងគ្រោះ ជាពិសេសទៅនឹងផលប៉ះពាល់ធ្ងន់ធ្ងរនៃការប្រែប្រួលអាកាសធាតុ។

៣. កិច្ចប្រឹងប្រែងបន្សុំរបស់បណ្ដាភាគីប្រទេសកំពុងអភិវឌ្ឍន៍ ត្រូវបានទទួលស្គាល់ស្របតាមបែបបទដែលបានអនុម័តដោយសន្និសីទ បណ្ដាភាគីដែលមាននាទីជាកិច្ចប្រជុំបណ្ដាភាគីក្នុងកិច្ចព្រមព្រៀងនេះ នាសម័យប្រជុំលើកទីមួយរបស់ខ្លួន។

៤. បណ្ដាភាគីទទួលស្គាល់ថា តម្រូវការបច្ចុប្បន្នសម្រាប់បន្សុំមានសារៈសំខាន់ណាស់ ហើយកម្រិតនៃការកាត់បន្ថយកាន់តែច្រើន អាចបន្ថយនូវតម្រូវការសម្រាប់កិច្ចប្រឹងប្រែងបន្សុំបន្ថែមទៀត ហើយតម្រូវការបន្សុំកាន់តែច្រើន អាចទាក់ទងនឹងការចំណាយ លើបន្សុំកាន់តែខ្ពស់។

៥. បណ្ដាភាគីទទួលស្គាល់ថា សកម្មភាពបន្សុំ គួរតែធ្វើទៅតាមអភិក្រមដែលមានតម្លាភាពពេញលេញ មានការចូលរួម គិតគូរពី យេនឌ័រ និងស្របតាមកម្មវិធីរបស់ប្រទេស ដោយពិចារណាផងដែរនូវក្រុមងាយរងគ្រោះសហគមន៍ និងប្រព័ន្ធអេកូឡូស៊ី ហើយគួរតែផ្អែកលើវិទ្យាសាស្ត្រថ្មីបំផុត និងប្រព័ន្ធចំណេះដឹងមូលដ្ឋាន ចំណេះដឹងប្រពៃណី ព្រមទាំងចំណេះដឹងរបស់ជនជាតិដើម ទៅតាមការណ៍សមស្រប ក្នុងបំណងរួមបញ្ចូលបន្សុំទៅក្នុងគោលនយោបាយ និងសកម្មភាពសេដ្ឋកិច្ចសង្គម និងបរិស្ថានដែល ពាក់ព័ន្ធទៅតាមការណ៍សមស្រប។

៦. បណ្ដាភាគី ទទួលស្គាល់សារៈសំខាន់នៃកិច្ចគាំទ្រ និងកិច្ចសហប្រតិបត្តិការអន្តរជាតិ លើការប្រឹងប្រែងបន្សុំ និងទទួលស្គាល់សារៈសំខាន់នៃការគិតគូរអំពីតម្រូវការរបស់បណ្ដាភាគីប្រទេសកំពុងអភិវឌ្ឍន៍ ជាពិសេស បណ្ដាភាគីដែលងាយរងគ្រោះទៅនឹងផលប៉ះ ពាល់ធ្ងន់ធ្ងរនៃការប្រែប្រួលអាកាសធាតុ។ ៧. បណ្ដាភាគីគួរពង្រឹងកិច្ចសហប្រតិបត្តិការរបស់ខ្លួនក្នុងការពង្រីកសកម្មភាពបដោយគិតគូរផងដែរនូវក្របខណ្ឌបន្សុំទីក្រុងកាន់គុន រួមទាំងប្រការនានាដែលជាប់ទាក់ទងនឹង៖

(ក). ការចែករំលែកព័ត៌មាន ការអនុវត្តល្អ បទពិសោធន៍ និងមេរៀននានា ដែលមាននៅតាមករណីសមស្រប ទាក់ទងនឹងវិទ្យាសាស្ត្រ ការរៀបចំផែនការ គោលនយោបាយ និងការអនុវត្តដែលពាក់ព័ន្ធនឹងសកម្មភាពបន្សុំ។

(ខ) ការពង្រឹងការចាត់ចែងស្ថាប័ន រួមទាំងការចាត់ចែងនានានៅក្រោមអនុសញ្ញានេះ ដែលបម្រើឱ្យផលប្រយោជន៍នៃកិច្ចព្រម ព្រៀងនេះ ដើម្បីគាំទ្រដល់ការសំយោគព័ត៌មាន និងចំណេះដឹងពាក់ព័ន្ធ ព្រមទាំងផ្ដល់នូវការគាំទ្របច្ចេកទេស និងសេច ក្ដីណែនាំដល់បណ្ដាភាគី។

(គ) ការពង្រឹងចំណេះដឹងវិទ្យាសាស្ត្រអំពីអាកាសធាតុ រួមទាំងការស្រាវជ្រាវ ការសង្កេតជាប្រព័ន្ធនៃប្រព័ន្ធអាកាសធាតុនិងប្រព័ន្ធ-ប្រកាសអាសន្នជាមុន តាមរបៀបផ្ដល់ព័ត៌មានសេវាកម្មអាកាសធាតុ និងគាំទ្រដល់ការធ្វើសេចក្ដីសម្រេច។

(ឃ) ការជួយបណ្តាភាគីប្រទេសកំពុងអភិវឌ្ឍន៍ក្នុងការកំណត់អត្តសញ្ញាណការអនុវត្តបន្សាំដែលមានប្រសិទ្ធភាព តម្រូវការបន្សាំ អាទិភាពនានា ការគាំទ្រដែលបានផ្តល់និងទទួលសម្រាប់សកម្មភាពបន្សាំនិងកិច្ចខិតខំប្រឹងប្រែងនានា ព្រមទាំង បញ្ហាប្រឈម និងចំណុចខ្វះចន្លោះតាមទម្រង់ដែលមានសង្គតិភាពជាមួយនឹងការលើកទឹកចិត្តការអនុវត្តល្អ និង

(ង) ការបង្កើនប្រសិទ្ធភាព និងអត្ថិភាពនៃសកម្មភាពបន្សាំ។

៨. ទីភ្នាក់ងារ និងអង្គការឯកទេសរបស់សហប្រជាជាតិ ត្រូវបានលើកទឹកចិត្ត ដើម្បីផ្តល់ការគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងរបស់បណ្ត ភាគីក្នុងការអនុវត្តសកម្មភាព ដោយយោងតាមកថាខណ្ឌ ៧ នៃមាត្រានេះ ដោយគិតគូរផងដែរនូវប្រការនានាក្នុងកថាខណ្ឌ ៥ នៃ មាត្រានេះ។

៩. ភាគីនីមួយៗត្រូវចូលរួមទៅតាមករណីសមស្របនៅក្នុងដំណើរការរៀបចំផែនការបន្សាំ និងការអនុវត្តសកម្មភាពដែលរួមទាំង ការរៀបចំ ឬការពង្រឹងគោលនយោបាយ ផែនការពាក់ព័ន្ធនិង/ឬការរួមចំណែកដែលអាចរួមបញ្ចូល៖

(ក) ការអនុវត្តសកម្មភាពបន្សាំ កិច្ចការ និង/ឬ កិច្ចខិតខំប្រឹងប្រែង

(ខ) ដំណើរការចងក្រង និងអនុវត្តផែនការជាតិបន្សាំ

(គ) ការវាយតម្លៃផលប៉ះពាល់និងភាពងាយរងគ្រោះពីការប្រែប្រួលអាកាសធាតុ ក្នុងបំណងកំណត់សកម្មភាពអាទិភាពដែល បានប្តេជ្ញាអនុវត្តនៅថ្នាក់ជាតិ ដោយគិតគូរផងដែរពីប្រជាជន ទីកន្លែង និងប្រព័ន្ធអេកូឡូស៊ីដែលងាយរងគ្រោះ

(ឃ) ការតាមដានត្រួតពិនិត្យនិងវាយតម្លៃ និងការរៀនសូត្រពីផែនការបន្សាំ គោលនយោបាយ កម្មវិធី និងសកម្មភាពនិង

(ង) ការកសាងភាពធន់នៃប្រព័ន្ធអេកូឡូស៊ី និងសេដ្ឋកិច្ចសង្គម ដែលរួមទាំង តាមរយៈពិពិធកម្មសេដ្ឋកិច្ច និងការគ្រប់គ្រងធនធានធម្មជាតិដោយនិរន្តរភាព។

១០. ភាគីនីមួយៗគួរដាក់ជូន និងការធ្វើបច្ចុប្បន្នកម្មទៀងទាត់នូវរបាយការណ៍បន្សាំទៅតាមករណីសមស្រប ដែលអាចរួមបញ្ចូលអាទិ ភាពរបស់ខ្លួន ការអនុវត្ត និងតម្រូវការគាំទ្រ ផែនការនិងសកម្មភាព ដោយមិនបង្កើតបន្ទុកបន្ថែមណាមួយសម្រាប់បណ្តាភាគី ប្រទេសកំពុងអភិវឌ្ឍន៍ឡើយ។

១១. របាយការណ៍បន្សាំដូចមានយោងក្នុងកថាខណ្ឌ ១០ នៃមាត្រានេះ ត្រូវដាក់ជូន និងធ្វើបច្ចុប្បន្នកម្មទៀងទាមករណីសមស្រប ដែលជាផ្នែកមួយនៃ/ឬភ្ជាប់ជាមួយរបាយការណ៍ ឬឯកសារដទៃទៀត រួមទាំងផែនការជាតិបន្សាំ ការរួមចំណែកប្តេជ្ញាអនុវត្តនៅថ្នាក់ជាតិ ដូចយោងតាមមាត្រា៤ កថាខណ្ឌ២ និង/ឬរបាយការណ៍ជាតិ។

១២. របាយការណ៍បន្សាំដូចមានយោងទៅក្នុងកថាខណ្ឌ ១០ នៃមាត្រានេះ ត្រូវតែកត់ត្រាក្នុងបញ្ជីសាធារណៈដែលរក្សាទុកដោយ លេខាធិការដ្ឋាន។

១៣. ការបន្តនិងការពង្រឹងកិច្ចគាំទ្រអន្តរជាតិ ត្រូវតែផ្តល់ឱ្យបណ្តាភាគីប្រទេសកំពុងអភិវឌ្ឍន៍ សម្រាប់ការអនុវត្តកថាខណ្ឌ ៧, ៩, ១០ និង១១ នៃមាត្រានេះ អនុលោមតាមប្រការនានានៃមាត្រា ៩, ១០, និង ១១។

១៤. របាយការណ៍សំយោគជាសាកល ដូចមានយោងក្នុងមាត្រា ១៤ ក្នុងចំណោមបញ្ហាទាំងនោះ ត្រូវតែះ

(ក) ទទួលស្គាល់កិច្ចខិតខំប្រឹងប្រែងបន្សាំរបស់បណ្តាភាគីប្រទេសកំពុងអភិវឌ្ឍន៍

(ខ) ពង្រឹងការអនុវត្តសកម្មភាពបន្សាំ ដោយគិតគូរផងដែរអំពីរបាយការណ៍បន្សាំ យោងក្នុងកថាខណ្ឌ ១០

(គ) ពិនិត្យភាពគ្រប់គ្រាន់ និងប្រសិទ្ធផលនៃបន្សាំ និងការគាំទ្រដែលបានផ្តល់សម្រាប់បន្សាំ និងនៃមាត្រា នេះ។

(ឃ) ពិនិត្យវឌ្ឍនភាពជារួមដែលបានធ្វើឡើងនៅក្នុងការសម្រេចគោលបំណងជាសកលស្តីពីបន្សាំ ដូចមានយោងក្នុងកថាខណ្ឌ១ នៃមាត្រានេះ។

## មាត្រា៨

១. បណ្តាភាគី ទទួលស្គាល់ពីសារៈសំខាន់នៃការបញ្ចៀសការបន្ថយជាអតិបរិមា និងការឆ្លើយតបបញ្ហានៃការខូចខាតនិងការបាត់បង់ ពាក់ព័ន្ធជាមួយផលប៉ះពាល់ធ្ងន់ធ្ងរពីការប្រែប្រួលអាកាសធាតុ រួមទាំងព្រឹត្តិការណ៍ធាតុអាកាសមិនប្រក្រតី និង ព្រឹត្តិការណ៍ដែលវិវត្តន៍យឺតៗ ព្រមទាំងតួនាទីនៃការអភិវឌ្ឍដោយចីរភាពនៅក្នុងការកាត់បន្ថយហានិភ័យនៃការខូចខាត និងការបាត់បង់។

២. យន្តការអន្តរជាតិទីក្រុងវ៉ាសូវីសម្រាប់ការខូចខាត និងការបាត់បង់ ដែលពាក់ព័ន្ធនឹងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ ត្រូវស្ថិតនៅក្រោមដែនសមត្ថកិច្ច និងសេចក្តីណែនាំរបស់សន្និសិទបណ្តាភាគីដែលមាននាទីជាកិច្ចប្រជុំបណ្តាភាគីក្នុងកិច្ចព្រមព្រៀងនេះ និងអាចពង្រឹង និងពង្រីកបន្ថែមទៀត តាមការសម្រេចដោយសន្និសីទបណ្តាភាគី ដែលមាននាទីជាកិច្ចប្រជុំរបស់ភាគីក្នុងកិច្ចព្រម ព្រៀងនេះ។

៣. បណ្តាភាគីគួរបង្កើនការយល់ដឹង សកម្មភាព និងការគាំទ្រ រួមទាំងតាមរយៈយន្តការអន្តរជាតិទីក្រុងវ៉ាសូវី ទៅតាមករណីសមស្របដោយផ្អែកលើកិច្ចសហប្រតិបត្តិការ និងការជួយសម្រួល នៅក្នុងក្របខណ្ឌនៃការខូចខាត និងការបាត់បង់ ដែលពាក់ព័ន្ធនឹងផល ប៉ះពាល់ធ្ងន់ធ្ងរពីការប្រែប្រួលអាកាសធាតុ។

៤. ក្នុងន័យនេះ វិស័យនានានៃកិច្ចសហប្រតិបត្តិការ និងការសម្របសម្រួល ដើម្បីបង្កើនការយល់ដឹង សកម្មភាព និងការគាំទ្រ អាចមាន

(ក) ប្រព័ន្ធប្រកាសអាសន្នជាមុន

(ខ) ការត្រៀមបង្ការសង្គ្រោះបន្ទាន់

(គ) ព្រឹត្តិការណ៍ដែលវិវត្តន៍យឺតៗ

(ឃ) ព្រឹត្តិការណ៍ដែលអាចពាក់ព័ន្ធនឹងការខូចខាត និងបាត់បង់ដែលមិនអាចត្រឡប់ក្រោយ និងជាអចិន្ត្រៃយ៍

(ង) ការវាយតម្លៃ និងការគ្រប់គ្រងហានិភ័យគ្រប់ជ្រុងជ្រោយ

(ច) មូលនិធិធានារ៉ាប់រងហានិភ័យ ការប្រមូលផ្តុំហានិភ័យអាកាសធាតុ និងដំណោះស្រាយផ្សេងទៀតនៃការធានារ៉ាប់រង

(ឆ) ការបាត់បង់មិនមែនសេដ្ឋកិច្ច និង

ជ. ភាពធន់របស់សហគមន៍ ជីវភាពរស់នៅ និងប្រព័ន្ធអេកូឡូស៊ី។

៥. យន្តការអន្តរជាតិទីក្រុងវ៉ារស្សូវី ត្រូវសហការជាមួយអង្គភាព និងក្រុមជំនាញការដែលមានស្រាប់នៅក្រោមកិច្ចព្រមព្រៀងនេះ ក៏ដូចជា អង្គការ និងអង្គភាពជំនាញពាក់ព័ន្ធដែលមិននៅក្រោមកិច្ចព្រមព្រៀងនេះ។

## មាត្រា៩

១. បណ្តាភាគីប្រទេសអភិវឌ្ឍន៍ ត្រូវផ្តល់ធនធានហិរញ្ញវត្ថុ ដើម្បីជួយបណ្តាភាគីប្រទេសកំពុងអភិវឌ្ឍន៍ចំពោះការកាត់បន្ថយ និងបន្ស៊ាំ ក្នុងការបន្តកាតព្វកិច្ចដែលមានស្រាប់របស់បណ្តាភាគីនៅក្រោមអនុសញ្ញានេះ។

២. បណ្តាភាគីដទៃទៀត ត្រូវបានលើកទឹកចិត្ត ដើម្បីផ្តល់ ឬបន្តផ្តល់ការគាំទ្របែបនេះដោយស្ម័គ្រចិត្ត។

៣.ជាផ្នែកមួយនៃកិច្ចខិតខំប្រឹងប្រែងជសកល បណ្តាភាគីប្រទេសអភិវឌ្ឍន៍ គួរបន្តនាំមុខក្នុងការកៀរគរហិរញ្ញវត្ថុអាកាសធាតុពី ប្រភព បរិធាន និងមធ្យោបាយផ្សេងៗ ដោយកត់សម្គាល់ពីតួនាទីដ៏សំខាន់នៃមូលនិធិសាធារណៈ តាមរយៈសកម្មភាពផ្សេងៗ រួមទាំងការគាំទ្រយុទ្ធសាស្ត្រស្របតាមប្រទេស និងការគិតគូរពីតម្រូវការ និងអាទិភាពរបស់បណ្តាភាគីប្រទេសកំពុងអភិវឌ្ឍន៍ ការ កៀរគរហិរញ្ញវត្ថុអាកាសធាតុបែបនេះគួរបង្ហាញពីភាពរីកចម្រើនដែលលើសពីកិច្ចខិតខំប្រឹងប្រែងកន្លងមក។

៤. ការផ្តល់ធនធានហិរញ្ញវត្ថុទ្រង់ទ្រាយធំជាងមុន គួរតែសំដៅសម្រេចឱ្យបានតុល្យភាពមួយ រវាងការកាត់បន្ថយនិងបន្ស៊ាំ ដោយគិតគូរ ពីយុទ្ធសាស្ត្រ និងអាទិភាពរបស់ប្រទេស ព្រមទាំងតម្រូវការរបស់បណ្តាភាគីប្រទេសកំពុងអភិវឌ្ឍន៍ ជាពិសេសបណ្តាភាគីដែល ងាយរងគ្រោះបំផុតពីផលប៉ះពាល់ធ្ងន់ធ្ងរនៃការប្រែប្រួលអាកាសធាតុ និងជួបឧបសគ្គច្រើនខាងសមត្ថភាពដូចជាបណ្តាប្រទេស អភិវឌ្ឍន៍តិចតួច និងរដ្ឋកូនកោះកំពុងអភិវឌ្ឍន៍ ដោយពិចារណាពីតម្រូវការធនធានសាធារណៈ និងជំនួយឥតសំណងសម្រាប់បន្ស៊ាំ។

៥. បណ្តាភាគីប្រទេសអភិវឌ្ឍន៍ ត្រូវរាយការណ៍រាល់ពីរឆ្នាំម្តងនូវព័ត៌មានដែលចង្អុលបង្ហាញជាលក្ខណៈបរិមាណវិស័យ និងគុណវិស័យ ដែលទាក់ទងនឹងកថាខណ្ឌ១ និង៣ នៃមាត្រានេះ ទៅតាមករណីដែលអាចធ្វើបាន ប្រសិនបើមាន រួមទាំងនៅកម្រិតចំណោលអំពីធនធានហិរញ្ញវត្ថុសាធារណៈ ដែលត្រូវផ្តល់ទៅ

ឱ្យបណ្តាភាគីប្រទេសកំពុងអភិវឌ្ឍន៍ គឺដទៃទៀតដែលផ្តល់ធនធាន ត្រូវបានលើកទឹកចិត្តឱ្យរាយការណ៍ព័ត៌មានរាល់ពីរឆ្នាំម្តងតាមការស្ម័គ្រចិត្ត។
៦. របាយការណ៍សំយោគជាសកល ដូចមានយោងក្នុងមាត្រា១៤ គួរតែបានគិតគូរអំពីព័ត៌មានពាក់ព័ន្ធដែលបានផ្តល់ដោយបណ្តាភាគី ប្រទេសអភិវឌ្ឍន៍ និង អង្គភាពនៅក្រោមកិច្ចព្រមព្រៀងនេះ អំពីកិច្ចខិតខំប្រឹងប្រែងដែលទាក់ទងនឹងហិរញ្ញវត្ថុអាកាសធាតុ។
៧. បណ្តាភាគីប្រទេសអភិវឌ្ឍន៍ ត្រូវផ្តល់ព័ត៌មានប្រកបដោយតម្លាភាពនិងសង្គតិភាពរាល់ពីរឆ្នាំម្តង អំពីការគាំទ្រសម្រាប់បណ្ត ភាគីប្រទេសកំពុងអភិវឌ្ឍន៍ដែលបានកៀរគរនិងបានផ្តល់ តាមរយៈអន្តរាគមន៍ក្នុងវិស័យសាធារណៈ ស្របតាមបែបបទ នីតិវិធី និង គោលការណ៍ណែនាំ ដែលត្រូវអនុម័តដោយសន្និសីទបណ្តាភាគីដែលមាននាទីជាកិច្ចប្រជុំបណ្តាភាគីក្នុងកិច្ចព្រមព្រៀងនេះ នា សម័យប្រជុំលើកទីមួយរបស់ខ្លួនដូចមានកំណត់នៅក្នុងមាត្រា ១៣ កថាខណ្ឌ១៣។ បណ្តាភាគីដទៃទៀត ត្រូវបានលើកទឹកចិត្ត ឱ្យធ្វើបែបនេះផងដែរ។
៨. យន្តការហិរញ្ញវត្ថុនៃអនុសញ្ញានេះ រួមទាំង អង្គភាពប្រតិបត្តិការរបស់យន្តការនេះ ត្រូវបំពេញនាទីជាយន្តការហិរញ្ញវត្ថុនៃកិច្ចព្រមព្រៀងនេះ។
៩. ស្ថានប័ននានាដែលគាំទ្រដល់ដំណើរការនៃកិច្ចព្រមព្រៀងនេះ រួមទាំង អង្គភាពប្រតិបត្តិការក្នុងយន្តការហិរញ្ញវត្ថុនៃអនុសញ្ញានេះ ត្រូវធានាប្រសិទ្ធភាពនៃការទទួលបានធនធានហិរញ្ញវត្ថុ តាមរយៈនីតិវិធីអនុម័តសាមញ្ញៗ និងការគាំទ្របន្ថែមទៀតដល់ការត្រៀម លក្ខណៈសម្រាប់បណ្តាភាគីប្រទេសកំពុងអភិវឌ្ឍន៍ ជាពិសេស សម្រាប់បណ្តាភាគីប្រទេសអភិវឌ្ឍន៍តិចតួច និងបណ្តារដ្ឋកូន កោះកំពុងអភិវឌ្ឍន៍ នៅក្នុងបរិបទនៃយុទ្ធសាស្ត្រ និងផែនការអាកាសធាតុថ្នាក់ជាតិរបស់ខ្លួន។

## មាត្រា១០

១. បណ្តាភាគី ចែករំលែកចក្ខុវិស័យរយៈពេលវែងអំពីសារៈសំខាន់នៃការសម្រេចបានពេញលេញនូវការផ្ទេរ និងការអភិវឌ្ឍបច្ចេកវិទ្យា ដើម្បីកែលម្អភាពធន់នឹងការប្រែប្រួលអាកាសធាតុ និងដើម្បីកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់។
២. ដោយកត់សម្គាល់អំពីសារៈសំខាន់នៃបច្ចេកវិទ្យាសម្រាប់ការអនុវត្តសកម្មភាពកាត់បន្ថយ និងបន្សាំនៅក្រោមកិច្ចព្រមព្រៀងនេះ និង ការទទួលស្គាល់ពីការដាក់ឱ្យប្រើប្រាស់បច្ចេកវិទ្យាដែលមានស្រាប់ និងកិច្ចខិតខំប្រឹងប្រែងផ្សព្វផ្សាយ បណ្តាភាគីត្រូវពង្រឹង សកម្មភាពសហប្រតិបត្តិការលើការផ្ទេរ និងការអភិវឌ្ឍបច្ចេកវិទ្យា។
៣. យន្តការបច្ចេកវិទ្យាបង្កើតឡើងនៅក្រោមអនុសញ្ញានេះ ត្រូវគាំទ្រដល់កិច្ចព្រមព្រៀងនេះ។

៤. ក្របខណ្ឌបច្ចេកវិទ្យាមួយត្រូវបានបង្កើតឡើង ដើម្បីផ្តល់សេចក្តីណែនាំសំខាន់ដល់ការងារនៃយន្តការបច្ចេកវិទ្យា សំដៅលើកកម្ពស់ និងសម្រួលដល់ការពង្រឹងសកម្មភាពពីការផ្ទេរ និងការអភិវឌ្ឍបច្ចេកវិទ្យា ដើម្បីគាំទ្រដល់ការអនុវត្តកិច្ចព្រមព្រៀងនេះឈានទៅរកការសម្រេចចក្ខុវិស័យរយៈពេលវែងដូចមានយោងក្នុងកថាខណ្ឌ១ នៃមាត្រានេះ។
៥. ការបង្កើនល្បឿន ការលើកទឹកចិត្ត និងការបង្កើតលក្ខខណ្ឌអំណោយផលសម្រាប់នវានុវត្តន៍ មានសារៈសំខាន់ណាស់ក្នុងការឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុជាសកលរយៈពេលវែង និងប្រកបដោយប្រសិទ្ធភាព និង ព្រមទាំងការលើកកម្ពស់កំណើន សេដ្ឋកិច្ច និងការអភិវឌ្ឍដោយចីរភាព។ កិច្ចខិតខំប្រឹងប្រែងបែបនេះ ត្រូវទទួលបានការគាំទ្រ ទៅតាមករណីសមស្រប ដោយរួម បញ្ចូលទាំង យន្តការបច្ចេកវិទ្យា និង យន្តការហិរញ្ញវត្ថុនៃអនុសញ្ញានេះតាមរយៈមធ្យោបាយហិរញ្ញវត្ថុ សម្រាប់អភិក្រមតាមបែប កិច្ចសហការក្នុងការស្រាវជ្រាវ និងអភិវឌ្ឍន៍ និងបង្កលក្ខណៈងាយស្រួលក្នុងការទទួលបានបច្ចេកវិទ្យា ជាពិសេសក្នុងដំណាក់ កាលដំបូងៗនៃវដ្តបច្ចេកវិទ្យាទៅដល់បណ្តាភាគីប្រទេសកំពុងអភិវឌ្ឍន៍។
៦. ការគាំទ្រ ដែលរួមបញ្ចូលទាំងការគាំទ្រហិរញ្ញវត្ថុ ត្រូវតែបានផ្តល់ឱ្យបណ្តាភាគីប្រទេសកំពុងអភិវឌ្ឍន៍សម្រាប់អនុវត្តមាត្រានេះ ដែលរួមទាំងសម្រាប់ពង្រឹងសកម្មភាពសហប្រតិបត្តិការលើការផ្ទេរ និងការអភិវឌ្ឍបច្ចេកវិទ្យានៅដំណាក់កាលខុសៗគ្នានៃវដ្ត បច្ចេកវិទ្យា ក្នុងបំណងសម្រេចបាននូវតុល្យភាពរវាងការគាំទ្រដល់ការកាត់បន្ថយ និងបន្សាំ របាយការណ៍សំយោគជាសកល ដូចមានយោងក្នុងមាត ១៤ ត្រូវគិតគូរអំពីព័ត៌មានដែលមានស្តីពីកិច្ចខិតខំប្រឹងប្រែងដែលទាក់ទងនឹងការគាំទ្រដល់ការ ផ្ទេរ និងការអភិវឌ្ឍបច្ចេកវិទ្យាសម្រាប់បណ្តាភាគីប្រទេសកំពុងអភិវឌ្ឍន៍។

## មាត្រា១១

១. ការកសាងសមត្ថភាពនៅក្រោមកិច្ចព្រមព្រៀងនេះ គួរតែជួយពង្រឹងសមត្ថភាព និងលទ្ធភាពនៃបណ្តាភាគីប្រទេសកំពុងអភិវឌ្ឍន៍ ជាពិសេស បណ្តាប្រទេសដែលមានសមត្ថភាពតិចតួច ដូចជាប្រទេសអភិវឌ្ឍន៍តិចតួច និងប្រទេសដែលងាយរងគ្រោះជាពិសេស នៅចំពោះមុខផលប៉ះពាល់ធ្ងន់ធ្ងរពីការប្រែប្រួលអាកាសធាតុ ដូចជាបណ្តារដ្ឋកូនកោះកំពុងអភិវឌ្ឍន៍ ដើម្បីចាត់វិធានការ ប្រកបដោយប្រសិទ្ធភាពក្នុងការឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ រួមទាំង ក្នុងចំណោមបញ្ហាទាំងនោះមានដូចជា ការអនុ វត្តសម្មភាពបន្សាំ និងកាត់បន្ថយ ហើយគួរសម្រួលឱ្យមានការអភិវឌ្ឍ ការផ្សព្វផ្សាយ និងការដាក់ឱ្យប្រើប្រាស់បច្ចេកវិទ្យា ការទទួលបានហិរញ្ញវត្ថុអាកាសធាតុ ទិដ្ឋភាពពាក់ព័ន្ធនានានៃការអប់រំ ការបណ្តុះបណ្តាល និងការយល់ដឹងជាសាធារណៈ និងការរាយ ការណ៍ព័ត៌មានដោយតម្លាភាព ទាន់ពេលវេលា និងសុក្រិត។
២. ការកសាងសមត្ថភាព គួរធ្វើឡើងស្របតាមកម្មវិធីរបស់ប្រទេស ផ្អែកលើនិងឆ្លើយតបនឹងតម្រូវជាតិ និងជំរុញភាពជាម្ចាស់របស់ ប្រទេសនៃបណ្តាភាគី ជាពិសេសបណ្តាភាគីប្រទេសកំពុងអភិវឌ្ឍន៍ រួមទាំងនៅ

ថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ និងថ្នាក់មូលដ្ឋាន។ ការកសាងសមត្ថភាព គួរតែធ្វើតាមមេរៀនជាបទពិសោធ ដែលទទួលបាន រួមទាំង មេរៀនចេញពីសកម្មភាពកសាងសមត្ថភាព នៅក្រោមអនុសញ្ញានេះ និងគួរតែជាដំណើរការធ្វើឡើងជាប្រចាំ និងប្រកបដោយប្រសិទ្ធភាព ដែលមានការចូលរួម មានលក្ខណៈអន្តរវិស័យ និងឆ្លើយតបទៅនឹងយេនឌ័រ។

៣. បណ្តាភាគីទាំងអស់គួរសហប្រតិបត្តិការដើម្បីពង្រឹងសមត្ថភាពរបស់បណ្តាភាគីប្រទេសកំពុងអភិវឌ្ឍន៍ ដើម្បីអនុវត្តកិច្ចព្រមព្រៀងនេះ។ បណ្តាភាគីប្រទេសអភិវឌ្ឍន៍ គួរពង្រឹងការគាំទ្រដល់សកម្មភាពកសាងសមត្ថភាពនៅក្នុងបណ្តាភាគីប្រទេសកំពុងអភិវឌ្ឍន៍។

៤. បណ្តាភាគីទាំងអស់ដែលពង្រឹងសមត្ថភាពនៃបណ្តាភាគីប្រទេសកំពុងអភិវឌ្ឍន៍ ដើម្បីអនុវត្តកិច្ចព្រមព្រៀងនេះ រួមទាំង តាមរយៈ អភិក្រមពហុភាគី ទ្វេភាគី និងតំបន់ ត្រូវរាយការណ៍ជាទៀងទាត់អំពីសកម្មភាព ឬ វិធានការទាំងនេះ លើការកសាងសមត្ថភាព។ បណ្តាភាគីប្រទេសកំពុងអភិវឌ្ឍន៍ គួររាយការណ៍ជាទៀងទាត់អំពីវឌ្ឍនភាពដែលសម្រេចបានលើការអនុវត្ត វិធានការ សកម្មភាព គោលនយោបាយ ឬផែនការកសាងសមត្ថភាព ដើម្បីអនុវត្តកិច្ចព្រមព្រៀងនេះ។

៥. សកម្មភាពកសាងសមត្ថភាពត្រូវតែបានពង្រឹង តាមរយៈការចាត់ចែងស្ថាប័នឱ្យសមស្រប ដើម្បីគាំទ្រការអនុវត្តកិច្ចព្រមព្រៀងនេះ រួមទាំងការចាត់ចែងស្ថាប័នឱ្យសមស្រប ដែលបានបង្កើតឡើងនៅក្រោមអនុសញ្ញានេះ ដែលគាំទ្រដល់ កិច្ចព្រមព្រៀងនេះ។ នៅក្នុងសម័យប្រជុំលើកទីមួយរបស់ខ្លួន សន្និសីទបណ្តាភាគីមាននាទីជាកិច្ចប្រជុំបណ្តាភាគីក្នុងកិច្ចព្រមព្រៀងនេះ ត្រូវតែពិចារណា និងអនុម័តសេចក្តីសម្រេចមួយស្តីការចាត់ចែងស្ថាប័នដំបូងសម្រាប់ការកសាងសមត្ថភាព។

## មាត្រា១២

បណ្តាភាគីត្រូវសហប្រតិបត្តិការ ក្នុងការចាត់វិធានការ ទៅតាមករណីសមស្រប ដើម្បីពង្រឹងការអប់រំការបណ្តុះបណ្តាល ការយល់ដឹងជាសាធារណៈ ការចូលរួមជាសាធារណៈ និងការទទួលបានព័ត៌មានជាសាធារណៈ អំពីការប្រែប្រួលអាកាសធាតុ ដោយទទួលស្គាល់ពីសារៈសំខាន់នៃជំហ៊ានទាំងនេះ ដែលទាក់ទងនឹងការពង្រឹងសកម្មភាពនៅក្រោមកិច្ចព្រមព្រៀងនេះ។

## មាត្រា១៣

១. ដើម្បីកសាងទំនុកចិត្ត និងការជឿជាក់គ្នាទៅវិញទៅមក និងដើម្បីលើកកម្ពស់ការអនុវត្តប្រកបដោយប្រសិទ្ធផល ក្របខណ្ឌពង្រឹង តម្លាភាពសម្រាប់សកម្មភាពនិងការគាំទ្រ គួបផ្សំជាមួយភាពបត់បែនបាន

ដែលគិតគូរអំពីសមត្ថភាពខុសៗគ្នារបស់បណ្ដាភាគី និងកសាងបន្ថែមលើបទពិសោធន៍រួម ត្រូវបានបង្កើតឡើង។

២. ក្របខណ្ឌតម្លាភាព ត្រូវផ្ដល់ភាពបត់បែននៅក្នុងការអនុវត្តប្រការនានានៃមាត្រានេះ ដល់បណ្ដាភាគីប្រទេសកំពុងអភិវឌ្ឍន៍ ដែលត្រូវការសមត្ថភាពបែបនេះ ដោយពិចារណាផងដែរអំពីសមត្ថភាពរបស់បណ្ដាភាគីទាំងនោះ។ បែបបទ នីតិវិធី និងគោលការណ៍ ណែនាំដូចមានយោងក្នុង កថាខណ្ឌ១៣ នៃមាត្រានេះ ត្រូវឆ្លុះបញ្ចាំងពីភាពបត់បែនបាននេះ។

៣. ក្របខណ្ឌតម្លាភាព ត្រូវកសាងបន្ថែមលើ និងពង្រឹងការរៀបចំតម្លាភាព នៅក្រោមអនុសញ្ញានេះ ដោយទទួលស្គាល់នូវកាលៈទេសៈ ជាពិសេសរបស់បណ្ដាប្រទេសអភិវឌ្ឍន៍តិចតួច និងរដ្ឋកូនកោះកំពុងអភិវឌ្ឍន៍ និងត្រូវអនុវត្តក្របខណ្ឌនេះតាមវិធីដែលមាន លក្ខណៈជួយសម្រួល គ្មានការរំលោភសិទ្ធិ គ្មានការដាក់ទណ្ឌកម្ម មានការគោរពអធិបតេយ្យជាតិ និងបញ្ចៀសការបង្កបន្ទុកមិនចាំបាច់មកលើបណ្ដាភាគី។

៤. ការរៀបចំតម្លាភាពនៅក្រោមអនុសញ្ញានេះ ដែលរួមទាំង របាយការណ៍ជាតិ របាយការណ៍ប្រចាំពីរឆ្នាំម្ដង និងរបាយការណ៍បច្ចុប្បន្នភាពប្រចាំពីរឆ្នាំម្ដង ការពិនិត្យនិងវាយតម្លៃជាអន្តរជាតិ ព្រមទាំងការពិគ្រោះយោបល់និងការវិភាគជាអន្តរជាតិ ត្រូវចងក្រងជាផ្នែកនៃបទពិសោធន៍ដែលបានដកស្រង់ សម្រាប់ការរៀបចំទម្រង់បែបបទ នីតិវិធី និងគោលការណ៍ណែនាំនៅក្រោមកថាខណ្ឌ១៣ នៃមាត្រានេះ។

៥. គោលបំណងនៃក្របខណ្ឌសម្រាប់តម្លាភាពនៃសកម្មភាព គឺដើម្បីផ្ដល់ការយល់ដឹងច្បាស់លាស់អំពីសកម្មភាពឆ្លើយតបនឹងការ ប្រែប្រួលអាកាសធាតុ ដោយគិតគូរផងដែរពីគោលដៅនៃអនុសញ្ញានេះ ដូចមានចែងនៅក្នុងមាត្រា២ រួមទាំងភាពច្បាស់លាស់ និងការតាមដានវឌ្ឍនភាពឆ្ពោះទៅសម្រេចបាននូវការរួមចំណែកប្ដេជ្ញាអនុវត្តនៅថ្នាក់ជាតិរបស់បណ្ដាភាគី នៅក្រោមមាត្រា៤ ហើយសកម្មភាពបន្សាំរបស់បណ្ដាភាគី នៅក្រោមមាត្រា៧ រួមទាំង ការអនុវត្តល្អ អាទិភាព តម្រូវការ និងភាពខ្វះចន្លោះ ដើម្បីរាយការណ៍ពីរបាយការណ៍សំយោគជាសកលនៅក្រោមមាត្រា១៤។

៦. គោលបំណងនៃក្របខណ្ឌសម្រាប់តម្លាភាពនៃការគាំទ្រ គឺដើម្បីផ្ដល់ភាពច្បាស់លាស់លើការគាំទ្រដែលបានផ្ដល់និងបានទទួលដោយបណ្ដាភាគីពាក់ព័ន្ធនីមួយៗ នៅក្នុងបរិបទនៃសកម្មភាពប្រែប្រួលអាកាសធាតុ នៅក្រោមមាត្រា៤, ៧, ៩, ១០ និង ១១ និងដើម្បីផ្ដល់ទិដ្ឋភាពរួមពេញលេញមួយ ទៅតាមកម្រិតអាចធ្វើបាន នៃការគាំទ្រហិរញ្ញវត្ថុសរុបដែលបានផ្ដល់ ដើម្បីរាយការណ៍ពីរបាយការណ៍សំយោគជាសកលនៅក្រោមមាត្រា១៤។

៧. ភាគីនីមួយៗត្រូវផ្ដល់ជាទៀងទាត់នូវព័ត៌មានខាងក្រោម៖

(ក) របាយការណ៍សារពើភ័ណ្ឌជាតិអំពីការបញ្ចេញឧស្ម័នដោយសកម្មភាពមនុស្សគិតតាមប្រភពបញ្ចេញ និងការស្រូបឧស្ម័នដោយអាងស្រូបឧស្ម័នផ្ទះកញ្ចក់ ដែលរៀបចំឡើងដោយប្រើប្រាស់វិធីសាស្ត្រអនុវត្តន៍ល្អ ដែលទទួលយកដោយក្រុមការងារអន្តររដ្ឋាភិបាលប្រែប្រួលអាកាសធាតុនិងឯកភាពពីសន្និសីទបណ្ដាភាគីមាននាទីជាកិច្ចប្រជុំបណ្ដាភាគីក្នុងកិច្ចព្រមព្រៀងនេះ។

(ខ) ព័ត៌មានចាំបាច់ដើម្បីតាមដានវឌ្ឍនភាពដែលសម្រេចបាននៅក្នុងការអនុវត្ត និងលទ្ធផលក្នុងការរួមចំណែកប្តេជ្ញាអនុវត្តនៅថ្នាក់ជាតិ នៅក្រោមមាត្រា៤។

៨. ភាគីនីមួយៗក៏គួរផ្តល់ព័ត៌មានទាក់ទងនឹងបន្សាំនិងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុនៅក្រោមមាត្រា៧ទៅតាមករណីសមស្រប។

៩. បណ្តាភាគីប្រទេសអភិវឌ្ឍន៍ត្រូវ ហើយបណ្តាភាគីដទៃទៀតដែលផ្តល់ការគាំទ្រក៏គួរ ផ្តល់ព័ត៌មានអំពីការគាំទ្រផ្នែកហិរញ្ញវត្ថុ ការផ្ទេរបច្ចេកវិទ្យា និងការកសាងសមត្ថភាព ដែលបានផ្តល់ឱ្យបណ្តាភាគីប្រទេសកំពុងអភិវឌ្ឍន៍នៅក្រោមមាត្រា៩, ១០ និង ១១។

១០. បណ្តាភាគីប្រទេសកំពុងអភិវឌ្ឍន៍គួរផ្តល់ព័ត៌មានអំពីតម្រូវការ និងការទទួលបាននូវការគាំទ្រផ្នែកហិរញ្ញវត្ថុ ការផ្ទេរបច្ចេកវិទ្យា និងការកសាងសមត្ថភាពនៅក្រោមមាត្រា៩, ១០ និង ១១។

១១. ព័ត៌មានដែលភាគីនីមួយៗបានដាក់ជូននៅក្រោមកថាខណ្ឌ៧និង៩ នៃមាត្រានេះ ត្រូវពិនិត្យដោយអ្នកជំនាញការបច្ចេកទេស អនុលោមតាមសេចក្តីសម្រេច 1/CP.21។ ចំពោះបណ្តាភាគីប្រទេសកំពុងអភិវឌ្ឍន៍ដែលត្រូវការព័ត៌មាននេះ ដោយគិតពិចារណាពី សមត្ថភាពរបស់ខ្លួន ដំណើរការពិនិត្យត្រូវរួមបញ្ចូលជំនួយក្នុងការកំណត់តម្រូវការកសាងសមត្ថភាព។ លើសពីនេះ ភាគីនីមួយៗ ត្រូវ ចូលរួមការអនុវត្ត និងការសម្រេចបានលើការចូលរួមចំណែកប្តេជ្ញាអនុវត្តថ្នាក់ជាតិរៀងៗខ្លួនតាមបែបសម្របសម្រួល និងការគិតគូរ បែបលក្ខណៈពហុភាគីអំពីវឌ្ឍនភាពដោយគោរពតាមកិច្ចខិតខំប្រឹងប្រែងនៅក្រោមមាត្រា៩។

១២. ការពិនិត្យរបស់អ្នកជំនាញបច្ចេកទេសនៅក្រោមកថាខណ្ឌនេះ ត្រូវរួមមានការពិចារណារបស់ភាគីដែលមានការគាំទ្រទៅតាមករណីពាក់ព័ន្ធនិងការអនុវត្តព្រមទាំងការសម្រេចបានលើការចូលរួមចំណែកប្តេជ្ញាអនុវត្តថ្នាក់ជាតិរបស់ភាគីនោះ។ ការពិនិត្យ ក៏ត្រូវកំណត់ពីវិស័យនានាសម្រាប់កែលម្អរបស់ភាគី និងរួមបញ្ចូលទាំងការពិនិត្យលើសង្គតិភាពនៃព័ត៌មានជាមួយបែបបទ នីតិវិធី និងគោលការណ៍ណែនាំ ដូចមានយោងនៅក្នុងកថាខណ្ឌ១៣ នៃមាត្រានេះ ដោយគិតគូរអំពីភាពបត់បែនដែលបានព្រមព្រៀងឱ្យ ទៅភាគីនៅក្រោមកថាខណ្ឌ២នៃមាត្រានេះ។ ការពិនិត្យនេះត្រូវផ្តោតការយកចិត្តទុកដាក់ជាពិសេសលើសមត្ថភាពនិងកាលៈទេសៈរបស់ជាតិនៃបណ្តាភាគី ប្រទេសកំពុងអភិវឌ្ឍន៍។

១៣. នាសម័យប្រជុំលើកទីមួយរបស់ខ្លួន ដោយបន្ថែមលើបទពិសោធន៍ចេញពីការចាត់ចែងដែលទាក់ទងនឹងតម្លាភាព នៅក្រោមអនុសញ្ញានេះ និងពន្យល់ពិស្តារអំពីប្រការនានានៅក្រោមមាត្រានេះ សន្និសីទបណ្តាភាគីមាននាទីជាកិច្ចប្រជុំបណ្តាភាគីក្នុងកិច្ចព្រមព្រៀងនេះត្រូវអនុម័តបែបបទ នីតិវិធី និងគោលការណ៍ណែនាំរួម ទៅតាមការណ៍សមស្រប សម្រាប់តម្លាភាពនៃសកម្មភាព និងការគាំទ្រ

១៤. ការគាំទ្រត្រូវផ្តល់ទៅឱ្យបណ្តាប្រទេសកំពុងអភិវឌ្ឍន៍សម្រាប់ការអនុវត្តមាត្រានេះ។

១៥. ការគាំទ្រត្រូវផ្តល់ជាបន្តបន្ទាប់ទៅឱ្យបណ្តាភាគីប្រទេសកំពុងអភិវឌ្ឍន៍ សម្រាប់ការកសាងសមត្ថភាពដែលទាក់ទងនឹងតម្លាភាព។

**មាត្រា១៤**

១. សន្និសីទបណ្តាភាគីមាននាទីជាកិច្ចប្រជុំបណ្តាភាគីក្នុងកិច្ចព្រមព្រៀងនេះ ត្រូវធ្វើរបាយការណ៍សំយោគទៀងទាត់អំពីការអនុវត្ត កិច្ចព្រមព្រៀងនេះ ដើម្បីវាយតម្លៃវឌ្ឍនភាពរួមគ្នា ក្នុងការឈានទៅសម្រេចបំណងនៃកិច្ចព្រមព្រៀងនេះ និងគោលបំណងរយៈពេលវែង (ដែលហៅថា "របាយការណ៍សំយោគជាសកល")។ សន្និសីទត្រូវរៀបចំឱ្យបានទូលំទូលាយ និងតាមរបៀបសម្រប សម្រួលផងដែរដោយពិចារណាអំពីការកាត់បន្ថយបន្សាំ និងមធ្យោបាយនៃការអនុវត្ត និងគាំទ្រ ហើយក្នុងបរិបទសមធម៌ និងវិទ្យាសាស្ត្រសមស្របបំផុតដែលមាន។

២. សន្និសីទបណ្តាភាគីមាននាទីជាកិច្ចប្រជុំបណ្តាភាគីក្នុងកិច្ចព្រមព្រៀងនេះ ត្រូវរៀបចំរបាយការណ៍សំយោគជាសកលលើកទី១របស់ខ្លួននៅឆ្នាំ២០២៣ និងបន្ទាប់ពីនោះ រៀងរាល់ប្រាំឆ្នាំម្តង លើកលែងតែមានការសម្រេចផ្ទុយពីនេះដោយសន្និសីទបណ្តា ភាគីមាននាទីជាកិច្ចប្រជុំបណ្តាភាគីក្នុងកិច្ចព្រមព្រៀងនេះ។

៣. លទ្ធផលនៃរបាយការណ៍សំយោគជាសកល ត្រូវជូនដំណឹងដល់បណ្តាភាគីក្នុងការធ្វើបច្ចុប្បន្នកម្ម និងការពង្រឹងសកម្មភាពនិង ការគាំទ្ររបស់ខ្លួនតាមបែបការប្តេជ្ញាអនុវត្តនៅថ្នាក់ជាតិ ស្របតាមប្រការនានានៃកិច្ចព្រមព្រៀងនេះ ក៏ដូចជាក្នុងការពង្រឹងកិច្ចសហប្រតិបត្តិការអន្តរជាតិសម្រាប់សកម្មភាពអាកាសធាតុ ។

**មាត្រា១៥**

១. យន្តការមួយដើម្បីសម្រួលឱ្យមានការអនុវត្ត និងលើកកម្ពស់អនុលោមភាពតាមប្រការនានានៃកិច្ចព្រមព្រៀងនេះ ត្រូវបានបង្កើត ឡើងចាប់ពីនេះទៅ។

២. យន្តការដូចមានយោងក្នុងកថាខណ្ឌ១ នៃមាត្រានេះ ត្រូវមានគណៈកម្មការមួយដែលមានមុខងារ និងចរិតលក្ខណៈជាអ្នកជំនាញ និងជួយសម្រួលយន្តការនេះ ប្រកបដោយតម្លាភាព មិនវាយប្រហារនិងមិនដាក់ទណ្ឌកម្មទៅភាគីណាមួយឡើយ។ គណៈកម្មការនេះត្រូវផ្តោតការយកចិត្តទុកដាក់ជាពិសេសលើកាលៈទេសៈនិងសមត្ថភាពជាតិ របស់បណ្តាភាគី។

៣. គណៈកម្មការនេះត្រូវប្រតិបត្តិការទៅតាមបែបបទ និងនីតិវិធីដែលអនុម័តដោយសន្និសីទបណ្តាភាគីមាននាទីជាកិច្ចប្រជុំបណ្តាភាគី ក្នុងកិច្ចព្រមព្រៀងនេះ នាសម័យប្រជុំលើកទី១របស់ខ្លួន និងរាយការណ៍ប្រចាំឆ្នាំទៅសន្និសីទបណ្តាភាគីមាននាទីជាកិច្ចប្រជុំបណ្តាភាគីក្នុងកិច្ចព្រមព្រៀងនេះ។

**មាត្រា១៦**

១. សន្និសីទបណ្តាភាគីដែលជាអង្គកំពូលនៃអនុសញ្ញានេះ ត្រូវមាននាទីជាកិច្ចប្រជុំបណ្តាភាគីនៅក្នុងកិច្ចព្រមព្រៀងនេះ។

២. បណ្តាភាគីក្នុងអនុសញ្ញា ដែលមិនមែនជាភាគីក្នុងកិច្ចព្រមព្រៀងនេះ អាចចូលរួមជាអ្នកសង្កេតការណ៍នៅក្នុងដំណើរការប្រព្រឹត្ត ទៅនៃសម័យប្រជុំនៃសន្និសីទបណ្តាភាគីមាននាទីជាកិច្ចប្រជុំបណ្តាភាគីក្នុងកិច្ចព្រមព្រៀងនេះ នៅពេលសន្និសីទបណ្តាភាគី មាននាទីជាកិច្ចប្រជុំបណ្តាភាគីក្នុងកិច្ចព្រមព្រៀងនេះ ការសម្រេចនានាដែលនៅក្រោមកិច្ចព្រមព្រៀង ត្រូវធ្វើឡើងដោយបណ្តាភាគីនៅក្នុងកិច្ចព្រមព្រៀងនេះតែប៉ុណ្ណោះ។

៣. នៅពេលសន្និសីទបណ្តាភាគីមាននាទីជាកិច្ចប្រជុំបណ្តាភាគីក្នុងកិច្ចព្រមព្រៀងនេះ សមាជិកណាមួយនៃការិយាល័យសន្និសីទ បណ្តាភាគី ដែលតំណាងឱ្យភាគីមួយនៅក្នុងអនុសញ្ញានេះ ប៉ុន្តែពេលនោះមិនមែនជាភាគីមួយនៅក្នុងកិច្ចព្រមព្រៀងនេះ ត្រូវជំនួសដោយសមាជិកបន្ថែមដែលត្រូវបានបោះឆ្នោតដោយនិងចេញពីក្នុងចំណោមបណ្តាកាគីនៅក្នុងកិច្ចព្រមព្រៀងនេះ។

៤. សន្និសីទបណ្តាភាគីមាននាទីជាកិច្ចប្រជុំបណ្តាកាគីក្នុងកិច្ចព្រមព្រៀងនេះ ត្រូវធ្វើការពិនិត្យជាទៀងទាត់នូវការអនុវត្តកិច្ចព្រម ព្រៀងនេះ និងត្រូវធ្វើសេចក្តីសម្រេចចាំបាច់នៅក្នុងអាណត្តិរបស់ខ្លួនដើម្បីជំរុញការអនុវត្តកិច្ចព្រមព្រៀងនេះឱ្យមានប្រសិទ្ធភាព។

សន្និសីទបណ្តាភាគីនេះត្រូវបំពេញមុខងារដែលកំណត់ដោយកិច្ចព្រមព្រៀងនេះ និងត្រូវៈ

(ក) បង្កើតអង្គចំណុះតាមការចាំបាច់សម្រាប់អនុវត្តកិច្ចព្រមព្រៀងនេះ និង

(ខ)អនុវត្តមុខងារដទៃទៀតតាមលក្ខខណ្ឌតម្រូវសម្រាប់អនុវត្តកិច្ចព្រមព្រៀងនេះ។

៥. វិធាននៃនីតិវិធីនៅក្នុងសន្និសីទបណ្តាភាគី និងនៅក្នុងនីតិវិធីហិរញ្ញវត្ថុ ដែលបានអនុវត្តនៅក្រោមអនុសញ្ញានេះ ក៏ត្រូវយកមកអនុ វត្តនៅក្រោមកិច្ចព្រមព្រៀងនេះផងដែរ ដោយមានការកែសម្រួលខ្លះៗតាមការចាំបាច់ លើកលែងតែមានការសម្រេចជាឯកឆន្ទៈ ផ្សេងទៀតដោយសន្និសីទបណ្តាភាគីមាននាទីជាកិច្ចប្រជុំបណ្តាភាគីក្នុងកិច្ចព្រមព្រៀងនេះ។

៦. សម័យប្រជុំលើកទីមួយនៃសន្និសីទបណ្តាភាគីមាននាទីជាកិច្ចប្រជុំបណ្តាភាគីក្នុងកិច្ចព្រមព្រៀងនេះនឹងត្រូវបានកោះប្រជុំ ដោយលេខាធិការដ្ឋាន ដោយភ្ជាប់ជាមួយសម័យប្រជុំលើកទីមួយនៃសន្និសីទបណ្តាភាគីដែលគ្រោងធ្វើឡើងនៅក្រោយកាល បរិច្ឆេទនៃការចូលជាធរមាននៃកិច្ចព្រមព្រៀងនេះ សម័យប្រជុំសាមញ្ញជាបន្តបន្ទាប់នៃសន្និសីទបណ្តាភាគីមាននាទីជាកិច្ចប្រជុំ បណ្តាភាគីក្នុងកិច្ចព្រមព្រៀងនេះ នឹងត្រូវធ្វើឡើងព្រមពេលជាមួយគ្នានឹងសម័យប្រជុំសាមញ្ញនៃសន្និសីទបណ្តាភាគី លើកលែង តែមានការសម្រេចផ្ទុយពីនេះដោយសន្និសីទបណ្តាភាគីមាននាទីជាកិច្ចប្រជុំបណ្តាភាគីក្នុងកិច្ចព្រមព្រៀងនេះ។

៧. សម័យប្រជុំវិសាមញ្ញនៃសន្និសីទបណ្តាភាគីមាននាទីជាកិច្ចប្រជុំបណ្តាភាគីក្នុងកិច្ចព្រមព្រៀងនេះ ត្រូវធ្វើឡើងនៅក្នុងពេលណាមួយផ្សេង តាមការចាំបាច់ដោយសន្និសីទបណ្តាកាគីមាននាទីជាកិច្ចប្រជុំបណ្តាភាគីក្នុងកិច្ចព្រមព្រៀងនេះ ឬ តាមការស្នើសុំជាលាយលក្ខណ៍អក្សរដោយភាគីណាមួយនៅក្នុងករណី ដែលមានការគាំទ្រយ៉ាងតិចមួយភាគបីនៃចំនួនភាគីទាំងអស់ នៅក្នុងកំឡុងពេលប្រាំមួយខែក្រោយការជូនដំណឹងដោយលេខាធិការដ្ឋានអំពីការស្នើសុំនេះ។

៨. អង្គការសហប្រជាជាតិ និងទីភ្នាក់ងារឯកទេសរបស់ខ្លួន និងទីភ្នាក់ងារថាមពលអាតូមិកអន្តរជាតិ ក៏ដូចជា រដ្ឋសមាជិកណាមួយនៃអង្គការឬទីភ្នាក់ងារ ឬអ្នកសង្កេតការណ៍ ដែលមិនមែនជាភាគីនៅក្នុងអនុសញ្ញានេះ អាចមានតំណាងនៅក្នុងសម័យប្រជុំនានានៃ សន្និសីទបណ្តាភាគីមាននាទីជាកិច្ចប្រជុំបណ្តាភាគីក្នុងកិច្ចព្រមព្រៀងនេះ ក្នុងនាមជាអ្នកសង្កេតការណ៍។ អង្គភាព ឬទី ភ្នាក់ងារណាមួយ ទោះជាថ្នាក់ជាតិ ឬអន្តរជាតិ រដ្ឋាភិបាល ឬមិនមែនរដ្ឋាភិបាល ដែលមានសមត្ថភាពលើកិច្ចការដូចមានចែងក្នុង កិច្ចព្រមព្រៀងនេះ ហើយដែលបានជូនដំណឹងមកលេខាធិការដ្ឋានអំពីបំណង ក្នុងការបញ្ជូនតំណាងរបស់ខ្លួនចូលរួមក្នុងសម័យប្រជុំណាមួយនៃសន្និសីទបណ្តាភាគីមាននាទីជាកិច្ចប្រជុំបណ្តាភាគីក្នុងកិច្ចព្រមព្រៀងនេះ ក្នុងនាមជាអ្នកសង្កេតការណ៍ អាចបានទទួលការអនុញ្ញាតឱ្យបញ្ជូនតំណាងដើម្បីចូលរួម លុះត្រាតែមានការជំទាស់យ៉ាងតិចមួយភាគបីនៃចំនួនភាគីទាំងអស់ ក្នុងកិច្ចព្រមព្រៀងនេះ។ ការអនុញ្ញាត និងការចូលរួមរបស់អ្នកសង្កេតការណ៍ ត្រូវធ្វើឡើងតាមវិធាននៃនីតិវិធីដូចមានយោងក្នុង កថាខណ្ឌ៥ នៃមាត្រានេះ។

## មាត្រា១៧

១. លេខាធិការដ្ឋានដែលបង្កើតឡើងតាមមាត្រា៨ នៃអនុសញ្ញានេះ ត្រូវដើរតួជាលេខាធិការដ្ឋាននៃកិច្ចព្រមព្រៀងនេះ។
២. មាត្រា៨ កថាខណ្ឌ២ នៃអនុសញ្ញានេះ អំពីមុខងាររបស់លេខាធិការដ្ឋាន ហើយមាត្រា៨ កថាខណ្ឌ៣ នៃអនុសញ្ញានេះ អំពីការ រៀបចំចាត់ចែងសម្រាប់មុខងាររបស់លេខាធិការដ្ឋាន ត្រូវយកមកអនុវត្ត ដោយមានការកែសម្រួលខ្លះៗតាមការចាំបាច់នៅក្នុងកិច្ច ព្រមព្រៀងនេះ។ លើសពីនេះ លេខាធិការដ្ឋាននេះត្រូវអនុវត្តមុខងារនានាដែលបានកំណត់នៅក្រោមកិច្ចព្រមព្រៀងនេះ និងដោយ សន្និសីទបណ្តាភាគីមាននាទីជាកិច្ចប្រជុំបណ្តាភាគីក្នុងកិច្ចព្រមព្រៀងនេះ។

## មាត្រា១៨

១. អង្គចំណុះសម្រាប់ប្រឹក្សាយោបល់ផ្នែកវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា និងអង្គចំណុះសម្រាប់អនុវត្តន៍ ដែលបានបង្កើតឡើងតាម មាត្រា៩ និង១០នៃអនុសញ្ញាត្រូវមាននាទីជាអង្គចំណុះសម្រាប់ប្រឹក្សាយោបល់ផ្នែកវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា និងអង្គចំណុះ សម្រាប់អនុវត្តន៍នៃកិច្ចព្រមព្រៀងនេះ។ ប្រការនានានៃអនុសញ្ញានេះ ដែលទាក់ទងនឹងមុខងាររបស់អង្គចំណុះទាំងពីរនេះ ត្រូវតែយកមកអនុវត្តសម្រាប់កិច្ចព្រមព្រៀងនេះ ដោយមានការកែសម្រួលខ្លះៗតាមការចាំបាច់ សម័យប្រជុំនៃអង្គចំណុះសម្រាប់ ប្រឹក្សាយោបល់ផ្នែកវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា និងអង្គចំណុះសម្រាប់អនុវត្តន៍កិច្ចព្រមព្រៀងនេះ ត្រូវធ្វើឡើងជាមួយគ្នា

នឹងកិច្ច ប្រជុំនៃអង្គចំណុះសម្រាប់ផ្តល់យោបល់ផ្នែកវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា និងអង្គចំណុះសម្រាប់អនុវត្តន៍នៃអនុសញ្ញានេះ។

២. បណ្តាភាគីក្នុងអនុសញ្ញាដែលមិនមែនជាបណ្តាភាគីនៅក្នុងកិច្ចព្រមព្រៀងនេះ អាចចូលរួមជាអ្នកសង្កេតការណ៍នៅក្នុង ដំណើរការប្រព្រឹត្តទៅនៃសម័យប្រជុំណាមួយរបស់អង្គចំណុះ។ នៅពេលដែលអង្គចំណុះទាំងនេះ ដើរតួជាអង្គចំណុះនៃកិច្ចព្រមព្រៀងនេះ សេចក្តីសម្រេចនានានៅក្រោមកិច្ចព្រមព្រៀងនេះ នឹងត្រូវធ្វើឡើងដោយបណ្តាភាគីក្នុងកិច្ចព្រមព្រៀងនេះតែប៉ុណ្ណោះ។

៣. នៅពេលដែលអង្គចំណុះនានាដែលបានបង្កើតឡើងតាមមាត្រា៩ និង១០ នៃអនុសញ្ញានេះ អនុវត្តមុខងាររបស់ខ្លួនទាក់ទង ជាមួយកិច្ចការនានាពាក់ព័ន្ធនឹងកិច្ចព្រមព្រៀងនេះ សមាជិកណាមួយក្នុងការិយាល័យរបស់អង្គចំណុះដែលតំណាងឱ្យភាគីណា មួយនៅក្នុងអនុសញ្ញានេះ ប៉ុន្តែនៅពេលនោះពុំមែនជាភាគីនៃកិច្ចព្រមព្រៀងនេះ ត្រូវតែជំនួសដោយសមាជិកបន្ថែមដែលនឹងត្រូវ ជ្រើសរើសដោយនិងក្នុងចំណោមបណ្តាភាគីនៃកិច្ចព្រមព្រៀងនេះ។

## មាត្រា១៩

១. អង្គចំណុះ ឬការចាត់ចែងស្ថាប័នដទៃទៀត បានបង្កើតឡើងដោយឬនៅក្រោមអនុសញ្ញានេះ ក្រៅពីនោះត្រូវយោងទៅក្នុងកិច្ចព្រមព្រៀងនេះ ត្រូវបម្រើនាទីក្នុងកិច្ចព្រមព្រៀងនេះ ទៅតាមសេចក្តីសម្រេចដោយសន្និសីទបណ្តាភាគីមាននាទីជាកិច្ចប្រជុំបណ្តាភាគី ក្នុងកិច្ចព្រមព្រៀងនេះ។ សន្និសីទបណ្តាភាគីមាននាទីជាកិច្ចប្រជុំបណ្តាភាគីក្នុងកិច្ចព្រមព្រៀងនេះ ត្រូវគូសបញ្ជាក់ពីមុខងារនានាដែលត្រូវអនុវត្តដោយអង្គចំណុះឬការចាត់ចែងបែបនេះ។

២. សន្និសីទបណ្តាភាគីមាននាទីជាកិច្ចប្រជុំបណ្តាភាគីក្នុងកិច្ចព្រមព្រៀងនេះ អាចផ្តល់សេចក្តីណែនាំបន្ថែមដល់អង្គចំណុះនិងការចាត់ចែងបែបនេះ។

## មាត្រា២០

១. កិច្ចព្រមព្រៀងនេះនឹងត្រូវបើកចំហរសម្រាប់ការចុះហត្ថលេខា និងផ្តល់សច្ចាប័ន ការទទួលយក ឬ ការអនុម័តដោយរដ្ឋនានា និង អង្គការសមាហរណកម្មសេដ្ឋកិច្ចតំបន់ ដែលជាភាគីក្នុងអនុសញ្ញានេះ។ កិច្ចព្រមព្រៀងនេះនឹងត្រូវបើកចំហរសម្រាប់ការចុះហត្ថលេខានៅស្នាក់ការកណ្តាលនៃអង្គការសហប្រជាជាតិ នាទីក្រុងញូវយ៉ក ចាប់ពីថ្ងៃទី២២ ខែមេសា ឆ្នាំ២០១៦ ដល់ ថ្ងៃទី២១ ខែ មេសា ឆ្នាំ២០១៧។ ចាប់ពីពេលនោះតទៅ កិច្ចព្រមព្រៀងនេះនឹងត្រូវបើកចំហរសម្រាប់ការសុំចូលរួមជាភាគី គិតចាប់ពីកាលបរិច្ឆេទ ដែល

បិទបញ្ចប់សម្រាប់ការចុះហត្ថលេខា។ លិខិតូបករណ៍នៃការផ្តល់សច្ចាប័ន ការទទួលយក ការអនុម័ត ឬការសុំចូលរួម ជាភាគី នឹងត្រូវរក្សាទុកនៅក្នុងកន្លែងតំកល់ឯកសារ។

២. អង្គការសមាហរណកម្មសេដ្ឋកិច្ចតំបន់ណាមួយដែលក្លាយជាភាគីមួយក្នុងកិច្ចព្រមព្រៀងនេះ ដោយគ្មានរដ្ឋសមាជិកណាមួយ របស់ខ្លួនជាភាគីនៅក្នុងកិច្ចព្រមព្រៀងនេះ ត្រូវតែមានភារៈកិច្ចអនុវត្តគ្រប់កាតព្វកិច្ចនៅក្រោមកិច្ចព្រមព្រៀងនេះ។ នៅក្នុងករណី ដែលអង្គការសមាហរណកម្មសេដ្ឋកិច្ចតំបន់ ដែលមានរដ្ឋជាសមាជិកមួយឬច្រើន ដែលជាភាគីនៅក្នុងកិច្ចព្រមព្រៀងនេះ អង្គការ នោះនិងរដ្ឋសមាជិករបស់ខ្លួន ត្រូវធ្វើសេចក្តីសម្រេចអំពីការទទួលខុសត្រូវរៀងៗខ្លួនសម្រាប់ការបំពេលកាតព្វកិច្ចនៅក្រោមកិច្ច ព្រមព្រៀងនេះ។ នៅក្នុងករណីបែបនេះ អង្គការនោះនិងរដ្ឋជាសមាជិករបស់ខ្លួន មិនត្រូវទទួលបានសិទ្ធិអនុវត្តន៍នានានៅក្រោម កិច្ចព្រមព្រៀងនេះ នៅក្នុងពេលទន្ទឹមគ្នា។

៣. នៅក្នុងលិខិតូបករណ៍នៃការផ្តល់សច្ចាប័ន ការទទួលយក ការអនុម័ត ឬការចូលរួមជាភាគី អង្គការសមាហរណកម្មសេដ្ឋកិច្ចតំបន់ត្រូវប្រកាសវិសាលភាពនៃសមត្ថកិច្ចរបស់ខ្លួន ដែលទាក់ទងនឹងកិច្ចការនានាមានចែងនៅក្នុងកិច្ចព្រមព្រៀងនេះ។ អង្គការទាំងនេះត្រូវជូនដំណឹងដល់កន្លែងតំកល់ឯកសារដែលត្រូវជូនដំណឹងជាបន្តទៅភាគីនានា អំពីការកែប្រែជាទ្រង់ទ្រាយធំណាមួយ ចំពោះវិសាលភាពនៃសមត្ថកិច្ចរបស់ពួកគេ។

## មាត្រា ២១

១. កិច្ចព្រមព្រៀងនេះត្រូវចូលជាធរមាននៅក្នុងរយៈពេលសាមសិបថ្ងៃក្រោយកាលបរិច្ឆេទ ដែលយ៉ាងតិចមានភាគីចំនួន៥៥ នៃអនុ សញ្ញានេះ ដែលគិតជាបរិមាណសរុប យ៉ាងតិចប្រមាណ៥៥ ភាគរយនៃការបញ្ចេញឧស្ម័នផ្ទះកញ្ចក់សរុបលើពិភពលោក បានដាក់តំកល់លិខិតូបករណ៍របស់ខ្លួននៃការផ្តល់សច្ចាប័ន ការទទួលយក ការអនុម័ត ឬ ការចូលរួមជាភាគី។

២. សម្រាប់គោលបំណងដែលបានកំណត់តែមួយគត់ដូចក្នុងកថាខណ្ឌ១ នៃមាត្រានេះ "ការបញ្ចេញឧស្ម័នផ្ទះកញ្ចក់សរុបលើពិភពលោក" មានន័យថាជាបរិមាណឧស្ម័នថ្មីបំផុតដែលមាននៅក្នុងរបាយការណ៍ ឬមុនកាលបរិច្ឆេទនៃការអនុម័តកិច្ចព្រមព្រៀងនេះដោយបណ្តាភាគីក្នុងអនុសញ្ញានេះ។

៣. សម្រាប់រដ្ឋនីមួយៗ ឬអង្គការសមាហរណកម្មសេដ្ឋកិច្ចតំបន់ដែលផ្តល់សច្ចាប័ន ទទួលយក ឬអនុម័តកិច្ចព្រមព្រៀងនេះ ឬចូលរួម ជាភាគីបន្ទាប់ពីបានបំពេញតាមលក្ខខណ្ឌដូចមានចែងក្នុងកថាខណ្ឌ១នៃមាត្រានេះកិច្ចព្រមព្រៀងនេះនឹងចូលជាធរមាន នៅក្នុងរយៈពេលសាមសិបថ្ងៃក្រោយកាលបរិច្ឆេទនៃការដាក់តំកល់លិខិតូបករណ៍របស់ខ្លួននៃការផ្តល់សច្ចាប័ន ការទទួលយក ការអនុម័ត ឬ ការចូលរួមជាភាគីដោយរដ្ឋ ឬអង្គការសមាហរណកម្មសេដ្ឋកិច្ចតំបន់។ ៤សម្រាប់បំណងនៃកថាខណ្ឌ១ នៃមាត្រានេះលិខិតូប

ករណីណាមួយដែលបានតំកល់ទុកដោយអង្គការសមាហរណកម្មសេដ្ឋកិច្ចតំបន់ មិនត្រូវបានរាប់បញ្ចូលបន្ថែមទៅលើលិខិតូបករណ៍ដែលបានតំកល់ដោយរដ្ឋជាសមាជិករបស់ខ្លួនឡើយ។

## មាត្រា២២

ប្រការនានាក្នុងមាត្រា១៥ នៃអនុសញ្ញាស្តីពីការអនុម័តលើវិសោធនកម្មអនុសញ្ញានេះ ត្រូវយកមកអនុវត្តដោយមានការកែសម្រួល ខ្លះៗតាមការចាំបាច់ចំពោះកិច្ចព្រមព្រៀងនេះ។

## មាត្រា២៣

១. ប្រការនានាក្នុងមាត្រា១៦ នៃអនុសញ្ញាស្តីពីការអនុម័ត និងវិសោធនកម្មឧបសម្ព័ន្ធនានានៃអនុសញ្ញានេះ ត្រូវយកមកអនុវត្តដោយមានការកែសម្រួលខ្លះៗតាមការចាំបាច់ចំពោះកិច្ចព្រមព្រៀងនេះ ។

២. ឧបសម្ព័ន្ធនានានៃកិច្ចព្រមព្រៀងនេះ ត្រូវតែជាទម្រង់ផ្នែកសំខាន់មួយ និងលើកលែងតែមានការចែងផ្ទុយពីនេះ សេចក្តីយោងនៃ កិច្ចព្រមព្រៀងនេះក៏ជាសេចក្តីយោងទៅនឹងឧបសម្ព័ន្ធណាមួយផងដែរ។ ឧបសម្ព័ន្ធបែបនេះត្រូវរៀបចំជាបញ្ជី ទម្រង់ឯកសារ និងសម្ភារៈដទៃទៀតដែលមានលក្ខណៈពិពណ៌នាតាមបែប វិទ្យាសាស្ត្រ បច្ចេកទេស នីតិវិធី ឬរដ្ឋបាល។

## មាត្រា២៤

ប្រការនានាក្នុងមាត្រា១៤ នៃអនុសញ្ញាស្តីពីការដោះស្រាយទំនាស់ ត្រូវយកមកអនុវត្តដោយមានការកែសម្រួលតាមការចាំបាច់ចំពោះកិច្ចព្រមព្រៀងនេះ។

## មាត្រា២៥

១. ភាគីនីមួយៗត្រូវមានសម្លេងមួយនៅក្នុងការបោះឆ្នោត លើកលែងតែករណីដូចមានចែងក្នុងកថាខណ្ឌ ២ នៃមាត្រានេះ។

២. នៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន អង្គការសមាហរណកម្មសេដ្ឋកិច្ចតំបន់ត្រូវអនុវត្តសិទ្ធិរបស់ខ្លួនដើម្បីបោះឆ្នោតដោយមាន សម្លេងឆ្នោតស្មើទៅនឹងចំនួនបណ្តារដ្ឋជាសមាជិកជាភាគីក្នុងកិច្ចព្រមព្រៀងនេះ។ អង្គការ នោះមិនត្រូវអនុវត្តសិទ្ធិរបស់ខ្លួនក្នុងការ បោះឆ្នោតឡើយ ផ្ទុយមកវិញ ប្រសិនបើរដ្ឋជាសមាជិករបស់ខ្លួនអនុវត្តសិទ្ធិ ក្នុងការបោះឆ្នោត។

## មាត្រា២៦

អគ្គលេខាធិការនៃអង្គការសហប្រជាជាតិ ត្រូវតែជាអ្នកតំកល់ទុកកិច្ចព្រមព្រៀងនេះ។

## មាត្រា២៧

គ្មានសេចក្តីបម្រុងណាមួយអាចត្រូវបានធ្វើឡើងសម្រាប់កិច្ចព្រមព្រៀងនេះ។

## មាត្រា២៨

១. ក្រោយរយៈពេលបីឆ្នាំក្នុងពេលណាមួយ គិតចាប់ពីកាលបរិច្ឆេទដែលកិច្ចព្រមព្រៀងនេះបានចូលជាធរមានសម្រាប់ភាគីមួយ ភាគីនោះអាចដកខ្លួនចេញពីកិច្ចព្រមព្រៀងនេះ ដោយជូនដំណឹងជាលាយលក្ខណ៍អក្សរមកកន្លែងតំកល់ឯកសារ។
២. រាល់ការដកខ្លួនណាមួយ ត្រូវមានប្រសិទ្ធភាពក្នុងរយៈពេលមួយឆ្នាំនៃការផុតកំណត់ដោយគិតចាប់ពីកាលបរិច្ឆេទ ដែលកន្លែងតំ កល់ឯកសារបានទទួលសេចក្តីជូនដំណឹងអំពីការដកខ្លួនចេញនេះ ឬនៅកាលបរិច្ឆេទណាមួយក្រោយមក តាមការបញ្ជាក់ក្នុងសេចក្តីជូនដំណឹងអំពីការដកខ្លួនចេញនោះ។
៣. បណ្តាភាគីណាមួយដែលដកខ្លួនចេញពីអនុសញ្ញានេះ ត្រូវបានចាត់ទុកថាបានដកខ្លួនចេញពីកិច្ចព្រមព្រៀងនេះផងដែរ។

## មាត្រា២៩

ច្បាប់ដើមនៃកិច្ចព្រមព្រៀងនេះ ដែលមានអត្ថបទជាភាសាអារ៉ាប់ ចិន អង់គ្លេស បារាំង រុស្ស៊ី និងអេស្ប៉ាញមានតម្លៃប្រើប្រាស់ត្រឹមត្រូវ ដូចគ្នា ត្រូវដាក់តំកល់ទុកដោយអគ្គលេខាធិការនៃអង្គការសហប្រជាជាតិ។

ធ្វើនៅក្រុងប៉ារីស ថ្ងៃទី១២ខែធ្នូ ឆ្នាំ២០១៥។
ដើម្បីជាសាក្សី អ្នកទទួលសិទ្ធិប្រទាន ដើម្បីចុះហត្ថលេខា បានចុះហត្ថលេខាដើម្បីផ្តល់សុពលភាពលើកិច្ចព្រមព្រៀងនេះ។

# មេរៀនទី ៥ ពិធីសារ និងអនុសញ្ញាក្របខណ្ឌពាក់ព័ន្ធផ្សេងៗ

## ១. ពិធីសារកាតាហ្សេណា

### ការអនុម័តយល់ព្រមលើពិធីសារកាតាហ្សេណាស្តីពីជីវសុវត្ថិភាព

ពិធីសារកាតាហ្សេណាស្តីពីជីវសុវត្ថិភាពបានរៀបចំឡើង និងអនុម័តដោយសន្និសីទនៃភាគីចុះកិច្ចសន្យា នៅថ្ងៃទី ២៧ ខែ មករា ឆ្នាំ ២០០២។ ពិធីសារនេះមានគោលបំណងការពារជីវៈចម្រុះ ឱ្យរួចផុតពីគ្រោះថ្នាក់ ដែលបង្កដោយសព៌ាង្គកាយកែច្នៃរស់ ដែលជាលទ្ធផលនៃបច្ចេកវិទ្យាទំនើប។ ពិធីសារនេះ បានបង្កើតនូវបែបបទ ព្រមព្រៀងជូនព័ត៌មានជាមុន ដែលធ្វើការធានាថាប្រទេសនីមួយៗត្រូវផ្តល់ព័ត៌មានចាំបាច់សម្រាប់ធ្វើសេចក្តីសម្រេច មុននឹងឯកភាពនាំចូលសព៌ាង្គកាយបែបនេះទៅក្នុងទឹកដីរបស់ខ្លួន។

ពិធីសារនេះ ត្រូវបានរៀបចំឡើងដោយយោងតាមមាត្រា១៩ កថាខ័ណ្ឌ ៣និង៤ នៃមាត្រា១៧ និង ១៨ នៃអនុសញ្ញាអន្តរជាតិស្តីពីជីវៈចម្រុះ ដែលព្រះរាជាណាចក្រយើងបានក្លាយជាសមាជិក នៅថ្ងៃទី ៩ ខែ កុម្ភៈ ឆ្នាំ ១៩៩៥ រួចមកហើយ ។ ពិធីសារនេះមាន ៤០ មាត្រា ហើយនិងមានប្រទេសជាង ៥០ បានផ្តល់សច្ចានុម័តរួចហើយ។

- ហេតុអ្វីបានជាចាំបាច់ចូលរួមពិធីសារកាតាហ្សេណាស្តីពីជីវសុវត្ថិភាពនេះ? ហេតុផលមានច្រើន ដែលទាក់ទង នឹងផ្លូវច្បាប់ និងផលប្រយោជន៍៖

១. នយោបាយ

ព្រះរាជាណាចក្រកម្ពុជា បានចូលជាសមាជិកនៃអនុសញ្ញាអន្តរជាតិស្តីពីជីវៈចម្រុះ ដែលពិធីសារកាតាហ្សេណាស្ថិតនៅក្រោមអនុសញ្ញានេះ យោងតាមមាត្រា៩នៃអនុសញ្ញាស្តីពីជីវៈចម្រុះ ប្រទេសយើងត្រូវតែ បំពេញកាតព្វកិច្ចក្នុងការរៀបចំផែនការនយោបាយ ដើម្បីគ្រប់គ្រងជីវសុវត្ថិភាព និងបច្ចេកវិទ្យា។ ក្រោយមក យោងតាមអនុសាសន៍សន្និសីទភាគីចុះកិច្ចសន្យា បានសំណូមពរឱ្យប្រទេសដែលចូលជាភាគីនៃអនុសញ្ញានេះស្តីពីជីវៈចម្រុះ ចុះហត្ថលេខា ឬផ្តល់សច្ចាប័នដល់ពីធីសារកាតាហ្សេណាស្តីពីជីវសុវត្ថិភាពឱ្យបានឆាប់ ។

២. ផលប្រយោជន៍សង្គកិច្ច

- ការពារផលិតផលកសិកម្ម សត្វ និងរុក្ខជាតិក្នុងស្រុក ដើម្បីកុំឱ្យមានការឈ្លានពានដោយផលិតផល សព៌ាង្គកាយកែច្នៃរស់ និងសព៌ាង្គកាយកែច្នៃដែលនាំចូលពីខាងក្រៅ និងបង្កឱ្យមានការប៉ះពាល់ប្រភេទក្នុងស្រុក ។
- ទទួលជំនួយពីអង្គការមូលនិធិបរិស្ថានពិភពលោក ដើម្បីរៀបចំក្របខ័ណ្ឌជីវសុវត្ថិភាពជាតិ ក្នុងការទប់ស្កាត់ គ្រោះថ្នាក់ ដែលបណ្តាលមកពីគ្មានការត្រួតពិនិត្យត្រឹមត្រូវ ឬការតាមដានការនាំចូលផលិតផល សព៌ាង្គកាយករស់ និងសព៌ាង្គកាយកែច្នៃមកពីក្រៅប្រទេស ។

- បណ្តុះបណ្តាលមន្ត្រីរាជការលើមុខវិជ្ជាពាក់ព័ន្ធឬសមត្ថភាពស្ថាប័ន ក្នុងការគ្រប់គ្រងសព៌ាង្គកាយកែច្នៃរសំ និងសពាង្គកាយកែច្នៃ ដូចជាការវាយតម្លៃហានិភ័យ និងគ្រប់គ្រងហានិភ័យ។
- ដើរទាន់និន្នាការពិភពលោក និងតំបន់លើវិស័យជីវៈចម្រុះ និងការគ្រប់គ្រងជីវសុវត្ថិភាព ។

៣. សហប្រតិបត្តិការអន្តរជាតិ

- កិច្ចប្រជុំរដ្ឋមន្ត្រីខាងផ្នែកកសិកម្ម និងរុក្ខា ដែលរៀបចំឡើង នៅថ្ងៃទី២៨-២៩ ឆ្នាំ ១៩៩៩ នៅប្រទេសប៊្រុយណេ បានសំណូមពរឱ្យប្រទេសនីមួយៗ បង្កើតអាជ្ញាធរទទួលខុសត្រូវកែតម្រូវលើសេនេទិច អង្គប្រជុំ ក៏បានឯកភាពលើគោលការណ៍ណែនាំស្តីពីការវាយតម្លៃគ្រោះថ្នាក់បណ្តាលមកពីសាព៌ាង្គកាយកែសម្រួលសេនទិច ទាក់ទងនឹងផ្នែកកសិកម្ម ។ តែទោះបីជាយ៉ាងណាក៏ដោយក៏គោលការណ៍នេះ ពុំទាន់មានប្រសិទ្ធភាពលើច្បាប់នេះឡើយ ។
- ផលប្រយោជន៍ផ្សេងៗទៀតដែលមិនអាចវាស់វែងបាន ដែលប្រទេសកម្ពុជាយើងនឹងទទួលពីការចូលជា សមាជិកនៃពិធីសារនេះ ដូចជាការពង្រឹងសមត្ថភាពផ្នែកស្ថាប័ន និងប្រព័ន្ធសម្រាប់ការគ្រប់គ្រងសព៌ាង្គកាយកែច្នៃរស់ ជាដើម ។

## ១.១ ពិធីសារកាតាហ្សេណា ស្តីពីជីវសុវត្ថិភាពនៃអនុសញ្ញាស្តីពីជីវៈចម្រុះ

ភាគីចុះកិច្ចសន្យាទៅនឹងពិធីសារនេះ ៖

ជាភាគីនៃអនុសញ្ញាអន្តរជាតិស្តីពីជីវៈចម្រុះ យោងទៅតាមអនុសញ្ញានេះ ។

បានឃើញមាត្រាទី ១៩ ក្នុងឃ្លាមី ៣ និងទី៤ ហើយនឹងមាត្រាទី ៨ និងទី ១៧នៃអនុសញ្ញានេះ ។ បានឃើញសេចក្តីសម្រេច II/៥ នៃសន្និសីទភាគីអនុសញ្ញាទាំងអស់ ដើម្បីធ្វើការកែសំរួលពិធីសារ ស្តីពីជីវសុវត្ថិភាព នៅថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ដោយផ្តោតការយកទុកដាក់ជាពិសេសទៅលើចលនាឆ្លងដែននៃសារពាង្គកាយកែច្នៃរស់ ដែលជាលទ្ធផលនៃបច្ចេកវិទ្យាទំនើប ហើយអាចបង្កអោយមានឥទ្ធិពលអវិជ្ជមានដល់ការអភិរក្ស និងនិរន្តរភាពន ការប្រើប្រាស់ធនធានជីវៈចម្រុះ ដែលកំណត់ចេញសម្រាប់ធ្វើការពិចារណាទៅលើនិតិវិធីសមស្របសម្រាប់ការព្រមព្រៀងដែលជូន ព័ត៌មានជាមុន។

ដោយធ្វើការអះអាងជាថ្មីឡើងវិញនូវវិធានការណ៍ការពារដែលមាននៅក្នុងគោលការណ៍ទី ១៥ នៃសេចក្តីប្រកាស Rio ស្តីពីបរិស្ថាន និងការអភិវឌ្ឍន៍ ។

ដោយយល់ដឹងពីការរីកចំរើននជីវបច្ចេកវិទ្យាទំនើប និង ការកើនឡើងនូវការព្រួយបារម្ភរបស់សាធារណៈពីឥទ្ធិពល អវិជ្ជមានទៅលើធនធានជីវៈចំរុះ និងសុខភាពមនុស្ស ។

ដោយទទួលស្គាល់ថា ជីវបច្ចេកវិទ្យាទំនើបមានអត្ថប្រយោជន៍យ៉ាងច្រើនសម្រាប់មនុស្សលោក ប្រសិនបើត្រូវបានប្រើប្រាស់ដោយមានវិធានការណ៍សុវត្ថិភាពត្រឹមត្រូវ សម្រាប់បរិស្ថាន និងសុខភាពមនុស្ស ។

ដោយទទួលស្គាល់ផងដែរនូវសារៈសំខាន់ដល់ប្រភពមជ្ឈមណ្ឌលដើមកំណើតរបស់មនុស្សលោក និងមណ្ឌលសេនេទិចចំរុះ

ដោយដឹងថាសមត្ថភាពនៃប្រទេសជាច្រើននៅមានកម្រិត ជាពិសេសប្រទេសកំពុងអភិវឌ្ឍន៍ ដើម្បីដោះស្រាយ។ គ្រោះថ្នាក់មកពីធម្មជាតិ និងកម្រិតនៃគ្រោះថ្នាក់ធំ១ដែលបណ្តាលមកពីសារពាង្គកាយកែច្នៃរស់ ។

ដោយទទួលស្គាល់ថាកិច្ចព្រមព្រៀងពាណិជ្ជកម្ម និងកិច្ចព្រមព្រៀងបរិស្ថានត្រូវមានទំនាក់ទំនងគ្នាទៅវិញទៅមកដើម្បីសម្រេចអោយបាននូវការអភិវឌ្ឍន៍ប្រកបដោយចីរភាព ។

ដោយកត់សំគាល់ផងដែរថា ពិធីសារនេះនឹងមិនត្រូវបានបកស្រាយទៅលើការផ្លះបញ្ចាំងនូវការផ្លាស់ប្តូរសិទ្ធិ និងកាតព្វកិច្ចនៃ ភាគីចុះកិច្ចសន្យានៅក្រោមកិច្ចព្រមព្រៀងអន្តរជាតិដែលមានស្រាប់ ។

ដោយយល់ឃើញថា រាល់ចំនុចដែលបានរៀបរាប់ខាងលើនេះ ពុំមានបំណងដាក់ពិធីសារនេះអោយរណបទៅនឹង កិច្ចព្រមព្រៀងអន្តរជាតិដទៃទៀតទេ ។ ភាគីចុះកិច្ចសន្យាបានឯកភាពខាងក្រោម ៖

### ១.១.១ គោលបំណង

អនុលោមទៅតាមវិធានការណ៍ប្រុងប្រយ័ត្នដែលចែងទៅក្នុងគោលការណ៍ទី១៥ នៃសចក្តីប្រកាសទីក្រុង Rio ស្តីពី បរិស្ថាន និងការអភិវឌ្ឍន៍ គោលបំណងនៃពិធីសារនេះ គឺដើម្បីរួមវិភាគទានក្នុងការធានាកម្រិតការពារឱ្យបានសមស្រប នៅក្នុងការផ្ទេរ ការគ្រប់គ្រង និងការប្រើប្រាស់ឱ្យមានសុវត្ថិភាពនៃសារពាង្គកាយកែច្នៃរស់ ដែលជាលទ្ធផលនៃជីវបច្ចេកវិទ្យាទំនើប ដែលអាចនាំមកនូវផលប៉ះពាល់អវិជ្ជមានដល់ការអភិរក្ស និងការប្រើប្រាស់ដោយនិរន្តរភាពនូវធនធានជីវៈចម្រុះដោយគិតគូរ អំពីគ្រោះថ្នាក់ដល់សុខភាពមនុស្ស និងជាពិសេសផ្តោតការចាប់អារម្មណ៍សំខាន់ទៅលើចលនាឆ្លងដែនផងដែរ ។

### ១.១.២ លក្ខខ័ណ្ឌទូទៅ

១. ភាគីនីមួយៗ នៃពិធីសារអន្តរជាតិនេះ ត្រូវប្រកាន់យកនូវវិធានការច្បាប់ គ្រប់គ្រងសមស្រប និងចាំបាច់ និងវិធានការណ៍ផ្សេងៗទៀត ដើម្បីប្រតិបត្តិកាតព្វកិច្ចរបស់ខ្លួនដែលមានចែងនៅក្នុងពិធីសារនេះ ។

២. ភាគីត្រូវធានាថា ការអភិវឌ្ឍន៍ ការគ្រប់គ្រង ការដឹកជញ្ជូន ការប្រើប្រាស់ ការផ្ទេរ និងការបញ្ចេញនូវសារពាង្គកាយកែច្នៃរស់ត្រូវបានធ្វើឡើងក្នុងគោលបំណងការពារ ឬ ការកាត់បន្ថយគ្រោះថ្នាក់ដល់ជីវៈចម្រុះ ៖ ដោយត្រូវគិតគូរពី គ្រោះថ្នាក់ដល់សុខភាពមនុស្សផងដែរ ។

៣. ពុំមានចំនុចណាមួយនៅក្នុងពិធីសារនេះ ប៉ះពាល់ទៅលើអធិបតេយ្យភាពដែនសមុទ្ររបស់រដ្ឋទាំងអស់ដែលបាន បង្កើតឡើងដោយអនុលោមទៅតាមច្បាប់អន្តរជាតិនោះទេ ហើយសិទ្ធិអធិបតេយ្យភាព និងដែនសមត្ថកិច្ចដែលរដ្ឋទាំងនោះ មានបញ្ជាក់នៅក្នុងតំបន់សេដ្ឋកិច្ចផ្តាច់មុខ (Exclusive Economic Zone) របស់ខ្លួន និងកិច្ចការពារទ្វីបរបស់គេដោយ ផ្អែកទៅតាមច្បាប់អន្តរជាតិ ព្រមទាំងការប្រើប្រាស់សិទ្ធិ និងសេរី

ភាពក្នុងការធ្វើចរាចរផ្លូវទឹក និងផ្លូវអាកាសរបស់ប្រទេស នីមួយៗ ដូចមានចែងក្នុងច្បាប់អន្តរជាតិ និងបានឆ្លុះបញ្ចាំងនៅក្នុងច្បាប់អន្តរជាតិពាក់ពន្ធ័នានា ។

៤. គ្មានចំនុចណាមួយនៃពិធីសារនេះ ត្រូវបានបកស្រាយថាជាការដាក់កំហិតសិទ្ធិរបស់ភាគីណាមួយក្នុងការចាត់ វិធានការណ៍ការពារបន្ថែមនៃការប្រើប្រាស់ និងការអភិរក្សជីវៈចម្រុះដោយនិរន្តភាពច្រើនជាងការអំពាវនាវដែលបញ្ជាក់ក្នុង ពិធីសារនេះ ចែងថាវិធានការណ៍នេះគឺស្របទៅនឹងគោលបំណង និង "ខ" នៃពិធីសារនេះ ហើយអនុលោមទៅនឹង កាតព្វកិច្ចដទៃទៀតរបស់ភាគីផ្សេងទៀតដែលស្ថិតនៅក្រោមច្បាប់អន្តរជាតិ ។

៥. ភាគីទាំងអស់ត្រូវបានជំរុញឱ្យធ្វើការពិចារណាឱ្យបានសមស្របទៅលើជំនាញដែលមានស្រាប់ ឧបករណ៍ ច្បាប់និងការងារដែលអនុវត្តក្នុងវេទិការអន្តរជាតិ រួមជាមួយនឹងសមត្ថកិច្ចនៅក្នុងផ្នែកព្រោះថ្នាក់ដល់សុខភាពមនុស្ស ។

### ១.១.៣ ការប្រើប្រាស់ពាក្យ

សម្រាប់គោលបំណងនៃពិធីសារនេះ៖

១. " សន្និសីទភាគី " មានន័យថាជាសន្និសីទនៃភាគីទាំងអស់ដែលចុះកិច្ចសន្យាទៅនឹងអនុសញ្ញា ។

២. "ព្រំដែននៃការប្រើប្រាស់ "មានន័យថាជាការប្រើប្រាស់ណាមួយ ដែលធ្វើឡើងនៅក្នុងឧបករណ៍ សម្ភារៈ តំឡើងការផ្ទុក ឬរចនាសម្ព័ន្ធរូបសាស្ត្រទាក់ទងទៅនឹងសារពាង្គកាយកែច្នៃរស់ ដែលត្រូវបានត្រួតពិនិត្យដោយវិធានការណ៍ច្បាស់លាស់ ដែលកាត់បន្ថយយ៉ាងសាកសិទ្ធនូវការប៉ះពាល់ផ្ទាល់ជាមួយសារពាង្គកាយនោះ និងប៉ះពាល់លើបរិស្ថានខាងក្រៅ ។

៣. " ការនាំចេញ " មានន័យថាចលនាឆ្លងដែនអន្តរជាតិពីភាគីមួយទៅភាគីមួយទៀត ។

៤. " អ្នកនាំចេញ " មានន័យថានីតិបុគ្គល ស្ថិតនៅក្រោមដែនសមត្ថកិច្ចនៃភាគីចុះកិច្ចសន្យា ចាត់ចែងធ្វើការនាំចេញនូវសារពាង្គកាយកែច្នៃរស់ ។

៥. "ការនាំចូល" មានន័យថាចលនាឆ្លងដែនអន្តរជាតិ ពីភាគីមួយទៅភាគីមួយទៀត

៦. "អ្នកនាំចូល" មានន័យថានីតិបុគ្គលណាមួយ ដែលស្ថិតនៅក្រោមដែនសមត្ថកិច្ចនៃភាគីចុះកិច្ចសន្យានាំចូលដែលជាអ្នកចាត់ចែងធ្វើការនាំចូលនូវសារពាង្គកាយកែច្នៃរស់ ។

៧. សារពាង្គកាយកែច្នៃរស់ " មានន័យថាសាពារង្គកាយរស់ដែលមានផ្ទុកនូវសារជាតុសេនេទិចថ្មី ទទួលយកតាមរយៈការប្រើប្រាស់ជីវបច្ចេកវិទ្យាទំនើប ។

៨. "សារពាង្គកាយរស់" មានន័យថាអង្គជីវៈចម្រុះទាំងឡាយណា ដែលមានសមត្ថភាពក្នុងការផ្ទេរ ឬ ផលិតឡើងវិញ នូវសារជាតុសេនទិច រួមទាំងសារពាង្គកាយដែលមិនអាចបន្តពូជបាន វីរុស និងវីរ៉ូអ៊ីត ។

៩. " ជីវបច្ចេកវិទ្យាទំនើប " មានន័យថាការអនុវត្តន៍នូវ ៖

ក) បច្ចេកទេសអាស៊ីតនុយក្លេអ៊ិចអាំងវីត្រូ (In-vitro nucleic acid techniques) រួមមានការប្រមូលផ្តុំនូវ អាស៊ីលើឌីអុកស៊ីរីបូនុយក្លេអ៊ិក (DNA) និងការចាក់អាស៊ីតនុយក្លេអ៊ិចដោយផ្ទាល់ទៅក្នុងកោសិកា ឬសរីរាង្គ ។

ខ) ការលាយចូលគ្នានៃកោសិកាដែលមិនមែនជាគ្រួសារតែមួយ ដែលមានលទ្ធភាពយកឈ្នះនូវការផលិត ឡើងវិញតាមលក្ខណៈរូបសាស្ត្រធម្មជាតិ ឬ ឧបសគ្គប្រមូលផ្តុំ ហើយដែលមិនមែនជាបច្ចេកទេសប្រើប្រាស់នៅក្នុងការបង្កាត់ ពូជ ឬ ការជ្រើសរើសតាមរបៀបបុរាណនោះទេ ។

១០. "អង្គការសមាហរកម្មសេដ្ឋកិច្ចតំបន់" ជាអង្គការបង្កើតដោយឯករាជ្យនៅក្នុងតំបន់ ដែលសមាជិករបស់វាបានផ្ទេរសមត្ថកិច្ចទាក់ទងនឹងអភិបាលកិច្ចទៅពិធីសារនេះ ហើយដែលបានផ្តល់អំណាចត្រឹមត្រូវតាមនីតិវិធីដើម្បីចុះហត្ថលេខា ផ្តល់សច្ចាប័ន ការទទួលយក ការយល់ព្រម ឬការចូលជាសមាជិកអនុលោមតាមបែបផ្ទៃក្នុង ។

១១. "ចលនាឆ្លងដែន" ជាចលនានៃសារពាង្គកាយកែច្នៃរស់ ពីភាគីមួយទៅភាគីមួយទៀត ការពារសម្រាប់គោល បំណងនៃមាត្រាទី ១៧ និង ២៤ ចលនាឆ្លងដែន គ្របដណ្តប់ដល់ចលនារវាងភាគីចុះកិច្ចសន្យា និងភាគីមិនចុះកិច្ចសន្យា ។

### ១.១.៤ វិសាលភាព

ពិធីសារនេះត្រូវអនុវត្តន៍ចំពោះចលនាឆ្លងដែន ការស្នាក់បណ្តោះអាសន្ន ការគ្រប់គ្រង និងការប្រើប្រាស់សារពាង្គកាយកែច្នៃរស់ ដែលអាចបង្កឱ្យមានផលប៉ះពាល់អាក្រក់លើការអភិរក្ស និងការប្រើប្រាស់ដោយនិរន្តរភាពនៃជីវៈចំរុះ ដោយគិតគូពីគ្រោះថ្នាក់ដល់សុខភាពមនុស្សផងដែរ ។

## ២. ពិធីសារម៉ុងរ៉េអាល់

### សេចក្តីព្រាងច្បាប់
### ស្តីពីការអនុម័តយល់ព្រមលើពិធីសារម៉ុងរ៉េអាល់ស្តីពីសារធាតុបំផ្លាញស្រទាប់អូហ្សូន

សារធាតុក្លរ៉ូភ្លុយអរក្លរូកាបូន Chlorofluorocarbons (CFCs) ត្រូវបានគេរកឃើញនៅឆ្នាំ ១៩២៨ ក្នុងប្រេងអប៉ុង សារធាតុធ្វើឱ្យត្រជាក់មាស៊ីនត្រជាក់ សារធាតុរំលាយ សារធាតុពន្លត់អគ្គីភ័យ។ សារធាតុ CFCs មានជីវិតយូរអង្វែងដែលការភាយរបស់វានឹងឆ្ពោះទៅរកស្រទាប់អូហ្សូន និងធ្វើការបំផ្លាញឧស្ម័នអូហ្សូន។ ការបាត់បង់ស្រទាប់អូហ្សូន ត្រូវបានគេរកឃើញនៅតំបន់អង់តាក់ទិកនាឆ្នាំ១៩៨៥ ដែលតាំងពីពេលនោះ មកការបាត់បង់នេះត្រូវបានគេរកឃើញនៅរយៈកម្ពស់មធ្យម និងរយៈកម្ពស់ខ្ពស់ ។

ក្នុងការគិតគូរអំពីបរិស្ថាន អង្គការកម្មវិធីបរិស្ថានសហប្រជាជាតិត្រូវបានចាត់តាំងបង្កើតឡើងដើម្បីតាមដាន និងឃ្លាំមើលសភាពការណ៍ប្រែប្រួលនៃបរិស្ថាននៅក្នុងក្របខ័ណ្ឌសកលលោកទាំងមូល និងជាពិសេស ដើម្បីលើកឡើងនូវវិធានការចាំបាច់បន្ទាន់មួយចំនួនដែលមនុស្សជាតិត្រូវអនុវត្ត ក្នុងទិសដៅធានានូវនិរន្តភាព បរិស្ថាន និងរក្សាឱ្យបាននូវតុល្យភាពនៃភពផែនដីនៅក្នុងការអភិវឌ្ឍ ។

ស្រទាប់អូហ្សូននាពេលបច្ចុប្បន្ននេះ មាននិន្នាការផ្លាស់ប្តូរទៅរកការអន្តរាយ យ៉ាងធ្ងន់ធ្ងរដោយសារតែសកម្មភាពរបស់មនុស្សបង្កឡើង។ ការសិក្សាស្រាវជ្រាវជាច្រើនបានបង្ហាញថា ផលវិបាកដ៏ធំបំផុតនៃការបំផ្លាញ ស្រទាប់អូហ្សូន គឺការប្រែប្រួលមិនធម្មតានៃអាកាសធាតុលើភពផែនដី ដែលជះឥទ្ធិពលជាអវិជ្ជមានយ៉ាងធ្ងន់ធ្ងរ ទៅលើសុខភាពមនុស្ស ហើយបង្កឱ្យមានការខូចខាតយ៉ាងដំណំដល់ផលិតភាពរបស់ស្ថានប្រព័ន្ធធម្មជាតិ ស្ថានប្រព័ន្ធ សង្គមព្រមទាំងកត្តារូបវន្តផ្សេងៗទៀតដែលមានប្រយោជន៍សម្រាប់មនុស្សជាតិ និន្នាការនេះកំពុងត្រូវបាន តាមដាន និងត្រួតពិនិត្យយ៉ាងយកចិត្តទុកដាក់ពីសំណាក់អ្នកឯកទេសវិទ្យាសាស្ត្រផ្នែកបរិស្ថានពិភពលោក ដើម្បីដាក់ចេញនូវវិធានការជាបន្ទាន់នានា ក្នុងទិសដៅកាត់បន្ថយ និងឈានទៅបំបាត់ចោលការប្រើប្រាស់សារធាតុដែលបំផ្លាញស្រទាប់អូហ្សូននៅក្នុងពេលអនាគត។

ដើម្បីកាត់បន្ថយនូវសារធាតុបំផ្លាញស្រទាប់អូហ្សូន និងអនុវត្តអនុសញ្ញាវីយែនឱ្យមានប្រសិទ្ធភាព អង្គការកម្មវិធីបរិស្ថានពិភពលោក និងប្រតិភូមកពីប្រទេសជាច្រើនបានជួបប្រជុំគ្នានៅទីក្រុងម៉ុងរ៉េអាល់នាឆ្នាំ ១៩៨៧ ដើម្បីអនុម័តលើពិធីសារម៉ុងរ៉េអាល់ស្តីពីសារធាតុបំផ្លាញស្រទាប់អូហ្សូន។ លទ្ធផលពិធីសារនេះ ត្រូវបាន អនុម័តដោយរដ្ឋាភិបាលមកពីប្រទេសជាច្រើន។ ពិធីសារនេះមានការកែសម្រួលជាបន្តបន្ទាប់ ការកែសម្រួលនេះ ត្រូវបានពង្រឹងតាមរយៈការកែតម្រូវចំនួនបួនដងនៅក្នុងការអនុម័តនៃពិធីសារទីក្រុងឡុងដុង ១៩៩ រធ្វើ វិសោធនកម្ម ទីក្រុងកូបេនហាហ្គែន ១៩៩២ ទីក្រុងម៉ុងរ៉េអាល់ ១៩៩៧ និងទីក្រុងប៉េ

កាំង ១៩៩៩។ ពិធីសារនេះមានគោលបំណងកាត់បន្ថយ និងលប់បំបាត់នូវការភាយចេញនៃសារធាតុ ដែលបំផ្លាញស្រទាប់អូហ្សូន ដែលផលិតដោយមនុស្សជាតិ ។

ដោយពិនិត្យឃើញថា កិច្ចការពារស្រទាប់អូហ្សូន ជាកាតព្វកិច្ចរួមដ៏ចាំបាច់របស់ប្រជាពលរដ្ឋទូទាំង ពិភពលោក និងដោយឈរលើទស្សនៈ ការការពារស្រទាប់អូហ្សូន គឺជាការការពារអាយុជីវិតមនុស្ស និងបរិស្ថាន ដូចនេះមកដល់ថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ២០០២ នេះ មានប្រទេសចំនួន ១៨៣ បានផ្តល់សច្ចាប័ន លើពិធីសារម៉ុងរ៉េអាល់រួចហើយ ដែលក្នុងនោះរាជរដ្ឋាភិបាលកម្ពុជាយើងបានសម្រេចចូលជាសមាជិកនៃពិធីសារ ម៉ុងរេអាល់ ស្តីពីសារធាតុបំផ្លាញស្រទាប់អូហ្សូន នៅថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០០១ កន្លងទៅនេះ ប៉ុន្តែយើងមិនទាន់បានផ្តល់សច្ចាប័នទៅលើវិសោធនកម្មណាមួយក្នុងចំណោមវិសោធនកម្មទាំងបួននៅឡើយទេ ។ វិសោធនកម្មទាំងបួននោះមាន៖

1. The London Amendment to the Montreal Protocol ( 1990 );
2. The Copenhagen Amendment to the Montreal Protocol ( 1992 );
3. The Montreal Amendment to the Montreal Protocol ( 1997 ); and
4. The Beijing Amendment to the Montreal Protocol ( 1999 ).

ដោយពេលវេលាមានរយៈពេលខ្លី ដូចនេះយើងគួរផ្តល់សច្ចាប័នដល់វិសោធនកម្មទាំងបួននេះកាន់តែឆាប់កាន់តល្អ ។

យោងទៅលើការសិក្សាឯកសា និងបទពិសោធពីប្រទេសនានានៅក្នុងតំបន់ លើការអនុវត្តពិធីសារនេះ ដោយប្រៀបធៀបស្ថានភាពជាក់ស្តែងនៅកម្ពុជា ការផ្តល់សច្ចាប័នលើពិធីសារម៉ុងរ៉េអាល់ ស្តីពីសារធាតុបំផ្លាញ ស្រទាប់អូហ្សូន មានសារប្រយោជន៍ដូចខាងក្រោម ៖

១-ក្នុងនាមជាសមាជិកនៃពិធីសារនេះប្រទេសកម្ពុជាពុំត្រូវបង់ថវិកា ឬចំណាយណាមួយឡើយ

២-ក្នុងនាមជាសមាជិកនៃពិធីសារនេះ ប្រទេសកម្ពុជាមានកាតព្វកិច្ចចូលរួមជាមួយសហគមអន្តរជាតិ

ក្នុងការទប់ស្កាត់នូវការរិចរិលនៃស្រទាប់អូហ្សូន ដែលបង្កដោយសារធាតុបំផ្លាញស្រទាប់អូហ្សូន ដោយកាត់បន្ថយ និងលប់បំបាត់សារធាតុដែលបំផ្លាញស្រទាប់អូហ្សូន ដោយទប់ស្កាត់ និងកាត់បន្ថយការនាំចូល ការប្រើប្រាស់ ការកែច្នៃ និងការផលិតសារធាតុបំផ្លាញស្រទាប់អូហ្សូន និងឧបករណ៍ដែលប្រើប្រាស់សារធាតុ ទាំងនេះដែលឧបករណ៍ទាំងនេះភាគច្រើនជាឧបករណ៍ចាស់ៗ ជាធម្មតាប្រទេសនៅក្នុងពិភពលោកយើងកំពុងខ្ទះខ្ទែងបោះចោល ហើយឧបករណ៍ទាំងនេះនឹងត្រូវប្រើប្រាស់លែងកើតបន្ទាប់ពីឆ្នាំ ២០១០ ព្រោះសារធាតុទាំងនេះ នឹងត្រូវលុបបំបាត់ទាំងស្រុងពីលើពិភពលោកយើង ។

៣.ទទួលផលចំណេញផ្នែកនយោបាយ

- បង្ហាញពីឆន្ទៈរបស់ប្រទេសកម្ពុជា ក្នុងការរួមចំណែកដោះស្រាយបញ្ហាបរិស្ថាន ជាមួយសហគមន៍អន្តរជាតិ
- លើកកម្ពស់កិត្យានុភាពជាតិ តាមរយៈការចូលរួមប្រជុំដែលរៀបចំឡើងសម្រាប់ពិភាក្សា ដោះស្រាយបញ្ហាកាត់បន្ថយសារធាតុដែលបំផ្លាញស្រទាប់អូហ្សូន។

៤-ទទួលផលចំណេញផ្នែកបរិស្ថាន៖

- ក្នុងនាមជាសមាជិកនពិធីសារនេះ ប្រទេសកម្ពុជាទប់ស្កាត់បាននូវឥទ្ធិពលនៃការកើនកំដៅដែលធ្វើឱ្យ ខូចខាតបរិស្ថានធម្មជាតិ និងការប៉ះពាល់លើសុខភាពសាធារណៈ ដោយសារការធ្លុះធ្លាយស្រទាប់អូហ្សូន
- ទទួលបាននូវការគាំទលើជំនួយបច្ចេកទេស ក្នុងការបណ្តុះបណ្តាលការផ្តល់នូវបច្ចេកវិទ្យា និងការទទួល ព័ត៌មាន និងជំនួយជាថវិកាសម្រាប់អនុវត្តគម្រោងដែលទាក់ទងនឹងការអនុវត្តពិធីសារនេះ ដូចជា ការកែច្នៃ ការត្រួតពិនិត្យ ការនាំចូលនូវឧបករណ៍ និងសារធាតុបំផ្លាញស្រទាប់អូហ្សូន ប្រកបដោយ សុវត្ថិភាព។ ដែលបច្ចុប្បន្ននេះ យើងទទួលបានជំនួយផ្នែកពង្រឹងសមត្ថភាព និងការរៀបចំធ្វើកម្មវិធីជាតិ ដើម្បីកាត់បន្ថយ និងលប់បំបាត់សារធាតុដែលបំផ្លាញស្រទាប់អូហ្សូន ។

៥-ផលចំណេញផ្នែកសេដ្ឋកិច្ច៖

- ដោយសារកម្ពុជាយើងមិនមែនជាប្រទេសអ្នកផលិត ឬអ្នកនាំចេញឧបករណ៍ និងសារធាតុបំផ្លាញស្រទាប់អូហ្សូន ដូចនេះ ចូលជាសមាជិកវានឹងមិនបង្កផលប៉ះពាល់ជាអវិជ្ជមានដល់កម្ពុជាយើងទ
- អាចចូលរួមក្នុងការអនុវត្តគម្រោងផ្នែក ការប្រើប្រាស់ឡើងវិញ ការកែច្នៃសារធាតុដែលបំផ្លាញស្រទាប់ អូហ្សូន ដែលថវិកាទាំងនេះនឹងទទួលបានពីថវិកាពហុភាគី
- អាចទទួលបានថវិកាក្នុងការរៀបចំប្រព័ន្ធផ្តល់អាជ្ញាប័ណ្ណក្នុងការត្រួតពិនិត្យការនាំចេញនាំចូលដោយបើ ប្រព័ន្ធព័ត៌មានវិទ្យាទំនើបដែលអាចទប់ស្កាត់ចរាចរទំនិញខុសច្បាប់បានដោយមានប្រសិទ្ធភាព ។

ពិនិត្យជារួម ការចូលជាសមាជិកនៃពិធីសារនេះ ពុំនាំមកនូវផលវិបាកជាអវិជ្ជមានណាមួយដល់ការអភិវឌ្ឍសេដ្ឋកិច្ច-សង្គមរបស់កម្ពុជាឡើយ ផ្ទុយទៅវិញវាគឺជាឱកាសដ៏ល្អមួយដែលអនុញ្ញាតឱ្យកម្ពុជាទទួល បាននូវផលចំណេញលើគ្រប់វិស័យ ដូចបានរៀបរាប់ខាងលើ ដែលជាទុនយ៉ាងសំខាន់សម្រាប់រាជរដ្ឋាភិបាល ក្នុងការអនុវត្តកម្មវិធីកាត់បន្ថយភាពក្រីក្រ ការពារបរិស្ថាន និងធនធានធម្មជាតិឆ្ពោះទៅសម្រេចបាននូវការអភិវឌ្ឍ ប្រទេសប្រកបដោយនិរន្តរភាព ។

## ៣. ពិធីសារម៉ុងរ៉េអាល់ស្តីពី សារធាតុដែលបំផ្លាញស្រទាប់អូហ្សូន

ភាគីនៃពិធីសារនេះ ជាភាគីនៃអនុសញ្ញាVienna ដើម្បីការពារស្រទាប់អូហ្សូន ។

ស្ថិតនៅក្រោមអនុសញ្ញានេះ ភាគីជាសមាជិកត្រូវយល់ដឹងអំពីការតព្វកិច្ចរបស់ខ្លួនគឺអនុវត្តវិធានការសមស្របសំដៅការពារសុខភាពមនុស្ស និងបរិស្ថានប្រឆាំងឥទ្ធិពលប៉ះពាល់ផ្សេងៗ បណ្តាលមកពីសកម្មភាពមនុស្សបង្កអោយមានការផ្លាស់ប្តូរ ឬមាននិន្នាការផ្លាស់ប្តូរស្រទាប់អូហ្សូន ។

គួរយល់ដឹងចំពោះការបញ្ចេញទៅក្នុងបរិយាកាសនូវសារធាតុពុលអាចបំផ្លាញស្រទាប់មួយ ដែលជះឥទ្ធិពលអាក្រក់ដល់សុខភាពមនុស្ស និងបរិស្ថាន ។

ការយល់ដឹងពីឥទ្ធិពលប៉ះពាល់យ៉ាងខ្លាំងក្លាដល់អាកាសធាតុ ដែលបណ្តាលមកពីការបញ្ចេញទៅក្នុងបរិយាកាសនូវសារធាតុពុល ។

យល់ដឹងពីវិធានការការពារស្រទាប់ អូហ្សូនប្រឆាំងនឹងសកម្មភាពបំផ្លាញផ្សេងៗ ដោយផ្អែកទៅលើចំណេះដឹងវិទ្យាសាស្រ្ត និង គិតគូរពីផ្នែកបច្ចេកទេស និងសេដ្ឋកិច្ច ។

កំណត់ការពារស្រទាប់អូហ្សូនដោយវិធានការបង្ការជាមុនសំដៅត្រួតពិនិត្យការបញ្ចេញសារធាតុពុលដែលបំផ្លាញស្រទាប់ អូហ្សូន ទៅក្នុងបរិយាកាស ក៏ដូចជាកំណត់នូវទិសដៅខ្ពស់ក្នុងការបំបាត់ការបំផ្លាញស្រទាប់ អូហ្សូនដោយផ្អែកទៅលើមូលដ្ឋាននៃការអភិវឌ្ឍន៍ផ្នែកចំណេះដឹងវិទ្យាសាស្រ្ត ត្រិះរិះពិចារណាទៅលើបច្ចេកទេស និងសេដ្ឋកិច្ច និងគិតទៅដល់តម្រូវការអភិវឌ្ឍន៍របស់ប្រទេសកំពុងអភិវឌ្ឍន៍ ។

ការទទួលស្គាល់ចំពោះសេចក្តី ដែលមានចែងជាពិសេស គឺទាមទារតម្រូវទៅតាមសេចក្តីត្រូវការរបស់ ប្រទេសកំពុងអភិវឌ្ឍន៍រួមទាំង ដែលមានអំពីធនធានហិរញ្ញវត្ថុបន្ថែម និងសម្រាប់ប្រើប្រាស់ទៅលើបច្ចេកវិទ្យាការគិតគូរប្រមើលមើលទៅលើបរិមាណថវិកាចាំបាច់ និងវិការពឹងទុកសម្រាប់បង្កើនសមត្ថភាពតាមលក្ខណៈវិទ្យាសាស្រ្ត ដើម្បីកំណត់នូវបញ្ហាបំផ្លាញស្រទាប់អូហ្សូន និងឥទ្ធិពលរបស់វា ។

កត់សំគាល់ទៅលើវិធានការបង្ការ សម្រាប់ត្រួតពិនិត្យការបញ្ចេញសារធាតុ Chlorofluorocarbons ដែលត្រូវបានអនុវត្តដោយថ្នាក់ជាតិ និងថ្នាក់តំបន់រួចទៅហើយ ។

ការត្រិះរិះពិចារណាទៅលើសារៈសំខាន់នៃការពង្រឹងកិច្ចសហការជាលក្ខណៈអន្តរជាតិ ក្នុងការស្រាវជ្រាវ ការអភិវឌ្ឍន៍ និងការផ្លាស់ប្តូរបច្ចេកវិទ្យា ដែលទាក់ទងនឹងការត្រួតពិនិត្យនិងការកាត់បន្ថយការបញ្ចេញសារធាតុដែលបំផ្លាញស្រទាប់អូហ្សូន ក៏ដូចជាការគិតទៅលើតម្រូវការផ្ទាល់របស់ប្រទេសកំពុងអភិវឌ្ឍន៍ ។

## ៤. អនុសញ្ញា ស្តុកខូម ស្តីពី សារធាតុបំពុលសរីរាង្គមិនងាយបំបែកធាតុ

### ភាគីនៃអនុសញ្ញានេះ

- ទទួលស្គាល់ថា សារធាតុបំពុលសរីរាង្គមិនងាយបំបែកធាតុ គឺមានលក្ខណៈពុល (toxic) មិនងាយបំបែកធាតុ (persistant) និងមានភាពកំណើនបរិមាណក្នុងភាវៈរស់ (មនុស្សឬសត្វ) (bioaccumulate) ហើយ ត្រូវបានសាយភាយតាមរយៈខ្យល់ ទឹក និងពពួកសត្វបំលាស់ទីឆ្លងកាត់ពីប្រទេសមួយទៅប្រទេសមួយ និងបានធ្លាក់កកផ្តុំឆ្ងាយ ពីប្រភពបញ្ចេញ ដែលនៅទីនោះពួកវាបានប្រមូលផ្តុំនៅក្នុងប្រព័ន្ធអេកូឡូស៊ីក្នុងទឹក និងលើគោក ។
- យល់ដឹងពីបញ្ហាសុខភាពសាធារណៈ ជាពិសេសនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ ដែលជាលទ្ធផលពីការទទួលរងនូវសារធាតុបំពុលសរីរាង្គមិនងាយបំបែកធាតុ ជាពិសេសការប៉ះពាល់ទៅលើស្ត្រី ហើយតាមរយៈពួកគេនឹងបន្តទៅអ្នកជំនាន់ក្រោយ ។
- ទទួលស្គាល់ថាអេកូឡូស៊ីនៅតំបន់អាក់ទិក និងសហគមន៍ជនជាតិដែលរស់នៅទីនោះ គឺស្ថិតនៅក្នុង សភាពគ្រោះថ្នាក់ ដោយសារតែភាពកំណើនបរិមាណពេលចំលងពីភាវៈរស់មួយទៅភាវៈរស់មួយ នសារធាតុបំពុលសរីរាង្គ មិនងាយបំបែកធាតុ និងទទួលស្គាល់ថាការពុលនចំណីអាហាររបស់ពួកគេគឺជាបញ្ហាសុខភាពសាធារណៈ ។
- មានស្មារតីយល់ដឹងពីសេចក្តីតម្រូវការ ដើម្បីជាវិធានការរួមលើបញ្ហាសារធាតុសរីរាង្គមិនងាយបំបែកធាតុ ។
- យកចិត្តទុកដាក់លើសេចក្តីសម្រេចលេខ ១៩/១៣ក ចុះថ្ងៃទី៧ ខែកុម្ភៈ ឆ្នាំ១៩៩៧ របស់ក្រុមប្រឹក្សា ភិបាលអង្គការកម្មវិធីបរិស្ថានសហប្រជាជាតិ (UNEP Council) ដើម្បីផ្តួចផ្តើមជាវិធានការអន្តរជាតិសម្រាប់ការពារសុខភាព មនុស្សនិងបរិស្ថាន តាមរយៈការកាត់បន្ថយឬលុបបំបាត់ចោលការសាយភាយ និងការបញ្ចេញចោលសារធាតុបំពុលសរីរាង្គ មិនងាយបំបែកធាតុ ។
- ចងចាំនូវបទបញ្ញត្តិផ្សេងៗ នៃអនុសញ្ញាបរិស្ថានអន្តរជាតិនានាដែលពាក់ព័ន្ធ ជាពិសេស អនុសញ្ញារ៉ូតឺដាម (Rotterdam: Convention) ស្តីពីគោលការណ៍កិច្ចព្រមព្រៀងជូនដំណឹងជាមុនសម្រាប់សារធាតុគីមីបកបដោយ គ្រោះថ្នាក់ និងថ្នាំពុលកសិកម្មមួយចំនួននៅក្នុងពាណិជ្ជកម្មពិភពលោក និងអនុសញ្ញាបាសែល (Basel) ស្តីពី ការត្រួតពិនិត្យ ចលនាឆ្លងដែននសំណល់ប្រកបដោយគ្រោះថ្នាក់និងការបោះបង់ចោល ដោយរាប់បញ្ចូលទាំងកិច្ចព្រមព្រៀងថ្នាក់តំបន់ ដែលបានបង្កើតឡើងនៅក្នុងក្របខ័ណ្ឌនៃមាត្រា ១១ នៃអនុសញ្ញានេះ ។
- ចងចាំផងដែរនូវបទបញ្ញត្តិផ្សេងៗនៃសេចក្តីប្រកាសនៅទីក្រុងរីយ៉ូ (Rio) ស្តីពីការអភិវឌ្ឍន៍និងបរិស្ថានព្រមទាំងរបៀបវារៈ ២១ (Agenda 21) ។

- ទទួលស្គាល់ថា ការប្រុងប្រយ័ត្នជាមុនជាចំនុចយកចិត្តទុកដាក់របស់ភាគីទាំងអស់ ដែលនឹងចែងក្នុងអនុសញ្ញានេះ ។
- ទទួលស្គាល់ថា អនុសញ្ញានេះនិងកិច្ចព្រមព្រៀងអន្តរជាតិនានានៅក្នុងវិស័យពាណិជ្ជកម្មនិងបរិស្ថាន គឺមានការគាំទ្រគ្នាទៅវិញទៅមក ។
- អះអាងជាថ្មីថា ដោយអនុលោមតាមធម្មនុញ្ញរបស់អង្គការសហប្រជាជាតិ និងពោលការណ៍ច្បាប់អន្តរជាតិ រដ្ឋទាំងអស់មានសិទ្ធិអធិបតេយ្យភាព ដើម្បីធ្វើអាជីវកម្មលើធនធាននានារបស់ពួកគេដែលស្របទៅតាមគោល នយោបាយ នៃការអភិវឌ្ឍន៍ និងបរិស្ថានរបស់ពួកគេផ្ទាល់ ហើយរដ្ឋទាំងនោះត្រូវមានភាពទទួលខុសត្រូវរៀងៗខ្លួនដើម្បី ធានាថា រាល់សកម្មភាពនៅក្នុងយុត្តាធិការរបស់ពួកគេ មិនបង្កឱ្យមានមហន្តរាយបរិស្ថានរបស់រដ្ឋដ៏ទៃ ដល់តំបន់ ដ៏ទៃដែលហួសពីការកំណត់នៃយុត្តាធិការរបស់ពួកគេ ។
- យកចិត្តទុកដាក់ពីកាលៈទេសៈ និងតម្រូវការចាំបាច់នានារបស់ប្រទេសកំពុងអភិវឌ្ឍន៍ ជាពិសេសប្រទេស ដែលមានការអភិវឌ្ឍន៍តិចតួច និងប្រទេសដែលសេដ្ឋកិច្ចស្ថិតក្នុងអន្តរកាល លើការយកចិត្តទុកដាក់ពីតម្រូវការដើម្បីជួយ ពង្រឹងសមត្ថភាពជាតិរបស់ពួកគេសម្រាប់ការគ្រប់គ្រងសារធាតុគីមី តាមរយៈការផ្ទេរនូវបច្ចេកវិទ្យា ការផ្តល់ជំនួយថវិកា និងបច្ចេកទេស ព្រមទាំងការបង្កើននូវកិច្ចសហប្រតិបត្តិការក្នុងចំណោមភាគីជាសមាជិក ។
- យកចិត្តទុកដាក់ពីកម្មវិធីជាសកម្មភាពសម្រាប់ការអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព នៃរដ្ឋកំពុងអភិវឌ្ឍន៍នៅតាមកោះតូចៗ ដូចដែលបានអនុម័តនៅបាបាដូស (Barbados) នាថ្ងៃទី ៦ ខែឧសភា ឆ្នាំ១៩៩៤ ។
- កំណត់ពីសមត្ថភាពដោយឡែកនៃប្រទេសអភិវឌ្ឍន៍ និងកំពុងអភិវឌ្ឍន៍ ក៏ដូចជាសមត្ថភាពរួម ប៉ុន្តែ ការទទួលខុសត្រូវផ្សេងៗគ្នារបស់រដ្ឋនីមួយៗ ដូចដែលបានចែងនៅក្នុងគោលការណ៍ទី ៧ នៃសេចក្តីប្រកាសក្រុងរីយ៉ូ ស្តីពី ការអភិវឌ្ឍន៍និងបរិស្ថាន ។
- ទទួលស្គាល់នូវសារៈសំខាន់នៃការចូលរួមវិភាគទានពីស្ថាប័នឯកជន និងអង្គការក្រៅរដ្ឋាភិបាលដែលអាច ធ្វើឱ្យសម្រេចបានការកាត់បន្ថយ ឬការលុបបំបាត់ការសាយភាយ និងការបញ្ចេញចោលសារធាតុបំពុលសរីរាង្គមិនងាយ បំបែកធាតុ ។
- គូសបញ្ជាក់ពីភាពសំខាន់នអ្នកផលិតសារធាតុបំពុលសរីរាង្គមិនងាយបំបែកធាតុ ក្នុងការទទួលខុសត្រូវកាត់បន្ថយហេតុប៉ះពាល់អាក្រក់ដែលបង្កដោយផលិតផលរបស់ពួកគេ និងក្នុងការទទួលខុសត្រូវផ្តល់ពត៌មាននានាដល់អ្នកប្រើប្រាស់ រដ្ឋាភិបាល និងសាធារណៈជនអំពីភាពប្រកបដោយគ្រោះថ្នាក់របស់សារធាតុគីមីទាំងនោះ ។
- មានស្មារតីយល់ដឹងពីសេចក្តីត្រូវ ដើម្បីចាត់វិធានការការពារឥទ្ធិពលអាក្រក់បង្កឡើងដោយសារធាតុបំពុលសរីរាង្គមិនងាយបំបែកធាតុនៅរាល់ដំណាក់កាលនៃវដ្តរបស់វា ។

- អះអាងបញ្ជាក់ជាថ្មីថា នូវគោលការណ៍ទី ១៦ នៃសេចក្តីប្រកាសនៅទីក្រុងរីយ៉ូ ស្តីពីការអភិវឌ្ឍន៍ និង បរិស្ថាន ដែលចែងថា អាជ្ញាធរជាតិត្រូវខិតខំដើម្បីធ្វើឱ្យប្រសើរឡើងនូវភាពរួមនៃតម្លៃបរិស្ថាន និងការប្រើប្រាស់បរិធាន សេដ្ឋកិច្ច ដោយយកចិត្តទុកដាក់លើដំណោះស្រាយគោលការណ៍អ្នកបំពុលត្រូវទទួលខុសត្រូវលើតម្លៃនៃការបំពុល ដែលទាក់ទងទៅនឹងផលប្រយោជន៍សាធារណៈ និង មិនធ្វើឱ្យមានការរំខានដល់ការធ្វើវិនិយោគទុននិងការធ្វើជំនួញអន្តរជាតិ ។
- ខិតខំជំរុញភាគីដែលមិនទាន់មានប្រព័ន្ធវាយតម្លៃ និងបទបញ្ញត្តិសម្រាប់សារធាតុគីមីឧស្សាហកម្ម និងថ្នាំសំលាប់សត្វល្អិតដើម្បីរៀបចំនូវប្រព័ន្ធទាំងនោះ ។
- ទទួលស្គាល់នូវភាពសំខាន់នៃការបង្កើតនិងការប្រើប្រាស់ជំរើសថ្មីនៃសារធាតុគីមី ដំណើរការផលិតកម្ម ដែលធ្វើឱ្យមានសុវត្ថិភាពបរិស្ថាន ។
- កំណត់កិច្ចការពារសុខភាពសាធារណៈ និងកិច្ចការពារបរិស្ថានឱ្យចៀសផុតពីផលប៉ះពាល់ជាគ្រោះថ្នាក់ដែលបង្កឡើងដោយសារធាតុបំពុលសរីរាង្គមិនងាយបំបែកធាតុ។

# ជំពូកទី ២ ផែនការសកម្មភាព យុទ្ធសាស្ត្រ និងគោលនយោបាយការប្រែប្រួលអាកាសធាតុ


មេរៀនទី ១ ផែនការសកម្មភាពការប្រែប្រួលអាកាសធាតុតាមវិស័យ

មេរៀនទី ២ ផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ

មេរៀនទី ៣ ផែនយុទ្ធសាស្ត្រជាតិ និងគោលនយោបាយជាតិពាក់ព័ន្ធផ្សេងៗ

# មេរៀនទី ១ ផែនការសកម្មភាពការប្រែប្រួលអាកាសធាតុតាមវិស័យ

## ១. ផែនការសកម្មភាពឆ្លើយតបការប្រែប្រួលអាកាសធាតុ ២០១៦-២០១៨ ក្រសួងបរិស្ថាន

### ១.១ ផែនការសកម្មភាពការប្រែប្រួលអាកាសធាតុ

#### ១.១.១ វិសាលភាពនៃផែនការសកម្មភាពប្រែប្រួលអាកាសធាតុ

ដើម្បីលើកកម្ពស់ការអនុវត្តទិសដៅជាយុទ្ធសាស្ត្រនៃផែនការCCCSP 2014-2023 ក្រសួងបរិស្ថាន បានរៀបចំផែនការសកម្មភាពប្រែប្រួលអាកាសធាតុសម្រាប់ឆ្នាំ 2016-2018 ដោយបន្សាគ្នាជាមួយអាណត្តិរបស់ក្រសួង និងអគ្គលេខាធិការដ្ឋាន NCSD។ ផែនការសកម្មភាពឆ្លើយតបនឹងប្រែប្រួលអាកាសធាតុ (CCAP) ចែងពីសកម្មភាពអាទិភាពសំខាន់ៗសម្រាប់អគ្គនាយកដ្ឋានបីនៃក្រសួងបរិស្ថាន ពោលគឺ អគ្គនាយកដ្ឋានព័ត៌មាននិងអប់រំបរិស្ថាន អគ្គនាយកដ្ឋានគាំពារបរិស្ថាន និងរដ្ឋបាលការពារអភិរក្សធម្មជាតិ តាមរយៈអគ្គនាយក ដ្ឋានទាំងនេះ ផែនការនេះអាចគាំទ្រដល់ការអនុវត្ត CCCSP ផែនការនេះក៏ចែងច្បាស់ដែរនូវការណែនាំអំពីសកម្មភាពជាអាទិភាព សំខាន់ៗសម្រាប់អគ្គលេខាធិការដ្ឋាន NCSD សម្រាប់នាយកដ្ឋានប្រែប្រួលអាកាសធាតុ ក៏ដូចជា នាយកដ្ឋានវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា នាយកដ្ឋានសេដ្ឋកិច្ចបៃតង និងនាយកដ្ឋានជីវៈចម្រុះផងដែរ។

ការពិភាក្សាផ្ទៃក្នុងអំពីវិភាគទានជាយុទ្ធសាស្ត្ររបស់ក្រសួងបរិស្ថាននៅក្នុងការអនុវត្ត CCCSP បានចាប់ផ្តើមនៅឆ្នាំ 2013 ហើយ បានបន្តនៅក្នុងរយៈពេលភាគច្រើននៃឆ្នាំ2014 អគ្គនាយកដ្ឋានទាំងអស់បានរួមចំណែកយ៉ាងសកម្មនៅក្នុងការរៀបចំផែនការយុទ្ធសាស្ត្រនេះ ដែលដឹកនាំដោយលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុ (NCCC) ដែលនៅពេលនោះ មានអាណត្តិសម្របសម្រួលការអនុវត្តវិធានការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ។ ជាលទ្ធផលតារាងវែងមួយអំពីសកម្មភាពនានា ដែលក្រសួងបរិស្ថានអាចយកទៅអនុវត្ត មានបង្ហាញជូននៅក្នុងឧបសម្ព័ន្ធ ។

នៅឆ្នាំ 2015 បន្ទាប់ពីកំណែទម្រង់ស្ថាប័នរបស់ក្រសួងបរិស្ថាន និង NCCC ដែលនាំឱ្យមានកំណែសម្រួលរចនាសម្ព័ន្ធរបស់ ក្រសួងនេះ និងការបង្កើតក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព (NCSD) នៅខែឧសភា ការងារជាបន្តរបស់ក្រសួងគឺរៀបចំ CCAP ដើម្បី ធានាថាផែនការនេះមានលក្ខណៈស្របគ្នាជាមួយទាំងរចនាសម្ព័ន្ធថ្មីនៃស្ថាប័ននេះសម្រាប់ការប្រែប្រួលអាកាសធាតុ និងបរិស្ថាន និង ជាមួយ CCCSP (2018-2023) ផងដែរ។

តារាងខ្លីមួយអំពីសកម្មភាពសំខាន់ៗដើម្បីរួមបញ្ចូល CCAP របស់ក្រសួងបរិស្ថានសម្រាប់អំឡុងឆ្នាំ 2016-2018 ត្រូវបានរៀបចំឡើង ដោយពិចារណាផងដែរពីការពិភាក្សានានាកន្លងមក អាណត្តិបច្ចុប្បន្ន របស់ក្រសួងបរិស្ថាន និង NCSD និងអាទិភាពនានាដែល មានបង្ហាញនៅក្នុងផែនការថវិកាយុទ្ធសាស្ត្រ របស់ក្រសួងបរិស្ថានសម្រាប់ឆ្នាំ 2016-2018 និងមានបង្ហាញនៅក្នុងជំពូកបន្ទាប់នៃតារាង (តារាងផែនការសកម្មភាព)។

### ១.១.២ តារាងផែនការសកម្មភាព

តារាងទី ៥ មានសកម្មភាពអាទិភាពសរុបចំនួន 17 ដែលក្រសួងបរិស្ថានត្រូវអនុវត្តនៅក្នុងអំឡុងឆ្នាំ 2016-2018 ដែលតំណាងឱ្យវិភាគទានរបស់ក្រសួងបរិស្ថានទៅក្នុងដំណាក់កាលដំបូងនៃការអនុវត្ត CCCSP តារាងនេះបង្ហាញវិភាគទាននៃសកម្មភាពទាំងនេះ ទៅក្នុងគោលបំណងយុទ្ធសាស្ត្រខុសៗគ្នានៃ CCCSP ដែលបង្ហាញផងដែរពីថ្លៃប៉ាន់ស្មានការចំណាយ និងនាយកដ្ឋានដែលទទួលខុសត្រូវលើការអនុវត្តសកម្មភាពទាំងនោះ។

នៅក្នុងការកំណត់អត្តសញ្ញាណសកម្មភាពនានាដែលរួមបញ្ចូលនៅក្នុង CCAP លើកទីមួយនេះ កម្មវិធី និងគម្រោងនានាដែលមានស្រាប់ ដែលបានបង្កើតឡើងដើម្បីពង្រឹងសមត្ថភាពស្ថាប័នសម្រាប់អនុវត្តការងារឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ ក៏ត្រូវបានគិតបញ្ចូលផងដែរ និងក្នុងករណីសមស្របគម្រោង និងកម្មវិធីទាំងនោះត្រូវបានរួមបញ្ចូលទៅក្នុងផែនការសកម្មភាពដែលមានស្រាប់ ដូច្នេះបានផ្អែកលើកិច្ចប្រឹងប្រែង និងភាពជាដៃគូនានាដែលមានស្រាប់។ សកម្មភាពទាំងនេះខ្លះត្រូវបានរំពឹងថានឹងត្រូវបន្តហួសឆ្នាំ 2018 ហើយការបន្តពិនិត្យតាមដាន និងវាយតម្លៃដែលគ្រោងធ្វើឡើងនៅពាក់កណ្ដាលឆ្នាំ 2018 នឹងកំណត់ជាការសម្រេចចុងក្រោយ។

សម្រាប់សកម្មភាពនីមួយៗនៅក្នុងចំណោមសកម្មភាពទាំង 17 នៃ CCAP សន្លឹកព័ត៌មានអំពីសកម្មភាព (ឧបសម្ព័ន្ធ) មានផ្ដល់ជូននូវ ព័ត៌មានបន្ថែម ដែលរួមទាំង ហេតុផល ធាតុចេញដែលរំពឹងទុក សូចនាករ និងលក្ខខណ្ឌនានាដើម្បីទទួលជោគជ័យ ការចាត់ចែងស្ថាប័នសម្រាប់ការអនុវត្ត ថ្លៃចំណាយ និងប្រភពមូលនិធីដែលអាចមាន ក៏ដូចជា មូលនិធិដែលបានកៀរគរួចមកហើយពីថវិកាជាតិ និងពីប្រភពខាងក្រៅ។ ថ្លៃប៉ាន់ស្មានកាន់តែសុក្រិត និងព័ត៌មានបន្ថែមអំពីប្រភពមូលនិធិដែលមានសក្ដានុពល និងកម្រិតហិរញ្ញប្បទាន ក៏ដូចជាសេចក្ដីពិស្ដាអំពីបច្ចេកទេស នឹងត្រូវធ្វើបច្ចុប្បន្នភាពនៅមុនការអនុវត្តសកម្មភាពនីមួយៗ ឬនៅក្នុងអំឡុងពេលនៃការរៀបចំសំណើសម្រាប់ការកៀរគរធនធាន។

## តារាង ៥ សកម្មភាពសំខាន់ៗឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុសម្រាប់ឆ្នាំ 2016-2018

| ល.រ | សកម្មភាព | នាយកដ្ឋានទទួលខុសត្រូវ | ថវិកាប៉ាន់ស្មាន | | | |
|---|---|---|---|---|---|---|
| | | | 2016 | 2017 | 2018 | សរុប |
| **ទិសដៅជាយុទ្ធសាស្ត្រ 1: លើកកម្ពស់ភាពធន់នឹងអាកាសធាតុ តាមរយៈការធ្វើឱ្យប្រសើរឡើងនូវសន្តិសុខស្បៀង ទឹក និងថាមពល (FWE)** | | | | | | |
| 1. | បង្កើតមណ្ឌលបច្ចេកវិទ្យាបញ្ចេញកាបូនតិចធន់នឹងអាកាសធាតុដើម្បីសន្តិសុខស្បៀង ទឹក និងថាមពល | DST | | | | 635.000 |
| **ទិសដៅជាយុទ្ធសាស្ត្រ 2: កាត់បន្ថយភាពងាយរងគ្រោះតាមវិស័យ តំបន់ យេនឌ័រ និងសុខភាពនៅចំពោះមុខផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ** | | | | | | |
| 2. | ធ្វើការវាយតម្លៃភាពងាយរងគ្រោះនៅថ្នាក់ជាតិ និងតាមវិស័យ | DCC | | | | មិនទាន់កំណត់ |
| **ទិសដៅជាយុទ្ធសាស្ត្រ 3: លើកកម្ពស់ភាពធន់នឹងអាកាសធាតុនៃប្រព័ន្ធអេកូឡូស៊ីសំខាន់ៗ (បឹងទន្លេសាប ទន្លេមេគង្គ តំបន់ឆ្នេរ តំបន់ខ្ពង់រាប។ល។) ជីវៈចម្រុះ តំបន់ការពារធម្មជាតិ និងតំបន់បេតិកភណ្ឌវប្បធម៌** | | | | | | |
| 3. | ធ្វើការវាយតម្លៃផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុមកលើជីវៈចម្រុះ និងសាកល្បងជម្រើសនានានៃការគ្រប់គ្រងដើម្បីឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ | GDNCPA | | | | 2.300.000 |
| 4. | រៀបចំការសិក្សាបឋមដើម្បីបង្កើតគណនេយ្យមូលធនធម្មជាតិ | DGE | | | | 120.000 |
| **ទិសដៅជាយុទ្ធសាស្ត្រ 4: លើកកម្ពស់ការកសាងផែនការ និងបច្ចេកវិទ្យាដែលបញ្ចេញកាបូនតិច ដើម្បីគាំទ្រដល់ការអភិវឌ្ឍដោយចីរភាព** | | | | | | |
| 5. | បង្កើតប្រព័ន្ធសារពើភណ្ឌ ឧស្ម័នផ្ទះកញ្ចក់ ជាតិ និងរៀបចំធាតុចូលសម្រាប់ BURs | DCC | | | | 450.000 |
| 6. | សម្រួលដល់ការកាត់បន្ថយការបញ្ចេញ ឧស្ម័នផ្ទះកញ្ចក់ តាមរយៈគម្រោង និងកម្មវិធីយន្តការឥណទានហិរញ្ញវត្ថុកាបូន | DCC | | | | 385.000 |
| 7. | បង្កើត និងសាកល្បងអភិក្រម និងជម្រើសបញ្ចេញកាបូនតិចធន់នឹងអាកាសធាតុសម្រាប់ទីប្រជុំជន | DGE | | | | 3.800.000 |
| **ទិសដៅជាយុទ្ធសាស្ត្រ 5: កែលម្អសមត្ថភាព ចំណេះដឹង និងការយល់ដឹង សម្រាប់ឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ** | | | | | | |
| 8. | បង្កើតប្រព័ន្ធគ្រប់គ្រងចំណេះដឹងអំពី ការប្រែប្រួលអាកាសធាតុ និងការអភិវឌ្ឍបៃតង | DCC | | | | 615.000 |
| 9. | ដាក់បញ្ចូល CC និងបញ្ហាបរិស្ថានទៅក្នុងកម្មវិធីសិក្សានៅគ្រប់លំដាប់ថ្នាក់ | DCC | | | | 450.000 |
| 10. | ការចូលរួម និងលើកកម្ពស់ការយល់ដឹងជាសាធារណៈអំពីការប្រែប្រួលអាកាសធាតុ និងអភិវឌ្ឍន៍បៃតងរួមទាំងការប្រើប្រាស់និងផលិតកម្មដោយចីរភាព ឱ្យដល់ | DCC; DGE | | | | 600.000 |

| | | | | | | |
|---|---|---|---|---|---|---|
| | ក្រុមគោលដៅផ្សេងៗ | | | | | |
| ទិសដៅជាយុទ្ធសាស្ត្រ 6: លើកកម្ពស់ការចូលរួម និងកិច្ចគាំពារសង្គមបែបបន្សាំនឹងការប្រែប្រួលអាកាសធាតុដើម្បីកាត់បន្ថយការបាត់បង់ និងខូចខាត | | | | | | |
| 11. | លើកកម្ពស់ និងកែលម្អសមត្ថភាពបន្សាំរបស់សហគមន៍ ដើម្បីឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ | DCC | | | | 2.500.000 |
| ទិសដៅជាយុទ្ធសាស្ត្រ 7: ពង្រឹងស្ថាប័ន និងក្របខ័ណ្ឌការងារសម្របសម្រួលសម្រាប់ឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុថ្នាក់ជាតិ | | | | | | |
| 12. | ប្រកាសឱ្យប្រើប្រាស់ និងអនុវត្តប្រព័ន្ធ M&E នៅថ្នាក់ជាតិ និងតាមវិស័យ | DCC; DAPF | | | | 215.000 |
| 13. | ការកសាងសមត្ថភាពស្ថាប័នជាតិ សម្របសម្រួលការអនុវត្តផែនការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ | DCC | | | | 5.000.000 |
| 14. | គាំទ្រដល់ក្រសួងពាក់ព័ន្ធដើម្បីបញ្ជ្រាបការប្រែប្រួលអាកាសធាតុទៅក្នុងការរៀបចំផែនការអភិវឌ្ឍន៍ និងការលើកគម្រោងថវិកា | DCC | | | | 8.000.000 |
| 15. | ពង្រឹងក្របខ័ណ្ឌច្បាប់ និងបទបញ្ញត្តនានាសម្រាប់ការអភិវឌ្ឍដែលបញ្ចេញកាបូនតិចធន់នឹងអាកាសធាតុ | DCC | | | | 100.000 |
| 16. | បង្កើតក្របខ័ណ្ឌជាតិហិរញ្ញវត្ថុកាបូន | DCC | | | | 1.000.000 |
| ទិសដៅជាយុទ្ធសាស្ត្រ 8: ពង្រឹងកិច្ចសហការ និងចូលរួមយ៉ាងសកម្មនៅក្នុងកិច្ចខិតខំប្រឹងប្រែងឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុនៅថ្នាក់តំបន់ និងពិភពលោក | | | | | | |
| 17. | ការរៀបចំរបាយការណ៍សម្រាប់ UNFCCC ទៅក្នុងក្របខ័ណ្ឌស្ថាប័ន | DCC | | | | 1.500.000 |
| តម្លៃប៉ាន់ស្មានសរុប | | | 27,7 លាន (*សកម្មភាព 2 មិនទាន់កំណត់ថ្លៃចំណាយ) | | | |

**អត្ថប្រយោជន៍រំពឹងទុកពីការអនុវត្តនេះ**

ផែនការ CCAP នឹងពង្រឹងតួនាទីសម្របសម្រួលរបស់ក្រុមប្រឹក្សា NCSD ជាស្ថាប័នអន្តរក្រសួងដើម្បីឆ្លើយតបប្រកបដោយប្រសិទ្ធភាពទៅនឹងការប្រែប្រួលអាកាសធាតុនៅថ្នាក់ជាតិ។ ផែនការ CCAP នឹងបង្កើតឱ្យមានការអនុវត្តដែលផ្អែកលើភស្តុតាងផងដែរ សម្រាប់អន្តរាគមន៍ឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុទៅអនាគត តាមរយៈការអប់រំបរិស្ថាន កិច្ចគាំពារបរិស្ថាន និងការអភិរក្ស ធនធានធម្មជាតិ និងជីវៈចម្រុះ។

### ១.១.៣ យន្តការគ្រប់គ្រង និងហិរញ្ញប្បទាន

*យន្តការគ្រប់គ្រង និងហិរញ្ញប្បទានដែលមានស្រាប់*

ក. រចនាសម្ព័ន្ធគ្រប់គ្រង

រូបភាព ១ និង ២ ខាងក្រោមបង្ហាញពីរចនាសម្ព័ន្ធគ្រប់គ្រងរបស់ក្រសួងបរិស្ថាន និងអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព។



រូបភាព ១ រចនាសម្ព័ន្ធគ្រប់គ្រងរបស់ក្រសួងបរិស្ថាន




រូបភាព ២ អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព

## ខ. ការលើកថវិការបស់ក្រសួងបរិស្ថាន

ច្បាប់ស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុ បានអនុម័តថវិកាចំនួន 17.360.000.000 រៀល សម្រាប់ក្រសួងបរិស្ថាន សម្រាប់ឆ្នាំ 2013 និងហិរញ្ញវត្ថុបន្ថែមចំនួន 849,300.000 រៀល ដែលបានស្នើនៅក្រោមជំពូកថវិកា 4 ដូច្នេះក្រសួងមានថវិកាអនុម័តសរុបចំនួន 18,209.300.000 រៀល។ ការផ្ទេរជាក់ស្តែងគឺ 17,221,401,000 រៀល ដែលត្រូវជា 94,57% នៃថវិកាគ្រោងសម្រាប់ឆ្នាំនោះ។

នៅក្នុងអំឡុងពេលនោះ ក្រសួងបរិស្ថានបានគ្រប់គ្រងគម្រោងមួយចំនួនដែលទទួលមូលនិធិពីប្រភពខាងក្រៅ ដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុ ក្នុងទឹកប្រាក់សរុបប្រមាណ 4,5 លានដុល្លាអាមេរិក។

ហិរញ្ញវត្ថុប្រែប្រួលអាកាសធាតុ មានប្រមាណមួយភាគបីនៃធនធានសរុបដែលគ្រប់គ្រងដោយក្រសួងបរិស្ថាន ដែលភាគច្រើនតាមរយៈកម្មវិធីសម្ព័ន្ធភាពប្រែប្រួលអាកាសធាតុកម្ពុជា (3,4 លានដុល្លាដែលបានចំណាយនៅក្នុងឆ្នាំ 2013)។

គួរកត់សំគាល់ផងដែរថា រហូតដល់ឆ្នាំ 2015 ក្រសួងបរិស្ថានមិនអាចធ្វើការគណនាចំនួនជាក់ស្តែងដែលក្រសួងបានចំណាយ លើការងារប្រែប្រួលអាកាសធាតុឡើយ ដោយសារពុំមានផែនការសកម្មភាពប្រែប្រួលអាកាសធាតុច្បាស់លាស់សម្រាប់ក្រសួងបរិស្ថាន និងពុំមានថវិកាតាមកម្មវិធី។ ក្រសួងបរិស្ថានចាត់ចែងឱ្យមានការលើកថវិកាសម្រាប់កម្មវិធី ដែលចាប់ផ្តើមនៅឆ្នាំ 2016 ដែលរាប់បញ្ចូល អនុកម្មវិធីស្តីពីការប្រែប្រួលអាកាសធាតុ (593 លានរៀល) និងកម្មវិធីមួយទៀតស្តីពីសេដ្ឋកិច្ចបៃតង (1,453 លានរៀល)។

គ. យន្តការកៀរគរហិរញ្ញវត្ថុ

ក្រៅពីថវិកាជាតិ ក្រសួងបរិស្ថានបានបង្កើតភាពជាដៃគូជាមួយម្ចាស់ជំនួយមួយចំនួនលើបញ្ហាប្រែប្រួលអាកាសធាតុ។ ក្រុមការងារមួយត្រូវបានបង្កើតនៅក្រោមក្រសួងបរិស្ថាន និងដឹកនាំដោយនាយខុទ្ទកាល័យ ដើម្បីអភិវឌ្ឍន៍ភាពជាដៃគូក្រសួងបរិស្ថាន-ម្ចាស់ ជំនួយជាបន្ថែមទៀត។

*ប្រភពដែលមានសក្តានុពល និងទំហំនៃហិរញ្ញវត្ថុសម្រាប់សកម្មភាពឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ*

ផែនការ CCAP បច្ចុប្បន្ននេះ ត្រូវបានប៉ាន់ស្មានអំពីតម្រូវការរវាង 28 និង 30 លានដុល្លាអាមេរិកសម្រាប់អំឡុងពេលបីឆ្នាំ។

មួយភាគធំនៃមូលនិធិនេះសម្រាប់ផែនការ CCAP និងត្រូវបានទទួលហិរញ្ញវត្ថុតាមរយៈដៃគូអភិវឌ្ឍន៍បច្ចុប្បន្ននៃក្រសួងបរិស្ថាន។ គំរូ សហប្រតិបត្តិការពហុម្ចាស់ជំនួយជាអាទិ៍ SIDA, UNDP និង EU កំពុងគាំទ្រដល់សម្ព័ន្ធភាពប្រែប្រួលអាកាសធាតុកម្ពុជា ជាមួយមូលនិធិ សរុបបច្ចុប្បន្ននេះដែលមានចំនួន 12,8 លានដុល្លាអាមេរិក សម្រាប់ឆ្នាំ 2014-19។ មូលនិធិពិភពលោក/មូលនិធិដែលផ្តោតលើការប្រែ ប្រួលអាកាសធាតុ ពោលគឺ CIF, GEF, LCDF, AF, FCPF និង UN-REDD កំពុងគាំទ្រគម្រោងនានានៅក្នុងក្រសួងបរិស្ថាន ដូចជា CIF ផ្តល់ហិរញ្ញប្បទានដល់ក្រសួងបរិស្ថាន តាមរយៈ ADB លើគម្រោង SPCR។ មូលនិធិពិភពលោក/មូលនិធិដែលផ្តោតលើការប្រែប្រួលអាកាសធាតុ ត្រូវបានរំពឹងថានឹងដើរតួកាន់តែ

សំខាន់នៅពេលដែលទំហំនៃមូលនិធិគាំទ្រកាន់តែមានធំជាងមុន។ លើសពីនេះ ដៃគូទ្វេភាគីសំខាន់ៗ ដែលគាំទ្រដល់ក្រសួងបរិស្ថានលើការងារឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុរួមមាន៖ អាល្លឺម៉ង់ (តាមរយៈ GIZ), USAID, JICA, KOICA, UKAID, និង SIDA។

*ចំណុចចាប់ផ្តើមសម្រាប់ការបញ្ជ្រាបការប្រែប្រួលអាកាសធាតុទៅក្នុងការគ្រប់គ្រង និងហិរញ្ញប្បទាន*

អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព ជាពិសេស នាយកដ្ឋានប្រែប្រួលអាកាសធាតុ និងគាំទ្រដល់នាយកដ្ឋានផែនការ និងនាយកដ្ឋានបច្ចេកទេសនានា ដើម្បីធានាថាសកម្មភាពនានាត្រូវបានបន្ស៊ីគ្នាជាមួយផែនការការងាររបស់ក្រសួងនេះ។ ការពិនិត្យតាមដាន និងវាយតម្លៃសម្រាប់ផែនការ CCAP មានអធិប្បាយនៅក្នុងជំពូកបន្ទាប់។

ក្រុមអ្នករៀបចំផែនការ CCAP នឹងធ្វើការជាមួយនាយកដ្ឋានពាក់ព័ន្ធ ដើម្បីកសាងភាពម្ចាស់ការលើសកម្មភាពទាំងនេះបន្ថែមទៀត។ សកម្មភាពនីមួយៗនឹងមានចែងពិស្តារនៅក្នុងសកម្មភាព ឬ កម្មវិធីការងារសម្រាប់ការិយាល័យនានានៅកមនាយកដ្ឋានពាក់ព័ន្ធ និងរួមបញ្ចូលនៅក្នុងផែនការការងារប្រចាំឆ្នាំសម្រាប់នាយកដ្ឋានពាក់ព័ន្ធ និងបន្ទាប់មកបញ្ចូលទៅក្នុងផែនការយុទ្ធសាស្ត្រថវិកា របស់ក្រសួងបរិស្ថាន។ ឱនភាពមូលនិធិសម្រាប់ការអនុវត្តនឹងត្រូវលើកយកមកពិភាក្សាជាមួយដៃគូអភិវឌ្ឍន៍។

## ២. ផែនការសកម្មភាព ស្តីពីយេនឌ័រ និងការប្រែប្រួលអាកាសធាតុ ២០១៤-២០១៨ ក្រសួងកិច្ចការនារី

ផែនការសកម្មភាព ស្តីពីយេនឌ័រនិងការប្រែប្រួលអាកាសធាតុនៃផ្អែកលើផែនការយុទ្ធសាស្ត្រ ស្តីពីយេនឌ័រនិងការប្រែប្រួលអាកាសធាតុ មានដំណើរការ ពិគ្រោះយោបល់ជាបន្តបន្ទាប់សម្រាប់ការបង្កើតផែនការសកម្មភាព ស្តីពីយេនឌ័រនិងការ ប្រែប្រួលអាកាសធាតុ (GCCAP) ៥ឆ្នាំ (ឆ្នាំ២០១៤-២០១៨)។ ផែនការសកម្មភាពនេះ មានគោលបំណងអនុវត្តអនុសាសន៍ នៃផែនការយុទ្ធសាស្ត្រ ស្តីពីយេនឌ័រនិងការប្រែប្រួលអាកាសធាតុ ដោយផ្តោតទៅលើស្ត្រី និងក្រុមជនងាយរងគ្រោះផ្សេងទៀត ដូចជាកុមារមនុស្សចាស់ ជនពិការ និងជនជាតិដើមភាគតិច តាមរយៈវិធានការអភិវឌ្ឍន៍សមត្ថភាព សម្រាប់ស្ត្រីក្នុងកិច្ចពិគ្រោះយោបល់លើគោលនយោបាយ ការដឹកនាំ ការបង្កើតបរេចិញ្ចឹមជីវិត "ការអភិវឌ្ឍន៍បៃតង" និងការបង្កើនសមត្ថភាពបន្សាំទៅនឹងការប្រែប្រួលអាកាស ធាតុក្នុងសហគមន៍។

ផែនការសកម្មភាព ស្តីពីយេនឌ័រនិងការប្រែប្រួលអាកាសធាតុ បានបង្កើតឡើងដោយមានគោលការណ៍ណែនាំពីក្រសួងបរិស្ថាន (MoE) និងការគាំទ្រពីសម្ព័ន្ធភាពប្រែប្រួលអាកាសធាតុកម្ពុជា (CCCA)។ ផ្អែកតាមកិច្ចពិគ្រោះយោបល់ក្នុងការរៀបចំផែនការយុទ្ធសាស្ត្រនារីរតនៈទី ៤ ក្រសួងកិច្ចការ

នារី បានដាក់បញ្ចូលវិស័យជាយុទ្ធសាស្ត្រទី៦ ស្តីពី "យេនឌ័រ និងការប្រែប្រួលអាកាសធាតុ ការអភិវឌ្ឍន៍បៃតងនិងការគ្រប់គ្រងគ្រោះមហន្តរាយ" ឆ្លើយតបនឹងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាល។ យេនឌ័របានចាត់ទុកថាជាគោលការណ៍ណែនាំសំខាន់មួយ នៃការរៀបចំផែនការ និងការបង្កើតវិធានការនិងសកម្មភាព ស្តីពីការប្រែប្រួលអាកាសធាតុ។ ផែនការសកម្មភាពនេះនឹង ត្រូវរៀបចំជាផែនការប្រចាំឆ្នាំ ដើម្បីអនុវត្តតាមរយៈថវិកាជាតិ និងដៃគូអភិវឌ្ឍន៍។

ផែនការសកម្មភាព ស្តីពីយេនឌ័រនិងការប្រែប្រួលអាកាសធាតុ ផ្អែកលើយុទ្ធសាស្ត្រដូច ខាងក្រោម៖

១) ពង្រឹងសមត្ថភាពស្ថាប័ន និងការសម្របសម្រួលអន្តរវិស័យដើម្បីកាត់បន្ថយភាពងាយរងគ្រោះរបស់ស្ត្រី ក្រុមស្ត្រីងាយរងគ្រោះពីផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ

២) បង្កើនសមត្ថភាព ចំណេះដឹង និងការយល់ដឹង ស្តីពីយេនឌ័រ និងការឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ និងភាពបន្សាំ

៣) លើកកម្ពស់ការឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ ដោយផ្អែកលើយេនឌ័រជាមូលដ្ឋាន។

តារាង ៦ អនុសាសន៍សម្រាប់គោលនយោបាយ

| | |
|---|---|
| បង្កើតក្របខណ្ឌគោលនយោបាយ និងកម្មវិធី ស្តីពី កសិកម្មសរីរាង្គ និងមាននិរន្តរភាព។ កម្មវិធីសេវា ផ្សព្វផ្សាយកសិកម្ម គួរផ្តោតលើកសិករជាស្ត្រីជាពិសេស ក្រុមស្ត្រងាយរងគ្រោះឱ្យបានខ្លាំងក្លា។ | ក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ ក្រសួងស្ថាប័នពាក់ព័ន្ធ ក្រសួងកិច្ចការនារី |
| សហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ក្នុងការផ្តល់ និង ផ្សព្វផ្សាយពីបច្ចេកទេសកសិកម្មសរីរាង្គបណ្តុំទៅ នឹងការប្រែប្រួលអាកាសធាតុដល់ស្ត្រីនិងក្រុមស្តីងាយ រងគ្រោះ។ | ក្រសួងកិច្ចការនារី ក្រសួង កសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍បៃតង គណៈកម្មាធិការជាតិគ្រប់គ្រង ការប្រែប្រួលអាកាសធាតុ |
| បង្កើនការយល់ដឹងដល់សហគ្រិនជាស្ត្រី អំពីការអភិវឌ្ឍន៍ បៃតង តាមរយៈការផ្តល់ព័ត៌មានពាក់ព័ន្ធនឹងបច្ចេកវិទ្យា បៃតង និងលើកកម្ពស់សហគ្រិនភាព។ | ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ក្រសួងកិច្ចការនារី ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍បៃតង |
| លើកកម្ពស់សកម្មភាពសេដ្ឋកិច្ចដែលបញ្ចេញកាបូនតិច រួមទាំងបច្ចេកវិទ្យាថ្មីៗដល់ស្ត្រីនិងក្រុមស្ត្រងាយរងគ្រោះ តាមរយៈកសិកម្ម និងឧស្សាហកម្មធុនស្រាល "បៃតង "។ | ក្រសួងកិច្ចការនារី ក្រុមប្រឹក្សាជាតិ អភិវឌ្ឍន៍បៃតង |

| | |
|---|---|
| ជំរុញ និងលើកកម្ពស់សមភាពយេនឌ័រក្នុងយុទ្ធនាការ អភិរក្ស និងគ្រប់គ្រងព្រៃឈើឱ្យមាននិរន្តរភាព ដើម្បី ស្រូបយកឧស្ម័នកាបូនិច តាមសហគមន៍ ជាពិសេស សហគមន៍ជនជាតិដើមភាគតិច ។ | ក្រសួងកិច្ចការនារី ក្រសួង កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍បៃតង |
| សិក្សាចងក្រង និងជំរុញឱ្យមានការប្រើប្រាស់ថាមពល កកើតឡើងវិញសម្រាប់គ្រួសារ និងសហគមន៍ ជាពិសេស ដល់ស្ត្រី ដូចជាថាមពលព្រះអាទិត្យ ខ្យល់ ជីវម៉ាស ជីវឧស្ម័ន ព្រមទាំងបច្ចេកវិទ្យាថ្មីៗ។ | ក្រសួងកិច្ចការនារី គណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុ ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍បៃតង |
| សិក្សាឱកាសសម្រាប់ការប្រើប្រាស់ព័ត៌មាន ទំនាក់ទំនង និងបច្ចេកវិទ្យា (ICT)ស្ត្រីក្នុងវិស័យកសិកម្ម ដើម្បីលើក កម្ពស់ការអភិវឌ្ឍសហគ្រាសខ្នាតមីក្រូ តូច និងមធ្យម បៃតង និងទទួលព័ត៌មានផ្សេងៗ ទាក់ទងនឹងការប្រែប្រួល អាកាសធាតុ។ | ក្រសួងកិច្ចការនារី ក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ ក្រសួងឧស្សាហកម្ម និងសិប្បកម្ម គណៈកម្មាធិការ ជាតិគ្រប់គ្រងការប្រែប្រួល អាកាសធាតុក្រុមប្រឹក្សាជាតិ អភិវឌ្ឍន៍បៃតង គណៈកម្មាធិការ ជាតិគ្រប់គ្រងគ្រោះមហន្តរាយ |
| ប៉ាន់ប្រមាណ និងសិក្សាស្រាវជ្រាវដើម្បីវាយតម្លៃភាព ងាយរងគ្រោះ និងបង្កើនគុណភាពសេវាសុខភាពដល់ ស្ត្រី ក្រុមស្ត្រីងាយរងគ្រោះនិងកុមារដែលរងផលប៉ះពាល់ ពីការប្រែប្រួលអាកាសធាតុ។ | ក្រសួងកិច្ចការនារី គណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុ |
| សហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ដៃគូអភិវឌ្ឍន៍ សង្គមស៊ីវិល ដើម្បីធានាថាបញ្ហាសុខភាពស្ត្រី ក្រុមស្ត្រី ងាយរងគ្រោះ និងកុមារ ឆ្លើយតបក្នុងបរិបទនៃការ ប្រែប្រួលអាកាសធាតុ។ | ក្រសួងកិច្ចការនារី គណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុ ក្រសួង ស្ថាប័នពាក់ព័ន្ធ |
| បញ្ជ្រាបយេនឌ័រ និងអនុវត្តផែនការទាំងថ្នាក់ជាតិ ថ្នាក់ ក្រោមជាតិ ដោយរួមបញ្ចូលទាំងផែនការត្រៀមបង្ការ ឆ្លើយតបទៅនឹងគ្រោះមហន្តរាយ ជាពិសេសគ្រោះទឹក ជំនន់រាំងស្ងួត និងខ្យល់ព្យុះ។ | ក្រសួងកិច្ចការនារី គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ គ.ជ.អ.ប |
| គួរបង្កើតយន្តការផ្តល់ព័ត៌មានត្រឡប់ពីសហគមន៍រងគ្រោះនៅពេលមានគ្រោះមហន្តរាយ។ | គណៈកម្មាធិការជាតិគ្រប់គ្រង គ្រោះមហន្តរាយ |

| | |
|---|---|
| បញ្ជ្រាបយេនឌ័រក្នុងដំណើរការរៀបចំ អនុវត្ត និង តាម ដានការអនុវត្តគោលនយោបាយ សកម្មភាព និងកញ្ចប់ ថវិកាទាក់ទងនឹងការប្រែប្រួលអាកាស ធាតុ ដោយមាន ការចូលរួមពីស្ថាប័នពាក់ព័ន្ធ ដើម្បីធានាតម្លាភាព និង គណនេយ្យភាព។ | ក្រសួងកិច្ចការនារី គណៈកម្មាធិការជាតិគ្រប់គ្រង ការប្រែប្រួលអាកាសធាតុ គ.ជ.អ.ប |
| វិភាជន៍ថវិកាជាតិ ដើម្បីគាំទ្រការអនុវត្តន៍គោល នយោបាយ និងផែនការសកម្មភាពយេនឌ័រ និង ការ ប្រែប្រួលអាកាសធាតុ ដើម្បីធានានិរន្តរភាព។ | ក្រសួងកិច្ចការនារី គណៈកម្មាធិការជាតិគ្រប់គ្រង ការប្រែប្រួលអាកាសធាតុ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ក្រសួង ស្ថាប័នពាក់ព័ន្ធ |
| បង្កើតក្របខ័ណ្ឌតាមដាន និងវាយតម្លៃទៅលើ យេនឌ័រ និងការប្រែប្រួលអាកាសធាតុ។ | ក្រសួងកិច្ចការនារី គណៈកម្មាធិការជាតិគ្រប់គ្រង ការប្រែប្រួលអាកាសធាតុ ក្រសួង ស្ថាប័នពាក់ព័ន្ធ |

## ៣. ផែនការយុទ្ធសាស្ត្រឆ្លើយតបទៅនឹងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ ២០១៣-២០១៨ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

### ៣.១ យុទ្ធសាស្ត្រ Strategies

#### ៣.១.១ វិធានការជាយុទ្ធសាស្ត្រលើវិស័យកសិកម្ម និងកសិឧស្សាហកម្ម

កសិកម្ម ជាវិស័យដែលងាយរងគ្រោះនឹងការប្រែប្រួលអាកាសធាតុ ហើយវាក៏អាចជាអ្នកបង្កឱ្យមានការប្រែប្រួលអាកាសធាតុដែរ ដោយសារវាមានទំនាក់ទំនងយ៉ាងជិតស្និទ្ធនឹងកត្តាអាកាសធាតុ។ ដើម្បីសម្រេចបាននូវការអភិវឌ្ឍផលិតកម្មកសិកម្មប្រកបដោយនិរន្តរភាពសេដ្ឋកិច្ច សង្គម និងបរិស្ថានក្នុងបរិបទនៃការប្រែប្រួលអាកាសធាតុ និងយន្តការអភិវឌ្ឍន៍ស្អាត វិស័យកសិកម្ម និងកសិឧស្សាហកម្មត្រូវអនុវត្តយុទ្ធសាស្ត្របន្សាំ ជាមួយនឹងការកាត់បន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់ដូចខាងក្រោម

**ទី១.** បង្កើនផលិតភាពកសិកម្មដើម្បីធានាសន្តិសុខស្បៀង លើកកម្ពស់អាហារូបត្ថម្ភ និងបង្កើនប្រាក់ចំណូល ដោយជំរុញឱ្យបាននូវកំណើនផលិតកម្មដំណាំគ្រប់ប្រភេទក្នុងកម្រិត ១០% ក្នុង១ឆ្នាំ តាមរយៈការជំរុញការធ្វើប្រពលវប្បកម្ម និងពិពិធកម្មដំណាំសមស្របដោយ ប្រើប្រាស់ទឹកប្រកបដោយប្រសិទ្ធភាពតាមប្រព័ន្ធក្បៀត្របរិស្ថាន ការអភិរក្ស និងប្រើប្រាស់ ពូតគាមរុក្ខជាតិ និងពង្រឹងសមត្ថភាពបន្សាំដើម្បីបង្កើនការងារ និងកសិពាណិជ្ជកម្មក្នុងវិស័យកសិកម្ម និងកសិ

ឧស្សាហកម្ម សំដៅលើកកម្ពស់ជីវភាពរស់នៅរបស់កសិករ និង សហគមន៍ជនបទក្នុងដំណើរការបន្សាំជាមួយការប្រែប្រួលអាកាសធាតុ ។

**ទី២.** ពង្រឹងសមត្ថភាពសិក្សាស្រាវជ្រាវផ្នែកវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងរបកគំហើញ ដើម្បី អភិវឌ្ឍន៍បច្ចេកទេសថ្មីៗ និងការគ្រប់គ្រងព័ត៌មាន និងចំណេះដឹងអំពីការប្រែប្រួល អាកាសធាតុសម្រាប់ពង្រឹងសមត្ថភាពបន្សាំ និងកាត់បន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់ក្នុង វិស័យកសិកម្ម និង កសិឧស្សាហកម្មសម្រាប់គ្រប់ប្រព័ន្ធអេកូឡូស៊ី ក្សេត្របរិស្ថាន ។

**ទី៣.** ជំរុញការអភិវឌ្ឍដោយបញ្ចេញឧស្ម័នផ្ទះកញ្ចក់តិចក្នុងវិស័យកសិកម្ម និង កសិឧស្សាហកម្មតាមរយៈការគ្រប់គ្រងធនធានធម្មជាតិសម្រាប់កសិកម្ម និងស្បៀងអាហារប្រកបដោយ និរន្តរភាពនិងការអនុវត្តកសិកម្មមានភាពឈ្លាសវៃជាមួយអាកាសធាតុដូចជាប្រព័ន្ធកសិកម្មចម្រុះ កសិរុក្ខកម្ម កសិកម្មតាមបែបអភិរក្ស ព្រមទាំងការគ្រប់គ្រងនិងប្រើប្រាស់ សំណល់កសិកម្ម និង កសិឧស្សាហកម្មគ្រប់ប្រភេទសម្រាប់ការកែលម្អជីជាតិដីសំដៅរួម ចំណែកដល់ការកសាងសង្គមដែលបញ្ចេញកាបូនតិច និង មានភាពធន់ទ្រាំនឹងអាកាសធាតុ។

**ទី៤.** ពង្រឹងសមត្ថភាពស្ថាប័នជំនាញក្នុងការសម្របសម្រួល ការធ្វើអន្តរាគមន៍គ្រោះមហន្តរាយដោយធម្មជាតិ ការអភិវឌ្ឍធនធានមនុស្ស ការកសាងគោល នយោបាយ និងក្របខ័ណ្ឌ ច្បាប់ និងការបញ្ជ្រាបការសិក្សាអប់រំលើចំណេះដឹងអំពីការប្រែប្រួលអាកាសធាតុសម្រាប់ គ្រប់កម្រិតសិក្សា ព្រមទាំងលើកកម្ពស់ ការបំពាក់បំប៉ន និងផ្សព្វផ្សាយចំណេះដឹងបច្ចេក វិទ្យាដល់អ្នកពាក់ព័ន្ធគ្រប់មជ្ឈដ្ឋាន រួមមានទាំងអ្នកនយោបាយ និងកសិករផងដែរ។

**ទី៥.** ពង្រឹងសមត្ថភាពសហគ្រាសវិនិយោគកសិកម្ម និង កសិឧស្សាហកម្មឱ្យមានការទទួលខុសត្រូវខ្ពស់ ចំពោះការរួមចំណែករបស់ខ្លួនឱ្យមានការប្រែប្រួលអាកាសធាតុ ដើម្បីកាត់បន្ថយ ភាពងាយរងគ្រោះ និងបង្កើនសមត្ថភាពឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុសំដៅ សម្រេចបាននូវផលប្រយោជន៍សេដ្ឋកិច្ចជាតិ ព្រមទាំងនិរន្តរភាពសង្គម និងបរិស្ថាន។

**ទី៦.** ការឆ្លើយតបចំពោះយេនឌ័រ តាមរយៈ ១-បង្កើនការយល់ដឹងរបស់ស្ត្រីអំពីការប្រែប្រួលអាកាសធាតុនិងផលប៉ះពាល់របស់វាលើវិស័យកសិកម្មក្នុងពេលអនាគត ២-ជំរុញស្ត្រីឱ្យប្រកបរបរកសិកម្មដែលឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ និង ៣-ជំរុញឱ្យមានគំនិតផ្តួចផ្តើមអំពីហិរញ្ញប្បទានសម្រាប់ការប្រកបរបរកសិកម្ម ដែលឆ្លើយតបទៅនឹងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ។

### ៣.១.២ វិធានការជាយុទ្ធសាស្ត្រលើវិស័យកៅស៊ូ

ដើម្បីសម្រេចបានតាមគោលបំណងជាយុទ្ធសាស្ត្រ ឆ្លើយតបទៅនឹងផលប៉ះពាល់នៃការ ប្រែប្រួលអាកាសធាតុលើវិស័យកៅស៊ូ វិធានការគោលនយោបាយមួយចំនួនត្រូវបានកំណត់ដូចខាងក្រោម៖

**ទី១.** ជំរុញការប្រើប្រាស់ខ្លួនកៅស៊ូដែលអាចបន្សុំាបានទៅនឹងការប្រែប្រួលអាកាសធាតុ ពោលគឺសំដៅដល់ការដាក់បញ្ចូលឱ្យប្រើប្រាស់នូវកៅស៊ូដែលមានស្រាប់ និងកៅស៊ូថ្មីនាំចូលពីបណ្តាប្រទេសផលិតកៅស៊ូនានា ជាពិសេសពីបណ្តាប្រទេសក្នុងតំបន់ ដែលអាចធន់ទ្រាំនឹងភាពរាំងស្ងួត ឬសីតុណ្ហភាពខ្ពស់សម្រាប់ដាំដុះនៅតំបន់ណាដែលងាយរង គ្រោះ ។

**ទី២.** ជំរុញការបង្កើត កៅស៊ូថ្មីដែលអាចបន្សុំាបានទៅនឹងការប្រែប្រួលអាកាសធាតុ នៅក្នុងលក្ខខណ្ឌក្សេត្របរិស្ថាននៃប្រទេសកម្ពុជា សម្រាប់ដាំដុះជំនួសឱ្យប្អូនកៅស៊ូដែលនាំចូល ពីក្រៅប្រទេស។

**ទី៣.** ជំរុញការសិក្សាស្រាវជ្រាវពីផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុលើដំណាំកៅស៊ូ ទៅតាមតំបន់ដាំដុះ និងលទ្ធភាពទទួលបានឥណទានកាបូន (Carbon Credit) ពីដំណាំ កៅស៊ូ ដែលផ្តោតការយកចិត្តទុកដាក់ស្រាវជ្រាវ តាមដាននូវកម្រិតលូតលាស់ ទិន្នផលជ័រ និងឈើកៅស៊ូ និងការរាតត្បាតនៃជម្ងឺផ្សេងៗទៅតាមប្រភេទខ្លួន និងទៅតាមតំបន់ដាំដុះ ផ្សេងគ្នា។ ដើម្បីកំណត់បាននូវកូនកៅស៊ូសមស្រប តំបន់ដាំដុះសមស្រប ឬ តំបន់ងាយ រងគ្រោះ និងឈានទៅរកការកំណត់បាននូវតំបន់ដាំដុះតាមពូជ និងតាមតំបន់។ លើក កម្ពស់ការយល់ដឹង និងសហការសិក្សាស្រាវជ្រាវជាមួយស្ថាប័ននានា អំពីលទ្ធភាពក្នុងការ ទទួលបាននូវឥណទានកាបូន (Carbon Credit) ពីដំណាំកៅស៊ូ។

**ទី៤.** សាងសមត្ថភាពមន្ត្រីជំនាញឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុលើដំណាំកៅស៊ូ ដើម្បីឆ្លើយតបបានទាន់ពេលវេលាទៅនឹងការប្រែប្រួលអាកាសធាតុ តាមរយៈការបណ្តុះ បណ្តាលរយៈពេលវែង និងមធ្យមអំពីការតាមដានលើ ប៉ារ៉ាម៉ែត្រអាកាសធាតុ ការបង្កើត គំរូម៉ូឌែលអាកាសធាតុ (Climate modeling) និងគំរូបែបផែនដាំដុះ (Crop Pattern) ទៅតាមតំបន់នីមួយៗ។

**ទី៥.** បង្កើនសមត្ថភាពបច្ចេកទេសដំណាំកៅស៊ូ ជំរុញការអនុវត្តកសិកម្មល្អ (GAP) ក្នុងសកម្មភាពការងារកៅស៊ូ និងបង្កើនការយល់ដឹងពីផលប៉ះពាល់ វិធានការបន្សុំា ឬកាត់ បន្ថយលើការប្រែប្រួលអាកាសធាតុ តាមរយៈការបង្កើនសមត្ថភាពអ្នកដាំកៅស៊ូឱ្យអនុវត្ត បានត្រឹមត្រូវតាម

បច្ចេកទេស និងការអនុវត្តកសិកម្មល្អចាប់តាំងពីការរៀបចំដី ការជ្រើស រើសពូជ ការដាំដុះទាន់ពេលវេលា ការដាំដំណាំគម្របដី ការប្រើប្រាស់ និងថ្នាំគីមី កសិកម្មបានត្រឹមត្រូវ។

**ទី៦**. ជំរុញប្រសិទ្ធភាពក្នុងការប្រើប្រាស់ធាតុចូល (Input) ក្នុងផលិតកម្មកែច្នៃជ័រ និងឈើកៅស៊ូតាមរយៈ (ក). ការសន្សំ ឬ ការប្រើប្រាស់ប្រកបដោយប្រសិទ្ធភាពនូវធាតុចូលក្នុងដំណើរ ការកែច្នៃ ដូចជាឥន្ទនៈ ទឹក អាស៊ីត និងធាតុគីមី (២). ការប្រើប្រាស់ថាមពលកកើតឡើង វិញ (Renewable Energy) សម្រាប់ការកែច្នៃជ័រ និងឈើកៅស៊ូ ដូចជាជីវថាមពល(Bio Energy) ចំហាយទឹក ឬឧស្ម័នបានពីកាកសំណល់រាវនៃការបង្កកជ័រកៅស៊ូ និង (៣). ការគ្រប់គ្រងសំណល់រាវពីរោងចក្របានត្រឹមត្រូវ តាមរយៈការធ្វើប្រព្រឹត្តកម្មសមស្រប ។

### ៣.១.៣ វិធានការជាយុទ្ធសាស្ត្រលើវិស័យផលិតកម្មសត្វ និង សុខភាពសត្វ

ដើម្បីឆ្លើយតបទៅនឹងគោលបំណងយុទ្ធសាស្ត្រ ដែលពាក់ព័ន្ធផលិតកម្មសត្វ និងសុខភាពសត្វខាងលើវិធានការគោលនយោបាយមួយចំនួន ដើម្បីរួមចំណែកក្នុងការកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់និងបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ ត្រូវបានកំណត់ដូចខាងក្រោម៖

**ទី១**. ការសម្របសម្រួលផលិតកម្មសត្វ ៖ ការអនុវត្តការចិញ្ចឹមសត្វត្រូវធ្វើការផ្លាស់ប្តូរដើម្បីបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុរួមមាន ការធ្វើពិពិធកម្ម ការពង្រឹងឱ្យបានខ្លាំងក្លា និង សមាហរណកម្មនូវការគ្រប់គ្រងវាលស្មៅ និងផលិតកម្មសត្វនិងដំណាំ ការអភិរក្សធម្មជាតិ និងប្រព័ន្ធបរិស្ថាន (រុក្ខជាតិ ឬ សត្វនឹងបរិស្ថាន) និងការបញ្ចូលនូវប្រព័ន្ធផលិតកម្មសត្វ លាយគ្នានិងប្រព័ន្ធកសិកម្មចម្រុះ។

**ទី២**. ការអភិវឌ្ឍវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា

- ការបង្កាត់ពូជសត្វ ៖ ពូជសត្វក្នុងស្រុកជាច្រើន បានបន្សាំទៅនឹងលក្ខខណ្ឌរស់នៅ ដែលពិបាក ដូច្នេះបច្ចេកវិទ្យាបង្កាត់ពូជសត្វអាចជួយបង្កើន ល្បឿននៃការបណ្តុំរបស់សត្វទៅនឹងការប្រែប្រួលអាកាសធាតុ ដែលការបន្សាំនេះ មិនត្រឹមតែអាចជួយឱ្យសត្វអាចធន់នឹងកម្តៅប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងជួយឱ្យសត្វមានសមត្ថភាពអាច រស់រានលូតលាស់ និងបន្តពូជក្នុងលក្ខខណ្ឌដែលមានចំណី ពុំសូវមានគុណភាពល្អ សត្វល្អិត និងជម្ងឺ ។

- ការកែលំអចំណីសត្វ៖ ការបញ្ចូលនូវប្រភេទចំណីសត្វថ្មីៗ ដែលធន់នឹងភាពរាំងស្ងួតនិងទឹកជំនន់ និងការកែច្នៃកាកសំណល់កសិកម្មជាចំណីសត្វ អាចជួយធ្វើឱ្យប្រសើរឡើងនូវបរិមាណនិងគុណភាពចំណីសត្វ សម្រាប់ផ្តល់ឱ្យសត្វ។
- ការធ្វើឱ្យប្រសើរឡើងសុខភាពសត្វ ៖ សុខភាពសត្វត្រូវបានការពារ តាមរយៈការ អភិវឌ្ឍវិធីសាស្ត្រថ្មីៗសម្រាប់ធ្វើរោគវិនិច្ឆ័យ ជម្ងឺសត្វ និងការ ផលិតថ្នាំវ៉ាក់សាំងការពារជម្ងឺសត្វ និងការពង្រឹងការត្រួតពិនិត្យ ចលនាសត្វនិងផលិតផលសត្វ។

**ទី៣.** ការពង្រឹងសមត្ថភាព និងការផ្សព្វផ្សាយ ការធ្វើឱ្យប្រសើរឡើងនូវសមត្ថភាពរបស់ស្ថាប័នធនធានមនុស្ស និង អ្នកចិញ្ចឹមសត្វត្រូវការចាំបាច់ណាស់ដើម្បីស្វែងយល់និងទប់ទល់ ជាមួយការប្រែប្រួលអាកាសធាតុ ដែលជួយបង្កើនការយល់ដឹងលើការប្រែប្រួលអាកាស ធាតុលើពិភពលោក។ បន្ថែមពីនេះ ការបណ្តុះបណ្តាលលើបច្ចេកវិទ្យា និងការអនុវត្តការ ចិញ្ចឹមសត្វល្អ ការបង្កាត់ពូជសត្វ ការដាំដំណាំចំណីសត្វនិងវាលស្មៅ និងការពារជម្ងឺសត្វនឹងចូលរួមចំណែកក្នុងការអនុវត្តពិពិធកម្មប្រាក់ចំណូលដល់កសិករ។

**ទី៤.** ការឆ្លើយតបនឹងទីផ្សារសត្វ ៖ ការពង្រឹងទីផ្សារសត្វនិងផលិតផលសត្វដែលប្រជាកសិករ ក្រីក្រ អាចជ្រៀតចូលបាន តាមរយៈការបង្កើតសហគមន៍ចិញ្ចឹមសត្វ និងការជំរុញពាណិជ្ជកម្មក្នុងតំបន់ និង ផែនការវេណទាន។

**ទី៥.** ការអន្តរាគមន៍និងការជួយសង្គ្រោះ ការបង្កើតប្រព័ន្ធព័ត៌មានឱ្យដឹងមុន លើបសុសត្វ និងការផ្តល់លើការថែរក្សាបសុព្យាបាល និងអន្តរាគមន៍សង្គ្រោះបន្ទាន់ដល់សត្វនៅពេល មានគ្រោះមហន្តរាយធម្មជាតិ នឹងជួយធ្វើឱ្យសុខភាពសត្វកាន់តែប្រសើរឡើង និងកាត់ បន្ថយហានិភ័យដល់សត្វ។

**ទី៦.** ការធ្វើឱ្យប្រសើរឡើងនូវការគ្រប់គ្រងលើការផ្តល់ចំណីសត្វ ការផ្តល់ចំណីដែលមានគុណភាពល្អដល់សត្វទំពារអៀងនឹងជួយបង្កើន ប្រសិទ្ធភាពការផ្លាស់ប្តូរចំណី របស់សត្វ ដែលនាំដល់ការកាត់បន្ថយឧស្ម័នមេតានដែលត្រូវបានបង្កើត ក្នុងផលិតកម្មនៃមួយឯកតាសាច់ ឬទឹកដោះគោ។

**ទី៧.** ការគ្រប់គ្រងវាលស្មៅ៖ ការរួមចំណែកការបំភាយឧស្ម័នផ្ទះកញ្ចក់សំខាន់ពីផលិតកម្មសត្វ បណ្តាលមកពីដំណាំចំណីសត្វឬផលិតកម្មដំណាំចំណីសត្វ និងការប្រើប្រាស់ដី។ ការគ្រប់គ្រងវាលស្មៅត្រឹមត្រូវតាមរយៈការផ្លាស់ប្តូរវេនគ្នានូវវាលស្មៅសម្រាប់សត្វជាមធ្យោបាយ ដ៏មានប្រសិទ្ធភាពបំផុតក្នុងការទប់ស្កាត់ការបំភាយឧស្ម័នផ្ទះកញ្ចក់ពីផលិតកម្មដំណាំ ចំណីសត្វ។ ការបញ្ចូលនូវ

ប្រភេទពូជស្មៅ និងអំបូរឡេគុយមីឈើ (Legume) ទៅក្នុងវាលស្មៅអាចជួយពង្រឹងការស្តុកកាបូន និងអាសូតនៅក្នុងដី។

**ទី៨.** ការកាត់បន្ថយការប្រើប្រាស់ចំណីអាហារមានប្រភពពីសត្វ ការកាត់បន្ថយការប្រើប្រាស់ ក្នុងបរិមាណខ្ពស់នូវចំណីអាហារដែលមានប្រភពពីសត្វនឹងជួយកែលម្អសុខភាពមនុស្ស និងជួយបន្ថយការខូចខាតពីការអនុវត្តផលិតកម្មសត្វដល់បរិស្ថាន តាមរយៈការប្រើ ប្រាស់ដី ទឹក និងធនធានធម្មជាតិលើសលប់ដែលនាំដល់បង្កើនកម្រិតនៃការបំភាយឧស្ម័នផ្ទះកញ្ចក់។

**ទី៩.** ការគ្រប់គ្រងកាកសំណល់សត្វ ការគ្រប់គ្រងកាកសំណល់សត្វត្រូវធ្វើឱ្យប្រសើរឡើង តាមរយៈយន្តការផ្សេងៗ ដូចជាការប្រើប្រាស់សម្ភារៈសម្រាប់ស្តុក និងគ្របកាកសំណល់សត្វ (លាមក និងទឹកនោមសត្វ និងកាកសំណល់សត្វពីសត្តឃាតដ្ឋាន)។ ការស្តុក និងគ្រប់ គ្រងឱ្យបានត្រឹមត្រូវ មិនត្រឹមតែជួយទប់ស្កាត់ការបំភាយឧស្ម័នផ្ទះកញ្ចក់ តែថែមទាំង បង្កើតឱកាសសម្រាប់ប្រើប្រាស់ថាមពលកកើតឡើងវិញទៀតផង។

**ទី១០.** ការពង្រឹងក្របខ័ណ្ឌច្បាប់ និងការអនុវត្តច្បាប់ ការអភិវឌ្ឍក្របខ័ណ្ឌច្បាប់ នយោបាយ និងយុទ្ធសាស្ត្រសម្រាប់ការប្រើប្រាស់ និងការគ្រប់គ្រងកាកសំណល់សត្វ អាចជួយរួមចំណែកកាត់បន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់ពីកាកសំណល់សត្វ រួមជាមួយការពង្រឹងការអនុវត្តច្បាប់ប្រកបដោយប្រសិទ្ធភាពខ្ពស់។

### ៣.១.៤ វិធានការជាយុទ្ធសាស្ត្រលើវិស័យព្រៃឈើ

យុទ្ធសាស្ត្រសំខាន់ៗក្នុងវិស័យព្រៃឈើដើម្បីចូលរួមចំណែកកាត់បន្ថយ និងបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុដោយបន្តអនុវត្តកម្មវិធីព្រៃឈើជាតិរួមមាន ការកែលំអ និងបង្កើនប្រសិទ្ធភាពក្នុងការគ្រប់គ្រងព្រៃឈើ ការដាំដុះស្តារព្រៃឈើឡើងវិញ ការបង្កើនសមត្ថភាពនិងការស្រាវជ្រាវដើម្បីផ្តល់ជាព័ត៌មានវិទ្យាសាស្ត្រ ក្នុងការធ្វើសេចក្តីសម្រេចគោលនយោបាយក្នុងការអភិវឌ្ឍវិស័យព្រៃឈើឱ្យមាននិរន្តរភាព និងប្រសិទ្ធភាពខ្ពស់។

**ទី១.** ការបង្កើនប្រសិទ្ធភាពក្នុងការគ្រប់គ្រងព្រៃឈើៈ មានកិច្ចការសំខាន់ៗមួយចំនួន ដែលនឹងជួយរួមចំណែកបង្កើនប្រសិទ្ធភាពក្នុងការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាព រួមមាន ជាអាទិ៍ ការពិនិត្យនិងកំណត់ឡើងវិញនូវព្រំប្រទល់ដែនព្រៃឈើ ការចុះបញ្ជី និងការរៀបចំផែនការគ្រប់គ្រងអភិវឌ្ឍន៍ និងអភិរក្សឱ្យស្របតាមមុខងារនិងស្ថានភាពព្រៃតាមតំបន់នីមួយៗ។ ក្នុងន័យនេះ តំបន់មានសក្តានុពលមួយចំនួន រួមទាំងតំបន់សហគមន៍ព្រៃឈើ ២លានហិកតានឹងត្រូវបាន

រៀបចំអនុវត្តគម្រោង REDD+ ដែលជាកិច្ចការបន្ថែមទៅលើ តំបន់មួយចំនួនដែលរដ្ឋបាលព្រៃឈើបាននិងកំពុងអនុវត្តគម្រោង REDD (Reducing Emission from Deforestation and Forest Degradation) កាបូន គឺជាកម្លាំងចលករដ៏សំខាន់មួយ ក្នុងការជំរុញឱ្យភាគីពាក់ព័ន្ធនានា ក្នុងវិស័យព្រៃឈើ ពិសេសប្រជាសហគមន៍ និង អាជ្ញាធរមូលដ្ឋានចូលរួមកាន់តែខ្លាំងក្លាថែមទៀតក្នុងការគ្រប់គ្រងធនធានព្រៃឈើប្រកបដោយនិរន្តរភាព។

**ទី២.** ការអភិរក្ស និង ការស្តារព្រៃឈើ ការងារអាទិភាពមួយចំនួនទៀតក្នុងការអភិរក្ស និង គ្រប់គ្រងព្រៃឈើក្នុងបរិបទនៃការការប្រែប្រួលអាកាសធាតុនេះរួមមាន ការជំរុញឱ្យមាន ផែនការប្រើប្រាស់ដីក្នុងតំបន់ដីសម្បទានសេដ្ឋកិច្ចឱ្យបានសមស្របតាមលក្ខណៈបច្ចេកទេស ការបង្កើនការយល់ដឹងអំពីភ្លើងឆេះព្រៃ និងការការពារ ការគាំទ្រដល់សហគមន៍ ជនជាតិដើមភាគតិច និងសហគមន៍មូលដ្ឋាន ព្រមទាំងការពារ និងអភិរក្សជីវៈចម្រុះ។ ការស្តារ ការដាំដុះដើមឈើ និងព្រៃឈើឡើងវិញ ជាពិសេសផ្តោតទៅលើការស្តារគម្រប ព្រៃឈើតំបន់ព្រៃរេចរឹលឱ្យបាន៥ម៉ឺនហិកតាក្នុងមួយឆ្នាំក៏ជាការងារចាំបាច់ផងដែរក្នុង ការឆ្លើយតបទៅនឹងឥទ្ធិពលនៃការប្រែប្រួលអាកាសធាតុ តាមរយៈការលើកទឹកចិត្តដល់ ការដាំចម្ការលើឯកជន សហគមន៍ និងជាលក្ខណៈចម្ការព្រៃឈើដៃគូរ ដោយដាំប្រភេទ ឈើចម្រុះ ឬ ឈើឧស្សាហកម្មក្នុងគោលបំណងសម្រាប់បង្កើនជីវភាព និងបង្កើនសេវាកម្មបរិស្ថាន។ ម៉្យាងទៀត ត្រូវផ្សារភ្ជាប់ការងារដាំឈើទៅនឹងវិស័យទេសចរតាមព្រះរាជ បន្ទូលរបស់ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជាដែលមានព្រះរាជបន្ទូលថា "ទេសចរ ម្នាក់ដាំដើមឈើមួយដើម"។ ទន្ទឹមគ្នានោះដែរ ត្រូវយកចិត្តទុកដាក់ផ្តោតលើការរៀបចំ គោលនយោបាយ បទប្បញ្ញត្តិច្បាប់ និងឯកសារបច្ចេកទេសផ្សេងៗសម្រាប់គាំទ្រការងារដាំឈើ និងស្តារព្រៃឈើប្រកបដោយប្រសិទ្ធភាពជាចាំបាច់។

**ទី៣.** ការស្រាវជ្រាវ និងការផ្សព្វផ្សាយ៖ ការសិក្សាស្រាវជ្រាវអំពីការបន្សាំ និងយុទ្ធសាស្ត្រដែលពាក់ព័ន្ធនឹងសកម្មភាពក្នុងការគ្រប់គ្រងព្រៃឈើជាកត្តាចាំបាច់ណាស់ក្នុងការរួមចំណែក ក្នុងការបន្សាំ និងជំនះក្នុងការដោះស្រាយបញ្ហាដែលកើតឡើងពីការប្រែប្រួលអាកាសធាតុ ដើម្បីធានាដល់សន្តិសុខស្បៀង ការបង្កើនជីវភាពរស់នៅ និងការកែលំអផ្នែកបរិស្ថាន ដែលការងារនេះអាចជួយបង្កើតប្រព័ន្ធនៃការគ្រប់គ្រង និងអភិរក្សធនធានធម្មជាតិផងដែរ។ បង្កើនសមត្ថភាពស្ថាប័ន និងជំនាញបច្ចេកទេសក្នុងការគ្រប់គ្រងព្រៃឈើ ជាកត្តាសំខាន់ ណាស់ក្នុងការចូលរួមចំណែកការគ្រប់គ្រងព្រៃឈើសំដៅកាត់បន្ថយការប្រែប្រួលអាកាសធាតុ ។ ការងារនេះអាចធ្វើឡើងតាមរយៈការផ្តល់វគ្គបណ្តុះបណ្តាល ការធ្វើទស្សនកិច្ច សិក្សា ការចូលរួមប្រជុំ សិក្ខាសាលាក្នុង និងក្រៅប្រទេស និង

បន្ទប់ពិសោធន៍សម្រាប់ បម្រើឱ្យការអនុវត្ត ការផ្សព្វផ្សាយ និងការបញ្ជ្រាបការយល់ដឹងជាសាធារណៈអំពីការ ប្រែប្រួលអាកាសធាតុឱ្យដល់គ្រប់មូលដ្ឋាន ជាពិសេស អាជ្ញាធរដែនដីនិងសហគមន៍មូលដ្ឋានជាកត្តាគន្លឹះផងដែរ។

**ទី៤.** ការពង្រឹងការអនុវត្តច្បាប់ សមត្ថភាពក្នុងការគ្រប់គ្រង និងការពារព្រៃឈើរបស់ស្ថាប័នជំនាញនៅមានកម្រិត ហើយព្រៃឈើចេះតែបន្តបាត់បង់និងរេចរឹលជារៀងរាល់ឆ្នាំ។ មូលហេតុសំខាន់គឺបណ្តាលមកពីស្ថាប័នជំនាញទទួលខុសត្រូវ ជាពិសេសរដ្ឋបាលព្រៃឈើ មិនមានមន្ត្រីគ្រប់គ្រាន់ដើម្បីបំពេញការងារ មន្ត្រីភាគច្រើនគ្មានជំនាញបច្ចេកទេសពិតប្រាកដ និងកង្វះខាតមធ្យោបាយសម្ភារៈនិងបរិក្ខារក្នុងការគ្រប់គ្រង និងការពារព្រៃឈើ។ ដើម្បីចូលរួមកាត់បន្ថយការបាត់បង់ព្រៃឈើដែលបង្កឱ្យមានការប្រែប្រួលអាកាសធាតុនេះ ចាំបាច់ត្រូវពង្រឹងសមត្ថភាពក្នុងការអនុវត្តច្បាប់ តាមរយៈការពង្រឹងសមត្ថភាពជំនាញ និង បំពាក់មធ្យោបាយគ្រប់គ្រាន់ដល់មន្ត្រីរដ្ឋ-បាលព្រៃឈើ។

**ទី៥.** ការបន្សាំទីខឹងការប្រែប្រួលអាកាសធាតុ ក្នុងបរិបទនៃការប្រែប្រួលអាកាសធាតុការងារ បន្សាំក៏មានសារៈសំខាន់ ដូចការកាត់បន្ថយការប្រែប្រួលអាកាសធាតុដែរ យុទ្ធសាស្ត្រសំខាន់ៗដើម្បីបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុរួមមាន ការផ្សព្វផ្សាយ និងការបង្កើន ការយល់ដឹងអំពីការប្រែប្រួលអាកាសធាតុដល់សហគមន៍ដែលរស់នៅក្បែរ និងក្នុងតំបន់ព្រៃឈើ ការកំណត់នូវតំបន់ព្រៃ និងសហគមន៍ព្រៃឈើណាខ្លះដែលងាយរងគ្រោះដោយ ការប្រែប្រួលអាកាសធាតុ ការរៀបចំផែនការកាត់បន្ថយភាពងាយរងគ្រោះ និងការស្រាវជ្រាវរក និង ដាំដុះនូវប្រភេទឈើដែលស៊ើទ្រាំបានល្អជាមួយការប្រែប្រួលអាកាសធាតុ។

## ៣.១.៥ វិធានការជាយុទ្ធសាស្ត្រលើវិស័យជលផល

ជលផល និងវារីវប្បកម្ម ជាផ្នែកមួយនៃវិស័យកសិកម្មដែលងាយរងឥទ្ធិពលដោយការប្រែប្រួលអាកាសធាតុ ព្រោះវាមានទំនាក់ទំនងជិតស្និទ្ធទៅនឹងរបបទឹកភ្លៀង ភាពរាំងស្ងួត ទឹកជំនន់ និងសីតុណ្ហភាពទឹក។ ដើម្បីប្រឈមបន្សាំ និងកាត់បន្ថយការប្រែប្រួលអាកាសធាតុប្រកបដោយប្រសិទ្ធភាព និងធានានូវការអភិវឌ្ឍ ធនធានជលផលនិងវារីវប្បកម្មដោយនិរន្តរភាព វិស័យជលផលកំណត់វិធានការគោលនយោបាយយុទ្ធសាស្ត្រឆ្លើយតបទៅនឹងការប្រែប្រួលអាជាតុ ស្របទៅតាមគោលនយោបាយយុទ្ធសាស្ត្រ ១០ឆ្នាំរបស់វិស័យជលផលទាំងមូលៈ

**ទី១.** បង្កើនផលិតភាព និងផលិតផលជលផល ដើម្បីធានាសន្តិសុខស្បៀង លើកកម្ពស់អាហាររូបត្ថម្ភ និងបង្កើនប្រាក់ចំណូលតាមរយៈការពង្រឹងការគ្រប់គ្រង ជំរុញការអភិវឌ្ឍ និងអភិរក្សធនធានជលផល។ ជំរុញការធ្វើវារីវប្បកម្មគ្រប់ប្រភេទឱ្យមានកំណើន ១៥% ជារៀងរាល់ឆ្នាំ។ ជំរុញការបង្កើត និងគ្រប់គ្រងស្រះជម្រកត្រីសហគមន៍ឱ្យបាន ៧៥% នៃ ចំនួនសរុបទូទាំងប្រទេសនៅដំណាច់ឆ្នាំ២០១៩។

**ទី២.** ស្វែងយល់អំពីឥទ្ធិពល និងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុលើធនធានជលផលនឹងវារីវប្បកម្មទូទាំងប្រទេស និងរៀបចំនិងអនុវត្តវិធានការយុទ្ធសាស្ត្របន្សុំ និងកាត់បន្ថយការប្រែប្រួលអាកាសធាតុក្នុងវិស័យជលផល។

**ទី៣.** លើកកម្ពស់គុណភាពសុវត្ថិភាពផលផលិតផលជលផល ដោយកំណត់យ៉ាងហោចណាស់ ៨០% នៃអ្នកកែច្នៃផលិតផលជលផល និង៨០%នៃផលិតផលជលផលត្រី នឹងត្រូវបានអនុវត្តនិងផលិតស្របតាមបទប្បញ្ញត្តិនៃការធានារ៉ាប់រងគុណភាព សុវត្ថិភាពនឹងស្តង់ដារនៅត្រឹមដំណាច់ឆ្នាំ ២០១៩។

**ទី៤.** ជំរុញការបង្កើតនិងសកម្មភាពភូមិមួយផលិតផលជលផលមួយ ដើម្បីលើកកម្ពស់កម្រិតជីវភាពរស់នៅ និងសុខមាភាពរបស់ប្រជានេសាទ ក្នុងការបន្សុំ និងចូលរួមកាត់បន្ថយការប្រែប្រួលអាកាសធាតុ ដោយបង្កើតឱ្យបានភូមិមួយផលិតផលជលផលមួយយ៉ាងហោចណាស់ចំនួន១៥០) នៅដំណាច់ឆ្នាំ២០១៩។

**ទី៥.** ពង្រឹងសម្ថតភាពសិក្សាស្រាវជ្រាវ អភិវឌ្ឍ និងផ្សព្វផ្សាយបច្ចេកទេសថ្មីៗ ក្នុងការភ្ញាស់ បង្កាត់ពូជ ចិញ្ចឹម ផលិតចំណី និងវិធីសាស្ត្រកែច្នៃផលផលិតផលជលផលថ្មីៗ ដែលមាន លក្ខណៈបន្សុំទៅនឹងការប្រែប្រួលនៃអាកាសធាតុ និងមានការីកចម្រើនលូតលាស់ឆាប់រហ័សស្របទៅតាមតម្រូវការសេដ្ឋកិច្ចទីផ្សារ។

**ទី៦.** ពង្រឹង និងពង្រីកសមត្ថភាពអង្គភាពជំនាញ និងអ្នកពាក់ព័ន្ធក្នុងការសម្របសម្រួលធ្វើអន្តរាគមន៍ ព្រមទាំងអភិវឌ្ឍធនធានមនុស្ស តាមរយៈការបណ្តុះបណ្តាលអំពីផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុក្នុងវិស័យជលផល និង វិធានការបន្សុំ។

**ទី៧.** ពង្រឹងការគ្រប់គ្រង និងថែរក្សាព្រៃលិចទឹកនិងព្រៃកោងកាង និងដាំឡើងវិញនៅតំបន់ព្រៃ វេចរីលប្រកបដោយប្រសិទ្ធភាព។ ក្នុងនោះនៅត្រឹមដំណាច់ឆ្នាំ២០១៩ ផ្ទៃដីព្រៃលិចទឹក នៅតំបន់ទឹកសាបចំនួន៣៥% និងនៅតំបន់ឆ្នេរសមុទ្រចំនួន៧៥% ត្រូវបានការពារយ៉ាងល្អ តាមរយៈការ

កំណត់និងបោះបង្គោលព្រំប្រទល់ និង៨០%នៃកន្លែងអភិរក្សនៅតំបន់បឹង ទន្លេសាបត្រូវបានកែ-លម្អ។ ការពារនិងផ្សព្វផ្សាយឱ្យមានការយល់ដឹងជាសាធារណៈ រួមជាមួយការជំរុញឱ្យមានការបង្កើតកន្លែងអភិរក្សធនធានជលផលនៅគ្រប់សហគមន៍នេសាទ ទាំងអស់ដើម្បីធានាឱ្យបាននូវនិរន្តរភាពប្រព័ន្ធអេកូឡូស៊ីធនធានជលផល និង បង្កើននូវផលផលិតផលជលផលដើម្បីចូលរួមការបន្សុំា និង កាត់បន្ថយការប្រែប្រួលអាកាសធាតុ។

**ទី៨.** ជំរុញការរៀបចំ និងអនុវត្តគោលនយោបាយ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា និងផ្សព្វផ្សាយចំណេះដឹងបច្ចេកទេសវិទ្យាសាស្ត្រដល់អ្នកពាក់ព័ន្ធទាំងអស់ដូចជា អ្នកនេសាទ ឬ អ្នកចិញ្ចឹមត្រី អ្នកកែច្នៃ និងអ្នកនយោបាយជាដើម ។

**ទី៩.** ជំរុញការការពារបរិស្ថាន និងប្រព័ន្ធអេកូឡូស៊ីតាមរយៈការទប់ស្កាត់ការបញ្ចេញចោលកាកសំណល់ពីនាវានេសាទ ការកាប់បំផ្លាញ ការដុតការរានយកដី ការប្រើប្រាស់ព្រៃលិចទឹក និងព្រៃកោងកាងសម្រាប់ការកែច្នៃផលិតផលជលផល និងសកម្មភាពបំពុលបរិស្ថានរបស់ទឹកនានា ដើម្បីរួមចំណែកទប់ស្កាត់ការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ដោយសកម្មភាពជលផលដោយផ្ទាល់។

**ទី១០.** យកចិត្តទុកដាក់លើកិច្ចការយែនឌ័រ ក្នុងការបន្សុំាទៅនឹងការប្រែប្រួលអាកាសធាតុ ក្នុងវិ-ស័យជលផល។

## ៤. ផែនការសកម្មភាព ឆ្លើយតបការប្រែប្រួលអាកាសធាតុ ក្រសួងអភិវឌ្ឍន៍ជនបទ

### វិសាលភាពនៃការធ្វើផែនការ

១. វិសាលភាពនៃផែនការសម្រាប់ផែនការសកម្មភាពនេះរួមមានសកម្មភាពដែលជួយសម្រួល

- លើស្ថាបត្យកម្មទូទៅសម្រាប់ការធ្វើផែនការយុទ្ធសាស្ត្រការត្រួតពិនិត្យនិងវាយតម្លៃនៅ MRD និងនៅក្នុង PDRDs
- ជួយ MRD ដើម្បីបង្កើនប្រតិបត្តិការឆ្ពោះទៅរកភាពធន់នឹងអាកាសធាតុនៅក្នុងបរិបទនៃកំណើនបៃតង″ នៅជនបទ
- គាំទ្រ MRD ដើម្បីធានាតុល្យភាពយេនឌ័រនៅកម្រិតស្ថាប័ន។

២. ផែនការសកម្មភាពនេះមិនជំនួស ការធ្វើផែនការមន្ទីរនៅក្រោមសមាសភាព ឬយុទ្ធសាស្ត្រគម្រោងផ្សេងៗរបស់ពួកគេឡើយ។ ផ្ទុយទៅវិញវាបង្កើតបានជាធាតុផ្សំបន្ថែមឆ្ពោះទៅរកការធ្វើសុខដុមនីយកម្មសមាហរណកម្ម ការតំរង់ទិសយុទ្ធសាស្ត្ររួមរបស់ MRD។

៣. ការផ្ដល់អាទិភាពដល់ការអនុវត្តជំហានសំខាន់ៗ ឆ្ពោះទៅរកសមភាពយេនឌ័រនៅក្នុងការងារបុគ្គលិកនៅ MRD និង PDRDs។ គោលដៅ ១ ដើម្បីសម្រេចបាននូវតុល្យភាពយេនឌ័រពេញលេញ (ជាចំនួនសរុប) ដូចក្នុងឆ្នាំ ២០២៣ ។




រូបភាព ៣ សមភាពយេនឌ័រនៅក្នុងការងារបុគ្គលិកនៅ MRD

តារាង ៧ ផែនការសកម្មភាពក្រសួងអភិវឌ្ឍន៍ជនបទ

| # | Action | 2019 | 2020 | 2021 | 2022 | 2023 |
|---|---|---|---|---|---|---|
| 1 | Mainstreaming of strategic actions for climate resilience across all departments; | x | x | | | x |
| 2 | Strengthening of provincial and sub-national entities toward planning and implementation of climate resilience projects, up-lifting of PDRD resources; | x | x | x | x | x |
| 3 | Structural re-adjustments within MRD matching the new challenges | x | x | | | |
| 4 | Increasing state budget for climate action; | x | x | x | x | x |
| 5 | Accessing international climate finance, active promotion to international climate finance institution; | x | x | x | x | x |
| 6 | Designs for climate-proofing of rural infrastructure, rural roads; | x | | x | | x |
| 7 | Management of water supply within the full water cycle (including sanitation, health) | x | x | | | |
| 8 | Income generation and livelihood protection through green economic measures; | x | x | x | x | x |
| 9 | Support to DRR/CCA measures undertaken by other parties, especially through NCDM and NCDD | x | | x | | x |
| | **Priorities on organizational Level:** | | | | | |

| | | | | | | |
|---|---|---|---|---|---|---|
| 10 | Mainstreaming CCA and gender in existing MRD programmes, sub-programmes, projects | x | x | | | |
| 11 | Development of overall budget format including state budget and third-part finance | | | | | |
| 12 | Strengthening capacity of M&E section (national and provinces) | x | x | | | |
| | Enhancing ICT capacity, focus | | | | | |
| 13 | i. CCA and climate resilience | x | x | x | | |
| 14 | ii. Rural technologies | x | x | x | x | x |
| 15 | iii. Vocational training | | | x | x | x |
| 16 | Institutionalization of a central Project Development Unit | x | x | | | |
| 17 | Development of project proposals with other Ministries, NCSD, CARD on new areas of interventions | | x | x | x | x |
| 18 | Bi-annual Cambodian Rural Development Conference | | x | | x | |
| 19 | Planning and implementation of country-wide survey on gender in rural Cambodia (quantitative and qualitative) | | x | x | | |
| 20 | Establishing links with academia, research and rural development institutions, both nationally and regionally. | x | x | x | x | x |
| 21 | Inclusion of climate audits in the annual agenda of the MRD internal auditor | | x | x | x | x |
| | **Priorities on implementation level** | | | | | |
| 22 | Further awareness creation on all aspects of WASH in rural villages | x | x | x | | |
| 23 | Economic diversification in small-scale farming and fishing | | | x | x | x |

| | | | | | | |
|---|---|---|---|---|---|---|
| | households (including economic empowerment of women) | | | | | |
| 24 | Vocational training options and working facilities for young people | | | x | x | x |
| 25 | Facilities for social, economic and cultural activities and engagement in the village (including ethnic groups) | | | x | x | x |
| 26 | Improved delivery of public services in villages and communes | x | x | x | x | x |

## ៥. ផែនការសកម្មភាព និងហានិភ័យដែលឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុក្រសួងធនធានទឹក និងឧតុនិយម

ក្រសួងធនធានទឹក និងឧតុនិយមត្រូវបានផ្តល់អាទិភាពជាក្រសួងគន្លឹះមួយក្នុងក្នុងវិស័យធនធានទឹក និងឧតុនិយម ចំណោមបណ្តាក្រសួងនានា ដើម្បីឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ (តារាង ៨) ។ កម្មវិធីសាកល្បងភាពធនទ្រាំនឹងអាកាសធាតុ (PPCR) របស់ធនាគារពិភពលោក (RGC-C, 2011) បានលើកទឹកប្រាក់ចំនួន ៣៣លានដុល្លាសម្រាប់វិនិយោគលើវិស័យធនធានទឹក ៖ សំណើថវិកានោះនឹងចែកជាពីរផ្នែក ការគ្រប់គ្រងអាកាសធាតុ និងការស្តារប្រព័ន្ធធារាសាស្ត្រខ្នាតតូច និងមធ្យមនៅអាងទន្លេសាប និង ការគ្រប់គ្រងជំនន់ និង ភាពរាំងស្ងួតក្នុងខេត្តពោធិសាត់ និងក្រចេះ ដើម្បីកសាងសមត្ថភាព និងបំពាក់ឧបករណ៍ ។ ការកសាងសមត្ថភាពមន្ត្រីរបស់ក្រសួងធនធានទឹក និងឧតុនិយម ពិសេសនាយកដ្ឋាន គ្រប់គ្រង និងអភិរក្សធនធានទឹក និងនាយកដ្ឋានឧតុនិយម គឺជាការចាំបាច់ផងដែរ ។ ក្នុងពេលជាមួយគ្នា ក្រសួងក៏បាន និងកំពុងកែលំអទេពកោសល្យរបស់មន្ត្រី និងជីវភាពរបស់កសិករ និងស្ត្រីភេទដោយពង្រឹងសមត្ថភាពរបស់ពួកគេឱ្យត្រៀមខ្លួនជាស្រេចក្នុង ការទប់ទល់នឹងភាពគ្រោះថ្នាក់អាកាសធាតុដូចជា ជំនន់ និងភាពរាំងស្ងួត ការកាត់បន្ថយ និងការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ ។

រួមគ្នាជាមួយនឹងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងធនធានទឹក និង ឧតុនិយម ធ្វើការអនុវត្តយុទ្ធសាស្ត្រកសិកម្ម និងទឹក (SAW, 2010 - 2013) ។ កិច្ចការដ៏សំខាន់ របស់យុទ្ធសាស្ត្រកសិកម្ម និងទឹក គឺការប្រតិបត្តិការនៅក្រោយគ្រោះមហន្តរាយ ។ គួរបញ្ជាក់ផងដែរថា យុទ្ធសាស្ត្រកសិកម្ម និងទឹកបានយកចិត្តទុកដាក់យ៉ាងខ្លាំងលើ ការទប់ស្កាតជំនន់ និងភាពរាំងស្ងួត ដោយយកចិត្ត

ទុកដាក់ផ្នែកសន្តិសុខស្បៀង និង ការគ្រប់គ្រងទឹកជាការឆ្លើយតប ។ យុទ្ធសាស្ត្រកសិកម្ម និងធនធានទឹក ក៏បានសង្កត់ធ្ងន់ ដែរថាការប្រែប្រួលអាកាសធាតុគឺជាកត្តាគំរាមកំហែងមួយសម្រាប់រយៈពេលវែងចំពោះ វិស័យកសិកម្ម និងការគ្រប់គ្រងធនធានទឹក ។

តារាង ៨ សកម្មភាពសំខាន់ៗ នៃវិស័យធនធានទឹកឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ

| ផ្នែកសំខាន់ៗ | សកម្មភាព | ហានិភ័យ | *ការសន្និដ្ឋាន* |
|---|---|---|---|
| បង្កើត និងកែលំអរសហគមន៍កសិករប្រើប្រាស់ទឹក | - ប្រមូលផ្តុំគ្រប់ធនធាន និងការទំប្រឹងប្រែង ដើម្បីកែលំអរសហគមកសិករប្រើប្រាស់ដែលមានស្រាប់។<br>- កំណត់ និងបង្កើតផ្នែក ឬតំបន់ថ្មីសម្រាប់បង្កើតសហគមកសិករប្រើប្រាស់ទឹក ។ | - ខ្វះការគាំទ្រផ្នែកហិរញ្ញវត្ថុ<br>- សមត្ថភាពកសិករក្នុងការចូលរួម | គោលនយោបាយរដ្ឋាភិបាលត្រូវបានគាំទ្រ |
| ការគ្រប់គ្រងធនធានទឹកចម្រុះ | - ជំរុញយន្តការការគ្រប់គ្រងធនធានទឹកចម្រុះ ដើម្បីគ្រប់គ្រងធនធានទឹក ដែលបណ្តាលមកពីការប្រែប្រួលអាកាសធាតុ<br>- បន្តសម្របសម្រួលក្នុងចំណោមក្រសួងសំខាន់ៗ សម្រាប់ដំណើរការគ្រប់គ្រងធនធានទឹកចម្រុះ។ | - សារៈសំខាន់នៃការសម្របសម្រួល និងការស្ម័គ្រចិត្តអ្នកពាក់ព័ន្ធសំខាន់ៗ<br>- មិនអាចព្យាករបានពីភាពងាយរងគ្រោះពីការប្រែប្រួលអាកាសធាតុ។ | គោលនយោបាយរដ្ឋាភិបាលត្រូវបានគាំទ្រ |
| ការចូលរួមរបស់វិស័យឯកជន និងការទទួលខុសត្រូវ | - ជំរុញវិស័យឯកជននៅក្នុងការបង់ថ្លៃសេវាកម្មបរិស្ថាន។<br>- លើកកំពស់ការយល់សំខាន់ៗ សម្រាប់ក្រុមហ៊ុនឯកជនក្នុងអភិវឌ្ឍន៍ទៅនឹងការបន្សាំការប្រែប្រួលអាកាសធាតុ។<br>- លើកទឹកចិត្តក្រុមហ៊ុនឯកជនក្នុងការអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព និងការអភិវឌ្ឍដែលប្រកបដោយមានការសាយភាយជាតិកាបូនតិច។ | - គោលនយោបាយជាតិត្រូវបានអនុវត្តយ៉ាងម៉ឺងម៉ាត់<br>- ការគាំទ្រផ្នែកហិរិញ្ញវត្ថុចំពោះការប្រតិបត្តិច្បាប់បន្តទៀត | គោលនយោបាយរដ្ឋាភិបាលត្រូវបានគាំទ្រ |
| វិមជ្ឈការ និងអភិបាលកិច្ចល្អ នៅក្នុងការគ្រប់គ្រងធនធានទឹក | - ប្រគល់តួនាទីក្នុងការទទួលខុសត្រូវទៅលើការគ្រប់គ្រងធនធានទឹកទៅដល់ថ្នាក់ក្រោមជាតិថែមទៀត។<br>- កសាងសមត្ថភាពក្នុងការគ្រប់គ្រងធនធានទឹក និងការប្រើប្រាស់បច្ចេកវិទ្យាធាតុអាកាសទំនើបនៅថ្នាក់ក្រោមជាតិ។ | - ខ្វះការគាំទ្រផ្នែកហិរញ្ញវត្ថុជាតិ | គោលនយោបាយរដ្ឋាភិបាលត្រូវបានគាំទ្រ |
| ឃ្លាំមើលក្នុងការគ្រប់គ្រង និងអភិវឌ្ឍធនធានទឹក | | | |
| គ្រោងការត្រួតពិនិត្យយ៉ាងច្បាស់លាស់ | - អភិវឌ្ឍផែនការរយៈពេលវែងសម្រាប់ការត្រួតពិនិត្យធនធានទឹកជាតិក្នុងការរៀបចំដោះស្រាយគ្រោះថ្នាក់ពីទឹកភ្លៀងខ្លាំងដោយការប្រែប្រួលអាកាសធាតុខុសពីធម្មតា។<br>- បង្កើតវិធានការការពារទឹកជំនន់នៅក្នុងតំបន់ដែលមានហានិភ័យដូចជាតំបន់ដែលមានសក្តានុពលកសិកម្ម និងប្រជាជនច្រើន។<br>- ដំឡើងប្រព័ន្ធប្រកាសភាពអាសន្ននៃទឹកជំនន់ | - ខ្វះការគាំទ្រផ្នែកហិរញ្ញវត្ថុ<br>- ខ្វះនូវទាតនូវធនធានមនុស្ស | រដ្ឋាភិបាលត្រូវមានការសន្យា |
| ការរៀបចំសម្រាប់បញ្ហានគរូបនីយកម្ម | ចាត់វិធានការទប់ទល់ពីផលប៉ះពាល់អវិជ្ជមានលើធនធានទឹកពីការអភិវឌ្ឍន៍ក្រុង ដូចជាបានថយចុះនូវរំហូទឹក បានធ្វើឲ្យខូចគុណភាពទឹក និងការដោះទឹក។ | - ការសម្របសម្រួលក្នុងចំណោមស្ថាប័នពាក់ព័ន្ធ<br>- ចំណេះដឹងនៃការប្រែប្រួលអាកាសធាតុនៃស្ថាប័នព័ន្ធ | រដ្ឋាភិបាលត្រូវមានការសន្យា |
| សុវត្ថភាព និងស្ថេរភាពនៃការប្រើប្រាស់ទឹក | - រៀបចំការប្រើប្រាស់ទឹកដោយពិចារណាពីគ្រោះរាំងស្ងួត។<br>- សាងសង់ប្រព័ន្ធធារាសាស្ត្រប្រកបដោយស្ថិរភាពក្នុងការដោះស្រាយពីការថយចុះនៃទឹកភ្លៀងដោយការប្រែប្រួលអាកាសធាតុ។ | | |
| ទឹកស្អាត និងការផ្គត់ផ្គង | ការពារគុណភាពទឹកនៃប្រភពផ្គត់ផ្គង់ទឹកស្អាត (ទន្លេ បឹង ។ល។) ក្នុងការដោះស្រាយជាមួយភាពងាយរងគ្រោះពីការប្រែប្រួលអាកាសធាតុ។ | | |
| ការប្រើប្រាស់ទឹកក្រោមដី | - រៀបចំផែនការអភិរក្សទឹកក្រោមដី។<br>- រៀបចំនិយ័តកម្មកំណត់ទឹកក្រោមដី។ | | |
| ផែនការយ៉ាច្បាស់លាស់លើបរិស្ថានទន្លេ | - កសាងមូលដ្ឋានគ្រឹះសម្រាប់ការប្រើប្រាស់ទឹកក្រោមដី និងត្រួតពិនិត្យ។.<br>- ធានានូវតួនាទីនៃបរិស្ថានទន្លេរួមទាំងការអភិរក្ស ប្រព័ន្ធអេកូឡូស៊ី និងតួនាទីដែលទាក់ទងនឹងទឹក។ | | |
| ការស្រាវជ្រាវ និងអភិវឌ្ឍន៍ធនធានទឹក | - បង្កើតការស្រាវជ្រាវលើអ្វីដែលសំខាន់បំផុតលើធនធានទឹកដូចជាផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ។<br>- ត្រូវកំណត់ជាអាទិភាពនូវសកម្មភាពដោះស្រាយនឹងការប្រែប្រួលអាកាសធាតុលើការគ្រប់គ្រង និងអភិវឌ្ឍន៍ធនធានទឹកប្រកបដោយនិរន្តរភាព | | |

## ៦. ផែនការសកម្មភាព ឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ ក្នុងវិស័យថាមពល (២០២១-២០២៣) ក្រសួងរ៉ែ និងថាមពល

### ៦.១ សង្ខេបវិសាលភាពនៃផែនការ

ផែនការសកម្មភាពឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុសម្រាប់វិស័យថាមពល គឺផ្តោតសំខាន់លើ ការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ និងការបន្សាំជាមួយការប្រែប្រួលអាកាសធាតុ តាមរយៈការកសាង សមត្ថភាពស្ថាប័នរបស់ក្រសួងរ៉ែ និងថាមពល និងមន្ត្រីរបស់ក្រសួង ក្នុងការរៀបចំគោលនយោបាយ និង សេចក្តីណែនាំចាំបាច់ក្នុងការអនុវត្តសកម្មភាពនានា និងក្នុងការសហការជាមួយភាគីពាក់ព័ន្ធដើម្បីដោះស្រាយ បញ្ហាដែលកើតឡើងពីការប្រែប្រួលអាកាសធាតុ និងព្រឹត្តិការណ៍អាកាសធាតុបន្ទាន់ៗ ដូចជាទឹកជំនន់ ព្យុះ គ្រោះរាំងស្ងួត ក៏ដូចជាការកើនឡើងសីតុណ្ហភាពជាដើម។ ផែនការសកម្មភាពនេះនឹងបន្តពង្រីកសកម្មភាព ដែលមានស្រាប់ទាំងឡាយ ព្រមទាំងស្នើដាក់នូវសកម្មភាពថ្មីៗដែលពាក់ព័ន្ធនឹងផលប៉ះពាល់អាកាសធាតុទៅ លើហេដ្ឋារចនាសម្ព័ន្ធថាមពល និងការអភិវឌ្ឍដែលមានមេត្រីភាពជាមួយបរិស្ថាន។

### ៦.២ តារាងផែនការសកម្មភាព

ក.រ.ថ. ស្នើដាក់ផែនការសកម្មភាពដើម្បីដោះស្រាយបញ្ហាពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុនៅក្នុងវិស័យ ថាមពលក្នុងដែនសមត្ថកិច្ចរបស់ក្រសួងរ៉ែ និងថាមពល ដូចមានសង្ខេបនៅក្នុងតារាងទី៩ ខាងក្រោម៖

# តារាង ៩ ផែនការសកម្មភាព ឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុក្រសួងរ៉ែ និងថាមពល

| យុទ្ធសាស្ត្រ ផ.យ.ប.អ.ក. | រ.ប.ផ.អ.ក.ស.ប.ប.អ. | យុទ្ធសាស្ត្រ ផ.យ.ប.អ.ថ. | ល.រ. ផែនការសកម្មភាព | ឈ្មោះផែនការសកម្មភាពប្រែប្រួលអាកាសធាតុ | ប្រភេទនៃសកម្មភាព | នាយកដ្ឋានទទួលខុសត្រូវ | ថវិកាប៉ាន់ស្មានបឋម (ពាន់ដុល្លារ) | | | | ប្រភពថវិកា |
|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | ២០២១ | ២០២២ | ២០២៣ | សរុប | |
| ១ | | | | លើកកម្ពស់ភាពធន់នឹងអាកាសធាតុ តាមរយៈការធ្វើឱ្យប្រសើរឡើងនូវសន្តិសុខស្បៀង ទឹក និងថាមពល។ | | | | | | | |
| | | ១ | | អភិវឌ្ឍគោលនយោបាយវិស័យថាមពលមួយដែលមានគោលដៅឆ្ពោះទៅរកថាមពលប្រកបដោយនិរន្តរភាពសម្រាប់ទាំងអស់គ្នា (SEforALL) ដោយធានាបាននូវគោលដៅគន្លឹះរបស់វិស័យថាមពលបច្ចុប្បន្នគឺការផ្គត់ផ្គង់ប្រភពថាមពលឱ្យបានគ្រប់គ្រាន់អាចទុកចិត្តបាន និងមានថ្លៃសមរម្យប្រកួតប្រជែងជាមួយប្រទេសជិតខាង។ | | | | | | | |
| | ១៨ | | ១ | រៀបចំផែនការមេអភិវឌ្ឍន៍វិស័យអគ្គិសនីនៅកម្ពុជាឡើងវិញ។ | កែលម្អ | អ.ន.ថ | ២.១០០,៤០ | ១២០,០០ | ១២០,០០ | ២.៣៤០,៤០ | ADB |
| | ម.ម. | | ២ | រៀបចំធ្វើបច្ចុប្បន្នភាពគោលនយោបាយជាតិស្តីពីប្រសិទ្ធភាពថាមពល។ | កែលម្អ | អ.ន.ថ | ៩៣៤,២៧ | ៥០០,០០ | ៥០០,០០ | ១.៩៣៤,២៧ | ADB |
| ២ | | | | កាត់បន្ថយភាពងាយរងគ្រោះតាមវិស័យ តំបន់ យេនឌ័រ និងសុខភាព ដោយសារផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ | | | | | | | |
| | | ២ | | ជំរុញការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធវិស័យថាមពលឱ្យមានលក្ខណៈស៊ាំឬធន់នឹងការ ប្រែប្រួលអាកាសធាតុ | | | | | | | |
| | ម.ម. | | ៣ | រៀបចំពង្រឹងសមត្ថភាព និងស្ថិរភាពអនុស្ថានីយ និងខ្សែបណ្តាញបញ្ជូនអគ្គិសនី។ | កែលម្អ | អ.ក. | ៤៩.៩៣០,០០ | ៨៦.០៤០,០០ | ៥៧.៧២០,០០ | ១៩៣.៦៩០,០០ | ADB |
| | ២៤ | | ៤ | រៀបចំសិក្សាហានិភ័យអាកាសធាតុសម្រាប់ប្រព័ន្ធថាមពលនៅកម្ពុជានិងផ្តល់អនុសាសន៍សម្រាប់ការអនុវត្តនាពេលអនាគត។ | ថ្មី | អ.ន.ថ. អ.ក. | ១៤៦,០០ | ១១៦,០០ | ៦០,០០ | ៣២២,០០ | មិនទាន់មាន |
| ៤ | | | | លើកកម្ពស់ការកសាងផែនការ និងបច្ចេកវិទ្យាបញ្ចេញកាបូនតិច ដើម្បីគាំទ្រដល់ការអភិវឌ្ឍដោយចីរភាព | | | | | | | |
| | | ៣ | | អនុវត្តវិធីសាស្ត្រគ្រប់គ្រងការបញ្ចេញឧស្ម័នផ្ទះកញ្ចក់សម្រាប់វិស័យថាមពល | | | | | | | |
| | ម.ម. | | ៥ | បង្កើតប្រព័ន្ធគ្រប់គ្រងទិន្នន័យឧស្ម័នផ្ទះកញ្ចក់និងការប្រើប្រាស់ថាមពលថ្នាក់ជាតិ | កែលម្អ | ន.អ.ថ. | ១៧៦,០០ | ១៤២,០០ | ២៥៨,០០ | ៥៧៦,០០ | មិនទាន់មាន |

| | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|
| | | | | សម្រាប់ការធ្វើសន្និធិឧស្ម័នផ្ទះកញ្ចក់ និងតុល្យភាពថាមពល | | | | | | | |
| | ១៧ | | ៦ | ផ្តល់ជូនប្រភពថាពលអគ្គិសនីស្អាតនិងបច្ចេកវិទ្យាបញ្ចេញកាបូនតិចទៅកាន់ភូមិនិងគ្រួសារដែលនៅដាច់ស្រយាលមិនទាន់មានអគ្គិសនីប្រើប្រាស់។ | ពង្រីក | ន.ថ.ក.ផ. | ២០.៧៨២,១៩ | ១៨.០៤៣,១៩ | ៣៦.០៨៦,៣៨ | ៧៤.៩១១,៧៦ | មិនទាន់មាន |
| | ម.ម. | | ៧ | រៀបចំនិងអនុវត្តគម្រោងប្រសិទ្ធភាពថាមពលក្នុងក្របខ័ណ្ឌនៃគោលនយោបាយជាតិស្តីពីប្រសិទ្ធភាពថាមពល។ | ថ្មី | ន.ប.ថ.គ.ថ. | ២០០,០០ | ២០០,០០ | ២០០,០០ | ៦០០,០០ | មិនទាន់មាន |
| | ១២ | | ៨ | រៀបចំនិងអនុវត្តកម្មវិធីស្លាកសញ្ញា និងស្តង់ដាប្រសិទ្ធភាពថាមពលក្នុងក្របខ័ណ្ឌនៃគោលនយោបាយជាតិស្តីពីប្រសិទ្ធភាពថាមពល។ | កែលម្អ | ន.ប.ថ.គ.ថ. | ២.១០០,០០ | ៤០០,០០ | ៤០០,០០ | ២.៩០០,០០ | មិនទាន់មាន |
| | ១៦ | | ៩ | រៀបចំសិក្សាថាមពលស្អាត ប្រកបដោយនិរន្តរភាពសម្រាប់ការចម្អិនអាហារនិងអនុវត្តជម្រើសដែលល្អបំផុត។ | ថ្មី | ន.អ.ថ. | ១០០,០០ | ១.០០០,០០ | ៤០០,០០ | ១.៥០០,០០ | មិនទាន់មាន |
| | ម.ម. | | ១០ | រៀបចំសិក្សាគំរូអាជីវកម្មប្រកបដោយនិរន្តរភាពដើម្បីប្រើប្រាស់ថាមពលកម្តៅ និងចំហាយទឹកប្រកបដោយប្រសិទ្ធភាព។ | ថ្មី | ន.ថ.ក. | ៦០០,០០ | ៤០០,០០ | ៣០០,០០ | ១.៣០០,០០ | មិនទាន់មាន |
| | ១៤ | | ១១ | បង្កើតកម្មវិធីគ្រប់គ្រងថាមពលសម្រាប់អគារធំៗ និងរោងចក្រធំៗ និងតាមបែបគោលការណ៍ស្ម័គ្រចិត្តសម្រាប់សហគ្រាសធុនតូចនិងមធ្យមក្នុងក្របខ័ណ្ឌនៃគោលនយោបាយជាតិស្តីពីប្រសិទ្ធភាពថាមពល។ | ថ្មី | ន.អ.ថ, ន.ប.ថ.គ.ថ. | ៤០០,០០ | ៥០០,០០ | ៤០០,០០ | ១.៣០០,០០ | មិនទាន់មាន |
| ៥ | | ៤ | | **បង្កើនសមត្ថភាព ចំណេះដឹង និងការយល់ដឹងសម្រាប់ការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ** | | | | | | | |
| | ម.ម. | | ១២ | បង្កើននិងរៀបចំការកសាងពង្រឹងសមត្ថភាពថាមពលកកើតឡើងវិញ និងប្រសិទ្ធភាពថាមពល។ | កែលម្អ | អ.ន.ថ | ១០០,០០ | ៥០,០០ | ៥០០,០០ | ៦៥០,០០ | មិនទាន់មាន |
| | ១៣ | | ១៣ | បង្កើនការយល់ដឹងជាសាធារណៈលើការសន្សំសំចៃថាមពល។ | ថ្មី | អ.ន.ថ | ១៥០,០០ | ៥០០,០០ | ៥០០,០០ | ១.១៥០,០០ | មិនទាន់មាន |
| សរុបរួម | | | | | | | ៧៧.៧៥៨,៨៧ | ១០៨.០១១,១៩ | ៩៧.៤៤៤,៣៨ | ២៨៣.២១៤,៤៤ | |

# មេរៀនទី ២ ផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ

## ផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ ២០១២-២០២៣

## ១. សេចក្តីផ្តើម

រាជរដ្ឋាភិបាលកម្ពុជាមានការប្តេជ្ញាចិត្តខ្ពស់ ក្នុងការឈានទៅអភិវឌ្ឍប្រទេសប្រកបដោយចីរភាព ដោយ ធានាបាននូវគុណភាព និងស្តង់ដារនៃជីវភាពរស់នៅប្រសើរជាងមុនរបស់ប្រជាពលរដ្ឋ។

កម្មវិធីអាទិភាពចម្បងមួយក្នុងការអភិវឌ្ឍជាតិ គឺការកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ ដូច្នេះ កិច្ច ប្រឹងប្រែងនានាក្នុងការដោះស្រាយការប្រែប្រួលអាកាសធាតុ មិនអាចកាត់ផ្តាច់ចេញពីការអភិវឌ្ឍសេដ្ឋកិច្ច និងការកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋបានឡើយ។ ការដោះស្រាយកិច្ចការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គម ដោយរួម បញ្ចូលការប្រែប្រួលអាកាសធាតុ នឹងជួយរាជរដ្ឋាភិបាលកម្ពុជាក្នុងការកាត់បន្ថយភាពងាយរងគ្រោះ នៅចំពោះមុខ ហានិភ័យនៃការប្រែប្រួលអាកាសធាតុដែលអាចកើតមានការកែលម្អគុណភាពខ្យល់ និងការចូលរួមជាមួយ សហគមន៍អន្តរជាតិដើម្បីកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ ដែលជាមូលហេតុនៃការប្រែប្រួលអាកាសធាតុ។ ការប្រែប្រួលអាកាសធាតុមានឥទ្ធិពលយ៉ាងខ្លាំងដល់ជីវភាពរស់នៅរបស់ប្រជាជន ជាពិសេសអ្នករស់នៅទីជនបទ ដោយអ្នកទាំងនោះពឹងផ្អែកយ៉ាងខ្លាំងលើធនធានធម្មជាតិ ដែលតាមរយៈការព្យាករណ៍បានបង្ហាញថា ធនធានទាំងនោះនឹងត្រូវរងការប៉ះពាល់ពីការប្រែប្រួលអាកាសធាតុ។ បច្ចុប្បន្ន បណ្តាគ្រួសារដែលប្រកបរបរកសិកម្មមានអត្រាភាពក្រីក្រខ្ពស់ជាងគេ ហើយពួកគេក៏ជាក្រុមដែលងាយរងគ្រោះបំផុតពីការប្រែប្រួលអាកាសធាតុ។

**ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (ផ.យ.អ.ជ.)** បច្ចុប្បន្នកម្ម ២០០៩-២០១៣ បានគូសបញ្ជាក់ថា "*ដើម្បី ដោះស្រាយប្រកបដោយប្រសិទ្ធភាពនូវបញ្ហាពាក់ព័ន្ធជាមួយការប្រែប្រួលអាកាសធាតុ ចាំបាច់ត្រូវពង្រឹងសមត្ថភាព ស្ថាប័នរបស់រាជរដ្ឋាភិបាលកម្ពុជា ដើម្បីកំណត់រក និងបង្កើតយុទ្ធសាស្ត្រដើម្បីដោះស្រាយផលប៉ះពាល់ ដែលរំពឹង ថា នឹងកើតចេញពីការប្រែប្រួលអាកាសធាតុ និងពង្រឹងសមត្ថភាពគ្រប់គ្រងគ្រោះមហន្តរាយ*"។ កិច្ចការនេះទាមទារឱ្យផ្តោតលើអាទិភាពនានា ដែលមានចែងនៅក្នុង **ផ.យ.អ.ជ.** បច្ចុប្បន្នកម្ម ២០០៩-២០១៣ ដូចខាងក្រោម ៖

- ពង្រឹងសមត្ថភាពរបស់លេខាធិការដ្ឋានគណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុ។
- ជំរុញ និងសម្របសម្រួលការបញ្ជ្រាបការប្រែប្រួលអាកាសធាតុនៅក្នុងវិស័យពាក់ព័ន្ធ។
- បន្តរៀបចំរបាយការណ៍ជាតិលើកទី២ ក្រោមអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ។

- រៀបចំយុទ្ធសាស្ត្រជាតិ និងផែនការសកម្មភាពជាតិ ដើម្បីឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ។
- ជំរុញការបង្កើតមូលនិធិប្រែប្រួលអាកាសធាតុជាតិ។
- ជំរុញការអនុវត្ត និងធ្វើបច្ចុប្បន្នកម្ម កម្មវិធីសកម្មភាពជាតិស្តីពីការបន្សាំនឹងការប្រែប្រួលអាកាសធាតុ។
- បន្តកំណត់រក និងជំរុញការអនុវត្តយន្តការអភិវឌ្ឍន៍ស្អាត និងគម្រោងកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់នានា។
- អប់រំ និងផ្សព្វផ្សាយដល់សាធារណជនស្តីពីការប្រែប្រួលអាកាសធាតុ។
- កៀរគរធនធាន និងគាំទ្រដល់ការដោះស្រាយបញ្ហាប្រែប្រួលអាកាសធាតុ។
- ធ្វើវិមជ្ឈការការងាររៀបចំសារពើភ័ណ្ឌឧស្ម័នផ្ទះកញ្ចក់ និងរៀបចំប្រព័ន្ធគ្រប់គ្រងកម្រងទិន្នន័យមូលដ្ឋាន។

ការសម្រេចបានចំណុចដៅអភិវឌ្ឍន៍ជាតិ ដែលមានចែងនៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ទាមទារឱ្យមានវិធានការនានា ដើម្បីឆ្លើយតបនឹងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ។ ការរៀបចំផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុកម្ពុជា ផ្តល់ជាចំណុចចាប់ផ្តើម ដើម្បីបង្កើតវិធីសាស្ត្រសមស្របប្រកបដោយសង្គតិភាពនៅក្នុងការបញ្ជ្រាបការប្រែប្រួលអាកាសធាតុ ទៅក្នុងដំណើរការអភិវឌ្ឍន៍ជាតិ។

ផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុកម្ពុជា (**ផ.យ.ប.អ.ក.**) បានរៀបរៀងឡើង ដោយអនុលោមតាមគោលការណ៍ណែនាំរបស់ទីស្តីការគណៈរដ្ឋមន្ត្រី។ នៅក្នុង **ផ.យ.ប.អ.ក.** មានគូសបញ្ជាក់អំពី ចក្ខុវិស័យ បេសកកម្ម គោលបំណងនិងគោលដៅ ក៏ដូចជាការវិភាគក្របខ័ណ្ឌយុទ្ធសាស្ត្រ ក្នុងការកំណត់ ទិសដៅជាយុទ្ធសាស្ត្រ និងយុទ្ធសាស្ត្រនានាផងដែរ។ ផែនការសកម្មភាពឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ នឹង ត្រូវរៀបចំឡើងជាឯកសារដោយឡែក ដែលចែងលម្អិតអំពីការកំណត់អត្តសញ្ញាណ និងអាទិភាពសកម្មភាពស្រប នឹងទិសដៅជាយុទ្ធសាស្ត្រ ដែលបានកំណត់ក្នុង **ផ.យ.ប.អ.ក.**។

ទន្ទឹមនឹងការរៀបចំ **ផ.យ.ប.អ.ក.** ក្រសួង ស្ថាប័នពាក់ព័ន្ធមួយចំនួនបានរៀបចំផែនការយុទ្ធសាស្ត្រឆ្លើយ តបនឹងការប្រែប្រួលអាកាសធាតុ (**ផ.យ.ប.អ.**) តាមវិស័យរៀងៗខ្លួន ដើម្បីធ្វើសមាហរណកម្មការប្រែប្រួលអាកាស ធាតុទៅក្នុងផែនការអភិវឌ្ឍន៍តាមវិស័យរបស់ខ្លួន។ ឯកសារ **ផ.យ.ប.អ.ក.** ផ្តល់នូវទស្សនវិស័យ និងក្របខ័ណ្ឌជាតិ សម្រាប់ដោះស្រាយការប្រែប្រួលអាកាសធាតុ ដោយឡែក **ផ.យ.ប.អ.** តាមវិស័យ របស់ក្រសួង ស្ថាប័នពាក់ព័ន្ធ ផ្តោតលើវិធានការជាក់ស្តែង សម្រាប់ឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុតាមវិស័យ។ ក្រសួង ស្ថាប័នពាក់ព័ន្ធ ទាំងនោះកំពុងរៀបចំផែនការសកម្មភាពឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុតាមវិស័យរៀងៗ ខ្លួន អនុលោមតាម **ផ.យ.ប.អ.** តាមវិស័យ ដែលពាក់ព័ន្ធ ការសម្របសម្រួលបានល្អលើវិធានការឆ្លើយតបនៅថ្នាក់ជាតិ និងថ្នាក់ ក្រោមជាតិ មានសារៈសំខាន់ខ្លាំងណាស់ សម្រាប់ដោះស្រាយបញ្ហាប្រែប្រួលអាកាសធាតុឱ្យមានប្រសិទ្ធភាព។ ផ្សារភ្ជាប់នឹងការបញ្ជ្រាបការ

ប្រែប្រួលអាកាសធាតុទៅក្នុងផែនការនៅថ្នាក់ក្រោមជាតិ គោលការណ៍ណែនាំមួយកំពុងរៀបចំឡើង នៅក្រោមការដឹកនាំរបស់លេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែប ប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (**គ.ជ.អ.ប.**)។

## ២. ចក្ខុវិស័យ

កម្ពុជាអភិវឌ្ឍឆ្ពោះទៅរកសង្គមមួយដែលបៃតង សមធម៌ ចីរភាព និងពឹងផ្អែកលើចំណេះដឹងជាគោល។

## ៣. បេសកកម្ម

បញ្ចេញកាបូនតិចជន់នឹងការប្រែប្រួលអាកាសធាតុបង្កើតក្របខ័ណ្ឌជាតិមួយសម្រាប់ជំរុញការចូលរួមពីស្ថាប័នរដ្ឋ វិស័យឯកជន អង្គការសង្គមស៊ីវិល និងដៃគូ អភិវឌ្ឍន៍នានា សម្រាប់ឆ្លើយតបទៅនឹងបញ្ហាប្រែប្រួលអាកាសធាតុ ដើម្បីគាំទ្រដល់ការអភិវឌ្ឍដោយចីរភាព។

## ៤. គោលបំណង

- កាត់បន្ថយភាពងាយរងគ្រោះរបស់ប្រជាជន ជាពិសេសក្រុមអ្នកដែលងាយរងគ្រោះបំផុត និងប្រព័ន្ធសំខាន់ៗ (ធម្មជាតិ និងសង្គម) បណ្ដាលមកពីផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ។
- បង្វែរទៅរកមាគ៌ាអភិវឌ្ឍបៃតង តាមរយៈការលើកកម្ពស់ការអភិវឌ្ឍបញ្ចេញកាបូនតិច និងបច្ចេកវិទ្យា ពាក់ព័ន្ធ។
- លើកកម្ពស់ការយល់ដឹង និងការចូលរួមរបស់សាធារណជន ក្នុងការឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ។

## ៥. ក្របខ័ណ្ឌយុទ្ធសាស្ត្រ

ប្រទេសកម្ពុជាងាយរងគ្រោះខ្លាំងនៅចំពោះមុខការប្រែប្រួលអាកាសធាតុ ហើយរាជរដ្ឋាភិបាលកម្ពុជាទទួលស្គាល់នូវតម្រូវការចាំបាច់ ដើម្បីបញ្ជ្រាបការប្រែប្រួលអាកាសធាតុទៅក្នុង ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងគោលនយោបាយនានា នៅគ្រប់លំដាប់ថ្នាក់ ដោយផ្អែកលើគោលការណ៍ណែនាំគន្លឹះមួយចំនួន។

### ៥.១. គោលការណ៍ណែនាំ

១. ប្រកាន់ខ្ជាប់នូវគុណតម្លៃនៃការអភិវឌ្ឍដោយចីរភាព។

២. ធានាថា អាទិភាពនៃការអភិវឌ្ឍជាតិអាចសម្រេចបាន នៅក្រោមលក្ខខ័ណ្ឌប្រែប្រួលអាកាសធាតុ។

៣. ផ្តោតលើការគំរាមកំហែង ក៏ដូចជាកាលានុវត្តភាពនៃការប្រែប្រួលអាកាសធាតុ និងឱកាសទាញយកប្រយោជន៍ពីការបំពេញគ្នារវាងការងារបន្សាំនឹងការប្រែប្រួលអាកាសធាតុ និងការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់។

៤. ទទួលស្គាល់ពីភាពស្មុគស្មាញ និងទំនាក់ទំនងគ្នានៃការប្រែប្រួលអាកាសធាតុ និងភាពចាំបាច់ក្នុងការ ប្រើប្រាស់វិធីសាស្ត្រពហុជំនាញ អន្តរវិស័យ និងវិសាលភាពផ្សេងៗ ក្នុងការដោះស្រាយបញ្ហាប្រែប្រួលអាកាសធាតុ។

៥. ទទួលស្គាល់ភាពមិនប្រាកដប្រជានៃការប្រែប្រួលអាកាសធាតុទៅអនាគត បង្កើតភាពបត់បែនបាននៅ ក្នុងការគ្រប់គ្រងប្រព័ន្ធសំខាន់ៗ ដើម្បីដោះស្រាយការប្រែប្រួលដែលមិនអាចដឹងមុន និងប្រើប្រាស់ ដំណោះស្រាយផ្អែកលើហានិភ័យ និងជាដំណាក់កាល នៅក្នុងការកសាងផែនការឆ្លើយតប។

៦. ដោះស្រាយជាមួយគ្នានូវព្រឹត្តិការណ៍មិនប្រក្រតី និងការប្រែប្រួលសំខាន់ៗ (ដូចជាការប្រែប្រួលរដូវ) ដែលបង្កដោយការប្រែប្រួលអាកាសធាតុ។

៧. ប្រើប្រាស់រួមគ្នាវិធីសាស្ត្រដែលផ្អែកលើវិទ្យាសាស្ត្រ ផ្អែកលើស្ថានប្រព័ន្ធ និងផ្អែកលើសហគមន៍។

៨. ធានាថាវិធានការឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុមានសមធម៌ គិតគូរអំពីយេនឌ័រ មានតម្លាភាព មានគណនេយ្យភាព និងសមស្របទៅតាមវប្បធម៌ជាតិ។

៩. ផ្អែកលើចំណេះដឹង នវានុវត្តន៍ និងការកែប្រែទម្លាប់ នៅក្នុងការបង្កើតដំណោះស្រាយសម្រាប់បន្សាំ នឹងការប្រែប្រួលអាកាសធាតុ និងកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់។

១០. ចូលរួមយ៉ាងសកម្មជាមួយសហគមន៍អន្តរជាតិ និងនៅថ្នាក់តំបន់ ក្នុងការដោះស្រាយបញ្ហាប្រែប្រួលអាកាសធាតុ។

## ៥.២. ការវិភាគយុទ្ធសាស្ត្រ

ដើម្បីធានាឱ្យមានការបន្សុីគ្នាជាមួយគោលបំណង និងអាទិភាពអភិវឌ្ឍន៍ជាតិ ឯកសារសំខាន់ៗមួយចំនួន ត្រូវបានលើកយកមកពិចារណា នៅពេលធ្វើការវិភាគជាយុទ្ធសាស្ត្រ។ ឯកសារទាំងនោះរួមមាន ៖

- យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី២
- ចក្ខុវិស័យកម្ពុជាឆ្នាំ២០៣០ (សេចក្តីព្រាង)
- របាយការណ៍អភិវឌ្ឍន៍មនុស្សកម្ពុជាឆ្នាំ២០១១
- គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា

- សមិទ្ធផល និងទិសដៅទៅអនាគតរបស់រដ្ឋាភិបាលកម្ពុជា សម្រាប់ការអភិវឌ្ឍដោយចីរភាព (របាយការណ៍ជាតិសម្រាប់កិច្ចប្រជុំកំពូលរីយ៉ូ +២០)
- ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម ២០០៩-២០១៣
- របាយការណ៍ជាតិលើកទី១ ក្រោមអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ
- សេចក្តីព្រាងរបាយការណ៍ជាតិលើកទី២ ក្រោមអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ
- កម្មវិធីសកម្មភាពជាតិបន្សាំនឹងការប្រែប្រួលអាកាសធាតុ
- សេចក្តីព្រាងគោលនយោបាយបរិស្ថានជាតិឆ្នាំ២០១២
- គោលនយោបាយ យុទ្ធសាស្ត្រ និងផែនការជាតិ និងតាមវិស័យ
- គោលនយោបាយជាតិស្តីពីការអភិវឌ្ឍបៃតង និងផែនការយុទ្ធសាស្ត្រជាតិស្តីពីការអភិវឌ្ឍបៃតងឆ្នាំ ២០១៣-២០៣០
- ឯកសារគោលនយោបាយស្តីពីការជំរុញផលិតកម្មស្រូវ និងការនាំចេញអង្ករ។

## ស្ថានភាពគោលនៃការអភិវឌ្ឍជាតិ

កម្ពុជាសម្រេចបានកំណើនសេដ្ឋកិច្ចសម្រាប់រយៈពេលវែង (១៩៩៤-២០១១) ក្នុងកម្រិត៦-៧% នៃ ផលិតផលក្នុងស្រុកប្រចាំឆ្នាំ ស្ថិរភាពកំណើនសេដ្ឋកិច្ចភាគច្រើនផ្អែកលើការលូតលាស់ក្នុងវិស័យកសិកម្ម វិស័យ កាត់ដេរ វិស័យសំណង់ និងទេសចរណ៍។ ជាបណ្តើរៗ ការកសាងផែនការផ្អែកលើគម្រោង ត្រូវបាន ជំនួសដោយការ កសាងផែនការផ្អែកលើកម្មវិធី នៅក្នុងការជំរុញឱ្យមានការអភិវឌ្ឍដោយចីរភាព។ ការ ប្រមូល និងគ្រប់គ្រងទិន្នន័យ ឱ្យបានប្រសើរកំពុងរួមចំណែកកែលម្អប្រព័ន្ធកសាងផែនការ និងវិភាជន៍ ធនធានប្រកបដោយប្រសិទ្ធភាព។ ទោះជាយ៉ាងណាក៏ដោយ ពិពិធកម្មសេដ្ឋកិច្ចនៅមានកម្រិតទាប ដោយសារប្រជាជនកម្ពុជា ដែលពុំមានជំនាញវិជ្ជាជីវៈ ច្បាស់លាស់នៅមានអត្រាខ្ពស់។

គម្របព្រៃឈើគិតជាភាគរយនៃផ្ទៃដីសរុបនៅក្នុងឆ្នាំ២០១០ មានចំនួន៥៧,០៧% ក្នុងនោះតំបន់ការពារ ធម្មជាតិក្រោមការគ្រប់គ្រងរបស់ក្រសួងបរិស្ថាន មានប្រមាណជាង៣ លានហិកតា។

កសិកម្មនៅតែបន្តជាវិស័យ ដែលស្រូបយកកម្លាំងពលកម្មច្រើនបំផុតក្នុងចំណោមប្រជាពលរដ្ឋ ដោយ បច្ចុប្បន្នមាន៥៧,៦% នៃមនុស្សពេញកម្លាំងធ្វើការនៅក្នុងវិស័យនេះ។

យោងតាម **ផ.យ.អ.ជ.** បច្ចុប្បន្នកម្ម (២០០៩-២០១៣) ដីដាំដំណាំនៅឆ្នាំ២០០៨ មានទំហំ ប្រមាណ ជាង៣,៣១លានហិកតា ដែលក្នុងនោះរួមមាន ដំណាំស្រូវ២,៦១លានហិកតា ដំណាំរួមផ្សំ ០,៥៩លានហិកតា និង ដំណាំកៅស៊ូ០,១១លានហិកតា។ យុទ្ធសាស្ត្រសម្រាប់កសិកម្ម និងទឹក (២០០៦-២០១០) គូសបញ្ជាក់ថា ផ្ទៃដី ដាំដំណាំប្រមាណ៧-៨% តែប៉ុណ្ណោះដែលទទួលបានទឹក

ស្រោចស្រពគ្រប់គ្រាន់ ហើយប្រហែល១០% ទៀត ទទួលបានទឹកស្រោចស្រពបន្ថែមលើទឹកភ្លៀង ចំណែកឯជាង៨០% ដែលនៅសល់ពឹងផ្អែកទាំងស្រុងលើទឹកភ្លៀង។

ត្រីជាប្រភពប្រូតេអ៊ីនរហូតដល់៨០%នៃប្រូតេអ៊ីនសត្វនៅក្នុងរបបអាហាររបស់ប្រជាជន ហើយវិស័យ ជលផលរួមចំណែកប្រមាណ១០% នៃផលិតផលក្នុងស្រុកសរុបរបស់កម្ពុជា ដោយផ្តល់ការងារពេញម៉ោង និងមិន ពេញម៉ោងសរុបដល់ប្រជាជន៦លាននាក់ នៅទូទាំងប្រទេស។ ភាគច្រើននៃដែននេសាទទឹកសាបមាននៅតាមទន្លេ បឹង និងតំបន់ដីសើម ដូចជាបឹងទន្លេសាប និងទន្លេមេគង្គ។

ទេសចរណ៍ជាវិស័យធំជាងគេទី៣ ដែលស្ថិតក្នុងលំដាប់បន្ទាប់ពីកសិកម្ម និងឧស្សាហកម្មកាត់ដេរ។ ប្រាក់ចំណូលជាតិបានពីវិស័យទេសចរណ៍មានកំណើន១៧ដង ពី១០០លានដុល្លារ នៅឆ្នាំ១៩៩៥ រហូតដល់១.៧៨៦ លានដុល្លារ នៅឆ្នាំ២០១០ ដែលបានបង្កើតការងារដោយផ្ទាល់សម្រាប់ប្រជាជន ៣,១៥ សែននាក់។

របាយការណ៍ជាតិសម្រាប់កិច្ចប្រជុំកំពូលរីយ៉ូ+២០ បង្ហាញថា ការផ្គត់ផ្គង់អគ្គិសនីនៅកម្ពុជាពុំទាន់គ្រប់គ្រាន់នៅឡើយទេ ហើយមានតែ១៧,២%នៃប្រជាជនសរុបទូទាំងប្រទេសប៉ុណ្ណោះ ក្នុងនោះប្រជាជននៅជនបទ ប្រមាណ៦% មានអគ្គិសនីប្រើប្រាស់ នៅឆ្នាំ២០១២។ អត្រាប្រើប្រាស់អគ្គិសនី សម្រាប់ប្រជាជនម្នាក់ មានតែ ១៩៩ គីឡូវ៉ាត់ម៉ោងក្នុងមួយឆ្នាំ (ប៉ាន់ប្រមាណឆ្នាំ២០១៣)។

ការផលិតអគ្គិសនីពីឥន្ទនៈហ្វូស៊ីលមាន៩៥,២%នៃសមត្ថភាពផលិតសរុប ចំណែកថាមពលវារីអគ្គិសនី មានត្រឹមតែ ៣,៣%ប៉ុណ្ណោះ ហើយប្រភពថាមពលកកើតឡើងវិញដទៃទៀតគឺ ១,៥%។ ប្រជាជនច្រើនជាង៨០% នៅតែពឹងផ្អែកលើអុស និងធ្យូងសម្រាប់ចំអិនអាហារប្រចាំគ្រួសារ។

យោងតាមក្រសួងសាធារណការ និងដឹកជញ្ជូន ចំនួនយានយន្តដែលចុះបញ្ជី ដូចជាទោចក្រយានយន្ត រថយន្តគ្រួសារ រថយន្តដឹកអ្នកដំណើរខ្នាតតូចនិងធំ រថយន្តដឹកទំនិញខ្នាតតូចនិងធំ មានចំនួន ៣០៧.០០០គ្រឿង នៅឆ្នាំ២០០៩ ជាមួយនឹងអត្រាកំណើនប្រមាណ១៩% ក្នុងមួយឆ្នាំ។

### ព្យាករណ៍អំពីការអភិវឌ្ឍជាតិ

- អត្រាកំណើនសេដ្ឋកិច្ចនៅកម្ពុជាត្រូវបានព្យាករណ៍ថាមាន៧-៨% សម្រាប់ឆ្នាំ២០១៤។
- វិស័យដំណាំកសិកម្មអាចមានកំណើន៥% ក្នុងមួយឆ្នាំ ដើម្បីសម្រេចចំណុចដៅកំណើនសេដ្ឋកិច្ចជាតិ។
- នៅឆ្នាំ២០១១ វិស័យកសិកម្មរួមចំណែក៣២,១% នៃផលិតផលក្នុងស្រុកសរុបប្រចាំឆ្នាំ និងត្រូវបាន ចាត់ទុកថាជាកម្លាំងចលករដ៏សំខាន់នៃកំណើនសេដ្ឋកិច្ចនៅក្នុង **ផ.ឃ.អ.ជ.** បន្ទាប់នេះ។
- ចំណុចដៅសម្រាប់វិស័យទេសចរណ៍ (គិតជាចំនួនមនុស្ស) គឺទទួលភ្ញៀវទេសចរអន្តរជាតិនៅឆ្នាំ ២០១៥ ចំនួន៤,៥លាននាក់ ហើយនៅឆ្នាំ២០១៨ កើនដល់៦,១លាននាក់ រួមជាមួយភ្ញៀវ

ទេសចរណ៍ជាតិ ប្រមាណ១០,៥ លាននាក់ ដែលអាចបង្កើតការងារដោយផ្ទាល់បានជិត ៧ សែននាក់។

- រាជរដ្ឋាភិបាលកម្ពុជាមានមហិច្ឆតាជំរុញស្ថានភាពប្រទេស ឱ្យចាកចេញផុតពីប្រទេលមានចំណូលទាប ឈានទៀងជាប្រទេសមានចំណូលមធ្យមកម្រិកទាប យ៉ាងយូរនៅឆ្នាំ២០១៨ និងក្លាយជាប្រទេសមាន ចំណូលមធ្យមកម្រិតខ្ពស់ នៅឆ្នាំ២០៣០។
- ដោយមានផ្ទៃដី៥៧,០៧%(ឆ្នាំ២០១០) ជាគម្របព្រៃឈើ កម្ពុជាមានឱកាសក្នុងការទទួលផលពីយន្តការទីផ្សារឥណទានការបូ ដូចជា នៅក្នុងក្របខ័ណ្ឌការកាត់បន្ថយការបញ្ចេញឧស្ម័ន ពីការបាត់បង់ព្រៃឈើ និងរេចរឹលព្រៃឈើ (REDD)។
- តាមរយៈអត្រាកំណើនផលិតផលស្រូវប្រចាំឆ្នាំ៥,៧២% កម្ពុជារំពឹងថា នឹងក្លាយខ្លួនជាប្រទេសនាំចេញអង្ករឱ្យបាន១លានតោន នៅឆ្នាំ២០១៥។
- យោងតាមក្រសួងបរិស្ថាន តួលេខប៉ាន់ស្មានអំពីការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ពីវិស័យដឹកជញ្ជូន នឹងកើនពី៧៨៥ពាន់តោនសមមូលឧស្ម័នកាបូនិក នៅឆ្នាំ២០០០ ដល់១១.៣៧៦ពាន់តោនសមមូលឧស្ម័នកាបូនិករហូតដល់ឆ្នាំ២០៥០ ដែលតំណាងឱ្យកំណើន២៧% ក្នុងមួយឆ្នាំ។

**បញ្ហាពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុដែលលើកឡើងនៅក្នុង ផ.យ.អ.ជ. បច្ចុប្បន្នកម្ម ២០០៩-២០១៣**

ផ.យ.អ.ជ. បានបញ្ជាក់ពីភាពចាំបាច់ក្នុងការដោះស្រាយបញ្ហា និងផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុ និងកំណត់វិធានការឆ្លើយតប ដែលរួមមាន ៖

- ស្ថានភាពទឹកជំនន់មកលើហេដ្ឋារចនាសម្ព័ន្ធ
  - ហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ត្រូវការពង្រឹងជាបន្ថែម ជាពិសេសផ្លូវថ្នល់ជនបទ ដើម្បីបញ្ចៀសការរំខានពីទឹកជំនន់មកលើការធ្វើដំណើររបស់ប្រជាជន និងការដឹកជញ្ជូនទំនិញ។
  - ទំនប់ និងប្រឡាយដោះទឹកនានាត្រូវសាងសង់បន្ថែម នៅក្នុងតំបន់ភូមិសាស្ត្រ ដែលងាយរងគ្រោះ ដើម្បីគ្រប់គ្រងលំហូរយ៉ាងច្រើនពីទឹកទន្លេ ឬស្ទឹងក្នុងពេលទឹកជំនន់។

- កម្ពុជានៅខ្វះថាមពលអគ្គិសនី ដែលជាមូលហេតុមួយក្នុងចំណោមមូលហេតុនានា ការអភិវឌ្ឍឧស្សាហកម្មមានកម្រិតទាប ត្រូវយកចិត្តទុកដាក់ទៅលើប្រភពថាមពល មេត្រីភាពជាមួយបរិស្ថាន ដូចជាថាមពលវារីអគ្គិសនីជាដើម។
- ការកាត់បន្ថយភាពក្រីក្រជាបន្ទបន្ទាប់ គឺជាគោលបំណងយូរអង្វែងរបស់រាជរដ្ឋាភិបាលកម្ពុជា ក៏ប៉ុន្តែដោយហេតុថា ប្រជាជនច្រើនជាង៨០%នៅតែពឹងអាស្រ័យលើវិស័យកសិកម្ម និងសកម្មភាពផលិតកសិផលសម្រាប់តែទ្រទ្រង់ជីវិត នោះគ្រោះទឹកជំនន់ និងគ្រោះរាំងស្ងួត អាចរុញច្រានប្រជាជន យ៉ាងច្រើន ឱ្យធ្លាក់ក្រោមកម្រិតខ្សែបន្ទាត់ភាពក្រីក្រ។

- ការគ្រប់គ្រងទឹក និងផលផលរួមចំណែកទ្រទ្រង់ជីវភាពរស់នៅរបស់ប្រជាជនកម្ពុជា។ ការប្រែប្រួលរបបធារាសាស្រ្តបណ្តាលមកពីការប្រែប្រួលអាកាសធាតុ អាចជះផលអវិជ្ជមានដល់ផលនេសាទ។
- កិច្ចការពារ និងរក្សាពពួករុក្ខជាតិ និងសត្វដ៏សំបូរបែបនៅកម្ពុជា។
- កិច្ចប្រឹងប្រែងផ្គត់ផ្គង់ទឹកស្អាត និងអនាម័យ ជាពិសេសនៅតាមទីជនបទ ត្រូវការពង្រីកជាបន្ថែម។ ក្រៅពីកិច្ចការពារធនធានទឹក និងព្រៃឈើ រាជរដ្ឋាភិបាលកំពុងជំរុញការដាំដើមឈើ ស្តារព្រៃរចរឹល និងការវិនិយោគលើដំណាំសម្រាប់ផលិតជីវឥន្ទនៈ។

## ព្យាករណ៍អាកាសធាតុ និងឥទ្ធិពលពាក់ព័ន្ធ

*ព្យាករណ៍អាកាសធាតុ*

- ក្នុងរយៈពេលកន្លងមក សីតុណ្ហភាពនៅកម្ពុជាបានកើនឡើងរួចទៅហើយ។ និន្នាការនេះត្រូវបានព្យាកណ៍ថា នឹងបន្តកើនឡើង ដោយសីតុណ្ហភាពមធ្យមប្រចាំខែនឹងកើនឡើងចន្លោះពី០,០១៣ °C ដល់០,០៣៦°C ក្នុងមួយឆ្នាំៗ ហូតដល់ឆ្នាំ២០៩៩ អាស្រ័យលើទីតាំង ដោយមានអត្រាកំណើនខ្ពស់ នៅតំបន់ទំនាប។
- ទោះបីពុំទាន់មានភស្តុតាងច្បាស់លាស់អំពីផលប៉ះពាល់លើកម្ពស់ទឹកភ្លៀង ក៏ការព្យាករណ៍នានាបានបញ្ជាក់ថា ជារួមកម្ពស់ទឹកភ្លៀងមធ្យមប្រចាំឆ្នាំនឹងកើននៅប្រទេសកម្ពុជា។ ការព្យាករណ៍របបទឹក ភ្លៀងប្រចាំរដូវ បង្ហាញពីនិន្នាការកើនឡើងរវាងខែមិថុនា និងសីហា នៅតំបន់ពាយព្យ និងនិន្នាការថយ ចុះនៅភាគឦសាន។
- របាយការណ៍វាយតម្លៃលើកទី៤ របស់ក្រុមការងារអន្តររដ្ឋាភិបាលស្តីពីការប្រែប្រួលអាកាសធាតុបានប៉ាន់ស្មានថា កម្ពស់ទឹកសមុទ្រនៅក្នុងតំបន់នេះ នឹងកើនឡើងទៅតាមកម្រិតដូចតទៅ ៖ រហូតដល់ឆ្នាំ២០៩០ ធៀបនឹងឆ្នាំ១៩៨០-១៩៩៩ កម្ពស់ទឹកសមុទ្រនឹងកើនឡើងពី០,១៨ ដល់០,៤៣ ម៉ែត្រ នៅក្រោមសេណារីយ៉ូអត្រាបញ្ចេញឧស្ម័នកម្រិតទាប (SRES B1) ០,២១-០,៥២ នៅក្រោម សេណារីយ៉ូអត្រាបញ្ចេញឧស្ម័នកម្រិតមធ្យម (SRES A1B) និង០,២៣-០,៥៦ម, នៅក្រោមសេណារីយ៉ូ អត្រាបញ្ចេញឧស្ម័នកម្រិតខ្ពស់ (SRES A2)។ នេះមានន័យថា នៅក្រោមសេណារីយ៉ូ SRES A2 អត្រាកំណើនកម្ពស់ទឹកសមុទ្រនឹងមាន០,៥៦ ម៉ែត្រ ដែលអាចបង្កឱ្យមានការជន់លិចជាអចិន្ត្រៃយ៍លើផ្ទៃ ដីទំហំប្រមាណ២៥.០០០ហិកតា នៅតាមតំបន់ឆ្នេរកម្ពុជា ក្នុងរយៈពេល៩០ឆ្នាំខាងមុខ។

ឥទ្ធិពលពាក់ព័ន្ធ

- កំណើនសីតុណ្ហភាពទំនងជាបង្កឱ្យមានឥទ្ធិពលមកលើផលិតភាពកសិកម្ម។ យោងតាមវិទ្យាស្ថានស្រាវជ្រាវពូជស្រូវបានបង្ហាញថា ទិន្នផលស្រូវនឹងថយចុះ១០% សម្រាប់កំណើនសីតុណ្ហភាព១°C ធៀបនឹងសីតុណ្ហភាពអប្បបរមានៅរដូវដាំដុះ (ពេលយប់) នៅក្នុងរដូវប្រាំង។
- គម្រោងបន្សាំ និងភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុក្នុងតំបន់មេគង្គ (Mekong ARCC) បានបង្ហាញថា ខេត្តនៅរយៈកម្ពស់ខ្ពស់នៃកម្ពុជានៅរដូវវស្សានឹងមានភ្លៀងច្រើនជាងមុន ដោយឡែកនៅ រដូវប្រាំងវិញមានសភាពស្ងួតហែង ដែលអាចរារាំងការផលិតកាហ្វេ និងកៅស៊ូ។
- ឆ្នេរសមុទ្រកម្ពុជាប្រវែង៤៣៥គ.ម. ងាយរងគ្រោះដោយសារកំណើនកម្ពស់ទឹកសមុទ និងផលប៉ះពាល់ធ្ងន់ធ្ងរពីខ្យល់ព្យុះទីហ្វុងកាន់តែញឹកញាប់ នៅក្រោមការព្យាករណ៍អាកាសធាតុ នាពេលអនាគត។ បញ្ហានេះអាចមានឥទ្ធិពលមកលើសក្តានុពលភ្ញៀវទេសចរ និងបង្កឱ្យមានការហូរច្រោះផងដែរ ហើយខ្យល់បក់ខ្លាំងបណ្តាលឱ្យខូចខាតដល់លំនៅស្ថាននៅតំបន់ឆ្នេរ។
- ក្នុងករណីដែលផ្ទៃដីស្រោចស្រពគ្រប់គ្រាន់មានតែ ៧-៨% កម្ពុជាប្រហែលជាពិបាកសម្រេចបានកំណើនកសិផល ៥% ក្នុងមួយឆ្នាំៗ ដើម្បីសម្រេចបានចំណុចដៅក្នុងការបង្កើនការនាំចេញផលិតផល កសិកម្មនៅឆ្នាំ២០៣០ ក្រោមលក្ខខណ្ឌប្រែប្រួលអាកាសធាតុ (ដូចជាគ្រោះរាំងស្ងួត) ជាពិសេស សម្រាប់ដំណាំសំខាន់ៗមួយចំនួន ដូចជាដំណាំស្រូវ ប្រសិនបើគ្មានការវិនិយោគក្នុងការពង្រីកប្រព័ន្ធ ស្រោចស្រពទេនោះ។

- យោងតាមកម្រងទិន្នន័យគ្រោះមហន្តរាយអន្តរជាតិ (EM-DAT) គ្រោះធម្មជាតិនៅឆ្នាំ២០១១ បាន បង្កការខូចខាតសេដ្ឋកិច្ចប្រមាណ៤,៣% នៃផលិតផលក្នុងស្រុកសរុប។ ទឹកជំនន់ដែលបង្កដោយការ ប្រែប្រួលអាកាសធាតុត្រូវបានព្យាករណ៍ថា នឹងកើតមានកាន់តែញឹកញាប់ និងធ្ងន់ធ្ងរជាងមុន ជាពិសេសនៅតំបន់ទំនាបកណ្តាល។ នៅពេលដែលតំបន់ឆ្នេរនឹងរងឥទ្ធិពលពីខ្យល់ព្យុះស៊ីក្លូន មកពីមហាសមុទ្រប៉ាស៊ីហ្វិក តំបន់ទំនាបកណ្តាលនឹងរងគ្រោះដោយសារទឹកជំនន់ ដែលបង្កដោយកំណើនភ្លៀងធ្លាក់។ តំបន់ទាំងពីរនេះមានសារៈសំខាន់ណាស់ចំពោះសេដ្ឋកិច្ចជាតិ ដោយសារតែវិភាគទាន ខ្ពស់ទៅក្នុងសារពើពន្ធទទួលបានពីទេសចរណ៍ សេវាកម្ម សកម្មភាពនាវាចរ ការនេសាទ និង ផលិតផលកសិកម្ម។ ជាការចាំបាច់ត្រូវចាត់វិធានការដើម្បីកាត់បន្ថយផលប៉ះពាល់នៃហានិភ័យ និង គ្រោះមហន្តរាយបណ្តាលមកពីប្រែប្រួលអាកាសធាតុ ដើម្បីឱ្យកម្ពុជាសម្រេចបានកំណើនសេដ្ឋកិច្ច និងការអភិវឌ្ឍ តាមការរំពឹងទុកក្នុងកម្មវិធីអភិវឌ្ឍន៍ជាតិ។
- ការបញ្ចេញឧស្ម័នផ្ទះកញ្ចក់របស់កម្ពុជា នៅមានកម្រិតទាបខ្លាំង បើប្រៀបធៀបនឹងតួលេខមធ្យមនៅ ថ្នាក់តំបន់ និងពិភពលោក។ យោងតាមរបាយការណ៍ជាតិលើកទី២ ក្រោមអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ បរិមាណឧស្ម័នផ្ទះកញ្ចក់សរុបដែលកម្ពុជាបញ្ចេញ

នៅឆ្នាំ២០០០ មានប្រមាណ៤៧,៦លានតោន ហើយវិស័យព្រៃឈើបានស្រូបយកចំនួនប្រមាណ ៤៨លាន តោន គិតជាសមមូលឧស្ម័នកាបូនិក។ នៅក្នុងអំឡុងពេលដូចគ្នានេះ វិស័យដឹកជញ្ជូន ប្រើប្រាស់ឥន្ទនៈ ហ្វូស៊ីលច្រើនជាងគេ បន្ទាប់មកគឺការផលិតអគ្គិសនី លំនៅដ្ឋាន និងវិស័យ ឧស្សាហកម្ម។ កម្ពុជាត្រូវ បង្កើនការផលិតថាមពល សំដៅជំរុញសកម្មភាពឧស្សាហកម្ម ទន្ទឹមនឹង ការកែលម្អប្រសិទ្ធភាពថាមពល នៅក្នុងវិស័យដឹកជញ្ជូន និងវិស័យលំនៅដ្ឋាន ដើម្បីកាត់បន្ថយការ បញ្ចេញឧស្ម័នផ្ទះកញ្ចក់។ នៅក្នុងដំណាក់កាលបង្កើនការផ្គត់ផ្គង់នេះ ចាំបាច់ត្រូវចាប់ផ្តើមគិតគូរ អំពីការបញ្ចូលប្រភពថាមពលកកើតឡើងវិញ ទៅក្នុងផលិតកម្មថាមពល។

## សមត្ថភាពឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ

ផែនទីស្តីពីភាពងាយរងគ្រោះពីការប្រែប្រួលអាកាសធាតុនៅតំបន់អាស៊ីអាគ្នេយ៍ ដែលរៀបចំឡើង ដោយ កម្មវិធីសេដ្ឋកិច្ច និងបរិស្ថានសម្រាប់អាស៊ីអាគ្នេយ៍ បានបង្ហាញថា កម្ពុជាជាប្រទេសងាយរងគ្រោះ បំផុតមួយ ពីការប្រែប្រួលអាកាសធាតុ ដោយសារសមត្ថភាពបន្សុំានៅមានកម្រិតទាប។

ការវិភាគ "ភាពខ្លាំង ភាពទន់ខ្សោយ កាលានុវត្តភាព និងការគម្រាមកំហែង" (SWOT) នៃវិធាន ការឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុរបស់កម្ពុជា បានធ្វើឡើងតាមរយៈការពិគ្រោះយោបល់ ជាមួយអ្នកពាក់ព័ន្ធជា ច្រើន រួមមានស្ថាប័នរដ្ឋ សង្គមស៊ីវិល ដៃគូអភិវឌ្ឍន៍ និងផ្នែកឯកជន។ លទ្ធផលពី ការវិភាគ SWOT (ដូចមានបង្ហាញជូនខាងក្រោម) ត្រូវបានយកមកពិចារណាបន្ថែម ក្នុងពេលរៀបចំ ផែនការយុទ្ធសាស្ត្រនេះ។

### ភាពខ្លាំង

- ព្រះរាជាចក្រកម្ពុជាមានកំណើនសេដ្ឋកិច្ចខ្ពស់
- ចំណាប់អារម្មណ៍លើចំណេះដឹង និងព័ត៌មានពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុ
- ចំណាប់អារម្មណ៍លើការអភិវឌ្ឍដោយចីរភាពមានកម្រិតខ្ពស់
- មូលដ្ឋានធនធានធម្មជាតិ និងជីវៈចម្រុះសម្បូរបែប
- គោលនយោបាយរបស់រដ្ឋាភិបាលស្តីពីការអភិវឌ្ឍសេដ្ឋកិច្ច
- ក្រសួង-ស្ថាប័នពាក់ព័ន្ធមួយចំនួនបានបង្កើតយុទ្ធសាស្ត្រប្រែប្រួលអាកាសធាតុតាមវិស័យអាទិភាព
- ការគាំទ្រពីស្ថាប័នពាក់ព័ន្ធសហគមន៍អន្តរជាតិនិងសង្គមស៊ីវិល លើដំណោះស្រាយការប្រែប្រួល អាកាសធាតុ
- កំណើនការយល់ដឹងស្តីពីការប្រែប្រួលអាកាសធាតុ
- គោលនយោបាយស្តីពីបរិស្ថាន និងសុខភាព
- ហេដ្ឋារចនាសម្ព័ន្ធបានកែលម្អជាបន្តបន្ទាប់

**ភាពទន់ខ្សោយ**

- ការធ្វើសេចក្តីសម្រេចចិត្តដោយផ្អែកលើចំណេះដឹងវិទ្យាសាស្ត្រនៅមានភាពទន់ខ្សោយ
- គ្មាននីតិវិធីច្បាស់លាស់សម្រាប់បញ្ជ្រាបការប្រែប្រួលអាកាសធាតុទៅក្នុងផែនការអភិវឌ្ឍន៍ជាតិ
- សមត្ថភាពស្ថាប័នជាតិទទួលបន្ទុកការប្រែប្រួលអាកាសធាតុ និងការចូលរួមរបស់អ្នកពាក់ព័ន្ធនៅមានកម្រិត
- ព័ត៌មានចាស់ៗសម្រាប់ដោះស្រាយផលប៉ះពាល់អាកាសធាតុ
- កង្វះខាតធនធានមនុស្ស
- មិនមានទម្លាប់កសាងផែនការអំពីការប្រែប្រួលអាកាសធាតុ
- មូលដ្ឋានចំណេះដឹង ការស្រាវជ្រាវវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាមានកម្រិតទាប
- ធនធានហិរញ្ញវត្ថុមានកម្រិត
- ប្រជាពលរដ្ឋមានសមត្ថភាពបន្សាំទាប

**កាលានុវត្តភាព**

- មូលនិធិប្រែប្រួលអាកាសធាតុពិភពលោកកើនឡើង
- ការបង្កើតរចនាសម្ព័ន្ធចំណេះដឹង និងព័ត៌មានជាតិ
- ការបង្កើតផែនការអភិវឌ្ឍន៍ដោយចីរភាពរបស់ជាតិ
- ការប្តេជ្ញា និងគាំទ្រខាងនយោបាយចំពោះដំណោះស្រាយការប្រែប្រួលអាកាសធាតុ
- កែលម្អជីវភាពប្រជាជន
- កិច្ចប្រឹងប្រែងពិភពលោកក្នុងការដោះស្រាយបញ្ហាប្រែប្រួលអាកាសធាតុ
- កម្មវិធីដែលមានស្រាប់ ដូចជាសម្ព័ន្ធភាពប្រែប្រួលអាកាសធាតុកម្ពុជា និងកម្មវិធីសាកល្បងសម្រាប់ភាពធន់នឹងអាកាសធាតុ
- ដៃគូអភិវឌ្ឍន៍គាំទ្ររាជរដ្ឋាភិបាលក្នុងការដោះស្រាយបញ្ហាប្រែប្រួលអាកាសធាតុ
- កម្មវិធីបង្កើតជំនាញ និងវិជ្ជាជីវៈ

**ការគម្រាមកំហែង**

- ៤៣% នៃឃុំសរុបងាយរងគ្រោះបំផុត
- ការយល់ដឹងកម្រិតទាបអំពីការប្រែប្រួលអាកាសធាតុ និងជម្រើសវិធានការឆ្លើយតប
- គោលនយោបាយ និងអាទិភាពជាច្រើនប្រជែងជាមួយគោលនយោបាយស្តីពីការប្រែប្រួលអាកាសធាតុ

- វិស័យសេដ្ឋកិច្ចចម្បងៗ នៅតែបន្តប្រឈមនឹងឥទ្ធិពលនៃការប្រែប្រួលអាកាសធាតុ សមត្ថភាពនៅមានកម្រិតសម្រាប់ឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ
- ព្រឹត្តិការណ៍អាកាសធាតុមិនប្រក្រតីកើតមានញឹកញាប់
- ខ្វះភាពធន់ទៅនឹងគ្រោះមហន្តរាយធម្មជាតិ

## ស្ថាប័នសម្របសម្រួលការងារប្រែប្រួលអាកាសធាតុ

គណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុ **(គ.ជ.គ.ប.អ.)** ត្រូវបានបង្កើតឡើងនៅឆ្នាំ២០០៦ ដោយមានអាណត្តិរៀបចំ សម្របសម្រួល និងតាមដានពិនិត្យការអនុវត្តគោលនយោបាយ យុទ្ធសាស្ត្រ បរិធានច្បាប់ ផែនការ និងកម្មវិធីនានា របស់រាជរដ្ឋាភិបាល សំដៅឆ្លើយតបទៅនឹងបញ្ហាប្រែប្រួលអាកាសធាតុ។ គណៈកម្មាធិការនេះមាន **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ជាប្រធានកិត្តិយស និងឯកឧត្តមរដ្ឋមន្ត្រីក្រសួងបរិស្ថាន ជាប្រធាន។ ក្រុមបច្ចេកទេសការងារប្រែប្រួលអាកាសធាតុ ត្រូវបានបង្កើតឡើង ដែលជាអង្គភាពអន្តរក្រសួង សម្រាប់ផ្តល់ការគាំទ្របច្ចេកទេសដល់សមាជិកគណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុ នៅក្នុងការបំពេញអាណត្តិរបស់ខ្លួន។ នាយកដ្ឋានប្រែប្រួលអាកាសធាតុ នៃក្រសួងបរិស្ថាន មាននាទីជាលេខាធិការដ្ឋានរបស់គណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុ និង សម្របសម្រួលសកម្មភាព របស់ក្រុមបច្ចេកទេសការងារប្រែប្រួលអាកាសធាតុ។ ក្រសួងពាក់ព័ន្ធសំខាន់ៗ បានតែង តាំងមន្ត្រីបង្គោល និងក្រុមការងារប្រែប្រួលអាកាសធាតុ ដើម្បីធ្វើការងារទាក់ទងនឹងការប្រែប្រួលអាកាសធាតុ ដូចជា ការរៀបចំផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាព និងគម្រោងប្រែប្រួលអាកាសធាតុតាមវិស័យ។

ជាការចាំបាច់ត្រូវពិនិត្យឡើងវិញនូវរចនាសម្ព័ន្ធស្ថាប័នប្រែប្រួលអាកាសធាតុបច្ចុប្បន្ន សំដៅដាក់ចេញជា អនុសាសន៍សម្រាប់កែលម្អ ដើម្បីលើកកម្ពស់ការសម្របសម្រួលអន្តរក្រសួង និងការអនុវត្ត **ផ.យ.ប.អ.ក.** ក៏ដូចជា វិធានការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុនានា។

## យេនឌ័រ និងការប្រែប្រួលអាកាសធាតុ

រាជរដ្ឋាភិបាលកម្ពុជាទទួលស្គាល់ថា ក្នុងចំណោមប្រជាពលរដ្ឋក្រីក្រនៅជនបទ ដែលក្នុងនោះភាគច្រើន ជាស្ត្រី ជាក្រុមងាយរងគ្រោះបំផុតពីផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ ដោយសារតែពួកគាត់ពឹងផ្អែកជាខ្លាំង លើកសិកម្ម និងធនធានធម្មជាតិ។ ក្រុមនេះងាយទទួលរងគ្រោះពីជម្ងឺ ដោយសារធនធាន និងសមត្ថភាពបន្សាំ នឹងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ ក៏ដូចជាការត្រៀមបង្ការរបស់ពួកគាត់សម្រាប់ទប់ទល់នឹងហានិភ័យអាកាសធាតុ និងមុខសញ្ញាមហន្តរាយ នៅមានកម្រិត។ ដូច្នេះ ចាំបាច់ត្រូវបញ្ជ្រាបយេនឌ័រទៅក្នុងវិធានការឆ្លើយតប នឹងការប្រែប្រួលអាកាសធាតុ រួមទាំងគោលនយោបាយ ច្បាប់ដែលមានស្រាប់ និងផែនការយុទ្ធសាស្ត្រឆ្លើយតបនឹង ការប្រែប្រួលអាកាសធាតុតាមវិស័យ ដើម្បីឱ្យបញ្ហាអន្តរវិស័យនេះបានទទួលការគាំទ្រពីស្ថាប័ន ដែលរដ្ឋាភិបាលទាំងអស់ នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ

ព្រមទាំងដៃគូអភិវឌ្ឍន៍ អង្គការមិនមែនរដ្ឋាភិបាល អង្គការសង្គមស៊ីវិលនានា ស្ថាប័នស្រាវជ្រាវអប់រំ និងវិស័យឯកជន។

**ការអប់រំ ការលើកកម្ពស់ការយល់ដឹង និងការប្រាស្រ័យទាក់ទង**

ការបញ្ជ្រាបចំណេះដឹង និងព័ត៌មានអំពីការប្រែប្រួលអាកាសធាតុទៅក្នុងការអប់រំក្នុងប្រព័ន្ធ និងក្រៅប្រព័ន្ធ គឺជាគោលការណ៍គន្លឹះក្នុងការទ្រទ្រង់ការយល់ដឹងអំពីការប្រែប្រួលអាកាសធាតុ សម្រាប់កសាងសង្គមមួយដែលបៃតង មានសមធម៌ និងធន់ទៅនឹងអាកាសធាតុ។ ប្រការសំខាន់ គឺត្រូវបង្កើតបរិយាកាសអំណោយផលសម្រាប់ ការសិក្សាអប់រំ និងការលើកកម្ពស់ការយល់ដឹងអំពីការប្រែប្រួលអាកាសធាតុ ដោយបង្កើត និងពង្រឹងរចនាសម្ព័ន្ធ ប្រព័ន្ធ និងឧបករណ៍សម្រាប់ការប្រាស្រ័យទាក់ទង។

## ៥.៣.ទិសដៅជាយុទ្ធសាស្ត្រ និងយុទ្ធសាស្ត្រ

**ទិសដៅជាយុទ្ធសាស្ត្រទី ១ ៖ លើកកម្ពស់ភាពធន់នឹងអាកាសធាតុ តាមរយៈការធ្វើឱ្យប្រសើរឡើងនូវសន្តិសុខ ស្បៀង ទឹក និងថាមពល**

យុទ្ធសាស្ត្រ

ក. សិក្សាវិភាគលើការរួមចំណែកនៃវិស័យពាក់ព័ន្ធក្នុងការធានាសន្តិសុខនៃប្រព័ន្ធសំខាន់ៗ។

ខ. ជំរុញ និងលើកទឹកចិត្តអ្នកពាក់ព័ន្ធ និងវិស័យនានា ឱ្យចូលរួមនៅក្នុងការកំណត់វិធានការឆ្លើយតបនឹង ការប្រែប្រួលអាកាសធាតុ។

គ. ពង្រឹងយន្តការសម្របសម្រួលសម្រាប់ការឆ្លើយតបឱ្យស៊ីសង្វាក់គ្នា នៅក្នុងគោលនយោបាយឆ្លើយតបនឹង ការប្រែប្រួលអាកាសធាតុ។

ឃ. បង្កើនសមត្ថភាពក្នុងការកំណត់រកកាលានុវត្តភាព ដែលកើតចេញពីការប្រែប្រួលអាកាសធាតុនៅក្នុង ប្រព័ន្ធផលិតកម្មកសិកម្ម ប្រព័ន្ធអេកូឡូស៊ី និងតំបន់ការពារធម្មជាតិ ៖

- ពិពិធកម្មកសិកម្ម( ឧ. ដំណាំ ការចិញ្ចឹមសត្វ។ល។)
- កំណើនផលិតភាព ( ឧ. ដំណាំ ជលផល ការចិញ្ចឹមសត្វ ព្រៃឈើ។ល។)
- ឱកាសសម្រាប់បង្កើនមុខដំណាំថ្មី
- ការគ្រប់គ្រងទីជម្រាល និងប្រព័ន្ធអេកូឡូស៊ី។

ង. សម្រួលដល់ធុរកិច្ច និងឧស្សាហកម្ម ដែលឆ្លើយតបទៅនឹងកាលានុវត្តភាពទីផ្សារ កាបូនសម្រាប់ពាណិជ្ជកម្ម និងការវិនិយោគបៃតង។

លើកកម្ពស់ថាមពលកកើតឡើងវិញនិងប្រសិទ្ធភាពថាមពលដើម្បីកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ និងផលប៉ះពាល់សុខភាព ៖

- ថាមពលកកើតឡើងវិញ
- ប្រសិទ្ធភាពថាមពល
- ការផ្ទេរបច្ចេកវិទ្យាសមស្រប
- ការគ្រប់គ្រងសំណល់រឹង/រាវតាមវិធានការចម្រុះ នៅរាជធានី ទីក្រុងទីប្រជុំជន និងការគ្រប់គ្រង សំណល់សត្វ។

ឆ. បង្កើតប្រព័ន្ធផលិតកម្មថាមពលវិមជ្ឈការ ដែលរួមបញ្ចូលទាំងការប្រើប្រាស់ថាមពលកកើតឡើងវិញ ជាពិសេសថាមពលព្រះអាទិត្យ។

ជ. ស្តារ និងកសាងហេដ្ឋារចនាសម្ព័ន្ធទឹក ដែលរួមទាំងប្រព័ន្ធធារាសាស្ត្រខ្នាតតូច មធ្យម និងខ្នាតធំ។

ឈ. ស្តារ និងពង្រីកហេដ្ឋារចនាសម្ព័ន្ធផ្លូវជនបទ ដែលធន់នឹងអាកាសធាតុ និងតភ្ជាប់តំបន់ផលិតកម្មទៅ ទីផ្សារ។

ញ.បញ្ចូលបញ្ហាប្រែប្រួលអាកាសធាតុទៅក្នុងដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន។

## ទិសដៅជាយុទ្ធសាស្ត្រទី ២ ៖ កាត់បន្ថយភាពងាយរងគ្រោះតាមវិស័យ តំបន់ យេនឌ័រ និងសុខភាព នៅចំពោះមុខផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ

យុទ្ធសាស្ត្រ

ក. ប្រើប្រាស់លទ្ធផលនៃការសិក្សាវាយតម្លៃដែលមានស្រាប់អំពីភាពងាយរងគ្រោះនិងហានិភ័យ ព្រមទាំង សិក្សាវាយតម្លៃជាថ្មី នៅក្នុងករណីចាំបាច់ ដើម្បីចាត់ជាអាទិភាពវិធានការបន្សាំសម្រាប់តំបន់សំខាន់ៗ នៃប្រទេសកម្ពុជា ដូចជាតំបន់ឆ្នេរ តំបន់ខ្ពង់រាប ទីជនបទ និងទីក្រុង។

ខ. អនុវត្តសកម្មភាពគន្លឹះនានា ដែលកំណត់នៅក្នុងផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ តាមវិស័យ របស់ក្រសួង-ស្ថាប័នពាក់ព័ន្ធ សម្រាប់ដោះស្រាយផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ។

គ. លើកកម្ពស់សមាហរណកម្ម ផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុកម្ពុជាទៅក្នុង យុទ្ធសាស្ត្រជាតិ ដូចជាផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងយុទ្ធសាស្ត្រជាតិគាំពារសង្គម។

ឃ. លើកកម្ពស់វិធានការបន្សាំនឹងការប្រែប្រួលអាកាសធាតុថ្នាក់សហគមន៍ និងពង្រឹងភាពជាដៃគូរវាងរាជរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ សង្គមស៊ីវិល និងវិស័យឯកជន។

ង. ជំរុញការប្រើប្រាស់បច្ចេកវិទ្យាសមស្របក្នុងផលិតកម្មដំណាំ និងការចិញ្ចឹមសត្វសម្រាប់កសិករដែលងាយរងគ្រោះ។

ច. កែលម្អប្រសិទ្ធភាពនៃការគ្រប់គ្រងវិស័យជលផល។

ឆ. កែលម្អស្ថានប្រព័ន្ធព្រៃឈើ ព្រៃលិចទឹក តំបន់ឆ្នេរ និងតំបន់ការពារធម្មជាតិ។

ជ. លើកកម្ពស់ការផលិតកៅស៊ូធម្មជាតិប្រកបដោយនិរន្តរភាព ដោយផ្តោតលើវិធានការបន្សុំ និងកាត់បន្ថយ ផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុ។

ឈ. លើកកម្ពស់ផលិតកម្មសត្វ និងកិច្ចការពារសុខភាពសត្វប្រកបដោយនិរន្តរភាព។

ញ. កែលម្អហេដ្ឋារចនាសម្ព័ន្ធថែទាំសុខភាព និងសមត្ថភាពរបស់បុគ្គលិកថែទាំសុខភាព ដើម្បីទប់ទល់នឹង ជម្ងឺដែលបង្កដោយភ្នាក់ងារចម្លង និងជម្ងឺឆ្លងតាមទឹក នៅក្នុងបរិបទនៃការប្រែប្រួលអាកាសធាតុ។

ដ. ណែនាំពីបច្ចេកវិទ្យាអភិវឌ្ឍន៍ និងស្តារឡើងវិញនូវហេដ្ឋារចនាសម្ព័ន្ធទឹកស្អាត ដើម្បីឆ្លើយតបទៅនឹងផល ប៉ះពាល់អវិជ្ជមាននៃការប្រែប្រួលអាកាសធាតុ។

ឋ. លើកកម្ពស់ការកសាងផែនការ និងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូននៅទីក្រុង ដែលត្រូវការទុនច្រើន។ ឌ. ពង្រឹងគុណភាពហេដ្ឋារចនាសម្ព័ន្ធជនបទ (ផ្លូវថ្នល់ ប្រព័ន្ធធារាសាស្ត្រ អណ្តូង និងលូដោះទឹក) ដើម្បីឱ្យ ធន់នឹងគ្រោះទឹកជំនន់ និងគ្រោះរាំងស្ងួត។

ឍ. លើកកម្ពស់ប្រព័ន្ធផ្តល់ព័ត៌មានជាមុនអំពីធាតុអាកាស។

ណ. ផ្តល់អាទិភាពដល់តម្រូវការរបស់ស្ត្រីនៅក្នុងការបន្សុំ និងសកម្មភាពកាត់បន្ថយការប្រែប្រួលអាកាសធាតុ។

**ទិសដៅជាយុទ្ធសាស្ត្រទី ៣៖ លើកកម្ពស់ ភាពធន់នឹងអាកាសធាតុនៃប្រព័ន្ធអេកូឡូស៊ីសំខាន់ៗ (បឹងទន្លេសាប ទន្លេមេគង្គ តំបន់ឆ្នេរ តំបន់ខ្ពង់រាប) ជីវៈចម្រុះ តំបន់ការពារធម្មជាតិ និងតំបន់ បេតិកភណ្ឌវប្បធម៌**

យុទ្ធសាស្ត្រ

ក. ពង្រឹងការអភិរក្សជីវៈចម្រុះ និងស្តារប្រព័ន្ធអេកូឡូស៊ី ដែលរងការគម្រាមកំហែងពីការប្រែប្រួលអាកាសធាតុ។

ខ. លើកកម្ពស់ និងលើកទឹកចិត្តឱ្យមានដំណោះស្រាយដែលផ្អែកលើសហគមន៍ ផ្អែកលើប្រព័ន្ធអេកូឡូស៊ី និងអេកូទេសចរណ៍ ជាមធ្យោបាយមានប្រសិទ្ធភាពក្នុងការដោះស្រាយបញ្ហាប្រែប្រួលអាកាសធាតុ។

គ. លើកកម្ពស់ការប្រើប្រាស់ការបង់ថ្លៃសេវាប្រព័ន្ធអេកូឡូស៊ី រួមទាំងកម្មវិធីកាត់បន្ថយការបញ្ចេញឧស្ម័ន ពី ការបាត់បង់ និងការរេចរឹលព្រៃឈើ (REDD+)។

ឃ. លើកកម្ពស់ការកសាងផែនការប្រើប្រាស់ដី ដោយមានការចូលរួមពីភាគីពាក់ព័ន្ធ។

### ទិសដៅជាយុទ្ធសាស្ត្រទី ៨ ៖ លើកកម្ពស់ការកសាងផែនការ និងបច្ចេកវិទ្យា ដែលបញ្ចេញកាបូនតិច ដើម្បីគាំទ្រ ដល់ការអភិវឌ្ឍដោយចីរភាព

យុទ្ធសាស្ត្រ

ក. សិក្សាវិភាគទៅលើជម្រើស ដែលបញ្ចេញឧស្ម័នផ្ទះកញ្ចក់តិចនៅតាមវិស័យ និងប្រភពបញ្ចេញឧស្ម័ន (កសិកម្ម ថាមពល ការដឹកជញ្ជូន ឧស្សាហកម្ម ការគ្រប់គ្រងការប្រើប្រាស់ដីនិងព្រៃឈើ និងការគ្រប់ គ្រងសំណល់)។

ខ. រៀបចំគោលនយោបាយ ក្របខ័ណ្ឌច្បាប់ និងផែនការសកម្មភាពអភិវឌ្ឍន៍ ដែលបញ្ចេញកាបូនតិច ដោយ អនុលោមតាមអាទិភាពអភិវឌ្ឍន៍នានារបស់ជាតិ។

គ. ជំរុញការផ្ទេរបច្ចេកវិទ្យាសមស្រប ដើម្បីលើកកម្ពស់ការអភិវឌ្ឍ ដែលបញ្ចេញកាបូនតិច (ដូចជា កែលម្អ ប្រសិទ្ធភាពថាមពល ថាមពលកកើតឡើងវិញ។ល។) និងសម្រួលឱ្យមានការប្រើប្រាស់តាមរយៈ ៖

- គោលការណ៍ណែនាំជំនួយបច្ចេកទេស និងការបង្កើតភាពជាដៃគូ
- ការលើកទឹកចិត្តផ្នែកហិរញ្ញវត្ថុ និងសារពើពន្ធ
- យន្តការទីផ្សារកាបូន
- ការកៀរគរភាពជាដៃគូសាធារណៈ និងឯកជន។

ឃ. លើកកម្ពស់ការកសាងផែនការអភិវឌ្ឍន៍ទីក្រុងដែលធន់នឹងអាកាសធាតុ និងបញ្ចេញកាបូនតិច ព្រមទាំងបង្កើតយន្តការសម្របសម្រួលនៅកម្រិតទីក្រុង (ដូចជា ប្រព័ន្ធដឹកជញ្ជូនសាធារណៈ ដែលមាន ប្រសិទ្ធភាព ទំនើបកម្មអាងប្រព្រឹត្តកម្ម និងទីលានចាក់សំណល់រឹង នៅរាជធានី ខេត្ត)។

ង. បង្កើតប្រព័ន្ធចុះបញ្ជីគម្រោង និងកម្មវិធីកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់។

ច. បង្កើតប្រព័ន្ធសារពើភ័ណ្ឌឧស្ម័នផ្ទះកញ្ចក់ជាតិប្រកបដោយគុណភាព។

### ទិសដៅជាយុទ្ធសាស្ត្រទី ៩ ៖ ពង្រឹងសមត្ថភាព ចំណេះដឹង និងការយល់ដឹងសម្រាប់ឆ្លើយតបទៅនឹងការប្រែប្រួល អាកាសធាតុ

យុទ្ធសាស្ត្រ

ក. ជំរុញការអនុវត្តមាត្រាទី៦ នៃអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ ស្តីពីការ អប់រំ ការបណ្តុះបណ្តាល ការយល់ដឹងជាសាធារណៈ ការចូលរួម និងការទទួលបានព័ត៌មានរបស់មហាជន និងកិច្ចសហប្រតិបត្តិការអន្តរជាតិ ក្រោមបរិបទប្រែប្រួលអាកាសធាតុ។

ខ. ពង្រឹងមធ្យោបាយដែលមានស្រាប់ សម្រាប់លើកកម្ពស់ការយល់ដឹងអំពីការប្រែប្រួលអាកាសធាតុ តាមរយៈភ្នាក់ងារផ្តល់សេវាកម្ម រាជរដ្ឋាភិបាល គ្រូបង្រៀន អ្នកសារព័ត៌មាន សេវាកម្មផ្សព្វផ្សាយ អ្នកដឹកនាំ សាសនា និងអ្នកដឹកនាំសហគមន៍។

គ. រៀបចំកម្មវិធីបង្កើនការយល់ដឹង ដោយផ្តោតលើក្រុមគោលដៅជាក់លាក់ ដូចជាក្រុមពលរដ្ឋងាយរង គ្រោះបំផុត ស្ត្រី កុមារ យុវជន និងក្រុមជនជាតិភាគតិច។

ឃ. សម្រួលឱ្យសាធារណជនទទួលបានព័ត៌មានអំពីការប្រែប្រួលអាកាសធាតុ តាមរយៈវិទ្យុ ទូរទស្សន៍សារព័ត៌មាន បច្ចេកវិទ្យាចល័ត វេបសាយ និងសម្ភារៈផ្សព្វផ្សាយសម្រាប់ក្រុមគោលដៅ។

ង. ផ្សព្វផ្សាយដល់វិស័យឯកជន ឱ្យស្វែងយល់អំពីការគំរាមកំហែង និងកាលានុវត្តភាព (ជំនួយបច្ចេកទេស ថវិកា និងការផ្ទេរបច្ចេកវិទ្យា) ទាក់ទងនឹងការប្រែប្រួលអាកាសធាតុ និងបង្កើតភាពជាដៃគូសាធារណៈ និងឯកជន សម្រាប់ការប្រាស្រ័យទាក់ទង។

ច. បញ្ចូលប្រធានបទប្រែប្រួលអាកាសធាតុទៅក្នុងកម្មវិធីសិក្សានៅគ្រប់កម្រិតសិក្សា។

ឆ. ពង្រឹងគុណភាពអប់រំគ្រូបង្រៀន និងបណ្តុះបណ្តាលអ្នកកសាងផែនការ អំពីវិធីសាស្ត្របង្រៀន និងសិក្សា រៀនសូត្រអំពីការប្រែប្រួលអាកាសធាតុ។

ជ. ពង្រឹងសមត្ថភាពក្នុងការប្រមូល វិភាគ ធ្វើម៉ូឌែល និងបកស្រាយទិន្នន័យអាកាសធាតុ ហើយផ្សព្វផ្សាយព័ត៌មានអាកាសធាតុដល់អ្នកប្រើប្រាស់ផ្ទាល់ ក្នុងវិស័យនានា ដែលរួមទាំងព្យាករណ៍ប្រចាំរដូវ សម្រាប់បន្សាំ និងត្រៀមសម្ភារៈប្រកាសអាសន្នជាមុនរបស់សហគមន៍ ក្នុងការគ្រប់គ្រងហានិភ័យគ្រោះ មហន្តរាយ។

ឈ. កែលម្អប្រព័ន្ធព្យាករណ៍ និងពិនិត្យតាមដានធាតុអាកាសរបស់ជាតិ និងកសាងភាពជាដៃគូសម្រាប់បង្កើត ម៉ូឌែលបង្រួញមាត្រដ្ឋាន អំពីអាកាសធាតុទៅអនាគត។

ញ. បង្កើតប្រព័ន្ធផ្តល់ព័ត៌មានអំពីធាតុអាកាសជាមុន និងកម្មវិធីសម្រាប់គ្រប់គ្រងគ្រោះមហន្តរាយដែលទាក់ទងនឹងអាកាសធាតុ និងការស្តារឡើងវិញ។

ដ. ពង្រឹងតួនាទីរបស់សកលវិទ្យាល័យក្នុងការបណ្តុះបណ្តាល ស្រាវជ្រាវ អភិវឌ្ឍបច្ចេកវិទ្យា ដោយកសាង ភាពជាដៃគូអន្តរជាតិ លើការស្រាវជ្រាវអំពីអាកាសធាតុ។

ឋ. ប្រើប្រាស់មេរៀនដែលទទួលបានចំណេះដឹង និងទម្លាប់ល្អៗនៅមូលដ្ឋាន សម្រាប់កសាងគោលនយោបាយ និងសកម្មភាពបន្សាំ និងកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់។

ឌ. បង្កើត "មជ្ឈមណ្ឌលគ្រប់គ្រងចំណេះដឹង ដើម្បីសម្រួលដល់ការទទួលបានព័ត៌មានទាន់ហេតុការណ៍ ដែលចាំបាច់សម្រាប់ការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ។

**ទិសដៅជាយុទ្ធសាស្ត្រទី ៦ ៖ លើកកម្ពស់ការចូលរួម និងកិច្ចគាំពារសង្គមបែបបន្សាំនឹងការប្រែប្រួលអាកាសធាតុដើម្បីកាត់បន្ថយការបាត់បង់ និងខូចខាត**

យុទ្ធសាស្ត្រ

ក. លើកកម្ពស់មីក្រូហិរញ្ញប្បទាន ដើម្បីបង្កភាពងាយស្រួលដល់សហគមន៍មូលដ្ឋាន ក្នុងការទទួលបាន ឥណទានសម្រាប់ធ្វើសកម្មភាពឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ។

ខ. ជំរុញ និងលើកទឹកចិត្តឱ្យមានប្រព័ន្ធធានារ៉ាប់រង សម្រាប់កាត់បន្ថយបន្ទុកហានិភ័យ និងគ្រោះមហន្តរាយ អាកាសធាតុមកលើសង្គម។

គ. ធ្វើសមាហរណកម្មយេនឌ័រទៅក្នុងការកសាងផែនការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ។

ឃ. ជំរុញដំណើរការវិមជ្ឈការ ដើម្បីពង្រឹងដំណើរការហិរញ្ញវត្ថុ និងស្ថាប័នសម្រាប់ការបន្សាំនៅមូលដ្ឋាន។

ង. ចាត់ចែងជាលក្ខណៈប្រព័ន្ធសម្រាប់ការចូលរួម និងការពិគ្រោះយោបល់ជាសាធារណៈ ដែលជាចំណុច ចាប់ផ្ដើមសម្រាប់កសាងផែនការបន្សាំ ការលើកកម្ពស់ឱ្យអ្នកពាក់ព័ន្ធនានាបានចូលរួមទាំងអង្គការមិន មែនរដ្ឋាភិបាល អង្គការសហគមន៍ យុវជន សហគមន៍ជនជាតិដើមភាគតិច និងវិស័យឯកជន។

ច. លើកកម្ពស់ភាពជាដៃគូរវាងវិស័យសាធារណៈ និងឯកជន រួមទាំងការទទួលខុសត្រូវចំពោះសង្គមរបស់ ក្រុមហ៊ុនផងដែរ។

### ទិសដៅជាយុទ្ធសាស្ត្រទី ៧ ៖ពង្រឹងស្ថាប័ន និងក្របខ័ណ្ឌការងារសម្របសម្រួល សម្រាប់ឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុថ្នាក់ជាតិ

យុទ្ធសាស្ត្រ

ក. បញ្ជ្រាបការប្រែប្រួលអាកាសធាតុទៅក្នុងផែនការអភិវឌ្ឍន៍ថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ និងយុទ្ធសាស្ត គាំពារសង្គម។

ខ. ពង្រឹងក្របខ័ណ្ឌស្ថាប័នជាតិ និងការសម្របសម្រួលអន្តរក្រសួង នៅក្នុងការកសាងគោលនយោបាយ។

គ. ពង្រឹងតួនាទី និងសមត្ថភាពរបស់លេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាស ធាតុសម្រាប់សម្របសម្រួលហិរញ្ញប្បទានអាកាសធាតុ និងជាស្ថាប័នជាតិសម្រាប់អនុវត្តហិរញ្ញប្បទាន អាកាសធាតុពិភពលោក។

ឃ. បង្កើតក្របខ័ណ្ឌជាតិសម្រាប់ការពិនិត្យតាមដាននិងវាយតម្លៃអំពីការប្រែប្រួលអាកាសធាតុ និងរួមបញ្ចូល ក្របខ័ណ្ឌនេះទៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ក៏ដូចជាផែនការយុទ្ធសាស្ត្រជាតិគាំពារ សង្គម។

ង. លើកទឹកចិត្តក្រសួងពាក់ព័ន្ធ ឱ្យកសាងយុទ្ធសាស្ត្រ និងផែនការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ តាមវិស័យ និងចូលរួមនៅក្នុងដំណើរការកសាងផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាស ធាតុកម្ពុជា។

**ទិសដៅជាយុទ្ធសាស្ត្រទី ៨៖ពង្រឹងកិច្ចសហការ និងចូលរួមយ៉ាងសកម្ម នៅក្នុងកិច្ចខិតខំប្រឹងប្រែងឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុនៅថ្នាក់តំបន់ និងពិភពលោក**

យុទ្ធសាស្ត្រ

ក. លើកកម្ពស់កិច្ចសហប្រតិបត្តិការថ្នាក់តំបន់ ស្តីពីការប្រែប្រួលអាកាសធាតុ នៅក្នុងយន្តការអន្តររដ្ឋាភិបាល និងមិនមែនរដ្ឋាភិបាល ៖

- ការអនុវត្តកាតព្វកិច្ចនៅក្រោមអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ
- កិច្ចសហប្រតិបត្តិការក្រោមក្របខ័ណ្ឌអាស៊ាន
- កិច្ចសហការត្បូង-ត្បូង និងជើង-ត្បូង
- កិច្ចផ្តួចផ្តើមឆ្លងដែន ដូចជាក្នុងក្របខ័ណ្ឌអាងទន្លេមេគង្គ។ល។
- កិច្ចសហប្រតិបត្តិការតាមរយៈយន្តការអភិវឌ្ឍន៍ស្អាត យន្តការទីផ្សាកាបូន និងយន្តការឥណទាន កាបូនពាក់ព័ន្ធនានា។

ខ. ពង្រឹងយន្តការស្ថាប័នជាតិសម្រាប់សម្របសម្រួលការពិគ្រោះយោបល់អំពីជំហរជាតិ និងការឆ្លើយតបទៅ នឹងបញ្ហាបច្ចុប្បន្ន និងអនាគត ក្នុងការចរចាជាអន្តរជាតិអំពីការប្រែប្រួលអាកាសធាតុ។

គ. ពង្រឹងជំនាញចរចារបស់កម្ពុជាក្នុងកិច្ចចរចាអន្តរជាតិអំពីការប្រែប្រួលអាកាសធាតុ និងពង្រឹងសមត្ថភាព សម្រាប់អនុវត្តកាតព្វកិច្ចអន្តរជាតិនានា។

ឃ. ចូលរួមយ៉ាងសកម្មជាមួយកិច្ចផ្តួចផ្តើម និងកម្មវិធីនៅថ្នាក់តំបន់ និងកម្រិតពិភពលោក សំដៅរៀនសូត ពីគ្នាទៅវិញទៅមក និងចែករំលែកជាមួយអន្តរជាតិនូវបទពិសោធរបស់កម្ពុជាអំពីការប្រែប្រួលអាកាសធាតុ។

ង. ជានាឱ្យមានហិរញ្ញប្បទានអាកាសធាតុពីយន្តការផ្តល់មូលនិធិអន្តរជាតិ។

## ៦. សកម្មភាព

ផែនការយុទ្ធសាស្ត្រនេះ ផ្តល់ជាក្របខ័ណ្ឌធំទូលាយមួយ សម្រាប់អនុវត្តវិធានការឆ្លើយតបនឹងការប្រែប្រួល អាកាសធាតុនៅកម្ពុជា។ ចាំបាច់ត្រូវរៀបចំផែនការសកម្មភាព និងយន្តការពាក់ព័ន្ធនានា ដូចជា

យន្តការហិរញ្ញប្បទានក្របខ័ណ្ឌត្រួតពិនិត្យតាមដាន និងវាយតម្លៃ និងក្របខ័ណ្ឌច្បាប់ ដើម្បីអនុវត្តផែនការយុទ្ធសាស្ត្រនេះ និងផ្តល់ជាមូលដ្ឋានរឹងមាំ សម្រាប់ការកៀរគរធនធាន។

## ៦.១. ដំណាក់កាលសម្រាប់អនុវត្ត ផ.យ.ប.អ.ក.

ការអនុវត្ត **ផ.យ.ប.អ.ក.** ត្រូវអនុលោមតាមដំណាក់កាលដូចខាងក្រោម ៖

- **នៅក្នុងរយៈពេលខ្លី** (២០១៣–២០១៤) ការចាត់ចែងស្ថាប័ន និងហិរញ្ញវត្ថុសម្រាប់អនុវត្ត **ផ.យ.ប.អ.ក.** ត្រូវរៀបចំឡើង រួមផ្សំជាមួយក្របខ័ណ្ឌជាតិសម្រាប់ការពិនិត្យតាមដាន និងវាយតម្លៃ។ នៅ ក្នុងដំណាក់កាលនេះក្រសួង-ស្ថាប័នពាក់ព័ន្ធនីមួយៗ ត្រូវកសាងផែនការសកម្មភាពលម្អ និងចាត់ អាទិភាព (២០១៤-២០១៨) ដែលរួមមានសកម្មភាពជាក់លាក់មួយ សម្រាប់ការគ្រប់គ្រងចំណេះដឹង និងការងារសម្របសម្រួល។
- **នៅក្នុងរយៈពេលមធ្យម** (២០១៤–២០១៨) ៖ ដំណាក់កាលនេះ នឹងបន្តគាំទ្រដល់ការអនុវតសកម្មភាព ដូចដែលបានគ្រោងក្នុងដំណាក់កាលទី១ ជាមួយការពង្រីកសកម្មភាពដទៃទៀត ដូចជា ការរៀបចំយន្តការ ទទួលបានមូលនិធិបន្សាំនិងមូលនិធិអាកាសធាតុបៃតង ការស្រាវជ្រាវ និងការគ្រប់គ្រងចំណេះដឹង ការអភិវឌ្ឍសមត្ថភាព ការបញ្ជ្រាបការប្រែប្រួលអាកាសធាតុនៅតាមកម្រិតថ្នាក់នៃវិស័យនានា ការប្រតិបត្តិ ប្រព័ន្ធត្រួតពិនិត្យនិងវាយតម្លៃ និងគ្រប់គ្រងទិន្នន័យ និងការចាប់ផ្តើមគម្រោងឬកម្មវិធីនានា ដែលមាន អាទិភាពខ្ពស់នៅក្នុងវិស័យសំខាន់ៗ ដូចបានកំណត់នៅក្នុងផែនការសកម្មភាពឆ្លើយតបនឹងការប្រែប្រួល អាកាសធាតុ ជាដំបូង អាទិភាពត្រូវផ្តោតលើសកម្មភាពបន្សាំ ហើយបន្តិចម្តងៗនឹងគាំទ្រការពង្រីកសកម្មភាពកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់ នៅក្នុងដំណាក់កាលនេះ ការបញ្ជ្រាបហិរញ្ញប្បទានប្រែប្រួល អាកាសធាតុទៅក្នុងការកសាងផែនការនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ការលើកគម្រោងថវិកា និងនីតិវិធី នៃការអនុវត្តនឹងចាប់ផ្តើម និងពង្រីកជាបណ្តើរៗ។ បន្ថែមលើនេះ កម្ពុជានឹងបង្កើតស្ថាប័នសមស្របមួយ ដែលមានសមត្ថភាពគ្រប់គ្រាន់ និងលក្ខណៈសម្បត្តិពេញលេញ ដែលអាចបានការទទួលស្គាល់ជាផ្លូវការ និងមានសិទ្ធិទទួលយកថវិកាដោយផ្ទាល់ពីមូលនិធិបន្សាំ និងមូលនិធិអាកាសធាតុបៃតង។
- **នៅក្នុងរយៈពេលវែង** (២០១៩–២០២៣)៖ ដំណាក់កាលនេះបន្តផ្តោតលើការស្រាវជ្រាវ និងការ រៀនសូត្រ ប៉ុន្តែគោលដៅចម្បង គឺការពង្រីកសកម្មភាពជោគជ័យទាំងឡាយ ដែលសម្រេចបានកន្លងមក និងបន្តបញ្ជ្រាបការប្រែប្រួលអាកាសធាតុទៅក្នុងកម្មវិធីនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ការប្រើប្រាស់ មូលនិធិគាំទ្រនឹងកាន់តែកើនច្រើន សម្រាប់កម្មវិធីជាតិ រួមទាំងការផ្តល់មូលនិធិសម្រាប់វិធានការឆ្លើយតប នឹងការប្រែប្រួលអាកាសធាតុ តាមរយៈរដ្ឋបាលនៅថ្នាក់ក្រោមជាតិផងដែរ។

ខាងក្រោមនេះមានរៀបរាប់អំពីសកម្មភាពនានា ដែលត្រូវអនុវត្តនៅក្នុងរយៈពេលខ្លី។

**ការចាត់ចែងរចនាសម្ព័ន្ធស្ថាប័ន**

នៅកម្រិតថ្នាក់ជាតិ **គ.ជ.គ.ប.អ.** មានតួនាទីទទួលខុសត្រូវរួម លើការគ្រប់គ្រង និងពិនិត្យតាមដានការអនុវត្ត **ផ.យ.ប.អ.ក.** ដោយមានការគាំទ្របច្ចេកទេសពីក្រុមបច្ចេកទេសការងារប្រែប្រួលអាកាសធាតុ និង ការគាំទ្រការងារចាត់ចែងរដ្ឋបាលពីលេខាធិការដ្ឋាន **គ.ជ.គ.ប.អ.**។

ជាការចាំបាច់ ត្រូវពិនិត្យកែសម្រួលការរៀបចំ អាណត្តិ និងតួនាទី-ភារកិច្ចនៃស្ថាប័នប្រែប្រួលអាកាសធាតុ កម្ពុជានានា សំដៅឆ្លុះបញ្ចាំងលើការទទួលខុសត្រូវជាក់លាក់របស់ខ្លួន ក្នុងការគ្រប់គ្រង និងពិនិត្យតាមដាន ការអនុវត្ត **ផ.យ.ប.អ.ក.**។ លេខាធិការដ្ឋាន **គ.ជ.គ.ប.អ.** ត្រូវមានឋានៈតាមផ្លូវច្បាប់ ជាស្ថាប័នអន្តរក្រសួងនៅ ក្រោម **គ.ជ.គ.ប.អ.** ដែលមានតួនាទី និងសិទ្ធិអំណាចពេញលេញ ក្នុងការសម្របសម្រួលការងារអន្តរវិស័យ ហើយ មានសមត្ថភាពគ្រប់គ្រាន់ និងលក្ខណៈសម្បត្តិពេញលេញ ដែលអាចបានការទទួលស្គាល់ជាផ្លូវការ និងមានសិទ្ធិ ទទួលយកថវិកាដោយផ្ទាល់ពីមូលនិធិអាកាសធាតុពិភពលោក។ នីតិវិធីផ្លូវច្បាប់ចាំបាច់នឹងមានចែងលម្អិតនៅក្នុង ផែនការសកម្មភាពសម្រាប់មុខងារគ្រប់គ្រងចំណេះដឹង និងការសម្របសម្រួលជាយុទ្ធសាស្ត្រ។

នៅកម្រិតក្រសួង មន្ត្រីបង្គោលប្រែប្រួលអាកាសធាតុ និង/ឬក្រុមការងារត្រូវបានបង្កើតឡើងរួចហើយ។ ការទទួលខុសត្រូវរបស់មន្ត្រីបង្គោលទាំងនេះនិងក្រុមការងារ ត្រូវធ្វើឱ្យច្បាស់លាស់ នាពេលឆាប់ៗខាងមុខ ជាពិសេស ទំនាក់ទំនងជាមួយនាយកដ្ឋានផ្សេងទៀតនៅក្នុងក្រសួងពាក់ព័ន្ធ ដើម្បីធានាថាការរៀបចំគោលនយោបាយ កម្មវិធី និងការវិនិយោគតាមវិស័យ បានគិតគូរពេញលេញអំពីហានិភ័យ និងឱកាសនៃការប្រែប្រួលអាកាសធាតុ។

នៅកម្រិតរដ្ឋបាលថ្នាក់ក្រោមជាតិ គោលការណ៍ណែនាំអំពីការកសាងផែនការអភិវឌ្ឍន៍នៅក្នុងបរិបទ ការប្រែប្រួលអាកាសធាតុនឹងត្រូវដាក់ឱ្យប្រើប្រាស់ នៅខែមិថុនា ឆ្នាំ២០១៤ ក្រោមការដឹកនាំរបស់លេខាធិការដ្ឋាន **គ.ជ.គ.ប.អ.**។ គោលការណ៍ណែនាំទាំងនេះត្រូវផ្អែកលើបទពិសោធជាច្រើន ដែលទទួលបានក្នុងបណ្ដាឆ្នាំកន្លងទៅ ថ្មីៗនេះ តាមរយៈគម្រោងសាកល្បង ដែលភាគច្រើនមាននៅថ្នាក់ឃុំ។ តាមតែអាចធ្វើបាន គោលការណ៍ណែនាំ ទាំងនេះនឹងមានរួមបញ្ចូលអនុសាសន៍នានាអំពីកិច្ចសហការរវាងរដ្ឋបាលថ្នាក់ក្រោមជាតិ នៅលំដាប់ខុសៗគ្នា (ខេត្ត/ក្រុង ស្រុក/ខណ្ឌ និងឃុំ/សង្កាត់) និងជាពិសេសនីតិវិធីសម្រាប់ឱ្យឃុំទទួលបានជំនាញបច្ចេកទេសអំពីការ ប្រែប្រួលអាកាសធាតុ ពីការិយាល័យ ឬមន្ទីរនានានៅថ្នាក់ស្រុក ឬថ្នាក់ខេត្ត។

**ការកសាងផែនការសកម្មភាព**

ក្រសួងពាក់ព័ន្ធទាំងអស់ ត្រូវបង្កើតផែនការសកម្មភាពអាទិភាពរបស់ខ្លួន ដោយមានកំណត់ថ្លៃចំណាយសម្រាប់អនុវត្ត **ផ.យ.ប.អ.** តាមវិស័យ ក្រោមជំនួយបច្ចេកទេស និងហិរញ្ញវត្ថុពីលេខាធិការដ្ឋាន

នៃ**គ.ជ.គ.ប.អ.**។ ផែនការសកម្មភាពទាំងនេះ នឹងត្រូវបន្សាគ្នាយ៉ាងជិតស្និទ្ធជាមួយយុទ្ធសាស្ត្ររបស់វិស័យពាក់ព័ន្ធ ត្រូវកសាង ផែនការសកម្មភាពជាក់លាក់មួយផងដែរ សម្រាប់មុខងារសម្របសម្រួល ដែលរួមទាំងតួនាទីរបស់គណៈកម្មាធិការ ជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុ ក្រុមបច្ចេកទេសការងារប្រែប្រួលអាកាសធាតុ និងលេខាធិការដ្ឋាន នៃ **គ.ជ.គ.ប.អ.** គោលការណ៍នាំមុខសម្រាប់ការកសាងផែនការសកម្មភាពទាំងនេះមានចែងនៅក្នុងផ្នែក ៦.២ ខាងក្រោម។

## ៧. ការឆ្លើយតបជាស្ថាប័នចំពោះការបន្សុំទៅនឹងការប្រែប្រួលអាកាសធាតុ

យុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្ររបស់កម្ពុជា បានកំណត់យ៉ាងច្បាស់ថា គ្រោះ មហន្តរាយធម្មជាតិ មានជាអាទិ៍ គ្រោះទឹកជំនន់ និងគ្រោះរាំងស្ងួតជាកត្តាយ៉ាង សំខាន់ដែលបាន និងបន្តធ្វើឱ្យមានកំណើនភាពងាយរងគ្រោះ ផ្នែកសេដ្ឋកិច្ចន ប្រជាជនក្រីក្រនៅទីជនបទ ក្នុងនោះរួមមានទាំងការដាក់បន្ទុកបកបដោយ វិសមភាពសម្រាប់ការដោះស្រាយចំពោះស្ត្រី។ តាមទស្សនៈនេះ ការប្រែប្រួលអាកា សធាតុមិនមែនត្រឹមតែជាបញ្ហាទាក់ទងនឹងបរិស្ថានតែប៉ុណ្ណោះទេ ប៉ុន្តែវាក៏ជា បញ្ហានៃការអភិវឌ្ឍផងដែរ។ នៅក្នុងបរិបទនេះ យន្តការមួយចំនួននៃកិច្ចសហការ និងការសំរបសំរួលត្រូវបានដាក់ឱ្យអនុវត្តដើម្បីសំរបសំរួលនូវការដាក់បញ្ចូល គ្នានៃកិច្ចខិតខំប្រឹងប្រែង ដើម្បីធ្វើឱ្យមានការយល់ដឹងកាន់តែប្រសើរអំពីផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុ និងការឆ្លើយតបចំពោះបញ្ហានេះឱ្យបានសម ស្របពីគ្រប់វិស័យទាំងអស់របស់សង្គម។ នៅក្នុងផ្នែកនេះ មានការបង្ហាញនូវ ស្ថាប័នរដ្ឋាភិបាលសំខាន់ៗ ដែលបានរួមចំណែកក្នុងដំណើរការនេះ។

### ៧.១ ស្ថាប័នសំរបសំរួលថ្នាក់ជាតិសំខាន់ៗដែលពាក់ព័ន្ធក្នុងការបន្សុំទៅនឹងការប្រែប្រួលអាកាសធាតុ

#### ៧.១.១ គណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុ

គណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុ (NCCC) ត្រូវបានបង្កើត ឡើងដោយអនុក្រឹត្យតែងតាំង នៅថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០០៦។ គណៈ កម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុ ជាយន្តការអន្តរក្រសួងមួយ ដែលទទួលបានអាណត្តិពីរាជរដ្ឋាភិបាល ដើម្បីរៀបចំសំរបសំរួល និងត្រួតពិនិត្យមើលលើការអនុវត្ត គោលនយោបាយ យុទ្ធសាស្ត្រ ឯកសារផ្លូវច្បាប់ ផែនការ និងកម្មវិធីនានារបស់រាជរដ្ឋាភិបាល ដើម្បីដោះស្រាយបញ្ហានានា ទាក់ទងនឹងការប្រែប្រួលអាកាសធាតុនៅក្នុងប្រទេស ដែលវាជាការរួមិភាគទាន យ៉ាងសំខាន់ចំពោះការការពារបរិស្ថាននិងធនធានធម្មជាតិ និងការប្រមើលមើល និងទប់ស្កាត់ការផ្លាស់ប្តូរធាតុអាកាសដែលបង្កឡើងដោយមនុស្សដែលអាចនាំ បណ្តាលឱ្យមាននូវផលប៉ះពាល់អាក្រក់ទៅលើសុខុមាលភាពរបស់មនុស្ស។ គណៈ កម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុជាគណៈកម្មាធិការអន្តរក្រសួង ស្ថិតក្រោមអធិបតេយ្យភាពដ៏ខ្ពង់ខ្ពស់របស់សម្តេច ហ៊ុន សែន រួមជាមួយរដ្ឋ

លេខាធិការ និងអនុរដ្ឋលេខាធិការមកពី ១៩ក្រសួង និងភ្នាក់ងាររដ្ឋាភិបាលផ្សេងទៀត (Mony, Ki, and C, Thou, 2007)។ សូមមើលគំនូសបង្ហាញ អំពីទំនាក់ ទំនងអង្គការលេខរបស់ គណៈកម្មាធិការគ្រប់គ្រងការប្រែប្រួលអាកាសធាតុ។

## ៧.២ ក្រុមបណ្តាល និងអង្គការមិនមែនរដ្ឋាភិបាលដែលរួមចំណែកក្នុងការបន្សាំទៅនឹងការ ប្រែប្រួលអាកាសធាតុ

### ៧.២.១ ក្រុមជំនាញសម្រាប់ប្រទេសមានការលូតលាស់តិច

ក្រុមជំនាញសម្រាប់ប្រទេសមានការលូតលាស់តិច (LEG) ដែលបានបង្កើតឡើងដោយ សេចក្តីសម្រេចចិត្តលេខ : 29/CP នៅឆ្នាំ ២០០១ ត្រូវបានប្រគល់អាណត្តិក្នុង លក្ខខណ្ឌយោងរបស់ខ្លួនដើម្បីសំរបសំរួលការផ្លាស់ប្តូរព័តមាន និងការលើកកម្ពស់ការ ប្រមូលផ្តុំគំនិតជាមួយស្ថាប័នបរិស្ថានពហុភាគីផ្សេងៗទៀត។ ក្រុមនេះក៏មានតួនាទី សំខាន់ក្នុងការរៀបចំនូវកម្មវិធីសកម្មភាពជាតិដើម្បីបន្សាំទៅនឹងការប្រែប្រួលអាស ធាតុផង និងធ្វើជាក្រុមបង្កាលចូលរួមក្នុងការអនុវត្តផង (Danida, 2008)។

### ៧.២.២ ក្រុមការងារអន្តរជាតិស្តីពីការប្រែប្រួលអាកាសធាតុ (IPCC) អង្គការឧតុនិយមពិភពលោក (WMO) និងកម្មវិធី បរិស្ថានសហប្រជាជាតិ (UNEP)

ផ្នែកមួយនៃកិច្ចខិតខំ ប្រឹងប្រែងរួមគ្នា ក្រោមគំនិតផ្តួចផ្តើមធ្វើការបាន់ប្រមាណផលប៉ះពាល់ និងការបន្សាំ ទៅនឹងការប្រែប្រួលអាកាសធាតុ ក្រុមការងារអន្តរជាតិស្តីពីការប្រែប្រួលអាកាសធាតុ អង្គការឧតុនិយមពិភពលោក និងកម្មវិធីបរិស្ថានសហប្រជាជាតិ បានប្រតិបត្តិរួមគ្នា នូវភារកិច្ចទាំងឡាយខាងក្រោមនេះ ៖

## ៧.៣ ក្រសួងបណ្តាល និងរដ្ឋបាលពាក់ព័ន្ធផ្សេងៗទៀត

### ៧.៣.១ ការិយាល័យប្រែប្រួលអាកាសធាតុ កម្ពុជា

នៅខែមិថុនា ឆ្នាំ ២០០៣ រាជរដ្ឋាភិបាលកម្ពុជា បានបង្កើតការិយាល័យប្រែប្រួលអាកាសធាតុ (ccco) ដែលសព្វថ្ងៃបានក្លាយទៅជា នាយកដ្ឋានប្រែប្រួលអាកាស ធាតុ (CCD) ជានាយកដ្ឋានដែលទទួលបន្ទុកទាំងស្រុងចំពោះបញ្ហានៃការប្រែប្រួល អាកាសធាតុ។ សមាសភាពផ្នែកបច្ចេកទេសនៃនាយដ្ឋាននេះ ស្ថិតនៅក្នុងក្រសួង បរិស្ថាន ហើយអ្នកបច្ចេកទេសទាំងនេះទទួលបានអាណត្តិជាមួយនឹងការកិច្ចអនុវត្ត សកម្មភាពបច្ចេកទេសទាំងអស់ទាក់ទងដល់ការអនុវត្តឱ្យស្របតាមអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ(UNFCCC) និងសកម្មភាពទាំងឡាយ ដែលទាក់ទងទៅនឹងអនុសញ្ញាអន្តរជាតិស្តីពីបរិស្ថាន។ នាយកដ្ឋានប្រែប្រួលអាកាសធាតុគាំទ្រ និងរៀបចំក្រុមការងារបច្ចេកទេសអន្តរក្រសួងដែលមានឯកទេសលើវិស័យផ្សេងៗ ដូចជា ថាមពល និងព្រៃឈើ និងវិស័យទាំងឡាយណាក្រោមការប្រែប្រួលអាកាសធាតុ ដូចជា ការធ្វើសារពើភ័ណ្ឌឧស្ម័នផ្ទះកញ្ចក់ (GHG) ការសំរាល ការបំភាយឧស្ម័ន

ការសំរាលដោយស្ម័គ្រចិត្ត និងការបន្សាំ យន្តការអភិវឌ្ឍន៍ស្អាត (CDM) និងការអនុវត្តនូវអនុសញ្ញាក្របខណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ (UNFCCC)។

### ៧.៣.២ គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ

គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ (NCDM) ជាភ្នាក់ងារថ្នាក់ជាតិ ទទួលខុសត្រូវផ្តល់នូវការសង្គ្រោះបន្ទាន់ និងបង្កើតវិធានការបង្ការដើម្បីកាត់ បន្ថយការបាត់បង់អាយុជីវិត និងទ្រព្យសម្បត្តិបណ្តាលមកពីគ្រោះមហន្តរាយធម្មជាតិ - គណៈកម្មាធិការគ្រប់គ្រង់គ្រោះមហន្តរាយត្រូវបានបង្កើតឡើងនៅឆ្នាំ ១៩៩៥ ក្នុងនាមជា ស្ថាប័នអន្តរក្រសួងមួយ ដែលមានសមាសភាពសមាជិក មកពីក្រសួងពាក់ព័ន្ធ និងមកពីកងកម្លាំងប្រដាប់អាវុធ។ ជាបន្តបន្ទាប់មកទៀត គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយត្រូវបានបង្កើតឡើងនៅថ្នាក់ខេត្ត និង ស្រុកនៅទូទាំងប្រទេស។ នៅឆ្នាំ ២០០៦ រាជរដ្ឋាភិបាលកម្ពុជាបានចេញនូវ អនុក្រិត្យមួយដើម្បីបង្កើត គណៈកម្មការ ឃុំ គ្រប់គ្រងគ្រោះមហន្ត (CCDM) ក្នុង គោលបំណងដើម្បីពង្រឹងប្រព័ន្ធស្ថាប័ននៅថ្នាក់មូលដ្ឋាន។

### ៧.៣.៣ អាជ្ញាធរជាតិទទួលបន្ទុកយន្តការអភិវឌ្ឍន៍ស្អាត

រាជរដ្ឋាភិបាលកម្ពុជាបានតែងតាំងក្រសួងបរិស្ថាន អាជ្ញាធរជាតិទទួលបន្ទុក យន្តការអភិវឌ្ឍន៍ស្អាតនៅថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៣។ នាយកដ្ឋានប្រែប្រួល អាកាសធាតុដើរតួនាទីជាលេខាធិការដ្ឋាននៃជនបង្គោលរបស់អនុសញ្ញាក្រប ខណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ និងជាអាជ្ញាធរជាតិទទួលបន្ទុកការអនុវត្តតាមពិធីសារកេ្យុងក្យូតូ។ មានការត្រួតស៊ីគ្នាផ្នែកស្ថាប័នរវាងស្ថាប័នថ្នាក់ក្រសួងសំខាន់ៗ ដែលរួមចំណែកដល់ការបន្សាំទៅនឹងការអាកាសធាតុ (NCCC) និងគណកម្មការធិការសហប្រតិបត្តិការដើម្បីកម្ពុជា (CCC)។

## ៧.៤ ស្ថាប័នថ្នាក់ក្រសួងសំខាន់ៗដែលចូលរួមចំណែកដល់ការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ

### ៧.៤.១ ក្រសួងធនធានទឹក និងឧតុនិយម

ក្រសួងធនធានទឹក និងឧតុនិយម ដើរតួនាទីកណ្តាលក្នុងការសំរាលផលប៉ះពាល់ បណ្តាលមកពីមហន្តរាយធម្មជាតិ ដូចជាទឹកជំនន់ និងគ្រោះរាំងស្ងួត តាមរយៈការអនុវត្តនូវវិធានការបន្សាំទាក់ទងនឹងការគ្រប់គ្រងទឹកជំនន់រយៈពេលវែង។

### ៧.៤.២ នាយកដ្ឋានឧតុនិយម នៃក្រសួងធនធានទឹក និងឧតុនិយម

នាយកដ្ឋានឧតុនិយម ស្ថិតនៅក្រសួងធនធានទឹក និងឧតុនិយម ជានាយកដ្ឋានបង្គោលមួយ សម្រាប់ផ្តល់នូវការព្យាករណ៍ និងព័ត៌មានអំពីធាតុអាកាស និងអាកាសធាតុ ដល់រាជរដ្ឋាភិបាលកម្ពុជា និង សាធារណជនទូទៅអំពីស្ថានភាព ធាតុអាកាស និងអាកាសធាតុ (Danida, 2008)។

### ៧.៤.៣ ក្រសួងបរិស្ថាន

ក្រៅពីការបង្កើតផែនការសកម្មភាពអំពីការប្រែប្រួលអាកាសធាតុនិងផែនការ យុទ្ធសាស្ត្រអំពីប្រព័ន្ធជីវសាស្ត្រចំរុះ (NBSAP) ការផ្សាភ្ជាប់ណាមួយទៅនឹងការ បន្សុាំចំពោះការប្រែប្រួលអាកាសធាតុនៅតំបន់ឆ្នេរតាមរយៈគោលនយោបាយ និងនីតិវិធីនានារបស់រដ្ឋាភិបាលឃើញនៅទន់ខ្សោយនៅឡើយ។ ក្នុងផែនការ សកម្មភាព អំពីការប្រែប្រួលអាកាសធាតុ និងកម្មវិធីសកម្មភាពជាតិដើម្បីបន្សុាំទៅ នឹងការប្រែប្រួលអាកាសធាតុ (NAPA) បានផ្តល់អនុសាសន៍សម្រាប់សកម្មភាពទាំង ឡាយដែលមានកម្រិតព្រំដែនមួយដែលសកម្មភាពភាគច្រើនសង្កត់ធ្ងន់លើ ការស្រាវជ្រាវ ដើម្បីប៉ាន់ប្រមាណផលប៉ះពាល់ដ៏មានសក្តានុពល និងវិធានការ ឆ្លើយតបដែលអាចមានចំពោះការកើនឡើងនូវកម្រិតនីវ៉ូទឹកសមុទ្រ (MoE, 2005) សូមមើលបន្ថែមនៅបអប់ខាងក្រោម អំពីអាណត្តិរបស់ក្រសួងបរិស្ថាន។

### ៧.៤.៤ ក្រសួងសុខាភិបាល

ក្រសួងសុខាភិបាល ដោយអនុវត្តតាមផែនការយុទ្ធសាស្ត្រជាតិវិស័យសុខាភិបាល ដំណាក់កាលទី ២ ឆ្នាំ ២០០៨-២០១៥ បានដើរតួនាទីឆ្លងកាត់វិស័យមួយក្នុងការ បន្សុាំទៅនឹងការប្រែប្រួលអាកាសធាតុ—ពេលគឺផ្តោតការយកចិត្តទុកដាក់ចំពោះ យេនឌ័រ និងសុខភាពរបស់ជនងាយរងគ្រោះបឋមជនមានតំណាង អ្វីដែលជាអាណត្តិជាស្នូលនៃក្រសួងសុខាភិបាលគឺពង្រឹងការធ្វើ អន្តរាគមន៍សុខាភិបាលដល់សាធារណជន និងការលើកស្ទួយប្រសិទ្ធិភាព នៃការកសាងភាពជាដៃគូជាមួយ សាធារណជន និងផ្នែកឯកជន ក្នុងការផ្តល់សេវាដល់ជនក្រីក្រ និងក្រុមជនងាយរងគ្រោះលើវិស័យអនាម័យផ្ទាល់ខ្លួន និង សាធារណៈសុខភាពតាមសាលាហានិយភ័យ បរិស្ថាន សុខភាព និង ការបន្ថយមហន្តរាយផ្នែក បរិស្ថាន និងផលប៉ះពាល់ផ្នែកសុខភាពពីជម្ងឺផ្សេងៗ (MoH, 2008)។

### ៧.៤.៥ ក្រសួងផែនការ

ក្រសួងផែនការដើរតួនាទីជាគន្លឹះក្នុងការបន្សុាំទៅនឹងការប្រែប្រួលអាកាសធាតុ ដោយអនុលោមតាមលំនាំនៃការការអភិវឌ្ឍផែនការយុទ្ធសាស្ត្រជាតិកាត់បន្ថយ ភាពក្រីក្របច្ចុប្បន្នកម្ម ២០០៩-២០១៣ (Chhieng Yanara, H. E., 2009), មើលប្រអប់ ២ តួនាទី និងការទទួលខុសត្រូវរបស់ក្រសួងផែនការទាក់ទងនឹង ការប្រែប្រួលអាកាសធាតុ។

ប្រអប់ ២- ក្រសួងផែនការ -តួនាទី និងការទទួលខុសត្រូវក្នុងសកម្មភាពទាក់ទងដល់ការបន្ស៊ាំទៅនឹងការប្រែប្រួលអាកាសធាតុ

- ផ្តល់ការណែនាំផ្នែកបច្ចេកទេសដល់ក្រសួងពាក់ព័ន្ធ និងភ្នាក់ងារនានា អំពីការអភិវឌ្ឍនូវខ្លឹមសារនិងដំណើរការជារួមសម្រាប់ការស្ថាបនាផែនការយុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្របច្ចុប្បន្នកម្ម២០០៩-២០១៣
- ផ្តល់នូវក្របខណ្ឌថ្នាក់ជាតិសម្រាប់ការដាក់បញ្ចូល កម្មវិធីសកម្មភាពជាតិដើម្បីបន្ស៊ាំទៅនឹងការប្រែប្រួល អាកាសធាតុ និងការដោះស្រាយការប្រែប្រួលអាកាសធាតុនៅគ្រប់វិស័យទាំងអស់។
- ធានាថា ការដាក់ស្នើគំនិតយោបល់ពីគ្រប់ក្រសួង និងភ្នាក់ងារពាក់ព័ន្ធទាំងអស់និងធានាថារាល់រចនាសម្ព័ន្ធគ្រប់គ្រង់ ជំនួយទាំងអស់របស់កម្ពុជា គោលការណ៍ និងអាទិភាពទាំងអស់មានភាពសមស្រប និងបានបញ្ចូលក្នុងផែនការ និងបានលើកស្ទួយដល់ការបន្ស៊ាំទៅនឹងការប្រែប្រួលអាកាសធាតុ និង
- អភិវឌ្ឍ និងពិនិត្យឡើងវិញចំពោះឯកសារពង្រឹងផ្នែកលើមកំយោបល់ សំណើ និងអនុសាសន៍ទាំងឡាយដែលទទួល បានពីគ្រប់អ្នកពាក់ព័ន្ធទាំងអស់ នៅដំណាក់កាលនីមួយៗនៃការអភិវឌ្ឍផែនការរបស់ខ្លួន ដែលរួមមានទាំងបាន

### ៧.៤.៦ ក្រសួងបង្គោល និងរដ្ឋបាលពាក់ព័ន្ធផ្សេងៗ

ប្រព័ន្ធអេកូឡូស៊ី និងផលផលតំបន់ឆ្នេរៈ ភ្នាក់ងារសំខាន់ៗដែលរួមចំណែកក្នុងការអភិវឌ្ឍ និងគ្រប់គ្រង់តំបន់ឆ្នេរ រួមមាន ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងឧស្សាហកម្ម និងថាមពល ក្រសួងសាធារណការ និងដឹកជញ្ជូន ក្រសួងអភិវឌ្ឍន៍ជនបទ និងក្រសួងបរិស្ថាន។ ដើម្បីដោះស្រាយបញ្ហាដែលមាននៅគ្រប់វិស័យ។ រដ្ឋាភិបាលបានបង្កើតគណៈកម្មាធិការជាតិទទួលបន្ទុកតំបន់ឆ្នេរ (NCSC)។ គណៈកម្មាធិការជាតិទទួលបន្ទុកតំបន់ឆ្នេរ ទទួលខុសត្រូវក្នុងការ បង្កើតទិសដៅរួម លើរាល់គម្រោងតំបន់ឆ្នេរ និងសកម្មភាព ទាំងឡាយទាក់ទងដល់ធនធានធម្មជាតិ ស្របតាមគោលនយោបាយជាតិបច្ចុប្បន្នរួម ជាមួយបណ្តាក្រសួងទាំងឡាយដែលលើកឡើងខាងលើ។

- ដាក់បញ្ចូលគ្នានូវការប៉ាន់ប្រមាណផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុ ការបន្ស៊ាំទៅនឹងការប្រែប្រួលអាកាសធាតុ និងភាពងាយរងគ្រោះនៅតំបន់ទីជំរាល និងសហគមន៍ទាំងឡាយនៅភូមិភាគអាស៊ីអាគ្នេយ៍ (Philippines, Indonesia, Laos, Cambodia and Vietnam);
- ប៉ាន់ប្រមាណភាពងាយរងគ្រោះកម្រិតតំបន់ ពីការប្រែប្រួលនធនធានទឹក និងព្រឹត្តិការណ៍ជលសាស្ត្រអាក្រក់ៗ បណ្តាលមកពីការប្រែប្រួលអាកាសធាតុ (Cambodia, Vietnam, Laos and Thailand) (AIACC, 2007)។

### កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ

ចំពោះការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ មានភារកិច្ចផ្តោតសំខាន់លើ ការកសាងសមត្ថភាពអាជ្ញាធរជាតិនិងអាជ្ញាធរមូលដ្ឋាន អង្គការសង្គមស៊ីវិល និងផ្នែកឯកជន ដើម្បីលើកកម្ពស់នូវការបន្សាំ និងសំរាលផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុ។

### ធនាគារពិភពលោក - មូលនិធិសាកលសម្រាប់កាត់បន្ថយគ្រោះមហន្តរាយ

ធនាគារពិភពលោក-មូលនិធិសាកល សម្រាប់កាត់បន្ថយគ្រោះមហន្តរាយមានការចូលរួមយ៉ាងសកម្មក្នុងការផ្តល់នូវកញ្ចប់ថវិកាសម្រាប់ទីប្រឹក្សាបច្ចេកទេស ដើម្បីជានាឱ្យ មានការសំរបសំរួល និងអនុវត្តឱ្យកាន់តែប្រសើរនូវផែនការយុទ្ធសាស្រ្តជាតិ–កាត់បន្ថយគ្រោះមហន្តរាយ និងការដាក់បញ្ចូលនូវការកាត់បន្ថយគ្រោះមហន្តរាយទៅក្នុងផែនការអភិវឌ្ឍន៍ជាតិ រួមទាំងការបង្កើតនូវគោលការណ៍ណែនាំសម្រាប់ការដាក់ បញ្ចូលនូវ ការកាត់បន្ថយគ្រោះមហន្តរាយ ទៅក្នុងការកសាងផែនការអភិវឌ្ឍន៍ថ្នាក់ មូលដ្ឋាន ។ និង ការផ្តួចផ្តើមបញ្ចូលការកាត់បន្ថយគ្រោះមហន្តរាយទៅក្នុងគោលនយោបាយ និងកម្មវិធីទាំងឡាយរបស់ក្រសួងពាក់ព័ន្ធ។

### ជំនួយអភិវឌ្ឍន៍អន្តរជាតិប្រទេសដានីម៉ាក (DANIDA)

DANIDA កំពុងរួមវិភាគទានជាច្រើនចំពោះការអភិវឌ្ឍសង្គមប្រជាធិបតយ្យនៅថ្នាក់ក្រោមជាតិតាមរយៈការគាំទ្រដល់ការបន្ថយភាពងាយរងគ្រោះ និងភាពក្រីក្រនៅទី ជនបទក្រីក្រ ដោយផ្តល់ជំនួយទៅដល់រាជរដ្ឋាភិបាលក្នុង អនុវិស័យចំនួន ដែលទាក់ទងទៅនឹងការគ្រប់គ្រងធនធានធម្មជាតិ និងការចិញ្ចឹមជីវិត ការគ្រប់គ្រងដីធ្លី បរិស្ថាន វិស័យព្រៃឈើ និងជលផល។

### សហព័ន្ធអន្តរជាតិកាកបាទក្រហម និងសង្គមអឌ្ឍចន្ទក្រហមអន្តរជាតិ

តួនាទីរបស់សហព័ន្ធអន្តរជាតិកាកបាទក្រហម និងសង្គមអឌ្ឍចន្ទក្រហមអន្តរជាតិ (IFRC-RCS) ទាក់ទងនឹងការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ មានជាចំបង លើការសំរបសំរួល និងសហការលើការងារខាងក្រោមៈ

- កសាងសមត្ថភាព ជាពិសេសដល់មន្រ្តីរាជការនៅថ្នាក់ខេត្ត ស្រុក ឃុំ និងថ្នាក់ ភូមិ បុគ្គលិកអង្គការអន្តរជាតិ និងអង្គការមិនមែនរដ្ឋាភិបាល។
- ផ្តល់ជំនួយសង្គ្រោះបន្ទាន់ ការគៀងគរធនធាន និងចែកចាយសម្ភារៈសង្គ្រោះដល់ អ្នករងគ្រោះដោយធ្វើការងារជាមួយបណ្តាក្រសួង អាជ្ញាធរ សហព័ន្ធអន្តរជាតិ កាកបាទក្រហម ក្រុមការងារគ្រប់គ្រងគ្រោះមហន្តរាយសហប្រជាជាតិ ការិយាល័យទទួលបន្ទុកសំរបសំរួលកិច្ចការមនុស្សធម៌ (OCHA) និងអង្គការ អន្តរជាតិ និងអង្គការមិនមែនរដ្ឋាភិបាលខ្លះ និង

– កសាងសមត្ថភាពអំពីការគ្រប់គ្រងគ្រោះមហន្តរាយថ្នាក់មូលដ្ឋាន។

### ភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិប្រទេសស៊ុយអែដ (SIDA)

កិច្ចសហការរបស់ (SIDA) ផ្តោតសំខាន់លើការគាំទ្រការធ្វើកំណែទម្រង់វិមជ្ឈការ និងប្រជាធិបតេយ្យនីយកម្ម និងសិទ្ធិមនុស្ស តាមការផ្តល់នូវការគាំទ្រដល់ការ អភិវឌ្ឍ សង្គមស៊ីវិល និងការអប់រំ។ ការគាំទ្រកម្មវិធីបរិស្ថាន និងកម្មវិធីទាក់ទង នឹងអាកាស ធាតុជាតិ ផ្តោតសំខាន់ និងមានការផ្សាភ្ជាប់ទៅនឹងវិធានការទាំងឡាយថ្នាក់តំបន់ ដើម្បីធ្វើឱ្យគោលគំនិតទាំងឡាយអាចសម្រេចជោគជ័យទាំងគោលគំនិតថ្នាក់តំបន់ និងទ្វេភាគី។ អ្វីដែលគួរឱ្យកត់ សំគាល់គឺថា តាមរយៈការគាំទ្រដល់ អភិបាលកិច្ចបែបប្រជាធិបតេយ្យ (SIDA) បានផ្តល់ជំនួយដោយផ្ទាល់ដើម្បីបង្កើត និងពង្រឹងស្ថាប័ន និងប្រព័ន្ធដែលសំរួលឱ្យមាននូវសមមាត្រមួយចំណែកធំនៃការបងចកថវិកាជាតិ ដល់ថ្នាក់មូលដ្ឋាន និងការប្រើប្រាស់ថវិកាទាំងនោះសម្រាប់ការអភិវឌ្ឍនៅសហគមន៍ មូលដ្ឋាន ដូចជា លើប្រសិទ្ធិភាពវិស័យ កសិកម្ម ការប្រើប្រាស់ដីធ្លី និងការបន្សុំាទៅនឹងការប្រែប្រួលអាកាសធាតុ (Sida, 2008)។

(SIDA)ក៏បានផ្តល់ជំនួយដល់គម្រោងសាកល្បងរួមគ្នាមួយអំពីការប្រែប្រួលអាកាសធាតុ (CCP) ដែលមានទិសដៅជួយដល់អង្គការមិនមែនរដ្ឋាភិបាលដាក់បញ្ចូល គម្រោងបន្សុំាទៅនឹងការប្រែប្រួលអាកាសធាតុ។ វាជាកិច្ចខិតខំប្រឹងប្រែងកសាងសមត្ថភាពដ៏ ធំធេងដែលឥឡូវកំពុងចេញដំណើរឆ្ពោះទៅបង្កើតនូវការផ្តួចផ្តើមគំនិតស្រាវជ្រាវធ្វើ សកម្មភាពអំពីការប្រែប្រួលអាកាសធាតុថ្នាក់មូលដ្ឋានចំនួន ១០ នៅកម្ពុជា។

### ផែនការសកម្មភាពយុទ្ធសាស្ត្រគាំទ្រដល់ការបន្សុំាទៅនឹងការប្រែប្រួលអាកាសធាតុ ផែនការយុទ្ធសាស្ត្រសកម្មភាពជាតិ ២០០៨-២០១៣ សម្រាប់ការកាត់បន្ថយគ្រោះមហន្តរាយ (SNAP-DRR)

ប្រទេសកម្ពុជាបានដាក់ឱ្យអនុវត្តនូវ ផែនការយុទ្ធសាស្តសកម្មភាពជាតិ ២០០៨-២០១៣ សម្រាប់កាត់បន្ថយគ្រោះមហន្តរាយ (SNAP-DRR) របស់ខ្លួននៅឆ្នាំ ២០០៩ ផែនការនេះ មានរួមបញ្ចូលនូវសមាសធាតុ នៃការកាត់បន្ថយ គ្រោះមហន្តរាយទៅក្នុងគោលនយោបាយ តាមវិស័យ និងក្នុងផែនការវិនិយោគ។ សកម្មភាព ជាអាទិភាពគឺការប្រើប្រាស់នូវ "វិធីសាស្ត្រម៉ាទ្រិច" មួយដែលមានបញ្ចូលនូវសមាសធាតុកាត់បន្ថយគ្រោះមហន្តរាយទៅក្នុងការងាររបស់ក្រសួងសំខាន់ៗ (ដូចជា ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្រសួងធនធានទឹក និងឧតុនិយម ក្រសួងកសិកម្មរុក្ខាប្រមាញ់និងនេសាទ ក្រសួងអភិវឌ្ឍន៍ជនបទ និងក្រសួងសុខាភិបាល)។ (Rinbo, E., 2009) លក្ខណៈសំខាន់ៗនៃSNAP-DRR (Danida, 2008)។

### អង្គការ GROUPE ENERGIES RENOUVELABLES, ENVIRONEMENTET SOLIDARITÉS (GERES) CAMBODIA

GERES Cambodia, ជាអង្គការមិនមែនរដ្ឋាភិបាលមួយដែលផ្តោតការងារជាចំបងលើ ការអភិវឌ្ឍ និងការប្រែប្រួលអាកាសធាតុ ជាអង្គការមិនមែនរដ្ឋាភិបាលមិនរកកំរៃ របស់ប្រទេសបារាំង បង្កើតឡើងនៅឆ្នាំ ១៩៧៦ ក្រោយព្រឹត្តិការណ៍កលយុគ លើកដំបូង - សព្វថ្ងៃនេះអង្គការ GERES កម្ពុជា មានការជាប់ទាក់ទីនជាពិសេស លើការអនុវត្តនូវដំណោះស្រាយផ្នែកវិស្វកម្មសម្រាប់ការអភិវឌ្ឍ និងផ្តល់នូវអ្នកជំនាញ ឯកទេសជាក់លាកសម្រាប់ការអភិរក្សបរិស្ថាន ការសំរាលនិងបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ កាត់បន្ថយការប្រើប្រាស់ថាមពល និងការលើកស្ទួយការ ចិញ្ចឹមជីវិតរបស់ជនក្រីក្រ។

### អង្គការ PLAN - កម្ពុជា

អង្គការ PLAN កម្ពុជាកំពុងអនុវត្តគម្រោង "ការកាត់បន្ថយភាពក្រីក្រដែលមានបញ្ហាក់ ពីទំនោរបរិស្ថានរាំងស្ងួត (PROVIDE)" ដែលជួយដល់អ្នកភូមិ ដើម្បីបង្កើននូវផលិត ផលស្រូវរបស់គេ នៅតំបន់ដែលមានទំនោរចំពោះភាពរាំងស្ងួត។ ពួកគេធ្វើការសាក ពិសោធន៍លើពូជស្រូវដែលមានភាពធន់ទៅនឹងអាកាសធាតុស្ងួតហួតហែងដោយធ្វើ ជាដៃគូជាមួយវិទ្យាស្ថានស្រាវជ្រាវដំណាំស្រូវអន្តរជាតិ និងវិទ្យាស្ថានស្រាវជ្រាវ កសិកម្ម និងអភិវឌ្ឍកម្ពុជា។

### អង្គការអុកស្វាមសហរដ្ឋអាមេរិក Oxfarm

គម្រោងទាក់ទងនឹងការប្រែប្រួលអាកាសធាតុរបស់ អង្គការ អុកស្វាមសហរដ្ឋអាមេរិក ផ្តោតសំខាន់លើការលើកកម្ពស់ការយល់ដឹងដល់សាធារណៈជនអំពីការបប្រួលអាកាសធាតុ ការព្យាករធាតុអាកាសទាក់ទងនឹងវិស័យកសិកម្ម ដើម្បីផ្តល់ដល់កសិករនូវព័តមានអាកាសធាតុងយប្រើប្រាស់ និងទាន់ពេលវេលា និងការផ្តល់នូវវេទិកា សម្រាប់កិច្ចសន្ទនា ការចង់បណ្តាញ ឧទាហរណ៍ បណ្តាញថ្នាក់ជាតិស្តីពីការប្រែប្រួលអាកាសធាតុ។

### កម្មវិធីសកម្មភាពជាតិដើម្បីបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ

កម្មវិធីសកម្មភាពជាតិ ដើម្បីបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ (NAPA) សម្រាប់ប្រទេសកម្ពុជា មានមូលដ្ឋានលើសេចក្តីសម្រេចចិត្តលេខ ២៨ ក្នុងសន្និសីទបណ្ត ភាគី (CoP) លើកទី ៧ នៃក្របខ័ណ្ឌអនុសញ្ញាសហប្រជាជាតិស្តីពី ការប្រែប្រួលអាកាសធាតុ ការបង្កើតនូវកម្មវិធីសកម្មភាពជាតិ ដើម្បីបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ (NAPA) ធ្វើឡើងតាមដំណើរការមានការចូលរួម ដែលរួមមានអ្នកទាំងឡាយណាដែលមានការប៉ះពាល់ខ្លាំងពីការប្រែប្រួលអាកាសធាតុ មានដូចជា ប្រជាជននៅទីជនបទ និងជនក្រីកជាដើម។

**ផែនការយុទ្ធសាស្ត្រសកម្មភាពជាតិ ២០០៤-២០១៣ ស្តីពីការកាត់បន្ថយគ្រោះមហន្តរាយ**

- រួមចំណែកដល់ការយល់ឃើញស្របគ្នា និងចំណេះដឹងអំពីការកាត់បន្ថយគ្រោះមហន្តរាយ
- ផ្តល់នូវក្របខ័ណ្ឌទូលំទូលាយ ដែលណែនាំ និងត្រួតពិនិត្យ លើការអនុវត្តនូវគម្រោងកាត់បន្ថយគ្រោះមហន្តរាយក្នុងប្រទេស
- បង្កើតឱ្យមាននូវបរិយាកាសល្អសម្រាប់ការបញ្ជ្រាបនូវការកាត់បន្ថយគ្រោះមហន្តរាយ ទៅក្នុងផែនការអភិវឌ្ឍន៍ គោលនយោបាយ និងគម្រោងទាំងឡាយរបស់រាជរដ្ឋាភិបាលកម្ពុជា
- ពង្រឹងការសំរបសំរួល និងកិច្ចសហការរវាងអ្នកពាក់ព័ន្ធទាំងឡាយក្នុងការគ្រប់គ្រងគ្រោះមហន្តរាយ
- កែលំអភាពត្រឹមត្រូវនៃការបែងចែក និងប្រើប្រាស់ធនធានក្នុងការកាត់បន្ថយគ្រោះ មហន្តរាយ
- ចង្អុលទិសដល់អ្នកផ្តល់ជំនួយក្នុងការគាំទ្រដល់ការកាត់បន្ថយគ្រោះ មហន្តរាយដែលកំណត់អាទិភាពនៅ ថ្នាក់ជាតិ Danida, 2008

គោលបំណងសំខាន់របស់ កម្មវិធីសកម្មភាពជាតិដើម្បីបន្សាំទៅនឹងការប្រែប្រួល អាកាសធាតុ (NAPA) មាន៖

- យល់ដឹងអំពីលក្ខណៈចំបងៗ នៃគ្រោះហានិយភ័យផ្នែកអាកាសធាតុនៅកម្ពុជា(ទឹកជំនន់គ្រោះរាំងស្ងួត ខ្យល់ព្យុះ ការជោរនៃទឹកសមុទ្រ ការរាតត្បាតនៃទឹកសមុទ និងជម្ងឺគ្រុនចាញ់)
- យល់ដឹងនូវយន្តការដោះស្រាយចំពោះហានិយភ័យពីអាកាសធាតុ និងការប្រែប្រួលអាកាសធាតុនៅកម្រិតមូលដ្ឋាន
- លើកកម្ពស់ផលិតភាពកសិកម្ម តាមរយៈការពង្រីកប្រព័ន្ធធារាសាស្ត្រ និងការគ្រប់គ្រងធនធានទឹកសំដៅកាត់បន្ថយភាពងាយរងគ្រោះចំពោះមហន្តរាយបណ្តាលពី ធម្មជាតិនិង
- កំណត់ និងចាត់អាទិភាពសកម្មភាពបន្សាំទៅនឹងគ្រោះហានិយភ័យពីអាកាសធាតុ និងផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុ

កម្មវិធីសកម្មភាពជាតិ ដើម្បីបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ (NAPA) របស់ កម្ពុជា ពិតជាបានគាំទ្រយ៉ាងខ្លាំងក្លាចំពោះគោលបំណងអភិវឌ្ឍន៍របស់រាជរដ្ឋាភិបាល ដូចដែលមានចែងក្នុង "យុទ្ធសាស្ត្រចតុកោណសម្រាប់ការអភិវឌ្ឍន៍វិស័យការងារ សមធម៌ និង ប្រសិទ្ធិផល" បានអនុម័តនៅខែកក្កដា ២០០៤ (RGC, ២០០៤) ក៏ដូចជា "ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០០៦-២០១០" ដែលដាក់អោយអនុវត្តនៅខែ ឧសភា ២០០៦។

### យុទ្ធសាស្ត្ររយៈពេលមធ្យមសំរាបវិស័យកសិកម្ម និងធនធានទឹក ២០០៦-២០១០

ផ្អែកតាមផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០០៦-២០១០ ផែនការយុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ ក្របខ័ណ្ឌយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលសម្រាប់កំណែទម្រង់តាមបែបវិមជ្ឈការ និងវិសហមជ្ឈការ និងយុទ្ធសាស្ត្រដែលមានស្រាប់របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនសាទ និងក្រសួងធនធានទឹក និងឧតុនិយម នោះសំណើយុទ្ធសាស្ត្រ រយៈពេលមធ្យមមួយសម្រាប់វិស័យកសិកម្ម និងធនធានទឹក (២០០៦-២០១០) ត្រូវបាន តាក់តែងឡើងរួមគ្នារវាងក្រុមអ្នកផ្តល់ជំនួយ និងសមាជិកក្រុមការងារបច្ចេកទេស កសិកម្ម និងធនធានទឹក (TWG-AW) សំណើរនេះ ត្រូវបានអនុម័ត ដោយរដ្ឋមន្ត្រីនៃក្រសួងទាំងពីរ ពោលគឺក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងធនធានទឹក និងឧតុនិយម នៅថ្ងៃទី ៣០ មិនា ២០០៧ (Veng Sakhon, H. E, 2007) ដើម្បីសម្រេចនូវយុទ្ធសាស្ត្រ រយៈពេលមធ្យមនេះគេបានរៀបចំរួម បញ្ចូលគ្នានូវកម្មវិធីជាចំបងៗចំនួន៥ វិស័យ ១. ការកសាងសមត្ថភាព ស្ថាប័ន ការគ្រប់គ្រង និងការគាំទ្រកម្មវិធីសំរាបវិស័យកសិកម្ម និងធនធានទឹក ២. កម្មវិធី គាំទដលវិស័យសន្តិសុខ សៀង ៣. កម្មវិធីកសិកម្ម និងកសិពាណិជ្ជកម្ម ៤. កម្មវិធី គ្រប់គ្រងធនធានទឹក ជាវាសាស្ត្រ និងដីធ្លី (កម្មវិធីគ្រប់គ្រងកសិកម្ម ធនធានទឹក និងដីធ្លី (Veng Sakhon, H. E., 2007) ។

# មេរៀនទី ៣ ផែនយុទ្ធសាស្ត្រជាតិ និងគោលនយោបាយជាតិពាក់ព័ន្ធផ្សេងៗ

## ១.ដំណើរការរៀបផែនការជាតិបន្សាំការប្រែប្រួលអាកាសធាតុ

### ១.១ ផែនការរដ្ឋាភិបាល និងគោលនយោបាយឆ្លើយតបការប្រែប្រួលអាកាសធាតុ

ផែនទីបង្ហាញផ្លូវផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (២០១៤-២០១៨) សម្រាប់ការអនុវត្តផែនការយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលកម្ពុជាបានប្ដេជ្ញា កាត់បន្ថយផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ តាមរយៈការពង្រឹងសមត្ថភាពបន្សាំនិងភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុ។ នៅក្នុងឆ្នាំ ២០១៤ ផែនការយុទ្ធសាស្ត្រឆ្លើយតបការប្រែប្រួលអាកាសធាតុកម្ពុជា ២០១៤-២០២៣ (ផ.យ.ប.ក.) និងគោលនយោបាយជាតិ អភិវឌ្ឍន៍បៃតងនិងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍បៃតង ២០១៣-២០៣០ ត្រូវបានអនុម័ត

ផ.យ.ប.ក ២០១៤-២០២៣ បានកំណត់ចង្កោមសកម្មភាពដែលត្រូវអនុវត្តន៍ក្នុង ៣ ដំណាក់កាលគឺ

- ២០១៣-២០១៤៖ បានរៀបចំស្ថាប័ន និងហិរញ្ញវត្ថុសម្រាប់អនុវត្តន៍ ផ.យ.ប.ក. រៀបចំ ក្របខ័ណ្ឌតាមដាន និងវាយតម្លៃថ្នាក់ជាតិ និងសូចនាករ និងផែនការសកម្មភាពប្រែប្រួលអាកាសធាតុ (២០១៤-២០១៨) របស់ក្រសួងតាមវិស័យ។
- ២០១៤-២០១៨៖ បន្តគាំទ្រការអនុវត្តសកម្មភាពជំហានទី១ ដោយពង្រីកការអនុវត្តដែលគ្រប-ដណ្តប់ផ្សេងៗទៀត ដូចជាការចុះបញ្ជីដើម្បីទទួលបានសេចក្តីទុកចិត្ត(Accreditation) ពីមូលនិ-ធិបន្សាំ អាកាសធាតុបៃតង និងការគ្រប់គ្រងចំណេះដឹង ការអភិវឌ្ឍសមត្ថភាព ការបញ្ជ្រាបការប្រែប្រួលអាកាសធាតុទៅក្នុងអន្តរវិស័យតាមកម្រិតផ្សេងៗ ប្រតិបត្តិការការតាមដាន និងវាយតម្លៃប្រព័ន្ធគ្រប់គ្រងទិន្នន័យ និងផ្សព្វផ្សាយកម្មវិធី/គម្រោងអាទិភាពមួយចំនួន នៅក្នុងវិស័យ ដែលបានរៀបចំផែនការសកម្មភាពប្រែប្រួលអាកាសធាតុ(CCAPs)។ អាទិភាពដំបូងគួរផ្តោតសំខាន់លើសកម្មភាពបន្សាំ ប៉ុន្តែសកម្មភាពកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់នឹងត្រូវដាក់បញ្ចូលផងដែរ។
- ២០១៩-២០២៣៖ ផ្តោតទៅលើការសិក្សាស្រាវជ្រាវ និងរៀនសូត្រ ប៉ុន្តែគោលបំណងចម្បង នឹងផ្តោតលើការពង្រីកករណីដែលជោគជ័យ និងបន្តបញ្ជ្រាបការប្រែប្រួលអាកាសធាតុទៅក្នុង ផែនការជាតិ និងថ្នាក់ក្រោមជាតិ។ ការងារនេះនឹងពាក់ព័ន្ធដល់ការបង្កើននូវការប្រើប្រាស់ថវិកា គាំទ្រដល់កម្មវិធីថ្នាក់ជាតិ។

គោលនយោបាយជាតិអភិវឌ្ឍន៍បៃតង និងផែនការយុទ្ធសាស្ត្រជាតិអភិវឌ្ឍន៍បៃតង (២០១៣-២០២០) ឯកសារទាំងពីរនេះត្រូវបានអនុម័តនៅក្នុងខែមីនា ឆ្នាំ២០១៣។ គោលបំណងនោះគឺអភិវឌ្ឍន៍កំណើនសេដ្ឋកិច្ចបៃតងដោយប្រើប្រាស់ធនធានជាតិដោយមានប្រសិទ្ធភាព និរន្តរភាពបរិស្ថាន ការងារ

បៃតង បច្ចេកវិទ្យាបៃតង ហិរញ្ញវត្ថុបៃតង ឥណទានបៃតង និងការវិនិយោគបៃតង។ ទំហំការងារមានភាពទូលំទូលាយជាង ប៉ុន្តែមានការត្រួតគ្នាជាមួយការប្រែប្រួលអាកាសធាតុ និងគោលនយោបាយបរិស្ថាននានា។ នៅក្នុងឆ្នាំ២០០៦ កម្ពុជាបានអនុម័តកម្មវិធី NAPA ដែលឥឡូវនេះអស់សុពលភាព និងមានការពាក់ព័ន្ធតិចតួចណាស់។

ក្នុងឆ្នាំ២០១៥ កម្ពុជាបានផ្ញើរនូវរបាយការណ៍ស្តីពីការចូលរួមចំណែករបស់ជាតិក្នុងការអនុវត្តន៍អនុសញ្ញា UNFCCC ដែលហៅកាត់ថា INDC ទៅលេខាធិការដ្ឋាន UNFCCC ដែលជាផ្នែកមួយនៃការចូលរួម នៅក្នុងកិច្ចប្រជុំសមាជិកភាគីលើកទី២១។ ដំណាក់កាលដំបូង វាបានកំណត់នូវគោលដៅកាត់បន្ថយការបញ្ចេញឧស្ម័នពីការប្រើប្រាស់វិស័យថាមពលឱ្យបាន ២៧%(៣១ មេហ្គាតោនឧស្ម័នកាបូនិច) នៅ ឆ្នាំ ២០៣០ បើប្រៀបធៀបទៅនឹងសេណារ៉ូប្រើប្រាស់ធម្មតា(BAU) និងកំណើនគម្របព្រៃឈើជាតិឱ្យបាន ៦០% នៅឆ្នាំ២០៣០។

ជាទូទៅ ការកាត់បន្ថយជាគោលដៅតិចតួចជាងការបន្សាំសម្រាប់ប្រទេសកម្ពុជា។ ក្របខ័ណ្ឌហិរញ្ញប្បទានអាកាសធាតុ (CCFF) ត្រូវបានរៀបចំឡើងដោយបង្ហាញអំពីរចនាសម្ព័ន្ធថវិកា និងការកៀរគរហិរញ្ញប្បទានអាកាសធាតុ។ ឯកសារនេះមានគោលបំណងដើម្បីកំណត់ពីការសម្របសម្រួល អាទិភាព និងហិរញ្ញប្បទានសម្រាប់សកម្មភាពបន្សាំ និងកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់។ ប្រភពហិរញ្ញប្បទានអាកាសធាតុត្រូវបានកំណត់នៅក្នុង CCFF ដែលបានគូសបញ្ជាក់ពីថវិការដ្ឋាភិបាល ឬប្រភពមកពីមូលនិធិពិភពលោក ព្រមទាំងម្ចាស់ជំនួយទ្វេភាគី និងពហុភាគីផងដែរ។

នៅកម្រិតវិស័យ ផែនការសកម្មភាពប្រែប្រួលអាកាសធាតុ (CCAPs) បានអនុម័តដោយក្រសួង និងស្ថាប័នពាក់ព័ន្ធ ដើម្បីកំណត់សកម្មភាពដែលពាក់ព័ន្ធនឹងគោលបំណងនៃផែនការយុទ្ធសាស្ត្រ ផ.យ.ប.ក. ផែនការសកម្មភាពតាមវិស័យ (CCAPs) រួមបញ្ចូលនូវសកម្មភាពសរុប ៦៨ ជាមួយនឹងគោលនយោបាយ ផែនការ ការពង្រឹងសមត្ថភាព ពង្រឹងស្ថាប័ន ៣៩សកម្មភាពទៀតពាក់ព័ន្ធនឹងការផ្តល់សេវាកម្មដល់ក្រុមទទួលផលគម្រោង និង១០ សកម្មភាពទៀតពាក់ព័ន្ធនឹងការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធ ។ ជាឧទាហរណ៍ សកម្មភាពមួយដែលបានកំណត់នៅក្នុងវិស័យដឹកជញ្ជូនដែលនឹងអាចមានឥទ្ធិពលដោយផ្ទាល់ទៅដល់វិស័យឯកជន សង្កតភាពទៅនឹងការជំរុញនូវការថែទាំ ការត្រួតពិនិត្យរថយន្តដែលជាផ្នែកមួយនៃការខិតខំប្រឹងប្រែងកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់ ។

## ១.២ ក្របខ័ណ្ឌស្ថាប័នសម្រាប់ការប្រែប្រួលអាកាសធាតុ

រវាងឆ្នាំ២០០៦ និង២០១៥ ស្ថាប័នសាធារណៈទទួលបន្ទុកការប្រែប្រួលអាកាសធាតុ (មិនរួម បញ្ចូល។ REDD+ ដែលបានបញ្ជាក់អំពីស្ថាប័នទទួលបន្ទុក) គឺជាគណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុ (NCCC) ដែលមានតួនាទីក្នុងការសម្របសម្រួលការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុនៅក្នុងប្រទេសកម្ពុជា (ឧទាហរណ៍ ៖ ការរៀបចំសម្របសម្រួលនិងតាមដានការអនុវត្តគោល

នយោបាយ យុទ្ធសាស្ត្រ ការណែនាំផ្នែកច្បាប់ ផែនការកម្មវិធីដែលពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុ) ។

ក្នុងខែឧសភា ឆ្នាំ២០១៥ ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព (ក.ជ.អ.ច.) បានទទួលរាប់រងតួនាទី និងភារកិច្ចនេះពី NCCC និងគណៈកម្មាធិការផ្សេងៗចំនួនបួនទៀត។ ក.ជ.អច. មានសមាសភាពពីរដ្ឋលេខាធិការ និងអនុរដ្ឋលេខាធិការពីក្រសួងនានា និងដឹកនាំដោយរដ្ឋមន្ត្រីក្រសួងបរិស្ថាន។ បើប្រៀបធៀបទៅនឹង NCCC សមាជិករបស់ ក.ជ.អ.ច.បានកើនឡើង (ក្រសួងជាច្រើនត្រូវបានបញ្ចូល និងអភិបាលនៃគណៈអភិបាលខេត្តផងដែរ) ក.ជ.អ.ច.បានដើរតួនាទីយ៉ាងសំខាន់ក្នុងការរៀបចំផែនការ យុទ្ធសាស្ត្រប្រែប្រួលអាកាសធាតុកម្ពុជា ២០១៤-២០២៣ ផែនការសកម្មភាពប្រែប្រួលអាកាសធាតុតាមវិស័យ និងក្របខ័ណ្ឌហិរញ្ញប្បទានអាកាសធាតុ ។

ក្រសួងបរិស្ថានបានដើរតួនាទីជាអ្នកដឹកនាំក្នុងការឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុក្នុងប្រទេសកម្ពុជា

- នៅក្នុងក្រសួងបរិស្ថាន នាយកដ្ឋានប្រែប្រួលអាកាសធាតុ(DCC) ត្រូវបានបង្កើតឡើងក្នុងឆ្នាំ ២០០៩។ នាយកដ្ឋាននេះមានតួនាទីទទួលខុសត្រូវសកម្មភាពកម្រិតទូលំទូលាយមួយពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុនិងជាស្ថាប័នបង្គោលរបស់ប្រទេសកម្ពុជាសម្រាប់អនុសញ្ញ UNFCC ក្រុមប្រឹក្សាអន្តរដ្ឋាភិបាលស្តីពីការប្រែប្រួលអាកាសធាតុ (IPCC និងពិធីសារក្យូតូ។ នាយកដ្ឋានមានតួនាទីសម្របសម្រួលក្រុមការងារលើការងារ ឬបញ្ហាពាក់ព័ន្ធប្រែប្រួលអាកាសធាតុ ដូចជា ថាមពល ព្រៃឈើ សារពើភណ្ឌឧស្ម័នផ្ទះកញ្ចក់ ភាពងាយរងគ្រោះ និងការបន្សាំជា ដើម។ល។
- ក្នុងខែកក្កដា ឆ្នាំ២០០២ ក្រសួងបរិស្ថានត្រូវបានចាត់តាំងជាអាជ្ញាធរជាតិសម្រាប់យន្តការអភិវឌ្ឍស្អាត(DNA)។ នាយកដ្ឋានប្រែប្រួលអាកាសធាតុត្រូវបានចាត់តាំងជាលេខាធិការដ្ឋានរបស់អាជ្ញាធរជាតិ(DNA)។

ក្រុមការងារបច្ចេកទេសការប្រែប្រួលអាកាសធាតុ (CCTT) ត្រូវបានបង្កើតឡើងក្នុងខែឧសភា ឆ្នាំ ២០១១ បានដើរតួនាទីជាក្រុមផ្តល់ប្រឹក្សាដល់ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព។ ជាមួយគ្នាផងដែរ ពួកគេក៏ជាក្រុម ដែលផ្តល់នូវការគាំទ្រដល់ក្រសួងពាក់ព័ន្ធក្នុងការរៀបចំផែនការសកម្មភាពប្រែប្រួលអាកាសធាតុតាមវិស័យ។



រូបភាព ៤ អង្គការលេខក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព

## ២. ការអនុវត្តផែនការជាតិបន្សាំក្នុងប្រទេសកម្ពុជា

### ២.១ ការចូលរួមរបស់អ្នកពាក់ព័ន្ធ និងការដាក់បញ្ចូលសម្រាប់ដំណើរការរៀបចំគម្រោងបន្សាំ

ផ្អែកលើលទ្ធផលនៃការសិក្សានៅមូលដ្ឋាន និងការសម្ភាសអ្នកផ្តល់ព័ត៌មានសំខាន់ៗ បង្ហាញថាអ្នកពាក់ព័ន្ធទាំងអស់ត្រូវបានពិគ្រោះយោបល់ពាក់ព័ន្ធនឹងដំណើរការរៀបចំគម្រោង ពិសេសវិធានការបន្សាំ។ ពួកគេបានកំណត់នូវក្រុមដែលងាយរងគ្រោះទៅនឹងផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុ។ យោងលើទ្ធផលនៃការពិគ្រោះយោបល់ ព័ត៌មានទាំងអស់ត្រូវបានដាក់បញ្ចូលទៅក្នុងការរៀបចំគម្រោងដើម្បីដាក់សំណើសុំមូលនិធិបន្សាំ។ ផ្អែកលើរបាយការណ៍ពីប្រធានដឹកនាំក្រុមការងារ ការពិគ្រោះយោបល់បានធ្វើឡើងដូចខាងក្រោមនេះៈ

- ក្រសួងបរិស្ថាន រួមបញ្ចូលនាយកដ្ឋានស្រាវជ្រាវ និងអភិវឌ្ឍន៍សហគមន៍តំបន់ការពារ នាយកដ្ឋានប្រែប្រួលអាកាសធាតុ នាយកដ្ឋានសត្វព្រៃ និងឧទ្យានជាតិ
- ក្រសួងពាក់ព័ន្ធនានារួមបញ្ចូល ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងផែនការ ក្រសួងធនធានទឹក និងឧតុនិយម គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ក្រសួងអភិវឌ្ឍន៍ជនបទ ជាដើម
- អង្គការមួយចំនួនដូចជា WWF, World Vision, WCS, IUCN, CDRI, MRC, FFI, WA, NTFP, RCOFT, etc.

ការពិគ្រោះយោបល់ចំនួនពីរដងត្រូវបានធ្វើឡើងនៅក្នុងតំបន់ការពារ និងខេត្តគោលដៅ។ គាត់រាយការណ៍ថា យ៉ាងហោចណាស់ ៣៦៤នាក់ និងគណៈកម្មាការគ្រប់គ្រងត្រូវបានសម្ភាសន៍ដើម្បីកំណត់សកម្មភាពអាទិភាពសម្រាប់ការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ។ រាល់លទ្ធផលនៃការសិក្សានិងពិគ្រោះយោបល់ត្រូវបានកត់ត្រា និងភ្ជាប់ក្នុងគម្រោងសំណើ។

### ២.២ ដំណើរការប្រកបដោយប្រសិទ្ធភាពនៃការប្រើប្រាស់មូលនិធិបន្សាំ និងការទទួលបានជាសាធារណៈ

មូលនិធិបន្សាំបានប្រើប្រាស់នូវអភិក្រមថ្មីមួយដើម្បីបែងចែកមូលនិធិអាកាសធាតុ។ មូលនិធិនេះជាផ្នែកមួយនៃចំណែកចូលរួមចំនួន ២% ពីគម្រោងយន្តការអភិវឌ្ឍន៍ស្អាត។ វាបានដើរតួនាទីយ៉ាងសំខាន់ក្នុងការពង្រីកហិរញ្ញប្បទានអាកាសធាតុដល់ប្រទេសកំពុងអភិវឌ្ឍន៍ ដោយចាប់ផ្តើមនូវទិន្នន័យគោលដែលទាបបំផុត និងប្រតិបត្តិការដោយមានតម្លាភាពខ្ពស់បំផុត។ វឌ្ឍនភាពដំបូងលើក្របខ័ណ្ឌលទ្ធផលបានជួយដល់ប្រតិបត្តិការមូលនិធិ និងជំរុញការរៀនសូត្រ។ ការសិក្សាប្រភពមូលនិធិថ្មីប្រមូលបានតាមរយៈកម្មវិធី CDM បានផ្តល់នូវចំណូលទាបជាងការរំពឹងទុក។ បើទោះបីយ៉ាងនេះក្តី ការប៉ាន់ប្រមាណមូលនិធិនៅតែចោទជាសំណួរនៅឡើយ។ ការត្រួយត្រាយរៀបចំមូលនិធិដែលអាចទទួលបានដោយផ្ទាល់ "direct

access" មានបំណងកាត់បន្ថយការចំណាយ និងភាពស្មុគស្មាញនៃការទទួលបានមូលនិធិ និងពង្រឹងប្រទេសដែលទទួលមូលនិធិឱ្យក្លាយជាម្ចាស់សម្រាប់គម្រោងដែលបានគាំទ្រ ដំណើរការចុះបញ្ជី នៃការផ្តល់សេចក្តីទុកចិត្ត(Accreditation processes) បានបង្កើតឡើងជាច្រើនក្នុងរយៈពេលកន្លងមក ប៉ុន្តែ ការអនុវត្តជានាបាននូវភាពខ្លាំងផ្នែកសម្របសម្រួល និងភាពជាម្ចាស់នៃកម្មវិធីដែលបានឆ្លងកាត់ពហុភាគី ពាក់ព័ន្ធក្នុងប្រទេសនឹងមានបញ្ហាប្រឈម។ មានការទទួលស្គាល់យ៉ាងទូលំទូលាយថា ឥទ្ធិពលនៃគម្រោង នឹងកែប្រែឱ្យទៅជាមូលដ្ឋាននីយកម្ម និងមានតម្រូវការពិតប្រាកដដើម្បីធានាថាអ្នកពាក់ព័ន្ធនៅកម្រិតមូលដ្ឋាន និងថ្នាក់ក្រោមជាតិទទួលបានផលប្រយោជន៍ពីកិច្ចខិតខំប្រឹងប្រែងបន្ស៊ាំ និងមូលនិធិបន្ស៊ាំ ។ សកម្មភាពគាំទ្រមាននៅកម្រិតមួយដែលមានលក្ខណៈចម្រាស់ភាព។ ការចូលរួមនៅកម្រិតផ្សេងៗគ្នាគឺជាចំណុចផ្តោតដ៏សំខាន់របស់មូលនិធិបន្ស៊ាំ រាល់កម្មវិធីដែលបានអនុម័តរួចរួមទាំងសមាសភាគថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិត្រូវតែផ្តោតលើចំណុចទាំងអស់ខាងលើ។

ទំហំកម្មវិធីខ្នាតតូចតម្រូវជម្រើសជាយុទ្ធសាស្ត្រដែលផ្អែកនៅមូលដ្ឋានអាចចូលរួមបាន។ គម្រោងមួយចំនួនបានស្នើនូវលក្ខណៈវិនិច្ឆ័យទៅនឹងទីតាំងដែលមានសក្តានុពលត្រូវបានពិចារណា បន្ទាប់មកការចូលរួមរបស់អ្នកពាក់ព័ន្ធដើម្បីឈានដល់ការជ្រើសរើសគម្រោងសម្រាប់មូលនិធិបន្ស៊ាំនេះ គម្រោងខ្លះ បានស្នើឱ្យមានការកំណត់លក្ខ័ណ្ឌដែលអាចកែសម្រួលបាននៅពេលដែលកម្មវិធីដំណើរការ មានករណីច្រើនណាស់ ជម្រើសគឺអាស្រ័យការចូលរួមពីអ្នកពាក់ព័ន្ធ អាទិភាព និងចំណាប់អារម្មណ៍របស់ដៃគូអនុវត្តន៍នៅកម្រិតមូលដ្ឋាន។

## ២.៣ ដំណើរការផែនការបន្ស៊ាំកម្រិតមូលដ្ឋាន និងការចូលរួមពីសហគមន៍ងាយរងគ្រោះ

កម្មវិធីសកម្មភាពជាតិបន្ស៊ាំនឹងការប្រែប្រួលអាកាសធាតុ (NAPA) ត្រូវបានរៀបចំឡើងដោយអនុលោមតាមសេចក្តីសម្រេចលេខ២៨ នៅក្នុងកិច្ចប្រជុំសមាជិកភាគីអនុសញ្ញា UNFCCC លើកទី០៧។ ការរៀបចំ NAPA អនុលោមតាមរយៈដំណើរការចូលរួមយ៉ាងពេញលេញពីគ្រប់ភាគីពាក់ព័ន្ធដែលទទួលរងឥទ្ធិពលនៃការប្រែប្រួលអាកាសធាតុ។ ឧទាហរណ៍៖ ស្ថាប័នរដ្ឋាភិបាល ស្ថាប័នសិក្សាធិការ អ្នកសិក្សាស្រាវជ្រាវ តំណាងសហគមន៍ ដៃគូអភិវឌ្ឍន៍ និងអ្នកពាក់ព័ន្ធផ្សេងៗទៀត។

### គោលបំណងនៃកម្មវិធី NAPA

- ស្វែងយល់អំពីលក្ខណៈសំខាន់ៗនៃហានិភ័យអាកាសធាតុក្នុងប្រទេសកម្ពុជា (ទឹកជំនន់ រាំងស្ងួត ព្យុះ ខ្យល់កន្ត្រាក់ កំណើននីវ៉ូទឹកសមុទ្រ និងជម្ងឺគ្រុនចាញ់)
- ស្វែងយល់អំពីយន្តការដោះស្រាយទៅនឹងហានិភ័យអាកាសធាតុ និងការប្រែប្រួលអាកាសធាតុនៅកម្រិតមូលដ្ឋាន

- លើកកម្ពស់ផលិតភាពកសិកម្មតាមរយៈការពង្រីកនូវប្រព័ន្ធធារាសាស្ត្រ និងការគ្រប់គ្រងធនធានទឹកដើម្បីកាត់បន្ថយភាពងាយរងគ្រោះទៅនឹងគ្រោះធម្មជាតិ និង
- កំណត់នូវសកម្មភាពបន្សាំអាទិភាពចំពោះហានិភ័យនៃការប្រែប្រួលអាកាសធាតុ និងផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុ

ប្រទេសកម្ពុជាមិនបានរៀបចំផែនការបន្សាំកម្រិតមូលដ្ឋាននោះទេ ប៉ុន្តែរដ្ឋាភិបាលបានលើកទឹកចិត្តដល់អាជ្ញាធរមូលដ្ឋានដាក់បញ្ចូលការប្រែប្រួលអាកាសធាតុទៅក្នុងផែនការដែលមានស្រាប់ ពិសេសកម្មវិធីវិនិយោគឃុំជាដើម។ ក.ជ.អ.ប របស់ក្រសួងមហាផ្ទៃមានតួនាទី និងភារកិច្ចចាត់ចែង សម្របសម្រួលការងារនេះដើម្បីគាំទ្រដល់ដំណើរការរៀបចំផែនការអភិវឌ្ឍឃុំ/កម្មវិធីវិនិយោគឃុំក្នុងប្រទេសកម្ពុជា ។ គម្រោងដែលមានឈ្មោះថា អភិបាលកិច្ចមូលដ្ឋាន និងការបន្សាំកាប្រែប្រួលអាកាសធាតុ ក.ជ.អ.ប បានជ្រើសរើសខេត្តចំនួន០២ ស្រុកចំនួន០៨ ៣០ឃុំ )សម្រាប់សាកល្បងគម្រោងបញ្ជ្រាបការប្រែប្រួល អាកាសធាតុ និងអភិបាលកិច្ចល្អ ដំណើរការផែនការវិនិយោគឃុំ និងផែនការអភិវឌ្ឍឃុំបានផ្តល់នូវ ឱកាសដល់សហគមន៍ដែលរងផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុបានលើកឡើងនូវការព្រួយបារម្ភណ៍ របស់ពួកគេតាមរយៈការវាយតម្លៃភាពងាយរងគ្រោះ (VRA)។

## ៣. ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

### ៣.១ គោលនយោបាយនៃការប្រែប្រួលអាកាសធាតុ និង ផែនការយុទ្ធសាស្ត្រ

វិស័យកសិកម្មនៅកម្ពុជាបានដើរតួនាទីយ៉ាងសំខាន់ក្នុងការកាត់បន្ថយភាពក្រីក តាមរយៈការបង្កើតការងារសម្រាប់ប្រជាពលរដ្ឋនៅតាមជនបទ និងចូលរួមចំណែកដល់ គោលដៅអភិវឌ្ឍន៍ជាតិ និងសមាហរណកម្មទីផ្សារក្នុងតំបន់។ ទោះជាយ៉ាងណាក៏ដោយ វិស័យនេះផ្សារភ្ជាប់ទៅនឹងការប្រែប្រួលអាកាសធាតុដែលកំពុងកើតឡើងផងដែរ។ ប្រវត្តិនៃផលប៉ះពាល់ និងភាពងាយរងគ្រោះនៃផលិតកម្មដំណាំ ការចិញ្ចឹមសត្វ ការនេសាទ និងព្រៃឈើ ដោយសារការប្រែប្រួលអាកាសធាតុ ត្រូវបានបង្ហាញតាមការវិភាគស្ថានភាព នៅក្នុងប្រអប់ដូចខាងក្រោម៖

### ៣.២ ការវិភាគស្ថានភាពផលិតកម្មដំណាំ ការចិញ្ចឹមសត្វ ការនេសាទ និងព្រៃឈើនៅកម្ពុជា

**<u>ផលិតកម្មដំណាំ</u>**

- ទំនាបលិចទឹកនៅកម្ពុជាដែលប្រព័ន្ធកសិកម្មពឹងផ្អែកលើដំណាំស្រូវជាមូលដ្ឋាន ហើយប្រភេទដំណាំដាំដុះអាស្រ័យទៅតាមរយៈពេលនៃការជន់លិច។
- ការវិភាគសេដ្ឋកិច្ចនាពេលថ្មីៗនេះបានបង្ហាញថា សីតុណ្ហភាពកើនឡើងកម្ដៅ១អង្សាសេ នាំឱ្យដំណាំប្រចាំឆ្នាំធ្លាក់ចុះគិតជាមធ្យមប្រហែល១០%។

- វិស័យកសិកម្មនៅកម្ពុជា ងាយរងគ្រោះបំផុតដោយសារការប្រែប្រួលអាកាសធាតុ។
- នៅកន្លែងដែលមានសំណើម ការកើនឡើងនៃទឹកជំនន់ និងការជន់លិចរយៈពេលយូរអាចបណ្តាលឱ្យតំបន់ដែលមានដីទំនេរមិនអាចធ្វើស្រែបានដោយថាហេតុដែលទាមទារឱ្យមានការផ្លាស់ប្តូរប្រព័ន្ធផលិតកម្ម ដូចជាការធ្វើស្រែវិលជុំនៅរដូវប្រាំង ដោយពឹងផ្អែកលើប្រព័ន្ធធារាសាស្ត្រ។
- ចម្ការកៅស៊ូត្រូវរងផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរ ដោយតំបន់ផលិតកម្មនៅភាគខាងលិចប្រទេសកម្ពុជាបានផ្លាស់ប្តូរដោយសារតែមានភ្លៀងធ្លាក់ខ្លាំង ឬគ្រោះរាំងស្ងួតកើតឡើងរយៈពេលយូរ។

**ការចិញ្ចឹមសត្វ**

- ប្រតិបត្តិការពាណិជ្ជកម្មខ្នាតតូច និងមធ្យមងាយរងគ្រោះបំផុត ហើយមានសមត្ថភាពតិចតួចក្នុងការបន្សាំ។
- ការបង្កើនកម្រិតពាណិជ្ជកម្ម។ត្រូវផ្សារភ្ជាប់ជាមួយនឹងការកើនឡើងនៃការស្តែងចេញនូវ សេនេទិចខ្ពស់ និងការអនុវត្តការគ្រប់គ្រងផលិតភាពខ្ពស់ ដូចជាអត្រាស្តុកខ្ពស់ជាដើម។ ពូជបង្កាត់ដែលបានគ្រប់គ្រងក្នុងប្រព័ន្ធដង់ស៊ីតេខ្ពស់នឹងត្រូវរងផលប៉ះពាល់អវិជ្ជមាន ដោយសារការ ប្រែប្រួលអាកាសធាតុ។
- ការគំរាមកំហែងដែលត្រូវបានគេពិចារណា រួមមានការប្រែប្រួលសីតុណ្ហភាព ការប្រែប្រួលរបបទឹកភ្លៀង ការប្រែប្រួលបរិមាណទឹក ដី និងការប្រែប្រួលភាពញឹកញាប់ និងអាំងតង់ស៊ីតេនៃគ្រោះរាំងស្ងួត គ្រោះទឹកជំនន់ និងខ្យល់ព្យុះ។ នៅក្នុងរបាយការណ៍ស្តីពីការចិញ្ចឹមសត្វបានឱ្យដឹងថាការគំរាមកំហែងទាំងនេះ ត្រូវបានគេចាត់ទុកថានៅកម្រិតថ្នាក់ខេត្ត ដែលការប្រឈមនឹងការគំរាមកំហែងជាក់លាក់មានភាពខុសគ្នាគួរឱ្យកត់សម្គាល់។

**ព្រៃឈើ**

- ធនធានព្រៃឈើត្រូវបាន បាត់បង់យ៉ាងធ្ងន់ធ្ងរ។
- រាជរដ្ឋាភិបាលកម្ពុជាបានកំណត់គោលដៅគោលនយោបាយថែរក្សាគម្របព្រៃឈើចំនួន៦០%។
- ការព្យាករអំពីការប្រែប្រួលអាកាសធាតុបានបង្ហាញថា ព្រៃឈើនឹងរងផលប៉ះពាល់ដោយសារការប្រែប្រួលសីតុណ្ហភាព ទឹកភ្លៀង និងការផ្លាស់ប្តូរតាមរដូវកាល។ ការផ្លាស់ប្តូរទាំងនេះប៉ះពាល់ដោយផ្ទាល់ទៅលើជីវិត និងភាពរឹងមាំនៃប្រភេទសត្វផ្សេងៗ និងប្រព័ន្ធអេកូឡូស៊ី ហើយវានឹងបង្កើនហានិភ័យដែលទាក់ទងនឹងកត្តាចង្រៃផ្សេងៗ។
- នៅក្រោមសេណារីយ៉ូនៃការបំភាយ SRESB1 និង SRESA2 រហូតដល់ឆ្នាំ២០៥០ ព្រៃឈើ តំបន់ទំនាបភាគច្រើននឹងត្រូវរងការប៉ះពាល់រយៈពេលកាន់តែយូរ ជាពិសេសតំបន់ព្រៃនៅភាគ ឦសាន និងភាគនិរតី។ ព្រៃឈើតំបន់ទំនាបជាង៤លានហិចតាដែលបច្ចុប្បន្នមានឱនភាពទឹកក្នុង ចន្លោះពី៤ខែ ទៅ៧ខែ ប្រឈមនឹងឱនភាពទឹករយៈពេលពី៦ខែ ទៅ៨ខែ ឬយូរជាងនេះ។ ទោះជាយ៉ាង

ណាក៏ដោយ ដោយសារលក្ខខណ្ឌទឹកដី ត្រឹមឆ្នាំ២០៨០ និងមានលក្ខណៈស្រដៀងគ្នានឹងលក្ខខណ្ឌបច្ចុប្បន្ន។

**ការនេសាទ**

- ការនេសាទនៅអាងទន្លេមេគង្គក្រោម ត្រូវបានទប់ទល់នឹងការប្រែប្រួលអាកាសធាតុដោយជីវៈចម្រុះតាមប្រព័ន្ធអេកូឡូស៊ីដ៏ធំ។ ជាលទ្ធផល ប្រភេទសត្វមួយចំនួនអាចនឹងទទួលបានអត្ថប្រយោជន៍ពី ស្ថានភាពប្រែប្រួលដែលអាចរក្សាបាននូវផលិតភាពនេសាទទូទៅបាន ខណៈដែលប្រភេទសត្វ ដែលមិនសូវមានការបន្សាំនឹងធ្លាក់ចុះ នេះអាចនាំទៅរកការបាត់បង់ជីវៈចម្រុះទូទៅ។
- វិស័យនេសាទនៅកម្ពុជាងាយទទួលរងគ្រោះដោយសារការប្រែប្រួលអាកាសធាតុ ការសិក្សាជាសាកលថ្មីមួយ ស្តីពីភាពងាយរងគ្រោះនៃសេដ្ឋកិច្ចជាតិ ចំពោះផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុលើវិស័យជលផល បានរកឃើញថា កម្ពុជាក្លាយជាប្រទេសងាយរងគ្រោះបំផុត ចាត់ទុកថាទី៣០ នៅលើពិភពលោក។
- វារីវប្បកម្ម គឺសកម្មភាពមួយដែលត្រូវបានបង្កើតឡើងជាយូរយារណាស់មកហើយ នៅតាមផ្នែកខ្លះនៃអាងទន្លេមេគង្គក្រោម ជាពិសេសនៅបឹងទន្លេសាប និងដីសណ្តទន្លេមេគង្គ។ វារីវប្បកម្មហាក់ដូចជាកាន់តែងាយរងគ្រោះ ដោយសារស្ថានភាពប្រែប្រួលអាកាសធាតុ ទោះបីវារីវប្បកម្មទំនងជាមានសមត្ថភាពបន្សាំក៏ដោយ។
- ការវាយតម្លៃភាពងាយរងគ្រោះ បញ្ជាក់ពីសម្មតិកម្មដែលថាវារីវប្បកម្មនឹងកាន់តែងាយរងគ្រោះដោយសារការប្រែប្រួលអាកាសធាតុច្រើនជាងការនេសាទ។

**បញ្ហាអន្តរវិស័យ**

- ផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុទៅលើវិស័យកសិកម្ម មិនមែនតែនៅក្នុងអនុវិស័យដូចបាន រៀបរាប់ខាងលើឡើយ គឺជាបញ្ហាអន្តរវិស័យ និងជះឥទ្ធិពលដល់ធាតុទាំង៥ រួមទាំងធនធានទឹកជាដើម។
- វិស័យកសិកម្ម (បុរស និងស្ត្រីចំនួន ៧១% នៅកម្ពុជាដែលពឹងផ្អែកលើវិស័យនេះ) និងការគ្រប់គ្រងធនធានធម្មជាតិនឹងក្លាយជាកត្តាសំខាន់សម្រាប់ការបន្សាំរយៈពេលមធ្យម និងការកាត់បន្ថយភាពងាយរងគ្រោះ។
- ការធ្លាក់ចុះណាមួយនៃផលិតភាពធម្មជាតិ នឹងមានផលវិបាកដល់សន្តិសុខស្បៀងយ៉ាងធ្ងន់ធ្ងរ ដែលមិនអាចត្រូវបានទូទាត់ដោយទម្រង់ផលិតកម្មស្បៀងដទៃទៀតឡើយ។
- ការរេចរិលនៃធនធានព្រៃឈើ និងដីធ្លីជាបន្តបន្ទាប់ រួមចំណែកដ៏ធំបំផុតចំពោះការបំភាយឧស្ម័នផ្ទះកញ្ចក់នៅក្នុងប្រទេសកម្ពុជា ហើយធនធានព្រៃឈើទំនងជាត្រូវបានបំផ្លាញដោយសកម្មភាព

មនុស្សបន្តិចម្តងៗ។ ផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ ក៏អាចរួមចំណែកដល់ការផ្លាស់ប្តូរប្រភេទព្រៃឈើនាពេលអនាគតផងដែរ។

*ប្រភព: MAFF (2016) Cambodia's Climate Change Priorities Action Plan for Agriculture, Forestry and Fisheries 2016-2020*

## ៣.៣ អាណត្តិ បេសកកម្ម និងការទទួលខុសត្រូវ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវបានរាជរដ្ឋាភិបាលប្រគល់បេសកកម្មឱ្យដឹកនាំ និងគ្រប់គ្រង លើវិស័យកសិកម្មនៃព្រះរាជាណាចក្រកម្ពុជា។ ក្រសួង កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានមុខងារ និងភារកិច្ចដូចតទៅៈ

- រៀបចំ និងដាក់ឱ្យដំណើរការនយោបាយអភិវឌ្ឍន៍វិស័យកសិកម្មក្នុងគោល បំណង កែលម្អកម្រិតជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ។
- ចូលរួមក្នុងការរៀបចំគោលនយោបាយ កែទម្រង់ និងប្រើប្រាស់ដីធ្លី។
- តម្រង់ទិស និងធ្វើផែនការអភិវឌ្ឍន៍វិស័យកសិកម្មគ្រប់ផ្នែក។
- សម្របសម្រួល តាមដាន និងវាយតម្លៃលើការអនុវត្តគោលនយោបាយ និង សកម្មភាពអភិវឌ្ឍន៍កសិកម្ម។
- តាមដានការវិវត្តនៃធនធានធម្មជាតិរបស់វិស័យកសិកម្ម និងសម្រួលដល់ការធ្វើ អាជីវកម្មធនធានជាតិទាំងនោះដើម្បីបំពេញតម្រូវការរបស់ប្រទេសជាតិ និង ស្របតាមលំនឹង អេកូឡូស៊ី។
- កំណត់បទប្បញ្ញត្តិ ក្នុងការគ្រប់គ្រង និងថែរក្សាការពារធនធានធម្មជាតិរបស់ វិស័យកសិកម្ម និងតាមដានការអនុវត្ត។
- វាយតម្លៃ និងបណ្តុះបណ្តាលធនធានមនុស្សសម្រាប់ការចូលរួមក្នុងការអភិវឌ្ឍ កសិកម្ម ដោយលើកកម្ពស់កម្រិតយល់ដឹងបច្ចេកទេស និងបង្កលក្ខណៈប្រើប្រាស់ធនធាននេះ ឱ្យមានប្រសិទ្ធិ-ភាព។
- ផ្តល់ការគាំទ្រ និងការណែនាំបច្ចេកទេសជាចាំបាច់ដល់កសិករដើម្បីកែលម្អផលិតកម្ម និងផលិតភាពកសិកម្ម។
- កំណត់គោលការណ៍តាមដានការអនុវត្ត លើកកម្ពស់ និងកែលម្អដំណើរប្រព្រឹត្តទៅរបស់អង្គការវិជ្ជាជីវៈ សមាគមនានាដែលពាក់ពន្ធ័នឹងវិស័យកសិកម្ម។
- សិក្សាស្រាវជ្រាវ និងផ្សព្វផ្សាយអំពីវិទ្យាសាស្ត្របច្ចេកទេស និងសេដ្ឋកិច្ចក្នុងវិស័យកសិកម្មគ្រប់ផ្នែក។
- ណែនាំការងារអភិវឌ្ឍន៍ដី និងការកែលម្អគុណភាពដី និងប្រើប្រាស់ជីកសិកម្ម ពូជរុក្ខជាតិ ពូជសត្វ ជីគីមី និងថ្នាំកសិកម្មឱ្យបានសមស្របទៅតាមលក្ខណៈ ភូមិសាស្ត្រអាកាសធាតុរបស់តំបន់ ដើម្បីធានាបានទិន្នផលខ្ពស់ និងរក្សា តុល្យភាពបរិស្ថានធម្មជាតិ។

- ធ្វើសហការជាតិ និងសហប្រតិបត្តិការជាមួយបរទេស អង្គការអន្តរជាតិ អង្គការ ក្រៅរដ្ឋាភិបាល ដើម្បីអភិវឌ្ឍវិស័យកសិកម្មគ្រប់ផ្នែក។
- ចូលរួមក្នុងការជំរុញ និងលើកកម្ពស់ការវិនិយោគ និងការនាំចេញផលិតផលកសិកម្ម និងម្ហូបអា-ហារ។
- ចូលរួមកសាងគោលនយោបាយរកទីផ្សារសម្រាប់ផលិតផលកសិកម្ម។
- ត្រួតពិនិត្យសុវត្ថិភាពស្បៀងនៃផលិតផលកសិកម្ម ចាប់ពីដំណាក់កាលដាំដុះ រហូតដល់ដំណាក់កាលកែច្នៃជាម្ហូបអាហារ។

## ៣.៤ បទដ្ឋានគតិយុត្ត និងគោលនយោបាយ

បទដ្ឋានគតិយុត្ត និងគោលនយោបាយដែលមានស្រាប់របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទដែលពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុ រួមមាន៖ (ក) ច្បាប់ស្តី ពីការគ្រប់គ្រងជី និងថ្នាំកសិកម្ម (ខ) ច្បាប់ស្តីពីជលផល (គ) ច្បាប់ស្តីពីព្រៃឈើ (ឃ) ច្បាប់ស្តីពីសហគមន៍កសិកម្ម (ង) អនុក្រឹត្យសម្បទានដីសេដ្ឋកិច្ច (ច) អនុក្រឹត្យសម្បទាន ដីសង្គមកិច្ច(ឆ)អនុក្រឹត្យស្តីពីការគ្រប់គ្រងសម្បទានព្រៃឈើ និង (ជ) ផែនការយុទ្ធសាស្ត្រ ឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុសម្រាប់វិស័យកសិកម្ម។ ទោះជាយ៉ាងណាក៏ ដោយពុំមានលក្ខខណ្ឌ ឬបទបញ្ញត្តិជាក់លាក់ណាមួយសម្រាប់ការប្រែប្រួលអាកាសធាតុ នៅក្នុងច្បាប់ទាំងនេះឡើយ ទោះបីជាវាពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុក៏ដោយ ក៏នៅតែបានបង្ហាញយ៉ាងទូលំទូលាយផងដែរ។

## ៣.៥ យុទ្ធសាស្ត្រ និងផែនការ

ដោយមានការសម្របសម្រួលពីសម្ព័ន្ធភាពប្រែប្រួលអាកាសធាតុកម្ពុជា នាយកដ្ឋានប្រែប្រួលអាកាសធាតុនៃក្រសួងបរិស្ថាន និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទបានរៀបចំបង្កើត និងដាក់ចេញនូវផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ តាមវិស័យរយៈពេល៥ឆ្នាំ និងផែនការសកម្មភាពអាទិភាពឆ្លើយតបនឹងការប្រែប្រួល អាកាសធាតុរយៈពេលប្រាំឆ្នាំសម្រាប់វិស័យកសិកម្ម ផែនការយុទ្ធសាស្ត្រឆ្លើយតបទៅ នឹងការប្រែប្រួលអាកាសធាតុតាមវិស័យ និងផែនការសកម្មភាពអាទិភាពឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ ដើរតួនាទីជាឧបករណ៍ណែនាំ និងការណែនាំនៅក្នុងការដោះស្រាយ បញ្ហាទាក់ទងនឹងការប្រែប្រួលអាកាសធាតុ និងបញ្ជ្រាបការបន្សុំា និងភាពធន់ទៅនឹងការ ប្រែប្រួលអាកាសធាតុនៅក្នុងវិស័យកសិកម្ម។ ផែនការសកម្មភាពអាទិភាពឆ្លើយតបនឹង ការប្រែប្រួលអាកាសធាតុរយៈពេល៥ឆ្នាំ (២០១៦-២០២០) ចង្អុលបង្ហាញសកម្មភាព អាទិភាពដែលត្រូវអនុវត្តដោយក្រសួង កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលសកម្មភាព ជាអាទិភាពទាំងនោះរួមមាន៖ ក) ពង្រឹងសមត្ថភាព និងការស្រាវជ្រាវលើការប្រែប្រួលអាកាសធាតុ និងការបន្សុំា (ខ) កសាងសមត្ថភាពធន់នឹងអាកាសធាតុ (គ) ការបង្កើតទំនាក់

ទំនងចំណេះដឹង និងប្រព័ន្ធព័ត៌មានស្តីពីការប្រែប្រួលអាកាសធាតុ (ឃ) ការលើកកម្ពស់ប្រព័ន្ធកសិកម្ម និងការអនុវត្តដែលមានការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុកាន់តែច្រើន និង (ង) ការលើកកម្ពស់ និងការជំរុញឱ្យក្រុមងាយរងគ្រោះ មានភាពប្រសើរឡើងចំពោះការបន្សាំ និងភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុ។ ទោះជាយ៉ាងណាក៏ដោយ នៅតែមានបញ្ហាប្រឈមកើតឡើងក្នុងការធ្វើឱ្យសកម្មភាពជាអាទិភាពទាំងនេះអាចអនុវត្តបាន។ សកម្មភាពទាំងនេះត្រូវការថវិកាយ៉ាងច្រើន ហើយមិនទាន់មានប្រភពនៃការគាំទ្រផ្នែកហិរញ្ញវត្ថុគ្រប់គ្រាន់។ សមត្ថភាព និងលទ្ធភាពទទួល បានបច្ចេកវិទ្យា ដើម្បីសម្របសម្រួល និងអនុវត្តសកម្មភាពជាអាទិភាពទាំងនេះនៅមានកម្រិតនៅឡើយ។

គោលដៅផែនការយុទ្ធសាស្ត្រឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុរបស់ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រួមមាន៖

- ធានាសន្តិសុខស្បៀង និងលើកកម្ពស់ជីវភាពរស់នៅរបស់កសិករតាមរយៈការ បង្កើនផលិតកម្មដំណាំកសិឧស្សាហកម្មប្រចាំឆ្នាំចំនួន១០%។
- ជំរុញការអភិវឌ្ឍដំណាំកៅស៊ូធម្មជាតិប្រកបដោយនិរន្តរភាព ដោយផ្តោតលើ ការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ និងវិធានការក្នុងការកាត់បន្ថយ។
- បង្កើនផលិតកម្មចិញ្ចឹមសត្វប្រកបដោយចីរភាព (៣%ក្នុងមួយឆ្នាំ) និងការត្រួត ពិនិត្យសុខភាពសត្វ និងរួមចំណែកកាត់បន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់១% ពី ផលិតកម្មសត្វក្រោយឆ្នាំ ២០១៥។
- ពង្រឹងការគ្រប់គ្រងព្រៃឈើប្រកបដោយចីរភាព តាមរយៈការថែរក្សាព្រៃឈើ និង កាត់បន្ថយការបំភាយឧស្ម័នពីការរេចរិលព្រៃឈើ និងការបាត់បង់ព្រៃឈើ ដើម្បី ទទួលបានឥណទានកាបូន និងលើកកម្ពស់សហគមន៍ព្រៃឈើ ដោយធានា តុល្យភាពសូន្យនៃការកាប់បំផ្លាញព្រៃឈើត្រឹមឆ្នាំ ២០២០។
- ពង្រឹងការគ្រប់គ្រង ការអភិរក្ស និងការអភិវឌ្ឍធនធានមច្ឆាជាតិដោយចីរភាព តាមរយៈការពង្រឹងសមត្ថភាពដោយការចាត់វិធានការសមស្រប និងឆ្លើយតបយ៉ាងសកម្មទៅនឹងការប្រែប្រួលអាកាសធាតុ។

គោលបំណងនៃផែនការយុទ្ធសាស្ត្រឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ ដើម្បីដោះស្រាយការប្រែប្រួលអាកាសធាតុនៅក្នុងវិស័យកសិកម្ម ត្រូវផ្អែកលើការកាត់បន្ថយផលប៉ះពាល់អវិជ្ជមាននៃការប្រែប្រួលអាកាសធាតុ។ ផែនការនេះកំណត់នូវការ ឆ្លើយតបជាយុទ្ធសាស្ត្រចំនួនប្រាំ ដូចខាងក្រោម៖

១. ការកសាងសមត្ថភាពស្ថាប័ន ដើម្បីអភិវឌ្ឍបច្ចេកវិទ្យា និងការអនុវត្តថ្មីៗ ក្នុងការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុដែលជះឥទ្ធិពលលើគ្រប់អនុវិស័យនានា។

២. លើកកម្ពស់ការទទួលយកបច្ចេកទេសទាំងនេះដោយកសិករ អ្នកអភិរក្សព្រៃឈើ និងអ្នកនេសាទ។

៣. កាត់បន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់ពីការបាត់បង់ព្រៃឈើ សត្វ និងដំណាំ និង លើកទឹកចិត្តឱ្យមានការគ្រប់គ្រងព្រៃឈើប្រកបដោយចីរភាព។

៤. ការបន្សាំនៃការនេសាទតាមរយៈការស្រាវជ្រាវ និងការគ្រប់គ្រងធនធានទឹក។

៥. ការកសាងសមត្ថភាព ក្នុងការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុសម្រាប់ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

ដើម្បីឆ្លើយតបទៅនឹងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ ផែនការ សកម្មភាពជាអាទិភាពឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុក្នុងប្រទេសកម្ពុជាសម្រាប់ វិស័យកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ឆ្នាំ២០១៦-២០២០ បានដាក់ចេញនូវយុទ្ធសាស្ត្រ ដើម្បីសម្រេចគោលដៅផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុកម្ពុជា នៃគោលនយោបាយរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ លទ្ធផលរំពឹងទុករួមមានៈ

- ផលកសិកម្មបានកើនឡើងដល់៣៦,៨០លានតោន ទិន្នផលស្រូវជាមធ្យមថ្នាក់ជាតិមានចំនួន៣ ២៥០គីឡូក្រាម នៅត្រឹមឆ្នាំ២០១៨ ហើយតម្លៃនៃការនាំ ចេញផលិតផលកសិកម្មបានកើនឡើងដល់៣០%។
- ប្រាក់ចំណូលរបស់អ្នកទទួលផល នៅតាមតំបន់ដែលងាយរងគ្រោះដោយសារ ការប្រែប្រួលអាកាសធាតុបានកើនឡើងដល់២០% ហើយការងារក្នុងវិស័យ កសិកម្ម និងកសិឧស្សាហកម្មកើនឡើងដល់២០%។ លើសពីនេះ មានការកើនឡើងនូវផ្ទៃដីដំណាំរួមផ្សំដែលធន់នឹងការប្រែប្រួលអាកាសធាតុរហូតដល់ ២០% ផងដែរ។
- រៀបចំផែនទីកំណត់តំបន់ដាំដុះ ការកំណត់ព្រំដែនព្រៃឈើ និងតំបន់អភិវឌ្ឍន៍ ពហុវិស័យដែលបានបង្កើតឡើង។
- ជំរុញកសិករផ្នែកវារីវប្បកម្ម ១០ ០០០នាក់ ដែលរំពឹងថានឹងបង្កើនទិន្នផលពី ៧៤ ០០០តោន ក្នុងឆ្នាំ២០១២ ដល់១៧១ ១៦០តោន នៅត្រឹមឆ្នាំ២០១៨ ជាកសិករគម្រូផ្នែកវារីវប្បកម្មដែលធន់នឹងអាកាសធាតុ។
- ពង្រីកសេវាកម្មបន្ថែមផ្នែកកសិកម្ម សំដៅលើកកម្ពស់ភាពធន់នឹងការប្រែប្រួលអាកាសធាតុដល់កសិករយ៉ាងតិច៥លាននាក់។
- បង្កើនផលិតកម្មបសុសត្វ៣% ក្នុងមួយឆ្នាំ និងកាត់បន្ថយការបាត់បង់សត្វ ចិញ្ចឹមដោយសារការប្រែប្រួលអាកាសធាតុមកត្រឹម៥% ជារៀងរាល់ឆ្នាំ។
- ចែកចាយកូនកៅស៊ូបំបៅយ៉ាងហោចណាស់៥០កូន ដល់អ្នកដាំដុះសម្រាប់ដាំ នៅក្នុងតំបន់ក្សេត្របរិស្ថានណាមួយពីឆ្នាំ ២០១៦ ដល់ឆ្នាំ២០២០។

- បង្កើតគម្រោងរេដបូក (REDD+) ដំណើរការពេញលេញចំនួន៣គម្រោង ដើម្បីទទួលបានឥណទានកាបូន និងស្តារឡើងវិញនូវព្រៃឈើ១០ ០០០ហិចតា ដើម្បីបង្កើនការស្តុកកាបូន និងជីវៈចម្រុះ។
- ការពារព្រៃកោងកាងបានល្អប្រមាណ០,៧៨លានហិចតា និងព្រៃលិចទឹក ០,០៦៨លានហិចតា ហើយកំណត់អត្តសញ្ញាណ និងការពារពូជត្រីជាង៣០០ ប្រភេទ និងជម្រកសំខាន់ៗរបស់វា។

## ៣.៦ ការរៀបចំស្ថាប័ន

រចនាសម្ព័ន្ធស្ថាប័នរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវបានរៀបចំ ជាអង្គភាពសំខាន់ៗចំនួន ៦ គឺៈ (ក) អគ្គលេខាធិការដ្ឋានរបស់ក្រសួង (ខ) រដ្ឋបាលព្រៃឈើ (គ) រដ្ឋបាលជលផល (ឃ) អគ្គនាយកដ្ឋានកសិកម្ម GDA) (ង) អគ្គនាយកដ្ឋានកៅស៊ូ និង (ច) អគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ។ ក្រោមការដឹកនាំ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានសាកលវិទ្យាល័យភូមិន្ទកសិកម្ម សាលាជាតិកសិកម្មព្រែកលៀប សាលាកសិកម្មជាតិកំពង់ចាម និងវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា ព្រមទាំងមានមន្ទីរកសិកម្ម រុក្ខាម្រមាញ់ និងនេសាទចំនួន ២៥រាជធានី/ខេត្ត។

## ៣.៧ នីតិវិធីសម្រាប់ការប្រែប្រួលអាកាសធាតុ

ដើម្បីឆ្លើយតប និងដោះស្រាយបញ្ហាប្រែប្រួលអាកាសធាតុ ការបន្សាំ និងការកាត់បន្ថយក្នុងវិស័យកសិកម្ម ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានបង្កើតក្រុមការងារ បច្ចេកទេសរៀបចំគោលនយោបាយនិងយុទ្ធសាស្ត្រឆ្លើយតបនឹងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុនៅឆ្នាំ២០១២ ដែលមានសមាជិកមកពីអង្គភាពផ្សេងៗដែលស្ថិត នៅក្រោមក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ ក្រុមការងារធ្វើការងារលើការ ប្រែប្រួលអាកាសធាតុ ប្រសិនបើទាក់ទងនឹងក្រសួងបរិស្ថាន និងមានវិសាលភាពទូលាយ ប៉ុន្តែប្រសិនបើទាក់ទងទៅនឹងនាយកដ្ឋាន ឬរដ្ឋបាលតាមវិស័យណាមួយនោះ សមាជិកពាក់ព័ន្ធរបស់ក្រុមការងារនឹងលើកយកទៅពិភាក្សាគ្នាដោយផ្ទាល់នៅក្នុងវិស័យមួយៗ។ នាយកដ្ឋានផែនការ និងស្ថិតិមានការិយាល័យវាយតម្លៃផលប៉ះពាល់បរិស្ថាន (EIA)។

នាយកដ្ឋានផែនការ និងស្ថិតិ ទទួលខុសត្រូវក្នុងការបង្កើតផែនការសម្រាប់ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ ទី១ នាយកដ្ឋាននេះត្រូវផ្តល់ការណែនាំដល់ អង្គភាពដែលស្ថិតក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទអំពីរបៀបរៀបចំផែនការ។ ទី២ អង្គភាពនីមួយៗត្រូវរៀបចំផែនការសកម្មភាពសម្រាប់នាយកដ្ឋានរបស់ខ្លួន។ ទី៣ អង្គភាពនីមួយៗត្រូវដាក់ផែនការរបស់ខ្លួនទៅនាយកដ្ឋានផែនការ និងស្ថិតិ ដើម្បីពិនិត្យ ហើយនាយកដ្ឋានត្រូវចងក្រងជាផែនការសម្រាប់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

## ៣.៨ ជំនាញ និងសមត្ថភាពផ្សេងៗ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទបានធ្វើការស្ទង់មតិមួយស្តីពីតម្រូវការ សមត្ថភាពឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុសម្រាប់វិស័យកសិកម្ម ការប្រែប្រួល អាកាសធាតុគឺជាបញ្ហាដែលកំពុងកើតឡើង ហើយសមត្ថភាពឆ្លើយតបនឹងការប្រែប្រួល អាកាសធាតុនៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទនៅមានកម្រិត។ ដូចនេះ ក្រសួង កសិកម្ម រុក្ខាប្រមាញ់ និងនេសាទបានគូសបញ្ជាក់ថា មានតម្រូវការចាំបាច់សម្រាប់ ហិរញ្ញប្បទានសហប្រតិបត្តិការបច្ចេកទេស (T 8719-CAM) លើការផ្តល់យោបល់ ការបណ្តុះបណ្តាល និងការគាំទ្រផ្សេងៗ សម្រាប់មន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ជំនួសឱ្យការគាំទ្រជាទូទៅ។ វាជាការចាំបាច់ណាស់សម្រាប់ការងារបន្តបន្ទាប់ក្នុង ការពិភាក្សាយ៉ាងជិតស្និទ្ធរវាងជាមួយមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និង ក្រុមការងារបច្ចេកទេសទទួលបន្ទុកផ្នែកការប្រែប្រួលអាកាសធាតុ គោលការណ៍ណែនាំ។ មកកំណត់នូវអ្វីជានៅក្រោមក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទមានសាកលវិទ្យាល័យភូមិន្ទកសិកម្ម សាលាជាតិកសិកម្មព្រែកលៀប និងសាលាជាតិកសិកម្មកំពង់ចាមបាននឹងកំពុងដំណើរការវគ្គសិក្សាស្តីពីការប្រែប្រួលអាកាសធាតុ។

ដោយមានការគាំទ្រពីដៃគូ អភិវឌ្ឍន៍។ សាកលវិទ្យាល័យភូមិន្ទកសិកម្មបានអនុវត្តគម្រោងប្រែប្រួលអាកាសធាតុដែល បានដាក់បញ្ចូលការប្រែប្រួលអាកាសធាតុទៅក្នុងកម្មវិធីសិក្សាសម្រាប់គ្រឹះស្ថានអប់រំកសិកម្មនៅកម្ពុជា។ ទន្ទឹមនឹងនេះ នៅក្នុងដំណើរការសមាហរណកម្មអាស៊ាន ក្រសួង កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ កំពុងពិចារណាបញ្ចូលកម្មវិធីសិក្សាដែលពាក់ព័ន្ធ សម្រាប់ប្រទេសកម្ពុជា។ លើសពីនេះទៅទៀតកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (UNDP) បានសហការជាមួយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដាក់បញ្ចូលការប្រែប្រួល អាកាសធាតុទៅក្នុងវគ្គសិក្សារបស់សាកលវិទ្យាល័យភូមិន្ទកសិកម្ម។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទត្រូវចូលរួមកសាងហេដ្ឋារចនាសម្ព័ន្ធ ដូចជាឃ្លាំងស្តុក និងកន្លែងសម្ងួតជាដើម។ សំខាន់ជាងនេះទៅទៀត ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ទី១ ចាំបាច់ត្រូវចូលរួមកសាងហេដ្ឋារចនាសម្ព័ន្ធធន់នឹងអាកាសធាតុ នៅកម្រិតថ្នាក់សហគមន៍ជាមុនសិន ទី២ កសាងសមត្ថភាពរបស់ក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ និងជាពិសេសគ្រឹះស្ថានសិក្សាទាំង៣ និងទី៣ ក្រសួងត្រូវការជំនួយ ដើម្បីកសាងសមត្ថភាពរបស់វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មនៅកម្ពុជា និងវិទ្យាស្ថានស្រាវជ្រាវតាមអង្គភាពក្រោមក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្នុងការ បញ្ជ្រាបភាពធន់នឹងអាកាសធាតុ។

## ៣.៩ ការបញ្ជ្រាបការប្រែប្រួលអាកាសធាតុ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទបានលើកយកប្រធានបទដ៏ទូលំទូលាយ ទាក់ទងនឹងការប្រែប្រួលអាកាសធាតុ តែមានសារៈសំខាន់ក្នុងការពិភាក្សាទាក់ទងទៅ នឹងផ្នែកណាខ្លះនៅក្នុងផែនការសកម្មភាពជាអាទិភាពឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ (CCPAP) ដែលជំនួយបច្ចេកទេស (TA

B179) គួរពិចារណា។ បើទោះបីជា ផែនការសកម្មភាពជាអាទិភាពឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុស្នើសុំគម្រោង ចំនួន២៨គម្រោង ក៏ដោយ ក៏វាជាការសំខាន់ដែលត្រូវដឹងថាតើផ្នែកណាមួយដែល ក្រសួងត្រូវការការគាំទ្រ។ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទបានបញ្ជាក់ថា ក្រុមការងារបច្ចេកទេសទទួលបន្ទុកផ្នែកការប្រែប្រួលអាកាសធាតុ ត្រូវការការគាំទ្រពីTA 8179 ជាពិសេសបញ្ហាអន្តរវិស័យ។

កសិកម្មវៃឆ្លាតនឹងអាកាសធាតុមានសារៈសំខាន់ណាស់ ហើយក្នុងការងារនេះ ទឹកគឺជាបញ្ហាគន្លឹះដ៏សំខាន់។ ប្រសិនបើប្រព័ន្ធធារាសាស្រ្តមិនមានប្រសិទ្ធភាពក្នុងការផ្តល់ទឹកដល់កសិករទេនោះ ទិន្នផលស្រូវនឹងថយចុះ។ ដូច្នេះ ការជួយដល់សហគមន៍ មូលដ្ឋានក្នុងការគ្រប់គ្រងទឹក ពិតជាមានសារៈសំខាន់ណាស់។ បញ្ហាអន្តរវិស័យសម្រាប់ ផ្នែកណាមួយដែលត្រូវការជំនួយមកពីខាងក្រៅគឺទី១ ការកសាងសមត្ថភាពធនធានមនុស្ស និងទី២ ការពង្រីកភាពធន់រហូតដល់សហគមន៍។

ការរៀបចំផែនការសកម្មភាពជាអាទិភាពឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ គឺជាចំណុចចាប់ផ្តើមមួយសម្រាប់បញ្ជ្រាបការប្រែប្រួលអាកាសធាតុទៅក្នុងផែនការអភិវឌ្ឍន៍។ វាមានសារៈសំខាន់ណាស់ដែលសកម្មភាពទាំងនេះត្រូវបានដាក់បញ្ចូលទៅក្នុង គម្រោងបន្តបន្ទាប់ ឬគម្រោងដែលកំពុងដំណើរការសម្រាប់កម្មវិធីវិនិយោគជាសាធារណៈ របស់ក្រសួង (PIPs)។ នៅពេលកំពុងមានបញ្ហាកើតឡើង ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទពុំបានផ្តល់ធនធានហិរញ្ញវត្ថុគ្រប់គ្រាន់ពីថវិកាជាតិសម្រាប់ការប្រែប្រួលអាកាសធាតុទេ។

# ជំពូកទី ៣ ការរៀបចំក្របខណ្ឌស្ថាប័នពាក់ព័ន្ធ

- មេរៀនទី ១ ការរៀបចំក្របខណ្ឌស្ថាប័ននៃការប្រែប្រួលអាកាសធាតុ
- មេរៀនទី ២ ស្ថាប័នបង្គោលថ្នាក់ជាតិ
- មេរៀនទី ៣ គ្រឹះស្ថានអប់រំ និងស្រាវជ្រាវ
- មេរៀនទី ៤ អង្គការក្រៅរដ្ឋាភិបាល និងសង្គមស៊ីវិល
- មេរៀនទី ៥ វិស័យឯកជន

# មេរៀនទី ១ ការរៀបចំក្របខណ្ឌស្ថាប័ននៃការប្រែប្រួលអាកាសធាតុ

ការរៀបចំស្ថាប័នបច្ចុប្បន្នសម្រាប់ការងារប្រែប្រួលអាកាសធាតុ អនុញ្ញាតឱ្យស្ថាប័នរដ្ឋាភិបាលនិងអង្គការមិនមែនរដ្ឋាភិបាលអាចចូលរួមកាន់តែមានប្រសិទ្ធភាព ក្នុងការអនុវត្តវិធានការឆ្លើយតបរបស់កម្ពុជា។

ការបង្កើតឡើងនៃក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព(NCSD) នៅខែឧសភាឆ្នាំ២០១៥ ដែលជាអង្គភាពអន្តរក្រសួងត្រួតពិនិត្យការងារឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ គឺបង្ហាញពីចំណុចសំខាន់មួយនៃដំណើរការជាតិកំណែទម្រង់ស្ថាប័នដើម្បីឱ្យមានការឆ្លើយតបដ៏ប្រសិទ្ធភាព បរិយាបន្ន និងពេញលេញ។ អគ្គលេខាធិការដ្ឋាន(GSSD) និងជាពិសេសនាយកដ្ឋានប្រែប្រួលអាកាសធាតុ (DCC) ក៏ដូចជាក្រុមការងារបច្ចេកទេសប្រែប្រួលអាកាសធាតុ (CCTWG)អន្តរវិស័យ ដើរតួនាទីយ៉ាងសំខាន់ក្នុងការសម្របសម្រួលការអនុវត្តការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុរបស់ប្រទេស។

NCSD មានសម្តេចនាយករដ្ឋមន្ត្រីជាប្រធានកិត្តិយស រដ្ឋមន្ត្រីក្រសួងបរិស្ថានជាប្រធាន និងអគ្គលេខាធិការដ្ឋាន។ សមាជិកភាពរួមមានតំណាងមន្ត្រីជាន់ខ្ពស់មកពីក្រសួង / ស្ថាប័នចំនួន៣៦ និងអភិបាលខេត្ត/រាជធានីទាំងអស់។ ក្រុមប្រឹក្សាពិនិត្យមើលកិច្ចប្រឹងប្រែងរបស់ប្រទេសក្នុងការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ ហើយមានអណត្តិរៀបចំ សម្របសម្រួល និងត្រួតពិនិត្យការអនុវត្តគោលនយោបាយយុទ្ធសាស្ត្រ បទដ្ឋានគតិយុត្ត ផែនការនិងកម្មវិធីនានាដែលទាំងការអនុវត្ត CCCSP និងផែនការសកម្មភាពប្រែប្រួលអាកាសធាតុតាមវិស័យ។

CCTWG ជាក្រុមការងារបច្ចេកទេសប្រែប្រួលអាកាសធាតុអន្តរក្រសួង ដែលបង្កើតឡើងនៅឆ្នាំ២០១៧ ដឹកនាំដោយអគ្គលេខាធិការរងនៃNCSD និងមានសមាជិកសារុបចំនួន២៥ រូប តំណាងមកពីក្រសួង / ស្ថាប័នផ្សេងៗគ្នាចំនួន១៩។ CCTWG ផ្តល់ការគាំទ្រផ្នែកបច្ចេកទេសនិងមតិយោបល់ស្តីពីការប្រែប្រួលអាកាសធាតុជូនដល់សមាជិក NCSD ដោយមានលក្ខខណ្ឌការងារគ្របដណ្តប់លើគោលនយោបាយ ក្របខ័ណ្ឌគតិយុត្តិ ការគ្រប់គ្រងចំណេះដឹងនិងការធានាគុណភាព ការត្រួតពិនិត្យនិងវាយតម្លៃការរៀបចំរបាយការណ៍ជូនទៅ UNFCCC ការវាយតម្លៃបច្ចេកទេស ការកៀរគរធនធាននិងភាពជាដៃគូ ការកសាងសមត្ថភាព និងការលើកកម្ពស់ការយល់ដឹងនិងការរាយការណ៍លើការងារប្រែប្រួលអាកាសធាតុ។

**យន្តការសម្របសម្រួលជាមួយដៃគូរមិនមែនរដ្ឋាភិបាល** មានដូចជា ដៃគូអភិវឌ្ឍន៍ ស្ថាប័នសិក្សាស្រាវជ្រាវ អង្គការមិនមែនរដ្ឋាភិបាល និងវិស័យឯកជន ត្រូវបានរៀបចំឡើងតាមរយៈកិច្ចប្រជុំរួមគ្នាជាមួយ CCTWG ចំនួន២ដងក្នុងមួយឆ្នាំ ។

**នាយកដ្ឋានប្រែប្រួលអាកាសធាតុ (DCC)** ជានាយកដ្ឋានចំណុះឱ្យអគ្គលេខាធិកាដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព បានដើរតួនាំមុខក្នុងការអនុវត្តកិច្ចប្រឹងប្រែងឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុរបស់កម្ពុជា និងជាស្ថាប័នបង្គោលរបស់កម្ពុជា ទៅអនុសញ្ញាក្របខណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ។ ភារកិច្ចសំខាន់ៗរបស់នាយកដ្ឋានមានដូចជា៖

- រៀបចំឧបករណ៍ច្បាប់និងសារពើពន្ធ គោនយោបាយ យុទ្ធសាស្ត្រ ផែនការសកម្មភាព កម្មវិធី និងគម្រោងស្តីពីការប្រែប្រួលអាកាសអាតុក្នុងន័យកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ និងបន្សាំនឹងការប្រែប្រួលអាកាសធាតុ។
- សម្របសម្រួលនិងគាំទ្រការអនុវត្តគោលនយោបាយ ច្បាប់ លិខិតុបករណ៍ រៀបចំផែនការ និងការត្រួតពិនិត្យ ការវាយតម្លៃ និងការរាយការណ៍ជាប្រចាំ។
- សម្របសម្រួល និងផ្តល់ការគាំទ្រផ្នែកបច្ចេកទេស ដល់ការរៀបចំនិងគ្រប់គ្រងសារពើភ័ណ្ឌ GHGs របាយការណ៍ជាតិ របាយការណ៍បច្ចុប្បន្នភាពពីរឆ្នាំម្តង(BURs) និងអនុវត្តកាតព្វកិច្ចរបស់រដ្ឋាភិបាលក្រោមអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ (UNFCCC) និងកិច្ចព្រមព្រៀងអន្តរជាតិផ្សេងៗទៀតលើសកម្មភាពអាកាសធាតុ។
- កៀរគរនិងគ្រប់គ្រងធនធាននិងកសាងភាពជាដៃគូដើម្បីបង្កើនការអនុវត្តការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ។

រាជរដ្ឋាភិបាលកម្ពុជាបានចាត់វិធានការសំខាន់ៗ ដើម្បីដោះស្រាយការប្រែប្រួលអាកាសធាតុទាំងក្នុងគោលនយោបាយនិងដំណើរការរៀបចំស្ថាប័ន។ កាលប្បវត្តិនៃកិច្ចខិតខំប្រឹងប្រែងកន្លងមកមានបង្ហាញដូចខាងក្រោម គឺជាការកំណត់សម្គាល់សំខាន់ៗអំពីក្របខ័ណ្ឌគោលនយោបាយរបស់កម្ពុជាក្នុងការឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ។

**ឆ្នាំ១៩៩៥៖** ព្រះរាជាណាចក្រកម្ពុជាបានផ្តល់សច្ចាប័នលើអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ (UNFCCC) ។

**ឆ្នាំ២០០២៖** កម្ពុជាបានក្លាយជាសមាជិកនៃពិធីសារក្យូតូនិងបានដាក់ជូននូវរបាយការណ៍ជាតិលើកទី១ (INC) ទៅសន្និសិទបណ្តាភាគីលើកទី៨ ក្រោមUNFCCC។

**ឆ្នាំ២០០៣៖** ការិយាល័យប្រែប្រួលអាកាសធាតុត្រូវបានបង្កើតឡើងនៅក្រសួងបរិស្ថាន។ បន្ទាប់មកការិយាល័យនេះបានក្លាយជានាយកដ្ឋានប្រែប្រួលអាកាសធាតុក្នុងឆ្នាំ២០១០។

**ឆ្នាំ២០០៦៖** រដ្ឋាភិបាលបានបង្កើតគណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុ(NCCC)ដែលជាស្ថាប័នកម្រិតខ្ពស់សម្រាប់រៀបចំគោលនយោបាយ និងរៀបចំកម្មវិធីសកម្មភាពជាតិបន្ស៊ាំទៅនឹងការប្រែប្រួលអាកាសធាតុ (NAPA) ដែលរួមមានគម្រោងអាទិភាពសម្រាប់បញ្ចូលទៅក្នុងផែនការជាតិឬផែនការមូលដ្ឋាន។ បន្ទាប់មកក្រុមការងារបច្ចេកទេសប្រែប្រួលអាកាសធាតុ(CCTT) ត្រូវបានបង្កើតឡើងជាមួយការទទួលខុសត្រូវលើសកម្មភាពបច្ចេកទេសនិងការផ្តល់មតិយោបល់ដល់ NCCC ។

**ឆ្នាំ២០០៩៖** ផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិ(NSDP) បច្ចុប្បន្នភាពឆ្នាំ២០០៩-២០១៣ ជាលើកដំបូងបានដាក់បញ្ចូលការប្រែប្រួលអាកាសធាតុ។ NSDP បានសង្កត់ធ្ងន់ថាដើម្បីដោះស្រាយប្រកបដោយប្រសិទ្ធភាពបញ្ហាប្រែប្រួលអាកាសធាតុ សមត្ថភាពរបស់ស្ថាប័នរាជរដ្ឋាភិបាលកម្ពុជាត្រូវតែពង្រឹងដើម្បីកំណត់អត្តសញ្ញាណនិងរៀបចំផែនការយុទ្ធសាស្ត្រដើម្បីដោះស្រាយ ផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុនិងពង្រឹងសមត្ថភាពគ្រប់គ្រងគ្រោះមហន្តរាយ និងជាពិសេសស្នើឱ្យរៀបចំយុទ្ធសាស្ត្រជាតិនិងផែនការសកម្មភាពសម្រាប់ការប្រែប្រួលអាកាសធាតុ។

**ឆ្នាំ២០១៣៖** សម្តេចនាយករដ្ឋមន្ត្រីកម្ពុជាបានអនុម័តផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុកម្ពុជា២០១៤-២០២៣ ដែលនាំឱ្យមានការរៀបចំក្របខ័ណ្ឌចាំបាច់នានាដូចជាការត្រួតពិនិត្យនិងវាយតម្លៃ ហិរញ្ញវត្ថុ បទដ្ឋានច្បាប់ និង ការគ្រប់គ្រងព័ត៌មាននិងចំណេះដឹង។ នៅឆ្នាំ២០១៤-២០១៥ ក្រសួងស្ថាប័នចំនួន១៤ បានអនុម័តលើផែនការសកម្មភាពប្រែប្រួលអាកាសធាតុតាមវិស័យរបស់ខ្លួន ហើយបានចាប់ផ្តើមអនុវត្តសកម្មភាពអាទិភាពចាប់ពីពេលនោះមក។

**ឆ្នាំ២០១៤៖** បញ្ហាប្រែប្រួលអាកាសធាតុត្រូវបានកំណត់ជាបញ្ហាអន្តរវិស័យនិងបញ្ជ្រាបទៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ២០១៤-២០១៨ ជាមួយគ្នានោះដែរមានក្រសួងមួយចំនួនបានដាក់បញ្ចូលវិធានការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុនៅក្នុងអាទិភាពរបស់ស្ថាប័ន។

**ឆ្នាំ២០១៥៖** ការរៀបចំស្ថាប័នថ្មីសម្រាប់ការប្រែប្រួលអាកាសធាតុបាននាំមកនូវការច្របាច់បញ្ចូលគ្នារវាងក្រុមប្រឹក្សាជាតិ និងគណៈកម្មាធិការជាតិចំនួនបួន ដើម្បីបង្កើតក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាពនិងអគ្គលេខាធិការដ្ឋានរបស់ខ្លួនដែលរួមមាននាយកដ្ឋានប្រែប្រួលអាកាសធាតុ។ រដ្ឋាភិបាលបានដាក់ជូននូវរបាយការណ៍ជាតិលើកទីពីរទៅ UNFCCC ។

**ឆ្នាំ២០១៦៖** ប្រទេសកម្ពុជាបានផ្តល់សច្ចាប័នលើកិច្ចព្រមព្រៀងទីក្រុងប៉ារីស៍ស្តីពីការប្រែប្រួលអាកាសធាតុ។ មុនកិច្ចព្រមព្រៀងទីក្រុងប៉ារីស៍ កម្ពុជាបានដាក់ជូននូវរបាណការណ៍(I)NDC ទៅUNFCCC។

**ឆ្នាំ២០១៧៖** ក្រសួងផែនការនិងក្រសួងមហាផ្ទៃបានចេញនូវសេចក្ដីណែនាំបច្ចេកទេសសម្រាប់បញ្ជ្រាបការប្រែប្រួលអាកាសធាតុនៅដំណើរការរៀបចំផែនការថ្នាក់ក្រោមជាតិ។ នៅថ្នាក់ជាតិ ក្រុមការងារបច្ចេកទេសប្រែប្រួលអាកាសធាតុត្រូវបានបង្កើតឡើងនិងបានជួបប្រជុំជាទៀងទាត់។

**ឆ្នាំ២០១៨៖** យុទ្ធសាស្រ្តចតុកោណដំណាក់កាលទី៤ (២០១៩-២០២៣) បានដាក់បញ្ចូលការប្រែប្រួលអាកាសធាតុនៅក្នុងចតុកោណទី៤ "ការអភិវឌ្ឍប្រកបដោយចីរភាពនិងបរិយាប័ន្ន"។ នេះត្រូវនឹងមុំទី៤ "ការធានាចីរភាពបរិស្ថាន និង ការរៀបចំខ្លួនឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ" ដែលជាក្របខណ្ឌគោលនយោបាយសម្រាប់បញ្ជ្រាបការប្រែប្រួលអាកាធាតុទៅក្នុង ផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិ ២០១៩-២០២៣។

**ឆ្នាំ២០១៩៖** ការធ្វើមូលដ្ឋានីយកម្មនៃ SDG១៣ ត្រូវបានបញ្ចប់ដោយកំណត់បាននូវសូចនាករចំនួន ៥ ស្ដីពីការប្រែប្រួលអាកាសធាតុ។ MOP ដោយមានការគាំទ្រពី DCC ខិតខំប្រឹងប្រែងយ៉ាងម៉ត់ចត់ក្នុងការតម្រង់សូចនាករប្រែប្រួលអាកាសធាតុរបស់ SDG១៣ ជាមួយសូចនាករ NSDP ២០១៩-២០២៣ ។

**ឆ្នាំ២០១៩៖** សេចក្ដីព្រាងក្រមធនធានធម្មជាតិនិងបរិស្ថាន បានដាក់ចេញនូវមាតិកាស្ដីពីការប្រែប្រួលអាកាសធាតុ។ នៅពេលដែលក្រុមENR ត្រូវបានអនុម័ត មាតិកាស្ដីពីការប្រែប្រួលអាកាសធាតុនឹងផ្ដល់នូវក្របខ័ណ្ឌច្បាប់រឹងមាំមួយសម្រាប់ការងារប្រែប្រួលអាកាសធាតុ និងសម្រាប់បទប្បញ្ញត្តិប្រែប្រួលអាកាសធាតុនាខាងមុខនេះ។

# មេរៀនទី ២ ស្ថាប័នបន្ទោលថ្នាក់ជាតិ

## ១. ការរៀបចំនិងការប្រព្រឹត្តទៅនៃ អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព

### ១.១ បទប្បញ្ញត្តិទូទៅ

អនុក្រឹត្យនេះកំណត់អំពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាជាតិ អភិវឌ្ឍន៍ដោយចីរភាព ដែលហៅកាត់ថា អគ្គលេខាធិការដ្ឋាន ក.ជ.អ.ច.។

### ១.២ តួនាទីនិងភារកិច្ច

អគ្គលេខាធិការដ្ឋាន ក.ជ.អ.ច. មានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

- សម្របសម្រួលនិងអនុវត្តការងារប្រចាំថ្ងៃ តាមការណែនាំនិងសេចក្តីសម្រេចនានារបស់ ក.ជ.អ.ច
- រៀបចំកម្មវិធីនិងផែនការការងារ ដើម្បីដាក់ជូន ក.ជ.អ.ច. ពិនិត្យសម្រេច
- ដឹកនាំនិងសម្របសម្រួលការអនុវត្តកម្មវិធីនិងផែនការការងារដែលបានអនុម័តដោយ ក.ជ.អ.ច.
- សម្របសម្រួលការរៀបចំសេចក្តីព្រាងលិខិតបទដ្ឋានគតិយុត្ត គោលនយោបាយ ផែនការយុទ្ធសាស្ត្រផែនការសកម្មភាព កម្មវិធី និងគម្រោងនានា ដែលពាក់ព័ន្ធនឹងការអភិវឌ្ឍដោយចីរភាព
- សម្របសម្រួលនិងផ្តល់ការគាំទ្រដល់ការអនុវត្តលិខិតបទដ្ឋានគតិយុត្ត គោលនយោបាយ ផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាព កម្មវិធី និងគម្រោងនានា ដែលពាក់ព័ន្ធនឹងការអភិវឌ្ឍដោយ ចីរភាព ព្រមទាំងពិនិត្យ តាមដាន វាយតម្លៃ និងធ្វើរបាយការណ៍ជាប្រចាំ
- កៀរគរនិងគ្រប់គ្រងធនធាន សម្រាប់អនុវត្តលិខិតបទដ្ឋានគតិយុត្ត គោលនយោបាយ ផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាព កម្មវិធី និងគម្រោងនានា ពាក់ព័ន្ធនឹងការអភិវឌ្ឍដោយចីរភាព
- លើកសំណើបង្កើតយន្តការចាំបាច់សម្រាប់កិច្ចការតាមវិស័យ ដែលពាក់ព័ន្ធនឹងតួនាទីនិងភារកិច្ចរបស់ ក.ជ.អ.ច. និងផ្តល់ការគាំទ្រដល់សកម្មភាពនានាពាក់ព័ន្ធនឹងប្រតិបត្តិការជាប្រចាំរបស់យន្តការទាំងនោះ
- សម្របសម្រួលនិងគាំទ្រដល់ការពង្រឹងកិច្ចសហប្រតិបត្តិការ ទាក់ទងនឹងការអភិវឌ្ឍដោយចីរភាពជាមួយដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល វិស័យឯកជន គ្រឹះស្ថានសិក្សាស្រាវជ្រាវ និងអ្នកពាក់ព័ន្ធ ទាំងថ្នាក់ជាតិ ថ្នាក់តំបន់ និងថ្នាក់ពិភពលោក
- ដឹកនាំនិងសម្របសម្រួលការងារសិក្សា ស្រាវជ្រាវ អប់រំ បណ្តុះបណ្តាល និងផ្លាស់ប្តូរបច្ចេកវិទ្យាពាក់ព័ន្ធនឹងការអភិវឌ្ឍដោយចីរភាព

- គ្រប់គ្រងទិន្នន័យនិងផ្សព្វផ្សាយព័ត៌មានពាក់ព័ន្ធនឹងការអភិវឌ្ឍដោយចីរភាព និងសកម្មភាពរបស់ ក.ជ.អ.ច. ដល់សាធារណជន
- ពិនិត្យនិងសិក្សាអំពីលទ្ធភាពនៃការចូលរួមក្នុងកិច្ចព្រមព្រៀងអន្តរជាតិនានា ពាក់ព័ន្ធនឹងការ អភិវឌ្ឍដោយចីភាពជូនដល់ ក.ជ.អ.ច
- រៀបចំសេចក្ដីព្រាងឯកសារជំហរនិងយុទ្ធសាស្ត្រ សម្រាប់ចូលរួមក្នុងកិច្ចចរចាអន្តរជាតិនានា
- ដែលពាក់ព័ន្ធនឹងការអភិវឌ្ឍដោយចីរភាព
- សម្របសម្រួលការរៀបចំរបាយការណ៍ជាតិ ស្របតាមកិច្ចព្រមព្រៀងអន្តរជាតិនានាពាក់ព័ន្ធនឹង ការអភិវឌ្ឍដោយចីរភាព ដែលកម្ពុជាជាសមាជិក
- ចូលរួមក្នុងកិច្ចប្រជុំនានានៅថ្នាក់ជាតិ ថ្នាក់តំបន់ និងថ្នាក់ពិភពលោក លើបញ្ហាដែលពាក់ព័ន្ធនិង ការអភិវឌ្ឍដោយចីរភាព
- គ្រប់គ្រងហិរញ្ញវត្ថុនិងថវិការបស់ ក.ជ.អ.ច.
- រៀបចំកិច្ចប្រជុំនានា ធ្វើកំណត់ហេតុ និងរបាយការណ៍របស់ ក.ជ.អ.ច.
- រៀបចំរបាយការណ៍របស់អគ្គលេខាធិការដ្ឋានប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំជូន ក.ជ.អ.ច.
- ទទួលអនុវត្តភារកិច្ចដទៃទៀតតាមការប្រគល់ជូនពីប្រធាន ក.ជ.អ.ច. និងប្រធានគណៈកម្មាធិការ ប្រតិបត្តិ ក.ជ.អ.ច. ។

### ១.៣ រចនាសម្ព័ន្ធ

អគ្គលេខាធិការដ្ឋាន ក.ជ.អ.ច. ដឹកនាំដោយអគ្គលេខាធិការមួយរូប អមដោយអគ្គលេខាធិការរង មួយចំនួន តាមការចាំបាច់។

អគ្គលេខាធិការដ្ឋានត្រូវអនុវត្តការងារនៅក្រោមការដឹកនាំរបស់ប្រធានគណៈកម្មាធិការប្រតិបត្តិ ក. ជ.អ.ច។

**អគ្គលេខាធិការដ្ឋាន ក.ជ.អ.ច. មានរចនាសម្ព័ន្ធ ដូចខាងក្រោម៖**

- នាយកដ្ឋានរដ្ឋបាល ផែនការ និងហិរញ្ញវត្ថុ
- នាយកដ្ឋានប្រែប្រួលអាកាសធាតុ
- នាយកដ្ឋានសេដ្ឋកិច្ចបៃតង
- នាយកដ្ឋានវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា

- នាយកដ្ឋានជីវៈចម្រុះ។

អង្គការលេខរបស់អគ្គលេខាធិការដ្ឋាន កជ.អ.ចមានភ្ជាប់ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

នាយកដ្ឋាននីមួយៗ ដឹកនាំដោយប្រធានមួយរូប និងអមដោយអនុប្រធានមួយចំនួន តាមការចាំបាច់ ។ ការរៀបចំនិងការប្រព្រឹត្តទៅរបស់នាយកដ្ឋាននីមួយៗត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងបរិស្ថាន។

អគ្គលេខាធិការដ្ឋាន ក.ជ.អ.ច. មានមន្ត្រីបម្រើការមកពីក្រសួងបរិស្ថាន និងមន្ត្រីរាជការនៅ ក្នុងក្របខ័ណ្ឌមុខងារសាធារណៈផ្សេងទៀត។ ក្នុងករណីចាំបាច់ អគ្គលេខាធិការដ្ឋាន ក.ជ.អ.ច. អាចស្នើសុំជ្រើសរើសទីប្រឹក្សា អ្នកជំនាញការ ឬ បុគ្គលិកជាប់កិច្ចសន្យា ដើម្បីជួយបំពេញការងាររបស់ខ្លួន។

ការតែងតាំងមន្ត្រីរាជការ ការរៀបចំប្រាក់បៀវត្ស និងប្រាក់បំណាច់ផ្សេងៗរបស់មន្ត្រីរាជការបម្រើការងារក្នុងអគ្គលេខាធិការដ្ឋាន ក.ជ.អ.ច. ជាបន្ទុករបស់ក្រសួងបរិស្ថាន។

## ១.៤ តួនាទីនិងភារកិច្ចរបស់នាយកដ្ឋាននីមួយៗ

**នាយកដ្ឋានរដ្ឋបាល ផែនការ និងហិរញ្ញវត្ថុ** មានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

- គ្រប់គ្រងផ្នែករដ្ឋបាលនិងសម្របសម្រួលការងាររបស់អគ្គលេខាធិការដ្ឋាន
- គ្រប់គ្រងនិងចរាចរឯកសាររបស់អគ្គលេខាធិការដ្ឋាន
- លើកសំណើនិងសម្របសម្រួលការងារលទ្ធកម្មសាធារណៈរបស់អគ្គលេខាធិការដ្ឋាន
- គ្រប់គ្រងបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិ ឧបករណ៍ និងសម្ភារៈការិយាល័យរបស់អគ្គលេខាធិការដ្ឋាន
- គ្រប់គ្រងនិងការកសាងសមត្ថភាពមន្ត្រីរាជការនិងបុគ្គលិកទាំងក្នុងក្របខ័ណ្ឌនិងក្រៅក្របខ័ណ្ឌរបស់អគ្គលេខាធិការដ្ឋាន
- គ្រប់គ្រងគណនេយ្យនិងហិរញ្ញវត្ថុរបស់អគ្គលេខាធិការដ្ឋាន
- គ្រប់គ្រងការងារពិធីការរបស់អគ្គលេខាធិការដ្ឋាន
- គ្រប់គ្រងការងារសង្គមកិច្ចរបស់អគ្គលេខាធិការដ្ឋាន
- សម្របសម្រួលការរៀបចំផែនការសកម្មភាពផែនការថវិកា និងផែនការពិនិត្យ វាយតម្លៃ និង ធ្វើកំណត់ហេតុនិងរបាយការណ៍ប្រជុំរបស់អគ្គលេខាធិការដ្ឋាន

- រៀបចំរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំរបស់នាយកដ្ឋាននិងរបស់ អគ្គលេខាធិការដ្ឋាន
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតតាមការប្រគល់ជូនពីអគ្គលេខាធិការ ក.ជ.អ.ច។

**នាយកដ្ឋានប្រែប្រួលអាកាសធាតុ** មានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

- រៀបចំសេចក្តីព្រាងលិខិតបទដ្ឋានគតិយុត្ត គោលនយោបាយ ផែនការយុទ្ធសាស្ត្រ ផែនការ និងថវិកា លើកស្ទួយកិច្ចសហការជាមួយអ្នកពាក់ព័ន្ធ កសាងសមត្ថភាពមន្ត្រីនាយកដ្ឋាន គ្រប់គ្រងហិរញ្ញវត្ថុ អង្កេតតាមដានការងារផ្ទៃក្នុង និងគ្រប់គ្រងការងាររដ្ឋបាលនានា ដែលពាក់ព័ន្ធនឹង តួនាទីនិងភារកិច្ចរបស់នាយកដ្ឋាន
- សម្របសម្រួលនិងអនុវត្តលិខិតបទដ្ឋានគតិយុត្ត គោលនយោបាយ ផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាព កម្មវិធី និងគម្រោងនានា សម្រាប់កាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ និងការបន្សាំនឹងការប្រែប្រួលអាកាសធាតុ ព្រមទាំងពិនិត្យ តាមដាន វាយតម្លៃ និងធ្វើរបាយការណ៍ជាប្រចាំ
- សម្របសម្រួលការរៀបចំនិងគ្រប់គ្រងសារពើភ័ណ្ឌឧស្ម័នផ្ទះកញ្ចក់ របាយការណ៍ជាតិ និង ការអនុវត្តកាតព្វកិច្ចនានារបស់រាជរដ្ឋាភិបាល នៅក្រោមអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ
- សម្របសម្រួលផ្តល់ការគាំទ្របច្ចេកទេសក្នុងការធ្វើសារពើភ័ណ្ឌឧស្ម័នផ្ទះកញ្ចក់នៅតាមប្រភពបញ្ចេញនានា
- សម្របសម្រួលការវាយតម្លៃអំពីហានិភ័យ និងកាលានុវត្តភាពនានា ពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុ
- ពង្រឹងភាពជាដៃគូនិងកិច្ចសហប្រតិបត្តិការអន្តរជាតិ ដើម្បីកៀរគរធនធានសម្រាប់ឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ
- លើកសំណើបង្កើតនិងគ្រប់គ្រងមូលនិធិ ដើម្បីគាំទ្រដល់ការអនុវត្តគោលនយោបាយឆ្លើយតប នឹងការប្រែប្រួលអាកាសធាតុ
- រៀបចំបង្កើតនិងគ្រប់គ្រងប្រព័ន្ធព័ត៌មាននិងចំណេះដឹងស្តីពីការប្រែប្រួលអាកាសធាតុ
- ផ្សព្វផ្សាយវិធានការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុរបស់រាជរដ្ឋាភិបាល ជូនដល់សាធារណជនដៃគូអភិវឌ្ឍន៍ និងសហគមន៍អន្តរជាតិ
- បំពេញភារកិច្ចជាស្ថាប័នបង្គោលជាតិនៃអនុសញ្ញា ពិធីសារ និងកិច្ចព្រមព្រៀងអន្តរជាតិពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុ
- សម្របសម្រួលការងារជាមួយមន្ត្រីបង្គោលនៅតាមបណ្តាក្រសួង ស្ថាប័នពាក់ព័ន្ធ សម្រាប់ការងារប្រែប្រួលអាកាសធាតុ

- រៀបចំរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំ
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតតាមការប្រគល់ជូនពីអគ្គលេខាធិការ ក.ជ.អ.ច។

**នាយកដ្ឋានសេដ្ឋកិច្ចបៃតង** មានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

- រៀបចំសេចក្តីព្រាងលិខិតបទដ្ឋានគតិយុត្ត គោលនយោបាយ ផែនការយុទ្ធសាស្ត្រ ផែនការ និងថវិកា លើកស្ទួយកិច្ចសហការជាមួយអ្នកពាក់ព័ន្ធ កសាងសមត្ថភាពមន្ត្រីនាយកដ្ឋានគ្រប់គ្រងហិរញ្ញវត្ថុ អង្កេតតាមដានការងារផ្ទៃក្នុង និងគ្រប់គ្រងការងាររដ្ឋបាលនានា ដែលពាក់ព័ន្ធនឹង តួនាទីនិងភារកិច្ចរបស់នាយកដ្ឋាន
- សម្របសម្រួលនិងអនុវត្តលិខិតបទដ្ឋានគតិយុត្ត គោលនយោបាយ ផែនការយុទ្ធសាស្ត្រ ផែនការ
- សកម្មភាព កម្មវិធី និងគម្រោងនានា ដើម្បីគាំទ្រមាគ៌ាអភិវឌ្ឍន៍សេដ្ឋកិច្ចបៃតង ព្រមទាំងពិនិត្យតាមដាន វាយតម្លៃ និងធ្វើរបាយការណ៍ជាប្រចាំ
- សម្របសម្រួលការសិក្សាស្រាវជ្រាវអំពីផលប៉ះពាល់និងអត្ថប្រយោជន៍ជាក់ស្តែងនៃសកម្មភាពអភិវឌ្ឍន៍ មកលើសេដ្ឋកិច្ច បរិស្ថាន សង្គម និងវប្បធម៌
- សម្របសម្រួលការធ្វើគណនេយ្យមូលធនធម្មជាតិនិងការវាស់វែងផលិតផលបៃតងក្នុងស្រុកសរុប
- សម្របសម្រួលការសិក្សាសមិទ្ធិលទ្ធភាពនឹងរៀបចំបង្កើតយន្តការនៃការយកកម្រៃលើការបំពុល និងការទូទាត់សេវាបរិស្ថាន ព្រមទាំងសម្របសម្រួលតាមដាននិងវាយតម្លៃការអនុវត្តយន្តការ ទាំងនោះ
- សម្របសម្រួលការសិក្សានិងរៀបចំឧបករណ៍គាំទ្រដល់ការធ្វើសេចក្តីសម្រេចផ្សេងៗ ជាអាទិ៍ការវាយតម្លៃផលប៉ះពាល់ ការវិភាគពហុលក្ខណៈវិនិច្ឆ័យ ការវិភាគចំណេញ ខាត ដើម្បី រួមចំណែកដល់ការកែសម្រួល ឬ បង្កើតលិខិតបទដ្ឋានគតិយុត្ត គោលនយោបាយ ផែនការ យុទ្ធសាស្ត្រ ផែនការសកម្មភាព កម្មវិធី និងគម្រោងនានា
- សិក្សា ស្រាវជ្រាវ និងរៀបចំគោលនយោបាយនិងយន្តការនានាពាក់ព័ន្ធនឹងការប្រើប្រាស់ និង ការផលិតដោយនិរន្តរភាព ជាអាទិ៍ ការផ្តល់ស្លាកសញ្ញាបរិស្ថាន ការធ្វើលទ្ធកម្មសាធារណៈ បៃតង និងការផ្តល់វិញ្ញាបនបត្របៃតង ព្រមទាំងសម្របសម្រួល តាមដាន និងវាយតម្លៃ ការអនុវត្តនៃយន្តការទាំងនោះ
- វាស់វែងនិងតាមដានសូចនាករនៃការប្រើប្រាស់ និងការផលិតដោយនិរន្តរភាព ដើម្បីតម្រង់ទិសលើការរៀបចំកម្មវិធីនិងគម្រោងនានា សំដៅលើកកម្ពស់ការប្រើប្រាស់និងការផលិតដោយនិរន្តរភាព

- សម្របសម្រួលការរៀបចំនិងអនុវត្តលិខិតបទដ្ឋានគតិយុត្ត គោលនយោបាយ ផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាព កម្មវិធី និងគម្រោងនានា ដើម្បីជំរុញការអភិវឌ្ឍទីក្រុង និងតំបន់ជនបទ មាននិរន្តរភាព ព្រមទាំងពិនិត្យ តាមដាន វាយតម្លៃ និងធ្វើរបាយការណ៍ជាប្រចាំ
- កសាងនិងពង្រឹងកិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល វិស័យឯកជន គ្រឹះស្ថានសិក្សាស្រាវជ្រាវ និងអ្នកពាក់ព័ន្ធផ្សេងទៀត ដើម្បីគាំទ្រដល់ការអភិវឌ្ឍសេដ្ឋកិច្ចបៃតង
- ពង្រឹងភាពជាដៃគូនិងកិច្ចសហប្រតិបត្តិការអន្តរជាតិ ដើម្បីកៀរគរធនធានសម្រាប់អនុវត្តគោលនយោបាយ និងកម្មវិធីនានាពាក់ព័ន្ធនឹងការអភិវឌ្ឍសេដ្ឋកិច្ចបៃតង
- ផ្សព្វផ្សាយគោលនយោបាយ និងវិធានការនានារបស់រាជរដ្ឋាភិបាល ពាក់ព័ន្ធនឹងការអភិវឌ្ឍសេដ្ឋកិច្ចបៃតង ជូនដល់សាធារណជន ដៃគូអភិវឌ្ឍន៍ និងសហគមន៍អន្តរជាតិ
- សម្របសម្រួលការងារជាមួយមន្ត្រីបង្គោលនៅតាមបណ្តាក្រសួង ស្ថាប័នពាក់ព័ន្ធសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចបៃតង
- រៀបចំរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំ
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតតាមការប្រគល់ជូនពីអគ្គលេខាធិការ ក.ជ.អ.ច។

**នាយកដ្ឋានវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា** មានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

- រៀបចំសេចក្តីព្រាងលិខិតបទដ្ឋានគតិយុត្ត គោលនយោបាយ ផែនការយុទ្ធសាស្ត្រ ផែនការ ថវិកា លើកស្ទួយកិច្ចសហការជាមួយអ្នកពាក់ព័ន្ធ កសាងសមត្ថភាពមន្ត្រីនាយកដ្ឋាន គ្រប់គ្រង និងហិរញ្ញវត្ថុ អង្កេតតាមដានការងារផ្ទៃក្នុង និងគ្រប់គ្រងការងាររដ្ឋបាលនានាដែលពាក់ព័ន្ធនឹង តួនាទីនិងភារកិច្ចរបស់នាយកដ្ឋាន
- សម្របសម្រួលការរៀបចំគោលនយោបាយ និងកម្មវិធីនានា ដើម្បីគាំទ្រដល់ការស្រាវជ្រាវ ការអភិវឌ្ឍ និងការប្រើប្រាស់បច្ចេកវិទ្យា ទម្លាប់ប្រតិបត្តិ និងទម្រង់ដទៃទៀតនៃនវានុវត្តន៍សំដៅលើកកម្ពស់ការអភិវឌ្ឍដោយចីរភាព
- សម្របសម្រួលការសិក្សាស្រាវជ្រាវ ដើម្បីផ្តល់ព័ត៌មានវិទ្យាសាស្ត្រសម្រាប់រួមចំណែកដល់ការរៀបចំគោលនយោបាយនិងយន្តការនានាពាក់ព័ន្ធនឹងការអភិវឌ្ឍដោយចីរភាព
- សម្របសម្រួលការសិក្សានិងវាយតម្លៃស្តង់ដាបរិស្ថាន និងវឌ្ឍនភាពទៅរកការអភិវឌ្ឍដោយចីរភាព និងឱកាសសម្រាប់ការកែលម្អ ដោយផ្អែកលើភស្តុតាងវិទ្យាសាស្ត្រ
- សម្របសម្រួលនិងគាំទ្រដល់ដំណើរការនៃការបង្កើតវិធីសាស្ត្រសិក្សាស្រាវជ្រាវរួម ពាក់ព័ន្ធនឹងការអភិវឌ្ឍដោយចីរភាព

- កសាងនិងពង្រឹងកិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល វិស័យឯកជន គ្រឹះស្ថានសិក្សាស្រាវជ្រាវ និងអ្នកពាក់ព័ន្ធ ដើម្បីកៀរគរធនធាន និងការគាំទ្រ សម្រាប់ពង្រឹងសមត្ថភាពនិងលើកកម្ពស់ការសិក្សាស្រាវជ្រាវវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- លើកកម្ពស់ការយល់ដឹងរបស់សាធារណជន ពីតួនាទីវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ នៅក្នុងការជំរុញការអភិវឌ្ឍដោយចីរភាព
- រៀបចំបង្កើតក្រមសីលធម៌និងយន្តការសម្រាប់វាយតម្លៃការស្រាវជ្រាវ និងនវានុវត្តន៍ពាក់ព័ន្ធនឹងការអភិវឌ្ឍដោយជីរភាព
- សម្របសម្រួលការងារជាមួយមន្ត្រីបង្គោលនៅតាមបណ្ដាក្រសួង ស្ថាប័នពាក់ព័ន្ធសម្រាប់ការសិក្សាស្រាវជ្រាវវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- រៀបចំរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំ
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតតាមការប្រគល់ជូនពីអគ្គលេខាធិការ ក.ជ.អ.ច.។

**នាយកដ្ឋានជីវៈចម្រុះ ជាមជ្ឈមណ្ឌលជីវៈចម្រុះ** មានតួនាទីនិងភារកិច្ចដូចខាងក្រោមៈ

- រៀបចំសេចក្ដីព្រាងលិខិតបទដ្ឋានគតិយុត្តិ គោលនយោបាយ ផែនការយុទ្ធសាស្ត្រ ផែនការ និងថវិកា លើកស្ទួយកិច្ចសហការជាមួយអ្នកពាក់ព័ន្ធ កសាងសមត្ថភាពមន្ត្រី គ្រប់គ្រងហិរញ្ញវត្ថុ អង្កេតតាមដានការងារផ្ទៃក្នុង និងគ្រប់គ្រងការងាររដ្ឋបាលនានា ដែលពាក់ព័ន្ធនឹងតួនាទីនិងភារកិច្ចរបស់នាយកដ្ឋាន
- សម្របសម្រួលនិងអនុវត្តលិខិតបទដ្ឋានគតិយុត្ត គោលនយោបាយ ផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាព កម្មវិធី និងគម្រោងនានា សម្រាប់ធានាការការពារនិងការអភិរក្សធនធានជីវៈចម្រុះ និងប្រព័ន្ធអេកូឡូស៊ីឱ្យមាននិរន្តរភាព និងជីវសុវត្ថិភាព ព្រមទាំងពិនិត្យតាមដាន វាយតម្លៃ និងធ្វើរបាយការណ៍ជាប្រចាំ
- រៀបចំបង្កើតនិងគ្រប់គ្រងប្រព័ន្ធព័ត៌មាននិងចំណេះដឹងស្ដីពីធនធានជីវៈចម្រុះ ប្រព័ន្ធអេកូឡូស៊ី និងជីវសុវត្ថិភាព
- សិក្សានិងស្រាវជ្រាវផ្នែកវិទ្យាសាស្ត្របច្ចេកទេសនិងវាយតម្លៃអំពីធនធានជីវៈចម្រុះ ប្រព័ន្ធអេកូឡូស៊ី និងជីវសុវត្ថិភាព ដោយសហការជាមួយស្ថាប័នជាតិ វិស័យឯកជន និងគ្រឹះស្ថានសិក្សាស្រាវជ្រាវ
- កសាងនិងពង្រឹងកិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល វិស័យឯកជន គ្រឹះស្ថានសិក្សាស្រាវជ្រាវ និងភាគីពាក់ព័ន្ធផ្សេងទៀត ដើម្បីគាំទ្រដល់ការអភិរក្ស និងការគ្រប់គ្រងជីវៈចម្រុះ ប្រព័ន្ធអេកូឡូស៊ី និងជីវសុវត្ថិភាព

- ពង្រឹងភាពជាដៃគូនិងកិច្ចសហប្រតិបត្តិការអន្តរជាតិ ដើម្បីកៀរគរធនធានសម្រាប់អនុវត្តគោលនយោបាយនិងកម្មវិធីជាតិស្តីពីជីវៈចម្រុះនិងជីវសុវត្ថិភាព ក៏ដូចជាកិច្ចព្រមព្រៀងអន្តរជាតិស្តីពីជីវៈចម្រុះនិងពិធីសារនានា
- រៀបចំបង្កើតនិងគ្រប់គ្រងមធ្យោបាយដោយឡែកសម្រាប់ការគ្រប់គ្រងធនធានជីវៈចម្រុះ ប្រព័ន្ធអេកូឡូស៊ីនិងជីវសុវត្ថិភាព
- សហការរៀបចំបង្កើតនិងគ្រប់គ្រងរុក្ខឧទ្យា និងភូតគាម សម្រាប់ការអភិរក្សក្រៅតំបន់ និងអនុវត្តន៍កម្មវិធីគ្រប់គ្រងប្រភេទរងគ្រោះថ្នាក់ធ្ងន់ធ្ងរនិងប្រភេទបង្កគ្រោះថ្នាក់ដល់ជីវៈចម្រុះ ប្រព័ន្ធអេកូឡូស៊ី និងជីវសុវត្ថិភាព
- ផ្សព្វផ្សាយវិធានការនានារបស់រាជរដ្ឋាភិបាល ពាក់ព័ន្ធនឹងការងារគ្រប់គ្រងធនធានជីវៈចម្រុះ ប្រព័ន្ធអេកូឡូស៊ី និងជីវសុវត្ថិភាព ជូនដល់សាធារណជន ដៃគូអភិវឌ្ឍន៍ និងសហគមន៍អន្តរជាតិ
- វាយតម្លៃ គ្រប់គ្រង និងឃ្លាំមើលហានិភ័យពាក់ព័ន្ធនឹងការគ្រប់គ្រងចលនាឆ្លងដែននៃសារពាង្គកាយ កែច្នៃរស់ ដោយសហការជាមួយស្ថាប័នជាតិ វិស័យឯកជន និងគ្រឹះស្ថានសិក្សាស្រាវជ្រាវ
- សម្របសម្រួលការរៀបចំនិងគ្រប់គ្រងសារពើភ័ណ្ឌជីវៈចម្រុះ របាយការណ៍ជាតិ និងការអនុវត្តកាតព្វកិច្ចនានារបស់រាជរដ្ឋាភិបាល នៅក្រោមអនុសញ្ញាសហប្រជាជាតិស្តីពីជីវៈចម្រុះនិងពិធីសារ
- សម្របសម្រួលការងារជាមួយមន្ត្រីបង្គោលនៅតាមបណ្តាក្រសួង ស្ថាប័នពាក់ព័ន្ធ សម្រាប់ការងារគ្រប់គ្រងធនធានជីវៈចម្រុះ ប្រព័ន្ធអេកូឡូស៊ី និងជីវសុវត្ថិភាព
- បំពេញភារកិច្ចជាស្ថាប័នបង្គោលជាតិនៃអនុសញ្ញា ពិធីសារ និងកិច្ចព្រមព្រៀងអន្តរជាតិ ពាក់ព័ន្ធនឹងជីវៈចម្រុះ
- រៀបចំរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំ
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតតាមការប្រគល់ជូនពីអគ្គលេខាធិការ ក.ជ.អ.ច.។

## ១.៥ អវសានបញ្ញត្តិ

អនុក្រឹត្យនេះនិរាករណ៍អនុក្រឹត្យនិងសេចក្តីសម្រេចដូចខាងក្រោម៖

- អនុក្រឹត្យលេខ១៨៨ អនក្រ.បក ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០១២ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍បៃតង
- អនុក្រឹត្យលេខ៩៩ អនក្រ.បក ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០១០ ស្តីពីការបង្កើតគណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុ
- អនុក្រឹត្យលេខ៦៥ អនក្រ.បក ចុះថ្ងៃទី២ ខែឧសភា ឆ្នាំ២០១២ ស្តីពីការរៀបចំនិងការប្រព្រឹត្យទៅរបស់លេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិជីវសុវត្ថិភាព

– សេចក្តីសម្រេចលេខ១៦ ចុះថ្ងៃទី៣ ខែមេសា ឆ្នាំ២០០១ ស្តីពីការបង្កើតគណៈកម្មាធិការជាតិគ្រប់គ្រងជីវៈចម្រុះ។ បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួង បរិស្ថាន រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ ........ថ្ងៃទី ....... ខែ ........ឆ្នាំ២០១៥ អង្គការលេខរបស់អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិចឌ្ឍន៍ដោយចិរភាព



រូបភាព ៥ អង្គការលេខរបស់អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិចឌ្ឍន៍ដោយចិរភាព

## ២. ការរៀបចំ និងការប្រព្រឹត្តទៅរបស់នាយកដ្ឋានប្រែប្រួលអាកាសធាតុ នៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព

**សម្រេច**

ប្រការ១

ប្រកាសនេះកំណត់ការរៀបចំ និងការប្រព្រឹត្តទៅរបស់នាយកដ្ឋានប្រែប្រួលអាកាសធាតុ អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព។

ប្រការ ២

នាយកដ្ឋានប្រែប្រួលអាកាសធាតុ មាន ៥(ប្រាំ)ការិយាល័យ ដូចខាងក្រោម៖

– ការិយាល័យរដ្ឋបាល ផែនការ និងហិរញ្ញវត្ថុ
– ការិយាល័យគ្រប់គ្រងព័ត៌មានប្រែប្រួលអាកាសធាតុ
– ការិយាល័យសារពើភ័ណ្ឌ និងកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់

- ការិយាល័យវាយតម្លៃភាពងាយរងគ្រោះ និងការបន្សាំ
- ការិយាល័យគោលនយោបាយ និងសម្របសម្រួល។

បណ្ដាការិយាល័យ នៃនាយកដ្ឋានប្រែប្រួលអាកាសធាតុ ដឹកនាំដោយប្រធានមួយ អមដោយអនុប្រធានពី ២(ពីរ)រូបទៅ៤(បួន)រូប។

ប្រការ ៣

ការិយាល័យរដ្ឋបាល ផែនការ និងហិរញ្ញវត្ថុ មានតួនាទី និងភារកិច្ចដូចខាងក្រោម៖

- សម្របសម្រួលការរៀបចំផែនការការងារ ផែនការថវិកាផែនការបេសកកម្ម និងការអង្កេតតាមដានការអនុវត្តផែនការរបស់នាយកដ្ឋាន
- គ្រប់គ្រងលិខិតចេញ-ចូលក្នុងនាយកដ្ឋាន
- គ្រប់គ្រងឯកសារ និងលិខិតរដ្ឋបាលរបស់នាយកដ្ឋាន
- គ្រប់គ្រងការងារបេសកកម្មក្នុង និងក្រៅប្រទេសរបស់នាយកដ្ឋាន
- រៀបចំបទបញ្ជាផ្ទៃក្នុង ធានាសន្តិសុខសណ្ដាប់ធ្នាប់ក្នុងនាយកដ្ឋាន
- ផ្សព្វផ្សាយគោលនយោបាយច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ សារាចរ សេចក្តីប្រកាស និង ព័ត៌មានផ្សេងៗ ដល់គ្រប់ការិយាល័យក្នុងនាយកដ្ឋាន
- ធ្វើកំណត់បង្ហាញសំណុំឯកសារផ្សេងៗរបស់នាយកដ្ឋាន រៀបចំកម្មវិធីប្រជុំ ការណាត់ជួបការងាររបស់ថ្នាក់ដឹកនាំនាយកដ្ឋាន
- ចូលរួមប្រជុំ ធ្វើកំណត់ហេតុបាយការណ៍ និងចុះបេសកកម្មជាមួយថ្នាក់ដឹកនាំ តាមការចាំបាច់
- ស្រាវជ្រាវ តាមដាន និងចងក្រងរាល់ព្រឹត្តិការណ៍ដែលទាក់ទងការងារនាយកដ្ឋាន
- គ្រប់គ្រងការងារមន្ត្រីរាជការ គ្រប់គ្រងវត្តមានមន្ត្រីរាជការ និងបុគ្គលិកជាប់កិច្ចសន្យា
- គ្រប់គ្រងបែបបទសុំតម្លើងកាំប្រាក់បៀវត្ស ឋានន្តរសក្តិ លិខិត/បណ្ណសរសើរ និងគ្រឿងឥស្សរិយយសរបស់មន្ត្រីរាជការ
- សម្របសម្រួលលើកគម្រោងតម្រូវការក្របខណ្ឌជំនាញ
- គ្រប់គ្រងសម្ភារៈការិយាល័យ ឧបករណ៍ គ្រឿងសង្ហារឹម បន្ទប់ការិយាល័យ មធ្យោបាយធ្វើដំណើរ និងធ្វើបញ្ជីសារពើភ័ណ្ឌ និងលើកសំណើស្នើសុំតាមការចាំបាច់
- ធ្វើទំនាក់ទំនងជាមួយស្ថាប័នពាក់ព័ន្ធ អង្គការជាតិ-អន្តរជាតិ និងដៃគូអភិវឌ្ឍន៍នានា
- រៀបចំ និងសម្របសម្រួលការងាររដ្ឋបាលនៃកិច្ចប្រជុំ សិក្ខាសាលា វគ្គបណ្តុះបណ្តាល វេទិកា យុទ្ធនាការ និងទិវានានា
- គ្រប់គ្រងហិរញ្ញវត្ថុ អង្កេតតាមដានការងារផ្ទៃក្នុង រួមមាន ចំណូល-ចំណាយនានារបស់នាយកដ្ឋាន

- រៀបចំរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំ
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀត តាមការប្រគល់ជូនរបស់ប្រធាននាយកដ្ឋាន។

ប្រការ ៤

ការិយាល័យគ្រប់គ្រងព័ត៌មានប្រែប្រួលអាកាសធាតុ មានតួនាទី និងភារកិច្ចដូចខាងក្រោម៖

- រៀបចំផែនការការងារ និងផែនការថវិការបស់ការិយាល័យ
- សហការជាមួយការិយាល័យជំនាញក្នុងការរៀបចំ និងអនុវត្តកម្មវិធីអប់រំ ផ្សព្វផ្សាយ បណ្តុះបណ្តាល
- ផ្សព្វផ្សាយសកម្មភាពអនុវត្តអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ កិច្ចព្រមព្រៀង និងពិធីសារនានា ដែលពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុ
- រៀបចំ បង្កើត និងគ្រប់គ្រងប្រព័ន្ធព័ត៌មាន និងចំណេះដឹងស្តីការប្រែប្រួលអាកាសធាតុ ផ្សព្វផ្សាយវិធានការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ
- សហការជាមួយការិយាល័យជំនាញក្នុងការរៀបចំឯកសារ សម្ភារៈឧបទ្ទេស និងមធ្យោបាយសម្រាប់បណ្តុះបណ្តាល អប់រំ និងផ្សព្វផ្សាយ ដែលទាក់ទងនឹងការប្រែប្រួល អាកាសធាតុ
- គ្រប់គ្រង និងធ្វើបច្ចុប្បន្នភាពគេហទំព័រ និងបណ្តាញសង្គមរបស់នាយកដ្ឋាន
- រៀបចំ និងគ្រប់គ្រងបណ្ណាល័យរបស់នាយកដ្ឋាន
- សហការជាមួយការិយាល័យជំនាញ ក្នុងការរៀបចំវគ្គបណ្តុះបណ្តាល និងយុទ្ធនាការផ្សព្វ ផ្សាយនានា ស្តីពីការប្រែប្រួលអាកាសធាតុ
- បំពេញតួនាទីជាស្ថាប័នបង្គោលនៃមាត្រា៦ របស់អនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ
- រៀបចំរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំ
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀត តាមការប្រគល់ជូនរបស់ប្រធាននាយកដ្ឋាន។

ប្រការ ៥

ការិយាល័យសារពើភ័ណ្ឌ និងកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់ មានតួនាទី និងភារកិច្ចដូចខាងក្រោម៖

**រៀបចំផែនការការងារ និងផែនការថវិការបស់ការិយាល័យ**

- សម្របសម្រួល រៀបចំ និងគ្រប់គ្រងប្រព័ន្ធសារពើភ័ណ្ឌឧស្ម័នផ្ទះកញ្ចក់ជាតិ
- ផ្តល់ការគាំទ្របច្ចេកទេសក្នុងការធ្វើសារពើភ័ណ្ឌ និងការគណនាការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ នៅតាមប្រភពបញ្ចេញ និងប្រភពស្រូបនានា
- ដឹកនាំការរៀបចំគោលនយោបាយឥណទានកាបូនជាតិ ដោយសហការជាមួយស្ថាប័នពាក់ព័ន្ធ
- សិក្សាវាយតម្លៃសក្តានុពលកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ និងជំរុញការអនុវត្តគម្រោងកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់នៅព្រះរាជាណាចក្រកម្ពុជា
- ចូលរួមរៀបចំរបាយការណ៍ជាតិ ក្រោមអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ ដែលពាក់ព័ន្ធនឹងការរៀបចំសារពើភ័ណ្ឌ និងការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់
- ជំរុញការបញ្ជ្រាបការងារកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ ទៅក្នុងផែនការអភិវឌ្ឍន៍ថ្នាក់ជាតិ ក្រោមជាតិ និងផែនការតាមវិស័យ
- ប្រមូល ចងក្រង និងគ្រប់គ្រងទិន្នន័យពាក់ព័ន្ធនឹងការរៀបចំសារពើភ័ណ្ឌ និងការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់
- លើកសំណើគម្រោង និងកម្មវិធីនានា ព្រមទាំងកៀរគរធនធានសម្រាប់គាំទ្រការសិក្សាស្រាវ ជ្រាវការរៀបចំសារពើភ័ណ្ឌ និងការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់តាមវិស័យនានា
- ពិនិត្យ តាមដានវាយតម្លៃ និងធ្វើរបាយការណ៍ជាប្រចាំអំពីការអនុវត្តគម្រោង កម្មវិធី និងគោលនយោបាយ ទាក់ទងនឹងការងារសារពើភ័ណ្ឌ និងការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់
- បំពេញតួនាទីជាស្ថាប័នបង្គោល និងលេខាធិការដ្ឋាន សម្រាប់ការអនុវត្តគម្រោង និងកម្មវិធីទាក់ទងនឹងការកាត់បន្ថយការបរញ្ចេញឧស្ម័នផ្ទះកញ្ចក់
- រៀបចំរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំ
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតតាមការប្រគល់ជូនរបស់ប្រធាននាយកដ្ឋាន។

ប្រការ ៦

ការិយាល័យវាយតម្លៃភាពងាយរងគ្រោះ និងការបន្សាំ មានតួនាទី និងភារកិច្ចដូចខាងក្រោម៖

- ធ្វើផែនការការងារ និងផែនការថវិការបស់ការិយាល័យ
- សម្របសម្រួលការវាយតម្លៃអំពីហានិភ័យ ភាពងាយរងគ្រោះ និងកាលានុវត្តភាពនានា ពាក់ព័ន្ធនឹងការបន្សាំ និងភាពធន់នឹងការប្រែប្រួលអាកាសធាតុ

- ចូលរួមរៀបចំរបាយការណ៍ជាតិ ក្រោមអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្ដីពីការប្រែប្រួលអាកាសធាតុ ដែលពាក់ព័ន្ធនឹងការវាយតម្លៃភាពងាយរងគ្រោះ និងការបន្សាំ
- ជំរុញការបញ្ជ្រាបប្រការងារការបន្សាំ និងភាពធន់នឹងការប្រែប្រួលអាកាសធាតុទៅក្នុងផែនការអភិវឌ្ឍន៍ថ្នាក់ជាតិ ក្រោមជាតិ និងផែនការតាមវិស័យ
- ប្រមូល ចងក្រង និងគ្រប់គ្រងទិន្នន័យពាក់ព័ន្ធនឹងភាពងាយរងគ្រោះ ភាពធន់ និងការបន្សាំនឹងការប្រែប្រួលអាកាសធាតុ
- លើកសំណើគម្រោង និងកម្មវិធីនានា ដែលពាក់ព័ន្ធនឹងការសិក្សាស្រាវជ្រាវ ភាពធន់ និង ការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ តាមវិស័យនានា
- ពិនិត្យ តាមដានវាយតម្លៃ និងធ្វើរបាយការណ៍ជាប្រចាំចំពោះការអនុវត្តសកម្មភាពគម្រោង និងកម្មវិធី ដែលទាក់ទងនឹងហានិភ័យ ភាពធន់ និងការបន្សាំនឹងការប្រែប្រួលអាកាសធាតុ
- រៀបចំរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំ
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតតាមការប្រគល់ជូនរបស់ប្រធាននាយកដ្ឋាន។

ប្រការ ៧

ការិយាល័យគោលនយោបាយ និងសម្របសម្រួល មានតួនាទី និងភារកិច្ចដូចខាងក្រោម ៖

- ធ្វើផែនការការងារ និងផែនការថវិការបស់ការិយាល័យ
- សម្របសម្រួលការរៀបចំគោលនយោបាយ លិខិតបទដ្ឋានគតិយុត្ត ផែនការយុទ្ធសាស្រ្ត ដោយសហការនិងផែនការសកម្មភាពនានាពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុជាមួយស្ថាប័នពាក់ព័ន្ធ
- ពិនិត្យតាមដានវាយតម្លៃ និងធ្វើរបាយការណ៍ជាប្រចាំចំពោះការអនុវត្តគោលនយោបាយ លិខិតបទដ្ឋានគតិយុត្ត ផែនការយុទ្ធសាស្រ្ត និងផែនការសកម្មភាពនានា ពាក់ព័ន្ធនឹងការ ប្រែប្រួលអាកាសធាតុ ដោយសហការជាមួយស្ថាប័នពាក់ព័ន្ធ
- សម្របសម្រួលការរៀបចំ និងគ្រប់គ្រងក្របខ័ណ្ឌហិរញ្ញប្បទានប្រែប្រួលអាកាសធាតុ
- សម្របសម្រួលការរៀបចំរបាយការណ៍ជាតិ និងការអនុវត្តកាតព្វកិច្ចនានារបស់កម្ពុជា នៅក្រោមអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិ ស្ដីពីការប្រែប្រួលអាកាសធាតុ
- សម្របសម្រួលជាមួយមន្ត្រីបង្គោល និងក្រុមការងារប្រែប្រួលអាកាសធាតុ នៅតាមបណ្ដា ក្រសួងស្ថាប័នពាក់ព័ន្ធ
- កៀរគរធនធាន ពិសេសជំនួយឥតសំណង សម្រាប់អនុវត្តគោលនយោបាយ ផែនការយុទ្ធសាស្រ្តផែនការសកម្មភាព កម្មវិធី និងគម្រោងនានា ពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុ
- ជំរុញកិច្ចសហការជាមួយស្ថាប័នពាក់ព័ន្ធជាតិ និងអន្តរជាតិ ក្នុងការអនុវត្តវិធានការឆ្លើយ តបនឹងការប្រែប្រួលអាកាសធាតុ

- រៀបចំរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំ
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតតាមការប្រគល់ជូនរបស់ប្រធាននាយកដ្ឋាន។

ប្រការ ៨

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

ប្រការ ៩

អគ្គលេខាធិការក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋានចំណេះដឹង និងព័ត៌មានបរិស្ថាន អគ្គនាយកនៃអគ្គនាយកដ្ឋានគាំពារ បរិស្ថាន អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាលការពារ និងអភិរក្សធម្មជាតិ អគ្គាធិការនៃអគ្គាធិការដ្ឋាន នាយកដ្ឋានសវនកម្មផ្ទៃក្នុង នាយកខុទ្ទកាល័យ គ្រប់ប្រធានអង្គភាពចំណុះក្រសួងបរិស្ថាន ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។




រូបភាព ៦ អង្គការលេខរបស់នាយកដ្ឋានប្រែប្រួលអាកាសធាតុ

## ៣. ការបង្កើតក្រុមការងារបច្ចេកទេសសម្របសម្រួលអាកាសធាតុ

**រដ្ឋមន្ត្រីក្រសួងបរិស្ថាន**

**និងជាប្រធានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព CCTWG**

**សម្រេច**

ប្រការ១

ត្រូវបានបង្កើតក្រុមការងារបច្ចេកទេសប្រែប្រួលអាកាសធាតុ ដែលសរសេរជាអក្សរកាត់ថា ក.ប.ប.អ. និងជាភាសាអង់គ្លេសថា Climate Change Technical Working Group (CCTWG) ដើម្បីសម្របសម្រួលនឹង គាំទ្រផ្នែកបច្ចេកទេសដល់ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព(ក.ជ.អ.ច.) ក្នុងការដោះស្រាយបញ្ហា ប្រែប្រួលអាកាសធាតុក្នុងព្រះរាជាណាចក្រកម្ពុជា។

ប្រការ២

ក.ប.ប.អ មានសមាសភាពដូចខាងក្រោម៖

| | |
|---|---|
| ១. ឯកឧត្តម ជួប ប៉ារីស៍ អគ្គលេខាធិការរង អគ្គលេខាធិការដ្ឋាន អ.ជ.អ.ច | ប្រធាន |
| ២. ប្រធាននាយកដ្ឋានប្រែប្រួលអាកាសធាតុ អគ្គលេខាធិការដ្ឋាន ក.ជ.អ.ច. | អនុប្រធានទី១ |
| ៣. ប្រធាននាយកដ្ឋានអភិរក្សសមុទ្រនិងតំបន់ឆ្នេរ ក្រសួងបរិស្ថាន | អនុប្រធានទី២ |
| ៤. ទីប្រឹក្សា គ.ជ.គ.ម. និងជា អនុប្រធាននាយកដ្ឋានត្រៀមរៀបចំនិងបណ្តុះបណ្តាល គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ | សមាជិក |
| ៥. អគ្គនាយករង អគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ គ្រប់គ្រងបំណុល ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | សមាជិក |
| ៦. អគ្គនាយករង អគ្គនាយកដ្ឋានទេសចរណ៍ ក្រសួងទេសចរណ៍ | សមាជិក |
| ៧. អគ្គនាយករង អគ្គនាយកដ្ឋានឧស្សាហកម្ម ក្រសួងឧស្សាហកម្មនិងសិប្បកម្ម | សមាជិក |
| ៨. ប្រធាននាយកដ្ឋានគ្រប់គ្រងគុណភាពខ្យល់និងសំឡេង ក្រសួងបរិស្ថាន | សមាជិក |
| ៩. ប្រធាននាយកដ្ឋានផែនការវិនិយោគ ក្រសួងផែនការ | សមាជិក |
| ១០. ប្រធាននាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា ក្រសួងអប់រំ យុវជន និងកីឡា | សមាជិក |
| ១១. ប្រធាននាយកដ្ឋានការពារសុខភាព ក្រសួងសុខាភិបាល | សមាជិក |
| ១២. ប្រធាននាយកដ្ឋានផែនការ ក្រសួងសាធារណការនិងដឹកជញ្ជូន | សមាជិក |
| ១៣. ប្រធាននាយកដ្ឋានគោលនយោបាយ និងសម្របសម្រួលសមាជិក ហិញ្ញប្បទានសហប្រតិបត្តិការ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | សមាជិក |
| ១៤. ប្រធាននាយកដ្ឋានវាយតម្លៃខាងបរិស្ថាន ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | សមាជិក |

១៥. ប្រធានវិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍ព្រៃឈើ-សត្វព្រៃ សមាជិក
ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
១៦. អនុប្រធាននាយកដ្ឋានគ្រប់គ្រងធនធានដីកសិកម្ម សមាជិក
ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
១៧. អនុប្រធានវិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍ជលផលទឹកសាបសមាជិក សមាជិក
ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
១៨. អនុប្រធាននាយកដ្ឋានរដ្ឋបាលនិងព័ត៌មានវិទ្យា ក្រសួងរ៉ែនិងថាមពល សមាជិក
១៩. អនុប្រធាននាយកដ្ឋានគ្រប់គ្រងនិងអភិរក្សធនធាន សមាជិក
ក្រសួងធនធានទឹកនិងឧតុនិយម
២០. អនុប្រធាននាយកដ្ឋានអភិវឌ្ឍន៍សហគមន៍ ក្រសួងអភិវឌ្ឍន៍ជនបទ សមាជិក
២១. អនុប្រធាននាយកដ្ឋានស្រាវជ្រាវនិងបទប្បញ្ញត្តិ សមាជិក
ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ សមាជិក
២២. អនុប្រធាននាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ ក្រសួងព័ត៌មាន សមាជិក
២៣. អនុប្រធាននាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ ក្រសួងកិច្ចការនារី សមាជិក
២៤. អនុប្រធានអង្គភាពគ្រប់គ្រងនិងគាំទ្រកម្មវិធី សមាជិក
លេខាធិការដ្ឋានគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍ តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
២៥. អនុប្រធាននាយកដ្ឋានប្រែប្រួលអាកាសធាតុ អគ្គលេខាធិការដ្ឋាន ក.ជ.អ.ច. សមាជិកអចិន្ត្រៃយ៍។

ប្រការ៣
សមាជិក ក.ប.ប.អ. មានភារកិច្ចដូចខាងក្រោម៖

- បញ្ជ្រាបការប្រែប្រួលអាកាសធាតុទៅក្នុងបទដ្ឋានគតិយុត្តនិងបទប្បញ្ញត្តិថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ ឬតាមវិស័យ ដែលកំពុងរៀបចំឬកែសម្រួល
- ផ្តល់ធាតុចូលសំខាន់ៗដល់ការរៀបចំផលិតផលចំណេះដឹង សម្ភារៈឧបទ្ទេស និងចែករំលែក មេរៀនបទពិសោធន៍ក្នុងការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុក្នុងវិស័យរបស់ខ្លួន និងចូលរួមក្នុងការសិក្សាស្រាវជ្រាវទាក់ទងនឹងការប្រែប្រួលអាកាសធាតុ
- បញ្ជ្រាបការប្រែប្រួលអាកាសធាតុទៅក្នុងសកម្មភាពត្រួតពិនិត្យនិងវាយតម្លៃក្នុងវិស័យរបស់ខ្លួន
- ចូលរួមពិនិត្យនិងពង្រឹងក្របខណ្ឌត្រួតពិនិត្យនិងវាយតម្លៃការប្រែប្រួលអាកាសធាតុក្នុងវិស័យរបស់ខ្លួន

– វិភាគនិងផ្សព្វផ្សាយលទ្ធផលនិងអនុសាសន៍ ពីការត្រួតពិនិត្យនិងវាយតម្លៃវិធានការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុនៅថ្នាក់ជាតិនិងថ្នាក់វិស័យ សំដៅពង្រីកវិសាលភាពការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ
– ចូលរួមរៀបចំបាយការណ៍ប្រចាំឆ្នាំ អំពីសូចនាករទាក់ទងនឹងការប្រែប្រួលអាកាសធាតុ ដូចមាននៅក្នុងក្របខណ្ឌ ត្រួតពិនិត្យនិងវាយតម្លៃនៅថ្នាក់ជាតិនិងថ្នាក់វិស័យ ផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិ និងនៅក្នុងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព
– ចូលរួមក្នុងការរៀបចំបាយការណ៍ជាទៀងទាត់ អំពីការអនុវត្តផែនការយុទ្ធសាស្រ្តឆ្លើយតបនឹង ការប្រែប្រួលអាកាសធាតុកម្ពុជា និងផែនការយុទ្ធសាស្រ្តនិងសកម្មភាពឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុតមវិស័យ
– សហការនិងចែករំលែកព័ត៌មាននិងទិន្នន័យ ដើម្បីរៀបចំរបាយការណ៍ជាតិ សារពើភ័ណ្ឌឧស្ម័នផ្ទះកញ្ចក់ និងរបាយការណ៍ផ្សេងទៀត តាមតម្រូវការរបស់អនុសញ្ញាក្របខណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ( LNFCCC ) និងដើម្បីជាព័ត៌មានដល់ការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ
– ពិនិត្យនិងផ្តល់អនុសាសន៍ លើការរៀបចំរបាយការណ៍ជាតិនានា រាប់បញ្ចូលទាំងរបាយការណ៍សម្រាប់UNFCCC
– ចូលរួមវាយតម្លៃផ្នែកបច្ចេកទេសនៃគម្រោងហិរញ្ញវត្ថុអាកាសធាតុតមការអញ្ជើញរបស់ប្រធាន
– ចូលរួមក្នុងការកៀរគរធនធានសម្រាប់ការឆ្លើយតបដោយប្រសិទ្ធភាព ទៅនឹងការប្រែប្រួលអាកាស ធាតុ តាមរយៈការពិភាក្សាគោលនយោបាយនិងការសម្របសម្រួលជាមួយម្ចាស់ជំនួយ វិស័យឯក ជន និងអង្គការសង្គមស៊ីវិលយ៉ាងទៀងទាត់
– ផ្តល់ព័ត៌មានអំពីការចំណាយសាធារណៈលើការប្រែប្រួលអាកាសធាតុ និងកំណត់អត្តសញ្ញាណតម្រូវការនិងកាលានុវត្តភាពសម្រាប់ហិរញ្ញប្បទានប្រែប្រួលអាកាសធាតុ
– ចូលរួមនិងសម្របសម្រួលដំណើរការវាយតម្លៃសមត្ថភាពនិងការកសាងសមត្ថភាព ក្នុងវិស័យពាក់ព័ន្ធ ដើម្បីពង្រឹងការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុនៅថ្នាក់ខេតិ ថ្នាក់វិស័យ និងថ្នាក់ក្រោមជាតិ
– ចូលរួមកំណត់តម្រូវការនិងកាលានុវត្តភាពនៃបន្ទោរនិងអភិវឌ្ឍន៍បច្ចេកវិទ្យា ការអនុវត្តសាកល្បងបច្ចេកវិទ្យានវានុវត្ត និងការផ្សព្វផ្សាយព័ត៌មានទាក់ទងនឹងការប្រែប្រួលអាកាសធាតុ ដើម្បីជួយដល់ការពង្រីកការឆ្លើយតបនឹងការប្រែប្រួពរអាកាសធាតុ
– ចូលរួមនិងសម្របសម្រួលសកម្មភាពលើកកម្ពស់ការយល់ដឹងនិងការផ្សព្វផ្សាយអំពីការឆ្លើយតបជាតិទៅនឹងការប្រែប្រួលអាកាសធាតុដល់សាធារណជន ដៃគូអភិវឌ្ឍសហគមន៍អន្តរជាតិ និងភាគីពាក់ព័ន្ធផ្សេងៗ

- ចូលរួមកំណត់អាទិភាពនិងរៀបចំផែនការការងារសម្រាប់ ក.ប.ប.អ.
- ដើរតួជាជនបង្គោលបច្ចេកទេសតាមស្ថាប័នរបស់ខ្លួន ដើម្បីសម្របសម្រួលដល់ការពិនិត្យ ការចងក្រង និងការអនុវត្តគោលនយោបាយ យុទ្ធសាស្ត្រ ផែនការសកម្មភាព និងកម្មវិធី សំដៅពង្រឹងការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ
- សម្របសម្រួលនិងរាយការណ៍ជាទៀងទាត់ជូនសមាជិក ក.ជ.អរ.ច. តាមស្ថាប័នរបស់ខ្លួន។

ប្រការ៤

ក.ប.ប.អ. ត្រូវរៀបចំប្រជុំជាទៀងទាត់ ចំនួន ២ដង ក្នុង១ឆ្នាំ ដើម្បីពិនិត្យពីវឌ្ឍនភាពនិងរៀបចំផែនការ។ ប្រធានក.ប.ប.អ. អាចកោះប្រជុំបន្ថែមតាមការចាំបាច់។ សមាជិក ក.បប.អ. ក៏ត្រូវចូលរួមក្នុងក្រុម ការងារពិសេសដែលបង្កើតឡើងដោយ ក.ប.ប.អ. តាមការស្នើសុំរបស់ប្រធាន។

ក្នុងករណីប្រធានអវត្តមាន អនុប្រធានមួយរូបត្រូវដឹកនាំប្រជុំជំនួស តាមការប្រគល់សិទ្ធិពីប្រធាន។ សមាជិក ក.ប.ប.អ. អាចផ្តល់សិទ្ធទៅអ្នកជំនួសរបស់ខ្លួនពេលអវត្តមាន ដោយជូនដំណឹងទៅប្រធានជាមុន។

តំណាងអង្គការជាតិនិងអង្គការអន្តរជាតិពាក់ព័ន្ធ អាចចូលរួមប្រជុំជាអ្នកសង្កេតការណ៍ តាមការអញ្ជើញរបស់ប្រធានឬអនុប្រធាន។ សមាជិក ក.ប.ប.56. មានសិទ្ធិស្នើទៅប្រធាន ដើម្បីឱ្យតំណាងអង្គការ ជាតិនិងអង្គការអន្តរជាតិពាក់ព័ន្ធ បានចូលរួមប្រជុំជាអ្នកសង្កេតការណ៍។

នាយកដ្ឋានប្រែប្រួលអាកាសធាតុនៃអគ្គលេខាធិការដ្ឋាន ក.ជអច. ត្រូវដើរតួនាទីជាលេខាធិការដ្ឋាននៃ ក.ប.ប.អ។

ប្រការ៥

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

ប្រការ៦

ក្រសួងស្ថាប័នពាក់ព័ន្ធ សមាជិក ក.ជ.អ.ច. ដែលមានសមាជិកក្នុងស្ថាប័នរបស់ខ្លួនដូចមានចែងក្នុងប្រការ២ អគ្គលេខាធិការ ប្រធាននាយកដ្ឋានប្រែប្រួលអាកាសធាតុ និងប្រធាននាយកដ្ឋានផែនការ រដ្ឋបាល និងហិរញ្ញវត្ថុ នៃអគ្គលេខាធិការដ្ឋាន ក.ជ.អ.ច និងសាមីខ្លួនដូចមានចែងក្នុងប្រការ២ ត្រូវអនុវត្តសេចក្តី សម្រេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ ឧសភា ឆ្នាំ២០១៧

រដ្ឋមន្ត្រីក្រសួងបរិស្ថាន និងជាប្រធានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព

# មេរៀនទី ៣ គ្រឹះស្ថានអប់រំ និងស្រាវជ្រាវ និងវិស័យឯកជន

ការយល់ដឹងពីភាពពាក់ព័ន្ធនៃ "ការប្រែប្រួលអាកាសធាតុ" នៅក្នុងកម្មវិធីសិក្សា។ យោងទៅតាមទិន្នន័យដែលប្រមូលបានពីស្ថាប័ននានា ទំនងជាមាន វគ្គសិក្សាដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុនៅក្នុងកម្រិតខុសគ្នា។ លទ្ធផល ទទួលបានពីស្ថាប័នចំនួន ២៩ ដែលបានចូលរួមក្នុងការអង្កេតនេះ មាន ២០ ស្ថាប័នបាន ផ្តល់វគ្គសិក្សាអំពីការប្រែប្រួលអាកាសធាតុ។ មានតែស្ថាប័នចំនួន ២ ប៉ុណ្ណោះនៅក្នុងប្រទេសកម្ពុជា និងឡាវដែលមានផ្តល់នូវកម្មវិធីសិក្សាអំពីការប្រែប្រួលអាកាសធាតុនៅ កម្រិតបរិញ្ញាបត្រជាន់ខ្ពស់ នៅសាកលវិទ្យាល័យជាតិឡាវ មានកម្មវិធីថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់អំពីការប្រែប្រួលអាកាសធាតុលើសពីមួយ គឺថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងព្រៃឈើសម្រាប់ការបន្សាំ និងកាត់បន្ថយការប្រែប្រួលអាកាសធាតុ និង បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកការប្រែប្រួលអាកាសធាតុសម្រាប់ការអភិវឌ្ឍជនបទ។ លើសពីនេះ សាកលវិទ្យាល័យភូមិន្ទភ្នំពេញនៅកម្ពុជា បានចាប់ផ្តើមថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ នៅ ឆ្នាំ ២០១៧ ដែលមានឈ្មោះថា "បរិញ្ញាបត្រជាន់ខ្ពស់វិទ្យាសាស្ត្រការប្រែប្រួលអាកាសធាតុ" ។

វគ្គសិក្សាដែលមាននៅ ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ និងថ្នាក់បរិញ្ញាបត្រផ្សេងៗត្រូវបាន ចុះបញ្ជីដូចខាងក្រោម។ វគ្គ សិក្សាមួយចំនួនត្រូវបានផ្តល់ជូនដោយស្ថាប័នលើសពីមួយ

- ✓ សេចក្តីផ្តើមពីការប្រែប្រួលអាកាសធាតុ
- ✓ ការបន្សាំ និងកាត់បន្ថយការប្រែប្រួលអាកាសធាតុ
- ✓ ការវាយតម្លៃផលប៉ះពាល់ បរិស្ថាននៅក្នុងកម្មវិធីជលផលនិងព្រៃឈើ

នៅក្នុងប្រទេសកម្ពុជាមានឯកសារបទបង្ហាញ ស្លាយ Power Point និងវីដេអូដែលទាក់ទងទៅនឹងមុខវិជ្ជាទាំងនោះត្រូវបានផ្តល់ឱ្យ សិស្ស។ លើសពីនេះ នៅស្ថាប័នមួយចំនួនសិស្សត្រូវបានឱ្យចូលអនុវត្តន៍នៅក្នុងមន្ទីរពិសោធន៍មួយចំនួននិងបន្ទប់កុំព្យូទ័រក្នុងកំឡុងពេលសិក្សា។ ជាពិសេសសាកលវិទ្យាល័យបាត់ដំបងក្នុងប្រទេសកម្ពុជាក្នុងការសិក្សាជាក់ស្តែងមួយស្តីអំពីផលប៉ះពាល់កំដៅលើ ត្រី ប្រព័ន្ធប្រដាប់បម្លែងធ្យូងថ្ម ប្រដាប់ស្ទង់បង្ហូរទឹក ជាដើមត្រូវបានប្រើប្រាស់។

## ប្រទេសកម្ពុជា៖ អាជ្ញាធរជាតិ និងវិស័យឯជន

ការពិភាក្សាជាមួយតំណាងមកពីនាយកដ្ឋានការប្រែប្រួលអាកាសធាតុចំនួន ១២ នាក់ នៃក្រសួងបរិស្ថានព្រមទាំងតំណាងដែលអញ្ជើញមកពីវេទិកានៃអង្គការក្រៅរដ្ឋាភិបាលស្តីពីកម្ពុជាចំនួន ១៤ នាក់បានចូលរួមការពិភាក្សាក្រុម។ ការពិភាក្សាត្រូវបានបែងចែកជាបីក្រុម ដូចនេះការបង្ហាញ ពីទិន្នន័យនឹងត្រូវបានដាក់តាមលំដាប់លំដោយដូចខាងក្រោម៖

## ទស្សនៈការយល់ឃើញ និងការផ្សព្វផ្សាយ

យោងទៅលើការពិភាក្សារបស់តំណាងក្រុមនីមួយៗ "អាជ្ញាធរមូលដ្ឋាន" និង "វិស័យឯកជន" នៅក្នុងប្រទេសកម្ពុជា ការប្រែប្រួលអាកាសធាតុត្រូវបានគេដឹងថា ជាបាតុភូតពិតប្រាកដមួយដែលគ ចាត់ទុកថាបានផ្តល់ផលលំបាកជាច្រើនដូចជា៖ ការកើនឡើងនៃសីតុណ្ហភាព ការប្រែប្រួលរបប ទឹកភ្លៀង ការកើនឡើងកម្ពស់ទឹកសមុទ្រ និងការកើនឡើងទឹកប្រៃនៅតំបន់មាត់សមុទ្រ និង ព្រឹត្តិការណ៍ធាតុអាកាសធាតុធ្ងន់ធ្ងរនានាដូចជា៖ គ្រោះទឹកជំនន់ ភាពរាំងស្ងួត និងខ្យល់ព្យុះជា ដើម។ ផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុបានប៉ះពាល់ដល់វិស័យសំខាន់ៗដែលជួយដល់ សេដ្ឋកិច្ចជាតិ ជាពិសេសសង្គមដែលងាយនឹងទទួលរងគ្រោះ ដែលបណ្តាលឱ្យមានការពន្យា ពេលដល់ស្ថេរភាពសេដ្ឋកិច្ច នៅក្នុងប្រទេស និងការប្រកួតប្រជែងនៅកម្រិតអន្តរជាតិ វិស័យ ដែលទទួលរងគ្រោះខ្លាំងបំផុតនោះគឺវិស័យកសិកម្មដោយធនធានទឹកមានការថយចុះ។ វិស័យកសិកម្ម ផលប៉ះពាល់ដែលបានទទួលរងកន្លងមកមានដូចខាងក្រោម៖

- ✓ ក្នុងការផ្លាស់ប្តូររដូវការដាំដុះ
- ✓ ការទទួលគ្រោះទឹកជំនន់ ភាពរាំងស្ងួត និងខ្យល់ព្យុះញឹកញាប់
- ✓ ផ្លាស់ប្តូរវិសមរូបអាកាសធាតុដូចជា៖ សីតុណ្ហភាព កម្ពស់ទឹកភ្លៀង និងរបបទឹកភ្លៀង ជាមួយគ្នានឹងការជ្រាបចូលនៃទឹកក្រោមដី ក៏ដូចជាសំណើមក្នុងបរិយកាស
- ✓ ទិន្នផលដំណាំធ្លាក់ចុះដែលនាំឱ្យមានការនាំចេញថយចុះជាលំដាប់
- ✓ ទទួលរងដោយការបំផ្លាញផលដំណាំដោយសារតែគ្រោះទឹកជំនន់ធ្ងន់ធ្ងរកំឡុងពេល
- ✓ រដូវវស្សា ការផ្ទុះឡើងជម្ងឺ និងសត្វល្អិត ដែលបំផ្លាញប្រភេទដំណាំដែលងាយរងគ្រោះ
- ✓ ការកើនឡើងកម្ពស់ទឹកសមុទ្រធ្វើឱ្យប៉ះពាល់ផលិតកម្មកសិកម្មតាមបណ្តោយឆ្នេរសមុទ្រ
- ✓ កំណើនការប្រើប្រាស់ទឹកពីអាងស្តុកដោយសារគ្រោះរាំងស្ងួតរយៈពេលយូដែលពេល ខ្លះបានឈានទៅដល់ការខូចផលដំណាំទាំងស្រុង។
- ✓ ការរំពឹងទុកបានបង្ហាញថាទិន្នផលស្រូវនៅរដូវវស្សាបានបន្តធ្លាក់ចុះរហូតដល់ឆ្នាំ ២០៨០ និងធ្លាក់រហូតដល់ ៧០%ធៀបនឹងទិន្នផលស្រូវបច្ចុប្បន្ន។ ទិន្នផលស្រូវនៅ រដូវប្រាំង (ស្រូវស្រោចស្រព) ទិន្នផលដំណាំដែលបានដាំដុះនៅខែវិច្ឆិកា និងខែធ្នូអាចធ្លាក់ចុះរហូតដល់ ៤០%។
- ✓ ការបាត់បង់ផលិតផលខ្លាំងនោះដោយសារគ្រោះទឹកជំនន់ (ប្រហែល ៦២%) និង គ្រោះរាំងស្ងួត (ប្រហែល ៣៦%)

វិស័យទេសចរណ៍ងាយនឹងទទួលរងគ្រោះដោយសារទទួលរងឥទ្ធិពលខាងក្រៅរួមមាន៖ តម្លៃប្រេង ឡើងថ្លៃ រោគរាតត្បាត និងគ្រោះធម្មជាតិដែលកើតឡើងផ្ទួនៗ ការសិករេចរឹលបរិស្ថានធម្មជាតិ ការបំផ្លាញកេរ៏ដំណែលមរតកវប្បធម៌ ការប្រែប្រួលរបបទឹកប្រើប្រាស់ ការបាត់បង់ពពួកជីវចម្រុះ ការបាត់បងសោភ័ណភាពតំបន់ទេសភាព ការប្រកួតប្រជែងផលិតផលកសិកម្ម និងការសឹករេចរឹ កតំបន់ឆ្នេរសមុទ្រ។

ការបាត់បង់ជីវចម្រុះដែលជាផ្នែកមួយដែលបានទាក់ទាញភ្ញៀវទេសចរណ៍ ក៏ទទួលរងផលប៉ះពាល់ដោយការប្រែប្រួលអាកាសធាតុ។ ការបំផ្លាញពពួកសត្វ និងរុក្ខជាតិតូចៗ ដែលជាលទ្ធផលនាំឱ្យថយចុះចំនួនទេសចរណ៍ដែលបានមកទស្សនាក្នុងប្រទេស។ ការប្រែប្រួល អាកាសធាតុត្រូវបានគេមានជំនឿថាបង្កឱ្យសឹករេចរឹលតំបន់បេតិកភណ្ឌជាប្រវត្តិសាស្ត្រផងដែរ ដោយសារតែភាពរាំងស្ងួត និងគ្រោះទឹកជំនន់ ព្រមទាំងកើនឡើងចំនួនថ្ងៃក្តៅ។

ព្រៃឈើ ជាវិស័យមួយដ៏សំខាន់នៅក្នុងប្រទេសកម្ពុជាដែលមានប្រជាជនជាច្រើនរស់នៅក្នុងតំបន់ជនដែលពឹងអាស្រ័យជាចម្បងទៅលើអនុផលព្រៃឈើសម្រាប់ប្រើប្រាស់ក្នុងគ្រួសារ និងបង្កើន ប្រាក់ចំណូលបន្ថែម។ ផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុទៅលើព្រៃឈើ ពាក់ព័ន្ធជាមួយ ភ្លើងឆេះព្រៃ និងការបាត់បង់ជីវចម្រុះ ដំណុះមិនល្អ និងថយចុះផលិទ្ធភាពព្រៃឈើដោយសារត ការពន្យាពេលភាពរាំងស្ងួត។ ផលប៉ះពាល់ដែលអាចនឹងកើតនាពេលអនាគតរួមមាន៖

- ✓ ការគំរាមកំហែងពពួករុក្ខជាតិពូជដើមតាមរយៈការធ្វើឱ្យបរិស្ថានមានផលិតភាព សម្រាប់ពពួករាតត្បាតណាដែលមិនចាំបាច់ និងធ្វើឱ្យមានសមភាពរបស់ប្រព័ន្ធអេកូឡូ ស៊ីព្រៃឈើ។
- ✓ ស្ថិតនៅក្រោមចំហាកបញ្ចេញឧស្ម័ន Scenarios B1 និង A2 ព្រៃឈើនៅតំបន់ទំនាប ភាគច្រើននឹងទទួលរងរយៈពេលស្ងួតយូររហូតដល់ឆ្នាំ ២០៥០ ជាពិសេសតំបន់ព្រៃ ស្ថិតនៅភាគឦសាន និងនិរតីនៃប្រទេស។
- ✓ ព្រៃឈើនៅតាមតំបន់ទំនាបប្រមាណជាង ៤ លាន ហិកតា ដែលបច្ចុប្បន្នដែលមាន បរិមាណទឹកលើស ចន្លោះ ៤ ទៅ ៦ខែ ក៏នឹងអាចទទួលរងបរិមាណទឹកលើសផងដែរ ចន្លោះពី ៦ ទៅ ៨ខែ ឬលើសនេះ។

ការប្រែប្រួលអាកាសធាតុក៏ទទួលរងផលប៉ះពាល់ដល់វិស័យផ្សេងៗទៀតផងដែរដូចខាងក្រោម៖

**វិស័យជលផល៖** តាមរយៈការពន្យាពេល រដូវប្រាំងកាន់តែក្តៅ និងពន្យាពេលមកដល់នៃរដូវវស្សាបានប៉ះពាល់ដល់រដូវត្រីពង ជម្រកត្រីចរាចរណ៍ការធ្វើដំណើររបស់ត្រី និងកម្រិតរស់រហូត ដល់ភាពពេញវ័យ ហើយក៏មានការកើនឡើងវត្តមានពពួករាតត្បាតនៅតាមបណ្តោយទន្លេ ឬ តំបន់វាលទំនាប។ ភាពរាំងស្ងួតមានរយៈពេលយូរ និងកម្រិតភ័យខ្ពស់ដោយសារតែកំណើនសី តុណ្ហភាពដែលនាំឱ្យបឹងរីងស្ងួត បង្កឱ្យបាត់បង់ ឬសឹករេចរិលបរិមាណទិន្នផលត្រី។ ឧទាហរណ៍ ត្រីរាប់ពាន់តោនក្នុងបឹងទន្លេសាបបានងាប់កំឡុងពេលអាកាសធាតុក្តៅមិនបានរំពឹងទុកនៅរដូវប្រាំងឆ្នាំ ២០១៥។

**វិស័យអប់រំ៖** ការកើនឡើងព្រឹត្តិការណ៍ធាតុអាកាសធ្ងន់ធ្ងរបានប៉ះពាល់ដលសេវាកម្មអប់រំ ការ អភិវឌ្ឍធនធាន មនុស្ស និងហេដ្ឋារចនសម្ព័ន្ធ។ គ្រោះទឹកជំនន់ ភាពរាំងស្ងួត និងខ្យល់ព្យុះនាំឱ្យ មានកំណើនថ្ងៃ

ក្ដៅខ្លាំងធ្វើឱ្យសិស្សជាពិសេសកុមារ និងគ្រូមិនអាចធ្វើដំណើរទៅសាលារៀន បាន។ ជាក់ស្ដែង មានសាលារៀនប្រមាណ ៥០០ បានពន្យារពេលសិក្សាដោយសារមានទឹក ជំនន់ខ្ពស់ពេកនៅឆ្នាំ ២០១៣។ ចំណែកឯនៅឆ្នាំ២០១៥ មានសាលាបឋមទាំងអស់នៅក្នុង ប្រទេសកម្ពុជា បានបិទទ្វារយ៉ាង ១ខែកំឡុងពេលរដូវក្ដៅខ្លាំងក្នុងធមាសនោះដើម្បី ចៀសវាងហានិភ័យដែលនាំឱ្យកុមារមានជម្ងឺនៅពេលទៅសាលារៀនកំឡុងពេលនោះ។

**យេនឌ័រ៖** ការប្រែប្រួលអាសកាសធាតុបានប៉ះពាល់ដល់បុរស និងស្រ្តីតាមរបៀបផ្សេងគ្នា ដោយសារតែការចូលរួមកម្លាំងពលកម្មក្នុងផ្ទះ សហគមន៍ និងសង្គម។ ស្រ្តីមានផ្ទៃពោះប្រហែលជាទទួលរងដោយការប្រែប្រួលធាតុអាកាស និងអាកាសធាតុច្រើនជាងបុរស។

**វិស័យសុខាភិបាល៖** បាតុភូតធាតុអាកាសធ្ងន់ធ្ងរអាចបណ្ដាលប៉ះពាល់ដោយផ្ទាល់ និងប្រយោលទៅលើការស្លាប់ រងរបួស មានជម្ងឺ និងបញ្ហាខួរក្បាល។ ការកើនឡើងជម្ងឺគ្រុនឈាម និងជម្ងឺឆ្លងតាមទឹកត្រូវបានកត់ត្រា ព្រមទាំងប៉ះពាល់ខ្លាំងបំផុតទៅលើកុមារ និងគ្រួសារក្រីក្រក្នុង សង្គមដែលបានបែងចែកតាមរយៈវិសមភាពអាហាររូបត្ថម្ភ និងលក្ខខណ្ឌសុខភាពដែលងាយ ទទួលរងគ្រោះ។

**ហេដ្ឋារចនាសម្ព័ន្ធ** ៖ គ្រោះទឹកជំនន់ និងភាពរាំងស្ងួត ក្នុងនោះគ្រោះទឹកជំនន់បណ្ដាលដាច់ផ្លូវ ជនបទ និងផ្លូវជាតិតាមតំបនជនបទ ក៏ដូចជាតំបន់ទីក្រុង បង្កឱ្យមានឧបសគ្គដល់ការអភិវឌ្ឍ សេដ្ឋកិច្ចសង្គមក្នុងប្រទេស។

**ធនធានទឹក៖** ភាពរាំងស្ងួតយូរបង្កឱ្យមានការផ្គត់ផ្គង់ទឹកមានកំណត់សម្រាប់ប្រើប្រាស់ក្នុងគ្រួសារ និងដំណើរការផលិតកម្មកសិកម្ម។ ការហៀរចេញ និងការបំពេញទឹកក្រោមដី និងគុណភាពទឹក លើផ្ទៃដីត្រូវបានប៉ះពាល់ដោយគ្រោះទឹកជំនន់ និងទឹកជំនន់យ៉ាងគំហុក ក៏ដូចជាលក្ខខណ្ឌទី ជម្រាលមិនល្អ និងផ្ទៃរងទឹកភ្លៀង ព្រមទាំងការគ្រប់គ្រងតំបន់វាលទំនាប។

**តំបន់ឆ្នេរសមុទ្រ** ៖ ការកើនឡើងនីវ៉ូទឹកសមុទ្របណ្ដាលឱ្យលេចធ្លាយចូលទឹកប្រៃធ្វើឱ្យប៉ះពាល់ដោយផ្ទាល់លើអនាម័យទឹក ជីវចម្រុះសមុទ្រ និងអនាម័យ។ ផលប៉ះពាល់ទាំងអស់ខាងលើបាន បង្កឱ្យមានឥទ្ធិពលដោយផ្ទាល់ និងប្រយោលទៅលើការអភិវឌ្ឍសេដ្ឋកិច្ចសង្គមជាតិ។ ប្រជាជន ជិតស្និទ្ធជាមួយនឹងការថយចុះនៃធនធានទឹក សំដៅដល់គុណភាព និងទឹកដែលមាន។ ការបំផ្លាញហេដ្ឋានរចនសម្ព័ន្ធដោយសារតែភាពរាំងស្ងួត និងខ្យល់ព្យុះបានគំរាមកំហែងដល់ការ ទំនាក់ទំនង ការផ្លាស់ប្ដូរផលិតផលជាតិ និងអន្តរជាតិ និងបន្តឱ្យមានសេវាកម្មផ្សេងៗដូចជា អគ្គិសនី និងការផ្គត់ផ្គង់ទឹកនៅតាមតំបន់ជនបទ និងទីប្រជុំជន។ ការហូរចូលនៃទឹកប្រៃនៅតាម តំបន់ឆ្នេរសមុទ្របានបង្កដល់ការគំរាមកំហែងដល់ការប្រមូលផលពីវារីវប្បកម្ម

និងសកម្មភាព សេដ្ឋកិច្ចដល់ប្រជាជននៅតំបន់ទាំងនេះ ។ ការកើនឡើងជម្ងឺគ្រុនឈាម និងជម្ងឺឆ្លងតាមទឹកផ្សេងៗទៀតហួសកំណត់ពីសេវាកម្មសុខភាពសារធារណៈបណ្តាលមកពីការវិនិយោគថវិការដ្ឋ ព្រមទាំងប៉ះពាល់ដល់ផលិតកម្មជាតិ និងសុខមាលភាពរបស់ប្រជាជន។

ទិន្នន័យដែលបានប្រមូលកំឡុងពេលធ្វើកិច្ចសម្ភាសបានបង្ហាញថាតំណាងអាជ្ញាធរថ្នាក់ជាតិ និងវិស័យឯកជនបានយល់ដឹងច្បាស់ពីផលប៉ះពាល់ជាសក្តានុពលពីការប្រែប្រួលអាកាសធាតុនៅ ក្នុងប្រទេសរបស់ពួកគេ។ទោះជាយ៉ាងនេះក៏ដោយ វាមិនទាន់បញ្ជាក់ច្បាស់នៅឡើយថាអ្វីដែល ពួកគេនឹងគិតថាប៉ះពាល់ដល់ប្រជាជន និងសេដ្ឋកិច្ចជាតិ។ យោងទៅលើចម្លើយរបស់អ្នកចូលរួម ផ្តល់សម្ភាស៍ ការយល់ដឹងពីសំណាក់តួអង្គពាក់ព័ន្ធពិតជាបានទូលំទូលាយ ផ្ទុយទៅវិញ រាល់ ចម្លើយខ្លះនៅមានកម្រិត និងមានប្រសិទ្ធភាពតិចតួច។ តាមពិតដោយសារតែខ្វះខាតចំណេះដឹង និងជំនាញការប្រែប្រួលអាកាសធាតុ។ វាជាការចង់បានសម្រាប់ការដាក់បញ្ចូលទៅក្នុងកម្មវិធី សិក្សាគ្រប់កម្រិតទាំងអស់ចាប់ពីថ្នាក់បឋមសិក្សារហូតដល់គ្រឹះស្ថានឧត្តមសិក្សាកម្រិតឧត្តមក្នុង គោលបំណងដើម្បីបង្កើតឱ្យមានអ្នកជំនាញអាជីពដើម្បីឆ្លើយតបផលប៉ះពាល់នៃការប្រែប្រួល អាកាសធាតុនៅតាមវិស័យផ្សេងៗ។

នៅកម្រិតស្ថានប័ន មានគណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុ (NCCC) ដែលមានតួនាទីជាក់ស្តែង ក្នុងការសម្របសម្រួលសកម្មភាពការងារឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុពង្រឹង និងជាដៃគូរសម្របសម្រួលជាមួយស្ថាប័នពាក់ព័ន្ធនិងត្រួតពិនិត្យការអនុវត្ត ផែនការយុទ្ធសាស្ត្រសម្រាប់ការបន្សុំា និងការកាត់បន្ថយការប្រែប្រួលអាកាសធាតុ។

នៅកម្រិតក្រសួង ជនបង្គោលការប្រែប្រួលអាកាសធាតុ និងក្រុមការងារបច្ចេកទេសត្រូវបានបង្កើតឡើងដើម្បីសម្របសម្រួលការងារនេះ។ យោងទៅលើចម្លើយរបស់អ្នកចូលរួមផ្តល់សម្ភាស ទំនួល ខុសត្រូវរបស់ក្រុមការងារនេះមិនត្រូវបានកំណត់នៅឡើយជាពិសេសការប្រាស្រ័យទាក់ទងនៅ ក្នុងនាយកដ្ឋាននៃក្រសួងសាមីនីមួយៗ ដើម្បីធ្វើឱ្យជាក់ច្បាស់ថាការរៀបចំផែនការ កម្មវិធី និង ការវិនិយោគតាមវិស័យនីមួយៗមានភាពច្បាស់លាស់ត្រឹមត្រូវដើម្បីធ្វើការសម្រេចចិត្តលើ ហានិភ័យការប្រែប្រួលអាកាសធាតុ និងឱកាស។ នៅក្នុងរយៈពេល ១៧ ឆ្នាំចុងក្រោយនេះ នាយកដ្ឋានការប្រែប្រួលអាកាសធាតុ នៃក្រសួងបរិស្ថានបានដើរតួនាទីយ៉ាងសំខាន់ក្នុងការ សម្របសម្រួល និងគាំទ្រដល់គោលនយោបាយថ្នាក់ជាតិស្តីពីការស្រាវជ្រាវ និងការអភិវឌ្ឍតាមរ យៈការអនុវត្តផែនការសកម្មភាព ផែនការយុទ្ធសាស្ត្រ និងគោលនយោបាយដែលពាក់ព័ន្ធការប ប្រួលអាកាសធាតុ។ ដូចនេះ ការប្រែប្រួលអាកាសធាតុដើរតួនាទីយ៉ាងសំខាន់ក្នុងគោលនយោបាយថ្នាក់ជាតិស្តីពីការស្រាវជ្រាវ និងការអភិវឌ្ឍ ជាធម្មតាមិនមានកម្រិតខ្ពស់នោះទេ និងមានលក្ខ

ណៈខុសគ្នាតិចតួចទៅតាមក្រសួងនីមួយៗ។ ការស្រាវជ្រាវក្នុងវិស័យសំខាន់រួមមាន៖ កសិកម្ម អប់រំ សុខាភិបាល និងហេដ្ឋារចនាសម្ព័ន្ធបានចូលរួមចំណែកយ៉ាងខ្លាំងដល់ថវិកាជាតិ។

សរុបសេចក្តីមក តម្រូវការចាំបាច់មួយដើម្បីបន្ត និងបង្កើនភាពជាដៃគូជាមួយគ្រឹះស្ថានឧត្តមសិក្សាសំខាន់ រីកលូតលាស់ពីការស្រាវជ្រាវនេះ។ ស្ថាប័នស្រាវជ្រាវអាចជួយវិស័យឯកជន និង ស្ថាប័នរដ្ឋាភិបាលដែលពាក់ព័ន្ធដើម្បីឱ្យមានកិច្ចពិភាក្សាជាយុទ្ធសាស្ត្រក្នុងការកំណត់វស័យអាទិ ភាព និងធ្វើសេចក្តីព្រាងរបៀបវារៈក្នុងការស្វែងយល់បាតុភូត និងសកម្មភាពណាល្អបំផុតសម្រាប់ដោះស្រាយ។ លទ្ធផលទទួលបានពីកិច្ចពិភាក្សាក្រុមបានបង្ហាញថាដើម្បីដោះស្រាយបញ្ហាការ ប្រែប្រួលអាកាសធាតុនេះរួមមាន៖ ១២ ក្រសួង-ស្ថាប័ន ព្រមទាំងគណៈកម្មាធិការជាតិគ្រប់គ្រង ការប្រែប្រួលអាកាសធាតុដែលបានចូលរួមក្នុងដំណើរការវាយតម្លៃផលប៉ះពាល់នៃការប្រែប្រួល អាកាសធាតុដូចខាងក្រោម៖

- ✓ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ✓ គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ
- ✓ ក្រសួងអប់រំ យុវជន និងកីឡា
- ✓ ក្រសួងកិច្ចការនារី
- ✓ ក្រសួងសុខាភិបាល
- ✓ ក្រសួងអភិវឌ្ឍន៍ជនបទ ក្រសួងធនធានទឹក និងឧតុនិយម
- ✓ ក្រសួងដែនដី នគរូបនីយកម្ម និងសំណង់
- ✓ ក្រសួងទេសចរណ៍
- ✓ ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- ✓ ក្រសួងសាធារណការ និងដឹកជញ្ជូន
- ✓ ក្រសួងព័ត៌មាន
- ✓ ក្រសួងបរិស្ថាន
- ✓ ក្រសួងរ៉ែ និងថាមពល

ទិន្នន័យដែលបានប្រើប្រាស់ដោយស្ថាប័ន និងវិស័យដែលពាក់ព័ន្ធដើម្បីវាស់វែងពីផលប៉ះពាល់ និងការប្រែប្រួលតាមរដូវកាលនីមួយៗជាប្រភេទទិន្នន័យឧតុនិយម (កម្ពស់ទឹកភ្លៀង សីតុណ្ហភាព ខ្យល់) ការប្រែប្រួលគម្របដី (ឧ. ការថយចុះដីព្រៃ ការថយចុះ ឬកើនឡើងកម្រិតទឹកសមុទ្រ) គុណភាពដី

ទិន្នន័យជលសាស្ត្រ។ វាមិនបានបញ្ជាក់ច្បាស់ថាប្រភពព័ត៌មានណាមួយ និងសុពលភាព និងគុណភាពទិន្នន័យដែលបានធានាអះអាងនោះទេ។

មានម្ចាស់ជំនួយ និងដៃគូអភិវឌ្ឍន៍អន្តរជាតិជាច្រើនបានលើកកម្ពស់ការស្រាវជ្រាវ ត្រួតពិនិត្យ និងវាយតម្លៃលើការប្រែប្រួលអាកាសធាតុ។ អន្តរាគមន៍ទាំងនេះក៏បានជួយដល់ការសម្រប សម្រួលដោយនាយកដ្ឋានប្រែប្រួលអាកាសធាតុនៃក្រសួងបរិស្ថាន។ ស្ថាប័នសិក្សាស្រាវជ្រាវ របស់ប្រទេសជប៉ុនចំនួន ០២ ដែលបានសិក្សា និងវាយតម្លៃលើផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ និងត្រូវបានរកឃើញដោយស្ថាប័នរដ្ឋាភិបាល និងវិស័យឯកជន។

**មជ្ឈមណ្ឌលសហប្រតិបត្តិការបរិស្ថានអន្តរជាតិ (OECC)៖** ការស្រាវជ្រាវរួមគ្នាមួយលើប្រសិទ្ធភាពនៃការប្រើប្រាស់ថាមពល ការពិនិត្យគុណភាពទឹកក្នុងអណ្តូងរាក់នៅសណ្ឋាគារប្រណិតក្នុងទីក្រុង ភ្នំពេញ និងសៀមរាប ប្រទេសកម្ពុជា ឆ្នាំ២០១៥។ បេសកកម្មរបស់ OECC ដើម្បីប្រមូលព័ត៌មាន បរិស្ថានប្រចាំឆ្នាំនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ដោយសហការរួមគ្នាជាមួយនឹងប្រទេសជប៉ុន។ សមាជិកទាំងអស់ក្នុងបេសកកម្មនេះត្រូវសហការគ្នាក្នុងការប្រឹក្សាពីបញ្ហាបរិស្ថាន ឬត្រួតពិនិត្យ/ តាមដានវិភាគទៅលើបរិស្ថានសហការក្នុងការផលិត ឬសាងសងសម្ភារការពារបរិស្ថាន ការ ផលិត ឬលក់សម្ភារត្រួតពិនិត្យបរិស្ថាន ឬស្ថាប័នជំនួញផ្សេងៗទៀត ស្ថាប័នរដ្ឋាភិបាលថ្នាក់ ក្រោមជាតិ និងអង្គការមិនដើម្បីប្រាក់កំរៃផ្តោតទៅលើសកម្មភាពការអភិរក្សបរិស្ថាន។ គោលដៅ ក្នុងការអង្កេតរុក្ខជាតិ បរិយាកាស ទឹក ជីវចម្រុះ ការគ្រប់គ្រងសំរាម និងការយកចិត្តទុកដាក់លើ សង្គម និងបរិស្ថាន។ សមាជិកទាំងអស់ចាប់ផ្តើមការអង្កេតជាទូទៅតាមរយៈការសិក្សាជាបឋម ទស្សនកិច្ចសិក្សា និងទទួលបានព័ត៌មានពីមន្ត្រីនៅតាមក្រសួងពាក់ព័ន្ធ ម្ចាស់ជំនួយអន្តរជាតិ អង្គការក្រៅរដ្ឋាភិបាល និងអង្គភាពផ្សេងៗទៀតផងដែរ។ បន្ទាប់ពីប្រមូលទិន្នន័យរួចសិក្ខាសាលា មួយត្រូវបានរៀបចំឡើងនៅទីក្រុងដែលមានបទបង្ហាញពីដំណោះស្រាយផលលំបាកបរិស្ថាននៅក្នុងប្រទេសគោលដៅទាំងអស់។

**វិទ្យាស្ថានយុទ្ធសាស្ត្របរិស្ថានពិភពលោក (IGES)៖** សិក្សាស្រាវជ្រាវទិន្នន័យគោលដែលមាន លក្ខណៈស្តង់ដារម៉ាស៊ីនកិនស្រូវក្នុងប្រទេសកម្ពុជា ដើម្បីអភិវឌ្ឍន៍មេគុណបញ្ចេញនៅក្នុងគម្រោងយន្តការអភិវឌ្ឍន៍ស្អាត (CDM) សហការជាមួយនាយកដ្ឋានប្រែប្រួលអាកាសធាតុន ក្រសួងបរិស្ថាន វិទ្យាស្ថាននេះត្រូវបានបង្កើតឡើងដើម្បីសម្រេចបានគំរូថ្មីសម្រាប់ការរីកចំរើន និងអភិវឌ្ឍន៍គោលនយោបាយនវានុវត្តន៍ព្រមទាំងការស្រាវជ្រាវជាយុទ្ធសាស្ត្រសម្រាប់វាស់វែងបរិស្ថាន ឆ្លុះបញ្ចាំងពីលទ្ធផលនៃការស្រាវជ្រាវនេះទៅក្នុងក្តីសម្រេចនយោបាយការអភិវឌ្ឍដោយចីរភាពទាំងក្នុងតំបន់ និងពិភពលោក។ IGES ប្រមូលព័ត៌មានបរិស្ថានហើយលក់ទៅឱ្យតួអង្គពាក់ ព័ន្ធដើម្បីបានថវិកាស្រាវជ្រាវ។ នៅក្នុងប្រទេសកម្ពុជា វិស័យឯកជន

ដើរតួនាទីយ៉ាងសំខាន់មិន ត្រឹមតែបានចូលរួមស្រាវជ្រាវការប្រែប្រួលអាកាសធាតុ ប្រសិនបើមានកិច្ចសហប្រតិបត្តិការជា អន្តរជាតិនិងក្រុមហ៊ុនធំៗធ្វើការសិក្សាពីផលប៉ះពាល់ពីការចូលរួមរបស់ពួកគេ វាមិនទំនង់ថាលទ្ធ ផលត្រូវបានបោះពុម្ពផ្សាយជាសាធារណៈ។ ផលលំបាកចម្បងសម្រាប់អង្គការមិនមានរដ្ឋាភិបា លក្នុងស្រុកដែលបានចូលរួមយ៉ាងសកម្មចំពោះការស្រាវជ្រាវថ្នាក់ជាតិស្តីពីការប្រែប្រួលអាកាស ធាតុ គឺខ្វះខាតប្រភពមូលនិធិចុះអង្កេតតាមទីវាលទៅតាមក្របខណ្ឌគម្រោងជាក់លាក់មួយ។ កត្តាដែលសំខាន់មួយទៀតនោះគឺ ធនធានមនុស្សនៅមានកម្រិត។ តម្រូវការចាំបាច់សម្រាប់ដំណោះស្រាយនៅតែមានការកើនឡើង។ នាយកដ្ឋានប្រែប្រួលអាកាសធាតុជាក់ស្តែតកំពុងស្វែងរកអ្នកជំនាញខាងផ្នែកយុទ្ធសាស្ត្របន្សុំ និងការតំបន្ថយការប្រែប្រួលអាកាសធាតុ ក៏ដូចជា ការវាយតម្លៃផលប៉ះពាល់ការប្រែប្រួលអាកាសធាតុ និងសារពើភណ្ឌឧស្ម័នផ្ទះកញ្ចក់។

## ការផ្តល់ហិរញ្ញវត្ថុ និងធនធានសម្រាប់ការស្រាវជ្រាវ និងការអភិវឌ្ឍការប្រែប្រួលអាកាសធាតុ

លទ្ធផលទទួលបានពីកិច្ចសម្ភាស វាបានបញ្ជាក់ថាមានផែនការសកម្មភាព និងយុទ្ធសាស្ត្រមួយ ចំនួនដើម្បីដោះស្រាយជាមួយការប្រែប្រួលអាកាសធាតុត្រូវបានបង្កើតឡើងដោយរាជរដ្ឋាភិបាលកម្ពុជា។ កម្មវិធីខាងក្រោមបានអនុវត្តន៍៖

- ✓ ផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុកម្ពុជា ២០១៤-២០២៣ ដែលមាន ៣ ដំណាក់កាលសំខាន់ៗ៖
    - រយៈពេលខ្លី (២០១៣-២០១៤)
    - រយៈពេលមធ្យម (២០១៤-២០១៨)
    - រយៈពេលង (២០១៩-២០២៣)
- ✓ យុទ្ធសាស្ត្រជាតិសម្រាប់ការអភិវឌ្ឍបៃតង និងផែនការអភិវឌ្ឍន៍តាមវិស័យ
    - ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (NSDP)
    - យុទ្ធសាស្ត្រចតុកោណ
    - ផែនការសកម្មភាពឆ្លើយតបនឹងការប្រែប្រួលអាកាធាតុ (CCAP)
    - ផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុតាមវិស័យ (SCCSP)
    - ក្របខណ្ឌហិរញ្ញប្បទានប្រែប្រួលអាកាសធាតុ (CCFF)

CCCSP ជាមួយគ្នាផែនការសកម្មភាពដែលពាក់ព័ន្ធបានផ្តល់ជាក្របខណ្ឌយុទ្ធសាស្ត្រសម្រាប់ កម្មវិធីអន្តរាគមន៍ការប្រែប្រួលអាកាសធាតុនៅក្នុងប្រទេសកម្ពុជា។ យន្តការហិរញ្ញប្បទានប ប្រួលអាកាសធាតុថ្នាក់ជាតិជួយគាំទ្រដល់វិធីសាស្ត្រដែលជាយុទ្ធសាស្ត្រតាមរយៈការដាក់ចេញ គោលការណ៍ដូចខាងក្រោម៖

- ✓ ការរៀបចំវិស័យអាទិភាពថ្នាក់ជាតិ
- ✓ ការបញ្ចូលធនធាន
- ✓ ការប្រើប្រាស់តាមប្រព័ន្ធ និងនិតិវិធីជាតិ
- ✓ ការឧបត្ថម្ភដើមទុន

នៅក្នុងឆ្នាំ ២០១៤ សកម្មភាពខាងក្រោមនេះត្រូវបានយកមកពិភាក្សាដោយមានចាប់អារម្មណ៍ និងក្របខណ្ឌហិរញ្ញប្បទានប្រែប្រួលអាកាសធាតុដ៏មានប្រសិទ្ធភាពសម្រាប់កម្ពុជា៖

- ✓ វិភាគលើឱកាសចល័តប្រភពធនធាន (ប្រភពខាងក្នុង និងខាងក្រៅ ទាំងនៅកម្រិត ជាតិ និងវិស័យជាអាទិភាព
- ✓ វាយតម្លៃពីថ្លៃដើមសម្រាប់ CCCSP និង SCCSPs ដោយធ្វើអាទិភាពលើគម្រោងពាក់ព័ន្ធខ្ពស់
- ✓ វាយតម្លៃពីផលប៉ះពាល់សេដ្ឋកិច្ចសង្គមចំពោះផលប្រយោជន៍សរុប និងពុំមានសកម្មភាពលើចំហាកឆ្លើយតបជាច្រើនដើម្បីផ្តល់ជាអាទិភាពចំពោះការចំណាយក្នុង១វិស័យ និងអនុវិស័យ។
- ✓ វិភាគលើការអនុវត្តថ្នាក់ជាតិល្អៗ និងការអនុវត្តជាអន្តរជាតិដែលពាក់ព័ន្ធក្នុងការ
- ✓ គ្រប់គ្រងរៀបចំប្រភពមូលនិធិដែលបានដាក់បញ្ចូលសម្រាប់យន្តការហិរញ្ញប្បទានប្រែ ប្រួលអាកាសធាតុថ្នាក់ជាតិ និងក្រោមជាតិ។

## ប្រទេសកម្ពុជា៖ មុខវិជ្ជាសិក្សា

តំណាងក្រុមចំនួន ១៤ នាក់ របស់ស្ថាប័នគ្រឹះស្ថានឧត្តមសិក្សាមកពីសាកលវិទ្យាល័យភូមិន្ទកសិកម្ម និង១៥ នាក់ មកពីសាកលវិទ្យាល័យ ហេងសំរិន ត្បូងឃ្មុំ និងសាកលវិទ្យាល័យស្វាយ រៀងដែលបានចូលរួមក្នុងការអង្កេត។ លទ្ធផលពីកិច្ចពិភាក្សាក្រុមបានបង្ហាញថា ការស្រាវជ្រាវស្តី ពីការប្រែប្រួលអាកាសធាតុ និងទិដ្ឋភាពផ្សេងៗគ្នានៃផលប៉ះពាល់លើវិស័យផ្សេងៗគ្នាត្រូវបានធ្វើ ការសិក្សាស្រាវជ្រាវយ៉ាងទូលំទូលាយដូចជា៖

- ✓ ទឹក និងសន្តិសុខស្បៀង
- ✓ ការពង្រឹងស្ថាប័នរដ្ឋាភិបាលដើម្បីជួយកសិករបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ

- ✓ កសិកម្មវៃឆ្លាតខាងអាកាសធាតុ
- ✓ ការអភិរក្សកសិដ្ឋាន និងការប្រើប្រាស់ដំណាំធញ្ញជាតិចម្រុះប្រកបដោយនិរន្តរភាពតាម រយៈការចូលរួមបង្កាត់ពូជរុក្ខជាតិនិងធ្វើឱ្យមានសុវត្ថិភាពប្រព័ន្ធគ្រាប់ពូជក្នុងតំបន់នៅតាមបណ្តាខេត្តងាយរងគ្រោះ ដោយសារការប្រែប្រួលអាកាសធាតុ
- ✓ ការវាយតម្លៃសេដ្ឋកិច្ចបន្សាំលើការប្រែប្រួលអាកាធាតុនៅក្នុងវស័យកសិកម្ម
- ✓ ការវាយតម្លៃការប្រែប្រួលអាកាសធាតុអតីតកាល ភាពងាយរងគ្រោះ និងការព្យាករអាកាសធាតុអនាគតក្នុងប្រទេសកម្ពុជា
- ✓ អភិបាលកិច្ចទឹក និងការបន្សុំាទៅនឹងការប្រែប្រួលអាកាសធាតុ
- ✓ គម្រោងការស្តាររុក្ខជាតិពូជនៅប្រទេសកម្ពុជា
- ✓ ភាពធន់នឹងអាកាសធាតុ និងការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ
- ✓ ការអភិវឌ្ឍមេគុណាសមីការដើម្បីគណនាកាបូនក្នុងព្រៃឈើ
- ✓ ការកំណត់គ្រោះថ្នាក់ធម្មជាតិ
- ✓ ផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុក្នុងវិស័យកសិកម្ម
- ✓ ផលប៉ះពាល់នៃភាពរាំងស្ងួតលើជីវភាពរស់នៅតាមតំបន់ជនបទ
- ✓ ការសិក្សាពីការបញ្ចេញឧស្ម័នមេតានពីសត្វទំពាររអៀងដោយប្រើប្រព័ន្ធ INVITRO SYSTEM
- ✓ ការផលិតឧស្ម័នមេតានដោយប្រើកាកសំណល់ចេញពីបន្លែ ផ្លែឈើ និងជីលាមក
- ✓ មេរៀនស្តីពីការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ចេញពីការចញ្ចឹមសត្វ
- ✓ ការពង្រឹងជីវភាពរស់នៅរបស់សហគមន៍តាមរយៈការបន្សុំា និងការកាត់បន្ថយការប្រែប្រួលអាកាសធាតុ

ប្រធានបទខាងក្រោមបាននឹងកំពុងសិក្សានាពេលបច្ចុប្បន្ន៖

- ✓ ការពង្រីកការអនុវត្តគ្រប់គ្រងដីប្រកបដោយចីរភាព (SLM)
- ✓ ការបន្សុំាទៅនឹងការប្រែប្រួលអាកាសធាតុដោយប្រើការដាំដុះដោយផ្ទាល់
- ✓ ប្រសិទ្ធភាពនៃការស្តារព្រៃឈើលើតំបន់ដែលមានទឹកសម្រាប់កសិកម្មវៃឆ្លាត
- ✓ ការពង្រឹងសមត្ថភាពការស្រាវជ្រាវ និងនវានុវត្តន៍នៃការប្រែប្រួលអាកាសធាតុ
- ✓ គម្រោងការកសាងសមត្ថភាពបន្សុំាតាមរយៈការពង្រីកបច្ចេកវិទ្យាថាមពលកកើតឡើងវិញនៅតំបន់ជនបទប្រទេសកម្ពុជា

- ✓ គម្រោងការធ្វើឱ្យប្រសើរឡើងភាពធន់នឹងការប្រែប្រួលអាកាសធាតុដល់សហគមន៍មូលដ្ឋាននៅតំបន់ការពារធម្មជាតិក្នុងប្រទេសកម្ពុជា

កម្មវិធីស្រាវជ្រាវ និងប្រព័ន្ធផ្តល់មូលនិធិត្រូវបានផ្តល់ជូនដោយម្ចាស់ជំនួយថ្នាក់ជាតិនិងអន្តរជាតិ ដល់គ្រឹះស្ថានឧត្តមសិក្សាសម្រាប់ការបណ្តុះបណ្តាលវគ្គសិក្សា និងការស្រាវជ្រាវ គម្រោង ស្រាវជ្រាវ ការពង្រឹងសមត្ថភាព និងផ្តល់អាហាររូបករណ៍ដល់បរិញ្ញាបត្រជាន់ខ្ពស់ពាក់ព័ន្ធនឹងការ ប្រែប្រួលអាកាសធាតុ។ ខាងក្រោមនេះជាគម្រោង និងកម្មវិធីដែលបានអនុវត្តន៍៖

**គម្រោងអនុវត្តន៍ពីអតីតកាល៖**

- ✓ វគ្គបណ្តុះបណ្តាលខ្លីៗគាំទ្រដោយបណ្តាញអាស៊ី-ប៉ាស៊ីហ្វិកសម្រាប់ការផ្លាស់ប្តូរការ ស្រាជ្រាវសកល APN ( ឥណ្ឌូណេស៊ី ហ្វីលីពីន និងកម្ពុជា )
- ✓ ការពង្រឹងសមត្ថភាពស្ថាប័នរដ្ឋាភិបាលដើម្បីជួយកសិករបស៊ាំទៅនឹងការប្រែប្រួលអាកាសធាតុ ផ្តល់មូលនិធិដោយកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិប្រចាំកម្ពុជា
- ✓ ការអភិរក្សកសិដ្ឋាន និងការប្រើប្រាស់ដំណាំធញ្ញជាតិចម្រុះប្រកបដោយនិរន្តរភាពតាម រយៈការចូលរួមបង្កាត់ពូជរុក្ខជាតិនិងធ្វើឱ្យមានសុវត្ថិភាពប្រព័ន្ធគ្រាប់ពូជក្នុងតំបន់នៅ តាមបណ្តាខេត្តងាយរងគ្រោះដោយសារការប្រែប្រួលអាកាសធាតុផ្តល់មូលនិធិដោយ វេទិកាមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា
- ✓ ការដាក់បញ្ចូលការប្រែប្រួលអាកាសធាតុក្នុងការអភិវឌ្ឍកម្មវិធីសិក្សាសម្រាប់គ្រឹះស្ថាន អប់រំកសិកម្មនៅប្រទេសកម្ពុជាផ្តល់មូលនិធិដោយគម្រោងលើកកម្ពស់គុណភាព និង សមត្ថភាពឧត្តមសិក្សាគាំទ្រដោយ ធនាគារពិភពលោក
- ✓ ការគាំទ្រដល់ការធ្វើសារពើភណ្ឌព្រៃឈើថ្នាក់ជាតិស្តីពី ការអភិវឌ្ឍសមីកា និងមេគុណ បញ្ចេញផ្តល់ មូលនិធិដោយ៖ អង្គការស្បៀង និងកសិកម្មនៃសហប្រជាជាតិ ( FAO )
- ✓ ជំនួយអង្គការកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិជួយប្រទេសអភិវឌ្ឍន៍តិចតួចក្នុងការ ដំណើរការរៀបចំផែនការបន្ស៊ាំថ្នាក់ជាតិ ( NAPs ) គាំទ្រដោយ UNDP
- ✓ កម្មវិធីពង្រឹងសមត្ថភាពរបស់កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិជាមួយជំនួយពីពលរដ្ឋសហរដ្ឋអាមេរិច UNDP-USAID ស្តីពីសេដ្ឋកិច្ចបន្ស៊ាំការសិក្សាបន្ស៊ាំការប្រែប្រួលអាកាសធាតុនៅអាស៊ីផ្តោតសំខាន់ទៅ លើវិស័យកសិកម្មផ្តល់មូលនិធិដោយ UNDP
- ✓ ការវាយតម្លៃការប្រែប្រួលអាកាសធាតុអតីតកាល ភាពងាយរងគ្រោះ និងការព្យាករអាកាសធាតុអនាគត ក្នុងប្រទេសកម្ពុជាផ្តល់មូលនិធិដោយមូលនិធិបៃតងឥណ្ឌា

- ✓ អភិបាលកិច្ចទឹក និងការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុនៅប្រទេសកម្ពុជាផ្ដល់ មូនលិធិដោយ វិទ្យាស្ថានស្រាវជ្រាវអភិវឌ្ឍន៍កម្ពុជា (CDRI)
- ✓ ការផ្ដល់អាហាររូបករណ៍ដល់និស្សិតបរិញ្ញាបត្រជាន់ខ្ពស់ជំនាញការគ្រប់គ្រងធនធាន ធម្មជាតិ ដែលគាំទ្រថវិកាដោយគម្រោង USAID-Post Harvest ក្រសួងបរិស្ថាន និងអង្គការវីនរ៉ក់អន្តរជាតិ
- ✓ ការអភិវឌ្ឍកម្មវិធីសិក្សាស្ដីពីការប្រែប្រួលអាកាសធាតុថ្នាក់តំបន់ស្ដីពីការប្រែប្រួលអាកាសធាតុផ្ដល់ថវិកាដោយ USAID Leaf Program
- ✓ គម្រោងការស្ដាររុក្ខជាតិពូជនៅប្រទេសកម្ពុជាដោយមានការចូលរួមពីការស្រាវជ្រាវ ដោយមានការស្រាវជ្រាវប្រព័ន្ធអេកូឡូស៊ីព្រៃឈើជាមួយសហគមន៍ព្រៃឈើក្រោមការឧបត្ថម្ភដោយវិទ្យាស្ថានសម្រាប់យុទ្ធសាស្រ្តពិភពលោករបស់ប្រទេសជប៉ុន
- ✓ ការធ្វើបច្ចុប្បន្នភាពកម្មវិធីសិក្សាស្ដីពីភាពធន់អាកាសធាតុ និងការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ ផ្ដល់មូលនិធិដោយធនាគារអភិវឌ្ឍន៍អាស៊ី
- ✓ គាំទ្រដល់ការអភិវឌ្ឍដល់មេគុណស្រូប និងបញ្ចេញសម្រាប់សកម្មភាពទាក់ទងនឹង REDD+ និងការធ្វើ តែសការគ្រប់គ្រងសកម្មភាពបង្ហាញផ្ដល់មូលនិធិដោយ FAO
- ✓ ការពង្រឹងសមត្ថភាពស្ថាប័នរដ្ឋាភិបាលស្ដីពីការប្រែប្រួលអាកាសធាតុដល់គ្រូបង្គោល ផ្ដល់មូលនិធិដោយគណៈកម្មការទន្លេមេគង្គ

គម្រោងអនុវត្តន៍នាពេលបច្ចុប្បន្នះ

- ✓ គម្រោងពង្រីកបច្ចេកទេសអនុវត្តន៍ការគ្រប់គ្រងដីប្រកបដោយចីរភាព(SLM) តាមរយៈ កសិករខ្នាតតូច ធ្វើការជាមួយសេវាកម្មផ្សព្វផ្សាយកសិកម្ម ដើម្បីកំណត់ វាយតម្លៃ និង ផ្សព្វផ្សាយការអនុវត្ត SLM ផ្ដល់មូលនិធិដោយមូលនិធិអន្តរជាតិសម្រាប់ការ អភិវឌ្ឍកសិកម្ម (IFAD)
- ✓ ប្រសិទ្ធភាពនៃការស្ដារព្រៃឈើលើតំបន់ដែលមានទឹកសម្រាប់កសិកម្មវៃឆ្លាត៖ ករណីសិក្សានៅប្រទេសកម្ពុជា (FRAWASA) ផ្ដល់មូលនិធិដោយរដ្ឋាភិបាលស៊ុយអែត
- ✓ ការពង្រឹងសមត្ថភាពស្រាវជ្រាវ និងនវានុវត្តន៍នៃការប្រែប្រួលអាកាសធាតុនៅក្នុងប្រទេសកម្ពុជាឡាវ និងវៀតណាម ហៅកាត់ថា ("REACT") ផ្ដល់មូលនិធិដោយសហភាពអឺរ៉ុប (EU)
- ✓ គម្រោងការកសាងសមត្ថភាពបន្សាំតាមរយៈការពង្រីកបច្ចេកវិទ្យាថាមពលកកើតឡើង វិញនៅតំបន់ជនបទ ប្រទេសកម្ពុជាផ្ដល់មូលនិធិដោយមូលនិធិអន្តរជាតិសម្រាប់ការអភិវឌ្ឍកសិកម្ម (IFAD)

- ✓ គម្រោងការធ្វើឱ្យប្រសើរឡើងភាពធន់នឹងការប្រែប្រួលអាកាសធាតុដល់សហគមន៍ មូលដ្ឋាននៅតំបន់ការពារធម្មជាតិក្នុងប្រទេសកម្ពុជាផ្តល់មូលនិធិក្រសួងបរិស្ថាន/កម្ម វិធីបរិស្ថានសហប្រជាជាតិ

លទ្ធផលទទួលបានពីកិច្ចសម្ភាសបានបង្ហាញថា កត្តាសំខាន់សម្រាប់ប្រធានស្រាវជ្រាវ និង របៀបវារៈគឺជាការអនុវត្តន៍គោលនយោបាយថ្នាក់ជាតិ និងការបំពេញបន្ថែមទៅលើគោលបំណង ដែលមានស្រាប់។ ជាក់ស្តែង សាកលវិទ្យាល័យភូមិន្ទកសិកម្ម (RUA) បានផ្តល់ព័ត៌មានដែល ជួយគាំទ្រដល់សេចក្តីសម្រេចចិត្តគ្រប់កម្រិត។ បន្ថែមពីនេះទៀត គោលបំណងរបស់សាកលវិទ្យា ល័យដើម្បីផ្ទេរចំណេះដឹង និងបច្ចេកវិទ្យាដល់និស្សិត បុគ្គលិកសិក្សា អ្នកស្រាវជ្រាវវ័យក្មេង និង នៅកម្រិតសហគមន៍មូលដ្ឋានដែលបានដើរតួនាទីយ៉ាងសំខាន់ក្នុងការផ្សព្វផ្សាយបន្ត។ តាមរយៈ ការបង្កើតឱ្យមានការស្រាវជ្រាវ និងអភិវឌ្ឍន៍ស្តីពីការប្រែប្រួលអាកាសធាតុ ស្ថាប័នគ្រឹះស្ថានឧត្តម សិក្សាមានសមត្ថភាពគ្រប់គ្រាន់ និងអាចទទួលបានការគាំទ្រផ្នែកមូលនិធិពីម្ចាស់ជំនួយជាតិ និង អន្តរជាតិ កាលពីមុន មិនមានស្ថាប័នថ្នាក់កណ្តាលណាមួយសម្របសម្រួលដល់បណ្តាញ ស្ថាប័នស្រាវជ្រាវនោះទេ។ គ្រឹះស្ថានឧត្តមសិក្សា និង ដេប៉ាតឺម៉ង់នៅក្នុងសាកលវិទ្យាល័យតែមួយ នៅតែបន្តធ្វើការជាលក្ខខណៈបុគ្គលក្រោមរូបភាពនៃលក្ខខណ្ឌស្រាវជ្រាវ និងធនធានដែលមាន ស្រាប់នៅក្នុងប្រទេស។ ហេតុដូចនេះ ការប្រាស្រ័យទាក់ទងនៅតែបន្តពឹងអាស្រ័យលើទំនាក់ ទំនងបុគ្គលរវាងអ្នកស្រាវជ្រាវ អ្នកសម្របសម្រួល បុគ្គលិករដ្ឋបាល និងមន្ត្រីជាន់ខ្ពស់នៅក្នុង មហាវិទ្យាល័យនីមួយៗ។ មិនមានស្តង់ដារណាមួយក្នុងការបង្កើតឱ្យមានសមសភាពក្រុមការងារ ស្រាវជ្រាវដែលបានកសាងឡើងយោងទៅលើតម្រូវការអ្នកជំនាញទាំងអស់នោះ និងប្រធានបទ ស្រាវជ្រាវ។ សម្រាប់ការអនុវត្តគម្រោងរួមគ្នារវាងស្ថាប័នដែលមានកិច្ចព្រមព្រៀងពហុភាគី (អនុសារណៈយោគយល់គ្នា) ត្រូវបានបញ្ជាក់ឡើង និងមានលិខិតកិច្ចព្រមព្រៀងដែលមានលក្ខខណ្ឌច្បាស់លាស់ត្រូវបានចុះហត្ថលេខាដោយអ្នកទទួលខុសត្រូវគម្រោង។ ប៉ុន្តែនៅពេលដែលមានភាគីអនុវត្តន៍ក្នុងស្ថាប័នតែមួយមិនមានកិច្ចព្រមព្រៀងជាផ្លូវការ និងបុគ្គលិកអាច ចូលរួមអនុវត្តន៍គម្រោងក្រោមលក្ខខណ្ឌធម្មតារបស់ស្ថាប័នពួកគេ។ បើទោះបីជាយ៉ាងណាក៏ដោយ ការបង្កើនយន្តការទាំងអស់ត្រូវបានរៀបចំបានល្អប្រសើរ តួនាទីរបស់សាកលវិទ្យាល័យចំពោះការស្រាវជ្រាវ និងការអភិវឌ្ឍសម្រាប់ការពង្រឹងសមត្ថភាពថ្នាក់ជាតិដែលនៅមានកម្រិត។ ផ្ទុយទៅវិញ ការអនុវត្តគម្រោងរួមគ្នាជាមួយមហាវិទ្យាល័យនិងមូលនិធិសម្រាប់អ្នកស្រាវជ្រាវវ័យ ក្មេងនិងមេរៀនគ្រោងនឹងដាក់បញ្ចូលក្នុងការស្រាវជ្រាវលើលើប្រធានបទជាក់លាក់ណាមួយ។ ការរៀបចំវេទិកាថ្នាក់ជាតិមួយក្នុងគោលបំណងដើម្បីចែករំលែកព័ត៌មានដល់គ្រឹះស្ថានឧត្តមសិក្សា បើយោងទៅតាមអ្នកចូលរួមផ្តល់

ចម្លើយបានបង្ហាញថា រាល់ព័ត៌មានទាំងអស់មិនទាន់មានស្តង់ ដារ ហើយក៏មិនអាចរកបានជាសាធារណៈទេ។

ការស្រាវជ្រាវ និងការអភិវឌ្ឍទទួលប៉ះពាល់ជាអវិជ្ជមានដោយសារខ្វះចំណេះដឹងនិងបទពិសោធន៍ថវិកានៅមានកំណត់ អវត្តមានទិន្នន័យក្នុងស្រុក សម្ភារចាស់ៗ និងមិនមានប្រើប្រាស់ គ្រប់គ្រាន់ក្នុងមន្ទីរពិសោធន៍ និងឧបករណ៍វាស់វែងសម្រាប់ទីវាល។ ឧបសគ្គទាំងអស់នេះផងដែរ បាននាំឱ្យមានអារម្មណ៍ថាមិនបានសម្រេចការងារ និងខ្វះការលើកទឹកចិត្តនូវអ្វីដែលបានអនុត្តន៍ សម្រាប់អ្នកស្រាវជ្រាវទាំងអស់ ការទំលាយចេញគំនិតច្នៃប្រឌិតនិងសក្តានុពលនៃការវិភាគតាម រយៈអង្កេត និងពន្យឺតការស្វែងរកដំណោះស្រាយសមរម្យដល់កិច្ចអន្តរគមន៍ក្នុងតំបន់។ ជាទូទៅ ចំពោះចំណេះដឹងសាស្ត្រាចារ្យ និស្សិត ចូលរួមក្នុងគម្រោងដើម្បីប្រមូលទិន្នន័យ ការងារទីវាល មូលនិធិស្រាវជ្រាវផ្សេងៗ និងការសរសេរនិក្ខេបបទបញ្ចប់ការសិក្សាដែលពួកគេដើរតួនាទីយ៉ាង សំខាន់ក្នុងការស្រាវជ្រាវដោយខ្លួនរបស់ពួកគេ និងចំណុចខ្វះខាតសម្រាប់ការស្រាវជ្រាវបែបវិទ្យា សាស្ត្រលើការប្រែប្រួលអាកាសធាតុ។ ឧទាហរណ៍ វិធីសាស្រ្ត និងម៉ូឌែលអាកាសធាតុធ្ងន់ធ្ងរ ឬ ការវិភាគទៅលើផលប៉ះពាល់ និងការតាមដាន ការវាយតម្លៃភាពងាយរងគ្រោះ ការវាយតម្លៃរូប ភាពលំហរអាកាស និងចំណេះដឹងផ្នែកទន់ដ៏មានសារៈសំខាន់ដូចជាប្រព័ន្ធព័ត៌មានភូមិសាស្ត្រ (GIS) ជាដើម។ ជារួម សំណូមពរលើប្រធានបទបណ្តុះបណ្តាលចាប់ពីចំណេះដឹងមូលដ្ឋានគ្រឹះ ការប្រែប្រួលអាកាសធាតុរហូតដល់ទទួលបានចំណេះដឹងជំនាញការស្រាវជ្រាវក្នុងវិស័យផ្សេងៗ៖

- ✓ មូលដ្ឋានគ្រឹះនៃការប្រែប្រួលអាកាសធាតុ
- ✓ ការបន្សាំ និងការកាត់បន្ថយប្រែប្រួលអាកាសធាតុ
- ✓ យុទ្ធសាស្ត្រការប្រែប្រួលអាកាធាតុ
- ✓ ការគ្រប់គ្រងកាកសំណល់ និងការបំពុលខ្យល់
- ✓ ម៉ូឌែលអាកាសធាតុ
- ✓ វិធីសាស្ត្រក្នុងការស្រាវជ្រាវការប្រែប្រួលអាកាសធាតុ
- ✓ ការប្រែប្រួលអាកាធាតុ និងសុវត្ថិភាពស្បៀងអាហារ
- ✓ ការភិវក្សជីវចម្រុះ
- ✓ ការគ្រប់គ្រងសត្វល្អិតចង្រៃ
- ✓ ការសរសេរសំណើស្នើសុំមូលនិធិ
- ✓ ការសរសេរបែបវិទ្យាសាស្ត្រ

# មេរៀនទី ៤ អង្គការក្រៅរដ្ឋាភិបាល និងសង្គមស៊ីវិល

## ១. កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ

ចំពោះការបន្សុាំទៅនឹងការប្រែប្រួលអាកាសធាតុ កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ មានភារកិច្ចផ្តោតសំខាន់លើ ការកសាងសមត្ថភាពអាជ្ញាធរជាតិនិងអាជ្ញាធរមូលដ្ឋាន អង្គការសង្គមស៊ីវិល និងផ្នែកឯកជន ដើម្បីលើកកម្ពស់នូវការបន្សុាំ និងសំរាលផល ប៉ះពាល់ ពីការប្រែប្រួលអាកាសធាតុ។

## ២. ធនាគារពិភពលោក - មូលនិធិសាកលសម្រាប់កាត់បន្ថយគ្រោះមហន្តរាយ

ធនាគារពិភពលោក-មូលនិធិសាកល សម្រាប់កាត់បន្ថយគ្រោះមហន្តរាយមានការចូលរួមយ៉ាងសកម្មក្នុងការផ្តល់នូវកញ្ចប់ថវិកាសម្រាប់ទីប្រឹក្សាបច្ចេកទេស ដើម្បីធានាឱ្យ មានការសំរបសំរួល និងអនុវត្តឱ្យកាន់តែប្រសើរនូវផែនការយុទ្ធសាស្ត្រជាតិ–កាត់បន្ថយគ្រោះមហន្តរាយ និងការដាក់បញ្ចូលនូវការកាត់បន្ថយគ្រោះមហន្តរាយទៅក្នុងផែនការអភិវឌ្ឍន៍ជាតិ រួមទាំងការបង្កើតនូវគោលការណ៍ណែនាំសម្រាប់ការដាក់ បញ្ចូលនូវ ការកាត់បន្ថយគ្រោះមហន្តរាយ ទៅក្នុងការកសាងផែនការអភិវឌ្ឍន៍ថ្នាក់ មូលដ្ឋាន និងការផ្តួចផ្តើមបញ្ចូលការកាត់បន្ថយគ្រោះមហន្តរាយទៅក្នុងគោល នយោបាយ និងកម្មវិធីទាំងឡាយរបស់ក្រសួងពាក់ព័ន្ធ។

## ៣. ជំនួយអភិវឌ្ឍន៍អន្តរជាតិប្រទេសដាណឺម៉ាក (DANIDA)

DANIDA កំពុងរួមវិភាគទានជាច្រើនចំពោះការអភិវឌ្ឍសង្គមប្រជាធិបតយ្យនៅថ្នាក់ ក្រោមជាតិតាមរយៈការគាំទ្រដល់ការបន្ថយភាពងាយរងគ្រោះ និងភាពក្រីក្រនៅទី ជនបទ ក្រីក ដោយផ្តល់ជំនួយទៅដល់រាជរដ្ឋាភិបាលក្នុង អនុវិស័យចំនួន ដែល ទាក់ទងទៅនឹងការគ្រប់គ្រងធនធានធម្មជាតិ និងការចិញ្ចឹមជីវិត ការគ្រប់គ្រងដីធ្លី បរិស្ថាន ស័យព្រៃឈើ និងជលផល។

## ៤. សហព័ន្ធអន្តរជាតិកាកបាទក្រហម និងសង្គមអឌ្ឍចន្ទក្រហមអន្តរជាតិ

តួនាទីរបស់សហព័ន្ធអន្តរជាតិកាកបាទក្រហម និងសង្គមអឌ្ឍចន្ទក្រហមអន្តរជាតិ (IFRC-RCS) ទាក់ទងនឹងការបន្សុាំទៅនឹងការប្រែប្រួលអាកាសធាតុ មានជាចំបង លើការសំរបសំរួល និងសហការលើការងារខាងក្រោមៈ

- កសាងសមត្ថភាព ជាពិសេសដល់មន្ត្រីរាជការនៅថ្នាក់ខេត្ត ស្រុក ឃុំ និងថ្នាក់ ភូមិ បុគ្គលិកអង្គការអន្តរជាតិ និងអង្គការមិនមែនរដ្ឋាភិបាល។
- ផ្តល់ជំនួយសង្គ្រោះបន្ទាន់_ការគៀងគរធនធាន និងចែកចាយសម្ភារៈសង្គ្រោះដល់ អ្នករងគ្រោះដោយធ្វើការងារជាមួយបណ្តាក្រសួង អាជ្ញាធរ សហព័ន្ធអន្តរជាតិ កាកបាទក្រហម ក្រុមការងារ

គ្រប់គ្រងគ្រោះមហន្តរាយសហប្រជាជាតិ ការិយា ល័យទទួលបន្ទុកសំរបសំរួលកិច្ចការមនុស្សធម៌ (OCHA ) និងអង្គការ អន្តរជាតិ និងអង្គការមិនមែនរដ្ឋាភិបាលខ្លះ និង

– កសាងសមត្ថភាពអំពីការគ្រប់គ្រងគ្រោះមហន្តរាយថ្នាក់មូលដ្ឋាន

## ៥. ភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិប្រទេសស៊ុយអែដ (SIDA)

កិច្ចសហការរបស់ (SIDA) ផ្តោតសំខាន់លើការគាំទ្រការធ្វើកំណែទម្រង់វិមជ្ឈការ និងប្រជាធិបតេយ្យនីយកម្ម និងសិទ្ធិមនុស្ស តាមការផ្តល់នូវការគាំទ្រដល់ការ អភិវឌ្ឍ សង្គមស៊ីវិល និងការអប់រំ។ ការគាំទ្រកម្មវិធីបរិស្ថាន និងកម្មវិធីទាក់ទង នឹងអាកាស ធាតុជាតិ ផ្តោតសំខាន់ និងមានការផ្សាភ្ជាប់ទៅនឹងវិធានការទាំងឡាយថ្នាក់តំបន់ ដើម្បីធ្វើឱ្យគោលគំនិតទាំងឡាយអាចសម្រេចជោគជ័យទាំងគោល គំនិតថ្នាក់តំបន់ និងទ្វេភាគី។ អ្វីដែលគួរឱ្យកត់ សំគាល់គឺថា តាមរយៈការគាំទ្រដល់ អភិបាលកិច្ចបែប ប្រជាធិបតេយ្យ (SIDA) បានផ្តល់ជំនួយដោយផ្ទាល់ដើម្បីបង្កើត និងពង្រឹងស្ថាប័ន និងប្រព័ន្ធដែលសំរួលឱ្យមាននូវសមមាត្រមួយចំណែកធំនៃការបងចកថវិកាជាតិ ដល់ថ្នាក់មូលដ្ឋាន និងការប្រើប្រាស់ថវិកាទាំងនោះសម្រាប់ការអភិវឌ្ឍនៅសហគមន៍ មូលដ្ឋាន ដូចជា លើប្រសិទ្ធិភាពវិស័យ កសិកម្ម ការប្រើប្រាស់ដីធ្លី និងការបន្សាំទៅ នឹងការប្រែប្រួលអាកាសធាតុ (Sida, 2008).

(SIDA)ក៏បានផ្តល់ជំនួយដល់គម្រោងសាកល្បងរួមគ្នាមួយអំពីការប្រែប្រួលអាកាសធាតុ (CCP) ដែលមានទិសដៅជួយដល់អង្គការមិនមែនរដ្ឋាភិបាលដាក់បញ្ចូល គម្រោង បន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ។ វាជាកិច្ចខិតខំប្រឹងប្រែងកសាងសមត្ថភាពដ៏ ធំធេងដែលឥឡូវកំពុងរចេញដំណើរឆ្ពោះទៅបង្កើតនូវការផ្តួចផ្តើមគំនិតស្រាវជ្រាវធ្វើ សកម្មភាពអំពីការប្រែប្រួលអាកាសធាតុថ្នាក់មូលដ្ឋានចំនួន ១០ នៅកម្ពុជា។

ប្រទេសកម្ពុជាបានដាក់ឱ្យអនុវត្តនូវ ផែនការយុទ្ធសាស្តសកម្មភាពជាតិ ២០០៨ - ២០១៣ សម្រាប់កាត់បន្ថយគ្រោះមហន្តរាយ (SNAP-DRR) របស់ខ្លួននៅ ឆ្នាំ ២០០៩ ផែនការនេះ មានរួមបញ្ចូលនូវសមាសធាតុ នៃការកាត់បន្ថយ គ្រោះមហន្តរាយទៅក្នុងគោលនយោបាយ តាមវិស័យ និងក្នុងផនការវិនិយោគ។ សកម្មភាព ជាអាទិភាពគឺការប្រើប្រាស់នូវវិធីសាស្ត្រម៉ាទ្រិច" មួយដែលមាន បញ្ចូលនូវសមាសធាតុកាត់បន្ថយគ្រោះមហន្តរាយទៅក្នុងការងាររបស់ក្រសួងសំខាន់ៗ (ដូចជា ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្រសួងធនធានទឹក និងឧតុនិយម ក្រសួងកសិកម្មរុក្ខាប្រមាញ់និងនេសាទ ក្រសួងអភិវឌ្ឍន៍ជនបទ និងក្រសួងសុខាភិ បាល)។ (Rinbo, E., 2009). មើលប្រអប់ ៣. លក្ខណៈសំខាន់ៗនៃSNAP-DRR (Danida, 2008)។

## ៦. អង្គការ GROUPE ENERGIES RENOUVELABLES, ENVIRONEMENTET SOLIDARITÉS ( GERES ) CAMBODIA

GERES Cambodia, ជាអង្គការមិនមែនរដ្ឋាភិបាលមួយដែលផ្តោតការងារជាចំបងលើ ការអភិវឌ្ឍ និងការប្រែប្រួលអាកាសធាតុ ជាអង្គការមិនមែនរដ្ឋាភិបាលមិនរកកំរៃ របស់ប្រទេសបារាំង បង្កើតឡើងនៅឆ្នាំ ១៩៧៦ ក្រោយព្រឹត្តិការណ៍កលិយុគបង លើកដំបូង - សព្វថ្ងៃនេះអង្គការ GERES កម្ពុជា មានការជាប់ទាក់ទីនជាពិសេស លើការអនុវត្តនូវដំណោះស្រាយផ្នែកវិស្វកម្មសម្រាប់ការអភិវឌ្ឍ និងផ្តល់នូវអ្នកជំនាញឯកទេសជាក់លាកសម្រាប់ការអភិរក្សបរិស្ថាន ការសំរាលនិងបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ កាត់បន្ថយការប្រើប្រាស់ថាមពល និងការលើកស្ទួយការ ចិញ្ចឹមជីវិតរបស់ជនក្រីក្រ។

## ៧. អង្គការ PLAN - កម្ពុជា

អង្គការ PLAN កម្ពុជាកំពុងអនុវត្តគម្រោង "ការកាត់បន្ថយភាពក្រីក្រដែលមាន បញ្ហាក់ ពីទំនោរបរិស្ថានរាំងស្ងួត ( PROVIDE )" ដែលជួយដល់អ្នកភូមិ ដើម្បីបង្កើននូវ ផលិតផលស្រូវរបស់គេនៅតំបន់ដែលមានទំនោរចំពោះភាពរាំងស្ងួត។ ពួកគេធ្វើការសាក ពិសោធន៍លើពូជស្រូវដែលមានភាពធន់ទៅនឹងអាកាសធាតុស្ងួតហួតហែងដោយធ្វើ ជាដៃគូជាមួយវិទ្យាស្ថានស្រាវជ្រាវដំណាំស្រូវអន្តរជាតិ និងវិទ្យាស្ថានស្រាវជ្រាវកសិកម្ម និងអភិវឌ្ឍកម្ពុជា។

## ៨. អង្គការអុកស្វាមសហរដ្ឋអាមេរិក

គម្រោងទាក់ទងនឹងការប្រែប្រួលអាកាសធាតុរបស់ អង្គការអុកស្វាមសហរដ្ឋអាមេរិក ផ្តោតសំខាន់លើការលើកកម្ពស់ការយល់ដឹងដល់សាធារណៈជនអំពីការបប្រួលអាកាសធាតុ ការព្យាករជាតុអាកាសទាក់ទងនឹងវិស័យកសិកម្ម ដើម្បីផ្តល់ដល់កសិក រនូវព័តមានអាកាសធាតុងយប្រើប្រាស់ និងទាន់ពេលវេលា និងការផ្តល់នូវវេទិកា សម្រាប់កិច្ចសន្ទនា ការចង់បណ្តាញ ឧទាហរណ៍ បណ្តាញថ្នាក់ជាតិស្តីពីការប្រែប្រួលអាកាសធាតុ។

## ៩. កម្មវិធីសកម្មភាពជាតិដើម្បីបន្សុំទៅនឹងការប្រែប្រួលអាកាសធាតុ

កម្មវិធីសកម្មភាពជាតិ ដើម្បីបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ ( NAPA ) សម្រាប់ ប្រទេសកម្ពុជា មានមូលដ្ឋានលើសេចក្តីសម្រេចចិត្តលេខ ២៨ ក្នុងសន្និសីទបណ្តា ភាគី ( CoP ) លើកទី ៧ នៃក្របខ័ណ្ឌអនុសញ្ញាសហប្រជាជាតិស្តីពី ការប្រែប្រួលអាកាសធាតុ ការបង្កើតនូវកម្មវិធីសកម្មភាពជាតិ ដើម្បីបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ ( NAPA ) ធ្វើឡើងតាមដំណើរការមានការចូលរួម ដែលរួមមានអ្នក ទាំងឡាយណាដែលមានការប៉ះពាល់ខ្លាំងពីការប្រែប្រួលអាកាសធាតុ មានដូចជា ប្រជាជននៅទីជនបទ និងជនក្រីកជាដើម។

ការប្រែប្រួលអាកាសធាតុ ជាបញ្ហាប្រឈមមួយសម្រាប់ពិភពលោក ជាពិសេសប្រទេសកំពុងអភិវឌ្ឍន៍ដែលមានការអភិវឌ្ឍតិចតួច ដូចជាប្រទេសកម្ពុជា ដោយសមត្ថភាពបន្សាំ និងបច្ចេកទេសនៅមានកម្រិត ដើម្បីឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ។ ផ្អែកលើកិច្ចព្រមព្រៀងទីក្រុងប៉ារីសស្តីពី អាកាសធាតុឆ្នាំ ២០១៥ ប្រទេសកម្ពុជា និងសហគមន៍អន្តរជាតិ បានឯកភាពរក្សាឱ្យបានការកើនឡើងសីតុណ្ហភាពមធ្យមសកលនៅក្រោម ២ °C លើកម្រិតមុនបដិវត្តន៍ឧស្សាហកម្ម និងបន្តកិច្ចប្រឹងប្រែងដើម្បីកម្រិតការកើនឡើងសីតុណ្ហភាពមធ្យមសកលនៅក្រោម ១,៥ °C ដោយផ្តោតលើការកាត់បន្ថយហានិភ័យ និងផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុ និងការអភិវឌ្ឍដែលបញ្ចេញឧស្ម័នផ្ទះកញ្ចក់តិច។ ហេតុដូចនេះ ប្រទេសនីមួយៗ ត្រូវរៀបចំរបាយការណ៍បច្ចុប្បន្នភាព NDC ដាក់ជូនទៅលេខាធិការដ្ឋានអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពី ការប្រែប្រួលអាកាសធាតុ រៀងរាល់៥ឆ្នាំម្តង។ តាមរយៈរបាយការណ៍NDCលើកទី២នេះ គិតត្រឹមឆ្នាំ២០៣០ ប្រទេសកម្ពុជា នឹងចូលរួមចំណែកកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់ចំនួនប្រមាណ៣៧% (កើនឡើងចំនួន ៣៩% បើប្រៀបធៀបជាមួយរបាយការណ៍NDCលើកទី១ ដែលបានដាក់ជូនទៅលេខាធិការដ្ឋានអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុនៅឆ្នាំ២០១៥)។ របាយការណ៍ NDCលើកទី២នេះ មិនគ្រាន់តែបង្ហាញអំពីជំហររបស់ប្រទេសកម្ពុជា ក្នុងការចូលរួមជាមួយសហគមន៍អន្តរជាតិដើម្បីកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់ និងបង្កើនសកម្មភាពបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុតែប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបង្ហាញនូវគោលនយោបាយ និងសកម្មភាពទាំងនេះ បានចូលរួមចំណែកយ៉ាងសំខាន់ក្នុងការអភិវឌ្ឍសេដ្ឋកិច្ចសង្គមប្រកបដោយចីរភាព តាមរយៈកម្មវិធី/គម្រោងដូចជា គម្រោង REDD+ និងថាមពលកកើតឡើងវិញជាដើម។ រាជរដ្ឋាភិបាលកោតសរសើរ និងអរគុណដល់ក្រសួងស្ថាប័នពាក់ព័ន្ធ ក្រុមការងារបច្ចេកទេសប្រែប្រួលអាកាសធាតុ និងដៃគូអភិវឌ្ឍន៍ដូចជា (**UNDP, World Bank, FAO, UNICEF, GGGI, UN Women** ។ល។) ដែលចូលរួមរៀបចំរបាយការណ៍ក្នុងការផ្តល់សុពលភាពដ៏មានសារៈសំខាន់នេះឱ្យលេចជារូបរាងឡើង និងពិនិត្យផ្តល់យោបល់លើសកម្មភាពអាទិភាពនៃផ្នែកនិងវិស័យនីមួយៗ ដើម្បីឱ្យសម្រេចបានផែនការមុនពេលសន្និសីទកំពូលលើកទី២៦នៃអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ (COP26) ឆ្នាំ២០២១ នៅប្រទេសអង់គ្លេស។

# ជំពូកទី ៤ ហិរញ្ញប្បទានការប្រែប្រួលអាកាសធាតុ


មេរៀនទី ១ ស្ថានភាពមូលនិធិបន្សាំការប្រែប្រួលអាកាធាតុនៅក្នុងប្រទេសកម្ពុជា

មេរៀនទី ២ ទិដ្ឋភាពទូទៅនៃមូលនិធិការប្រែប្រួលអាកាសធាតុ

មេរៀនទី ៣ ក្របខណ្ឌហិរញ្ញប្បទានការប្រែប្រួលអាកាសធាតុ

មេរៀនទី ៤ ការគ្រប់គ្រងហិរញ្ញប្បទានអាកាសធាតុ

- ៤.៤.១ កម្មវិធីហិរញ្ញប្បទានអាកាសធាតុថ្នាក់ជាតិ
- ៤.៤.២ មូលនិធិអាកាសធាតុថ្នាក់ជាតិ
- ៤.៤.៣ ការតាមដាន និងវាយតម្លៃ

# មេរៀនទី ១ ស្ថានភាពមូលនិធិបន្សាំការប្រែប្រួលអាកាសធាតុនៅក្នុងប្រទេសកម្ពុជា

## ១. ហិរញ្ញប្បទានអាកាសធាតុក្នុងប្រទេសកម្ពុជា

ការចំណាយលើការប្រែប្រួលអាកាសធាតុមានការកើនឡើងគួរកត់សម្គាល់នៅក្នុងប្រទេសកម្ពុជា ក្នុងរយៈពេលចាប់ ពី ៣៦៧ពាន់លានរៀលក្នុងឆ្នាំ២០០៩ ទៅដល់ ៨៤៧ ពាន់លានរៀលនៅឆ្នាំ ២០១៤។ ការបែងចែកការចំណាយលើការប្រែប្រួលអាកាសធាតុធៀបនឹងចំណូលក្នុងស្រុកសរុបក៏មាន ការ កើនឡើងផងដែរ ពី ០,៩%នៃGDP ក្នុងឆ្នាំ២០០៩ ទៅ ១,៣% នៃGDP ក្នុងឆ្នាំ២០១៤ តែមាន ចំណុច មួយធ្លាក់ចុះនៅក្នុងឆ្នាំ២០១១ (០,៨% នៃGDP)។ នៅក្នុងឆ្នាំ២០០៩ និង២០១០ត្រូវបានកត់ សម្គាល់ ថាមានការចំណាយខ្ពស់លើមហន្តរាយដែលបានកើតឡើងដោយសារព្យុះកសាណា និងទឹកជំនន់ ចុងឆ្នាំ ២០០៩។

នៅឆ្នាំ២០១៤, ១/៣នៃការចំណាយសាធារណៈបានចូលរួមពេញលេញ ឬដោយផ្អែកលើការ ប្រែប្រួលអាកាសធាតុ (រហូតដល់ ២៨,៩% ក្នុងឆ្នាំ២០០៩)។ ការចំណាយលើការប្រែប្រួលអាកាសធាតុ ដែលពាក់ព័ន្ធនឹង ទំងន់/បន្ទុកអាកាសធាតុត្រូវបានអនុវត្តន៍ ហើយហិរញ្ញប្បទានអាកាសធាតុបានកើន ឡើង ៤ ,១%នៃការចំណាយសាធារណៈ (មានការកើនឡើងពី ៣៣%ក្នុងឆ្នាំ២០០៩)។

តារាង ១០ ការបែងចែកការចំណាយលើការប្រែប្រួលអាកាសធាតុធៀបនឹងការចំណាយសរុប និងGDP

| | 2009 | 2010 | 2011 | 2012 | 2013 | 2014 |
|---|---|---|---|---|---|---|
| ការចំណាយលើការប្រែប្រួលអាកាសធាតុពាក់ព័ន្ធនឹងចំណាយសរុប | 28.9% | 28.9% | 29.8% | 30.9% | 28.7% | 33.3% |
| ការចំណាយលើការប្រែប្រួលអាកាសធាតុ ទៅនឹងការចំណាយសរុប | 3.3% | 3.5% | 2.9% | 3.1% | 3.3% | 4.1% |
| ការចំណាយលើការប្រែប្រួលអាកាស ធាតុ ទៅនឹងGDP | 0.9% | 1% | 0.8% | 0.9% | 1% | 1.3% |

បរិមាណវិភាជន៍ពីធនធានក្នុងស្រុក(ថវិកាជាតិ សម្រាប់ការចំណាយពាក់ព័ន្ធនឹងការប្រែប្រួល អាកាសធាតុបានកើនឡើងគួរកត់សម្គាល់ពី ៨៧ ពាន់លានរៀលក្នុងឆ្នាំ២០០៩ ទៅ ២១១ ពាន់លាន រៀលក្នុងឆ្នាំ២០១៤។ នៅក្នុងឆ្នាំ២០១៤ ស្ទើរតែមួយត្រីមាស (២៤,៨%) នៃការចំណាយសាធារណៈលើ

ការប្រែប្រួលអាកាសធាតុបានទទួលមូលនិធិពីថវិកាជាតិ។ ហិរញ្ញប្បទានខាងក្រៅនៅតែជាប្រភពដ៏ធំសម្រាប់ការចំណាយ។

ហិរញ្ញប្បទានខាងក្រៅមានទំហំធំសម្រាប់ ការចំណាយលើការប្រែប្រួលអាកាសធាតុក្នុងប្រទេសកម្ពុជា មានការផ្លាស់ប្តូរច្រើនជាងមូលនិធិក្នុងស្រុកដោយមានការធ្លាក់ចុះនៅក្នុងឆ្នាំ២០១១ នេះ ប្រហែលជាមកពីមានការកើតឡើងដំណាលគ្នានៃការធ្លាក់ចុះមូលនិធិដែលមានទំហំ ប៉ុន្តែទិន្នាការមានភាព វិជ្ជមានដែលមានការកើនឡើងចន្លោះឆ្នាំ២០១៣ និង២០១៤។

មានតែ ៤១% នៃកម្មវិធីដែលផ្តល់មូលនិធិពីខាងក្រៅទាំងនេះត្រូវបានបញ្ជូនតាមរយៈប្រព័ន្ធនេះក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុក្នុងឆ្នាំ ២០០៩ ស្ថានភាពបានផ្លាស់ប្តូរយ៉ាងខ្លាំងចាប់តាំងពីឆ្នាំ២០១១ដោយភាគច្រើននៃការចំណាយអាកាសធាតុដែលផ្តល់មូលនិធិខាងក្រៅហូរតាមរយៈប្រព័ន្ធក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (៦៧% នៅឆ្នាំ ២០១៤) ដែលភាគច្រើនសម្រាប់ហេដ្ឋារចនាសម្ព័ន្ធដែលមានទំហំធំនិងកសិកម្ម គម្រោង។

## ២. ប្រភពមូលនិធិ

តាមរយៈមូលដ្ឋានទិន្នន័យឆ្នាំ ២០១៤ បានបង្ហាញថា ជំនួយអភិវឌ្ឍន៍ផ្លូវការ ប្រទេសស៊ុយអែតសហគមន៍អឺរ៉ុបនិងអង្គការ UNIDO អ្នកផ្តល់ធនធានសំខាន់ក្នុងការទ្រទ្រង់ដល់វិស័យការប្រែប្រួល អាកាសធាតុជាមួយនឹងគណនីចំណាយចំនួន 24,1%, 23,2% និង11,7%នៃចំនួនប្រភពធនធានសំខាន់ៗសរុបសម្រាប់អាកាសធាតុ។ នៅឆ្នាំ ២០១៥ មូលនិធិជំនួយអភិវឌ្ឍន៍ផ្លូវការសរុបសម្រាប់ការប្រែប្រួល អាកាសធាតុជាវិស័យមួយដែលសំខាន់គឺថវិកា ៧,១ លានដុល្លារអាមេរិកសម្រាប់ដោះស្រាយការប្រែប្រួល អាកាសធាតុចំនួន១៤,៥% ចាប់ពីឆ្នាំ 2014 ខណៈដែលបញ្ជ្រាបការប្រែប្រួលអាកាសធាតុត្រូវបានគាំទ្រ "សញ្ញាសម្គាល់" បានធ្លាក់ចុះពី 15% ជុំវិញ_159,5 លានដុល្លារឆ្នាំ 2014 ។ វិស័យកសិកម្ម វិស័យដឹក ជញ្ជូន និងបរិស្ថានគឺជាវិស័យដែលមានការបញ្ជ្រាបការប្រែប្រួលអាកាសធាតុធំបំផុត "ជាមួយនឹងការរួម បញ្ចូលគ្នា 100 លានដុល្លារអាមេរិក (70% នៃមូលនិធិការបញ្ជ្រាបការប្រែប្រួលអាកាសធាតុ) ។ បរិស្ថាន ការប្រែប្រួលអាកាសធាតុ, ការធ្វើផែនការទីក្រុង កសិកម្ម និងអភិវឌ្ឍន៍ជនបទគឺជាវិស័យសំខាន់ ដែលបានបញ្ជ្រាបរួមចំណែកធំបំផុតនៃការប្រែប្រួលអាកាសធាតុនៃឥណទានក្នុងវិស័យរបស់ខ្លួនផ្ទាល់។

## ៣. គម្រោងបន្សាំ និងគម្រោងកាត់បន្ថយ

គម្រោងស្រាវជ្រាវនេះបានចាត់ថ្នាក់ចូលទៅក្នុងការបន្សាំអាកាសធាតុនិងការកាត់បន្ថយនិងបានរកឃើញថាភាគច្រើននៃការផ្តល់ហិរញ្ញប្បទាននេះត្រូវវិភាជន៍សម្រាប់គម្រោងការបន្សាំដោយឆ្នាំ។ មូល

ដ្ឋាន នៅលើ CPEIR, ចាប់តាំងពីឆ្នាំ 2009 ដល់ឆ្នាំ 2014 គម្រោងការបន្ស៊ាំត្រូវបានកើនឡើងពី 88,84 លាន ដុល្លារទៅ 207,69 លានដុល្លារ។

តារាង ១១ ការចំណាយសាធារណៈលើសកម្មភាពការបន្ស៊ាំ និងកាត់បន្ថយ

| វិស័យ | ថវិកា2009 (លានដុល្លារ) | ថវិកា2010 (លានដុល្លារ) | ថវិកា2011 (លាន ដុល្លារ) | ថវិកា2012 (លាន ដុល្លារ) | ថវិកា2013 (លាន ដុល្លារ) | ថវិកា2014 (លាន ដុល្លារ) |
|---|---|---|---|---|---|---|
| កាត់បន្ថយ | 3.04 | 5.56 | 5.10 | 6.19 | 7.88 | 4.12 |
| បន្ស៊ាំ | 88.84 | 105.04 | 97.47 | 116.11 | 152.15 | 207.69 |




រូបភាព ៧ ក្រាហ្វិចការចំណាយសរុបលើសកម្មភាពបន្ស៊ាំ និងកាត់បន្ថយផ្អែកលើទិន្នន័យ ODA និងថវិកាជាតិ

ប្រភព៖ MEF and CCCA, 2016, CPER 2009-2014




រូបភាព ៨ ក្រាហ្វិចការចំណាយហិរញ្ញប្បទានការប្រែប្រួលអាកាសធាតុតាមវិស័យ

## ៤. ការបន្ស៊ាំនឹងការប្រែប្រួលអាកាសធាតុតាមវិស័យ

វិភាជន៍តាមវិស័យបង្ហាញពីការផ្តោតអារម្មណ៍យ៉ាងខ្លាំងទៅលើប្រព័ន្ធធារាសាស្ត្រផ្លូវជាតិ និងផ្លូវលំជនបទធន់នឹងអាកាសធាតុមានចំនួន រៀល 433 ពាន់លាន 51% នៃការចំណាយសរុបលើអាកាសធាតុបានប៉ាន់ប្រមាណដោយ 20,7%លើឆ្លើយតបគ្រោះមហន្តរាយ, 16% លើការចិញ្ចឹមជីវិតធន់នឹងអាកាសធាតុ (រួមទាំងវិស័យកសិកម្ម) 3,4% លើសុខភាព, 1,3% លើវិស័យថាមពលនិង 1% លើការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ។

ការចំណាយធំបំផុតរបស់ក្រសួងនានារួមមានធនធានទឹកក្រសួងនិងឧតុនិយម(MOWRAM) ក្រសួងសាធារណៈការនិងដឹកជញ្ជូន (MPWT) ក្រសួងអភិវឌ្ឍន៍ជនបទ (MRD) ក្រសួងកសិកម្ម រុក្ខា

ប្រមាញ់ និងនេសាទ (MAFF) ក្រសួងសុខាភិបាល (MoH) និង ក្រសួងបរិស្ថាន (MoE)។ សរុបមក តម្រូវការ CAP ជាមធ្យមប្រចាំឆ្នាំរបស់ក្រសួងទាំង 15 716 ពាន់លានរៀល។ នៅឆ្នាំ 2014 ការ ចំណាយទាក់ទងនឹងអាកាសធាតុបានប៉ាន់ប្រមាណថាសម្រាប់ក្រសួងដូចគ្នាទាំងនេះ 778 ពាន់លាន រៀល (847 ពាន់លានរៀលប្រសិនបើភាគីពាក់ព័ន្ធផ្សេងទៀតត្រូវបានរួមបញ្ចូល)។ នេះបង្ហាញថាតម្រូវការ ហិរញ្ញប្បទានរបស់កម្ពុជាបានបញ្ជាក់នៅក្នុង CCAP គឺមិនប្រាកដប្រជានិងពិតជាស្របជាមួយនឹងកម្រិតន ការផ្តល់ហិរញ្ញប្បទានដែលអាចរកបាន។ កម្ពុជាពិតជាមានបំណងក្នុងការគៀរគរធនធានស្របជាមួយនឹង សេណារីយ៉ូកំណើនខ្ពស់បានបង្ហាញនៅក្នុងក្របខ័ណ្ឌហិរញ្ញប្បទានការប្រែប្រួលអាកាសធាតុ (832 ពាន់ លានរៀលសម្រាប់ឆ្នាំ 2014 ទល់នឹង 792 ពាន់លានរៀលក្នុងសេណារីយ៉ូកំណើនទាប)។

ទោះជាយ៉ាងណាវាគួរឱ្យកត់សម្គាល់ថាភាគច្រើននៃមូលនិធិនេះបានចំណាយនៅឆ្នាំ 2014 ត្រូវបានកម្មវិធីអាទិភាពការអភិវឌ្ឍ និងការបើកដំណើរការ CCAPsនេះ។ ជាលទ្ធផលការចំណាយទាក់ទង នឹងអាកាសធាតុមិនត្រូវអនុលោមយ៉ាងពេញលេញជាមួយនឹងផែនការទាំងនេះហើយនៅតែមានគម្លាតមូល និធិសម្រាប់សកម្មភាពថ្មីដែលបានរួមបញ្ចូលនៅក្នុងការ CCAPs នេះ។ វាមានឱកាសដើម្បីបង្កើនកម្រិតនៃអាកាសធាតុភាពពាក់ព័ន្ធនៃការចំណាយទាំងនេះផងដែរ។ ឧទាហរណ៍ ខណៈពេលដែលប្រព័ន្ធធារា សាស្ត្រមួយរួមចំណែកដល់ការបន្សាំនឹងការប្រែប្រួលអាកាសធាតុតាមរយៈការកាត់បន្ថយការពឹងផ្អែកលើ របបទឹកភ្លៀងពាក់ព័ន្ធអាកាសធាតុរបស់ខ្លួនគួរតែខ្ពស់ជាងនេះ ប្រសិនបើវាត្រូវបានរចនាឡើងជាពិសេស ដល់កម្មវិធីដែលគិតគូរពីការប្រួលអាកាសធាតុ(ឧទាហរណ៍៖ ទប់ទល់នឹងគ្រោះទឹកជំនន់)។ សម្លឹងមើលក្រសួងដែលមាន CCAP, ការវិភាជន៍ការចំណាយដែលទាក់ទងទៅនឹងការប្រែប្រួលអាកាសធាតុនេះគឺមានភាពទូលំទូលាយស្របជាមួយនឹងការបែងចែកធនធានតាមវិស័យនៅក្នុងCCAPs នេះ។ ក្រសួងធនធានទឹក និងឧតុនិយម (42,7%), ក្រសួងសាធារណៈការ និងដឹកជញ្ជូន (22,6%), ក្រសួងកសិកម្មរុក្ខប្រមាញ់ និងនេសាទ (8,9%) និងក្រសួងអភិវឌ្ឍន៍ជនបទ (8%)គឺក្រសួងសំខាន់បំផុតនៃការចំណាយដែលទាក់ទងនឹងអាកាសធាតុ។

ទោះជាយ៉ាងណា ខណៈពេលដែលហេដ្ឋារចនាសម្ព័ន្ធ (ក្រសួងធនធានទឹក និងឧតុនិយម ក្រសួងសាធារណៈការ និងដឹកជញ្ជូន ក្រសួងអភិវឌ្ឍន៍ជនបទ ព្រមទាំងក្រសួងរ៉ែ និងថាមពល និងក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍) ទទួលបានអត្ថប្រយោជន៍គ្រប់គ្រាន់នៃការផ្តល់មូលនិធិ ក្នុងនោះរួមមាន រួមទាំងមូលនិធិពីរាជរដ្ឋាភិបាលកម្ពុជា និងដៃគូអភិវឌ្ឍន៍, CCAP របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទនៅតែមិនទាន់បានទទួលមូលនិធិ (តែ45%នៃសេណារីយ៉ូសុទិដ្ឋិនិយមមួយ សន្មត់ថាហិរញ្ញប្បទានការប្រែប្រួលអាកាសធាតុទាំងអស់ត្រូវស្របជាមួយ CCAP) នេះក៏ជាករណីរបស់ក្រសួងបរិស្ថាន (34% ប៉ុណ្ណោះដែលបានផ្តល់មូលនិធិ), ក្រសួងសុខាភិបាល (ដែលផ្តល់មូលនិធិ 76%) ក្រសួងឧស្សាហកម្ម និងសិប្បកម្ម(ដែលផ្តល់មូលនិធិ 61%) និងក្រសួងអប់រំ យុវជន និងកីឡា(ដែលផ្តល់មូលនិធិ 7%) ព្រមទាំងក្រសួងផ្សេងៗទៀតបានទទួលហិរញ្ញប្បទានមានទំហំតូច។

ដោយសារតែ CCAPs ត្រូវបានអនុម័តជាលើកដំបូងនៅក្នុងឆ្នាំ 2014 តែវាជាការមិនទំនងដែលថាផែនការទាំងនេះមានឥទ្ធិពលយ៉ាងខ្លាំងលើហិរញ្ញប្បទានអាកាសធាតុសម្រាប់ឆ្នាំនោះ។ ការវាយតម្លៃជាក់លាក់បន្ថែមទៀតនៅថ្នាក់ក្រសួងនឹងត្រូវបានធ្វើឡើង ជាផ្នែកមួយនៃដំណើរត្រួតពិនិត្យមើលសម្រាប់ CCAPs មួយ។ ខណៈពេលហិរញ្ញប្បទានអាកាសធាតុគឺអាចរកបាននិងទូលំទូលាយស្របជាមួយនឹងអាទិភាពតាមវិស័យនោះមានឱកាសដើម្បីកែលម្អការបែងចែកមូលនិធិទាំងនេះ ទៅនឹងសកម្មភាពមានសក្តានុពលខ្ពស់បំផុតបានកំណត់នៅក្នុង CCAPs។

ក្រាហ្វិច១៣ ការវិភាជន៍ ២០១៤ការចំណាយលើការប្រែប្រួលអាកាសធាតុតាមក្រសួង




រូបភាព ៩ ក្រាហ្វិចការវិភាជន៍ ២០១៤ ការចំណាយលើការប្រែប្រួលអាកាសធាតុតាមក្រសួង

## ៥. គម្រោងមូលនិធិបន្សាំនៅក្នុងប្រទេសកម្ពុជា

គម្រោងមូលនិធិបន្សាំនៅក្នុងប្រទេសកម្ពុជាមានចំណងជើងថា "បង្កើនការបន្សាំទៅនិងការប្រែប្រួលអាកាសធាតុនៃការរស់នៅរបស់ប្រជាជននៅក្នុងតំបន់ការពារក្នុងប្រទេសកម្ពុជា" គឺជាគម្រោងបន្សាំមួយដែលបានធ្វើនៅក្នុងតំបន់ការពារដែលបានជ្រើសរើសចំនួន៥ នៅក្នុងប្រទេសកម្ពុជា។ គម្រោងនេះបានអនុម័តកញ្ចប់ថវិកាចំនួន ៤,៩៥៤,២៧៣ ដុល្លារ ដែលចាប់ផ្តើមអនុវត្តន៍ចាប់ពីខែតុលា ឆ្នាំ ២០១២ ដល់ខែមករា ឆ្នាំ២០១៧។ គម្រោងនេះបានទទួលមូលនិធិដំបូងចំនួន ១,១០៧,២៣១ ដុល្លារ នៅខែមករា ឆ្នាំ២០១២។ មូលនិធិបន្សាំនេះបានអនុវត្តន៍ជោគជ័យលើផ្នែកមួយចំនួននៃគម្រោងដែលបាន អនុវត្តន៍ទៅលើការដាំដើមឈើ ការបង្កើតអាងស្តុកទឹកសម្រាប់សហគមន៍ការពង្រឹងសមត្ថភាពក្នុងការ ដោះស្រាយបញ្ហា -ល-។ គោលដៅរបស់គម្រោងក្នុងឆ្នាំ២០១៥ នឹងទៅថ្ងៃអនាគតផ្តោតសំខាន់ទៅលើការ ពង្រីកតំបន់កសិកម្មធម្មជាតិតាមរយៈ CPAs( ឧ. សួនបន្លែ និងការចិញ្ចឹមសត្វជាដើម ) ការបង្កើតតំបន់ ទេសចរណ៍ធម្មជាតិ និងការជំរុញអោយដាំដើមឈើឡើងវិញនៅក្នុងតំបន់នោះ។

គម្រោងនេះស្ថិតនៅក្នុងអនុវត្តន៍របស់កម្មវិធីបរិស្ថានជាតិ និងក្រសួងបរិស្ថានកម្ពុជា។ គម្រោងនេះមានគោលបំណងបង្កើនការផ្គត់ផ្គង់ស្បៀងអាហារ និងកាត់បន្ថយការសិកវិចរិលដីនៅជើឌិកបឹងប្រីយ៍, ជុំធ្លក ស្ពម្រិច (តំបន់ដែនជម្រកសត្វព្រៃបឹងពែ), ពួកខ្វែង (តំបន់ដែនជម្រកសត្វភ្នំព្រិច) និង ជួបតាសុក (ឧទ្យានជាតិភ្នំគូលែន)។ ជាងនេះទៅទៀតសមិទ្ធិផលសំខាន់ៗនៃគម្រោងសកម្មភាពមានយ៉ាងហោចណាស់ ១៨៧៥ ហិចតានៃតំបន់ព្រៃដែលបានបំផ្លាញ, រួមបញ្ចូលទាំងការដាំពូជរុក្ខាជាតិឡើងវិញ បង្កើតផ្ទៃដីដាំស្រូវ និងតំបន់ដាំដុះផ្សេងៗទៀតដោយពហុប្រយោជន៍ប្រភេទដើមឈើណាដែលជួយបង្កើនទិន្នផលដំណាំយ៉ាងហោចណាស់១,៩០៧គ្រួសារក្នុងតំបន់កសិកម្ម(រួមទាំងការរៀបចំសួនបន្លែ ក្នុងទីទាំង ០២ ហិចតានៃដីមួយហិចតា) នៅក្នុងសហគមន៍ជុំវិញតំបន់ព្រៃ ដាំពូជស្រូវបង្កាត់ដែលធន់ទ្រាំទៅនឹងភាពរាំងស្ងួត ដើម្បីបង្កើនសក្តានុពលទិន្នផល ការដាំដុះដោយនិរន្តរភាព និងការប្រើប្រាស់រយៈពេលខ្លីហើយទទួលបានផលចំរុះ ។

ការវាយតម្លៃពីភាពងាយរងគ្រោះនៅក្នុងតំបន់គោលដៅរបស់គម្រោង បានរៀបចំឡើងដោយការប្រឹក្សាដោយទូលាយជាមួយដៃគូពាក់ព័ន្ធ រួមមានស្ថាប័នរដ្ឋ អជ្ញាធរមូលដ្ឋាន អង្គការក្រៅរដ្ឋាភិបាល សហគមន៍រងគ្រោះ(អ្នកទទួលផល និងដៃគូអភិវឌ្ឍន៍ផ្សេងៗទៀត។ លទ្ធផលនៃការវាយតម្លៃបានផ្ទេរទៅជាទិន្នន័យមូលដ្ឋាន និងសកម្មភាពគោលនយោបាយដើម្បីដោះស្រាយទៅនិងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ។ ការបន្សាំសហគមន៍មូលដ្ឋានត្រូវបានដាក់បញ្ចូលទៅក្នុងដំណើរការនៃការរៀបចំគម្រោង។

ក្នុងរយៈពេលនៃការចុះទស្សនានៅក្នុងតំបន់របស់គម្រោងក្នុងខែសីហា ឆ្នាំ២០១៦ សមាជិករបស់សហគមន៍តំបន់ការពារបានរាយការណ៍ថា ពួកគេមានឱកាសបានចូលរួមក្នុងការរៀបចំ និងអនុវត្តន៍ គម្រោង។ ប្រធានសហគមន៍ម្នាក់បាននិយាយថា " ប្រសិនបើមិនមានគម្រោងមូលនិធីបន្សាំ ព្រៃ និងសត្វ ព្រៃគឺមិនមាននៅទីនេះទេ។ តំណាងសហគមន៍បាននិយាយថា គម្រោងនេះបានផ្តល់អោយពួកគាត់នូវភាព ជាម្ចាស់ការលើការអនុវត្តនិងគ្រប់គ្រងគម្រោង។ ស្ទើរតែទាំងអស់នៃអ្នកទទួលផលមានជីវភាពប្រសើរឡើងតាមរយៈការផ្លាស់ប្តូរមុខរបរ ពីមុនការរស់នៅរបស់ប្រជាជនគឺពឹងផ្អែកទៅលើអនុផលព្រៃឈើ និងការ កាប់ឈើប៉ុន្តែឥឡូវនេះពួកគាត់បានផ្លាស់ប្តូរមកអនុវត្តន៍កសិកម្មខាងអាកាសធាតុវិញ។

# ៦. ទំនាក់ទំនងជាមួយនឹងផែនការជាតិបន្សាំ

## ៦.១ ភាពបន្សាំគ្នាទៅនឹងកម្រិតជាតិ

ការពិនិត្យជាទូទៅ និងការវិភាគឆ្លុះបញ្ចាំងទៅនឹងការតម្រង់ទិសដ៏ល្អរវាងពាក់ព័ន្ធនឹងគោលនយោបាយរបស់រដ្ឋាភិបាលដូចជា ផែនការយុទ្ធសាស្ត្រប្រែប្រួលអាកាសធាតុកម្ពុជា ផែនការសកម្មភាពលើវិស័យ ប្រែប្រួលអាកាសធាតុ និង INDC ដូចដែលបានរៀបរាប់នៅក្នុងអនុវិស័យខាងក្រោម៖

## ៦.២ ភាពបន្សុំគ្នាទៅនឹងផែនការសកម្មភាព និងផែនការយុទ្ធសាស្ត្រការប្រែប្រួលអាកាសធាតុ

សកម្មភាពនៅក្នុងផែនការសកម្មភាពក្នុងវិស័យប្រែប្រួលអាកាសធាតុ ដកស្រង់ស្ទើតែទាំងស្រុងពី វិស័យអទិភាព និងស្របទៅនឹងផែនការយុទ្ធសាស្ត្រប្រែប្រួលអាកាសធាតុកម្ពុជា។ មានសកម្មភាពចម្បងសរុបចំនួន១៧៨ ដែលសកម្មភាពទាំងអស់មានថវិការគ្រូបផ្សំសម្រាប់ឆ្នាំ១០១៤ ដល់២០១៨។ តារាង ទី ១២ គឺកំណត់បង្ហាញពីចំនួនសកម្មភាព CCAPដែលគាំទ្រទៅនឹងគោលបណណងទាំង៨របស់CCCSP។

តារាង ១២ ភាពបន្សុំគ្នារវាង CCAPs និង CCCSP គោលបំណងជាយុទ្ធសាស្ត្ររបស់ CCCSP

| គោលបំណងជាយុទ្ធសាស្ត្ររបស់ CCCSP | CCAP (ចំនួនសកម្មភាព) | CCAP (%) |
|---|---|---|
| 1. លើកកម្ពស់ភាពធន់នឹងអាកាសធាតុ តាមរយៈការធ្វើឱ្យប្រសើរឡើងនូវសន្តិសុខស្បៀង ទឹក និង ថាមពល។ | 37 | 14% |
| 2. កាត់បន្ថយភាពងាយរងគ្រោះតាមវិស័យ តំបន់ យេនឌ័រ និងសុខភាពនៅចំពោះមុខផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ។ | 51 | 20% |
| 3. លើកកម្ពស់ភាពធន់នឹងអាកាសធាតុ នៃប្រព័ន្ធអេកូឡូស៊ីសំខាន់ៗ បឹង) ទន្លេមេគង្គ តំបន់ឆ្នេរ តំបន់ខ្ពង់រាប ។ល។) ជីវៈចម្រុះ តំបន់ ទន្លសាប ការពារធម្មជាតិ និងតំបន់បេតិកភណ្ឌវប្បធម៌។ | 27 | 10% |
| 4. លើកកម្ពស់ការកសាងផែនការ និងបច្ចេកវិទ្យាដែលបញ្ចេញកាបូនតិច ដើម្បីគាំទ្រដល់ការអភិវឌ្ឍដោយចីរភាព។ | 56 | 22% |
| 5. កែលម្អសមត្ថភាព ចំណេះដឹង និងការយល់ដឹងសម្រាប់ឆ្លើយតបទៅនឹង ការប្រែប្រួលអាកាសធាតុ។ | 68 | 26% |
| 6. លើកកម្ពស់ការចូលរួម និងកិច្ចគាំពារសង្គមបែបបន្សុំនឹងការប្រែប្រួលអាកាសធាតុ ដើម្បីកាត់បន្ថយការបាត់បង់ និងការខូចខាត។ | 8 | 3% |
| 7. ពង្រឹងស្ថាប័ន និងក្របខ័ណ្ឌការងារសម្របសម្រួល សម្រាប់ឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុថ្នាក់ជាតិ។ | 11 | 4% |
| 8. ពង្រឹងកិច្ចសហការ និងចូលរួមយ៉ាងសកម្មនៅក្នុងកិច្ចខិតខំប្រឹងប្រែង ឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ នៅថ្នាក់តំបន់ និងពិភពលោក។ | 2 | 1% |
| **សរុប** | **260** | **100%** |

សកម្មភាពអាទិភាពចម្បងរបស់ CCAP (សរុប៦៦ភាគរយ) គាំទ្រទៅគោលបំណងយុទ្ធសាស្ត្រទាំង៣ ៖

- គោលបំណងយុទ្ធសាស្ត្រ ទី៥៖ បង្កើតសមត្ថភាព ចំណេះដឹង និងបណ្តុះបណ្តាលពីការឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ
- គោលបំណងយុទ្ធសាស្ត្រ ទី៤៖ ជំរុញផែនការបញ្ចេញកាបូនទាន និងបច្ចេកវិទ្យាដើម្បីគាំទ្រដល់ការអភិវឌ្ឍប្រកបដោយនិរន្តរភាព
- គោលបំណងយុទ្ធសាស្ត្រ ទី២៖ កាត់បន្ថយថ្នាក់វិស័យ ថ្នាក់តំបន់ ភាពងាយរងគ្រោះយេនឌ័រ និងហានិភ័យសុខភាពទៅនឹងផលប៉ះពាល់កាប្រែប្រួលអាកាសធាតុ

គោលបំណងទី៦ ទី៧ និងទី៨ មានទំនាក់ទំនងតិចទៅនឹងផែនការសកម្មភាពរបស់ CCAP ហើយវាផ្តោតសំខាន់ទៅលើការការពារសង្គម ក្របខ័ណ្ឌសម្របសម្រួល និងស្ថាប័ន និងការកិច្ចសហការ អន្តរជាតិ។ ទោះជាយ៉ាងណាក្តី វាមិនងាយស្រួលក្នុងការគ្រប់គ្រងការអនុវត្តសកម្មភាពអោយស្របជាមួយ និងលទ្ធផលរំពឹងទុកក្នុងគោលបំណងCCCSP។ ជាពិសេស៖

M & E៖ សូចនាករគឺមិនទាន់បានបង្កើតនៅឡើយទេនៅក្នុងCCCSP។ បន្ថែមលើនេះទៀត ដូចដែលបានពន្យល់នៅក្នុងផ្នែកទី ៣.៤ ដែលវាមិនទាន់បានបញ្ចូលនូវយន្តការសម្របសម្រួលដើម្បីវាស់វែងពីការរីកចម្រើននៅក្នុងការអនុវត្ត CCAP។

ភាពដែលអាចបត់បែនបាន៖សកម្មភាពរបស់CCAP គឺមិនបានដាក់បញ្ចូលទៅក្នុងការរៀបចំម៉ឹងម៉ាត់នោះទេ៖ មានសកម្មភាពជាច្រើនដែលបានបំពេញទៅនឹងសកម្មភាពដែលមិនបានកំណត់ ហើយវាអាចប្រែប្រួលទៅតាមពេលវេលាបានដូចដែលមាននៅក្នុងដំណើរការនៃការអនុវត្តហើយ គម្រោងនេះនឹងលើកយកទៅចចារជាមួយដៃគូអភិវឌ្ឍន៍។

ផ្នែកនៃការប្រែប្រួលអាកាសធាតុ៖ ទោះបីជាមានគោលការណ៍ណែនាំដោយ CCCA សកម្មភាពសំខាន់ៗជាច្រើនដែលមានកម្រិតទាបនៅក្នុងជាតុនៃប្រែប្រួលអាកាសធាតុ។

CCCSP ផ្តោតសំខាន់ទៅលើតំបន់រងគ្រោះដែលមិនមានកំណត់នៅក្នុងគោលដៅរបស់ CCAP ។ CCCSP ផ្តោតសំខាន់ទៅលើអ្នកដែលងាយរងគ្រោះបំផុត។ ទោះបីជាយ៉ាងនេះក្តី CCAOs មិនបានកំណត់អោយច្បាស់នៅឡើយទេ (សម្ភាសន៍ក្រុម CCCA)។ នេះគឺជាស្ថានភាពភូមិសាស្ត្រនៃតំបន់គោលដៅ៖ ក្រុមគោលដៅរបស់NCDM គឺសហគមន៍នៅតំបន់រងគ្រោះ ជាពិសេសគឺតំបន់ជនបទ និងជាយ ក្រុងគឺនៅតែជាតំបន់មិនអាទិភាព។

## ៦.៣ ទំនាក់ទំនងរវាង CCAPs និង INDCs

- ការអនុលោមខ្លាំងទៅតាមសកម្មភាពបន្សាំរវាង CCAPS និង INDC ។ ដូចដែលបានបង្ហាញនៅក្នុងតារាងខាងក្រោមគំនិតសំខាន់ៗនៃសកម្មភាពភាគច្រើនរបស់ INDC គឺដកស្រង់មកពី CCCPs លើលែងតែសកម្មភាពដែលយកមកពី Second National Communication (SNC) (2016)

តារាង ១៣ ភាពបន្សីគ្នារវាងការបន្សាំក្នុង INDCs និងការឆ្លើយតបរបស់ CCAPs

| លេខសកម្មភាព INDC | សកម្មភាពក្នុង INDC | លេខរៀងសកម្មភាព CCAP | ក្រសួង |
|---|---|---|---|
| 1 | ការជំរុញ និងការលើកកម្ពស់សមត្ថភាពបន្សាំរបស់សហគមន៍ និងការស្តារប្រព័ន្ធអេកូឡូស៊ីធម្មជាតិដើម្បីឆ្លើយតបទៅនឹងការផ្លាស់ប្តូរអាកាសធាតុ | 121 | MOE |
| 2 | ការអនុវត្តវិធានការនៃការគ្រប់គ្រង និងការការពារតំបន់ដើម្បីសម្របខ្លួនទៅនឹងការប្រែប្រួលប្រួលអាកាសធាតុ | 120 | MOE |
| 3 | ការពង្រឹងប្រព័ន្ធព័ត៌មានអាកាសធាតុ និងប្រព័ន្ធប្រកាសអាសន្ន | 41 | MOWRAM |
| 4 | ការអភិវឌ្ឍ និងស្តារទំនប់ការពារទឹកជំនន់សម្រាប់ការអភិវឌ្ឍកសិកម្ម / តំបន់ទីក្រុង | 168 | MOWRAM |
| 5 | បង្កើនការប្រើប្រាស់ស្ថានីយ៍បូមចល័ត និងស្ថានីយ៍អ ចិន្ត្រៃយ៍នៅក្នុងការឆ្លើយតបទៅនឹងការរាំងស្ងួតខ្នាតតូច និងការលើកកម្ពស់ការស្រាវជ្រាវទឹកក្រោមដីឆ្លើយតបទៅ នឹងគ្រោះរាំងស្ងួត និងហានិភ័យអាកាសធាតុ | 167 | MOWRAM |
| 6 | ការអភិវឌ្ឍប្រព័ន្ធធារាសាស្ត្រសហគមន៍អាកាសធាតុ ដើម្បីបង្កើនទិន្នផលពីផលិតកម្មកសិកម្មនៃដំណាំស្រូវ | 129 | MOWRAM |
| 7 | លើកកម្ពស់ភាពធន់អាកាសធាតុនៃកសិកម្មតាមរយៈការកសាងទំនប់ទឹកសមុទ្រនៅតំបន់ឆ្នេរនិងការពង្រីកបន្ថែមប្រព័ន្ធកសិកម្មធ្លាតវៃខាងអាកាសធាតុ | 132 | MOWRAM |
| 8 | ការអភិវឌ្ឍពូជដំណាំដែលសមស្របទៅនឹងតំបន់ កសិកម្មធម្មជាតិ (AEZ) និងភាពធន់ការប្រែប្រួល អាកាសធាតុ (រួមបញ្ចូលទាំងតំបន់ឆ្នេរសមុទ) | 84 | MAFF |
| 9 | ការលើកកម្ពស់ប្រព័ន្ធផលិតកម្មវារីវប្បកម្មនិងការអនុវត្តដែលមានបន្សាំការប្រែប្រួលអាកាសធាតុ | 108 | MAFF |

| | | | |
|---|---|---|---|
| 10 | ការជួសជុលនិងស្តារហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ដែលមានស្រាប់ និងធានាប្រតិបត្តិការដែលមានប្រសិទ្ធភាព និងថែទាំដោយការយកចិត្តទុកដាក់លើផលប៉ះពាល់ពីការ ប្រែប្រួលអាកាសធាតុ | 169 | MPWT |
| 11 | ការពង្រីកប្រយុទ្ធនឹងជម្ងឺគ្រុនចាញ់ឆ្ពោះទៅរកការត្រួត ពិនិត្យមុនការលុបបំបាត់-ស្ថានភាពជម្ងឺគ្រុនចាញ់ | 37 | MOH |
| 12 | ការពង្រីកនៃកម្មវិធីជាតិលើការឆ្លងមេរោគតាមផ្លូវដង្ហើមធ្ងន់ធ្ងរ, ជម្ងឺរាគរូស និងជម្ងឺអាសន្នរោគក្នុងតំបន់ងាយជួប នឹងគ្រោះមហន្តរាយក្នុងនោះមានទាំងការឃ្លាំមើលការ រៀបចំនិងការស្រាវជ្រាវអំពីជម្ងឺបង្កឡើងដោយទឹក និង ជម្ងឺកង្វះអាហារដោយផ្សារភ្ជាប់ជាមួយនឹងការប្រែប្រួល អាកាសធាតុ | 38 | MOH |
| 13 | ការពង្រឹងសមត្ថភាពបច្ចេកទេសនិងស្ថាប័នដើម្បីធ្វើការ វាយតម្លៃការប្រែប្រួលអាកាសធាតុ ការព្យាករណ៍ការប្រែ ប្រួល និងបញ្ជ្រាបការប្រែប្រួលអាកាសធាតុទៅក្នុង ផែនការអភិវឌ្ឍតាមវិស័យ និងអនុវិស័យ | From SNC | MOE ? |

មិនមានជាការឆ្លើយឆ្លងមួយទៅមួយរវាងសកម្មភាពកាត់បន្ថយនេះក្នុង INDC និងនៅក្នុង CCAPs ដូចដែលបានបង្ហាញនៅក្នុងតារាងទី ៣ ខាងក្រោម, សកម្មភាពកាត់បន្ថយត្រូវបានចេញមកទាំង អស់ពីក្រុម SNC ជាជាង CCAPs នោះប៉ុន្តែការអនុវត្តរំពឹងថាតាមរយៈការ CCAPs។ SNC បានបង្កើតជា មូលដ្ឋាននៃផ្នែកការកាត់បន្ថយពី INDC នេះដោយសារតែSNC បានផ្តល់នូវការព្យាករណ៍ឧស្ម័នផ្ទះកញ្ចក់, ជម្រើសកាត់បន្ថយ និងចក្ខុវិស័យដល់ឆ្នាំ 2030 ដែលនេះជាអ្វី INDC នេះតម្រូវឱ្យមានខណៈ CCAPs មានការផ្តោតជាក់លាក់តិចជាងនេះមិនបានបង្ហាញការព្យាករណ៍ និងថយចុះ, និងរយៈពេលការអន្តរាគមន៍របស់ពួកគេ( 2014-18 ) ។

តារាង ១៤ ភាពបន្សុីគ្នារវាងកាត់បន្ថយក្នុង INDCs និងការឆ្លើយតបរបស់ CCAPs

| លេខក្នុង INDC | សកម្មភាព INDC | លេខក្នុង CCAP | សកមកម្មភាពក្នុងCCAP | ក្រសួង |
|---|---|---|---|---|
| 12 | ថាមពលកកើតឡើងវិញមួយសម្រាប់វិស័យឧស្សាហកម្ម | 14 | ឧស្សាហកម្មថាមពល៖ តំណភ្ជាប់បណ្តាញ | MIH |

| | | | | |
|---|---|---|---|---|
| 13 | លើកកម្ពស់ការបង្កើតថាមពលកកើត ឡើងវិញនៅលើតំបន់និងសហបង្កើត សម្រាប់វិស័យឧស្សាហកម្មព្រមទាំងតំបន់ សេដ្ឋកិច្ចពិសេស | | ថាមពលកកើតឡើងវិញ (ថាមពលព្រះអាទិត្យ, វារីអគ្គិសនី ជីវម៉ាស និងជីវឧស្ម័ន) និងការតភ្ជាប់ថាមពលកកើតឡើងវិញបែបចំរុះទៅបណ្តាញនេះ បណ្តាញអគ្គិសនីមិនតភ្ជាប់ដូចជាប្រព័ន្ធថាមពលព្រះអាទិត្យតាមផ្ទះ, វារីអគ្គិសនី (មធ្យម, តូចនិងខ្នាតតូច); ការលើកកម្ពស់ប្រសិទ្ធភាពថាមពលដោយអ្នកប្រើចុងក្រោយ | |
| 15 | សាកល្បងនិងឯកសារយុទ្ធសាស្ត្រសម្រាប់ការបម្លែងកាកសំណល់ទៅជាឧស្សាហកម្មថាមពល | | | |
| 88 | ការវាយតម្លៃនៃសក្តានុពលនៃកម្មវិធីថាមពលកកើតឡើងនៅក្នុងវិស័យ ឧស្សាហកម្ម | | | |
| 95 | ការវាយតម្លៃតម្រូវការបច្ចេកវិទ្យាសម្រាប់ ការកាត់បន្ថយ GHGs ក្នុងវិស័យថាមពល | 15 | ការកាត់បន្ថយការបំភាយឧស្ម័នជាលទ្ធផលពីរោងម៉ាស៊ីនកិនស្រូវកាត់ដេរនិងការងារឡេតដ្ឋ | MME |
| 55 | ជំរុញការថែទាំ និងត្រួតពិនិត្យយានយន្ត | 16 | ការត្រួតពិនិត្យម៉ូទ័រយានយន្ត ការធ្វើដំណើរសារធារណៈ និងការកែលម្អប្រសិទ្ធភាពយានយន្ត | MPWT |
| 8 | រៀបចំការអនុវត្ត ធនធាន និងប្រសិទ្ធភាពថាមពលសម្រាប់ឧស្សាហកម្ម និងសហគ្រាសខ្នាតមធ្យម | 17 | ចង្ក្រានប្រសិទ្ធភាពឡជីវឧស្ម័ន និងធុងចំពោះទឹក | MIH |
| 71 | រៀបចំ និងអនុវត្តន៍ក្របខណ្ឌគតិយុត្តិ និងយន្តការ REDD+ | 18 | បង្កើនគម្រោងព្រៃឈើ 60%នៃផ្ទៃដីរបស់ជាតិ និងរក្សាគម្របនេះរហូតដល់ឆ្នាំ ២០៣០ | MAFF |

ប្រភព៖ ក្រុមអ្នកវិភាគលើ CCAPs និង INDC

## ៧. បរិយាកាសអំណោយផលផ្នែកការគាំទ្របរិស្ថាន និងរដ្ឋាភិបាលសម្រាប់ដំណើរការបន្សុំជាតិ

ការរៀបចំ CCCSP ជាជំហានយ៉ាងសំខាន់ឆ្ពោះទៅរកការប្រែប្រួលអាកាសធាតុដែលបង្កប់ក្នុងផែនការអភិវឌ្ឍជាតិនិងផែនការអភិវឌ្ឍតាមវិស័យនៃក្រសួងពាក់ព័ន្ធ។ បន្ទាប់ពីការអនុម័ត CCCSP បានគេបញ្ចូលនៅក្នុង ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ 2014-2018 ។

នៅតាមវិស័យក្រសួងស្ថាប័នពាក់ព័ន្ធបានចាប់ផ្តើមរៀបចំផែនការសកម្មភាពការប្រែប្រួលអាកាសធាតុដោយសម្របទៅ CCCSP និងផែនការអភិវឌ្ឍន៍វិស័យរបស់ពួកគេ។ នៅចុងឆ្នាំ 2014 នេះជាលើកដំបូងដែលមានក្រសួងពាក់ព័ន្ធចំនួនប្រាំបីត្រូវបានអនុម័ត CCAPs របស់ពួកគេពេលគឺក្រសួងកសិកម្ម រុក្ខប្រមាញ់ និងនេសាទ (MAFF), ក្រសួងអប់រំ យុវជន និងកីឡា (អយក) ក្រសួងធនធានទឹក និងឧតុនិយម (MOWRAM) ក្រសួងកិច្ចការនារី (MoWA), ក្រសួងសាធារណៈការ និងដឹកជញ្ជូន (MPWT), គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ (NCDM) ក្រសួងអភិវឌ្ឍន៍ជនបទ (MRD) និងក្រសួងសុខាភិបាល (MoH)។

នេះជាលើកទីពីរ ដែលមានសង្កត់ភាពជាមួយបណ្តាក្រសួងពាក់ព័ន្ធចំនួនប្រាំមួយបានអនុម័ត CCAPS នៅឆ្នាំ 2015។ ក្រសួងទាំងនោះរួមមាន ក្រសួងបរិស្ថាន (MoE), ក្រសួងទេសចរណ៍ (MOT), ក្រសួងព័ត៌មាន (MoINFO), រៀបចំដែនដី នគរូបនីយកម្ម និងសំណង់ (MLMUPC) ក្រសួងរ៉ែនិងថាមពល (MME) និងក្រសួងឧស្សាហកម្មនិងសិប្បកម្ម (MIH) ។

ដូចគ្នានេះផងដែរក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍បានរៀបចំ CCAP នេះប៉ុន្តែផែនការនេះមិនត្រូវបានអនុម័ត។ ដូច្នេះសរុបមាន 14 ក្រសួងពាក់ព័ន្ធដែលមានផែនសកម្មភាពការប្រែប្រួលអាកាសធាតុបានអនុម័ត។ ការរៀបចំ CCCSP និង CCAP បានអនុវត្តន៍តាមគោលការណ៍ណែនាំសម្រាប់រៀបចំគោលនយោបាយមកពីទីស្តីការគណៈរដ្ឋមន្ត្រី (ឆ្នាំ 2011) ដោយមានការគាំទ្របច្ចេកទេសពីនាយកដ្ឋានការប្រែប្រួលអាកាសធាតុ (DCC) និងសម្ព័ន្ធភាពប្រែប្រួលអាកាសធាតុកម្ពុជា (CCCA) ។

បានអនុម័តផែនការកម្មភាពការប្រែប្រួលអាកាសធាតុចំនួនសកម្មភាពរហូតដល់ 171 ដែលត្រូវការថវិកាដល់ 865,47លានដុល្លារ សម្រាប់អនុវត្តន៍ឆ្នាំ 2014-20183 ។ នាពេលថ្មីៗនេះ, ការងារដែលអនុវត្តន៍ដោយហិរញ្ញប្បទានត្រៀមអាកាសធាតុ(GIZ)បានវាយតម្លៃកង្វះចន្លោះហិរញ្ញវត្ថុអប្បបរមាសម្រាប់ការ ប្រតិបត្តិ CCAP ។ វាត្រូវបានគេរកឃើញថាវានៅមានគម្លាតហិរញ្ញប្បទានចំនួន 71,68% នៃចំនួនប៉ាន់ប្រមាណសរុប ។

តារាង ១៥ គម្លាតផ្នែកហិរញ្ញវត្ថុ CCAP សម្រាប់អនុវត្តន៍ផែនការសកម្មភាពការប្រែប្រួលអាកាសធាតុសម្រាប់ CCAPs ដែលបានអនុម័ត (ប្រភព: សេចក្តីព្រាងរបាយការណ៍ស្តីពីគម្លាតហិរញ្ញវត្ថុជីអាយហ្សិត CCAP ឆ្នាំ 2016)

| លរ | ក្រសួង | ចំនួន | តម្លៃ លាន USD | # សកម្មភាពដែលទទួលបានមូលនិធិ | ហិរញ្ញប្បទានបានទទួល (លាន USD) | កង្វះខាត (លាន USD) | កង្វះខាត % |
|---|---|---|---|---|---|---|---|
| 1 | MAFF | 29 | 187.55 | 8 | 54.69 | 132.86 | 70.84 |
| 2 | MIH | 17 | 11 | 2 | 11.7 | -0.70 | -6.39 |
| 3 | MLMUPC | 8 | 9.12 | 1 | 0.25 | 8.87 | 97.26 |
| 4 | MME | 9 | 5.02 | 1 | 0.25 | 4.77 | 95.02 |
| 5 | MOE | 17 | 27.67 | 11 | 19.29 | 8.38 | 30.28 |
| 6 | MOEYS | 7 | 10.6 | 1 | 0.35 | 10.25 | 97.70 |
| 7 | MOH | 11 | 46.8 | 1 | 0.40 | 46.4 | 99.15 |
| 8 | MOINFO | 5 | 4.33 | 1 | 0.13 | 4.205 | 97.12 |
| 9 | MoT | 8 | 3.4 | 1 | 0.13 | 3.28 | 96.79 |
| 10 | MoWA | 6 | 3.62 | 1 | 0.10 | 3.52 | 97.24 |
| 11 | MoWRAM | 16 | 272.5 | 3 | 75.2 | 197.3 | 72.40 |
| 12 | MPTC | 6 | 4.61 | 0 | 0.00 | 4.61 | 100 |
| 13 | MPWT | 11 | 210.98 | 3 | 8.21 | 202.775 | 96.11 |
| 14 | MRD | 10 | 56.53 | 2 | 74.33 | -17.8 | -31.00 |
| 15 | NCDM | 11 | 11.75 | 1 | 0.10 | 11.65 | 99.15 |
| | Total | 171 | 865.47 | 37 | 245.12 | 620.37 | 71.68 |

ភាគច្រើននៃ CCAPs បានអនុម័តដែលឥឡូវនេះកំពុងត្រូវបានអនុវត្តន៍តាមរយៈមធ្យោបាយផ្សេងៗពោលគឺ (1) ដំណើរការថវិកានិងការធ្វើផែនការថ្នាក់ជាតិ (2) គម្រោងការប្រែប្រួលអាកាសធាតុដែលផ្តល់មូលនិធិដោយដៃគូអភិវឌ្ឍន៍និង (3) ការផ្តល់ជំនួយពី DCC /កម្មវិធី CCCA ដើម្បីអនុវត្តន៍សាកល្បងលើអាទិភាពរបស់ CCAP ។

ដំណើរការផែនការនិងថវិកាជាតិ តម្រូវឱ្យភ្នាក់ងាររដ្ឋាភិបាលដាក់ស្នើសំណើរថវិការបស់ខ្លួនជារៀងរាល់ឆ្នាំ( ចំណាយចរន្តនិងចំណាយមូលធន ) ទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ( MEF តាមរយៈ ថវិកាកម្មវិធីនិង ក្រសួងផែនការតាមរយៈការធ្វើបច្ចុប្បន្នភាពនិង / ឬការស្នើសុំសកម្មភាពថ្មីនៅក្នុង កម្មវិធី វិនិយោគសាធារណៈ (PIP) ដែលនឹងត្រូវដាក់ជូនទៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា( CDC) ដើម្បីផ្តល់មូលនិធិទាំងខាងក្នុង និងមូលនិធិខាងក្រៅ។

ការពិនិត្យឡើងវិញនូវចំណាយសាធារណៈលើអាកាសធាតុសម្រាប់ឆ្នាំ 2013-2014 ត្រូវបានរៀបចំដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដោយក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព និងកម្មវិធី CCCA ជាអ្នកផ្តល់ជាតុចូល បច្ចេកទេស របាយការណ៍ CPER ឆ្នាំ 2016 នេះបានបង្ហាញថានៅឆ្នាំ 2014 ស្ទើរ តែមួយភាគបួន (24,8%) នៃការចំណាយ សាធារណៈលើអាកាសធាតុត្រូវបានឧបត្ថម្ភដោយថវិកាជាតិ។ ជាទូទៅគម្រោងដែលមានបញ្ហាបការប្រែប្រួលអាកាសធាតុ ឬផ្តោតលើការប្រែប្រួលអាកាសធាតុទទួល បានមូលនិធិគាំទ្រពីដៃគូអភិវឌ្ឍន៍ខាងក្រៅ។

យោងតាមរបាយការណ៍ CPER ឆ្នាំ២០១៦ នៅកំឡុងឆ្នាំ២០១៤ ថវិកាប្រែប្រួលអាកាសធាតុចំនួនពីរភាគបី រឺស្មើនឹង៦៧%ទទួលបានមកពីដៃគូខាងក្រៅ ដែលផ្តោតទៅលើវិស័យហេដ្ឋារចនាសម្ព័ន្ធ និងកសិកម្ម លើសពីនេះ ឃើញមានការកើនឡើងប្រព័ន្ធថវិការបស់រាជរដ្ឋាភិបាលតាមរយៈក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលថវិកាទាំងនេះ បានផ្តល់សារៈសំខាន់សម្រាប់បញ្ជ្រាបការប្រែប្រួលអាកាសធាតុទៅក្នុងផែនការអភិវឌ្ឍន៍វិស័យនៅថ្នាក់ជាតិ។

គម្រោងអភិវឌ្ឍន៍ជោគជ័យរបស់ CCCSP និង CCAPs_កម្មវិធី CCCA នៃនាយកដ្ឋានប្រែប្រួលអាកាសធាតុ បានគាំទ្រដល់ក្រសួងចំនួន១៤ ក្នុងការអនុវត្ត សាកល្បងសកម្មភាពអាទិភាពរបស់ CCAP ជាពីរដំណាក់កាលនៃថវិកាគាំទ្រ ដែលមានប្រមាណចន្លោះពី ១០០០០០ ទៅ ៤៥០០០០ដុល្លារតាមក្រសួងនីមួយៗ។ ថវិកាដំណាក់កាលទីមួយបានគាំទ្រដល់ក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ, ក្រសួងអប់រំ, ក្រសួងធនធានទឹក និងឧតុនិយម, ក្រសួងកិច្ចការនារី, ក្រសួងសាធារណៈការ និងដឹកជញ្ជូន គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ, ក្រសួងអភិវឌ្ឍន៍ជនបទ និងក្រសួងសុខាភិបាល ដែល បានចាប់ផ្តើមនៅឆ្នាំ២០១៥។ ថវិកាដំណាក់កាលទីពីរបានគាំទ្រដល់ក្រសួងដែល នៅសល់ដូចជាក្រសួង បរិស្ថាន ក្រសួងពាណិជ្ជកម្ម ក្រសួងព័ត៌មាន ក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ ក្រសួងរ៉ែ និងថាមពល និងក្រសួងឧស្សាហកម្ម និងសិប្បកម្ម ដែលបានចាប់ផ្តើមនៅឆ្នាំ២០១៦។

## ៧.១ គម្លាតចន្លោះនៃការរៀបចំ NAP នៅកម្ពុជា

តម្រូវការថវិកាក្នុងការអនុវត្តបានកើនឡើង បានធ្វើអោយសកម្មភាពរបស់ CCAPs) នៅមិនទាន់មានថវិកានៅឡើយនៅខែសីហា ឆ្នាំ២០១៥ ក្របខ័ណ្ឌហិរញ្ញវត្ថុការប្រែប្រួលអាកាសធាតុបានព្យាករណ៍ការចំណាយ ក្នុងការឆ្លើយតបទៅនឹងតម្រូវការសាធារណៈប្រមាណ ១,១៣ពាន់លានដុល្លារសម្រាប់ឆ្នាំ២០១៤-២០១៨ នេះបើយោងទៅតាមផែនការសកម្មភាពបច្ចុប្បន្ន និងការព្យាករណ៍ទៅតាមវិស័យដែលមិនទាន់បានរៀបចំផែនការនាពេលនោះ។

ផ្អែកតាមការវិភាគដោយកម្មវិធីហិរញ្ញប្បទានត្រៀមសម្រាប់ការប្រែប្រួលអាកាសធាតុរបស់ GIZ បានគណនាចំនួនថវិកាដែល ខ្វះខាតសម្រាប់អនុវត្តន៍ CCAP ចំនួនពាក់កណ្ដាលនៃ ៨៦៥លានដុល្លារសម្រាប់អនុវត្តសកម្មភាពប្រែប្រួលអាកាស ជាតុអាទិភាពរបស់ក្រសួងមួយចំនួនសម្រាប់ឆ្នាំ២០១៨ ២០១៩ នៅមិនទាន់មាននៅឡើយ ដែលតម្រូវអោយមាន ការខិតខំប្រឹងប្រែងក្នុងការគៀងគរធនធាន។ តម្រូវការ ដើម្បីទទួលបានថវិកាត្រូវបានកំនត់ដោយកត្តាជាច្រើនដូចជាសមត្ថភាពក្នុងការអនុវត្ត តំបន់គោលដៅក្នុងការបន្សាំ កម្រិតនៃការប្រៀបធៀបរវាងឥទ្ធិពលនៃការប្រែប្រួល អាកាសធាតុ ការចំណាយលើការបន្សាំ និងកាចំណាយក្រោយការបន្សាំ។

ជាទូទៅការចំណាយលើការបន្សាំនៅកម្ពុជាមានកម្រិតខ្ពស់ ដែលធ្វើអោយមានកង្វះខាតថវិកានៅ CCAP ដែលមានប្រមាណច្រើនជា ៤០០លានដុល្លាររហូតដល់ឆ្នាំ២០១៨។

## ៧.២ ការគៀងគរធនធានសម្រាប់សកម្មភាពបន្សាំ

យុទ្ធសាស្រ្តក្នុងការគៀងគរធនធានបន្ថែម ត្រូវផ្តោតលើប្រភពថវិកាមួយចំនួន ដែលថវិកាខាង ក្នុង ត្រូវបានរំពឹងថា នឹងមានចំនួនច្រើនសម្រាប់សកម្មភាពការប្រែប្រួលអាកាសធាតុ។ ធន្ទះនយោបាយ ការជំរុញនីតិវិធីរៀបចំ ផែនការ និងថវិកាបញ្ជ្រាបការប្រែប្រួលអាកាសធាតុ រួមទាំងកម្មវិធីវិនិយោគសាធារណៈ។ យោងតាមថវិកាប្រែប្រួលអាកាសធាតុអន្តរជាតិ កជ.អ.ច. ជាមួយការចូលរួមរបស់ GIZ បានសម្រាំងសកម្មភាពអាទិភាពរបស់វិស័យ CCAP ព្រមទាំងការកំណត់ថវិកាអាទិភាពខ្ពស់ ទាំងនេះជាការអភិវឌ្ឍផ្សេងៗ របស់គម្រោងសំណើរថវិកា ដែលនឹងត្រូវបានបង្ហាញទៅដៃគូម្ចាស់ជំនួយចម្រុះ។
លើសពីនេះទៀត ឧបករណ៍ក្នុងការសម្រាំង ត្រូវបានបង្កើតក្នុងការកែតម្រូវសម្រាំង ចាត់អាទិភាពសកម្មភាព CCAP សម្រាប់គោលបំណងផ្សេងៗនៅអនាគត។ ធនធានចម្បងរបស់ហិរញ្ញវត្ថុបន្សាំអន្តរ ជាតិ គឺជាមូលនិធិអាកាសធាតុបៃតង(GCF)។ កម្ពុជាកំពុងស្ថិតនៅក្នុងដំណាក់កាលត្រៀមរួចជាស្រេច ដើម្បីទទួលបាន ថវិកាបន្សាំពី GCF តាមរយៈពហុដៃគូ និងការទទួលបានដោយផ្ទាល់។ លេខាធិការ ដ្ឋានគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ត្រូវបាន ជ្រើសរើសដោយក្រសួងបរិស្ថាន (អាជ្ញាធរជាតិសម្រាប់យន្តការអភិវឌ្ឍស្អាត)ដែលជាស្ថាប័នជាតិដ៏មាន សក្តានុពលក្នុង

ការចុះបញ្ជីជាស្ថាប័នអនុវត្តន៍ជាតិ(NIE) ដែលកំពុងពិនិត្យដំណើរការ ហើយនេះជាអង្គ ភាពដំបូង ដែល GCF បានជ្រើសរើសសម្រាប់ការផ្តល់មូលនិធិទៅថ្នាក់ក្រោមជាតិ។

# មេរៀនទី ២ ទិដ្ឋភាពទូទៅនៃមូលនិធិការប្រែប្រួលអាកាសធាតុ

## ១. មូលនិធិការប្រែប្រួលអាកាសធាតុសកល

ស្ថាប័នមូលនិធិការប្រែប្រួលអាកាសធាតុសកល បានបង្កើតឡើងនៅមុនថ្ងៃកិច្ចប្រជុំកំពូលទីក្រុង រីយ៉ូ ១៩៩២ គឺជាកាតាលីករដ៏សំខាន់សម្រាប់សកម្មភាពការពារបរិស្ថាន និងសកម្មភាពជាច្រើនលើសពីនេះ។ តាមរយៈការវិនិយោគជាយុទ្ធសាស្ត្ររបស់ខ្លួន GEF បានធ្វើការជាមួយដៃគូដើម្បីដោះស្រាយបញ្ហាបរិស្ថានធំៗជាច្រើន។ មូលនិធិនេះបានជួយដល់ការកាត់បន្ថយភាពក្រីក្រ ពង្រឹងអភិបាលកិច្ច និងសម្រេចបាននូវសមភាពរវាងស្ត្រីនិងបុរស ក្នុងភាពជាដៃគូសកលសម្រាប់ភពផែនដីប្រកបដោយនិរន្តរភាព។

i. ភាពជាដៃគូសកលរបស់ស្ថាប័នទាំង១៨ រួមមានទីភ្នាក់ងារអង្គការសហប្រជាជាតិ ធនាគារអភិវឌ្ឍន៍ពហុភាគី អង្គភាពជាតិ និងអង្គការអន្តរជាតិ ដែលធ្វើការជាមួយប្រទេសចំនួន១៨៣ ដើម្បីដោះស្រាយបញ្ហាបរិស្ថាននៅលើពិភពលោក។ GEF មានបណ្តាញសំខាន់មួយ ដែលរួមមានអង្គការសង្គមស៊ីវិលបានកំពុងធ្វើការយ៉ាងជិតស្និទ្ធជាមួយវិស័យឯកជននៅជុំវិញពិភពលោក និងទទួលបានជាតុចូលជាបន្តបន្ទាប់ពីការិយាល័យវាយតម្លៃឯករាជ្យ និងជាក្រុមប្រឹក្សាវិទ្យាសាស្ត្រលំដាប់ពិភពលោក។

ii. យន្តការមូលនិធិ មាននៅក្នុងអនុសញ្ញាបរិស្ថានអន្តរជាតិ ចំនួន ៥៖ អនុសញ្ញា Minamata Stockholm ស្តីអំពីការបំពុលសរីរាង្គ (POP) អនុសញ្ញាសហប្រជាជាតិស្តីពីជីវចម្រុះ (UNCBD) អនុសញ្ញាអង្គការសហប្រជាជាតិដើម្បីប្រយុទ្ធប្រឆាំងភាពក្លាយជាវាលរហោឋាន (UNCCD) និងក្របខ័ណ្ឌអង្គការសហប្រជាជាតិ អនុសញ្ញាស្តីពីការប្រែប្រួលអាកាសធាតុ (UNFCCC)។

iii. នវានុវត្តន៍ និងកាតាលីករ ដែលគាំទ្រការចងសម្ព័ន្ធភាពនៃអ្នកពាក់ព័ន្ធ ដើម្បីការពារប្រព័ន្ធអេកូឡូស៊ីដែលរងការគំរាមកំហែងនៅលើដី និងនៅក្នុងសមុទ្រ ការកសាងទីក្រុងបៃតង បង្កើនសន្តិសុខស្បៀងនិងជំរុញថាមពលស្អាតសម្រាប់វិបុលភាព ភាពធន់ទៅនឹងអាកាសធាតុពិភពលោកដែលបានបង្កើតមូលនិធិ ៥,២ដុល្លារ បន្ថែមលើរាល់ការវិនិយោគ១ដុល្លារ។




រូបភាព ១០ ក្រាហ្វិចក្របខណ្ឌនៃស្ថាប័នមូលនិធិបរិស្ថានពិភពលោក (GEF)

## ២. មូលនិធិវិនិយោគលើការប្រែប្រួលអាកាសធាតុ (CIF)

មូលនិធិវិនិយោគបានផ្តល់នូវធនធានចាំបាច់សម្រាប់ប្រទេសកំពុងអភិវឌ្ឍន៍ និងប្រទេសមានប្រាក់ចំណូលមធ្យម ដើម្បីកាត់បន្ថយនិងគ្រប់គ្រងបញ្ហាប្រឈមនៃការប្រែប្រួលអាកាសធាតុ។ ចាប់តាំងពី ឆ្នាំ ២០០៨ មកក្រុមម្ចាស់មូលនិធិCIF បានដឹកនាំការវិនិយោគប្រកបដោយភាពច្នៃប្រឌិតលើបច្ចេកវិទ្យា ស្អាត ថាមពលកកើតឡើងវិញ ការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាព និងភាពធន់ទៅនឹងអាកាស ធាតុ។ CIF មានមូលនិធិចំនួនពីរ គឺមូលនិធិបច្ចេកវិទ្យាស្អាត និងមូលនិធិអាកាសធាតុជាយុទ្ធសាស្ត្រ ដែលគ្រប់គ្រងដោយគណៈកម្មាធិការ និងអនុគណៈកម្មាធិការ CIF មានកម្មវិធីសំខាន់ចំនួនបួន ដែលជួយដល់ប្រទេសកំពុងអភិវឌ្ឍន៍សាកល្បងការបំភាយឧស្ម័នកម្រិតទាប និងភាពធន់ទៅនឹងអាកាសធាតុ រួម មាន (១)មូលនិធិបច្ចេកវិទ្យាស្អាត (២)កម្មវិធីវិនិយោគព្រៃឈើ (៣)ការសាកល្បងសម្រាប់ភាពធន់ទៅ នឹងអាកាសធាតុ និង (៤)បង្កើនថាមពលកកើតឡើងវិញនៅបណ្តាប្រទេសដែលមានប្រាក់ចំណូលទាប។ កម្ពុជាទទួលបានប្រាក់សរុប ៩១លានដុល្លារ (៥៥លានសម្រាប់ធនធាន និង៣៦លានជាជំនួយឥណទាន ការប្រាក់ទាបបំផុត) ពីកម្មវិធី PPCR តាមរយៈ ADB សម្រាប់អនុវត្តន៍គម្រោងវិនិយោគ៧ SPCR និង គម្រោងជំនួយការបច្ចេកទេសមួយរូប។ មានប្រទេសអភិវឌ្ឍន៍ចំនួន១៤បានចូលរួមផ្តល់ថវិកា ៨,១ពាន់លានដុល្លារទៅ CIF ដែលត្រូវបានគេរំពឹងថានឹងពង្រីកបន្ថែមថវិកាសរុបចំនួន ៥៧ពាន់លានរួមបញ្ចូលពី ប្រភពផ្សេង

ទៀត។ កាលពីខែកញ្ញាឆ្នាំ ២០០៨ ប្រទេសម្ចាស់ជំនួយបានសន្យាផ្តល់ជំនួយជាង ៦,១ ពាន់លានដុល្លារ ដល់មូលនិធិបច្ចេកវិទ្យាស្អាត និងមូលនិធិយុទ្ធសាស្ត្រអាកាសធាតុ។ មូលនិធិនេះត្រូវបានផ្តល់ ជាជំនួយឥតសំណង កម្ចីសម្បទានខ្ពស់ និង ឬជាឧបករណ៍ការបន្ថយហានិភ័យ។

រចនាសម្ព័ន្ធរបស់ CIF ចែកជាមូលនិធិចំនួនពីរ គឺមូលនិធិបច្ចេកវិទ្យាស្អាត និងមូលនិធិយុទ្ធសា ស្ត្រអាកាសធាតុ ដែលមូលនិធិនីមួយៗមានគណៈកម្មាធិការ និងអនុគណៈកម្មាធិការ ដែលមានតំណាងពី ប្រទេសម្ចាស់ជំនួយ និងប្រទេសទទួលជំនួយ ដើម្បីគ្រប់គ្រង និងផ្តល់ការណែនាំដល់កម្មវិធីគោលដៅទាំង បី។ មូលនិធិមានគោលបំណង ក្នុងការជំរុញការកាត់បន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់ ការបន្សុំ និងភាព ធន់ទៅនឹង ការប្រែប្រួលអាកាសធាតុនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍។

## ៣. មូលនិធិបន្សុំ

មូលនិធិបន្សុំបានបង្កើតឡើងនៅឆ្នាំ២០០១ ដើម្បីផ្តល់មូលនិធិដល់គម្រោងបន្សុំរបស់ប្រទេសកំពុងអភិវឌ្ឍន៍ ដែលជាសមាជិកពិធីសារ ក្យូតូ ដែលរងផលប៉ះពាល់ទៅនឹងឥទ្ធិពលនៃការប្រែប្រួលអាកាសធាតុ និងកំពុងប្រឈមទៅនឹងកង្វះធនធាន។ កម្ពុជាបានទទួលបាននូវគម្រោងកម្មវិធីស្តីពី "ការលើកកម្ពស់ភាពធន់ទៅនឹងការប្រែប្រួលអកាសធាតុរបស់សហគមន៍ជនបទនៅក្នុងតំបន់ការពារ ដែលមានទឹកប្រាក់សរុបប្រមាណ ៥លានដុល្លារនៅចុងឆ្នាំ ២០១២ ហើយគម្រោងនេះបានអនុវត្តន៍ដោយក្រសួងបរិស្ថាន និង UNEP ។

មូលនិធិនេះទទួលបានពីបណ្តាប្រទេសអឺរ៉ុប អូស្ត្រាលី ស្វីស និងវិស័យឯកជន ដែលមូលនិធិនេះគ្រប់គ្រងដោយគណៈកម្មាការមូលនិធិបន្សុំ (AFB) រួមមានសមាសភាព ១៦រូបមកពីបណ្តាប្រទេសម្ចាស់ជំនួយ និងតំណាងវិស័យឯកជនធំៗ។ គណៈកម្មការមូលនិធិមានកិច្ចប្រជុំចំនួនពីរដងក្នុងមួយឆ្នាំ ដើម្បីវាយតម្លៃ និងឯកភាពលើគម្រោង ដោយមានការសម្របសម្រួលដោយលេខាធិការដ្ឋាន (GEF) និងគ្រប់គ្រងថវិកាជាបណ្តោះអាសន្នដោយធនាគារពិភពលោក។

គោលបំណងមូលនិធិបន្សុំ គឺដើម្បីផ្តល់មូលនិធិដល់គម្រោងបន្សុំ និងសហគមន៍របស់ប្រទេសកំពុងអភិវឌ្ឍន៍ ដែលរងផលប៉ះពាល់ទៅនឹងឥទ្ធិពលនៃប្រែប្រួលអកាសធាតុ និងកំពុងប្រឈមទៅនឹងកង្វះ

ធនធាន។ មូលនិធិបន្សុំផ្តោតទៅលើការបន្សុំ និងភាពធន់ដែលចូលរួមក្នុងការដោះស្រាយបញ្ហាទាក់ទង នឹងការប្រែប្រួលអាកាសធាតុនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍។ មូលនិធិមានពីរ ដែលមូលនិធិកម្រិតតូចមាន គម្រោងថវិការហូតដល់១លានដុល្លារ រីឯមូលនិធិទំហំធម្មតាមានថវិកាប្រមាណ១០លានដុល្លារ។ មូលនិធិ នឹងគាំទ្រទៅរាល់គម្រោងសំណើររបស់ប្រទេសកំពុងអភិវឌ្ឍន៍ ដែលមានគុណវឌ្ឍន៍ខ្ពស់។

## ៤. សម្ព័ន្ធការប្រែប្រួលអាកាសធាតុសកល (GCCA)

សម្ព័ន្ធការប្រែប្រួលអាកាសធាតុសកល បានបង្កើតឡើងដោយសហគមន៍អឺរ៉ុបក្នុងឆ្នាំ២០០៧ ដើម្បីពង្រឹងការចរចា និងកិច្ចសហប្រតិបត្តិការជាមួយប្រទេសកំពុងអភិវឌ្ឍន៍ពិសេសប្រទេសមានការអភិវឌ្ឍតិចតួច (LDCs) និងរដ្ឋនៅតាមបណ្តាកោះ (SIDS) ហើយសម្ព័ន្ធប្រែប្រួលអាកាសធាតុសកលមានតួនាទីក្នុងការគាំទ្រដល់កិច្ចខិតខំរបស់ពួកគេក្នុងការបន្សាំ និងការកាត់បន្ថយការប្រែប្រួលអាកាសធាតុ។ បច្ចុប្បន្ន សម្ព័ន្ធបានប្រែក្លាយជា GCCA+ ក្រោមក្របខណ្ឌហិរញ្ញប្បទាន (២០១៤-២០២០) ដែលជាគំនិតផ្តួចផ្តើមរបស់សហគមន៍អឺរ៉ុប កំពុងគាំទ្រកម្មវិធីប្រែប្រួលអាកាសធាតុចំនួន៣៨ ទាំង ៨តំបន់ និងអនុតំបន់ទូទាំងពិភពលោក។

អាទិភាពសំខាន់ចំនួន៥ ត្រូវបានកំណត់សម្រាប់សម្ព័ន្ធ៖

- បញ្ជ្រាបការប្រែប្រួលអាកាសធាតុទៅក្នុងការកាត់បន្ថយភាពក្រីក្រ និងកិច្ចប្រឹងប្រែងអភិវឌ្ឍន៍។
- បង្កើនចំនេះដឹងទាក់ទងទៅនឹងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ និងការរៀបចំគម្រោង
- អនុវត្តន៍ការបន្សាំសមស្រប ជាពិសេសនៅផ្នែកទឹក និងកសិកម្ម។
- កាត់បន្ថយការបំភាយឧស្ម័នដែលកើតឡើងពីការកាប់បំផ្លាញ និងការសឹករិចរិលព្រៃឈើ (REDD)។
- ជំរុញការចូលរួមការលក់កាបូនសកល រួមបញ្ចូលទាំងយន្តការអភិវឌ្ឍន៍ស្អាត (CDM)។
- ការកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយ (DRR)។

មូលនិធិផ្តោតសំខាន់លើវិស័យចំនួន៣ដូចខាងក្រោម

- ការបញ្ជ្រាបការប្រែប្រួលអាកាសធាតុទៅក្នុងការកាត់បន្ថយភាពក្រីក្រ (កិច្ចសន្ទនាគោលនយោបាយ ការចូលរួម UNFCCC អនុវត្តន៍កិច្ចខិតខំប្រឹងប្រែងជាសកលដើម្បីសម្រេចបាននូវការអភិវឌ្ឍប្រកបដោយចីរភាព ។ល។
- វិស័យបន្សាំ និងការកាត់បន្ថយប្រែប្រួលអាកាសធាតុ (ការបញ្ជ្រាបប្រែប្រួលអាកាសធាតុទៅក្នុងការកាត់បន្ថយភាពក្រីក្រ, បង្កើនចំនេះដឹងទាក់ទងទៅនឹងការបន្សាំនៅក្នុងវិស័យទឹក និងកសិកម្ម REDD CDM DRR
- លើកកម្ពស់ភាពធន់ទៅនឹងប្រែប្រួលអាកាសធាតុ ទាក់ទងទៅនឹងភាពតានតឹង និងតក់ស្លុត។

## ៥. មូលនិធិអាកាសធាតុបៃតង (GCF)

មូលនិធិអាកាសធាតុបៃតង បានបង្កើតឡើងដោយសមាជិក UNFCCC ក្នុងកិច្ចប្រជុំ Cancun នាខែធ្នូ ឆ្នាំ២០១០ និងបានដំណើរការជាផ្លូវការនៅឆ្នាំ២០១១ នៅពេលដែលយន្តការគ្រប់គ្រងជំនួយត្រូវបានបង្កើត និងឯកភាព។ មូលនិធិនេះជាយន្តការក្នុងការផ្តល់ជំនួយរបស់ UNFCCC ស្របទៅនឹងមាត ១១

នៃអនុសញ្ញា សំដៅគាំទ្រដល់ការកាត់បន្ថយ និងការបន្សាំនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ ដើម្បីកម្រិត រឺកាត់បន្ថយការសាយភាយឧស្ម័នផ្ទះកញ្ចក់ និងបន្សាំទៅនឹងឥទ្ធិពលនៃប្រែប្រួលអាកាសធាតុ របស់ ប្រទេសក្រីក្រ។ មូលនិធិមានគោលបំណងក្នុងការចូលរួមដល់កិច្ចខិតខំរបស់ពិភពលោក ដើម្បីសម្រេចបាន នូវគោលបំណងចុងក្រោយរបស់ UNFCCC ក្នុងការប្រយុទ្ធប្រឆាំងទៅនឹងប្រែប្រួលអាកាសធាតុ។ មូលនិធិ ត្រូវបានគ្រប់គ្រងដោយគណៈកម្មការ ជាមួយនឹងការគាំទ្រប្រតិបត្តិដោយលេខាធិការដ្ឋាន អ្នកទទួល និង ក្រុមផ្តល់យោបល់បច្ចេកទេស ដើម្បីទទួលមូលនិធិនេះ ប្រទេសកម្ពុជា តាមរយៈ នាយកដ្ឋានប្រែប្រួល អាកាសធាតុនៃក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព (CCD/NCSD) ក្រោមការគាំទ្ររបស់កម្មវិធីសម្ព័ន្ធ ភាពប្រែប្រួលអាកាសធាតុកម្ពុជា(CCCA) កំពុងសម្របសម្រួលបង្កើតអង្គភាពអនុវត្តរបស់ជាតិ សម្រាប់ ការអនុវត្តមូលនិធិបៃតង ដែលក្រសួងបរិស្ថានដើរតួនាទីជាអាជ្ញាធរជាតិ។ មូលនិធិបានដើរតួនាទីយ៉ាង សំខាន់ក្នុងការផ្តល់មូលនិធិទៅប្រទេសកំពុងអភិវឌ្ឍន៍ ជាកាតាលីករនៃមូលនិធិអាកាសធាតុ ស្ថាប័នរដ្ឋ និង ឯកជន នៅថ្នាក់ជាតិ និងអន្តរជាតិ។ មូលនិធិនេះបានខិតខំបង្កើនឥទ្ធិពលរបស់ខ្លួនសម្រាប់ការបន្សាំ ការ បង្ការ និងស្វែងរកតុល្យភាពរវាងយន្តការពីរខាងលើ ខណៈពេលដែលការលើកកម្ពស់បរិស្ថាន សង្គម សេដ្ឋ កិច្ច និងការអភិវឌ្ឍបានផ្តល់សហប្រយោជន៍ និងការទទួលយកវិធីសាស្ត្រឆ្លើយតបចំពោះយេនឌ័រ។

មូលនិធិនេះត្រូវបានគ្រប់គ្រង និងត្រួតពិនិត្យដោយក្រុមប្រឹក្សាភិបាល ដែលមានការទទួលខុសត្រូវពេញលេញសម្រាប់ការសម្រេចចិត្តលើមូលនិធិនេះ និងទទួលការណែនាំពីសន្និសីទបណ្តាភាគីជាសមាជិក(COP)។ សមាជិកក្រុមប្រឹក្សាភិបាល មានសមាសភាពមកពីបណ្តាប្រទេសសំខាន់ៗ នៃការចូលរួមចំណែករបស់មូលនិធិនេះ រួមមានសហរដ្ឋអាមេរិក ជប៉ុន ចក្រភពអង់គ្លេស បារាំង អាល្លឺម៉ង់ ស៊ុយអែត អ៊ីតាលី កាណាដា ន័រវេស អូស្ត្រាលី អេស្ប៉ាញ ហូល្លង់ ហ្វាំងឡង់ កូរ៉េ ស្វីស ដាណឺម៉ាក បែលហ្ស៊ិក អូទ្រីស និង ម៉ិកស៊ិកូ។ ក្រុមប្រឹក្សាភិបាល GCF អនុម័តការបង្កើតលេខាធិការដ្ឋានមូលនិធិអាកាសធាតុបៃតងឯករាជ្យនៅក្នុងខែតុលាឆ្នាំ២០១៣។ លេខាធិការដ្ឋានមានតួនាទីឆ្លើយតបចំពោះការគ្រប់គ្រងប្រតិបត្តិ និងការប្រតិបត្តិនៃមូលនិធិនេះដែរ រួមមានការផ្តល់ការគាំទ្រទាំងផ្នែកបច្ចេកទេស រដ្ឋបាល និងការផ្គត់ផ្គង់ទៅឱ្យក្រុមប្រឹក្សាភិបាលដោយមានលក្ខណៈឯករាជ្យភាព។ មូលនិធិនេះមានអ្នកទទួលដែលមានតួនាទី និងគណនេយ្យភាពទៅក្រុមប្រឹក្សាភិបាលក្នុងការគ្រប់គ្រងទ្រព្យសកម្ម ធ្វើរបាយការណ៍ហិរញ្ញវត្ថុ និងផ្តល់បច្ចេកទេសប្រឹក្សាឯករាជ្យ ដើម្បីផ្តល់នូវការវាយតម្លៃបច្ចេកទេសឯករាជ្យ និងដំបូន្មានលើសំណើរថវិការបស់មូលនិធិ។

**គោលលបំណងជាក់លាក់នៃមូលនិធិនេះគឺះ**

– ដើម្បីចូលរួមចំណែកយ៉ាងសំខាន់ និងប្រកបដោយមហិច្ឆតា ដល់កិច្ចខិតខំប្រឹងប្រែងឆ្ពោះទៅរកការសម្រេចបានគោលដៅដែលបានកំណត់ដោយសហគមន៍អន្តរជាតិ ដើម្បីប្រយុទ្ធប្រឆាំងនឹង ការប្រែប្រួលអាកាសធាតុ

– ដើម្បីរួមចំណែកដល់សមិទ្ធិផលនៃគោលដៅចុងក្រោយនៃអនុសញ្ញាក្រោមក្របខ័ណ្ឌអង្គការសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ (UNFCCC) និង
– ដើម្បីលើកកម្ពស់ការផ្លាស់ប្តូរជាគំរូ ឆ្ពោះទៅរកការបំភាយឧស្ម័នទាប និងការអភិវឌ្ឍធន់ទៅនឹងអាកាសធាតុ ដោយផ្តល់ការគាំទ្រដល់ប្រទេសកំពុងអភិវឌ្ឍន៍ ដើម្បីកម្រិត ឬកាត់បន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់របស់ខ្លួន និងដើម្បីសម្របខ្លួនទៅនឹងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ និងមានគណនេយ្យភាពទៅនឹងតម្រូវការរបស់ប្រទេសកំពុងអភិវឌ្ឍន៍ទាំងនោះ ពិសេសបណ្តុ ប្រទេសងាយរងគ្រោះទៅនឹងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ។

មូលនិធិនេះផ្តោតលើការកាត់បន្ថយ ការបន្សាំ និងការរួមបញ្ចូលគ្នានៃយន្តការទាំងពីរនេះបានជាកម្មវិធីកាត់បន្ថយឧស្ម័នពីការបាត់បង់ និងការរិចរឹលនៃព្រៃឈើ (REDD) ដើម្បីដោះស្រាយក្តីបារម្ភទាក់ទងនឹងការប្រែប្រួលអាកាសធាតុនៅប្រទេសកំពុងអភិវឌ្ឍ ការបន្សាំសំដៅទៅលើសកម្មភាពដែលធ្វើឡើងនៅក្នុងការឆ្លើយតបទៅនឹងការប្រែប្រួលពិតប្រាកដ និងការរំពឹងថានឹងអាចមានការប្រែប្រួលអាកាសធាតុ ដែលសកម្មភាពទាំងនេះនឹងអាចកាត់បន្ថយភាពងាយរងគ្រោះនៃការប្រែប្រួលទាំងនេះ។ កិច្ចប្រជុំអំពីការបន្សាំបានចំណាយធនធានជាច្រើនរបស់សហគមន៍អន្តរជាតិ UNFCCC បានចំណាយប្រមាណ២៨ – ៦៧ពាន់លានដុល្លារក្នុងមួយឆ្នាំសម្រាប់ប្រទេសកំពុងអភិវឌ្ឍរហូតដល់ឆ្នាំ២០៣០។ ការបង្ការសំដៅទៅលើ ការអន្តរាគមន៍របស់មនុស្សក្នុងការកាត់បន្ថយការបំភាយឧស្ម័នពុល រឺឧស្ម័នផ្ទះកញ្ចក់ ផ្ទុយមកវិញការចាំបាច់ដើម្បីចាត់វិធានការកាត់បន្ថយផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុ នៅមិនបានគិតថាបន្ទាន់នៅឡើយ ទោះបីជាមានកិច្ចខិតខំប្រឹងប្រែងជាអន្តរជាតិ ដោយការបំភាយឧស្ម័នផ្ទះកញ្ចក់នៅតែបន្តកើនឡើង។ ប្រភេទមូលនិធិ ដែលបានស្នើឡើងមានទំហំគម្រោង/កម្មវិធីបួនប្រភេទៈ មីក្រូ តូច មធ្យម និង សំណើធំ។ សំណើខ្នាតមីក្រូមានទំហំទឹកប្រាក់សរុបរហូតដល់ទៅ ១០លានដុល្លារ សំណើតូចនឹងមានទំហំ ទឹកប្រាក់សរុបលើសពី ១០លានដុល្លាររហូតដល់ ៥០លាន សំណើមធ្យមនឹងមានទំហំទឹកប្រាក់សរុប លើសពី ៥០លាន រហូតដល់ ២៥០លាន និងសំណើដែលមានទំហំធំនឹងមានទំហំទឹកប្រាក់សរុបចំនួន ២៥០លានឡើង។

## ៦. យន្តការហិរញ្ញប្បទានអាកាសធាតុ

### ៦.១ ស្ថាបត្យកម្មនៃហិរញ្ញប្បទានអាកាសធាតុសាកល

ស្ថាបត្យកម្មនៃហិរញ្ញប្បទានអាកាសធាតុសាកលគឺមានភាពស្មុកស្មាញៈ ហិរញ្ញប្បទានគឺលំហូរតាម រយៈមូលនិធិពហុភាគី ដូចជា មូលនិធិបរិស្ថានពិភពលោក(GEF) និងមូលនិធិវិនិយោគអាកាសធាតុ និង ការកើនឡើងនៃលំហូមូលនិធិតាមរយៈទ្វេភាគីផងដែរ។ បន្ថែមពីនេះ មានការកើនឡើងនៃចំនួនប្រទេស ដែលអាចទទួលបានមូលនិធិអាកាសធាតុបានបង្កើតឡើងនូវមូលនិធិប្រែប្រួលអាកាសធាតុជាតិ

ដែលយន្តការនេះអាចទទួលបានមូលនិធិពីប្រទេសអភិវឌ្ឍន៍ពហុភាគី ក្នុងកិច្ចខំប្រឹងប្រែងសម្របសម្រួល និងផ្សារ ភ្ជាប់ចំណាប់អារម្មណ៍របស់ម្ចាស់ជំនួយទៅនឹងអាទិភាពរបស់ជាតិ។




រូបភាព ១១ ក្រាហ្វិចស្ថាបត្យកម្មនៃហិរញ្ញប្បទានអាកាសធាតុសាកល (បច្ចុប្បន្នភាពនៃហិរញ្ញប្បទានអាកាសធាតុ ខែតុលា ឆ្នាំ ២០១៦)

ជាទូទៅ មានតម្លាភាពច្រើនអំពីស្ថានភាពនៃការអនុវត្តគំនិតផ្តួចផ្តើមហិរញ្ញប្បទានអាកាសធាតុពហុភាគីប្រសើរជាងគំនិតផ្តួចផ្តើមហិរញ្ញប្បទានអាកាសធាតុត្រីភាគី យន្តការនៃការបែងចែកហិរញ្ញប្បទានអាកាសធាតុបានបង្កើតនូវបញ្ហាប្រឈមក្នុងការសម្របសម្រួលមូលនិធិ និងការទទួលបានហិរញ្ញប្បទាន។




រូបភាព ១២ ក្រាហ្វិចនិន្នាការសកលសម្រាប់ហិរញ្ញប្បទានអាកាសធាតុក្នុងពិភពលោក (ប្រភព៖ http://www.climatefundsupdate.org/global-trends/size-spending)

## ៧. មូលនិធិការប្រែប្រួលអាកាសធាតុសម្រាប់សកម្មភាពបន្សាំនៅលើពិភពលោក

កិច្ចខិតខំប្រឹងប្រែងក្នុងការកាត់បន្ថយការប្រែប្រួលអាកាសធាតុគឺខ្លាំងក្លា ហើយវាមានសារៈសំខាន់ណាស់ក្នុងការជួយប្រទេសកំពុងអភិវឌ្ឍន៍ ដើម្បីបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ ទៅនឹងផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុដែលមានបទពិសោធន៍រួចរាល់ហើយកាលពីអតីតកាល និងការកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់នាពេលបច្ចុប្បន្ន ហិរញ្ញប្បទានអាកាសធាតុមានសារៈសំខាន់ណាស់ក្នុងការផ្តល់មូលនិធិគាំទ្រដល់សកម្មភាពដែលឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុដូចជា ទឹកជំនន់ ព្យុះស៊ីក្លូន ការហូរច្រើននៃតំបន់ឆ្នេរ រាំងស្ងួត និងមានការកើនឡើងនៃការប្រែប្រួលនៃរបបទឹកភ្លៀង។

បច្ចុប្បន្ននេះប្រហែលជា ២៤%នៃមូលនិធិអាកាសធាតុត្រូវបានអនុម័តកាលពីឆ្នាំ២០០៣ ដោយលំហូរពីកម្មវិធីគំនិតផ្តួចផ្តើមហិរញ្ញប្បទានអាកាសធាតុដែល បច្ចុប្បន្នភាពហិរញ្ញប្បទានអាកាសធាតុ (CFU) ត្រួតពិនិត្យលើការគាំទ្រដល់ការបន្សាំ។ ការផ្តល់ហិរញ្ញប្បទានអាកាសធាតុនេះបានធ្វើឱ្យមានភាពស្មុគស្មាញជាច្រើនដែលមានភាពមិនស្មើគ្នាលើ ផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុនៅក្នុងប្រទេសក្រីក្រដែលរងផលប៉ះពាល់អាក្រក់បំផុត(ពិសេសរដ្ឋកំពុងអភិវឌ្ឍន៍នៅលើតំបន់កោះតូចៗ) និងប្រទេសអភិវឌ្ឍន៍តិចតួចនានា។ ប្រទេសទាំងនេះមានភាពខុសប្លែកគ្នាលើសមត្ថភាពស្ថាប័នដើម្បីឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ និងធានាថាការប្រើប្រាស់ហិរញ្ញប្បទានប្រកបដោយប្រសិទ្ធភាព និងសមភាព

ដោយរួមបញ្ចូលនូវយេនឌ័រ។ ទិន្នន័យនៃបច្ចុប្បន្នភាពហិរញ្ញប្បទានអាកាសធាតុបានលើកឡើងថា ៥៧% មានការកើនឡើងលើការអនុម័តមូលនិធិពហុភាគីសម្រាប់ការបន្សាំកាលពីប៉ុន្មានឆ្នាំកន្លងទៅ។ ទោះបីយ៉ាងណាក៏ដោយ ការវាយតម្លៃចំនួនដែលបានទូទាត់ត្រូវបានពន្យាដោយសារកង្វះផ្នែកតម្លាភាព និងការរាយការណ៍ពីប្រទេសទទួលជំនួយ។

តារាង ១៦ បញ្ជីមូលនិធិពហុភាគី ដែលបានបញ្ជាក់ពីការប្រែប្រួលអាកាសធាតុដោយផ្តោតលើសកម្មភាពដែលមានគោលដៅលើការងារបន្សាំនឹងការប្រែប្រួលអាកាសធាតុពេញលេញ សម្ព័ន្ធភាពបម្រែបម្រួលអាកាសធាតុសាកលរបស់សហគមន៍អឺរ៉ុប បានផ្តល់មូនិធិអាកាសធាតុដោយផ្តោតលើការប្រែប្រួលអាកាសធាតុ ប៉ុន្តែមិនបានធ្វើបញ្ជីអំពីសកម្មភាពបន្សាំទេ តែផ្តោតលើការគាំទ្រសកម្មភាព និងពហុគោលបំណងដែលមានការបន្សាំផងដែរ។ កម្មវិធីសាកល្បងភាពធន់នឹងអាកាសធាតុ(PPCR) បានអនុម័តថវិកាទំហំធំសម្រាប់ការបន្សាំរហូតមកដល់បច្ចុប្បន្ន និងបានចុះបញ្ជីប្រហែល៩៣%កើនឡើងក្នុងឆ្នាំនេះ (៣៨៣លានដុល្លារអាមេរិច) បើយ៉ាងនេះក្តី ការគាំទ្រនេះផ្តោតសំខាន់តែលើប្រទេសមួយពីរ ប៉ុណ្ណោះដែលទទួលបានមូលនិធិគាំទ្រ ពីព្រោះអភិក្រមនៃកម្មវិធីសាកល្បងនេះមានលក្ខណៈបញ្ច្រាសពីមូលនិធិប្រទេសកំពុងអភិវឌ្ឍន៍(LDCF) គឺជាមូលនិធដែលមានចំនួនគម្រោងដែលបានអនុម័តច្រើនបំផុត(១៩៩ គម្រោង) ក្នុងប្រទេសចំនួន៥២ខុសគ្នា បើទោះបីជាគម្រោងឯកជនមានចំនួនតូចៗក៏ដោយ។ មូលនិធិបន្សាំ និងមូលនិធិអាកាសធាតុពិសេស(SCCF) បានអនុម័តដែលមានចំនួនប្រហាក់ប្រហែលគ្នា ដោយមានការកើនឡើងនៃការអនុម័តមូលនិធិនេះពី ២២% ទៅ៤១%។ មូលនិធិបន្សាំដែលទទួលបានពីការរួមចំណែកពីចំណូលពីគម្រោងអភិវឌ្ឍន៍ស្អាតនៅតែប្រឈមនឹងការធ្លាក់ចុះនៃតម្លៃកាបូន និងការចូលរួមពីប្រទេសឧស្សាហកម្ម។ ការធ្លាក់ចុះកើតចេញពីការចូលរួមផ្តល់ជំនួយឥតសំណង ពីប្រទេសអភិវឌ្ឍន៍ផងដែរ។

តារាង ១៦ ការគាំទ្រមូលនិធិលើការបន្សាំពេញលេញ (២០០៣-២០១៤)

| មូលនិធិ | ប្តេជ្ញា | ការផ្តល់ | អនុម័ត |
|---|---|---|---|
| កម្មវិធីសាកល្បងភាពធន់នឹងអាកាសធាតុ | 1160 | 973.0 | 796 |
| មូលនិធិប្រទេសអភិវឌ្ឍន៍តិចតួច(LDCF) | 914 | 903.0 | 733 |
| កម្មវិធីបន្សាំសម្រាប់កសិកម្មខ្នាតតូច(ASAP) | 352 | 300.6 | 149 |
| មូលនិធិប្រែប្រួលអាកាសធាតុពិសេស(SCCF) | 347 | 336.0 | 253 |
| មូលនិធិបន្សាំ(AF) | 226 | 231.7 | 231 |

ជាយូរមកហើយ ប្រទេសចក្រភពអង់គ្លេស តាមរយៈមូលនិធិអាកាសធាតុអន្តរជាតិ អាឡឺម៉ង់ ស៊ុយអែត និងកាណាដា បានចូលរួម៦៩%នៃថវិកាសរុប៣ពាន់លានដុល្លាអាមេរិចដែលបានប្តេជ្ញាសម្រាប់ មូលនិធិបន្សាំ ក្រៅពីនេះលុយប្រហែលជា ២.៧២ពាន់លានដុល្លាត្រូវបានផ្តល់ជូន។ ៧៩%នៃហិរញ្ញប្បទានដែលបានផ្តល់ជូនត្រូវបានអនុម័តដើម្បីគាំទ្រដល់គម្រោង និងកម្មវិធី។ កង្វះចន្លោះរវាងចំនួនមូលនិធិ ដែលបានប្តេជ្ញា និងមូលនិធិដែលបានផ្តល់នៅមានទំហំតូចប្រហែលជា ៩%។ នេះបញ្ជាក់ថាមូលនិធិបន្សាំ បានដើរស្របតាមផែនការបើទោះបីជាមូលនិធិដែលបានទូទាត់ជាក់ស្តែងពិបាកទទួលបានក៏ដោយ។




រូបភាព ១៣ ក្រាហ្វិចមូនិធិដែលបានគាំទ្រលើការបន្សាំពេញលេញ

កម្រិតតំបន់ មូលនិធិបន្សាំបានផ្តល់ដោយផ្ទាល់ជាដំបូងដល់តំបន់អាស៊ី និងអនុតំបន់អាហ្វ្រិចសាហារ៉ាន់ និងប៉ាស៊ីហ្វិច ដូចគ្នាទៅនឹងគម្រោង សកម្មភាព និងកម្មវិធីសាកលនៅក្នុងប្រទេសអាមេរិចឡាទីន និងការីបៀន ប្រទេសទាំង ២០ដែលទទួលបានចំនួនច្រើនជាងគេបំផុតពីមូលនិធិបន្សាំ(ក្នុងចំណោម ១១៤ប្រទេស) ទទួលបានថវិកាសុរប ៥៤%នៃថវិការអនុម័តសរុប ដែលបង្ហាញពីចំនួនតិចជាងមូលនិធិសម្រាប់ការកាត់បន្ថយ (ដែលមានប្រទេស ២០ទទួលបានថវិកាសរុប ៨៩%នៃថវិកាដែលបានអនុម័ត)។ ប្រទេសដែលបានជំនួយច្រើនបំផុតដូចជា បង់ក្លាដេស នេប៉ាល់ ណៃជឺ ម៉ូហាប៊ីក ហ្សែមបៀរ ប្រទេសនីមួយៗបានទទួលពី ៩៤ ទៅ ១៩០លានដុល្លារអាមេរិច (ក្នុងនោះ ៥ ជាប្រទេសដែលទទួលជំនួយពីគម្រោង PPCR) ហើយប្រទេសទាំងប្រាំដែលទទួលបានមូលនិធិបន្សាំតិចតួចបំផុតរួមមាន សូម៉ាលី និងសាធារណៈរដ្ឋអាហ្វ្រិចកណ្តាល ទាំងពីរនេះជាប្រទេសដែលងាយរងគ្រោះបំផុតពីការប្រែប្រួលអាកាសធាតុ

ក្នុងពិភពលោក បើយោងលើការវាយតម្លៃភាពងាយរងគ្រោះផ្សេងៗ ហើយបច្ចុប្បន្នទទួលបានប្រហែល ៨ លាន ទៅ ១០លានដុល្លារអាមេរិចពីមូលនិធិបន្សាំអាកាសធាតុ។

ទំហំនៃអ្វីដែលស្ថាប័នគម្រោងបន្សាំមានគឺមានភាពទូលំទូលាយ។ មូលនិធិខ្នាតធំដែលបានអនុម័តថ្មីៗគឺជាមូលនិធិសកម្រាប់ភាពធន់នឹងការប្រែប្រួលអាកាសធាតុក្នុងកសិកម្មខ្នាតតូច(ASAP) សម្រាប់តំបន់ខ្ពង់រាប(ASHA) ថវិកា១៥លានដុល្លាដែលផ្តល់ឱ្យប្រទេសនេប៉ាល់គឺមានគោលបំណងលើការពង្រឹងផែនការសកម្មភាពបន្សាំកម្រិតមូលដ្ឋាន(LAPA)សម្រាប់អនុវត្តន៍ការងារនៃកម្មវិធីសកម្មភាពជាតិបន្សាំនឹង ការប្រែប្រួលអាកាសធាតុ(NAPA) នៅមូលដ្ឋាន និងកម្ចីសម្បទានរបស់កម្មវិធី PPCR លើគម្រោងកាត់បន្ថយភាពងាយរងគ្រោះនៃគ្រោះមហន្តរាយ(១៥លានដុល្លារ) ក្នុងប្រទេស St. Lucia ដែលទទួលបានមូលនិធិដើម្បីគាំទ្រលើគម្រោងលំនៅដ្ឋានសរុប ១៧៤០០០ ដោយកាត់បន្ថយការបរាជ័យនៃគម្រោង ហេដ្ឋារចនាសម្ព័ន្ធ កែលម្អការស្វែងយល់ជាទូទៅកម្រិតជាតិលើហានិភ័យ ការស្តារហេដ្ឋារចនាសម្ព័ន្ធដែល ខូចខាតដោយសារមហន្តរាយធម្មជាតិ ។




រូបភាព ១៤ ការបែងចែកថវិកាបន្សាំតាមតំបន់

## ៨. មូលនិធិការប្រែប្រួលអាកាសធាតុសម្រាប់សកម្មភាពកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់ក្នុងពិភពលោក

របាយការណ៍លើកទី៥ ដែលបានសិក្សាដោយក្រុមប្រឹក្សាអន្តររដ្ឋាភិបាលស្តីពីការប្រែប្រួលអាកាសធាតុបានបង្ហាញថា សីតុណ្ហភាពនឹងបន្តកើនឡើងដែលគួរតែកម្រិតត្រឹម២អង្សាសេ ទើបផលប៉ះពាល់ធ្ងន់ធ្ងរអាចចៀសវាងបាន ហើយឱកាសក្នុងសកម្មភាពការកាត់បន្ថយឧស្ម័នត្រូវតែធ្វើឱ្យឆាប់បំផុត។ របាយការណ៍នេះបានប៉ាន់ស្មានថា ការបញ្ចេញឧស្ម័នផ្ទះកញ្ចក់នឹងត្រូវកាត់បន្ថយឱ្យបានយ៉ាងហោចណាស់ ៤០ ទៅ៧០% នៅឆ្នាំ២០៥០) ដោយធៀបនឹងកម្រិតឆ្នាំ២០១០ ដើម្បីសម្រេចបានគោលដៅនេះ (IPCC, 2014) បន្ទុកដ៏ធំនេះនឹងរំខានដល់ប្រទេសអភិវឌ្ឍន៍ក្នុងការកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់ដែលនៅសេស

សល់ ប៉ុន្តែវាជាការចាំបាច់ណាស់ដែលប្រទេសកំពុងអភិវឌ្ឍន៍ត្រូវចូលរួមចំណែកដល់ការកាត់បន្ថយឧស្ម័នដើម្បីដាក់បញ្ចូលទៅក្នុងផែនការរបស់ពួកគេដោយការអនុវត្តយុទ្ធសាស្ត្រអភិវឌ្ឍន៍កាបូនទាប។ មូលនិធិអាកាសធាតុអន្តរជាតិអាចជួយប្រទេសក្រីក្រក្នុងការអនុវត្តផែនការសកម្មភាពកាត់បន្ថយអាទិភាព រួមមានថាមពលកកើតឡើងវិញ ប្រសិទ្ធភាពថាមពល និងការដឹកជញ្ជូនដោយនិរន្តរភាពជាងមុន។




រូបភាព ១៥ ក្រាហ្វិចមូលនិធិគាំទ្រដល់ការកាត់បន្ថយ

តើអ្វីដែលហៅថាមូលនិធិអាកាសធាតុដែលផ្តោតលើការកាត់បន្ថយ? តារាងទី២ បង្ហាញអំពីមូលនិធិអាកាសធាតុដែលគាំទ្រអាទិភាពលើកសកម្មភាពកាត់បន្ថយក្នុងប្រទេសកំពុងអភិវឌ្ឍន៍ មូលនិធិនេះ មានភាពខុសគ្នាខ្លាំងនៅក្នុងទំហំនៃគម្រោង និងកម្មវិធីកាត់បន្ថយ ពួកគេអាចជាធាតុផ្សំ និងចំនួនដែល បានគាំទ្រដោយប្រទេសកំពុងអភិវឌ្ឍន៍។ ជាឧទាហរណ៍ គម្រោងដែលបានអនុម័តចំនួន៦៩ ល់ផល ប្រយោជន៍តិចតួចដល់ទីផ្សារសេដ្ឋកិច្ចក្រោមមូនិធិបច្ចេកវិទ្យាស្អាត(CTF)មានចំនួនថវិកា ៣.៨ ពាន់លាន ដុល្លាដែលបានអនុម័តជាកម្មវិធីខ្នាតធំ និងមូលនិធិកម្ចី។ ដោយប្រាស់ចាកទៅនឹងគម្រោងតូចជាង៤០០ គម្រោងដែលទទួលបានពីមូលនិធិឥតសំណងពីGEF_ជំហានទី៤ និងទី៥ ដែលជួយដល់ប្រទេសក្រីកបំផុត ប្រហែលជាងពាក់កណ្តាលនៃចំនួននេះ។ ប្រព័ន្ធមូលនិធិជំហានទី៥ ដែលបានផ្តោតលើការវិភាជន៍ធនធានប្រកបដោយតម្លាភាព(STAR) បានផ្តល់ជាចំនួនត្រីគុណដល់ប្រទេសដែលបានកំណត់នឹងទទួលបានមូលនិធិពី៥០ ទៅ ១៤៤ ដោយអនុលោមតាមប្រទេសកំពុងអភិវឌ្ឍន៍ដែលមានចំណូលកម្រិតទាបអាចទទួលបានមូលនិធិខ្នាតតូចសម្រាប់គម្រោងកាត់បន្ថយ(GEF,2011)។ ម្យ៉ាងវិញទៀត CTF មានបំណងប្រើប្រាស់ចំនួនសរុបនៃកម្ចី ដើម្បីសម្រេចផែនការពង្រីករបស់ខ្លួននៅក្នុងក្រុមប្រទេសដែលបានជ្រើសរើសជាកាសាកល្បង។

កម្មវិធីពង្រីកថាមពលកកើតឡើងវិញ (SREP) នៃមូលនិធិវិនិយោគអាកាសធាតុដែលផ្ដោតសំខាន់លើការផលិតថាមពលកកើតឡើងវិញ និងការកែលម្អការទទួលបានថាមពលក្នុងប្រទេសក្រីក្រ ដែល មានគម្រោងអនុម័តសរុប ១៤គម្រោង កាលពីខែកញ្ញា ឆ្នាំ២០១៤ ប៉ុន្តែមិនទាន់បានទូទាត់ការចំណាយ នៅឡើយទេ។

តារាង ១៧ មូលនិធិផ្ដោតអាទិភាពលើការកាត់បន្ថយ

| មូលនិធិ | ប្ដេជ្ញា (USD) | ការផ្ដល់ | អនុម័ត | ចំនួនគម្រោងដែលបានអនុម័ត |
|---|---|---|---|---|
| មូលនិធិបច្ចេកវិទ្យាស្អាត (CTF) | 5,242 | 4,599 | 3,840 | 69 |
| កញ្ចប់មូលនិធិបរិស្ថានពិភពលោក៤(GEF 4) | 754 | 754 | 956 | 240 |
| កញ្ចប់មូលនិធិបរិស្ថានពិភពលោក៥(GEF 5) | 754 | 777 | 799 | 232 |
| មូលនិធិថាមពលកកើតឡើងវិញ និងប្រសិទ្ធ (GEEREF) | 170 | 164 | 89.07 | 11 |
| កម្មវិធីពង្រីកថាមពលកកើតឡើងវិញសម្រាប់ប្រទេសចំណូលទាប (SREP) | 521 | 506 | 135.99 | 14 |

រហូតមកដល់ពេលនេះ សហរដ្ឋអាមេរិច ជប៉ុន អាល្លឺម៉ង់ និងបារាំងបានប្ដេជ្ញាផ្ដល់នូវមូលនិធិប្រាំប្រភេទនៅក្នុងតារាង១៧ ប្រហែលជា ៧៧%នៃថវិកាប្ដេជ្ញាចំនួន ៩ពាន់លានដុល្លារ។ ប្រហែលជា ៥.៣ ពាន់ លានដុល្លារអាមេរិចបានផ្ដល់ដោយប្រទេសទាំងនេះដែលបានដាក់រួចរាល់ហើយ ៥.៨ពាន់លានដុល្លារ ឬ៨៦% នៃថវិកាដែលបានផ្ដល់សរុបដោយម្ចាស់ជំនួយត្រូវបានអនុម័តសម្រាប់គម្រោង ឬកម្មវិធីកាត់ បន្ថយដែលបានទូទាត់ដោយតម្លាភាពនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍នៅថ្នាក់តំបន់។

មូលនិធិត្រូវបានទូទាត់នៅកម្រិតជាតិ មានប្រទេសចំនួន ២០ ទទួលបាន៨៨%នៃមូលនិធិគាំទ្រលើការកាត់បន្ថយ។ ប្រទេសកំពុងអភិវឌ្ឍន៍ដែលត្រូវការថវិកាបន្ថែមសម្រាប់សកម្មភាពកាត់បន្ថយរួមមាន ម៉ារុក(USD 615.51 លានដុល្លារ), ឥណ្ឌា (USD 592.08លាន), ម៉ិចស៊ិចកូ(USD 570,98លាន), អាហ្វ្រិចខាងត្បូង (USD 485.81 លាន និងឥណ្ឌូនេស៊ី ទទួលជំនួយផ្នែកកាត់បន្ថយកម្រិតខ្ពស់បំផុត មានភាពតានតឹងរវាងឱកាសនៃការកាត់បន្ថយឧស្ម័នផ្ទះ (USD 382.86 លាន) គឺជាប្រទេសដែលត្រូវទទួលបានជំនួយផ្នែកកាត់បន្ថយកម្រិតខ្ពស់បំផុត។ មានភាពតានតឹងរវាងឧកាសនៃការកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់ខ្នាតធំជាក់ស្ដែងនៅក្នុងប្រទេសតូចៗ និងការវិនិយោគនៅក្នុងដំណោះស្រាយកម្រិតតូចដែលប្រទេសកំពុងអភិវឌ្ឍន៍អាចទទួលបានប្រយោជន៍។ គម្រោងដែលទទួលបានការគាំទ្រដោយ GEF និង

SREP បានកែលម្អការទទួលបានថាមពល សម្រាប់ជនក្រីក្រដោយគាំទ្រលើអគ្គិសនីជនបទដោយប្រើប្រាស់បច្ចេកវិទ្យាថាមពលកកើតឡើងវិញ។ អាទិភាពរបស់គម្រោងកាត់បន្ថយទទួលបានហិរញ្ញប្បទានគាំទ្រដើម្បីលើកគម្រោងថាមពលកកើតឡើងវិញ ឬប្រសិទ្ធិភាពថាមពលដែលមានចំនួនច្រើនជាង ៤០% សម្រាប់គម្រោងកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់ពីការផលិតថាមពល និងប្រើប្រាស់។ ប្រទេសម៉ារ៉ុក និងឥណ្ឌា បានទទួលថវិកាចំនួន ៤០០ លានដុល្លា កាលពីឆ្នាំមុនសម្រាប់គម្រោងពង្រីកគម្រោងថាមពលសូឡា។ ហិរញ្ញប្បទាន សម្រាប់គម្រោងកាត់បន្ថយ ដើម្បីគាំទ្រដល់ដំណោះស្រាយការដឹកជញ្ជូនដែលបញ្ចេញកាបូនទាបដោយនិរន្តរភាពជាងមុន ពិសេសហេដ្ឋារចនាសម្ព័ន្ធទីក្រុង។




រូបភាព ១៦ ក្រាហ្វិចការទូទាត់ហិរញ្ញប្បទានសម្រាប់ការកាត់បន្ថយថ្នាក់តំបន់

# មេរៀនទី ៣ ក្របខណ្ឌហិរញ្ញប្បទានការប្រែប្រួលអាកាសធាតុ

## ១. ផលប៉ះពាល់សេដ្ឋកិច្ច សង្គម ពីការប្រែប្រួលអាកាសធាតុដែលបានប៉ាន់ស្មាននៅក្នុងប្រទេសកម្ពុជា

### ១.១ ផលប៉ះពាល់នៅថ្នាក់ជាតិ

ការវិភាគដំបូងដោយផ្អែកលើសេណារីយ៉ូកំណើនសីតុណ្ហភាព ២អង្សាសេ នៅឆ្នាំ២០១៥ បានប៉ាន់ស្មាន ថា ការខូចខាតទាំងមូលបណ្តាលពីការប្រែប្រួលអាកាសធាតុមកលើចំណូលក្នុងស្រុកសរុប (GDP) របស់ ប្រទេសកម្ពុជានឹងមានយ៉ាងហោចណាស់១,៥% នៅឆ្នាំ២០១៣០ និង៣,៥% នៅឆ្នាំ ២០៥០។ ម្យ៉ាងវិញ ទៀតប្រសិនបើអត្រាកំណើនចំណូលក្នុងស្រុកសរុបប្រចាំឆ្នាំក្នុងករណីដែលគ្មានការប្រែប្រួលអាកាសធាតុកើត ឡើងគេរំពឹងទុកថានឹងកើនឡើងរហូតដល់៤,៥% នៅឆ្នាំ២០៣០ តែអត្រានេះនឹងថយចុះមកត្រឹម ៣% វិញ ដោយសារតែផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ។ នៅឆ្នាំ២០៥០ អត្រាកំណើន GDP អាចស្ទើរតែបាត់ បង់ទាំងស្រុង(ថយចុះមកត្រឹម ១% ប៉ុណ្ណោះ) ដែលបណ្តាលមកពីផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ។

ភាគច្រើននៃការខូចខាតទាំងនេះនឹងកើតឡើងបណ្តាលមកពីការកើនឡើងនៃការប្រែប្រួល របបទឹកភ្លៀង ដែលរួមបញ្ចូលទាំងហានិភ័យនានាដូចជា គ្រោះទឹកជំនន់ និងគ្រោះរាំងស្ងួតជាដើម។ ប្រភពចំបងនៃការ ខូចខាតនេះកើតចេញពីផលប៉ះពាល់នៃគ្រោះរាំងស្ងួត និងគ្រោះទឹកជំនន់មកលើវិស័យកសិកម្ម (១,៤២% ន GDP) កំណើនករណីជម្ងឺរាគរូសនិងជម្ងឺស្រួចស្រាវដទៃទៀតដែលទាក់ទងនឹងអាកាសធាតុ (០,៨៥%នៃGDP) ការរេចរឹលនៃហេដ្ឋារចនាសម្ព័ន្ធកាន់តែឆាប់រហ័សដែលរួមមាន ផ្លូវថ្នល់ ប្រព័ន្ធស្រោចស្រព និងការផ្គត់ផ្គង់ ទឹកនៅជនបទ(០,៧១%) និងការខូចខាតដោយសារទឹកជំនន់មកលើហេដ្ឋារចនាសម្ព័ន្ធនៅទីក្រុង(០,២៥% នៃ GDP)។

ការវិភាគនេះមានភាពស្របគ្នាជាមួយនិងការសិក្សានានាដែលមានស្រាប់នៅថ្នាក់តំបន់ និងអន្តរជាតិ។ជាឧទាហរណ៍ ក្រុមការងារទី២សម្រាប់រៀបចំរបាយការណ៍វាយតម្លៃលើកទី៤របស់ក្រុមការងារអន្តររដ្ឋាភិបាលស្តីពីការប្រែប្រួលអាកាសធាតុ(IPCC)បានពិនិត្យមើលអំពីការប៉ាន់ស្មានដ៏ទូលំទូលាយចំពោះការ ខូចខាតដែលអាចបណ្តាលមកពីការប្រែប្រួលអាកាសធាតុ ដោយបានសន្និដ្ឋានថា កំណើនសីតុណ្ហភាព១-៣ អង្សាសេ អាចកាត់បន្ថយ GDP អស់ពី១% ទៅ៥% ក្នុងនោះប្រទេសកំពុងអភិវឌ្ឍន៍រងការខូចខាតធ្ងន់ធ្ងរខ្លាំងជាងប្រទេសដទៃទៀត។

ផលប៉ះពាល់ទ្រង់ទ្រាយធំមកលើសេដ្ឋកិច្ច-សង្គម ដែលបណ្តាលពីការប្រែប្រួលអាកាសធាតុអាចកាត់បន្ថយបាន តាមរយៈសកម្មភាពបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ និងការកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់ដែលមាន ប្រសិទ្ធភាព ការពិនិត្យថ្មីៗអំពីការចំណាយក្នុងវិស័យសាធារណៈដែលទាក់ទងនឹងអាកាសធាតុនៅក្នុងប្រទេស កម្ពុជាបានប៉ាន់ស្មានថា ការចំណាយ១,៣%នៃGDP បច្ចុប្បន្ននេះបានផ្តោតលើវិធានការឆ្លើយតបទៅនឹង ការប្រែប្រួលអាកាសធាតុ សេណារីយ៉ូហិរញ្ញប្បទានអាកាសធាតុបានប៉ាន់ស្មានថាការចំណាយលើសកម្ម ភាពអាកាសធាតុ ដែលអាចមានខ្ពស់បំផុតគឺរហូតដល់១,៨%នៃGDP។ ក្រាហ្វិចខាងក្រោមបង្ហាញពីនិន្នាការ នៃកំណើនGDP នៅក្នុងសេណារីយ៉ូខុសៗគ្នាចំនួនបួន។




រូបភាព ១៧ ក្រាហ្វិកផលប៉ះពាល់រយៈពេលនៃការប្រែប្រួលអាកាសធាតុ និងហិរញ្ញប្បទានអាកាសធាតុមកលើ GDP

តារាង ១៨ សេណារីយ៉ូនៃការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ

| សេណារីយ៉ូនៃការឆ្លើយតប | ២០១៣ | ២០១៣០ | ២០៥០ |
|---|---|---|---|
| សម្មតិកម្មនៃ GDP ប្រសិនបើគ្មានការប្រែប្រួលអាកាសធាតុ (CC) | ១៤,៩ | ៣៣,៨ | ៨១,៦ |
| GDPករណីមានការប្រែប្រួលអាកាសធាតុកើតឡើងតែគ្មានការកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់នៅកម្រិតពិភពលោក(សេណារីយ៉ូ SRES A2) | ១៤,៩ | ២៩,១ | ៤២,១ |
| GDP ករណីមាន CC និងមានការកាត់បន្ថយកម្រិតពិភពលោក (SRES B1) តែគ្មានសកម្មភាពការបន្សាំ | ១៤,៩ | ២៩,៥ | ៤៥,១ |

| | | | |
|---|---|---|---|
| GDPករណីមានCCនិងកាត់បន្ថយកម្រិតពិភពលោកនិងមានការបន្សាំតាមរយៈ១,៣% នៃGDP | ១៤,៩ | ៣១,៤ | ៥៦,១ |
| GDP ឧបមាថា CC និងកាត់បន្ថយកម្រិតពិភពលោកនិងការបន្សាំតាម រយៈ១,៨%នៃGDP | ១៤,៩ | ៣២,១ | ៦០,៧ |

*ពាន់លានដុល្លាអាមេរិក*

## ១.២ ផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុមកលើការវិនិយោគជាក់លាក់

ការវិភាគថ្លៃចំណាយផលចំណេញនៃការវិនិយោគនានាលើការប្រែប្រួលអាកាសធាតុបង្ហាញថា ការចំណាយ ទាំងនេះភាគច្រើនផ្តល់ផលចំណូលវិជ្ជមានខាងសេដ្ឋកិច្ច សូម្បីក្នុងករណីអវត្តមានការប្រែប្រួលអាកាសធាតុក៏ ដោយ ផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុមកលើផលចំណូលខាងសេដ្ឋកិច្ចមានការប្រែប្រួលដោយ សកម្មភាពខ្លះៗ បង្កើតអត្ថប្រយោជន៍កម្រិតខ្ពស់(ជួនកាលត្រូវបានហៅថា"**សកម្មភាពមិនស្តាយក្រោយ**")និងសកម្មភាពខ្លះផ្តល់អត្ថប្រយោជន៍កម្រិតទាប (ជួនកាលហៅថាសកម្មភាព "**ប្រថុយនឹងអាកាសធាតុ**")។ ស្ថានភាពនេះត្រូវបានសង្ខេបតាមរយៈក្រាហ្វិកចំនួនពីរខាង ក្រោម។

ជាឧទាហរណ៍ ការវិនិយោគលើប្រសិទ្ធភាពថាមពលច្រើនតែផ្តល់ផលចំណូលកម្រិតខ្ពស់ពីការវិនិយោគនានា បើទោះបីជាមិនគិតពីការប្រែប្រួលអាកាសធាតុ និងផ្តល់ផលកាន់តែខ្ពស់នៅក្នុងបរិបទនៃការបប្រួលអាកាសធាតុ។ ចំពោះការវិនិយោគលើថាមពលកកើតឡើងវិញ ស្ថានភាពនេះមានលក្ខណៈចម្រុះច្រើន ដោយសារការវិនិយោគខ្លះ(ដូចជាថាមពលវារីអគ្គិសនី ផ្តល់ផលចំណូលសេដ្ឋកិច្ចបានល្អនៅក្នុងលក្ខខណ្ឌ ដែលត្រឹមត្រូវ សូម្បីតែពុំបានគិតដល់ការសន្សំសំចៃនៃការបំភាយកាបូនក៏ដោយ ស្របពេលដែលការវិនិយោគ ផ្សេងៗទៀតអាចត្រូវការចំណាយខ្ពស់ជាងអគ្គសនីដែលបានពីឥន្ធនៈផូស៊ីល។ ក្នុងវិស័យកសិកម្ម ការណ៍ នាំឱ្យប្រើប្រាស់ពូជ និងការអនុវត្តនានាដែលធន់ទៅនឹងទឹកជំនន់និងគ្រោះរាំងស្ងួតផ្តល់ផលចំណូលបានល្អ សូម្បីពុំគិតពីការប្រែប្រួលអាកាសធាតុក៏ដោយ ប៉ុន្តែផលចំណូលកាន់តែមាន សារៈសំខាន់នៅក្នុងបរិបទនៃការ ប្រែប្រួលអាកាសធាតុដែលគ្រោះទឹកជំនន់ និងគ្រោះរាំងស្ងួត នឹងកើតមានកាន់តែញឹកញាប់។




រូបភាព ១៨ ក្រាហ្វិកផលធៀបរវាងអត្ថប្រយោជន៍និងថ្លៃចំណាយក្នុងករណីពុំគិត និងក្នុងករណីគិតពីការប្រែប្រួលអាកាសធាតុ សកម្មភាពនានាដែលផ្តល់ផលចំណូលកាន់តែប្រសើរជាងមុន

ហេដ្ឋារចនាសម្ព័ន្ធភាគច្រើន(ផ្លូវថ្នល់ ប្រព័ន្ធស្រោចស្រព សេវាអនាម័យ។ល។)នឹងផ្តល់ផលចំណូល កម្រិតទាបជាងនៅក្នុងបរិបទនៃការប្រែប្រួលអាកាសធាតុដោយសារតែគ្រោះទឹកជំនន់ និងគ្រោះរាំងស្ងួតនាំ មកនូវតម្រូវការចំណាយខ្ពស់លើការថែទាំនិងការជួសជុល។ ទោះជាយ៉ាងណាក៏ដោយ ផលចំណូលសេដ្ឋកិច្ច កម្រិតខ្ពស់ជាងអាចទទួលបានតាមរយៈ ការកែលម្អការរៀបចំ ឬរចនាហេដ្ឋារចនាសម្ព័ន្ធ (ភាពធន់នឹងអាកាសធាតុ)ដែលបានយកចិត្តទុកដាក់អំពីគ្រោះទឹកជំនន់និងគ្រោះរាំងស្ងួតដែលនឹងកើតមានកាន់តែញឹកញាប់ជាងមុន (សូមមើលក្រាហ្វិចខាងក្រោម)។




រូបភាព ១៩ ក្រាហ្វិកផលធៀបរវាងអត្ថប្រយោជន៍និងថ្លៃចំណាយសម្រាប់គម្រោងវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធដែលគិតគូរនិងដែលមិនគិតគូរអំពីការប្រែប្រួលអាកាសធាតុ

## ២. វិធានការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុនៅកម្ពុជា៖ កម្រិតបច្ចុប្បន្ននៃការចំណាយទាក់ទងនឹងអាកាសធាតុ និងវិធានការស្នើឡើងសម្រាប់ប្រាំឆ្នាំខាងមុខ

### ២.១ ស្ថានភាពបច្ចុប្បន្ននៃការចំណាយលើគម្រោងអាកាសធាតុ

ការវិភាគលើការចំណាយសាធារណៈដែលពាក់ព័ន្ធនឹងអាកាសធាតុត្រូវបានធ្វើឡើង សម្រាប់ចន្លោះឆ្នាំ ២០០៩-២០១២ ដែលរួមទាំងការចំណាយថវិកាជាតិ និងការចំណាយមូលនិធិពីម្ចាស់ជំនួយនានាក្រៅក្រប ខ័ណ្ឌថវិកាជាតិ។ ការចំណាយដែលទាក់ទងនឹងអាកាសធាតុត្រូវបានកំណត់ដោយប្រើប្រាស់វិធីសាស្ត្រដែល ផ្អែកលើអត្ថប្រយោជន៍ ប្រសិនបើ៥០%នៃអត្ថប្រយោជន៍ពីការវិនិយោគណាមួយកើតឡើងដោយសារតែការ ប្រែប្រួលអាកាសធាតុ ការវិនិយោគនោះត្រូវបានចាត់ទុកថាមាន៥០%ពាក់ព័ន្ធនឹងអាកាសធាតុ។ ការវិនិយោគ ខ្លះដូចជាទំនប់ការពារកំណើនកម្ពស់ទឹកសមុទ្រគឺពាក់ព័ន្ធ១០០%នឹងការប្រែប្រួលអាកាសធាតុ។ ការវិនិយោគ ដទៃទៀត ដូចជាលើប្រសិទ្ធភាពថាមពល ឬ ថាមពលកកើតឡើងវិញមានអត្ថប្រយោជន៍ដែលភាគច្រើនជា អត្ថប្រយោជន៍ខាងសេដ្ឋកិច្ចត្រឹមតែ២៧% នៃអត្ថប្រយោជន៍ទាំងនេះប៉ុណ្ណោះ ដែលទាក់ទងនឹងការប្រែប្រួល អាកាសធាតុ(បណ្តាលពីការថយចុះនៃការបំភាយឧស្ម័នផ្ទះកញ្ចក់)។ ផ្អែកលើវិធីសាស្ត្រនេះ កម្រិតចំណាយ ដែលទាក់ទងនឹងអាកាសធាតុបានកើនឡើងជាបន្តបន្ទាប់ពី០,៨៦%នៃ GDP (៣៦៨ពាន់លានរៀន) នៅឆ្នាំ ២០០៩ ដល់១,២៩% នៃ GDP (៧៤១ពាន់លានរៀល)នៅឆ្នាំ២០១២។ ស្ថានភាពដែលត្រូវគ្នានេះនឹងការ ចំណាយដែលពាក់ព័ន្ធនឹងអាកាសធាតុមានដូចខាងក្រោម៖




រូបភាព ២០ ក្រាហ្វិកការចំណាយលើការប្រែប្រួលអាកាសធាតុ ឆ្នាំ២០០៩-២០១២ (ពាន់លានរៀល)

តួនាទីរបស់វិស័យឯកជន និងអង្គការមិនមែនរដ្ឋាភិបាល (NGOs) នៅក្នុងហិរញ្ញវត្ថុអាកាសធាតុនឹងកាន់ តែសំខាន់នៅពេលដែលប្រទេសកម្ពុជាអភិវឌ្ឍន៍ដោយសារតែការវិនិយោគតម្រូវឱ្យមានការកាត់បន្ថយការ បំភាយឧស្ម័ន និងតម្រូវឱ្យមានការលើកកម្ពស់ការយល់ដឹងជាសាធារណៈ ព្រមទាំងការបញ្ចុះបញ្ចូលក្រុមហ៊ុន ទទួលខុសត្រូវលើផ្នែកសង្គម។ សក្តានុពលពេញលេញសម្រាប់ហិរញ្ញប្បទានតាមរយៈទីផ្សារកាបូនដែលកំពុង តែស្ថិតនៅក្នុងស្ថានភាពមិនប្រាកដប្រជា ដោយសារតែអវត្តមានកិច្ចព្រមព្រៀងអន្តរជាតិដែលរំពឹងថានឹងសម្រេច បាននៅឆ្នាំ២០១៥។ វិស័យឯកជនមានឱកាសគ្រប់គ្រាន់ដើម្បីធ្វើការវិនិយោគលើប្រសិទ្ធភាពថាមពលដោយ សារតែផលចំណូលខាងសេដ្ឋកិច្ចមានអត្រាខ្ពស់បន្ថែមលើអត្ថប្រយោជន៍ក្នុងការកាត់បន្ថយការបំភាយឧស្ម័ន ផ្ទុះកញ្ចក់ ការវិនិយោគនេះទាមទារឱ្យមានហិរញ្ញប្បទានដើម្បីបំពេញថ្លៃចំណាយដំបូងលើការវិនិយោគ។ ការសាកល្បងក្នុងពេលថ្មីៗនេះក្នុងឧស្សាហកម្មកម្ពុជាសាលបានបង្ហាញពីផលចំណូលជាមធ្យមពីការវិនិយោគ កម្រិត៨២%ក្នុងរយៈពេលនៃឆ្នាំដំបូង ដែលផ្តល់នូវការលើកទឹកចិត្តកម្រិតខ្ពស់សម្រាប់ពង្រីកការវិនិយោគពី ផ្នែកឯកជនក្នុងវិស័យនេះ។

## ២.២ ស្ថានភាព និងថ្លៃចំណាយលើវិធានការដែលស្នើសម្រាប់រយៈពេលប្រាំឆ្នាំខាងមុខ

វិធានការនៅថ្នាក់ជាតិឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុអាចមានគោលដៅដោះស្រាយត្រឹមតែមួយ ផ្នែកនៃការខូចខាតសរុបដែលបង្កដោយការប្រែប្រួលអាកាសធាតុប៉ុណ្ណោះ ដោយសារតែការបញ្ចៀសនូវការ ខូចខាតខ្លះៗ ដែលជាក់ស្តែងមិនអាចធ្វើបាន ឬការចំណាយដែលពុំមានប្រសិទ្ធភាព។ សមាមាត្រខ្ពស់បំផុតនៃការខូចខាតដែលអាចចៀសវាងបានគឺអាស្រ័យលើស្ថានភាពជាក់លាក់នៅ ក្នុងប្រទេសនីមួយៗ។ យោង តាមរបាយការណ៍ស្ទើនប្រទេសនានាអាចមានគោលដៅដោះស្រាយប្រមាណពីរភាគបីនៃការខូចខាតនេះ។ នៅប្រទេសកម្ពុជា ការធ្វើបែបនេះទាមទារនូវការចំណាយលើការបន្សាំរហូតដល់ ៣,៣% នៃGDP (ធៀបនឹង ១,២២% នៅឆ្នាំ២០១២) រវាងបច្ចុប្បន្ន និងឆ្នាំ២០៥០។

ទោះជាយ៉ាងណាក៏ដោយ គេត្រូវគិតបញ្ចូលឧបសគ្គខាងហិរញ្ញវត្ថុនិងសមត្ថភាពមុននឹងអាចទទួលបាន មូលនិធិកម្រិតខ្ពស់ សម្រាប់ឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ។ ការវិភាគសេណារីយ៉ូដែលអាចមាន ទាក់ទងនឹងការផ្តល់មូលនិធិត្រូវបានធ្វើឡើងសម្រាប់អំឡុងឆ្នាំ ២០១៤-២០១៨ ដោយផ្តោតលើធនធានក្នុង វិស័យសាធារណៈដែលពាក់ព័ន្ធនឹងការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុនៅកម្ពុជា៖

(ក)**មូលនិធិផ្តោតលើអាកាសធាតុ/ពិភពលោក** គឺជាហិរញ្ញវត្ថុដែលបានពីស្ថាប័ន និងយន្តការពិភពលោកសម្រាប់ការប្រែប្រួលអាកាសធាតុ ជាឧទាហរណ៍ៈ មូលនិធិវិនិយោគអាកាសធាតុ(CIF) ដែលរួមទាំង SPCR, GEF, LDCF, AF, FCPF', UN-REDD' និងមូលនិធិអាកាសធាតុបៃតងដែលនឹងមានក្នុងពេលឆាប់ៗ ខាងមុខ នេះដែលផ្តោតលើការដោះស្រាយបញ្ហាការប្រែប្រួលអាកាសធាតុតាមរយៈវិធានការកាត់បន្ថយឬវិធាន ការបន្សាំ។

(ខ)**មូលនិធិផ្តោតលើអាកាសធាតុ/ក្នុងប្រទេស** គឺជាចំណែកនៃមូលនិធិអាកាសធាតុដែលផ្តោតជាក់ស្តែងលើការដោះស្រាយបញ្ហាអាកាសធាតុដែលទទួលបានដោយផ្ទាល់ពីរដ្ឋាភិបាលកម្ពុជា តាមរយៈ ថវិកាប្រចាំឆ្នាំរបស់ខ្លួន ឬ តាមរយៈម្ចាស់ជំនួយទ្វេភាគី និងពហុភាគីដែលប្រតិបត្តិការនៅកម្ពុជា។

(គ)**មូលនិធិចម្រុះ/ក្នុងប្រទេស** សំដៅលើប្រភេទធនធានដែលបានទទួលពីរដ្ឋាភិបាល និងម្ចាស់ជំនួយ នៅកម្ពុជាដែលមិនមែនផ្តោតជាបឋមលើបញ្ហាអាកាសធាតុឡើយ ប៉ុន្តែមានការពាក់ព័ន្ធខ្លះៗ(កម្រិត ទាបនិងមធ្យម)ទៅនឹងការប្រែប្រួលអាកាសធាតុផ្ទាល់ ឬដោយប្រយោល។ នៅក្នុង

ហិរញ្ញវត្ថុប្រភេទ នេះ បញ្ហាអាកាសធាតុត្រូវបានដាក់បញ្ចូល ឬ បង្កប់នៅក្នុងគម្រោងអភិវឌ្ឍន៍នានា។

ធនធានសាធារណៈទាំងនេះដែលកម្ពុជាអាចប្រើប្រាស់សម្រាប់ឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ មានទំហំធំជាងហិរញ្ញវត្ថុអាកាសធាតុ **"ថ្មីនិងបន្ថែម"** ដែលបានកត់សម្គាល់នៅក្នុងការប្តេជ្ញាក្រោមអនុសញ្ញា UNFCCC(ការប្តេជ្ញាទាំងនេះមានក្នុងចំណុច(ក)និងមួយចំណែកពីម្ចាស់ជំនួយនៅក្នុង(ខ) ប៉ុណ្ណោះ)។ គេចាំ បាច់ត្រូវតាមដានទាំងហិរញ្ញវត្ថុអាកាសធាតុ **"ថ្មីនិងបន្ថែម"** ដើម្បីធានាថាធនធានទាំងអស់ដែលអាចទ្រទ្រង់ វិធានការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុត្រូវបានប្រមូលផ្តុំសម្រាប់ប្រើប្រាស់។

សេណារីយ៉ូដំបូងបង្ហាញថា ចំនួនសរុបនៃហិរញ្ញវត្ថុអាកាសធាតុក្នុងវិស័យសាធារណៈអាចកើនពីប្រមាណ ១៨៥លានដុល្លាអាមេរិកនៅឆ្នាំ២០១៣ ដល់២៥៥លានដុល្លាអាមេរិក(កើនឡើងតិចតួច) ឬ ៣០០លាន ដុល្លាអាមេរិក(កើនឡើងខ្លាំង) ក្នុងមួយឆ្នាំៗរហូតដល់ឆ្នាំ២០១៨។ ការបែងចែកធនធានក្នុងមូលនិធិអាកាសធាតុពិភពលោកត្រូវបានរំពឹងថានឹងកើនឡើងឆាប់រហ័ស ប៉ុន្តែធនធានមួយចំណែកធំនៅក្នុងអំឡុងពេលនេះ នឹងត្រូវផ្តល់ដោយរដ្ឋាភិបាល និងម្ចាស់ជំនួយនានានៅក្នុងប្រទេសតាមរយៈហិរញ្ញវត្ថុដែលផ្តោតលើអាកាស ធាតុ ឬ ជាផ្នែកមួយនៃគម្រោងអភិវឌ្ឍន៍ទូទៅ។




រូបភាព ២១ ក្រាហ្វិកការវិវត្តដែលចង្អុលបង្ហាញពីហិរញ្ញវត្ថុអាកាសធាតុ(២០១៤-២០១៨)សេណារីយ៉ូកំណើនកម្រិតទាប

បន្ថែមលើឧបសគ្គខាងហិរញ្ញប្បទាន សមត្ថភាពដែលមានស្រាប់ក្នុងការអនុវត្តកម្មវិធីប្រែប្រួលអាកាស ធាតុក៏ត្រូវតែជាចំណែកមួយដែលត្រូវពិចារណាផងដែរ នៅពេលកសាងផែនការសម្រាប់វិធានការឆ្លើយតប ដែលបានស្នើឡើង ផែនការយុទ្ធសាស្ត្រប្រែប្រួលអាកាសធាតុកម្ពុជា និងផែនការសកម្មភាពប្រែ

ប្រួលអាកាសធាតុនៃក្រសួងអាទិភាពបានកំណត់អត្តសញ្ញាណការត្រៀមរៀបចំសំខាន់ៗ មួយចំនួនសម្រាប់អនុវត្ត នៃវិធានការឆ្លើយតបដែលបានស្នើឡើងឱ្យបានពេញលេញ។ ការអភិវឌ្ឍសមត្ថភាព និងគោលនយោបាយការ កសាងផែនការ និងការសិក្សាស្រាវជ្រាវ តំណាងឱ្យប្រមាណ២៥% នៃវិធានការឆ្លើយតបដែលបានស្នើឡើង នៅក្នុងក្រសួងអាទិភាពទាំងប្រាំបួនសម្រាប់រយៈពេលប្រាំឆ្នាំខាងមុខ ហើយភាគរយនេះត្រូវបានរំពឹងថានឹង ថយចុះនៅពេលដែលកម្ពុជាមានសមត្ថភាពសម្រាប់កសាងផែនការ និងគ្រប់គ្រងវិធានការរបស់ខ្លួនឆ្លើយតប នឹងការប្រែប្រួលអាកាសធាតុ។




រូបភាព ២២ ក្រាហ្វិកការចំណាយដែលគ្រោងសម្រាប់២០១៤-២០១៨ ក្នុងផែនការសកម្មភាពប្រែប្រួលអាកាសធាតុនៃក្រសួងអាទិភាពទាំងប្រាំបួន( គិតជាដុល្លាអាមេរិច)

ផ្អែកតាមផែនការសកម្មភាពដែលមានស្រាប់ និងការប៉ាន់ស្មានសម្រាប់វិស័យនានាដែលពុំទាន់មានផែនការសកម្មភាពនៅឡើយការឆ្លើយតបសរុបក្នុងវិស័យសាធារណៈត្រូវបានប៉ាន់ស្មានថាមានតម្លៃ ១,១ពាន់ លានដុល្លាអាមេរិក សម្រាប់អំឡុងឆ្នាំ២០១៤-២០១៨ ដូចតទៅ៖




រូបភាព ២៣ ក្រាហ្វិកតួលេខប៉ាន់ស្មានការវិភាជន៍ពីប្រភពសាធារណៈសម្រាប់ចំណាយក្នុងការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ ឆ្នាំ២០១៤-២០១៨

ប្រភព៖ សេចក្តីព្រាង CCAPs (ខែមិនា ឆ្នាំ២០១៤) និងសេណារីយ៉ូហិរញ្ញប្បទាន CCFF

សក្តានុពលនៃការគាំទ្រហិរញ្ញវត្ថុពីវិស័យឯកជនដល់វិធានការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ នៅតែមិនប្រាកដប្រជា។ វិស័យឯកជនមានសក្តានុពលក្នុងការវិនិយោគលើប្រសិទ្ធភាពថាមពលដូចមាន សាកល្បងថ្មីៗនេះក្នុងឧស្សាហកម្មកម្មន្តសាល និងកសិ-ឧស្សាហកម្ម ដែលបានបង្ហាញពីផលចំណូលឆាប់ រហ័សយ៉ាងខ្លាំងពីការវិនិយោគក្នុងវិស័យនេះ ទាក់ទងនឹងទីផ្សារកាបូនសក្តានុពលខាងហិរញ្ញប្បទានពុំមាន ភាពប្រាកដប្រជាឡើយដោយសារគ្មានការឯកភាពជាអន្តរជាតិដែលឈានដល់កិច្ចព្រមព្រៀងជាប់ជាកាតព្វ កិច្ចផ្លូវច្បាប់នៅឡើយ។ ហើយប្រទេសនីមួយៗទំនងជាងាកចេញពីយន្តការដែលមានបច្ចុប្បន្នដូចជាយន្តការអភិវឌ្ឍន៍ស្អាត និងព្យាយាមបង្កើតគំរូរបស់ខ្លួនផ្ទាល់សម្រាប់ទីផ្សារកាបូន។ ថ្លៃកាបូនមានភាពប្រែប្រួលជាខ្លាំង ហើយបច្ចុប្បន្ននេះនៅមានកម្រិតទាប។ ក្នុងករណីគម្រោងយន្តការអភិវឌ្ឍន៍ស្អាត ឥឡូវនេះថ្លៃកាបូនមានត្រឹម ១-២ដុល្លាអាមេរិកក្នុង១តោនសមមូល$CO_2$(ពោលគឺថយចុះពីប្រមាណ ២០ដុល្លាអាមេរិចនៅឆ្នាំ១៩៩៧ និង ៥-៨ ដុល្លាអាមេរិចនៅឆ្នាំ២០១១ និងប្រមាណ៤-៨ដុល្លាអាមេរិចក្នុង១តោនសមមូលCO សម្រាប់ឥណទាន គម្រោង REDD។

## ៣. ការណែនាំដើម្បីបង្កើតក្របខ័ណ្ឌហិរញ្ញប្បទានបម្រែបម្រួលអាកាសធាតុដែលមាន តម្លាភាព អាចទុកចិត្តបាន និងមានភាពទាក់ទាញ

កម្ពុជាបានចាត់វិធានការធំៗខ្លះរួចមកហើយ ក្នុងការបង្កើតយន្តការដ៏រឹងមាំដើម្បីគ្រប់គ្រងហិរញ្ញវត្ថុអាកាសធាតុ ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព ក្រុមការងារបច្ចេកទេសប្រែប្រួលអាកាសធាតុនិង អគ្គលេខាធិការដ្ឋានត្រូវបានបង្កើតឡើងដោយមានអាណត្តិ សម្របសម្រួលវិធានការជាតិឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ ផែនការយុទ្ធសាស្ត្រមួយរយៈពេលដប់ឆ្នាំ ពោលគឺផែនការយុទ្ធសាស្ត្រប្រែប្រួលអាកាសធាតុកម្ពុជាឆ្នាំ២០១៤-២០២៣ ក៏ត្រូវបានដាក់ឱ្យអនុវត្តន៍ហើយក្រសួងជាអាទិភាពចំនួនប្រាំបួនបានបង្កើត ផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាពតាមវិស័យរបស់ខ្លួនរួចហើយដែរ នៅថ្នាក់ក្រោមជាតិមានការ ចាប់ផ្តើមបញ្ចូលការប្រែប្រួលអាកាសធាតុទៅក្នុងការកសាងផែនការ និងការលើកថវិកានៅថ្នាក់ខេត្ត ស្រុក និងឃុំនានា ដោយផ្អែកតាមមេរៀនដែលទទួលបានពីគម្រោងសាកល្បងមួយចំនួន។ ទោះជាយ៉ាងណាក៏ដោយ នៅមានការងារជាច្រើនដែលសម្រេចឱ្យបានដើម្បីកែលម្អការសម្របសម្រួលរវាងរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍លើការងារប្រែប្រួលអាកាសធាតុ ដើម្បីអាចតាមដានបានប្រសើរជាងមុននូវការចំណាយលើអាកាសធាតុ និងប៉ាន់ប្រមាណពីប្រសិទ្ធផលនិងឥទ្ធិពលនៃការចំណាយទាំងនោះដើម្បីបញ្ជ្រាបការប្រែប្រួលអាកាសធាតុឱ្យបានពេញលេញនៅក្នុងការគ្រប់គ្រងសាធារណៈ (គោលនយោបាយ ការកសាងផែនការ ការលើកថវិកា ការអនុវត្ត ការតាមដាន និងការវាយតម្លៃ) និងនិយ័តកម្ម ព្រមទាំងដើម្បីបង្កើតការលើកទឹកចិត្តដើម្បីឱ្យវិស័យឯកជនចូលរួមចំណែក។

តារាង ១៩ ដើម្បីគ្រប់គ្រងអន្តរកាលនេះមានការស្នើថាកម្ពុជាគួរបង្កើតមូលនិធិជាតិ អាកាសធាតុ (NCFF)ដែលមាន លក្ខណៈសំខាន់ៗ ដូចតទៅ៖

| | |
|---|---|
| ១ | មូលនិធិNCFFនឹងគ្របដណ្តប់រាល់គោលនយោបាយកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់និងបន្សាំនឹងការប្រែប្រួលអាកាសធាតុដែលរួមទាំងរដ្ឋាភិបាល និងម្ចាស់ជំនួយ ការវិនិយោគ ការចំណាយចរន្ត និង និយ័តកម្មព្រមទាំងការលើកទឹកចិត្តក៏ដូចជាការចំណាយផងដែរ។ |
| ២ | ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព(NCSD)នឹងផ្តល់ការដឹកនាំហើយលេខាធិការដ្ឋាននៃ ក្រុមប្រឹក្សានេះនឹងផ្តល់ការគាំទ្របច្ចេកទេស។ ផែនការយុទ្ធសាស្ត្រប្រែប្រួលអាកាសធាតុកម្ពុជា (CCCSP) ផែនការយុទ្ធសាស្ត្រប្រែប្រួលអាកាសធាតុតាមវិស័យ (CCSPs) និងផែនការសកម្មភាពប្រែប្រួល អាកាសធាតុ (CCAPs) នឹងត្រូវធ្វើបច្ចុប្បន្នភាពដើម្បីផ្តល់ការណែនាំជាយុទ្ធសាស្ត្រ។ |
| ៣ | និយមន័យហិរញ្ញវត្ថុប្រែប្រួលអាកាសធាតុនឹងត្រូវកំណត់ដោយផ្អែកលើថាតើអត្ថប្រយោជន៍ ពីគោល នយោបាយ/សកម្មភាពណាមួយនឹងរងឥទ្ធិពលពីការប្រែប្រួលអាកាសធាតុឬទេដោយប្រើ |

| | |
|---|---|
| | ប្រាស់ សំណៅវិធីសាស្រ្តដែលមានអធិប្បាយនៅក្នុងឯកសារនេះ និងដែលបានអនុម័តគាំទ្រតាមរយៈបញ្ញត្តិ ច្បាប់។ |
| ៤ | កម្រិតនៃការផ្តល់មូលនិធិប្រែប្រួលអាកាសធាតុនឹងត្រូវដាក់បញ្ចូលជាបណ្តើរៗនៅក្នុងថវិកាជាតិ និង ក្នុងគណនីរបស់រដ្ឋាភិបាលដោយប្រើប្រាស់សញ្ញាសំគាល់ និងពិន្ទុនៅក្នុងប្រព័ន្ធ PFM។ |
| ៥ | NCSD នឹងមាននាទីជាស្ថាប័នអនុវត្តរបស់ជាតិ(NIE) សម្រាប់AF និង GCF ហើយការផ្តល់មូលនិធិ តាមរយៈNIEនឹងវិវត្តទៅជាផ្នែកមួយនៃថវិកានិងបានពីរតនាគារជាតិ ទោះបីពីដំបូងគេអាចបើ ប្រាស់ត្រឹមគណនីគម្រោង និងគណនីពិសេសនៅក្នុងរតនាគារក៏ដោយ។ |
| ៦ | ម្ចាស់ជំនួយនឹងបានទទួលការលើកទឹកចិត្តដើម្បីរួមបញ្ចូលការប្រែប្រួលអាកាសធាតុទៅ ក្នុងគម្រោង ទាំងអស់ដែលមានការពាក់ព័ន្ធតាមរយៈការជ្រើសរើសគម្រោងរបស់ម្ចាស់ជំនួយនៅក្នុងដំណាក់ កាលកំណត់យុទ្ធសាស្រ្តរបស់ប្រទេស និងការកំណត់រកគម្រោង ចំណុចនេះនឹងត្រូវអនុវត្ត ។ សម្រាប់គ្រប់គំរូទាំងអស់ដែលរួមទាំងការគាំទ្រវិស័យណាមួយឬការគាំទ្រថវិកាជាទូទៅ ម្ចាស់ ជំនួយនឹងបានទទួលការលើកទឹកចិត្តឱ្យប្រមូលផ្តុំធនធានរួមគ្នានៅក្នុងករណីដែលអាចធ្វើបាន។ |
| ៧ | ការគាំទ្រនៃវិស័យសាធារណៈដល់ការកាត់បន្ថយការបញ្ចេញឧស្ម័ននឹងងាកចេញជាបណ្តើរៗពីជំនួយឥតសំណង និងការវិនិយោគផ្ទាល់ទៅរកគំរូនានាដែលលើកទឹកចិត្តដល់វិស័យឯកជនដើម្បីវិនិយោគលើការកាត់បន្ថយ។ |
| ៨ | អាជ្ញាធរនៅថ្នាក់ក្រោមជាតិនឹងទទួលបានចំណែកកាន់តែច្រើននៃហិរញ្ញវត្ថុអាកាសធាតុ ក្នុងករណី ដែលដំណើរការ PFM នៅតែមានជោគជ័យ។ ការធ្វើបែបនេះបានអាចទាមទារឱ្យមានវិមជ្ឈការសកម្មភាពខ្លះៗបន្ថែមទៀត។ |
| ៩ | លេខាធិការដ្ឋាន NCSD នឹងរក្សាក្របខ័ណ្ឌអ្នកជំនាញការកម្ពុជាដែលធ្វើការនៅក្នុងផ្នែកកសាងផែនការនៃក្រសួងពាក់ព័ន្ធដើម្បីជួយរួមបញ្ចូលការប្រែប្រួលអាកាសធាតុទៅក្នុងការរៀបចំគម្រោង និង ឯកសារថវិកា។ តាមធម្មតាកិច្ចការនេះនឹងធ្វើឡើងជាទម្រង់នៃការគាំទ្រក្នុងការងារផ្ទាល់ដែលផ្សារភ្ជាប់ទៅនឹងការសម្រេចលើចំណាយសម្រាប់កិច្ចការប្រែប្រួលអាកាសធាតុ។ |
| ១០ | NCCC នឹងរៀបចំរបាយការណ៍វឌ្ឍនភាពប្រចាំឆ្នាំស្តីពីហិរញ្ញវត្ថុអាកាសធាតុ(APR) ដែលនឹងកត់តនិន្នាការក្នុងការចំណាយ និងភស្តុតាងនានាដែលមានស្តីពីប្រសិទ្ធភាពនៃការចំណាយ។ |
| ១១ | NCFF ធ្វើការឆ្ពោះទៅរកទីបញ្ចប់រហូតដល់ឆ្នាំ២០២៣ ដែលនៅដំណាក់កាលនោះ មួយភាគធំនហិរញ្ញវត្ថុអាកាសធាតុត្រូវបានផ្តល់តាមរយៈការគាំទ្រថវិកាដែលរួមទាំងការគាំទ្រថវិកាតាមវិស័យ និងការគាំទ្រថវិកាទូទៅ។ |

NCFF សម្របសម្រួលសម្រាប់ការចាត់ចែងផ្តល់មូលនិធិតាមរបៀបខុសៗ គ្នាដែលរួមទាំងរាល់រចនា សម្ព័ន្ធចាត់ចែងដែលកំពុងប្រើប្រាស់បច្ចុប្បន្ននេះផងដែរ។ NCFF នឹងបង្កើនវឌ្ឍនភាពទៅរកការចូលរួមនិងការ ទទួលខុសត្រូវកាន់តែច្រើនឡើងរបស់រដ្ឋាភិបាល ប៉ុន្តែមិនបង្ខំឱ្យរដ្ឋាភិបាល ឬម្ចាស់ជំនួយចូលរួមនៅក្នុង ប្រព័ន្ធគ្រប់គ្រងរួមមួយ ដូចជាមូលនិធិជាតិអាកាសធាតុឡើយ។ ការវិភាគអំពីសេណារីយ៉ូហិរញ្ញប្បទាន អាកាសធាតុនិងទស្សនវិស័យរបស់ម្ចាស់ជំនួយស្តីពីគំរូនៃការផ្តល់ជំនួយនៅកម្ពុជាបង្ហាញថាមូលនិធិបែបនេះ មិនទំនងជាបង្កើនធនធានច្រើនឡើយនៅក្នុងរយៈពេលខ្លីទៅមធ្យម។ ការពិនិត្យឱកាសដើម្បីបង្កើតស្ថាប័ន មូលនិធិមួយត្រូវបានស្នើឡើងជាផ្នែកមួយនៃការពិនិត្យCCCSP ពាក់កណ្តាលអាណត្តិនៅក្នុងឆ្នាំ២០១៨ នៅ ពេលដែលមានការអេះអាងបន្ថែមអំពីគំរូនានាសម្រាប់ហិរញ្ញប្បទានអាកាសធាតុអន្តរជាតិ និងបន្ទាប់ពីបាន បញ្ចប់ដំណាក់កាលបច្ចុប្បន្ននៃកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៅកម្ពុជា។ គ្រឹះស្ថាននានាដូចខាងក្រោមនេះនឹងមានការទទួលខុសត្រូវអនុវត្តន៍មូលនិធិជាតិអាកាសធាតុដូចតទៅ៖

### ៣.១ អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព

- បង្កើតយន្តការសម្របសម្រួលរវាងរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍សម្រាប់ការអនុវត្តCCCSP និង ផែនការ សកម្មភាពដែលត្រូវគ្នានេះ។ យន្តការនេះនឹងធានាយ៉ាងហោចណាស់រាល់អន្តរាគមន៍ដែលទាក់ទង នឹងអាកាសធាតុត្រូវបានលើកផែនការនិងថវិកាស្របជាមួយCCCSP/CCAP និងរួមចំណែកនៅក្នុង ក្របខ័ណ្ឌជាតិសម្រាប់តាមដាន និងវាយតម្លៃអំពីការប្រែប្រួលអាកាសធាតុ។
- កែតម្រូវលក្ខខណ្ឌនៃច្បាប់ (ដូចជា អង្គភាពស្វយ័តអន្តរក្រសួង) និងនីតិវិធីធ្វើការតាមការចាំបាច់ និងដាក់ពាក្យសុំទៅមូលនិធិបន្សាំ និងមូលនិធិអាកាសធាតុបៃតង ឱ្យទទួលស្គាល់ស្ថាប័នអនុវត្តន៍របស់ ជាតិ។
- ក្រោមភាពជាដៃគូជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និង CDC-CRDB ត្រូវបង្កើតនីតិវិធីសម្រាប់ការ តាមដានប្រចាំឆ្នាំលើការចំណាយក្នុងវិស័យសាធារណៈដែលពាក់ព័ន្ធនឹងអាកាស ធាតុ។ កិច្ចការនេះ នឹងត្រូវវិវត្តជាបន្តបន្ទាប់ពីការពិនិត្យប្រចាំឆ្នាំជាករណីពិសេស ដើម្បីរួមបញ្ចូលវិធីតាមដានការប្រែប្រួល អាកាសធាតុនៅក្នុងកម្រងទិន្នន័យថវិកាជាតិ និងកម្រងទិន្នន័យជំនួយអភិវឌ្ឍន៍ផ្លូវការ (ODA)។
- ក្រោមភាពជាដៃគូជាមួយក្រសួងផែនការ និងក្រសួងពាក់ព័ន្ធនានា ត្រូវបង្កើតក្របខ័ណ្ឌតាមដាននិង វាយតម្លៃដែលកំពុងដំណើរការសម្រាប់ការប្រែប្រួលអាកាសធាតុ និងរៀបចំការវិភាគជាទៀងទាត់អំពីផលប៉ះពាល់នៃវិធានការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ ទាត់លើការអនុវត្ត CCCSP

- ក្រោមកិច្ចសហការជាមួយសកលវិទ្យាល័យ និងគ្រឹះស្ថានបណ្តុះបណ្តាលដែលពាក់ព័ន្ធ ត្រូវរៀបចំ និង គ្រប់គ្រងកម្មវិធីអភិវឌ្ឍន៍ជំនាញ ដែលឆ្លើយតបនឹងតម្រូវការរបស់ក្រុមសំខាន់ៗនៃមន្ត្រីរដ្ឋាភិបាល ដែលពាក់ព័ន្ធនៅក្នុងវិធានការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ (ការវិភាគគោលនយោបាយការ កសាងផែនការនិងថវិកា ការតាមដាននិងការពិនិត្យលើការចំណាយ ការវាយតម្លៃផលប៉ះពាល់ ។ល។)
- ផ្តល់ការគាំទ្របច្ចេកទេសដល់សមាជិក NCSD ដើម្បីទទួលបានហិរញ្ញវត្ថុអាកាសធាតុនិងការគ្រប់គ្រង ដែលរួមទាំង ការបង្កើតគម្រោង និងលើកថវិកា និងការតាមដានលទ្ធផលនៃការប្រែប្រួលអាកាសធាតុ
- ផ្តល់យោបល់ដល់ NCSD និងសមាជិកគណៈកម្មាធិការនេះ អំពីការកែប្រែសមស្របខាងផ្នែកច្បាប់ និង បទប្បញ្ញត្តិនានាសម្រាប់បញ្ជ្រាបការប្រែប្រួលអាកាសធាតុ ទៅក្នុងការកសាងផែនការ និងការអនុវត្ត និងក្នុងការគោរពតាមកាតព្វកិច្ចជាអន្តរជាតិរបស់កម្ពុជា
- បង្កើតយន្តការសន្ទនាជាមួយវិស័យឯកជន អំពីវិធានការដែលមានសក្តានុពលដើម្បីសម្រួលដល់ការ វិនិយោគរបស់វិស័យឯកជនលើវិធានការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ
- ក្រោមភាពជាដៃគូជាមួយឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងពាក់ព័ន្ធត្រូវធ្វើការវិភាគស៊ីជម្រៅអំពីសេដ្ឋកិច្ចនៃការប្រែប្រួលអាកាសធាតុដែលនាំមកនូវអនុសាសន៍ គោលនយោបាយស្តីពីវិធានការបន្សាំ និងការកាត់បន្ថយដែលកាន់តែមានប្រសិទ្ធភាពនៅក្នុងបរិបទ កម្ពុជា និងធ្វើការប៉ាន់ស្មានឱ្យសុក្រឹត្យជាងមុនអំពីផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុមកលើ លក្ខខណ្ឌសេដ្ឋកិច្ច និងសង្គមកម្ពុជា។

## ៣.២ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- កែលម្អការវិភាគថ្លៃចំណាយ-ផលចំណេញអំពីផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុមកលើសេដ្ឋ កិច្ច(ក្រោមកិច្ចសហការជាមួយ SNEC និង NCCC) និងអំពីការចំណាយ/ការវិនិយោគក គោលនយោបាយ នានា និងបម្លែងរបកគំហើញនានាឱ្យទៅជាអនុសាសន៍សម្រាប់រួមបញ្ចូលទៅក្នុងឯកសារថវិកាជាតិ (ដូចជា ផែនការយុទ្ធសាស្រ្តថវិកា) និងដំណើការនានា
- ក្រោមភាពជាដៃគូជាមួយ NCSD ត្រូវធ្វើការវិភាគប្រចាំឆ្នាំអំពីការចំណាយក្នុងវិស័យសាធារណៈដែល ពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុដើម្បីតាមដានស្ថានភាពនៃវិធានការឆ្លើយតបនឹងការប្រែប្រួល អាកាសធាតុនៅកម្ពុជា។ ក្នុងរយៈពេលមធ្យមត្រូវរួមបញ្ចូលវិធានការតាមដានការ

ចំណាយលើអាកាស ធាតុនៅក្នុងថវិកាជាតិ ដែលនៅពេលមានកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដែលនាំទៅ រកការអនុវត្តថវិកាកម្មវិធីបានពេញលេញ

- រួមជាមួយ NCSD ត្រូវដឹកនាំការសន្ទនាជាមួយម្ចាស់ជំនួយហិរញ្ញវត្ថុអាកាសធាតុ អំពីគំរូនានាសម្រាប់ ការរួមបញ្ចូលជាបណ្តើរៗនូវហិរញ្ញវត្ថុអាកាសធាតុទៅក្នុងប្រព័ន្ធថវិកាជាតិ
- រួមបញ្ចូលបញ្ហា/គំរូនៃហិរញ្ញវត្ថុអាកាសធាតុទៅក្នុងកញ្ចប់ស្តង់ដារសម្រាប់ការបណ្តុះបណ្តាលមន្ត្រីរដ្ឋាភិបា លស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- ចូលរួមនៅក្នុងការសន្ទនាមួយជាមួយវិស័យឯកជនអំពីគោលនយោបាយដែលមានសក្តានុពលសម្រាប់ លើកកម្ពស់ការវិនិយោគពីវិស័យឯកជននៅក្នុងវិធានការឆ្លើយតបនឹងអាកាសធាតុ ជាពិសេសការកាត់បន្ថយ។

### ៣.៣ ក្រសួងផែនការ

- ក្រោមភាពជាដៃគូជាមួយ NCSD ត្រូវប្រមូលនិងវិភាគទិន្នន័យអំពីសូចនាករដែលទាក់ទងនឹងអាកាស ធាតុនៅក្នុង NSDPដោយផ្ទាល់(តាមរយៈ NIS)ឬតាមរយៈគោលការណ៍ណែនាំនិងការគាំទ្រគ្រប់គ្រាន់ ដល់ក្រសួងពាក់ព័ន្ធ
- ក្រោមភាពជាដៃគូជាមួយ NCSD និង NCDD ត្រូវរួមបញ្ចូលការប្រែប្រួលអាកាសធាតុនៅក្នុងគោលការណ៍ណែនាំអំពីការកសាងផែនការសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ។

### ៣.៤ ក្រសួង និងស្ថាប័នពាក់ព័ន្ធនៅក្នុងវិធានការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ

- កសាងផែនការសកម្មភាពប្រែប្រួលអាកាសធាតុដែលផ្សារភ្ជាប់ទៅនឹងយុទ្ធសាស្ត្រវិស័យពាក់ព័ន្ធ និង NSDP ស្របតាមគោលការណ៍ណែនាំពី NCSD
- ធានាឱ្យមានសមាហរណកម្មជាបណ្តើរៗនៃសកម្មភាពប្រែប្រួលអាកាសធាតុនៅក្នុងកម្មវិធី/ផែនការសកម្មភាពសំខាន់ៗតាមវិស័យរបស់ខ្លួន
- បង្កើតនីតិវិធីនិងស្តង់ដារច្បាស់លាស់សម្រាប់ជ្រើសយកសកម្មភាព/គម្រោងនានានៅក្នុងដំណាក់កាល បង្កើតនិងកំណត់អត្តសញ្ញាណគម្រោង/សកម្មភាពដែលរងឥទ្ធិពលពីការប្រែប្រួលអាកាសធាតុ។ គិតបញ្ចូលថ្លៃចំណាយទៅក្នុងផែនការ និងការលើកថវិកាសម្រាប់សកម្មភាពទាំងនេះ

- បង្កើតរចនាសម្ព័ន្ធស្ថាប័ននៅក្នុងក្រសួងដើម្បីអនុវត្តន៍ និងតាមដានផែនការសកម្មភាពប្រែប្រួលអាកាសធាតុ(ជនបង្គោល ឬ ក្រុមការងារ) និងផ្តល់ការគាំទ្រដល់នាយកដ្ឋានពាក់ព័ន្ធនានាអំពីបញ្ហាប្រែប្រួលអាកាសធាតុ
- ក្រោមភាពជាដៃគូជាមួយ NCSD និង MEF បានធ្វើការវិភាគនិងវាយតម្លៃថ្លៃចំណាយ-ផលចំណេញ នៃសកម្មភាពដែលពាក់ព័ន្ធនឹងអាកាសធាតុ និងកំណត់សកម្មភាពដែលមានប្រសិទ្ធភាពខ្ពស់បំផុត ខាងការចំណាយ
- សហប្រតិបត្តិការជាមួយក្រសួង និងស្ថាប័នផ្សេងទៀតទៅតាមអាណត្តិរបស់ខ្លួន ក្នុងពេលចាំបាច់ត្រូវ រួមបញ្ចូលវិធានការឆ្លើយតបនឹងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុសហប្រតិបត្តិការជាមួយ NCSD ដើម្បីកៀរគរធនធានសម្រាប់សកម្មភាពនានាដែលទាក់ទងនឹងអាកាសធាតុដែលរួមទាំងការកំណត់អត្តសញ្ញាណប្រភព និងគំរូនៃការផ្តល់មូលនិធិដែលមានសក្តានុពល។

## ៣.៥ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា/គណៈកម្មាធិការស្តារនិងអភិវឌ្ឍន៍កម្ពុជា (CDC/CRDB)

- ក្រោមកិច្ចសហប្រតិបត្តិការជាមួយ NCSD ត្រូវធ្វើការកែលម្អវិធីតាមដានការប្រែប្រួលអាកាសធាតុនៅ ក្នុងកម្រងទិន្នន័យ ODA និងផ្តល់វគ្គបណ្តុះបណ្តាលដែលពាក់ព័ន្ធដល់ដៃគូ អភិវឌ្ឍន៍
- រួមបញ្ចូល NCSD នៅក្នុងការពិនិត្យសេចក្តីព្រាងយុទ្ធសាស្ត្រដៃគូអភិវឌ្ឍន៍សម្រាប់ប្រទេសកម្ពុជាដើម្បី ធានាថាកម្មវិធីនានាដែលទាក់ទងនឹងអាកាសធាតុត្រូវបានកំណត់អត្តសញ្ញាណតាំងពីដំណាក់កាលដើមដំបូងសម្រាប់ការរៀបចំឱ្យបានសមស្រប។

## ៣.៦ លេខាធិការដ្ឋានគណៈកម្មាធិការជាតិ សម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ និងរដ្ឋបាលក្រោមជាតិ

- រួមបញ្ចូលអាកាសធាតុទៅក្នុងគោលការណ៍ណែនាំសម្រាប់កសាងផែនការនិងការលើកថវិកាសម្រាប់ មូលនិធិឃុំ-សង្កាត់ និងមូលនិធិស្រុក-ក្រុង ដោយផ្អែកតាមមេរៀនដែលទទួលបានពីការអនុវត្តសាក ល្បងដែលមានស្រាប់
- រួមបញ្ចូលការប្រែប្រួលអាកាសធាតុទៅក្នុងអាទិភាពនានានិងនីតិវិធីកសាងផែនការ/ការអនុវត្តសម្រាប់ មូលនិធិវិនិយោគនៅថ្នាក់ក្រោមជាតិ

- ក្រោមកិច្ចសហប្រតិបត្តិការជាមួយ NCSD ត្រូវបង្កើតវិធីតាមដានអាកាសធាតុសម្រាប់ការចំណាយដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុ តាមរយៈ CSF, DMF និង SNIF (ស្របតាមវិធីសាស្ត្រដែល បានគ្រោងទុកសម្រាប់ កម្រងទិន្នន័យ ODA និងថវិកាជាតិ)
- ក្រោមកិច្ចសហប្រតិបត្តិការជាមួយ NCSD ត្រូវគូសបញ្ជាក់អំពីការទទួលខុសត្រូវដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុ នៅលំដាប់ថ្នាក់ខុសៗគ្នានៃរដ្ឋបាលថ្នាក់ក្រោមជាតិ (ខេត្ត ស្រុក ឃុំ)
- អភិវឌ្ឍន៍សមត្ថភាពខាងការប្រែប្រួលអាកាសធាតុនៅក្នុងអង្គភាពគាំទ្របច្ចេកទេសសម្រាប់ យន្តការរដ្ឋបាលនៅថ្នាក់ក្រោមជាតិ នៅថ្នាក់ស្រុក និងខេត្ត។

## ៣.៧ ដៃគូអភិវឌ្ឍន៍

- ផ្តល់ហិរញ្ញវត្ថុប្រែប្រួលអាកាសធាតុថ្មី និងបន្ថែមស្របជាមួយការប្តេជ្ញានៅក្រោមអនុសញ្ញា UNFCCC ប៉ុន្តែត្រូវជានាផងដែរថាគម្រោងODA ដូចមានកន្លងមក "**សកម្មភាពវៃឆ្លាតខាងកាសធាតុ**"
- នៅក្នុងដំណាក់កាលយុទ្ធសាស្ត្រតាមប្រទេស ត្រូវធានាថាមានការពិគ្រោះយោបល់ជាមួយ NCSD អំពី អាទិភាព និងកម្មវិធីនានាដែលបានស្នើឡើងដើម្បីឱ្យអន្តរាគមន៍នានាដែលពាក់ព័ន្ធនឹងអាកាសធាតុ (ODA ពីមុនមក និងហិរញ្ញវត្ថុអាកាសធាតុបន្ថែម) អាចកំណត់បានតាំងពីដំណាក់កាលដើមដំបូងនិងបានបន្សុីគ្នាជាមួយផែនការយុទ្ធសាស្ត្រប្រែប្រួលអាកាសធាតុកម្ពុជា (CCCSP)
- ចំពោះគម្រោងនានាដែលបានកំណត់អត្តសញ្ញាណថាពាក់ព័ន្ធនឹងអាកាសធាតុត្រូវធានាថាបានទទួល យោបល់បច្ចេកទេសពី NCSD / និងឬក្រុមការងារបច្ចេកទេសអាកាសធាតុតាំងពីនៅក្នុងដំណាក់កាល បង្កើតគម្រោងនៅក្នុងក្រសួងពាក់ព័ន្ធដែលរួមទាំងអំពីស្តង់ដារពង្រឹងភាពធន់នឹងអាកាសធាតុដែល ពាក់ព័ន្ធ លក្ខខណ្ឌចាំបាច់ផ្សេងទៀតនិងរួមបញ្ចូលថ្លៃចំណាយ និងធាតុចូលពាក់ព័ន្ធនានានៅ ក្នុងថវិកាគម្រោង
- ចូលរួមនៅក្នុងយន្តការរដ្ឋាភិបាល-ម្ចាស់ជំនួយសម្រាប់សម្របសម្រួលការប្រែប្រួលអាកាសធាតុចែក រំលែកព័ត៌មាន និងស្វែងរកយោបល់តបអំពីកម្មវិធីដែលពាក់ព័ន្ធនឹងអាកាសធាតុដែលមានក្នុងពេល ខាងមុខបន្សុីគ្នាជាមួយអាទិភាពជាតិដូចដែលបានកំណត់នៅក្នុង CCCSP និងផែនការនានាដែលពាក់ព័ន្ធ និងធានាថាគម្រោងដែលបានទទួលមូលនិធិគាំទ្រអាចរួមចំណែកទៅក្នុងក្របខ័ណ្ឌតាមដាននិង វាយតម្លៃរបស់ជាតិ ក្នុងករណីអាចធ្វើបានត្រូវពិចារណាប្រមូលផ្តុំធនធានជាមួយដៃគូដែលមាន ចំណាប់អារម្មណ៍ផ្សេងទៀតដើម្បីកាត់បន្ថយថ្លៃចំណាយអន្តរការ

- រាយការណ៍ជាលក្ខណៈប្រព័ន្ធអំពីការពាក់ព័ន្ធនៃអាកាសធាតុនៅក្នុងសំណុំរឿងរបស់ខ្លួនតាមរយៈ វិធី តាមដានអាកាសធាតុដូចមានក្នុងកម្រងទិន្នន័យ ODA របស់ CDC/CRDB
- នៅពេលផ្តល់ការគាំទ្រតាមវិស័យ ឬ ការគាំទ្រជាថវិកាទូទៅ ត្រូវរួមបញ្ចូលការប្រែប្រួលអាកាសធាតុ នៅក្នុងក្របខ័ណ្ឌលទ្ធផល (ស្របគ្នាជាមួយ CCCSP និងក្របខ័ណ្ឌតាមដាននិងវាយតម្លៃនៅថ្នាក់ ជាតិ សម្រាប់ការប្រែប្រួលអាកាសធាតុ) និងផ្តល់ហិរញ្ញវត្ថុអាកាសធាតុដែលគាំទ្រដល់គោល បំណងទាំងនេះ
- បង្កើនវត្តមានហិរញ្ញវត្ថុអាកាសធាតុនៅកម្រិតសមស្រប តាមរយៈ CSF, DMF និង SNIF អនុលោមតាម កម្រិតនៃសមាហរណកម្មការប្រែប្រួលអាកាសធាតុក្នុងនីតិវិធីកសាងផែនការនិង ការលើកថវិកាសម្រាប់ មូលនិធិទាំងនេះ
- ក្នុងករណីពាក់ព័ន្ធត្រូវរួមបញ្ចូលអន្តរាគមន៍អភិវឌ្ឍន៍សមត្ថភាពដែលពាក់ព័ន្ធនឹងការប្រែប្រួល អាកាស ជាតុទាំងនៅកម្រិតបុគ្គល(ការអភិវឌ្ឍជំនាញ) និងនៅកម្រិតស្ថាប័ន(និយមន័យស្តង់ ដារដែលអាច អនុវត្តបានគោលការណ៍ និងនីតិវិធីការស្រាវជ្រាវនិងការអភិវឌ្ឍ)។

# មេរៀនទី ៤ ការគ្រប់គ្រងហិរញ្ញប្បទានអាកាសធាតុ

## ១. កម្មវិធីហិរញ្ញប្បទានអាកាសធាតុថ្នាក់ជាតិ

### ១.១ ការបង្កើតក្របខ័ណ្ឌហិរញ្ញប្បទានប្រែប្រួលអាកាសធាតុ

ការផ្តល់ហិរញ្ញប្បទានសម្រាប់ ផ.យ.ប.អ.ក. នឹងប្រព្រឹត្តិទៅ តាមរយៈការប្រើប្រាស់នូវគំរូផ្តល់មូលនិធិផ្សេងៗគ្នាមួយចំនួន ដោយក្នុងនោះរួមមាន វិធីសាស្ត្រដែលធ្លាប់អនុវត្តកន្លងមក និងវិធីសាស្ត្រថ្មីៗដែលទាក់ទង នឹងហិរញ្ញប្បទានអាកាសធាតុ។ ដូច្នេះចាំបាច់ត្រូវជានាឱ្យមានការសម្របសម្រួលនូវគំរូហិរញ្ញប្បទានខុសៗគ្នាទាំង នេះ ដើម្បីឱ្យដៃគូដែលមានសក្តានុពលក្នុងការផ្តល់មូលនិធិ អាចយល់បានច្បាស់លាស់អំពីថ្លៃចំណាយ និងការចាត់ ជាអាទិភាពនូវសកម្មភាពនានានៅក្រោម **ផ.យ.ប.អ.ក.**។ គណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុ និងក្រុមបច្ចេកទេសការងារប្រែប្រួលអាកាសធាតុ ត្រូវដឹកនាំការបង្កើតក្របខ័ណ្ឌហិរញ្ញប្បទានប្រែប្រួលអាកាសធាតុ ដែលនឹងគាំទ្រដល់របៀបអនុវត្ត ជាកម្មវិធីសម្រាប់ការឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុនៅកម្ពុជា។

### ១.២ ការបង្កើតក្របខ័ណ្ឌពិនិត្យ តាមដាន និងវាយតម្លៃ

ក្របខ័ណ្ឌជាតិមួយសម្រាប់ (Monitoring and Evaluation or M&E) កំពុងស្ថិតក្នុងការរៀបចំហើយ រំពឹងថានឹងត្រូវរៀបចំរួចស្រេច នៅពាក់កណ្តាលឆ្នាំ២០១៤។ ក្របខ័ណ្ឌនេះត្រូវមានភាពស៊ីសង្វាក់គ្នា និងត្រូវដាក់បញ្ចូលជាមួយប្រព័ន្ធ M&E របស់ជាតិ។ សេចក្តីពិស្តារបន្ថែមអំពីក្របខ័ណ្ឌ M&E សម្រាប់ផែនការយុទ្ធសាស្ត្រនេះ មានបង្ហាញនៅក្នុងផ្នែកទី៨ ខាងក្រោម។

### ១.៣ ការបង្កើតក្របខ័ណ្ឌច្បាប់ស្តីពីការប្រែប្រួលអាកាសធាតុ

ក្របខ័ណ្ឌច្បាប់ចាំបាច់មានសារៈសំខាន់ក្នុងការគាំទ្រដល់ការអនុវត្ត **ផ.យ.ប.អ.ក** តាមរយៈការបញ្ជ្រាប បញ្ហាប្រែប្រួលអាកាសធាតុទៅក្នុងគោលនយោបាយពាក់ព័ន្ធ និងច្បាប់សំខាន់ៗ។ ប្រការនេះនឹងជួយពង្រឹង និង គោរពតាមអនុសាសន៍គោលនយោបាយសំខាន់ៗ ពាក់ព័ន្ធនឹងការឆ្លើយតបនឹងបញ្ហាប្រែប្រួលអាកាសធាតុ។

#### ១.៣.១ ការបង្កើតកម្មវិធី និងការកសាងផែនការសកម្មភាព

ការអនុវត្ត **ផ.យ.ប.អ.ក.** ទាមទារនូវអភិក្រមផ្អែកលើកម្មវិធី ដើម្បីជានាឱ្យមានការសម្របសម្រួលជាយុទ្ធសាស្ត្រ និងការចាត់អាទិភាពនូវសកម្មភាពនានា។ ក្រៅពីការរៀបចំកម្មវិធីដោយផ្អែកលើហានិភ័យគួរលើកទឹក ចិត្តឱ្យមានសកម្មភាពនានា ដែលជំរុញ ឬគាំទ្រដល់ការពង្រឹងបន្ថែមនូវកាលានុវត្តភាពនានា ក៏

ដូចជាការពង្រីក អត្ថប្រយោជន៍ និងផលចំណេញបន្ថែមសម្រាប់សង្គម និងប្រព័ន្ធនានា។ សេចក្តីពិស្តារនៃផែនការសកម្មភាពមាន ចែងនៅក្នុងឯកសារដាច់ដោយឡែក ទៅតាមការកំណត់របស់ទីស្តីការគណៈរដ្ឋមន្ត្រី។ គោលការណ៍ដូចខាងក្រោម នេះនឹងត្រូវយកមកអនុវត្តនៅក្នុងការបង្កើតកម្មវិធី ដែលនឹងត្រូវផ្អែកលើផែនការសកម្មភាពតាមវិស័យ។

### ក. រយៈពេល

**ផ.យ.ប.អ.ក.** ត្រូវបានរៀបចំឡើងសម្រាប់រយៈពេល១០ ឆ្នាំ (២០១៤-២០២៣) ដោយមានកំណត់កាល បរិច្ឆេទសម្រាប់ការពិនិត្យកែសម្រួលនៅឆ្នាំ២០១៨។ ផែនការសកម្មភាពតាមវិស័យ (និងកម្មវិធីរួមដែលស៊ីគ្នានេះ) នឹងត្រូវរៀបចំឡើងសម្រាប់ដំណាក់កាលដំបូង ដែលមានរយៈពេល៥ ឆ្នាំ (២០១៤-២០១៨) ពោលគឺស្របគ្នា ជាមួយវដ្តនៃការកសាងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (២០១៤-២០១៨)។ ផែនការសកម្មភាពនឹងប្រើប្រាស់ វិធីសាស្ត្រសមស្របសម្រាប់ការចាត់អាទិភាព និងការកំណត់ពេលវេលា ដែលក្នុងនោះរួមមាន ការវិភាគ និងការ បង្កើតផែនទីភាពងាយរងគ្រោះ និងការវិភាគថ្លៃចំណាយ-ផលចំណេញ។

### ខ. ការពង្រឹងបន្ថែមលើយុទ្ធសាស្ត្ររបស់ក្រសួង ស្ថាប័នពាក់ព័ន្ធនានា

ផែនការសកម្មភាពឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ របស់ក្រសួង ស្ថាប័នពាក់ព័ន្ធ ដែលរួមបញ្ចូលទៅ ក្នុងកម្មវិធីរបស់ **ផ.យ.ប.អ.ក.** នឹងមិនរៀបចំឡើងជាឯកសារដាច់ដោយឡែក នៅក្នុងក្រសួងស្ថាប័ននីមួយៗ ឡើយ។ ជាការពិត សកម្មភាពថ្មីមួយចំនួន ដែលផ្តោតលើការប្រែប្រួលអាកាសធាតុ នឹងត្រូវស្នើឡើង ប៉ុន្តែសកម្មភាពភាគ ច្រើននឹងពាក់ព័ន្ធដោយផ្ទាល់ជាមួយបញ្ជីគម្រោងវិនិយោគសាធារណៈ ដែលមានស្រាប់នៅក្នុងក្រសួង ស្ថាប័ន។ ក្នុងគ្រប់ករណីទាំងអស់ ផែនការសកម្មភាពដែលស្នើឡើង នឹងត្រូវរួមបញ្ចូលនៅក្នុងការចាត់ចែងកសាងផែនការនិងការគ្រប់គ្រងជាលក្ខណៈស្តង់ដាររបស់ក្រសួង ស្ថាប័នពាក់ព័ន្ធ។ ប្រការនេះរួមមានទាំងការគិតគូរពិចារណាអំពី សកម្មភាពនានា ដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុ នៅក្នុងដំណើរការលើកថវិកា និងការបង្កើតសូចនាករ ដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុ នៅក្នុងក្របខ័ណ្ឌ M&E តាមវិស័យ។

### គ. បញ្ហាអន្តរវិស័យ

ការបង្កើតកម្មវិធីនៅក្រោម **ផ.យ.ប.អ.ក.**ក៏ផ្តោតផងដែរលើបញ្ហាទូទៅ ដែលពាក់ព័ន្ធជាមួយបញ្ហា អន្តរវិស័យ ដូចជាយេនឌ័រ កិច្ចគាំពារសង្គម ការស្រាវជ្រាវ ការលើកកម្ពស់ការយល់ដឹង ការប្រាស្រ័យទាក់ទង M&E ហិរញ្ញប្បទានអាកាសធាតុ និងការគ្រប់គ្រងចំណេះដឹង។

### ឃ. ការបង្កើតកម្មវិធីចម្រុះ

ដោយសារការប្រែប្រួលអាកាសធាតុទាក់ទងនឹងវិស័យជាច្រើន ការបង្កើតកម្មវិធីចម្រុះមានសារៈសំខាន់ណាស់ ក្នុងការទាញយកប្រយោជន៍ពីវិធីសាស្ត្រនានា ដែលមានលក្ខណៈពហុជំនាញ អន្តរវិស័យ មានអ្នកពាក់ព័ន្ធចម្រុះ និងពហុទិដ្ឋភាព នៅក្នុងសកម្មភាពឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ។ ក្រសួង ស្ថាប័នពាក់ព័ន្ធទាំងអស់ គួរតែគិតគូរពិចារណាអំពីចំណងទាក់ទងជាមួយវិស័យដទៃទៀត នៅពេលកសាងផែនការសកម្មភាពរបស់ខ្លួន ហើយលេខាធិការដ្ឋាននៃ **គ.ជ.គ.ប.អ**. នឹងផ្តល់ការគាំទ្រ ដើម្បីពិនិត្យមើលចំណងទាក់ទងទាំងនេះ។

### ង. ភាពជាដៃគូ

ប្រការសំខាន់គឺត្រូវទទួលស្គាល់ថា ដៃគូអភិវឌ្ឍន៍ អង្គការមិនមែនរដ្ឋាភិបាល (ទាំងជាតិ និងអន្តរជាតិ) វិស័យឯកជន សហគមន៍មូលដ្ឋាន និងអង្គការដទៃទៀត គឺជាអ្នកដើរតួយ៉ាងសំខាន់នៅក្នុងការអនុវត្តសកម្មភាព ប្រែប្រួលអាកាសធាតុនៅថ្នាក់មូលដ្ឋាន ក៏ដូចជាក្នុងការស្រាវជ្រាវអភិវឌ្ឍន៍ និងការរៀនសូត្រ ដែលពាក់ព័ន្ធជាមួយ ការប្រែប្រួលអាកាសធាតុ។ ពិតមែនតែផែនការយុទ្ធសាស្ត្រនេះជាឯកសាររបស់រាជរដ្ឋាភិបាល ដែលផ្តោតលើការប្រើ ប្រាស់ធនធានសាធារណៈក្តី ក៏ប្រការសំខាន់គឺថាធនធានទាំងនេះនឹងត្រូវប្រើប្រាស់ជាកាតាលីករសម្រាប់ពង្រីក សកម្មភាព និងវិធានការនានាឱ្យកាន់តែធំទូលាយថែមទៀត ពីសំណាក់អ្នកពាក់ព័ន្ធដទៃទៀត ដើម្បីឆ្លើយតបនឹង ការប្រែប្រួលអាកាសធាតុ។ ក្នុងន័យនេះ គួរលើកទឹកចិត្តឱ្យស្ថាប័នរាជរដ្ឋាភិបាលទាក់ទាញដៃគូពាក់ព័ន្ធនានា ឱ្យមកចូលរួមនៅក្នុងការកសាងផែនការកម្មភាព និងកំណត់ភាពជាដៃគូនៅក្នុងការអនុវត្តផែនការសកម្មភាពរបស់ខ្លួន។

# ២. ការផ្តល់ធនធានហិរញ្ញវត្ថុ និងមូលនិធិអាកាសធាតុថ្នាក់ជាតិ

## ២.១ គោលការណ៍នានា

**ផ.យ.ប.អ.ក.** រួមជាមួយផែនការសកម្មភាពពាក់ព័ន្ធនានា នឹងផ្តល់ជាក្របខ័ណ្ឌយុទ្ធសាស្ត្រមួយសម្រាប់ ការបង្កើតកម្មវិធីអន្តរាគមន៍លើបញ្ហាប្រែប្រួលអាកាសធាតុនៅកម្ពុជា។ យន្តការហិរញ្ញប្បទានប្រែប្រួលអាកាសធាតុ របស់ជាតិត្រូវគាំទ្រវិធីសាស្ត្រជាយុទ្ធសាស្ត្រនេះ តាមរយៈការអនុវត្តគោលការណ៍នានាដូចតទៅ ៖

- **ការបន្សុីគ្នាជាមួយអាទិភាពជាតិ ៖** ការប្រើប្រាស់ធនធានហិរញ្ញវត្ថុ ត្រូវតែឆ្លើយតបទៅនឹងអាទិភាពរបស់ ជាតិ តាមរយៈការផ្តល់មូលនិធិសម្រាប់កម្មវិធី និងគម្រោងនានា ដែលមានចែងនៅក្នុងផែនការសកម្មភាព នៅក្រោម **ផ.យ.ប.អ.ក.**។ រាល់សំណើហិរញ្ញប្បទានប្រែប្រួលអាកាសធាតុ ត្រូវតែដាក់ជូនគណៈកម្មាធិការ ជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុពិនិត្យ និងសម្រេច។
- **ការប្រមូលផ្តុំធនធាន៖** ដើម្បីកាត់បន្ថយថ្លៃចំណាយប្រតិបត្តិការ និងនៅក្នុងករណីដែលអាចធ្វើបាន គួរ ផ្តល់ហិរញ្ញវត្ថុប្រែប្រួលអាកាសធាតុតាមរយៈយន្តការផ្តល់មូលនិធិរួមគ្នា។ យន្តការទាំងនេះរួមមានរាល់យន្ត ការប្រមូលផ្តុំធនធានដែលមានស្រាប់នៅក្នុងវិស័យពាក់ព័ន្ធ និងអាចជាមូលនិធិដែលផ្តោតលើការប្រែប្រួល អាកាសធាតុដាច់ដោយឡែក។
- **ការប្រើប្រាស់ប្រព័ន្ធនិង នីតិវិធីរបស់ជាតិ ៖** គំរូដែលរាជរដ្ឋាភិបាលកម្ពុជាចង់បានសម្រាប់ការផ្តល់ហិរញ្ញប្បទានការប្រែប្រួលអាកាសធាតុ នៅក្នុងរយៈពេលមធ្យម ទៅរយៈពេលវែង គឺការគាំទ្រថវិកាដោយ ផ្ទាល់។ ទោះជាយ៉ាងណាក៏ដោយ ការប្រែប្រួលអាកាសធាតុ គឺជាកិច្ចការថ្មីមួយ ដែលចាំបាច់ត្រូវមាន អន្តរកាល ដើម្បីដាក់ឱ្យអនុវត្តប្រព័ន្ធពិនិត្យតាមដានវាយតម្លៃ និងកត់ត្រាហិរញ្ញវត្ថុ ដើម្បីអាចឱ្យគេវាយ តម្លៃអំពីផលប៉ះពាល់ និងប្រសិទ្ធភាពនៃការគាំទ្រថវិកាសម្រាប់ការងារប្រែប្រួលអាកាសធាតុ។ មូលនិធិ ជាតិប្រែប្រួលអាកាសធាតុមួយអាចនឹងត្រូវបង្កើតឡើង ដើម្បីទទួលការគាំទ្រហិរញ្ញវត្ថុពីក្នុង និងក ប្រទេស ហើយវិភាជន៍មូលនិធិនេះទៅគម្រោងប្រែប្រួលអាកាសធាតុដែលមានអាទិភាពខ្ពស់។
- **ការផ្ទេរអំណាចទៅថ្នាក់ក្រោម ៖** ទោះបីការប្រែប្រួលអាកាសធាតុ ត្រូវការសម្របសម្រួលពី **គ.ជ.គ.ប.អ.** ដើម្បីបន្សុីជាមួយអាទិភាពនានារបស់ជាតិក៏ដោយ យន្តការហិរញ្ញប្បទានត្រូវតែធានាថា ធនធានថវិកាត្រូវ ស្ថិតនៅក្រោមការចាត់ចែងរបស់ក្រសួងពាក់ព័ន្ធ និងរដ្ឋបាលមូលដ្ឋានដែលពាក់ព័ន្ធ។ លេខាធិការដ្ឋាននៃ **គ.ជ.គ.ប.អ.** ត្រូវដើរតួជាស្ថាប័នអនុវត្តសម្រាប់តែគម្រោងយុទ្ធសាស្ត្រ ឬដែលមានលក្ខណៈអន្តរវិស័យ ដែលមិនស្ថិតនៅក្រោមអាណត្តិរបស់ក្រសួងស្ថាប័នពាក់ព័ន្ធណាមួយផ្សេង ឬរដ្ឋបាលថ្នាក់ក្រោមជាតិឡើយ។

## ២.២ វិធីសាស្ត្រ

ការបង្កើតក្របខ័ណ្ឌហិរញ្ញប្បទានប្រែប្រួលអាកាសធាតុសម្រាប់កម្ពុជា ត្រូវប្រព្រឹត្តទៅតាមរយៈជំហានមួយ ចំនួន។ ការពិនិត្យការចំណាយសាធារណៈ និងស្ថាប័នលើការងារអាកាសធាតុ (Climate Public Expenditure and Institutional Review or CPEIR) បានធ្វើឡើងនៅឆ្នាំ២០១២ និងបានផ្តល់ព័ត៌មានដំបូងអំពីស្ថានភាព បច្ចុប្បន្ននៃការចំណាយសម្រាប់ការងារប្រែប្រួលអាកាសធាតុនៅកម្ពុជា និងការប្រឈមនានាខាងសមត្ថភាព ដែល ពាក់ព័ន្ធ។

របាយការណ៍ CPEIR បានប៉ាន់ស្មានថា នៅក្នុងអំឡុងឆ្នាំ២០០៩-២០១១ ការចំណាយសាធារណៈ ជាមធ្យម១៥,៨% មានការពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុ។ នេះជាកម្រិតខ្ពស់បង្គួរមួយ ធៀបនឹងប្រទេស ដទៃទៀតក្នុងតំបន់ ហិរញ្ញប្បទានអាកាសធាតុ គួរតែផ្តោតមិនត្រឹមតែលើការទាក់ទាញធនធានថ្មីៗប៉ុណ្ណោះទ ប៉ុន្តែក៏ត្រូវផ្តោតផងដែរលើការកែលម្អភាពផ្តល់ផល និងប្រសិទ្ធភាពនៃការចំណាយជាច្រើនរួចមកហើយ ដែល ទាក់ទងជាមួយការប្រែប្រួលអាកាសធាតុ។ មូលនិធិដែលមានស្រាប់ទាំងនេះមិនសុទ្ធតែបានសម្របសម្រួលល្អនោះទ ដោយសារមូលនិធិភាគច្រើនបានមកតាមរយៈគម្រោងក្នុងវិស័យដាក់លាក់ (៦០% ហើយអន្តរាគមន៍នៃគម្រោង ទាំងនោះពុំបានទទួលការវាយតម្លៃជាលក្ខណៈប្រព័ន្ធដោយផ្អែកលើទស្សនទាននៃការប្រែប្រួលអាកាសធាតុឡើយ។ ការផ្តល់មូលនិធិលើការងារប្រែប្រួលអាកាសធាតុ ដែលបានមកពីម្ចាស់ជំនួយទ្វេភាគី ពហុភាគី ឬតាមរយៈមូលនិធិ អាកាសធាតុពិភពលោក មានត្រឹមតែ៤០%នៃតួលេខសរុបប៉ុណ្ណោះ។ នៅក្នុងបណ្តាឆ្នាំខាងមុខនេះ មានការរំពឹង ថា ភាគចំណែកនៃហិរញ្ញប្បទានដែលផ្តោតលើការងារប្រែប្រួលអាកាសធាតុ នឹងកើនឡើងថែមទៀត។ នេះជា ឱកាសមួយសម្រាប់កម្ពុជា ដោយហេតុថា ជាគោលការណ៍ មូលនិធិទាំងនេះអាចត្រូវបានវិភាជន៍សម្រាប់វិស័យ និង កម្មវិធីអាទិភាព ដូចមានចែងនៅក្នុង **ផ.យ.ប.អ.ក.**។ គម្រោងខ្លះនឹងបន្តទទួលមូលនិធិ តាមរយៈរបៀបដូចធ្លាប់ អនុវត្តពីមុនមក ប៉ុន្តែយន្តការប្រមូលផ្តុំអាចដាក់ឱ្យអនុវត្ត ដើម្បីផ្តល់មូលនិធិសម្រាប់គម្រោងដែលមានការពាក់ព័ន្ធ ខ្លាំង (រួមទាំងការអភិវឌ្ឍសមត្ថភាពស្ថាប័នលើការប្រែប្រួលអាកាសធាតុផងដែរ ការបំពេញបន្ថែមលើគម្រោងកំពុងដំណើរការដែលទាមទារឱ្យមានលក្ខខណ្ឌនៃភាពធន់នឹងអាកាសធាតុ និងបន្តអនុវត្តសាកល្បងវិធីសាស្ត្របែប ច្នៃប្រឌិតមួយចំនួននៅក្នុងការបន្សាំ និងការកាត់បន្ថយការប្រែប្រួលអាកាសធាតុ។

បច្ចុប្បន្ន ការចំណាយសាធារណៈតាមរយៈរដ្ឋបាលនៅថ្នាក់ក្រោមជាតិនៅតែមានចំនួនតិចតួចនៅឡើយ (៥ទៅ៦% នៃការចំណាយសរុបរបស់រដ្ឋ) ប៉ុន្តែមានសារៈសំខាន់ណាស់សម្រាប់កិច្ចផ្តួចផ្តើមបន្សាំនឹងការប្រែប្រួល អាកាសធាតុ ដែលទាមទារឱ្យផ្តល់ការគាំទ្រ ដើម្បីមានភាពធន់នឹងអាកាសធាតុប្រសើរជាងមុននៅកម្រិតសហគមន៍។យន្តការហិរញ្ញប្បទានទៅអនាគត គួរតែរួមបញ្ចូលនីតិវិធី និងបរិធានសមស្រប ដើម្បីបញ្ជ្រាបការប្រែប្រួលអាកាសធាតុ នៅក្នុងការកសាងផែនការ និងថវិកានៅថ្នាក់ក្រោមជាតិ។

ប្រការសំខាន់ គឺត្រូវធ្វើការពិនិត្យតាមដានទៀងទាត់អំពីការវិវត្តនៃការចំណាយលើការប្រែប្រួលអាកាសធាតុ និងការគាំទ្ររបស់ការចំណាយទាំងនោះលើអាទិភាពនៅក្នុង **ផ.យ.ប.អ.ក.** និង **ផ.យ.អ.ជ.** ក៏

ដូចជាភាពផ្តល់ផល និងប្រសិទ្ធភាពនៃការចំណាយទាំងនោះផងដែរ។ ត្រូវឱ្យមានការពិនិត្យជាទៀងទាត់ដើម្បីធ្វើបច្ចុប្បន្នភាពព័ត៌មាន នៅក្នុងរបាយការណ៍ CPEIR ហើយយន្តការនានាដើម្បីបញ្ជ្រាបការប្រែប្រួលអាកាសធាតុទៅក្នុងដំណើរការថវិកា ជាតិ ក៏នឹងត្រូវបង្កើតឡើងផងដែរ។

នៅឆ្នាំ២០១៤ សកម្មភាពនានាដូចខាងក្រោមនេះ នឹងត្រូវអនុវត្ត ដើម្បីដាក់ឱ្យប្រើប្រាស់ក្របខ័ណ្ឌហិរញ្ញប្បទានប្រែប្រួលអាកាសធាតុ ដែលមានភាពទាក់ទាញ និងប្រសិទ្ធភាពសម្រាប់កម្ពុជា ៖

- ការវិភាគឱកាសសម្រាប់កៀរគរធនធាន (ក្នុង និងក្រៅស្រុក) ទាំងនៅថ្នាក់ជាតិ និងក្នុងវិស័យអាទិភាព។
- ការកំណត់ថវិកា សម្រាប់អនុវត្ត ផ.យ.ប.អ.ក. និង ផ.យ.ប.អ. តាមវិស័យ ដោយមានការចាត់អាទិភាព សម្រាប់គម្រោង ដែលមានការពាក់ព័ន្ធកម្រិតខ្ពស់។
- ការកំណត់ថ្លៃខូចខាតពីផលប៉ះពាល់សេដ្ឋកិច្ច-សង្គមនៃការមិនធ្វើសកម្មភាព និងផលចំណេញសុទ្ធ ពីការ ឆ្លើយតប ក្រោមសេណារីយ៉ូផ្សេងៗ ដើម្បីផ្តល់ជាមូលដ្ឋានសម្រាប់កំណាត់អាទិភាពចំណាយក្នុងវិស័យ ឬ វិស័យរងនីមួយៗ។
- ការវិភាគទម្លាប់ប្រតិបត្តិល្អរបស់ជាតិ និងអន្តរជាតិ ដែលពាក់ព័ន្ធនៅក្នុងការចាត់ចែងគ្រប់គ្រងមូលនិធិ ប្រមូលផ្តុំ និងអនុសាសន៍អំពីរចនាសម្ព័ន្ធដែលបានស្នើឡើង សម្រាប់យន្តការហិរញ្ញវត្ថុអាកាសធាតុនៅថ្នាក់ ជាតិ និងថ្នាក់ក្រោមជាតិ។
- ការវិភាគភាពខ្វះចន្លោះនៃសមត្ថភាព និងអនុសាសន៍ ដើម្បីអភិវឌ្ឍសមត្ថភាពនៅថ្នាក់ជាតិ និងថ្នាក់ក្រោម ជាតិ សំដៅគ្រប់គ្រងយន្តការហិរញ្ញវត្ថុប្រែប្រួលអាកាសធាតុដែលបានស្នើឡើង។ ការវិភាគនេះក៏ត្រូវមាន អនុសាសន៍សម្រាប់ការងារបន្ថែម ដើម្បីពិនិត្យលទ្ធភាពក្នុងការកៀរគរហិរញ្ញវត្ថុ ពីវិស័យឯកជនផងដែរ សម្រាប់សកម្មភាពបន្សាំ និងកាត់បន្ថយការបញ្ចេញឧស្ម័ន។

សកម្មភាពទាំងនេះនឹងនាំទៅរកការបង្កើតក្របខ័ណ្ឌកម្មវិធីមួយ ដែលផ្អែកលើផែនការសកម្មភាពនៅក្នុងវិស័យជាអាទិភាព និងបន្សុីគ្នាជាមួយ **ផ.យ.អ.ជ.** ២០១៤-២០១៨។

## ២.៣ ការគ្រប់គ្រង និងរចនាសម្ព័ន្ធស្ថាប័នសម្រាប់ការអនុវត្ត

អនុក្រុមហិរញ្ញវត្ថុអាកាសធាតុ នៃក្រុមបច្ចេកទេសការងារប្រែប្រួលអាកាសធាតុ មានសមាសភាពមកពី ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងបរិស្ថាន ក្រសួងផែនការ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (គណៈកម្មាធិការស្តារ និងអភិវឌ្ឍន៍កម្ពុជា) និងលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។ - អនុក្រុមនេះត្រូវដឹកនាំការបង្កើតក្របខ័ណ្ឌហិរញ្ញប្បទានប្រែប្រួលអាកាសធាតុរបស់ជាតិ ដើម្បី ដាក់ជូនទៅ **គ.ជ.គ.ប.អ.** នៅឆ្នាំ២០១៤។

នៅខណៈដែលពុំទាន់បានកំណត់យន្តការហិរញ្ញប្បទានជាក់លាក់ ជាការចាំបាច់ត្រូវសម្របសម្រួល និង បសុីគ្នាជាមួយ **ផ.យ.ប.អ.ក.** នូវហិរញ្ញវត្ថុក្នុងស្រុក និងប្រភពហិរញ្ញវត្ថុអាកាសធាតុក្រៅស្រុក

ចម្បងៗ ចំនួន៣ (មូលនិធិអាកាសធាតុពិភពលោក មូលនិធិអាកាសធាតុទ្វេភាគី និងគម្រោងតាមវិស័យ ដែលបានដាក់បញ្ចូល សកម្មភាពប្រែប្រួលអាកាសធាតុ) ការសម្របសម្រួលរវាងគម្រោង "ពីថ្នាក់លើ និង យន្តការមូលនិធិប្រមូលផ្តុំ ក៏ជាតម្រូវការចាំបាច់ផងដែរ។

អនុលោមតាមគោលនយោបាយរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា គណៈកម្មាធិការស្តារ និងអភិវឌ្ឍន៍កម្ពុជា) រាជរដ្ឋាភិបាលចង់ឱ្យប្រើ អភិក្រមផ្អែកលើកម្មវិធី (Programme-based approach or PBA) ដើម្បី គ្រប់គ្រងគំរូខុសៗគ្នាទាំងនេះ។ **គ.ជ.គ.ប.អ.** នឹងដាក់ឱ្យប្រើប្រាស់រចនាសម្ព័ន្ធសមស្រប ដើម្បី គ្រប់គ្រងអភិក្រម ផ្អែកលើកម្មវិធី សម្រាប់ការងារប្រែប្រួលអាកាសធាតុ ដែលរួមទាំងរចនាសម្ព័ន្ធមួយ សម្រាប់ការពិភាក្សា និងការ សម្របសម្រួលជាមួយម្ចាស់ជំនួយផងដែរ។ អភិក្រមផ្អែកលើកម្មវិធីនេះនឹង ជួយសម្រួលការអនុវត្តគំរូហិរញ្ញប្បទាន ផ្សេងៗគ្នា ហើយវាផ្តល់ចំណុចចាប់ផ្តើម និងក្របខ័ណ្ឌឯកភាព មួយ សម្រាប់ការងារកសាងផែនការ និងប្រព័ន្ធ M&E សម្រាប់អន្តរាគមន៍នានា ទាក់ទងនឹងការប្រែប្រួល អាកាសធាតុនៅកម្ពុជា។ លេខាធិការដ្ឋាននៃ **គ.ជ.គ.ប.អ.** ត្រូវដើរ តួជាលេខាធិការដ្ឋានសម្រាប់អនុវត្តអភិក្រមផ្អែកលើកម្មវិធីនេះ។ ការបង្កើតយន្តការទាំងនេះទាមទារឱ្យមាន ការរៀបចំផែនការអភិវឌ្ឍន៍សមត្ថភាព ប្រកបដោយការសម្របសម្រួលរវាងគ្នា។

## ៣. ការតាមដាន និងវាយតម្លៃ

ផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុមកលើប្រព័ន្ធអេកូឡូស៊ី និងសង្គម មានលក្ខណៈស្មុគស្មាញ។ ការដោះស្រាយបញ្ហាទាំងនេះតាមរយៈការបន្សាំ ទាមទារឱ្យមានវិធានការបន្សាំប្រកបដោយការ សម្របសម្រួលរវាង វិស័យជាច្រើន និងតាមមាត្រដ្ឋានខុសៗគ្នា។ ការបង្កើតលំនាំអភិវឌ្ឍន៍ដែលបញ្ចេញកាបូនតិច និងការរួមចំណែក ក្នុងកិច្ចប្រឹងប្រែងកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ ទាមទារបច្ចេកវិទ្យាថ្មីៗ និងគោលនយោបាយអន្តរវិស័យ។ ដោយសារភាពស្មុគស្មាញនៃសកម្មភាពទាំងនេះ និងបញ្ហាបច្ចេកទេស ដែលពាក់ព័ន្ធនឹងការវាយតម្លៃប្រសិទ្ធភាព និងផលប៉ះពាល់នានា នោះការពិនិត្យតាមដាននិងវាយតម្លៃលើ ការកាត់បន្ថយការបញ្ចេញឧស្ម័ន និងបន្សាំនឹង ការប្រែប្រួលអាកាសធាតុ គឺជាការប្រឈមថ្មីមួយ។ **ផ.យ.ប.អ.ក.** ទទួលស្គាល់ពីសារៈសំខាន់នៃការដោះស្រាយ បញ្ហាប្រឈមទាំងនេះ តាមរយៈការបង្កើតក្របខ័ណ្ឌជាតិមួយសម្រាប់ M&E លើការងារប្រែប្រួលអាកាសធាតុ ដោយមានចក្ខុវិស័យក្នុងការរួមបញ្ចូលក្របខ័ណ្ឌនេះ ទៅក្នុងដំណើរការកសាងផែនការអភិវឌ្ឍន៍នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ការកសាង និងបញ្ជ្រាបក្របខ័ណ្ឌ M&E គឺជាកិច្ចប្រឹងប្រែងរយៈពេលវែងមួយ ដែលមានសារៈ សំខាន់ជាយុទ្ធសាស្ត្រ ពីព្រោះថាវានឹងបង្កើតលក្ខខណ្ឌអំណោយផល ដោយផ្អែកលើគណនេយ្យភាព និងការរៀន សូត្រ គណនេយ្យភាពល្អជាងមុននឹងសម្រួលដល់ការទទួលបានហិរញ្ញវត្ថុអាកាសធាតុអន្តរជាតិថ្មីៗ ហើយការ រៀនសូត្រពីការវិ

និយោគនានានឹងបង្កើតចំណេះដឹងថ្មីៗ ដែលមានសារៈសំខាន់សម្រាប់ការកសាងគោលនយោបាយ ទៅអនាគត។ ក្របខ័ណ្ឌជាតិសម្រាប់ M&E លើការប្រែប្រួលអាកាសធាតុមានបំណង ៖

- វាស់ស្ទង់ថា តើប្រសិទ្ធភាពនៃកិច្ចប្រឹងប្រែងក្នុងការងារបន្សាំនឹងការប្រែប្រួលអាកាសធាតុមានកម្រិតណា ក្នុងការធានាឱ្យការអភិវឌ្ឍស្ថិតក្នុងលំនាំត្រូវ នៅក្នុងលក្ខខណ្ឌអាកាសធាតុដែលប្រែប្រួល។
- ពិនិត្យតាមដានសកម្មភាពកាត់បន្ថយការប្រែប្រួលអាកាសធាតុ និងគោលនយោបាយអភិវឌ្ឍន៍ដែល បញ្ចេញកាបូនតិច។
- ចងក្រងភស្តុតាង និងមេរៀននានា ដើម្បីជាមូលដ្ឋានសម្រាប់ការកសាងគោលនយោបាយទៅអនាគត។
- សម្រួលឱ្យមានសមាហរណកម្មស៊ីសង្វាក់គ្នានៃ M&E លើការប្រែប្រួលអាកាសធាតុនៅក្នុងការកសាងផែន ការអភិវឌ្ឍន៍ជាតិ និងវិស័យសំខាន់ៗ។
- ផ្តល់ព័ត៌មានដែលចាំបាច់ក្នុងការបំពេញកាតព្វកិច្ចធ្វើរបាយការណ៍ក្រោមអនុ សញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ និងដៃគូអភិវឌ្ឍន៍។

### ៣.១ គោលការណ៍នានា

គោលការណ៍នានាដែលអាចពង្រឹងក្របខ័ណ្ឌនេះ រួមមាន៖

- **ការប្រើប្រាស់ប្រព័ន្ធ និងនីតិវិធីរបស់ជាតិ ៖** ក្របខ័ណ្ឌនេះនឹងរួមបញ្ចូលជាមួយប្រព័ន្ធ M&E របស់ជាតិ។ សូចនាករ និងនីតិវិធីពិនិត្យតាមដាន ត្រូវពឹងផ្អែកឱ្យបានច្រើនបំផុតលើទិន្នន័យ ដែលបច្ចុប្បន្ននេះស្ថិត ក្រោមការពិនិត្យតាមដានដោយក្រសួងពាក់ព័ន្ធ។ សូចនាករ និងនីតិវិធីទាំងនេះត្រូវតែមានសង្គតិភាពជា មួយគោលការណ៍ណែនាំរបស់ក្រសួងផែនការ អំពីប្រព័ន្ធ M&E របស់ជាតិផងដែរ។ ក្របខ័ណ្ឌនេះនឹងចាត់ ជាប្រព័ន្ធ និងពង្រឹងបន្ថែមលើកិច្ចផ្តួចផ្តើម ដែលកំពុងអនុវត្តសម្រាប់ការពិនិត្យតាមដាន និងរាយការណ៍ អំពីការបញ្ចេញឧស្ម័នផ្ទះកញ្ចក់។
- **ការបញ្ជ្រាប M&E ការប្រែប្រួលអាកាសធាតុទៅក្នុងផែនការអភិវឌ្ឍន៍នៅថ្នាក់ជាតិ ថ្នាក់វិស័យ និងថ្នាក់ក្រោមជាតិ ៖** ការប្រែប្រួលអាកាសធាតុអាចធ្វើឱ្យខូចខាតសមិទ្ធិផលនៃចំណុចដៅអភិវឌ្ឍន៍ដែលមានចែងនៅក្នុង ផ.យ.អ.ជ. និងយុទ្ធសាស្ត្រអភិវឌ្ឍន៍តាមវិស័យ។ នីតិវិធី និងសូចនាករនានាសម្រាប់តាមដានវិធានការឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ ត្រូវរួមបញ្ចូលទៅក្នុងប្រព័ន្ធ M&E របស់ជាតិ និងត្រូវប្រើជាឯកសារយោង សម្រាប់តាមដានប្រសិទ្ធភាពនៃយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ តាមវិស័យ និងផែនការសកម្មភាពនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។
- **ការពង្រឹងគណនេយ្យភាព សមធម៌ និងតម្លាភាព ៖** ក្របខ័ណ្ឌនេះនឹងផ្តល់ជាវិធីមួយ សម្រាប់វាស់ប្រសិទ្ធភាព និងភាពផ្តល់ផលនៃធនធានដែលប្រើប្រាស់ ដើម្បីសម្រេចតាមចំណុចដៅនានា ដូច

មានចែងក្នុងគោល នយោបាយ និងផែនការសកម្មភាព ហើយនឹងកែលម្អគណនេយ្យភាព ចំពោះមុខសាធារណជន ស្ថាប័នរដ្ឋ សង្គមស៊ីវិល និងម្ចាស់ជំនួយអន្តរជាតិ។

- **លើកកម្ពស់ការរៀនសូត្រដោយមានការចូលរួម ៖** ការកសាងគោលនយោបាយឆ្លើយតបទៅនឹងការប្រែប្រួល អាកាសធាតុ គឺជាកិច្ចប្រឹងប្រែងថ្មីមួយនៅកម្ពុជា និងលើពិភពលោក។ ការបង្ហាញភស្តុតាងច្បាស់លាស់ថា គោលនយោបាយ និងវិធានការនានាមានប្រសិទ្ធភាព មានសារៈសំខាន់ណាស់សម្រាប់ជាមូលដ្ឋានក្នុងការ កសាងគោលនយោបាយទៅអនាគត។ ដូច្នេះក្របខ័ណ្ឌនេះនឹងផ្តោតលើការបង្កើតចំណេះដឹង តាមរយៈ វិធីសាស្ត្រដែលមានការចូលរួម ហើយគាំទ្រដល់ការកំណត់រក និងចែករំលែកចំណេះដឹង។
- **ដំណោះស្រាយបញ្ហាយេនឌ័រ ៖** ស្ត្រី និងក្រុមអ្នកទន់ខ្សោយ ច្រើនតែស្ថិតក្នុងចំណោមអ្នកដែលរងឥទ្ធិពល ធ្ងន់ធ្ងរពីការប្រែប្រួលអាកាសធាតុ។ ក្របខ័ណ្ឌនេះនឹងដោះស្រាយបញ្ហាសមធម៌យេនឌ័រ ការប្រតិបត្តិដែល គិតគូរអំពីយេនឌ័រ នៅក្នុងការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ និងការបញ្ជ្រាបយេនឌ័រនៅក្នុងវិធាន ការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ។

## ៣.២. វិធីសាស្ត្រ

ក្របខ័ណ្ឌអាកាសធាតុរបស់ជាតិសម្រាប់ M&E លើវិធានការឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ នឹងត្រូវរៀបចំឡើង ដោយយោងទៅទម្លាប់ប្រតិបត្តិល្អអន្តរជាតិ។ ឯកសារគោលគំនិតមួយនឹងត្រូវរៀបចំឡើង ដើម្បី គណនា និងកៀគរធនធានចាំបាច់ សម្រាប់រៀបចំក្របខ័ណ្ឌនេះឱ្យបានឆាប់រហ័ស។ ក្របខ័ណ្ឌនេះនឹងត្រូវរៀបចំ រួចរាល់នៅឆ្នាំ២០១៤ ហើយមានរៀបរាប់អំពី ៖ ទ្រឹស្តីនៃការប្រែប្រួល, ក្របខ័ណ្ឌសូចនាករ ជាមួយស្ថានភាពគោល និងចំណុចដៅសម្រាប់តាមដាន **ផ.យ.ប.អ.ក.** និងផែនការសកម្មភាពដែលពាក់ព័ន្ធ, នីតិវិធីសម្រាប់ការប្រមូល ទិន្នន័យ, គោលការណ៍ណែនាំសម្រាប់វិភាគនិងរាយការណ៍, គោលការណ៍ណែនាំសម្រាប់រួមបញ្ចូលការគ្រប់គ្រង ចំណេះដឹង, ការរៀនសូត្រនិងចែករំលែកលទ្ធផល, គោលការណ៍ណែនាំសម្រាប់រួមបញ្ចូលនៅក្នុងប្រព័ន្ធ M&E របស់ក្រសួង ស្ថាប័នពាក់ព័ន្ធនានា, រចនាសម្ព័ន្ធស្ថាប័នលម្អិត និងយន្តការសម្របសម្រួល។

ក្របខ័ណ្ឌសូចនាករនេះនឹងមាន២ចំណុចសម្រាប់វាស់ស្ទង់វិធានការឆ្លើយតបខាងស្ថាប័នគ្រប់គ្រងការប្រែប្រួល អាកាសធាតុ និងគុណផលនៃការអភិវឌ្ឍនៅក្នុងលក្ខខណ្ឌនៃការប្រែប្រួលអាកាសធាតុ។

- **សូចនាករដើមខ្សែ** ដែលតាមដានប្រសិទ្ធភាពនៃការគ្រប់គ្រងហានិភ័យអាកាសធាតុ ៖ រាប់បញ្ចូលសូចនាករ នានា ដែលទាក់ទងនឹងក្របខ័ណ្ឌស្ថាប័ន ការបញ្ជ្រាបការប្រែប្រួលអាកាសធាតុនៅក្នុងគោលនយោបាយ និងដំណើរការកសាងផែនការ ហិរញ្ញប្បទានអាកាសធាតុ សមត្ថភាពស្ថាប័នសមធម៌ តម្លាភាព និងការ ចូលរួមរបស់អ្នកពាក់ព័ន្ធនានានិងវិស័យឯកជន។

- **សូចនាករចុងខ្សែ** ដែលតាមដានការប្រែប្រួលនៃស្ថានភាពអភិវឌ្ឍន៍ការបញ្ចេញឧស្ម័ន និងភាពងាយរង គ្រោះនៃសហគមន៍ និងប្រព័ន្ធអេកូឡូស៊ីពីការប្រែប្រួលអាកាសធាតុ សូចនាករទាំងនេះត្រូវដាក់បញ្ចូលនូវ ស្ថិតិអភិវឌ្ឍន៍ជាតិ ក៏ដូចជាសូចនាកររួមបញ្ចូលពីវិស័យនានា និងពីគម្រោងបន្សាំនិងកាត់បន្ថយ ដោយឡែក។ លទ្ធផលការងារនឹងត្រូវយកមកវាយតម្លៃស្របជាមួយនិន្នាការអាកាសធាតុ និងព្រឹត្តិការណ៍អាកាសធាតុ មិនប្រក្រតី។
- សូចនាករនានាសម្រាប់ការដាក់បញ្ចូលទៅក្នុង **ផ.យ.អ.ជ.**ក៏ត្រូវតែកំណត់ផងដែរ។ ផែនការមួយនឹងត្រូវ រៀបចំឡើង ដែលចែងអំពីសកម្មភាពនានា ការអភិវឌ្ឍសមត្ថភាព និងការកំណត់ថ្លៃចំណាយសម្រាប់ការអនុវត្ត រយៈពេលវែង និងការបញ្ជ្រាបក្របខ័ណ្ឌនេះនៅក្នុងក្រសួងពាក់ព័ន្ធ។

នៅក្នុងរយៈពេលមធ្យម (២០១៤-២០១៨) ក្របខ័ណ្ឌនេះនឹងត្រូវដាក់ឱ្យក្រសួងពាក់ព័ន្ធ និងគម្រោង នានា យកទៅអនុវត្តនៅតាមវិស័យជាអាទិភាព ដែលការជ្រើសរើសនេះនឹងធ្វើឡើង អាស្រ័យលើសមត្ថភាព និង ធនធានដែលមាន។ ការធ្វើសមាហរណកម្ម M&E នៅក្នុងផែនការថ្នាក់មូលដ្ឋានក៏នឹងត្រូវអនុវត្តសាកល្បងផងដែរ។ ធនធានគ្រប់គ្រាន់នឹងត្រូវផ្តល់នៅក្នុងដំណាក់កាលចាប់ផ្តើម សម្រាប់គម្រោងជ្រើសរើសមួយចំនួន ដើម្បីបំពេញ ការចំណាយបន្ថែមលើសមត្ថភាពបច្ចេកទេសជំនាញក្នុង M&E ការងារប្រែប្រួលអាកាសធាតុ ការប្រមូលទិន្នន័យ គោល ការបង្កើតទ្រឹស្តីអំពីការប្រែប្រួល ការរៀនសូត្រ និងការគ្រប់គ្រងចំណេះដឹង។

នៅក្នុងដំណាក់កាលនេះ បណ្តាញការងារមួយនៃទីតាំងនានាសម្រាប់ការពិនិត្យតាមដានរយៈពេលវែង នឹង ត្រូវបង្កើតឡើង សម្រាប់វាយតម្លៃប្រសិទ្ធភាព និងនិរន្តរភាពនៃវិធានការបន្សាំ និងកាត់បន្ថយការបញ្ចេញឧស្ម័ន ដែលអនុវត្តតាមរយៈគម្រោងសាកល្បង។ ទីតាំងទាំងនោះនឹងត្រូវកំណត់យកនៅក្នុងតំបន់ងាយរងគ្រោះខ្លាំង ដូច ជា ប្រព័ន្ធអេកូឡូស៊ីសំខាន់ៗ និងក្នុងទីតាំងនានា ដែលអន្តរាគមន៍សាកល្បងបានបង្ហាញលទ្ធផលជាទីពេញចិត្ត។ ប្រព័ន្ធនេះនឹងបង្កើតភស្តុតាង ដែលនឹងត្រូវរក្សាទុក នៅក្នុងកម្រងទិន្នន័យជាតិ ស្តីពីវិធាននិងបច្ចេកវិទ្យានានា ដែលនឹងត្រូវគ្រប់គ្រងដោយលេខាធិការដ្ឋាននៃ **គ.ជ.គ.ប.អ.** ក្រោមការសម្របសម្រួលជាមួយក្រសួងពាក់ព័ន្ធ និង ដៃគូអភិវឌ្ឍន៍។

នៅក្នុងរយៈពេលវែង (២០១៩ - ២០២៤) ក្របខ័ណ្ឌនេះនឹងត្រូវកែសម្រួល ដោយផ្អែកលើមេរៀនដែល កើតចេញពីដំណាក់កាលសាកល្បង ហើយត្រូវបញ្ជ្រាបទៅក្នុងក្រសួងពាក់ព័ន្ធ ដែលនៅសេសសល់ និងក្នុងការកសាងផែនការថ្នាក់ក្រោមជាតិ និងនៅតាមមូលដ្ឋាន។

## ៣.៣ ការគ្រប់គ្រង និងរចនាសម្ព័ន្ធស្ថាប័នសម្រាប់ការអនុវត្ត

លេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុ ត្រូវដើរតួជាលេខាធិការដ្ឋាន សម្រាប់សម្របសម្រួលការបង្កើត និងការអនុវត្តក្របខ័ណ្ឌនេះ។ លេខាធិការដ្ឋាននេះក៏មានភារៈទទួលខុសត្រូវលើ ការរៀបចំរបាយការណ៍វឌ្ឍនភាពប្រចាំឆ្នាំសម្រាប់ **ផ.យ.ប.អ.ក.** ក្រោមការ

សម្របសម្រួលជាមួយការពិនិត្យ វឌ្ឍនភាព **ផ.យ.អ.ជ.** ប្រចាំឆ្នាំផងដែរ។ អង្គភាពមួយដែលទទួលខុសត្រូវលើ M&E នឹងត្រូវបង្កើតឡើង នៅក្នុង លេខាធិការដ្ឋាននេះ។ យន្តការសម្របសម្រួលមួយនៅក្នុងក្រសួងផែនការ នឹងត្រូវស្នើឱ្យបង្កើតឡើង សម្រាប់ធ្វើ សមាហរណកម្មក្របខ័ណ្ឌនេះក្នុងប្រព័ន្ធ M&E សម្រាប់ **ផ.យ.អ.ជ.**។

អនុក្រុមមួយ នៃក្រុមបច្ចេកទេសការងារប្រែប្រួលអាកាសធាតុសម្រាប់ M&E នឹងត្រូវបង្កើតឡើង ដើម្បី សម្របសម្រួលការផ្លោះប្តូរទិន្នន័យ និងការបញ្ជ្រាបក្របខ័ណ្ឌនេះនៅក្នុងក្រសួងពាក់ព័ន្ធ ក្រសួងពាក់ព័ន្ធ វិទ្យាស្ថានជាតិស្ថិតិ និងភាគីដទៃទៀត ដែលមានចំណាប់អារម្មណ៍ចូលរួមនៅក្នុងដំណើរការនេះ ត្រូវឯកភាពគ្នាលើ សូចនាករ នីតិវិធី និងការទទួលខុសត្រូវនានាលើការប្រមូលទិន្នន័យ។

ត្រូវសិក្សាអំពីភាពជាដៃគូមួយជាមួយគ្រឹះស្ថានស្រាវជ្រាវ និងគ្រឹះស្ថានសិក្សានានា សម្រាប់គ្រប់គ្រងបណ្តាញការងារនៃទីតាំងទាំងឡាយ សម្រាប់ការពិនិត្យតាមដានរយៈពេលវែង។ រចនាសម្ព័ន្ធនេះក៏អាចយកទៅបើ ប្រាស់ផងដែរ សម្រាប់ការសិក្សាវាយតម្លៃបណ្តោះអាសន្ន អំពីប្រសិទ្ធភាពនៃការងារបន្សាំ និងការកាត់បន្ថយ ការបញ្ចេញឧស្ម័ន ដោយផ្អែកលើទិន្នន័យដែលបណ្តាញនេះប្រមូលបាន។

ជាសេចក្តីសន្និដ្ឋាន រាជរដ្ឋាភិបាលកម្ពុជាដាក់ចេញនូវ **ផ.យ.ប.អ.ក.** វិធានការត្រូវអនុវត្តបន្ត ក្នុងការឆ្លើយតបខាងគោល នយោបាយជាតិ ដោយផ្តល់នូវក្របខ័ណ្ឌមួយ សម្រាប់ឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ និងតម្រង់ទិស អន្តរកាល ឈានទៅរកការអភិវឌ្ឍដែលបញ្ចេញកាបូនតិច និងធន់នឹងអាកាសធាតុ។ **ផ.យ.ប.អ.ក.** គាំទ្រដល់ការត្រៀមលក្ខណៈរបស់ជាតិ ក្នុងការឆ្លើយតបទៅនឹងហានិភ័យអាកាសធាតុ និងការគ្រប់គ្រងគ្រោះមហន្តរាយ ហើយ ពង្រឹងជាបន្ថែមលើឱកាសនានា ដែលលេចឡើងដូចជាការអភិវឌ្ឍបៃតង ការកៀរគរមូលនិធិអាកាសធាតុពី ប្រភពទ្វេភាគីនិងពហុភាគី និងពង្រឹងការចូលរួមឱ្យមានប្រសិទ្ធភាពនៅក្នុងការពិភាក្សា និងការចរចាជាអន្តរជាតិ អំពីការប្រែប្រួលអាកាសធាតុ ទាំងនៅថ្នាក់តំបន់ និងកម្រិតពិភពលោក។

# បណ្ណាល័យសាស្ត្រ


ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព / ក្រសួងបរិស្ថាន (២០១៩) មគ្គុទេសក៍បច្ចេកវិទ្យាបន្សុាំសម្រាប់វិស័យកសិកម្ម។ គាំទ្របច្ចេកទេសដោយ មជ្ឈមណ្ឌលអន្តរជាតិសម្រាប់ការគ្រប់គ្រងបរិស្ថាន, មូលនិធិវិនិយោគអាកាសធាតុតាមរយៈធនាគារអភិវឌ្ឍន៍អាស៊ី។

ក្រសួងរ៉ែ និងថាមពល (២០២០) ផែនការសកម្មភាពឆ្លើយតបនឹងការប្រែប្រួល អាកាសធាតុក្នុងវស័យថាមពល ២០២១-២០២៣។

ក្រសួងកិច្ចការនារី (២០១៤) អាកាសធាតុ យេនឌ័រ និងការប្រែប្រួលអាកាសធាតុ ការអភិវឌ្ឍន៍បៃតង និងការគ្រប់គ្រងគ្រោះមហន្តរាយ ការប៉ាន់ប្រមាណអំពីយេនឌ័រនៅកម្ពុជា។

ក្រសួងធនធានទឹក និងឧតុនិយម (២០១២) ផែនការយុទ្ធសាស្ត្រប្រែប្រួលអាកាសធាតុ សម្រាប់ វិស័យធនធានទឹក (២០១៣-២០១៧)។

កិច្ចព្រមព្រាងទីក្រុងប៉ារីស ឆ្នាំ ២០១៥

ក្រសួងបរិស្ថាន (២០១៦) ផែនការសកម្មភាពឆ្លើយតបនឹងការបប្រួលអាកាសធាតុ ២០១៦-២០១៨

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ (២០១៥) ផែនការសកម្មភាពឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ ២០១៦- ២០១៨ ។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (២០១៣) ផែនការយុទ្ធសាស្តឆ្លើយតបទៅនឹងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ ឆ្នាំ២០១៣-២០១៨

ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព សីហា (២០១៥) ក្របខ័ណ្ឌហិរញ្ញប្បទានបប្រួលអាកាសធាតុ

គណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុ, MoE (២០១៣) ផែនការយុទ្ធសាស្ត្រឆ្លើយតបនឹង ការប្រែប្រួលអាកាសធាតុកម្ពុជា ២០១៤-២០២៣ ។

ពិធីសារម៉ុងរ៉េអាល់-ស្ដីពីសារធាតុបំផ្លាញស្រទាប់អូហ្សូន ឆ្នាំ ២០០៦

ពិធីសារកាតាហេ្សណា-ស្តីពីជីវសុវត្ថិភាព ឆ្នាំ ២០០៦

វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា (NGO Forum) (២០១៦) ការឃ្លាំមើលមូលនិធិបន្សាំ និងផែនការបន្សាំជាតិ ។

រាជរដ្ឋាភិបាលកម្ពុជា ឆ្នាំ (២០១៥) របាយការណ៍ស្តីពី ការចូលរួមចំណែករបស់កម្ពុជា ដើម្បីអនុវត្តអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិ ស្តីពីប្រែប្រួលអាកាសធាតុ។

សេចក្តីសម្រេច (២០១៧) ស្តីពីការបង្កើតក្រុមការងារបច្ចេកទេសបប្រួលអាកាសធាតុ ដោយរដ្ឋមន្ត្រីក្រសួងបរិស្ថាន និងជាប្រធានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព។

អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា (២០១៥) ការរួមចំណែករបស់សភានៅក្នុងសន្និសីទអង្គការ សហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ ។

អនុសញ្ញាស្តុកខូបស្តីពីសារធាតុបំពុលសរីរាង្គមិនងាយបំបកជាតុ ឆ្នាំ ២០០៦

អនុក្រឹត្យ (២០១៥) ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព។

ADB (2015); Climate Investment Fund/SPCR Programme

ACT 2015. Getting Specific on the 2015 Climate Change Agreement: Suggestions for the Legal Text with Explanatory Memorandum. Accessed on August 21, 2015 at:

http://www.wri.org/sites/default/files/uploads/ACT2015 LegalSuggestions.pdf

AF (2016) https://www.adaptation-fund.org/about/

ASEAN 2009. ASEAN Socio-Cultural Community Blueprint.

ASEAN Action Plan on Joint Response to Climate Change. Accessed on September 01, 2015 at: http://environment.asean.org/wp-content/uploads/2015/06/ANNEX-8-Lead-Countries-for-ASEANAction-Plan-on-Joint-Response-to-Climate Change-27-March-2013.pdf

ASEAN Cooperation on Climate Change. Accessed on September 01, 2015 at: http://environment.asean.org/asean-working group-on-climate-change/

ASEAN Cooperation on Climate Change. Accessed on September 01, 2015 at:

http://environment.asean.org/asean-working group-on-climate change/

ASEAN Leaders' Statement on Joint Response to Climate Change. Accessed on September 10, 2015 at: http://www.asean.org/news/item/asean-leaders-statement-on-joint-response-to-climate-change

AIT-UNEP RRC.AP (2010) ការសិក្សាក្នុងវិសាលភាពមួយការអនុវត្តថ្នាក់ជាតិ នៅកម្ពុជា របាយការណ៍សង្ខេប ខែ កក្កដា ២០១០។

C2ES 2014. Outcomes of the UN Climate Change Conference in Lima. Accessed on August 20, 2015 at: http://www.c2es.org/international/negotiations/cop-20-lima/summary

C2ES 2014. Outcomes of the UN Climate Change Conference in Lima. Accessed on August 20, 2015 at: http://www.c2es.org/international/negotiations/cop-20-lima/summary

CRDB/CDC database: climate finance under UNFCCC mechanism; http://odacambodia.com/Reports/reports_by_updated.asp? $status=0

CFU (2016); Briefing all climate financing flow and trend; http://www.climatefundsupdate.org/

DCC/GSSD (2016): Sectoral CCAPs and Strategic plans; http://www.camclimate.org.kh/en/documents-and-media/library.html

Green Climate Fund. Facts at a Glance. Accessed on September 1, 2015 at: http://news.acfund.org/download/PDF/introducing-the-GCF.pdf

GSSD-MoE. (2015). Climate Change Finance Framework (CCFF), Cambodia

GSSD-MoE. (2016). Climate Public Expenditure Review update 2009-2014

GSSD-MoE. (2015). Cambodia's Second National Communication under the United Nations Framework Convention on Climate Change. Kingdom of Cambodia.

GIZ-USAID, (2016). Costing for National Adaptation Plan

MoE 2006. National Adaptation Program of Action to Climate Change. Accessed on September 02, 2015 at: http://unfccc.int/resource/docs/napa/khm01.pdf

Ministry of Rural Development (2018) Rural Development Strategy, Action Plan 2019-2023.

MoE (2013), Third National Climate Change Forum Report

MoE and CDRI (2015). Public perspective on climate change

MME. (2013). National Policy, Strategy and Action Plan on Energy Efficiency in Cambodia (draft).

Ministry of Information (2015) Climate Change Action Plan for Ministry of Information (2015-2018). Cambodia

Ministry of Land Management, Urban Planning and Construction (2015) Climate Change Action (2015-2018). Cambodia

Ministry of Tourism (2015) Climate Change Action Plan in Tourism Sector (2015- 2018). Cambodia

Ministry of Environment (2014) Climate Change Action Plan (2014-2018). Cambodia

Ministry of Health (2014) National Climate Change Action Plan for Public Health (2014-2018). Cambodia

Ministry of Women's Affairs (2014) Gender and Climate Change Action Plan (2014-2018). Cambodia

Ministry of Education, Youth and Sports (2014) Climate Change Action Plan for Education (2014-2018). Cambodia

Ministry of Public Works and Transport (2014) Climate Change Action Plan for Transport Sector (2014-2018). Cambodia

RGC (2014) Climate Change Action Plan for Manufacturing Industry and Energy sectors (2014-2018). Cambodia

Ministry of Rural Development (2014) Climate Change Action Plan for Rural Development Sector (2014-2018). Cambodia

Ministry of Water Resources and Meteorology (2014) Climate Change Action Plan for Water Resources and Meteorology (2015-2018). Cambodia

MEF (2016): Budget Briefing 2016; http://www.mef.gov.kh/budget-in-brief.html

NCCC 2013. Cambodia Climate Change Strategic Plan (2014-2023). Accessed on September 08, 2015 at: http://camclimate.org.kh/en/policies/nccc-news/197-cccsp-2014-2023-kh-en-final.html

National Disaster Management Committee (2014) Climate Change Action Plan for Disaster Management (2014-2018). Cambodia

National Institute of Statistics - Ministry of Planning. (2007). Cambodia Socio- economic Survey.

National Institute of Statistics. (2014). Cambodia Socio-economic Survey.

NGOF, (2013). Climate Change Financing in Cambodia

NCDD-S (2016): mainstreaming climate change into sub national planning; http://www.ncdd.gov.kh/km/media-center/13-latest-news/3689-integrate_ climate _ changein_to_cip

ODI. (2012). Cambodia Climate Public Expenditure and Institutional Review.

OECD-DAC. (2011). Climate Markers.

Parliament and climate change, Professional Development Program for Parliamentarians and Parliamentary Staff. Access on August 20, 2015 at: http://www.parliamentarystrengthening.org/climatechangemodule/

Preparation of a Strategic Pilot Program for Climate Resilience Project - Phase I. About us. Accessed on September 12, 2015 at: https://ppcrcambodia.wordpress.com/2012/04/20/about-us/

Raman Letchumanan (2015). Is there an ASEAN policy on climate change? Accessed on September 02, 2015at: http://www.lse.ac.uk/IDEAS/publications/reports/pdf/SR004/ASEC.pdf

RGC, Sub-Decree On The Establishment Of The National Climate Change Committee, Article 1(April 2006), 1. http://www.asianiudges.org/wp-content/uploads/2014/09/sub-decree-on-the establishment of-nccc-english.pdf

RGC (2013) Cambodia Climate Change Strategic Plan 2014-2023. National Climate Change Committee, Cambodia

RGC (2014) National Strategic Development Plan (2014-2018). Cambodia

Speech by the IPU president, Hon. Saber Chowdhury, Accessed on August 24, 2015 at: http://www.ipu.org/spiz-e/cop20/shc.pdf

Speech by the IPU president, Hon. Saber Chowdhury, Accessed on August 24, 2015 at: http://www.ipu.org/splz-e/cop20/shc.pdf

The 2015 Global Climate Legislation Study, Foreword by the President of the Inter-Parliamentary Union. Accessed on September 2, 2015 at: http://www.lse.ac.uk/Granthaminstitute/publication/2015-globalclimate-legislation-study/

The 2015 Global Climate Legislation Study. Foreword by the President of the Inter-Parliamentary Union. Accessed on September 2, 2015 at: http://www.lse.ac.uk/Granthaminstitute/publication/2015-global climate-legislation-study/

UNFCCC website. http://unfccc.int/2860.php

UNFCCC (2016); situation of climate financing in the world http://unfccc.int/focus/climate _finance/items/7001.php

UNDP Cambodia website. Environment and Energy. Accessed on September 09, 2015 at: http://www.kh.undp.org/content/cambodia/en/home/operations/projects/environment and energy.html

UNDP, CFADE (2015) A methodological Guidebook on Climate Public Expenditure and Institutional Review (CPEIR).

UNDP, CFADE (2015) Draft Paper: Climate Change Tagging. The Case Studies of Bangladesh, Indonesia, Nepal and the Philippines.

What is COP21/CMP11? Paris 2015. Accessed on August 25, 2015 at: http://www.cop21.gouv.fr/en/cop21-cmp11/what-cop21-cmp11

World Bank 2009. Convenient Solutions to an Inconvenient Truth: Ecosystem-based Approaches to Climate Change. Accessed on August 27, 2015 at: http://siteresources.worldbank.org/ENVIRONMENT/Resources/ESW Ecosystem BasedApp.pdf